# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៦០

បាលីប្រែ ៧២ - ៧៣ - ៧៤

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

## វិសុទ្ធជនវិលាសិនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ អបទាន

## បឋមភាគ-ទុតិយភាគ-តតិយភាគ

# ៦០

## បាលីប្រែ ៧២-៧៣-៧៤



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៦០

# សុត្តន្តបិដក

# ខុទ្ទកនិកាយ អបទាន

## សីហាសនិយវគ្គទី ២

## សីហាសនទាយកត្ថេរាបទានទី ១

[ ១៣ ] កាលព្រះលោកនាថ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គប្រសើរជាងសត្វជើងពីរ ទ្រង់បរិនិព្វានហើយ កាលពាក្យជាប្រធាន គឺសាសនា ផ្សាយទៅហើយក្នុងជនច្រើន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានកសាងសីហាសនៈ លុះកសាងសីហាសនៈរួចហើយ ខ្ញុំធ្វើតាំងរងព្រះបាទទៀត ។ កាលបើភ្លៀងបង្អុរចុះ លើសីហាសនៈ ខ្ញុំក៏ធ្វើរោងលើសីហាសនៈនោះ ដោយចិត្តជ្រះថ្លានោះខ្ញុំបានទៅកើតក្នុងស្ថានតុសិត ។ វេលានោះ វិមានមានបណ្តោយ ២៤ យោជន៍ ទទឹង ១៤ យោជន៍ ដែលបុញ្ញកម្មតាក់តែងឡើងសម្រាប់ខ្ញុំ ។ ក្នុងវិមាននោះ មានកញ្ញា ៧ ពាន់ តែងចោមរោមខ្ញុំសព្វៗ កាល មានទាំងបល្ល័ង្កជាវិការនៃមាស ដែលបុញ្ញកម្មនិម្មិតល្អហើយ ។ យានដំរី យានសេះ និងយានជាទិព្វ កើតឡើងសម្រាប់ខ្ញុំ ប្រាសាទ និងសិវិកា ( អង្រឹង ) កើតតាមសេចក្តីប្រាថ្នាខ្ញុំ ។ បល្ល័ង្កជាវិការនៃកែវមណី បល្ល័ង្កឯទៀតជាច្រើន ជា

វិការនៃឈើ បល្ល័ង្កទាំងអស់នោះ កើតឡើងសម្រាប់ខ្ញុំ នេះជាផល
នៃសីហាសនៈ ។ ខ្ញុំតែងពាក់ទ្រនាប់ជើង ជាវិការនៃមាស ជា
វិការនៃវត្ថុគាប់ចិត្ត ជាវិការនៃកែវផលិក និងជាវិការនៃកែវពិទូរ្យ
នេះជាផលនៃតាំងរងព្រះបាទ ។ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម
ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ ក្នុងកាលនោះ ខ្ញុំមិនស្គាល់
ទុគ្គតិឡើយ នេះជាផលនៃបុញ្ញកម្មនោះ ។ ក្នុងកប្បទី ៧៣ អំពី
ភទ្ទកប្បនេះ ខ្ញុំបានកើតជាជនឈ្មោះឥន្ទៈ ៣ ដង ក្នុងកប្បទី ៧២
អំពីភទ្ទកប្បនេះ ខ្ញុំបានកើតជាជនឈ្មោះសុមនៈ ៣ ដង ក្នុងកប្ប
ទី ៧០ អំពីភទ្ទកប្បនេះ ខ្ញុំបានកើតជាជនឈ្មោះវរុណៈ ៣ ដង
ដែលជាស្តេចធំ ក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ។
បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់
ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសីហាសនទាយកត្ថេរមានអាយុ បានសម្តែង
នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សីហាសនទាយកត្ថេរាបទាន ចប់

# អដ្ឋកថា
# វិសុទ្ធជនវិលាសិនី
# ខុទ្ទកនិកាយ អបទាន
# ថេរាបទាន

## សីហាសនិយវគ្គ
## សីហាសនទាយកត្ថេរាបទាន

[ ១៣ ] អបទានរបស់ព្រះសីហាសនទាយកត្ថេរ មានពាក្យផ្ដើមថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសុទ្ធត្ថៈ លោកកើតក្នុងត្រកូលមួយ ដែលដល់ព្រមដោយទ្រព្យសម្បត្តិ សម្បូរដោយសទ្ធា កាលព្រះមានព្រះភាគគង់ព្រះជន្មនៅ លោកនៅក្នុងទេវលោក ព្រោះលោកកើតមក កាលព្រះមានព្រះភាគបរិនិព្វានហើយ កាលដល់នូវភាពជាអ្នកដឹងក្ដីហើយ បានឃើញចេតិយដែលបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះមានព្រះភាគ ទើបបង្អោនចិត្តថា ស្ដាយហ្ន៎ ដែលអាត្មាអញកើតមកមិនទាន់កាលព្រះមានព្រះភាគទ្រង់ព្រះជន្មនៅ មានចិត្តជ្រះថ្លាក្នុងព្រះចេតិយ កើតសោមនស្សឲ្យជាងសាង

អាសនសីហៈលើធម្មាសនៈ សម្រេចដោយកែវគ្រប់ប្រភេទ វិចិត្រដូចទេវ-និម្មិត ហើយធ្វើការបូជាដល់ព្រះពុទ្ធ ដូចទ្រង់គង់ព្រះជន្មនៅ ឲ្យសាងផ្ទះកំពូលដ៏វិចិត្រ ដូចទិព្វវិមានលើធម្មាសនៈនោះ ឲ្យសាងជ្រញ់វង់ព្រះបាទ ។ កុលបុត្តនោះ ធ្វើការបូជាដោយទៀន ធូបក្រអូប ផ្កា និងគ្រឿងក្រអូបជាដើមច្រើនប្រភេទ ដរាបដល់អស់ជីវិតបែបនេះ ចុតិអំពីមនុស្សលោកនោះហើយ កើតក្នុងឆកាមាវចរសួគ៌ ៦ ជាន់ សោយចក្កពត្តិសម្បត្តិក្នុងមនុស្សលោករាប់មិនអស់ និងសោយសម្បត្តិ គឺភាពជាព្រះរាជាក្នុងប្រទេសរាប់មិនអស់ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ បានបួស បំពេញសមណធម៌ក្នុងរវាងនេះ កុលបុត្តនោះ អន្ទោលទៅមកក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិមួយកន្លែង លុះដឹងក្តីហើយ បានស្តាប់ធម្មទេសនារបស់ព្រះសាស្តា បាននូវសទ្ធាចេញបួស ឧបសម្បទាហើយ រៀននូវកម្មដ្ឋាន បំពេញព្យាយាមមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។

លោកបានសម្រេចអរហត្តផលយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសដល់ការប្រព្រឹត្តដែលមានក្នុងកាលមុន ទើបលោកពោលគាថាថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះជាដើម ។ លោកនាថក្នុងគាថានេះ សំដៅដល់ជាទីពឹង គឺប្រធានរបស់សត្វលោក អធិប្បាយថា ជាធំក្នុងលោកទាំង ៣ ភ្ជាប់សេចក្តីថា កាលព្រះលោកនាថព្រះនាមសុទ្ធត្ថៈបរិនិព្វានហើយ ។ បទថា **វិត្ថារិតេ បាវចនេ** សេចក្តីថា

កាលបាវចនៈ គឺព្រះត្រៃបិដកផ្សាយចេញទៅ គឺប្រាកដច្បាស់ហើយ ។ បទថា **ពាហុជញ្ញម្ហិ សាសនេ** សេចក្តីថា កាលមហាជន បានដល់ ព្រះនិព្វានស្រេចច្រើនសែនកោដិ បានដឹង បានសម្រេចនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលសង្គ្រោះដោយត្រៃសិក្ខាហើយ ។

បទថា **បសន្នចិត្តោ សុមនោ** សេចក្តីថា ក្នុងកាលនោះ ខ្ញុំមិនមានឱកាសបានកើតទាន់ព្រះពុទ្ធ ខណៈដែលទ្រង់គង់ព្រះជន្មនៅ កាលព្រះអង្គបរិនិព្វានហើយ ទើបចុតិអំពីទេវលោក មកកើតក្នុងមនុស្សលោក បានឃើញតែព្រះចេតិយ បញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះមានព្រះភាគអង្គនោះ មានចិត្តជ្រះថ្លា មានចិត្តប្រកបដោយសទ្ធា មានចិត្តស្អាត កើតនូវសេចក្តីជ្រះថ្លា រាប់អានជាខ្លាំងថា ជាបុណ្យពន់ពេកហ្ន៎ ដែលអញមកជួប រាប់ថាជាការល្អហើយ ទើបគិតថា អញសមគួរបំពេញបុណ្យណាមួយ ដើម្បីសម្រេចព្រះនិព្វាន ទើបយកប្រាក់ មាស និងកែវជាដើមមករចនាអាសនសីហៈ ឧទ្ទិសចំពោះព្រះមានព្រះភាគ តម្កល់ក្នុងព្រះចេតិយរបស់ព្រះមានព្រះភាគ បានឲ្យមនុស្សធ្វើជ្រញ់រងជើង សម្រាប់រងព្រះបាទរបស់ព្រះមានព្រះភាគ ដែលប្រថាប់គង់លើធម្មាសនៈនោះ និងបានឲ្យមនុស្សធ្វើផ្ទះកំពូលខាងលើធម្មាសនៈនោះ ដើម្បីកុំឲ្យសីហាសនៈនោះសើមដោយភ្លៀង ។ ដោយហេតុនោះ ទើបព្រះថេរៈពោលថា **សីហាសនមកាសហំ ។បេ។ ឃរំ តត្ថ អកាសហំ** ដូច្នេះ ។ បទថា **តេន ចិត្តប្បសាទេន** សេចក្តីថា ខ្ញុំមានចិត្តជ្រះថ្លា សាងសីហាសនៈ ថ្វាយដល់ព្រះមានព្រះភាគ ហាក់ដូចទ្រង់គង់

ព្រះជន្មនៅ ។ បទថា **តុសិតំ ឧបបជ្ជហំ** សេចក្តីថា ខ្ញុំបានកើតក្នុងស្ថានតុសិត ។

បទថា **អាយាមេន ចតុព្វីស** សេចក្តីថា វិមាន មានចំណែកបណ្តោយនិងកម្ពស់ ២៤ យោជន៍ ទទឹង ១៤ យោជន៍ ជាវិមានដែលសាងយ៉ាងល្អកើតឡើងដល់ខ្ញុំដែលជាទេវតាក្នុងស្ថានតុសិតនោះ កើតឡើងមួយរំពេច គឺក្នុងខណៈដែលខ្ញុំកើតនោះឯង ។ បទដ៏សេសមានអត្ថងាយយល់ហើយ ។

បទថា **ចតុន្នវុតេ ឥតោ កប្បេ** សេចក្តីថា ខ្ញុំបានធ្វើ គឺបានបំពេញកម្មមកក្នុងកប្បទី ៩៤ អំពីកប្បនេះ អធិប្បាយថា តាំងអំពីនោះមក ដោយកម្លាំងនៃបុណ្យ ខ្ញុំមិនស្គាល់ទុគ្គតិឡើយ គឺទុគ្គតិណាមួយ មិនធ្លាប់មានឡើយ ។

បទថា **តេសត្តតិម្ហិតោ កប្បេ** បានដល់ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ។ បទថា **ឥន្ទនាមា តយោ ជនា** សេចក្តីថា ជាស្តេចចក្រពត្តិ ៣ អង្គ ព្រះនាមថា ឥន្ទៈ គឺក្នុងកប្បមួយ បានជាស្តេចចក្រពត្តិ ព្រះនាមថា ឥន្ទៈ ៣ ជាតិ ។ បទថា **ទ្វេសត្តតិម្ហិតោ កប្បេ** បានដល់ ក្នុងកប្បទី ៧២ អំពីកប្បនេះ បានជាស្តេចចក្រពត្តិ ៣ អង្គ មានព្រះនាមថា សុមនៈ ។

បទថា **សមសត្តតិតោ កប្បេ** សេចក្តីថា ក្នុងកប្បទី ៧០ អំពីកប្បនេះ ជាស្តេចចក្រពត្តិ ៣ ជង មានព្រះនាមថា វរុណៈ បរិបូណ៌ដោយចក្ករ័តន៍គ្រប់យ៉ាង ជាធំក្នុងទ្វីបទាំង ៤ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

# សុត្តន្តបិដក

## ឯកត្ថម្ភិកត្ថេរាបទានទី ២

[ ១៤ ] ពួកគណៈធំ របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ពួកជនទាំងនោះ បានដល់នូវព្រះពុទ្ធជាទីពឹង ហើយជឿព្រះតថាគត ។ ពួកជនទាំងពួង ជួបជុំប្រឹក្សាគ្នា ហើយធ្វើរោងថ្វាយព្រះសាស្តា តែនៅខ្វះសសរ ១ ក៏នាំគ្នាជ្រើសរកក្នុងព្រៃធំ ។ កាលនោះ ខ្ញុំឃើញជនទាំងនោះ ក្នុងព្រៃហើយ ចូលទៅជិតជនទាំងនោះ ក៏ផ្គងអញ្ជលីសាកសួរពួកនោះ ។ ពួកឧបាសក អ្នកមានសីលទាំងនោះ ដែលខ្ញុំសួរហើយ ក៏ប្រាប់ថា ពួកយើងប្រាថ្នានឹងធ្វើរោង តែនៅខ្វះសសរ ១ ។ ខ្ញុំតបថា អ្នកទាំងឡាយ ចូរឲ្យសសរ ១ ដែលខ្វះមកខ្ញុំចុះ ខ្ញុំនឹងថ្វាយចំពោះព្រះសាស្តា ខ្ញុំនឹងនាំសសរមក សូមពួកឧបាសកទាំងនោះ កុំមានសេចក្តីខ្វល់ខ្វាយឡើយ ។ ពួកឧបាសកទាំងនោះ មានចិត្តជ្រះថ្លាត្រេកអរហើយ នាំសសររបស់ខ្ញុំទៅលុះត្រឡប់អំពីទីនោះវិញ ក៏មកកាន់ផ្ទះរៀងខ្លួន ។ ក្នុងកាលនោះ កាលពួកគណៈដែលទើបនឹងទៅ មិនទាន់យូរប៉ុន្មាន ខ្ញុំបានថ្វាយសសរ ខ្ញុំមានចិត្តត្រេកអរហើយ បានលើកសសរជាដំបូង ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំចូលទៅកាន់វិមាន មានកម្ពស់ ៧ ជាន់ ដែលផុសឡើងសម្រាប់ខ្ញុំ ។ ក្នុងកប្បទី ៥៥ ខ្ញុំកើតជាស្តេចឈ្មោះយសោធរៈ កាលបើស្គរដែលគេកំពុងប្រគំ ខ្ញុំក៏ឲ្យគេបម្រើសព្វៗកាល ។ លំនៅរបស់ខ្ញុំក្នុងទីនោះ មានកម្ពស់ ៧ ជាន់ ប្រកប

ដោយផ្ទះមានកំពូលដ៏ប្រសើរ មានសសរតែមួយ ជាទីរីករាយនៃចិត្ត ។ ក្នុងកប្បទី ២១ ខ្ញុំកើតជាក្សត្រិយ៍ឈ្មោះឧទេនៈ លំនៅរបស់ខ្ញុំក្នុងទីនោះ មានជាន់ ៧ ដែលគេតាក់តែងល្អហើយ ។ ខ្ញុំកើតក្នុងកំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំតែងទទួលសេចក្តីសុខគ្រប់ប្រការ នេះជាផលនៃសសរមួយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសសរ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសសរមួយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកត្ថម្ភិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឯកត្ថម្ភិកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ឯកត្ថម្ពិកត្ថេរាបទាន

[ ១៤ ] *អបទានរបស់ព្រះឯកត្ថម្ពិកទាយកត្ថេរ មានពាក្យផ្ដើមថា* **សុទ្ធត្តស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈរូបនេះ ក៏ជាអ្នកមានអធិការដែលធ្វើហើយ ក្នុងព្រះសម្ពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមសុទ្ធត្ថៈ កើតក្នុងត្រកូលមួយដែលដល់ព្រមដោយសម្បត្តិ ជាអ្នកថែរក្សាព្រៃ ។ ក្នុងសម័យនោះ ឧបាសកនិងឧបាសិកាជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លា មានឆន្ទៈតែមួយ តាំងចិត្តថា ពួកយើងនឹងសាងឧបដ្ឋានសាលាថ្វាយព្រះមានព្រះភាគ ទើបចូលទៅព្រៃដើម្បីរកទព្វសម្ភារៈ បានឃើញឧបាសកនោះ ក៏សូមថា សូមអ្នកឲ្យសសរពួកយើងត្រឹមតែមួយចុះ ។ ឧបាសកនោះ លុះជ្រាបការប្រព្រឹត្តទៅនោះហើយ ក៏ពោលថា ពួកអ្នកកុំគិតថ្វីឡើយ ដូច្នេះហើយ បានបញ្ជូនជនទាំងនោះទៅ ខ្លួនឯងលើសសរខ្លឹមមួយដើមទៅបង្ហាញដល់ព្រះសាស្ដា ហើយប្រគល់ឲ្យមនុស្សទាំងនោះ ។ ដោយការឲ្យសសរខ្លឹមនោះឯង កុលបុត្តនោះកើតសោមនស្ស យកទាននោះជាចំណុចចាប់ផ្ដើមហើយ ធ្វើបុណ្យ មានការឲ្យទានជាដើមដទៃទៀតជាច្រើន ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសម្បត្តិក្នុងកាមាវចរសួគ៌ ៦ ជាន់ អន្ទោលទៅមកបានសោយចក្កពត្តិសម្បត្តិ ក្នុងមនុស្សលោកច្រើនដងទៀត និងបានសោយសម្បត្តិ គឺស្ដេចបទេសរាជ្យរាប់មិនអស់ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុង*

ត្រកូលមួយ ដែលសម្បូរដោយសទ្ធា បានស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះមានព្រះភាគ មួយអន្លើដោយមាតាបិតា មានសទ្ធា បព្វជ្ជាឧបសម្បទា រៀននូវកម្មដ្ឋានដោយយកចិត្តទុកដាក់ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

លោកបានជាព្រះអរហន្តយ៉ាងនោះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលខ្លួនប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សុទត្តស្ស** ដូច្នេះជាដើម ។

ព្រះមានព្រះភាគព្រះនាមសុទ្ធត្ថៈ ក្នុងគាថានោះ គឺព្រះសម្មាសម្ពុទ្ធ ដែលសម្បូរដោយកគធម៌ ។ បទថា **មហាបូគគណោ** សេចក្តីថា មានពួកនៃឧបាសកជាច្រើន ។ បទថា **សរណំ គតា ច តេ តុម្ហំ** សេចក្តីថា ឧបាសកទាំងនោះ ចូលដល់ គប់រក ឬឃើញថា ព្រះពុទ្ធជាទីពឹង ។ បទថា **តថាគតំ សទ្ទហំ** សេចក្តីថា តាំងពុទ្ធគុណក្នុងចិត្តសន្តានរបស់ខ្លួន ។

បទថា **សព្វេ សង្គម្ម មន្តេត្វា** សេចក្តីថា ទាំងអស់ ប្រជុំប្រឹក្សាគ្នា ឲ្យសញ្ញាគ្នានិងគ្នា មានឆន្ទៈតែមួយសាងរោង គឺធ្វើឧបដ្ឋានសាលា ដើម្បីប្រយោជន៍ដល់ព្រះសាស្តា ។ ភ្ជាប់សេចក្តីថា កាលមិនបានសសរមួយដើម ក្នុងបណ្តាទព្វសម្ភារៈទាំងឡាយ ទើបនាំគ្នាស្វែងរកក្នុងព្រៃធំ ។

បទថា **តេហំ អរញ្ញេ ទិស្វាន** ភ្ជាប់សេចក្តីថា ខ្ញុំបានឃើញពួកឧបាសកទាំងនោះក្នុងព្រៃ ចូលទៅជាក្រុមផ្គងអញ្ជលី ធ្វើនូវអញ្ជលីប្រជុំនូវម្រាមទាំង ១០ លើសិរសា ខ្ញុំក៏សួរពួកឧបាសកក្នុងវេលានោះ គឺក្នុងពេលនោះថា ពួកលោកមកកាន់ព្រៃនេះ ដើម្បីអ្វី ។

ក្នាប់សេចក្តីថា ឧបាសកទាំងនោះជាអ្នកមានសីល ត្រូវខ្ញុំសួរហើយ ក៏ប្រាប់ គឺប្រាប់ជាពិសេសថា ពួកខ្ញុំមានបំណងនឹងធ្វើសាលា តែពួកខ្ញុំនៅខ្វះសសរមួយដើម ។

ក្នាប់សេចក្តីថា សូមពួកអ្នកឲ្យសសរមួយដើមដល់ពួកខ្ញុំចុះ កុលបុត្តនោះប្រាប់ថា ខ្ញុំឯងនឹងនាំសសរនោះទៅថ្វាយក្នុងសម្នាក់ព្រះសាស្តា សូមអ្នកដ៏ចម្រើន កុំបាច់ព្យាយាមក្នុងការនាំយកសសរទៅឡើយ ។

បទថា **យំ យំ យោនុបបជ្ជាមិ** សេចក្តីថា ខ្ញុំចូលដល់កំណើតណាមួយ គឺជាទេវតា ឬមនុស្សក្តី ។ ម្យ៉ាងទៀត ពាក្យថា **យំ យំ**នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ប្រែថា ក្នុងលោកណា គឺទោះជាទេវលោក ឬមនុស្សលោកក៏ដោយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។l១៥២

## អដ្ឋកថាឯកត្ថម្ភិកត្ថេរាបទាន[១] ចប់

---

១- ក្នុងថេរគាថា ជាព្រះឧក្ខេបកដវច្ឆត្ថេរ ។

# សុត្តន្តបិដក

## ឆន្ទុត្ថោរាបទានទី ៣

[ ១៥ ] ខ្ញុំបានថ្វាយសំពត់សម្បកឈើ ចំពោះព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាចម្បងក្នុងលោក ទ្រង់ប្រកបដោយតាទិគុណ ជាព្រះសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះពុទ្ធជានាយក ព្រះនាមជលជុត្តមៈ ទ្រង់ព្យាករណ៍រឿងនោះប្រាប់ខ្ញុំថា

អ្នកនឹងមានពណ៌សម្បុរដូចមាស ដោយការថ្វាយសំពត់នេះ ។ អ្នកនឹងបានទទួលសម្បត្តិទាំងពីរប្រការ ត្រូវកុសលមូលជាស់តឿនហើយ នឹងបានជាប្អូន នៃព្រះមានព្រះភាគព្រះនាមគោតម ។ អ្នកនឹងមានសេចក្ដីត្រេកអរដោយរាគៈ មានសេចក្ដីសុខជាប្រក្រតី មានសេចក្ដីជាប់ជំពាក់ដោយចំណង់ក្នុងកាមទាំង-ឡាយ តែលុះព្រះពុទ្ធទ្រង់ជាស់តឿន នឹងប្រែជាបុគ្គលស្ងប់ ហើយចេញបួសក្នុងកាលនោះ ។ លុះអ្នកបួសហើយ ត្រូវកុសលមូលជាស់តឿន នឹងកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វានក្នុងទីនោះ ។ ក្នុងកប្បទីមួយសែន អ្នកនឹងបានជាព្រះរាជាព្រះនាមចេលៈ ៤ ដង ក្នុងកប្បទី ៦០ ពាន់ នឹងបានកើតជាជនឈ្មោះឧបចេលៈ ៤ ដង ។ ក្នុងកប្បទី ៥ ពាន់ នឹងបានជាជនឈ្មោះចេលៈ ៤ ដងទៀត ជាធំក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះនន្ទុត្តរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**នន្ទុត្តរាបទាន ចប់**

# អដ្ឋកថា

## ឆត្តុបកទាន

[ ១៥ ] *អបទានរបស់ព្រះឆត្តុបក មានពាក្យផ្តើមថា* **បទុមុត្តរស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈរូបនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កុលបុត្តនេះកើតក្នុងត្រកូលមួយនានគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីហើយ ខណៈស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះមានព្រះភាគ បានឃើញភិក្ខុមួយរូប ដែលព្រះសាស្តាស្ថាបនាក្នុងតំណែងឯតទគ្គៈ ជាងពួកភិក្ខុទាំងឡាយខាងគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ខ្លួនឯងប្រាថ្នាតំណែងនោះដែរ ទើបថ្វាយមហាទាន ដែលច្រើនទៅដោយការបូជា និងសក្ការៈដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ តាំងបណិធានថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងអនាគតកាល ខ្ញុំព្រះអង្គគប្បីដូចសាវ័ករូបនោះ របស់ព្រះពុទ្ធដូចទ្រង់ចុះ ។*

*ចាប់តាំងអំពីនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតជាអណ្តើកធំក្នុងស្ទឹងឈ្មោះធម្មតា*[១] *។ ថ្ងៃមួយ បានឃើញព្រះសាស្តាប្រថាប់ឈរត្រង់ច្រាំង ដើម្បីឆ្លងស្ទឹង អណ្តើកបំណងឲ្យព្រះមានព្រះភាគឆ្លងនូវ*

---

១- *ស្ទឹងនេះ ក្នុងទីខ្លះ ឈ្មោះថា វិនតា ក៏មាន ។*

ត្រើយ ទើបក្រាបចុះទៀបបាទារបស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់អណ្តើកហើយ ទ្រង់ក៏ប្រថាប់ឈរលើខ្នង ។ អណ្តើកត្រេកអរណាស់ ខំហែលកាត់ខ្សែទឹកដល់ត្រើយនាយយ៉ាងរហ័ស ។ ព្រះមានព្រះភាគត្រាស់អនុមោទនាដល់អណ្តើក ត្រាស់ចង្អុលបង្ហាញដល់សម្បត្តិដែលអណ្តើកនឹងបានទទួល ហើយយាងទៅ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងសុគតិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់ព្រះនាងមហាបជាបតិគោតមី អគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ ក្នុងក្រុងកបិលពស្តុ ក្នុងថ្ងៃថ្វាយព្រះនាមពួកញាតិមានសេចក្តីត្រេកអរ ទើបថ្វាយព្រះនាមថា នន្ទ ។ ក្នុងពេលដែលនន្ទកុមារចម្រើនវ័យហើយ ព្រះមានព្រះភាគទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅហើយ ទ្រង់ធ្វើអនុគ្រោះសត្វលោក យាងទៅកាន់នគរកបិលពស្តុដោយលំដាប់ ទ្រង់ធ្វើភ្លៀងបោក្ខរព័ស៌ ឲ្យជាអត្ថុប្បត្តិហេតុ ត្រាស់វេស្សន្តរជាតក ក្នុងសមាគមនៃពួកញាតិ ក្នុងថ្ងៃទី ២ យាងទៅបិណ្ឌបាតទ្រង់ញុំាងព្រះជនកឲ្យតាំងនៅក្នុងសោតាបត្តិផលដោយគាថា ( ក្នុងធម្មបទ ) ថា បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល ដូច្នេះជាដើម ។ ហើយយាងទៅកាន់ព្រះរាជនិវេសន៍ ទ្រង់ញុំាងព្រះនាងមហាបជាបតិឲ្យតាំងនៅក្នុងសោតាបត្តិផល និងឲ្យព្រះរាជាតាំងនៅក្នុងសកទាគាមិផលដោយគាថា ( ក្នុងធម្មបទ ) ថា បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិតដូច្នេះជាដើម ។ ក្នុងថ្ងៃទី ៣ យាងចូលទៅបិណ្ឌបាត ក្នុងថ្ងៃអាវាហមង្គល-

អភិសេក កាលឡើងកាន់ព្រះរាជនិវេសន៍ និងអាវាហមង្គលរបស់នន្ទកុមារ កំពុងប្រព្រឹត្តទៅ ព្រះសាស្តាប្រទានបាត្រក្នុងដៃរបស់នន្ទកុមារ ត្រាស់មង្គលហើយ មិនទទួលបាត្រអំពីដៃរបស់នន្ទកុមារនោះ យាងទៅកាន់វិហារ ទ្រង់ឲ្យនន្ទកុមារកាន់បាត្រតាមទ្រង់មកកាន់វិហារ ដែលជាអ្នកមិនមានចិត្តប្រាថ្នានឹងបួស ឲ្យបួសហើយ ទ្រង់ជ្រាបថា នន្ទ ត្រូវសេចក្តីមិនត្រេកអរបៀតបៀន ព្រោះត្រូវឲ្យបួសដោយអាការបែបនោះ ទើបទ្រង់បន្ទោបង់នូវការមិនត្រេកអររបស់នន្ទដោយឧបាយនោះ ។ លោកពិចារណាដោយយោនិសោមនសិការ ផ្តើមបំពេញវិបស្សនា មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ។ ស្អែកឡើងព្រះថេរៈចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គផុតចាកការធានា ដែលព្រះមានព្រះភាគធានាថា នឹងឲ្យស្រីទេពអប្សរ ៥០០ ដែលមានជើងក្រហមដូចពណ៌នៃជើងព្រាប បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមសងនូវការធានានោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនន្ទ ក្នុងកាលដែលអ្នកមានចិត្តផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ តថាគតក៏ផុតចាកការធានានោះដូចគ្នា ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា នន្ទ មានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយបានយ៉ាងវិសេស កាលទ្រង់ប្រកាសគុណនោះ ទើបទ្រង់ស្ថាបនាលោកក្នុងតំណែងជាឯតទគ្គៈ លើសភិក្ខុទាំងឡាយខាងគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងនន្ទ

ប្រសើរជាងគេ ដូច្នេះ ។ ព្រះថេរៈគិតថា អញអាស្រ័យសេចក្ដីមិនសង្រួមឥន្ទ្រិយ ទើបដល់នូវអាការខុសប្រក្រតីនេះ អញនឹងសង្កត់អាការខុសប្រក្រតីនោះឲ្យល្អ កើតនូវឧស្សាហ៍ មានហិរិ និងឱត្តប្បៈជាកម្លាំង នឹងបានសម្រេចដល់បារមីដ៏ឧត្តម ក្នុងការសង្រួមឥន្ទ្រិយ ព្រោះភាពដែលលោកបានសន្សំបំពេញមក ដើម្បីការសង្រួមឥន្ទ្រិយនោះ ។

កាលបានទទួលតំណែងឯតទគ្គៈយ៉ាងនេះហើយ ទើបរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលខ្លួនប្រព្រឹត្តមកអំពីមុន ទើបពោលគាថាថា **បទុមុត្តរស្ស ភគវតោ** ដូច្នេះជាដើម ។ បទថា **វត្ថំ ខោមំ មយា ទិន្នំ** សេចក្ដីថា ខ្ញុំថ្វាយសំពត់សម្បកឈើ គឺសំពត់ដែលកើតក្នុងដែនខោមៈ ដែលមានសាច់ម៉ដ្ឋក្រៃលែង ដោយចិត្តជ្រះថ្លា គឺដោយការគោរពរាប់អានច្រើន ក្នុងព្រះមានព្រះភាគ ។ បទថា **សយម្ភុស្ស** បានដល់ ជាអ្នកកើតឯង ឧបត្តិកឯង គឺកើតហើយដោយអរិយជាតិ ។ បទថា **មហេសិនោ** ភ្ជាប់សេចក្ដីថា ឈ្មោះថា មហេសី ព្រោះអត្ថថា ស្វះស្វែងស្វែងរកនូវគំនរសីល គំនរសមាធិ គំនរបញ្ញា គំនរវិមុត្តិ និងគំនរវិមុត្តិញ្ញាណទស្សនៈយ៉ាងធំ ខ្ញុំបានថ្វាយសំពត់ខោមៈ ដើម្បីប្រយោជន៍ធ្វើជាចីវរដល់ព្រះសយម្ភូ ដែលស្វែងរកគំនរគុណដ៏ធំក្រៃលែងនោះ ។

បទថា **តំ** ក្នុងបទថា **តំ មេ ពុទ្ធោ វិយាកាសិ** នេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ អធិប្បាយថា ព្រះពុទ្ធទ្រង់បានធ្វើ គឺត្រាស់ដល់ផលទានរបស់ខ្ញុំ ដែលថ្វាយសំពត់នោះដោយពិសេស ។ បទថា **ផលជុត្ត-**

**មណ្ឌាមកោ** បានដល់ មានទាមថា បទុមុត្តរៈ ។ បាឋៈថា **ជលុត្តមនាយកោ** ដូច្នេះក៏មាន ។ សេចក្តីនៃបាឋៈនោះថា ទ្រង់ជាអ្នកនាំ ដ៏កំពូល គឺជាធំជាងពួកទេវតា និងព្រហ្មទាំងឡាយដែលរុងរឿង ។ បទថា **ឥមិនា វត្ថទានេន** សេចក្តីថា ដោយផលនៃការថ្វាយសំពត់នេះ ក្នុងអនាគតកាល អ្នកនឹងមានពណ៌សម្បុរដូចមាស ។

បទថា **ទ្វេ សម្បត្តី អនុភោត្វា** បានដល់ នឹងបានសោយនូវសម្បត្តិ ទាំងពីរ គឺទិព្វសម្បត្តិ និងមនុស្សសម្បត្តិ ។ បទថា **កុសលមូលេហិ ចោទិតោ** សេចក្តីថា ជាបុគ្គលដែលមានចំណែកនៃគំនរកុសលជាស់តឿន ហើយ គឺបញ្ជូនទៅហើយ បានដល់ ដូចគ្នានឹងបញ្ជូនទៅថា ដោយបុណ្យនេះ ចូរអ្នកជួបនូវកុសលក្នុងសម្នាក់របស់ព្រះសាស្តាចុះ ភ្ជាប់សេចក្តីថា ទ្រង់ ព្យាករថា អ្នកនឹងបានជាប្អូនប្រុសរបស់ព្រះមានព្រះភាគគោតម ។

បទថា **រាគរត្តោ សុខសីលោ** សេចក្តីថា ត្រូវកិលេសកាមជ្រលក់ ហើយ គឺនៃបនិត្យ មានការសោយសេចក្តីសុខផ្លូវកាយ និងសេចក្តីសុខផ្លូវ ចិត្តជាសភាវៈ ។ បទថា **កាមេសុ គេធមាយុតោ** សេចក្តីថា ត្រូវតណ្ហា គឺចំណង់ក្នុងវត្ថុកាមទាំងឡាយប្រកប គឺចងហើយ ។ បទថា **ពុទ្ធេន ចោទិតោ សន្តោ តទា ត្វំ** ភ្ជាប់សេចក្តីថា ព្រោះត្រេកត្រអាលហើយ ក្នុងកាមទាំង ឡាយ ។ ហេតុនោះ អ្នកត្រូវព្រះគោតមសម្ពុទ្ធដែលជាព្រះភាតារបស់ខ្លួន បបួលហើយ គឺត្រូវដឹកនាំឲ្យបួស នឹងបួសក្នុងសម្នាក់របស់ព្រះអង្គ ។

បទថា **បព្ពជិត្វាន ត្វំ តត្ថ** សេចក្តីថា ក្នុងសាសនារបស់ព្រះមាន

ព្រះភាគព្រះនាមគោតមនោះ អ្នកបួសហើយ នឹងជាអ្នកដែលកុសលមូលជាដើមហេតុ គឺដែលបុញ្ញសម្ភារៈជាស់តឿនហើយ បំពេញការនា កំណត់ដឹង លះអាសវៈទាំងពួង គឺអាសវៈទាំងមូល ជាអ្នកមិនមានរោគ មិនមានទុក្ខ នឹងបរិនិព្វាន គឺនឹងសម្រេចដល់ភាពដែលមារមើលមិនឃើញ បានដល់នឹងដល់ភាវៈមិនមានបញ្ញត្តិ ។

បទថា **សតកប្បសហស្សម្ហិ** សេចក្តីថា ក្នុងកប្បទីមួយសែនអំពីកប្បនេះ បានជាស្តេចចក្រពត្តិ ៤ ដង មានព្រះនាមថា ចេលៈ ។ បទថា **សដ្ឋិកប្បសហស្សានិ** សេចក្តីថា ខាងក្រោយកន្លងទៅបាន ៦ ម៉ឺនកប្បបានជាស្តេចចក្រពត្តិ ៤ អង្គ ព្រះនាមថា ឧបចេលៈ ក្នុងកប្បតែមួយ គឺបានជាស្តេចចក្រពត្តិក្នុង ៤ ជាតិ ។

បទថា **បញ្ចកប្បសហស្សម្ហិ** សេចក្តីថា ក្នុងកប្បទី ៥ ពាន់ បានជាស្តេចចក្រពត្តិ ៤ អង្គ ព្រះនាមថា ចេលៈ ដល់ព្រម គឺព្រមព្រៀងដោយរតនៈ ៧ ប្រការ ជាធំ ជាប្រធានក្នុងទ្វីបទាំង ៤ គឺជម្ពូទ្វីបអបរគោយានទ្វីបឧត្តរកុរុទ្វីប និងបុព្វវិទេហទ្វីប ។ ពាក្យដ៏សេស មានអត្ថដូចពោលហើយនោះឯង ។៚

## អដ្ឋកថានន្ទុត្តរាបទាន ចប់

# សុត្តន្តបិដក

## ចុល្លបន្ថកត្ថេរាបទានទី ៤

[ ១៦ ] កាលនោះ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា គេចចេញចាកគណៈ ទៅគង់ក្នុងព្រៃហិមពាន្ត ។ គ្រានោះខ្ញុំនៅក្នុងអាស្រម នាព្រៃហិមពាន្ត បានចូលទៅគាល់ព្រះលោក-នាយក ព្រះអង្គមានព្យាយាមធំ ដែលទ្រង់ទើបស្តេចមកដល់ថ្មីៗ ។ ខ្ញុំកាន់ឆត្រជាវិការនៃផ្កា ហើយចូលទៅគាល់ព្រះនរាសភៈ ដែលកំពុងចូលសមាធិហើយ បានធ្វើឲ្យខ្ញុំចសមាធិព្រះអង្គ ។ ខ្ញុំផ្គងដៃទាំងពីរហើយ ថ្វាយឆត្រផ្កា ព្រះមានព្រះភាគ ជាមហាមុនី ព្រះនាមបទុមុត្តរៈ ទ្រង់បានទទួល ។ ពួកទេវតាទាំងអស់ មានចិត្តរីករាយ ចូលទៅកាន់ព្រៃហិមពាន្ត ពួកទេវតាទាំងនោះ បានញុំាងសាធុការឲ្យប្រព្រឹត្តទៅ ( ហើយពោលថា ) ព្រះពុទ្ធមានបញ្ញាចក្ខុនឹងធ្វើអនុមោទនា ។ ទេវតាទាំងនោះ លុះពោលពាក្យនេះហើយក៏ចូលទៅគាល់ព្រះសម្ពុទ្ធ ដ៏ប្រសើរជាងនរៈ ដែលកំពុងបាំងឆត្រផ្កាឈូកដ៏ឧត្តមរបស់ខ្ញុំ ឮដ៏អាកាស ។

( ព្រះបទុមុត្តរៈត្រាស់ថា ) តាបសបានលើកឆត្រប្រដាប់ដោយស្រទាប់ ៧ ថ្វាយតថាគត តថាគតនឹងសម្តែងសរសើរតាបសនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ តាបសនេះនឹងសោយទេវរាជ្យ អស់ ២៥ កប្ប មួយទៀត នឹងបានជាស្តេចចក្កពត្តិ អស់ ៣៤ ដង ។ តាបសនេះ បើអន្ទោលទៅកាន់កំណើត

ណាៗ ទោះជាទេវតា ឬជាមនុស្ស ផ្កាឈូកនឹងបាំងតាបសនោះ ដែលកំពុងស្ថិតនៅក្នុងទីវាល ។ កន្លងទៅមួយសែនកប្ប ព្រះបរមសាស្តា ព្រះនាមគោតម ទ្រង់កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ លុះដល់សាសនា ដែលព្រះពុទ្ធព្រះនាមគោតម ទ្រង់ប្រកាសហើយ តាបសនោះ នឹងបាននូវអត្តភាពជាមនុស្ស ជាអ្នកប្រសើរក្នុងកាយ ដ៏សម្រេចដោយចិត្ត ។ មានបងប្អូនពីរនាក់ ឈ្មោះបន្ថក:ដូចគ្នា ទាំងពីរនាក់ នឹងបានទទួលនូវប្រយោជន៍ដ៏ឧត្តម ហើយធ្វើពុទ្ធសាសនាឲ្យរុងរឿង ។

ខ្ញុំមានអាយុ ១៨ ឆ្នាំ បានចូលទៅកាន់ផ្នួស តែខ្ញុំមិនសម្រេចគុណវិសេស ក្នុងសាសនាព្រះពុទ្ធជាសក្យបុត្តទេ ។ គតិរបស់ខ្ញុំយឺត ( ព្រោះ ) ខ្ញុំបានមើលងាយគេ ក្នុងកាលមុន ឯភិក្ខុជាបងក៏បណ្តេញខ្ញុំថា លោកចូរទៅកាន់ផ្ទះរបស់ខ្លួនឥឡូវនេះចុះ ។ ខ្ញុំនោះ ដែលត្រូវបងបណ្តេញចេញហើយ ក៏តូចចិត្ត បានទៅឈរអែបត្រង់ខ្លោងទ្វារនៃអារាម របស់សង្ឃនោះ ឥតមានសេចក្តីអាឡោះអាល័យ ក្នុងសមណភេទឡើយ ។ គ្រានោះ ព្រះសាស្តាស្តេចមកដល់ទីនោះហើយ អង្អែលសីសៈរបស់ខ្ញុំ ចាប់ខ្ញុំត្រង់ដើមដៃ ហើយនាំចូលទៅកាន់អារាមនៃសង្ឃវិញ ។ ព្រះសាស្តា បានប្រទានសំពត់ជូតជើងដល់ខ្ញុំ ហើយទ្រង់ត្រាស់ដោយសេចក្តីអនុគ្រោះថា អ្នកចូរអធិដ្ឋានសំពត់ដ៏ស្អាតយ៉ាងនេះចុះ សំពត់នេះតបាគតអធិដ្ឋាន

ហើយ ក្នុងទីដ៏សមគួរ ។ ខ្ញុំក៏បានទទួលយកសំពត់នោះ ដោយដៃទាំងពីរហើយ នឹកនូវកម្មដ្ឋាន មានផ្កាឈូកក្រហមជាអារម្មណ៍ ចិត្តរបស់ខ្ញុំក៏រួចស្រឡះ ( ចាកកិលេស ) ក្នុងទីនោះ ខ្ញុំបានដល់អរហត្តផលហើយ ។ ខ្ញុំបានដល់នូវបារមីញាណ ក្នុងទីទាំងពួងក្នុងកាយដ៏សម្រេចដោយចិត្ត ហើយកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចុល្លបន្ថកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចុល្លបន្ថកត្ថេរាបទាន ចប់

# អដ្ឋកថា

## ចុល្លបន្ថកត្ថេរាបទាន

[ ១៦ ] អបទានរបស់ព្រះចុល្លបន្ថកត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។

ព្រះថេរៈរូបនេះ ក៏ជាអ្នកមានអធិការធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ខ្ញុំបានពោលរឿង ( របស់លោក ) ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាការផ្ដើមដំបូងក្នុងរឿងរបស់ព្រះមហាបន្ថកត្ថេរ ( ក្នុងថេរគាថា ) ក្នុងអដ្ឋកនិបាតនោះហើយ ។ ចំណែកសេចក្ដីដែលប្លែកគ្នា មានដូចតទៅ ព្រះមហាបន្ថកត្ថេរសម្រេចអរហត្តហើយ ញ៉ាំងពេលវេលាឲ្យកន្លងទៅ ដោយសេចក្ដីសុខដែលកើតអំពីផលសមាបត្តិ គិតថា ធ្វើដូចម្ដេចហ្ន៎ ទើបអញអាចឲ្យចុល្លបន្ថកៈ តាំងនៅក្នុងសេចក្ដីសុខយ៉ាងនេះដែរហ្ន៎ ។ ទើបព្រះថេរៈចូលទៅរកមហាធនសេដ្ឋី ដែលជាជីតារបស់ខ្លួន ពោលថា លោកមហាសេដ្ឋី បើលោកអនុញ្ញាត អាត្មានឹងឲ្យចុល្លបន្ថកៈបួស មហាសេដ្ឋីពោលថា សូមលោកម្ចាស់ឲ្យគេបួសចុះ ។ ព្រះថេរៈក៏ឲ្យចុល្លបន្ថកៈបួស ។ ចុល្លបន្ថកៈនោះ តាំងមាំក្នុងសីល ១០ ហើយ បានរៀនគាថា ( សំយុត្តនិកាយ សគាថវគ្គ ) ក្នុងសម្នាក់បងប្រុសថា

ផ្កាឈូក ( ក្រហមប្រាល ) រីកក្នុងវេលាព្រឹក មានក្លិនក្រអូប
មិនប្រាសចាកក្លិន យ៉ាងណា អ្នកចូរមើលនូវព្រះសម្មាសម្ពុទ្ធ

មានរស្មីផ្សាយចេញអំពីព្រះអង្គ កំពុងរុងរឿង ដូចព្រះអាទិត្យ
ដែលរុងរឿង ក្នុងអាកាសយ៉ាងនោះឯង ដូច្នេះ ។

ដោយកន្លងទៅ ៤ ខែ ក៏មិនអាចទន្ទេញចាំគាថានេះបាន ពាក្យដែលរៀនហើយ មិនជាប់នៅក្នុងចិត្ត ។ លំដាប់នោះ ព្រះមហាបន្ថកៈក៏ពោលនឹងលោកថា នែចុល្លបន្ថកៈ អ្នកប្រហែលជាអភព្វបុគ្គលក្នុងសាសនានេះពិតៗ ពេលវេលាកន្លងទៅ ៤ ខែ ក៏មិនអាចចាំនូវគាថាត្រឹមតែមួយបាន ហើយអ្នកនឹងធ្វើកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបានដូចម្តេច ចូរអ្នកទៅចុះ ចូរចេញអំពីទីនេះចុះ ។ ព្រះចុល្លបន្ថកៈនោះ ត្រូវព្រះថេរៈជាបងបណ្តេញ ទើបទៅឈរយំក្បែរខ្លោងទ្វារ ។

ក្នុងសម័យនោះ ព្រះសាស្តាគង់នៅក្នុងជីវកម្ពវ័ន ។ លំដាប់នោះ ជីវកប្រើឲ្យមនុស្សទៅនិមន្តថា ចូរអ្នកទៅនិមន្តព្រះសាស្តា មួយអន្លើដោយភិក្ខុ ៥០០ រូបមក ។ ក្នុងសម័យនោះ ព្រះមហាបន្ថកៈធ្វើជាភត្តុទ្ទេសក៍ ។ ព្រះមហាបន្ថកៈនោះ លុះបានទទួលនិមន្តអំពីពេទ្យជីវកថា សូមលោកម្ចាស់ទទួលភិក្ខាដើម្បីភិក្ខុ ៥០០ រូបផងចុះ ទើបលោកពោលថា អាត្មាទទួលនិមន្តសម្រាប់ភិក្ខុដ៏សេស វៀរចុល្លបន្ថកៈ ។ ព្រះចុល្លបន្ថកៈបានស្តាប់ពាក្យនោះហើយ ដល់នូវភាពទោមនស្សយ៉ាងក្រៃលែង ។ ព្រះសាស្តាទ្រង់ជ្រាបដល់សេចក្តីទុក្ខផ្លូវចិត្តរបស់ព្រះចុល្លបន្ថកៈ ទ្រង់ព្រះតម្រិះថា តថាគតនឹងឲ្យចុល្លបន្ថកៈត្រាស់ដឹងដោយឧបាយ ទើបទ្រង់សម្តែងព្រះកាយក្នុងទីមិនឆ្ងាយអំពីព្រះថេរៈ ត្រាស់សួរថា បន្ថកៈ ហេតុអ្វី ទើបអ្នកយំ ព្រះចុល្លបន្ថកៈ

ក្រាបទូលថា បពិត្រព្រះអង្គ បងប្រុសបណ្តេញខ្ញុំព្រះអង្គ ព្រះសាស្តាទ្រង់ត្រាស់ថា នែបន្ថក: អ្នកកុំគិតប្តីឡើយ អ្នកបួសក្នុងសាសនារបស់តថាគត ចូរមកទទួលសំពត់នេះហើយ ចូរធ្វើបរិកម្មក្នុងចិត្តថា **រជោហរណំ រជោហរណំ** សំពត់ជូតធូលី សំពត់ជូតធូលី ដូច្នេះហើយ បានប្រទានសំពត់ស្អាតដែលសម្រេចដោយឫទ្ធិ ។ ព្រះថេរៈអង្គុយយកដៃអង្អែល បរិកម្មកំណាត់សំពត់ដែលព្រះសាស្តាទ្រង់ប្រទានឲ្យមកថា **រជោហរណំ រជោហរណំ** ដូច្នេះ ។ កាលលោកបរិកម្ម ស្ទាបអង្អែលសំពត់នោះទៅមក សំពត់ស្អាតក៏ក្លាយជាសំពត់សៅហ្មង កាលលោកបរិកម្មអង្អែលហើយអង្អែលទៀត សំពត់ស្អាតក៏ក្លាយដូចជាសំពត់ជូតឆ្នាំងបាយ ព្រោះមានញាណចាស់ក្លា លោកក៏គិតយ៉ាងនេះថា ពីដើមមក សំពត់នេះបរិសុទ្ធស្អាត ព្រោះអាស្រ័យសរីរៈដែលមានវិញ្ញាណគ្រប់គ្រងនេះ ទើបជាសំពត់ប្រែប្រួលសៅហ្មងទៅ ក្លាយសភាពជាសំពត់ជូតឆ្នាំងដទៃ ហេតុនោះ សំពត់នេះ ជាអនិច្ចំ យ៉ាងណា ចិត្តក៏យ៉ាងនោះ ទើបផ្តើមកំណត់ការអស់ទៅ សូន្យទៅ ញុំាងឈានក្នុងនិមិត្តនោះឯងឲ្យកើតឡើង ធ្វើឈានឲ្យជាបាទផ្តើមចម្រើនវិបស្សនា ក៏បានសម្រេចអរហត្ត ព្រមទាំងបដិសម្ភិទា ៤ លុះលោកបានសម្រេចអរហត្តនោះឯង ព្រះត្រៃបិដក និងអភិញ្ញា ៥ ក៏កើតព្រមហើយ ។

ព្រះសាស្តាបានយាងទៅព្រមជាមួយភិក្ខុ ៤៩៩ រូប ហើយគង់លើអាសនៈដែលគេបានរៀបចំ ក្នុងនិវេសន៍របស់ពេទ្យជីវក តែព្រះចុល្លបន្ថកៈមិនបានទៅ ព្រោះបងប្រុសរបស់លោក មិនព្រមទទួលនិមន្តដើម្បីភិក្ខុ

សម្រាប់លោក ។ ពេទ្យជីវកផ្តើមថ្វាយបបរ ។ ព្រះសាស្តាទ្រង់យកព្រះហស្តបិទបាត្រ កាលពេទ្យជីវកក្រាបទូលសួរថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ទើបទ្រង់មិនទទួលភិក្ខា ព្រះសាស្តាក៏ត្រាស់តបថា ម្នាលជីវក ភិក្ខុនៅឯវិហារមានមួយរូប ។ ពេទ្យជីវកនោះ បានប្រើមនុស្សទៅថា នែបា ចូរបាទៅនាំលោកម្ចាស់ដែលគង់ក្នុងវិហារមក ។ ព្រះចុល្លបន្ថកត្រេកបាននិម្មិតភិក្ខុ ១ ពាន់រូប មួយរូបៗ មិនដូចគ្នា ទាំងរូបរាង និងអាកប្បកិរិយា ហើយអង្គុយ ។ លុះអ្នកបម្រើនោះឃើញថា ភិក្ខុក្នុងវិហារមានច្រើន ទើបត្រឡប់ទៅប្រាប់ពេទ្យជីវកថា ភិក្ខុសង្ឃក្នុងវិហារមានច្រើន ជាងភិក្ខុសង្ឃដែលមកក្នុងផ្ទះនេះ ខ្ញុំមិនដឹងថា និមន្តលោកម្ចាស់អង្គណាមក ពេទ្យជីវកក្រាបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុអង្គុយក្នុងវិហារ ឈ្មោះអ្វី ព្រះសាស្តាត្រាស់ថា ឈ្មោះចុល្លបន្ថកៈ ។ ទើបពេទ្យជីវកប្រើមនុស្សទៅជាថ្មីថា នែបា ចូរទៅសួរថា ភិក្ខុរូបណាឈ្មោះចុល្លបន្ថកៈ ហើយចូរនាំភិក្ខុរូបនោះមក ។ អ្នកបម្រើនោះទៅកាន់វិហារហើយ សួរថា បពិត្រលោកម្ចាស់ ភិក្ខុរូបណាឈ្មោះចុល្លបន្ថកៈ ភិក្ខុទាំង ១ ពាន់រូប ក៏ឆ្លើយព្រមគ្នាថា អាត្មាឈ្មោះចុល្លបន្ថកៈ អាត្មាឈ្មោះចុល្លបន្ថកៈ ។ អ្នកបម្រើនោះ ក៏ត្រឡប់មកទៀត ហើយប្រាប់ឲ្យពេទ្យជីវកជ្រាបរឿងនោះ ព្រោះអំណាចដែលលោកចាក់ធ្លុះសច្ចៈ ពេទ្យជីវកក៏ជ្រាបដោយន័យថា ប្រហែលលោកម្ចាស់មានឫទ្ធិ ទើបប្រាប់អ្នកបម្រើថា នែបា ចូរទៅជាថ្មី ចូរនិយាយថា ព្រះសាស្តាហៅរកលោកម្ចាស់ៗ អង្គណាឆ្លើយមុន ចូរចាប់ជាយចីវររបស់លោកម្ចាស់អង្គ

នោះ ។ អ្នកបម្រើនោះ ទៅកាន់វិហារហើយ បានធ្វើតាមពាក្យប្រាប់ ។ ក្នុងខណៈនោះឯង ភិក្ខុដែលនិម្មិតទាំងឡាយ ក៏អន្តរធានទៅ ។ អ្នកបម្រើបាននាំព្រះថេរៈទៅហើយ ។

ខណៈនោះ ព្រះសាស្តាទ្រង់ទទួលយាគូ និងរបស់ទំពាជាដើម ច្រើនប្រភេទ ។ ព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទើបត្រាស់ឲ្យព្រះចុល្លបន្ថកៈធ្វើអនុមោទនា ។ ព្រះចុល្លបន្ថកៈនោះ ជាអ្នកបែកធ្លាយក្នុងបដិសម្ភិទា ធ្វើអនុមោទនាត្រូវតាមព្រះហឫទ័យរបស់ព្រះសាស្តា ដោយការញ៉ាំងព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកឲ្យខ្វល់ខ្វាយ ដូចនាំក្អំសិនេរុមកកូរមហាសមុទ្ទឲ្យរញ្ជួយ ដូច្នោះ ។ កាលព្រះទសពលធ្វើភត្តកិច្ចស្រេចហើយ ទ្រង់យាងទៅកាន់វិហារ ទើបមានអន្តរកថាកើតឡើងក្នុងធម្មសភាថា គួរអស្ចារ្យហ្ន៎ អានុភាពរបស់ព្រះពុទ្ធទាំងឡាយ ដែលធ្វើឲ្យបុគ្គលមិនអាចទន្ទេញចាំគាថាមួយ ក្នុងរយៈពេល ៤ ខែ ឲ្យជាអ្នកមានឫទ្ធិច្រើនបែបនេះ បានត្រឹមមួយរំពេចខណៈ ។ សេចក្តីពិតដូច្នោះឯង ព្រះមានព្រះភាគគង់នៅក្នុងនិវេសន៍របស់ពេទ្យជីវក ទ្រង់ជ្រាបថា ចិត្តរបស់ព្រះចុល្លបន្ថកៈមាំទាំល្អហើយ វិបស្សនាប្រព្រឹត្តទៅកាន់វីថិហើយ ដូច្នេះ កំពុងគង់នោះឯង ទ្រង់សម្តែងព្រះអង្គឲ្យប្រាកដ កាលនឹងសម្តែងថា ម្នាលបន្ថកៈ សំពត់ចាស់នេះ មិនទាន់សៅហ្មងដោយធូលីប៉ុន្មានឡើយ តែក្នុងអរិយវិន័យ នៅមានវត្ថុដែលសៅហ្មងជាងធូលីជាងនេះទៀត ដូច្នេះហើយ ទើបទ្រង់ត្រាស់ ៣ គាថា ( ក្នុងខុទ្ទកនិកាយ មហានិទ្ទេស ) ថា

ធូលី គឺរាគៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃរាគៈ ភិក្ខុទាំងនោះ រមែងលះបង់នូវធូលីនុ៎ះហើយ សម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

ធូលី គឺទោសៈ ។បេ។ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

ធូលី គឺមោហៈ ។បេ។ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ដូច្នេះ ។

ក្នុងវេលាចប់ព្រះគាថា ព្រះចុល្លបន្ថកៈបានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ។ ព្រះសាស្តា ទ្រង់បានស្តាប់ពាក្យចរចាររបស់ភិក្ខុទាំងនោះហើយ ទ្រង់យាងមកគង់លើពុទ្ធាសនៈ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុល្លបន្ថកៈតាំងនៅក្នុងឱវាទរបស់តថាគត បានទទួលសម្បត្តិ គឺលោកុត្តរក្នុងកាលឥឡូវនេះ ចំណែកក្នុងកាលមុន បានទទួលត្រឹមតែលោកិយសម្បត្តិប៉ុណ្ណោះ កាលភិក្ខុទាំងនោះទូលអារាធនា ទើបត្រាស់ចុល្លសេដ្ឋីជាតកហើយ ។ ក្នុងកាលតមក ព្រះសាស្តាមានពួកព្រះអរិយៈចោមរោម គង់លើធម្មាសនៈ ទ្រង់តែងតាំងព្រះចុល្លបន្ថកៈនោះ ក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ ដែលឈ្លាសក្នុងការនិម្មិតកាយដែល

១- បិដកខ្មែរមហានិទ្ទេស ជាបណ្ឌិតទាំងនោះ ក្នុងចូឡនិទ្ទេស ជាអ្នកមានបញ្ញាចក្ខុ ។

សម្រេចដោយចិត្ត និងឈ្វាសក្នុងចេតោវិមុត្តិ ។

ព្រះចុល្លបន្ថកៈនោះ បានទទួលតំណែងដ៏ប្រសើរយ៉ាងនេះហើយ រឭក បុព្វកម្មរបស់ខ្លួន ដោយអំណាចបីតិ និងសោមនស្ស កាលនឹងប្រកាសអាង ដល់អបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលគាថាផ្តើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។ ពីរបទដំបូងក្នុងគាថានោះ ដូចគ្នានឹងខ្ញុំបានពោល ហើយនោះឯង ។ បទថា **គណម្ហា វូបកដ្ឋោ សោ** សេចក្តីថា ព្រះសាស្តា ទ្រង់ព្រះនាមបទុមុត្តរៈអង្គនោះ ទ្រង់ចៀសចេញចាកពួក គឺចាកពួកភិក្ខុ ជាច្រើន ចៀសចេញ គឺបែកចេញនៅដោយវិវេក ។ វេលានោះ គឺវេលា ដែលខ្ញុំនៅជាតាបស ខ្ញុំនៅ គឺបានសម្រេចការនៅអាស្រ័យ បានដល់ បាន នៅដោយឥរិយាបថទាំង ៤ ក្នុងហិមវន្តប្បទេស គឺក្នុងទីជិតភ្នំហិមាល័យ ។

បទថា **អហម្បិ ។បេ។ តទា** ភ្ជាប់សេចក្តីថា ក្នុងកាលដែលព្រះមាន ព្រះភាគអង្គនោះ យាងចូលទៅគង់ក្នុងហិមវន្តប្បទេស ។ ខ្ញុំឯង ក៏នៅក្នុង អាស្រមដែលបានសាងជិតហិមវន្តប្បទេស គឺក្នុងទីសម្រាកក្នុងព្រៃ ដែល បានឈ្មោះថា អាស្រម ព្រោះជាទីស្ងប់ចាកអន្តរាយ គឺវត្ថុដែលបៀតបៀន ផ្លូវកាយ និងចិត្តដោយជុំវិញ ។ បទថា **អចិរាគតំ មហាវីរំ** ភ្ជាប់សេចក្តី ថា ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគអង្គនោះ ដែលមានសេចក្តីព្យាយាម ច្រើន ជាលោកនាយក គឺជាប្រធាន ដែលមកមិនយូរប៉ុន្មាន អធិប្បាយថា ទើបតែបានយាងមកដល់ក្នុងខណៈនោះឯង ។

បទថា **បុប្ផឆត្តំ គហេត្វាន** សេចក្តីថា កាលចូលទៅរកយ៉ាងនោះ

បានកាន់យកធត្រប៉ាំងធ្វើដោយផ្កា ប្រក់ដោយផ្កាឈូក និងផ្កាឧប្បល ជាដើម ចូលទៅគាល់ គឺចូលទៅរកព្រះមានព្រះភាគ ដ៏ប្រសើរជាងនរជន គឺប្រសើរជាងនរជន ។ បទថា **សមាធឹ សមាបជ្ជន្តំ** ក្លាប់សេចក្តីថា ខ្ញុំបានធ្វើអន្តរាយដល់បុគ្គលដែលអង្គុយចូលរូបាវចរសមាធិជ្ឈាន ។

បទថា **ឧភោ ហត្ថេហិ បគយ្ហ** ក្លាប់សេចក្តីថា ខ្ញុំបានប្រើដៃទាំងពីរលើកធត្រផ្កា ដែលតាក់តែងរចនាល្អហើយនោះ ថ្វាយព្រះមានព្រះភាគ ។ បទថា **បដិគ្គហេសិ** សេចក្តីថា ព្រះមានព្រះភាគបទុមុត្តរៈ ទ្រង់ទទួល គឺទ្រង់អើពើទទួលធត្រផ្កា ដែលខ្ញុំបានថ្វាយហើយនោះ ។

បទថា **សតបត្តជត្តំ បគយ្ហ** សេចក្តីថា តាបសណាកាន់ធត្រផ្កាដែលប្រក់ដោយផ្កាឈូក ១០០ ត្របក ដោយផ្កាឈូកតែមួយផ្កា មាន ១០០ ត្របក ប៉ាំងថ្វាយដល់តថាគតដោយអាការអើពើ ។ បទថា **តមហំ កិត្ត-យិស្សាមិ** សេចក្តីថា តថាគតនឹងព្យាករតាបសនោះ គឺនឹងធ្វើឲ្យប្រាកដ អ្នកទាំងឡាយ ចូរស្តាប់ គឺចូរតាំងចិត្តស្តាប់នូវពាក្យរបស់តថាគតពោល គឺនឹងពោល ។

បទថា **បញ្ចវីសតិកប្បានិ** ក្លាប់សេចក្តីថា ដោយការបានថ្វាយធត្រផ្កានេះ តាបសនេះនឹងបានជាសក្កទេវរាជ គ្រប់គ្រងទេវសម្បត្តិ ក្នុងស្ថានតាវត្តិង្ស អស់ ២៥ ដង ។ បទថា **ចតុត្តឹសតិក្ខត្តុញ្ច** សេចក្តីថា នឹងបានជាស្តេចចក្រពត្តិ ក្នុងមនុស្សលោក អស់ ៣៤ ដង ។

បទថា **យំ យំ យោនឹ** សេចក្តីថា អន្ទោល គឺទៅ បានដល់ ចូល

ដល់កំណើតណាមួយ ក្នុងកំណើតមនុស្សជាដើម អធិប្បាយថា ផ្កាឈូក នឹងបាំង គឺបាំងលើតាបសនេះ ដែលនៅ គឺអង្គុយ ឬឈរក្នុងទីវាល គឺទីទទេក្នុងកំណើតនោះៗ ។

បទថា **បកាសិតេ បាវចនេ** សេចក្តីថា កាលព្រះមានព្រះភាគអង្គនោះ ទ្រង់ប្រកាស គឺសម្តែងព្រះត្រៃបិដកទាំងមូល តាបសនេះ នឹងកើត គឺចូលដល់ភាពជាមនុស្ស គឺជាតិនៃមនុស្ស ។ បទថា **មនោមយម្ហិ កាយម្ហិ** សេចក្តីថា ឈ្មោះថា មនោមយៈ ព្រោះអត្ថថា កើតដោយចិត្ត គឺដោយឈានចិត្ត អធិប្បាយថា ចិត្តប្រព្រឹត្តទៅយ៉ាងណា រមែងឲ្យកាយប្រព្រឹត្តទៅ គឺធ្វើឲ្យប្រព្រឹត្តទៅតាមចិត្តយ៉ាងនោះ អធិប្បាយថា តាបសនោះ នឹងមានឈ្មោះថា ចុល្លបន្ថកៈដ៏ឧត្តម គឺជាឯតទគ្គៈក្នុងកាយដែលសម្រេចដោយចិត្តនោះ ។ ពាក្យដ៏សេស ជាពាក្យដែលដឹងបានងាយ ព្រោះលោកពោលខាងដើមហើយ និងព្រោះមានអត្ថងាយយល់នោះឯង ។

បទថា **សីរិ កោកនទំ អហំ** សេចក្តីថា ខ្ញុំអង្អែលកំណាត់សំពត់ដែលព្រះមានព្រះភាគទ្រង់និម្មិត រឭកដល់ផ្កាឈូកឈ្មោះកោកនទៈ ។ បទថា **តត្ថ ចិត្តំ វិមុច្ចិ មេ** ក្នុងសេចក្តីថា ចិត្តរបស់ខ្ញុំបង្អោនទៅ គឺនៃបនៅជាមួយផ្កាឈូកឈ្មោះកោកនទៈ បន្ទាប់អំពីនោះ ខ្ញុំក៏សម្រេចអរហត្ត ។

ក្នុងសេចក្តីថា សម្រេចដល់បារមី គឺទីបំផុតក្នុងកាយដែលសម្រេចដោយចិត្ត គឺឲ្យកើតបានដូចចិត្តក្នុងទីគ្រប់ចំណែក គឺទីទាំងពួង ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ល។

# សុត្តន្តបិដក

## បិលិន្ទវច្ឆត្ថេរាបទានទី ៩

[ ១៧ ] កាលព្រះលោកនាថ ព្រះនាមសុមេធៈ ទ្រង់ជាអគ្គបុគ្គល ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើនូវការបូជាព្រះស្តូប ។ ព្រះខីណាស្រពទាំងឡាយណា ដែលបាន អភិញ្ញា ៦ មានឫទ្ធិច្រើន នៅក្នុងទីនោះ ខ្ញុំក៏បានប្រជុំព្រះខីណាស្រពទាំងនោះ ក្នុងទីនោះ ហើយបានធ្វើសង្ឃភត្ត ។ កាលនោះ ព្រះថេរៈឈ្មោះសុមេធៈ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ព្រះនាមសុមេធៈ ព្រះថេរៈនោះ បានធ្វើអនុមោទនាក្នុងកាលនោះ ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំបានចូលទៅក្នុងវិមាន ដែលមានស្រីអប្សរ ៨៦ ពាន់ កើតឡើងសម្រាប់ខ្ញុំ ។ ពួកស្រីអប្សរនោះ ប្រព្រឹត្តតម្រូវចិត្តខ្ញុំ ដោយកាមទាំងពួង សព្វៗ កាល ខ្ញុំគ្របសង្កត់នូវពួកទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ២៥ កាលនោះ ខ្ញុំបានជាស្តេចចក្កពត្តិ ឈ្មោះវរុណៈ មានភោជនដ៏បរិសុទ្ធ ។ មនុស្សទាំងឡាយនោះ មិនបាច់សាបព្រោះពូជ មិនបាច់ភ្ជួរដោយនង្គ័ល តែងបរិភោគស្រូវសាលី ដែលដុះក្នុងទីមិនបាច់ភ្ជួរ ។ ខ្ញុំសោយរាជ្យ ក្នុងអត្តភាពជាមនុស្សនោះហើយ ក៏បានទៅកាន់អត្តភាពជាទេវតាម្តងទៀត ការបរិបូរដោយភោគៈបែបនេះ ក៏កើតឡើងសម្រាប់ខ្ញុំក្នុងកាលនោះ ។ សត្វទាំងអស់ ទោះបីជាមិត្តក្តី មិនមែនជាមិត្តក្តី មិនដែលបៀតបៀនខ្ញុំ ខ្ញុំរមែងជាទីស្រឡាញ់នៃសត្វ

ទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣០ ពាន់ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃគ្រឿងក្រអូប និងគ្រឿងលាប ។ ក្នុងកទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិមួយអង្គ ជាធំជាងជន មានអានុភាពច្រើន ជាពជឥសី មានកម្លាំងច្រើន ។ ខ្ញុំនោះតាំងនៅក្នុងសីល ៥ ហើយញុំាងពួកជនច្រើននាក់ឲ្យដល់នូវសុគតិ ខ្ញុំជាទីស្រឡាញ់នៃទេវតាទាំងឡាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិលិន្ទវច្ឆត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## បិលិន្ទវច្ឆត្ថេរាបទាន ចប់

# អដ្ឋកថា

## បិលិន្ទវច្ឆត្ថេរាបទាន

[ ១៧ ] អបទានរបស់ព្រះបិលិន្ទវច្ឆត្ថេរ មានពាក្យផ្ដើមថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះ ។

ព្រះថេរៈរូបនេះ ក៏មានអធិការដែលធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កុលបុត្តនេះ កើតក្នុងត្រកូលមានភោគៈច្រើន ក្នុងនគរហង្សវតី ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដាដោយន័យដូចពោលហើយខាងដើម ឃើញព្រះសាស្ដាតាំងភិក្ខុមួយរូប ក្នុងតំណែងជាឯតទគ្គៈ ខាងជាទីស្រឡាញ់ពេញចិត្តរបស់ទេវតាទាំងឡាយ ប្រាថ្នាតំណែងនោះ ធ្វើបុណ្យដរាបដល់អស់ជីវិត ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសុមេធៈ កើតឡើងក្នុងផ្ទះមានត្រកូលមួយកន្លែង កាលព្រះមានព្រះភាគបរិនិព្វានហើយ លោកបូជាព្រះស្តូបរបស់ព្រះមានព្រះភាគអង្គនោះ ថ្វាយមហាទានដល់ព្រះសង្ឃ ឃ្លាតចាកអត្តភាពនោះហើយ សោយសម្បត្តិទាំងពីរ ក្នុងទេវតា និងមនុស្សទាំងឡាយ កាលព្រះពុទ្ធមិនទាន់កើតឡើង បានជាស្ដេចចក្រពត្តិ ឲ្យមហាជនតាំងនៅក្នុងសីល ៥ ឲ្យជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ កាលព្រះមានព្រះភាគនៃយើងទាំងឡាយ មិនទាន់កើតឡើងនោះឯង កុលបុត្តនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ញាតិទាំងឡាយដាក់ឈ្មោះថា បិលិន្ទៈ ។ ពាក្យថា **វច្ឆ** ជាឈ្មោះថារបស់គោត្ត ។ ក្នុងកាលតមក

លោកបានប្រាកដនាមថា បិលិន្ទវច្ឆៈ ព្រោះជាអ្នកច្រើនទៅដោយសេចក្តីសង្វេគ ទើបបួសជាបរិព្វាជក សម្រេចវិជ្ជាឈ្មោះចូឡគន្ធារៈ ដោយវិជ្ជានោះធ្វើឲ្យហោះបាន ទីងដឹងចិត្តអ្នកដទៃ ដល់នូវភាពជាបុគ្គលប្រសើរ ដោយលាភ និងយស អាស្រ័យនៅក្នុងនគររាជគ្រឹះ ។

លំដាប់នោះ ព្រះមានព្រះភាគនៃយើងទាំងឡាយ ជាអ្នកត្រាស់ដឹងក្រៃលែងហើយ យាងចូលទៅកាន់នគររាជគ្រឹះដោយលំដាប់ ។ ចាប់តាំងពីនោះមក ដោយអានុភាពរបស់ព្រះពុទ្ធ វិជ្ជានោះមិនឲ្យផលដល់លោក លោកមិនអាចធ្វើកិច្ចឲ្យសម្រេច ។ លោកត្រិះរិះថា អញបានស្តាប់មកអំពីសម្នាក់អាចារ្យថា ក្នុងទីណាមានអ្នកទ្រទ្រង់មហាគន្ធារវិជ្ជា ក្នុងទីនោះ ចូឡគន្ធារវិជ្ជាមិនសម្រេចផល ព្រោះហេតុនោះ តាំងអំពីព្រះសមណគោតមយាងមក វិជ្ជារបស់អញនេះមិនសម្រេចផល ព្រះសមណគោតម ទ្រង់ជ្រាបមហាគន្ធារវិជ្ជាដោយឥតសង្ស័យ បើដូច្នោះ អញគួរចូលទៅរកលោក គប្បីរៀនវិជ្ជានោះ ក្នុងសម្នាក់របស់ព្រះសមណគោតម ។ ព្រោះហេតុនោះឯងទើបទ្រង់ត្រាស់ថា បើយ៉ាងនោះ ចូរអ្នកបួសក្នុងសម្នាក់របស់តថាគត ។ លោកសម្គាល់ថា ការបួសជាបរិកម្មយ៉ាងរបស់វិជ្ជា ទើបបួស ព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់លោក ទ្រង់បានប្រទានកម្មដ្ឋានដែលសមគួរដល់ចរិត ព្រោះលោកសម្បូរដោយឧបនិស្ស័យ មិនយូរប៉ុន្មាន លោកផ្តើមវិបស្សនា សម្រេចនូវអរហត្ត ។

ម្យ៉ាងទៀត ទេវតាដែលទៅកើតក្នុងស្ថានសួគ៌ ព្រោះក្នុងជាតិមុន តាំង

នៅក្នុងឱវាទរបស់លោក អាស្រ័យភាពជាកតញ្ញូ កើតនូវការរាប់អានក្នុងលោកច្រើន ទើបចូលទៅអង្គុយជិតព្រះថេរៈ ទាំងល្ងាច ទាំងព្រឹក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់តាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈ ខាងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ ដែលជាសាវករបស់តថាគត ស្រេចនឹងបិលិន្ទវច្ឆៈប្រសើរជាគេ ដូច្នេះ ។ ព្រះថេរៈដល់នូវតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចបីតិ និងសោមនស្ស ទើបពោលពាក្យថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូច្នេះ ឈ្មោះថា **លោកនាថ** ព្រោះជាទីពឹង គឺជាប្រធានរបស់កាមលោក រូបលោក និងអរូបលោក ។ សព្វញ្ញុតញ្ញាណ និងអនាវរណញ្ញាណជាដើម ហៅថា **មេធា** ។ ឈ្មោះថា **អគ្គបុគ្គល** ព្រោះជាអ្នកមានមេធាល្អ គឺប្រសើរបំផុត អ្នកមានមេធាល្អនោះជាបុគ្គលប្រសើរផងដែរ ភ្ជាប់សេចក្ដីថា កាលព្រះលោកនាថ ជាអ្នកមានមេធាល្អ ជាអគ្គបុគ្គលនោះ បរិនិព្វានដោយខន្ធបរិនិព្វាន ។ បទថា **បសន្នចិត្តោ សុមនោ** សេចក្ដីថា ខ្ញុំជាអ្នកមានចិត្តជ្រះថ្លាដោយសទ្ធា ត្រេកអរដោយសោមនស្ស ឲ្យធ្វើនូវការបូជាព្រះស្តូប គឺព្រះចេតិយរបស់ព្រះមានព្រះភាគព្រះនាមសុមេធៈនោះ ។

បទថា **យេ ច ខីណាសវា តត្ថ** សេចក្ដីថា ព្រះខីណាស្រពឯណា

ជាអ្នកលះកិលេសបានហើយ ឈ្មោះថា បានអភិញ្ញា ៦ គឺប្រកបដោយអភិញ្ញា ៦ ឈ្មោះថា មានឫទ្ធិច្រើន គឺប្រកបដោយឫទ្ធិច្រើន មានអធិប្បាយថា ខ្ញុំនិមន្តព្រះខីណាស្រពទាំងអស់នោះឲ្យមកប្រជុំគ្នាក្នុងទីនោះ នាំមកដោយសេចក្តីអើពើ បានធ្វើសង្ឃភត្ត គឺភត្តដែលគប្បីថ្វាយដល់សង្ឃទាំងមូល ឲ្យព្រះខីណាស្រពនោះឆាន់ ។

បទថា **ឧបដ្ឋាកោ តទា អហុ** សេចក្តីថា ក្នុងកាលនោះ គឺក្នុងកាលដែលខ្ញុំថ្វាយសង្ឃភត្ត សាវកដែលជាឧបដ្ឋាកឈ្មោះសុមេធៈ របស់ព្រះមានព្រះភាគព្រះនាមសុមេធៈ អធិប្បាយថា សាវកនោះ បានអនុមោទនាសក្ការបូជារបស់ខ្ញុំ គឺត្រេកអរហើយសម្តែងអានិសង្ស ។

បទថា **តេន ចិត្តប្បសាទេន** សេចក្តីថា ខ្ញុំបានចូលដល់វិមានក្នុងទេវលោក ដោយចិត្តជ្រះថ្លា ដែលកើតឡើងដោយអំណាចការធ្វើ ការបូជានូវព្រះស្តូបនោះ អធិប្បាយថា ខ្ញុំកើតឡើងក្នុងទិព្វវិមាននោះ ។ បទថា **ឆឡាសីតិសហស្សានិ** សេចក្តីថា ស្រីទេពអប្សរ ៨ ម៉ឺន ៦ ពាន់ ក្នុងវិមាននោះ បានត្រេកអរ គឺញ៉ាំងចិត្តរបស់ខ្ញុំឲ្យត្រេកអរ ។

បទថា **មមេវ អនុវត្តន្តិ** សេចក្តីថា ទេពអប្សរទាំងនោះ ឧបដ្ឋាកដោយកាមទាំងពួង គឺដោយវត្ថុកាម មានរូបជាដើមដែលជាទិព្វ អនុលោមតាមខ្ញុំតែម្យ៉ាង គឺធ្វើតាមពាក្យរបស់ខ្ញុំសព្វកាល គឺអស់កាលជានិច្ច ។ បទដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាបិលិន្ទវច្ឆត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## រាហុលត្ថេរាបទានទី ៦

[ ១៨ ] ខ្ញុំបានក្រាលកញ្ចក់ ក្នុងប្រាសាទ ៧ ជាន់ ថ្វាយព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ទ្រង់ប្រកបតាទិគុណ ។ ព្រះមហាមុនិ ជាធំជាងសត្វជើងពីរ ព្រះអង្គប្រសើរជាងនរៈ មានពួកព្រះខីណាស្រពមួយពាន់អង្គហោមរោម ស្តេចចូលទៅកាន់គន្ធកុដិ ។ ព្រះសាស្តា ជាទេវតាប្រសើរជាងទេវតា ព្រះអង្គប្រសើរជាងនរៈ ទ្រង់ញុំាងគន្ធកុដិឲ្យរុងរឿង ស្ថិតនៅក្នុងកណ្តាលភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងឡាយនេះថា

ទីសេយ្យាសន៍នេះ ដែលបុគ្គលណា ធ្វើឲ្យរុងរឿងហើយដូចកញ្ចក់ដែលគេក្រាលដោយល្អ តថាគតនឹងសម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ ប្រាសាទណាមួយ ជាទីស្រឡាញ់ពេញចិត្ត ប្រាសាទទាំងនោះសុទ្ធតែជាវិការនៃមាស ទាំងជាវិការនៃកែវពៃទូរ្យ នឹងកើតឡើងសម្រាប់បុគ្គលនេះ ។ បុគ្គលនោះ នឹងសោយរាជ្យ ជាធំជាងទេវតា អស់ ៦៤ ដង ក្នុងជាតិជាលំដាប់មក នឹងបានជាស្តេចចក្កពត្តិ អស់មួយពាន់ដង ក្នុងកប្បទី ២១ នឹងបានជាស្តេចចក្កពត្តិព្រះនាមវិមលៈ ។ ជាឥស្សរៈលើផែនដី មានសមុទ្ទទាំង ៤ព័ទ្ធជុំវិញ ជាស្តេចឈ្នះសង្គ្រាម ។ ទីក្រុង ( របស់ព្រះបាទវិមលៈ

នោះ ) ឈ្មោះរេណុវតី ដែលគេស្ថាបនាដោយឥដ្ឋ មានបណ្ដោយ ៣០០ យោជន៍ ប្រកបដោយជ្រុង ៤ ។ ប្រាសាទឈ្មោះសុទស្សនៈ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ ស្ថិតស្ថេរដោយកែវ ៧ ប្រការ ដែលវិស្វកម្មបានសាងថ្វាយ ។ ទីក្រុងនោះ ស្ងប់ស្ងាត់ចាកសំឡេង ទាំង ១០ ដ៏ដេរដាសដោយពួកវិជ្ជាធរ ដូចជាទីក្រុងឈ្មោះ សុទស្សនៈរបស់ទេវតាទាំងឡាយដែរ ។ កាលព្រះអាទិត្យរះឡើង ពន្លឺរបស់ក្រុងនោះ នឹងរុងរឿងជានិច្ច ដោយជុំវិញ អស់ចម្ងាយ ៨ យោជន៍ ។ ក្នុងកប្បទីមួយសែន ព្រះសាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្តនោះ នឹងច្យុតចាកស្ថានតុសិតនោះមកវិញ ត្រូវកុសលមូលជាស់តឿន បានមកកើត ជាព្រះរាជឱរសរបស់ព្រះមានព្រះភាគ ព្រះនាម គោតម ។ កុលបុត្តនោះ ប្រសិនបើនៅគ្រប់គ្រងផ្ទះ នឹងបានជា ស្ដេចចក្កពត្តិ តែមិនមានហេតុ ដែលឲ្យកុលបុត្តជាតាទិបុគ្គលនុ៎ះ បានដល់នូវសេចក្ដីត្រេកអរក្នុងផ្ទះឡើយ កុលបុត្តនោះ នឹងចេញ ចាកផ្ទះទៅបួស ជាអ្នកមានវត្តល្អ នឹងបានជាព្រះអរហន្ត ឈ្មោះ រាហុល ។

ព្រះមហាមុនី ព្រះអង្គមានប្រាជ្ញាចាស់ បរិបូណ៌ដោយសីល ទ្រង់រក្សាខ្ញុំ ថែទាំខ្ញុំ ដូចជាមេបក្សីត្រដេវវិចរក្សាស៊ុត ពុំនោះសោត ដូចជាមេចាមរីរក្សារោម ។ ខ្ញុំបានដឹងធម៌ របស់ព្រះគោតមសម្ពុទ្ធ

នោះ ត្រេកអរក្នុងសាសនាហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះរាហុលត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

រាហុលត្ថេរាបទាន ចប់

# អដ្ឋកថា

## រាហុលត្ថេរាបទាន

[ ១៨ ] *អបទានរបស់ព្រះរាហុលត្ថេរ មានពាក្យផ្តើមថា* **បទុមុត្តរស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈរូបនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ព្រះធម្មទេសនាក្នុងសម្នាក់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុ ១ រូប ក្នុងឋានៈជាកំពូលជាងភិក្ខុទាំងឡាយ ដែលប្រាថ្នាចំពោះការសិក្សា ខ្លួនឯងក៏ប្រាថ្នាតំណែងនោះដែរ ទើបបំពេញបុណ្យដ៏ធំក្រៃលែង មានការជម្រះសេនាសនៈ ធ្វើឲ្យភ្លឺស្វាងជាដើម ហើយបានតាំងសេចក្តីប្រាថ្នា ។ លោកចុតិចាកអត្តភាពនោះហើយ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ ព្រោះអាស្រ័យព្រះពោធិសត្វនៃយើង ទើបកើតក្នុងព្រះគភ៌របស់ព្រះនាងយសោធរាទេវី មានឈ្មោះថា រាហុលកុមារ ទ្រង់ចម្រើនដោយខត្តិយបរិវារជាច្រើន ។ វិធីបព្វជ្ជារបស់ព្រះថេរៈ មកហើយក្នុងខន្ធកៈនោះឯង ។ លោកបព្វជ្ជាហើយ បានទទួលឱវាទដោយល្អ ដោយសុត្តបទជាច្រើន ក្នុងសម្នាក់របស់ព្រះសាស្តា មានញាណចាស់ក្លា ចម្រើនវិបស្សនា សម្រេចអរហត្ត ។ លោកបានជាព្រះអរហន្តហើយ ពិចារណា*

បដិបទារបស់ខ្លួន កាលព្យាករអរហត្តផល ទើបភាសិតទាំង ៤ គាថា ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) នេះថា

សព្រហ្មចារីបុគ្គលទាំងឡាយ ស្គាល់ច្បាស់នូវអាត្មាអញថា រាហុលដ៏ចម្រើន ជាអ្នកប្រកបដោយគុណទាំងពីរយ៉ាង គឺជាតិ និងប្រតិបត្តិ ព្រោះអាត្មាអញជាកូននៃព្រះពុទ្ធផង ជាអ្នកមាន បញ្ញាចក្ខុ ក្នុងធម៌ទាំងឡាយផង អាសវៈរបស់អាត្មាអញ អស់ ហើយផង ភពថ្មីទៀត អាត្មាអញមិនមានផង អាត្មាអញជាព្រះ អរហន្ត គួរដល់ទក្ខិណា មានវិជ្ជា ៣ ឃើញព្រះនិព្វាន ឈ្មោះ អមតៈ ។ សត្វទាំងឡាយ ជាអ្នកងងឹតព្រោះកាម ត្រូវបណ្ដាញ រួបរឹតហើយ ត្រូវដំបូល គឺតណ្ហាបិទបាំងហើយ ត្រូវមារចង ហើយ ដូចត្រីជាប់នៅក្នុងមាត់លប ដូច្នោះ ។ អាត្មាអញ លះបង់កាមនោះហើយ បានកាត់នូវចំណងនៃមារ ដកតណ្ហា ព្រមទាំងឫសចេញហើយ ជាអ្នកមានសេចក្ដីត្រជាក់កើតហើយ មានទុក្ខរលត់ហើយ ដូច្នេះ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា ប្រកបដោយគុណទាំងពីរយ៉ាង សេចក្ដីថា ជាអ្នកសម្បូរ គឺប្រកបដោយគុណសម្បត្តិ ២ យ៉ាង គឺជាតិសម្បត្តិ ១ បដិបត្តិសម្បត្តិ ១ ។ ពាក្យថា ស្គាល់ច្បាស់នូវអាត្មាអញថារាហុលដ៏ចម្រើន សេចក្ដីថា សព្រហ្មចារីទាំងឡាយស្គាល់ខ្ញុំថា រាហុលភទ្ទៈ ។ ពិតហើយ ព្រះបាទសុទ្ធោទនមហារាជទ្រង់ជ្រាបថា រាហុលនោះប្រសូតហើយ ទ្រង់កាន់

យកពាក្យដែលព្រះពោធិសត្វត្រាស់ថា **រាហុ** ដែលមានន័យថា **រាហុ ជាតោ** **ពន្ធនំ ជាតំ** អន្ទាក់កើតហើយ ចំណងកើតហើយ ទើបទ្រង់ថ្វាយព្រះនាមថា **រាហុល** ដូច្នេះ ។ ក្នុងសេចក្តីនោះ ព្រះរាហុលត្ថេរ ប្រើអត្ថដែលបិតាត្រាស់ហើយខាងដើមនោះឯង ទើបត្រាស់ថា ស្គាល់ច្បាស់នូវអាត្មាអញថា រាហុលដ៏ចម្រើន ដូច្នេះ ។ ពាក្យថា ដ៏ចម្រើន ជាពាក្យសរសើរនោះឯង ។ ក្នុងកាលតមក ព្រះសាស្តាទ្រង់តាំងលោកក្នុងតំណែងឯតទគ្គៈ ខាងស្រឡាញ់ចំពោះការសិក្សាថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកស្រឡាញ់សិក្ខាដែលជាសាវ័ករបស់តថាគត ស្រេចនឹងរាហុលប្រសើរជាងគេ ដូច្នេះ ។

លោកបានទទួលតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសដល់បុព្វចរិយាអបទាន ទើបត្រាស់ថា **បទុមុត្តរស្ស ភគវតោ** ដូច្នេះជាដើម ។ បទថា **សត្តភូមិម្ហិ បាសាទេ** សេចក្តីថា ឈ្មោះថា **បាសាទ** ព្រោះញ៉ាំងនូវការជ្រះថ្លា គឺញ៉ាំងសោមនស្សឲ្យកើត ។ ៧ ជាន់ ដែលខ្ពស់ឡើងៗ មានក្នុងប្រាសាទណា ប្រាសាទនោះឈ្មោះ **សត្តភូមិ** ( ប្រាសាទ ៧ ជាន់ ) ។ បទថា **អាទាសំ សន្ថរី អហំ** សេចក្តីថា ខ្ញុំបានធ្វើផ្ទៃកញ្ចក់ហើយ បានក្រាលថ្វាយដល់ព្រះមានព្រះភាគ ដែលជាជេដ្ឋបុរសនៃលោក ជាតាទិបុគ្គល អធិប្បាយថា ក្រាលកម្រាលកែវបូជា ។ បទថា **ខីណាសវសហស្សេហិ** សេចក្តីថា ជែរជាស គឺចោមរោមទៅដោយព្រះអរហន្ត ១ ពាន់អង្គ ។ បទថា **ទ្វិបទិន្ទោ** គឺជាកំពូល ជាធំជាងសត្វជើងពីរ ជាអ្នកអង់អាចជាងនរជន

ជាមហាមុនី យានចូលទៅ គឺចូលទៅកាន់ព្រះគន្ធកុដិ មួយអន្លើដោយព្រះ
ទីណាស្រេពទាំងនោះ ។

បទថា **វិរោចេន្តោ គន្ធកុដឹ** សេចក្តីថា ព្រះសាស្តា ជាទេវតាក្រៃលែងជាទេវតា គឺជាទេវតារបស់ទេវតាទាំងឡាយ ដែលអង់អាចជាងនរជន គឺដែលប្រសើរបំផុត ញុំាងព្រះគន្ធកុដិនោះឲ្យភ្លឺ គង់ត្រង់កណ្តាលភិក្ខុសង្ឃ បានត្រាស់គាថាព្យាករទាំងនេះ ។

បទថា **យេនាយំ ជោតិតា សេយ្យា** សេចក្តីថា ទីដេក ពោល គឺប្រាសាទនេះ ដែលឧបាសកណាឲ្យរុងរឿងហើយ គឺឲ្យភ្លឺស្វាង ឲ្យរុងរឿងហើយ អធិប្បាយថា ក្រាលដោយល្អ គឺធ្វើឲ្យស្មើដូចផ្ទៃកញ្ចក់ គឺដូចផ្ទៃកញ្ចក់ដែលសម្រេចដោយលោហសិទ្ធិ អធិប្បាយថា តថាគតនឹងព្យាករឧបាសកនោះ គឺនឹងធ្វើឲ្យប្រាកដ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

បទថា **អដ្ឋានមេតំ យំ តាទិ** សេចក្តីថា ជាអ្នកមិនញាប់ញ័រដោយហេតុណា គឺឈ្មោះថាជាតាទិបុគ្គល ព្រោះជាអ្នកមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ដល់ គឺទៅកាន់សេចក្តីត្រេកអរ គឺជាប់នៅក្នុងផ្ទះ ក្នុងការគ្រប់គ្រងផ្ទះ អធិប្បាយថា សេចក្តីនោះ មិនជាឋានៈ គឺមិនមានហេតុ ។

បទថា **និក្ខមិត្វា អគារស្មា** សេចក្តីថា បុគ្គលនេះនឹងចេញចាកការនៅគ្រប់គ្រងផ្ទះ លះបង់នូវការគ្រប់គ្រងផ្ទះនោះ ដូចលះបង់ស្លឹកស្មៅ ចេញបួស ជាអ្នកមានវត្តល្អ សិក្ខាល្អ ។ បទថា **រាហុលោ នាម នាមេន** សេចក្តីថា ឈ្មោះថា **រាហុល** ព្រោះជាព្រះនាមដែលព្រះសុទ្ធោទនៈជារាជបិតាស្តាប់

ដំណឹង ការប្រសូតិរបស់ព្រះរាជកុមារដែលព្រះបាទសុទ្ធោទនៈបញ្ជូនទៅឲ្យជ្រាប ទើបត្រាស់ថា អន្ទាក់កើតហើយ ចំណងកើតហើយ ។ គប្បីឃើញថា ទ្រង់ត្រាស់ថា អន្ទាក់កើតហើយ ព្រោះមានអត្ថថា ព្រះរាជកុមារនេះកើតមក ដូចធ្វើអន្តរាយចំពោះការចេញបួស និងបព្វជាជាដើមរបស់យើង ដូចរាហុ ស្តេចអសុរ គ្របសង្កត់ គឺបិទបាំងពន្លឺព្រះចន្ទ និងព្រះអាទិត្យធ្វើឲ្យសៅហ្មង ដូច្នោះ ។ បទថា **អរហា សោ ភវិស្សតិ** សេចក្តីថា លោកគឺបុគ្គលបែបនោះ នឹងជាអ្នកសម្បូរដោយឧបនិស្ស័យ ប្រកបការខ្វល់ខ្វាយក្នុងវិបស្សនា ជាព្រះអរហន្តខីណាស្រព ។

បទថា **កិកីវ អណ្ឌំ រក្ខេយ្យ** សេចក្តីថា គប្បីជាអ្នកមិនប្រមាទ រក្សាសីល ដូចសត្វត្រដេវិចរក្សាស៊ុត គឺកូន ដូច្នោះ ។ បទថា **ចាមរី វិយ វាលធឺ** សេចក្តីថា នឹងលះសូម្បីជីវិតមិនទម្លាយសីល រក្សាដូចចាមរីរក្សារោមកន្ទុយ មិនទាញរោមកន្ទុយ គឺកាលរោមកន្ទុយជាប់ត្រង់មែកឈើ ក៏មិនទាញមក ព្រោះខ្លាចដាច់ រមែងលះបង់ជីវិតនោះឯង ។ បញ្ញា លោកហៅថា **និបក** ក្នុងបទថា **និបកោ សីលសម្បន្នោ** នេះ ។ ព្រះមានព្រះភាគ កាលទ្រង់ព្យាករយ៉ាងនេះថា បុគ្គលប្រកបដោយបញ្ញា ជាគ្រឿងរក្សាខ្លួននោះ

*ឈ្មោះថា* **និបក** *ចាត់ជាអ្នកសម្បូរដោយសីល ព្រោះរក្សាមិនឲ្យដាច់ មិនឲ្យបែកធ្លាយជាដើម ។*

*ព្រះថេរៈសម្រេចអរហត្តផលយ៉ាងនេះហើយ ថ្ងៃមួយ អង្គុយក្នុងទីស្ងាត់ពោលពាក្យជាដើមថា ព្រះមហាមុនីទ្រង់ឃើញអាត្មាអញយ៉ាងនេះថា ជាអ្នកមានបញ្ញាជាដើម ដោយអំណាចសោមនស្ស ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។*

## អដ្ឋកថាភាហុលត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឧបសេនវគ្គទី ៤ ពុត្តត្តោកាបទានទី ៧

[ ១៩ ] ខ្ញុំចូលទៅគាល់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រះអង្គជាធ្មេីមក្នុងលោក អង់អាចជាងនរៈ ប្រសេីរជាងនរៈ ដែលទ្រង់គង់នៅក្នុងញកភ្នំ ។ គ្រានោះ ខ្ញុំបានឃេីញផ្កាកណិការរីក ក៏កាច់ផ្កានោះត្រង់ទង យកមកធ្វេីប្រដាប់លេីឆត្រ ហេីយបង្អោនចូលទៅថ្វាយព្រះសម្ពុទ្ធ ។ ទាំងបានថ្វាយចង្ហាន់បិណ្ឌបាតជាភោជនដ៏ល្អឧត្តម ញុំាងសមណៈ ៨ អង្គ គម្រប់ ៩ នឹងព្រះសម្ពុទ្ធ ឲ្យឆាន់ស្កប់ស្កល់ក្នុងទីនោះ ។ ព្រះសយម្ភូមានព្យាយាមធំ ព្រះអង្គប្រសេីរ ទ្រង់អនុមោទនាចំពោះការថ្វាយឆត្រ និងការថ្វាយចង្ហាន់ដ៏ប្រសេីរនេះថា

ដោយចិត្តជ្រះថ្លានោះ បុគ្គលនេះ នឹងបានទទួលសម្បត្តិ គឺនឹងបានគ្រប់គ្រងទេវរាជ្យ ជាធំជាងទេវតា អស់ ៣០ ដង ។ នឹងបានជាស្ដេចចក្កពត្តិ អស់ ២១ ដង នឹងបានគ្រប់គ្រងប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ ព្រះសម្ពុទ្ធទាំងឡាយ ទ្រង់ត្រាស់ហៅបណ្ឌិតណា ជាអ្នកមានប្រាជ្ញាដូចផែនដី មានប្រាជ្ញាល្អ ថាជាអ្នកមានប្រាជ្ញាល្អ បណ្ឌិតនោះ នឹងកេីតក្នុងឱក្កាកត្រកូល ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ បណ្ឌិតនុ៎ះនឹងបានជាព្រះពុទ្ធព្រះនាមគោតម កាលបេីសាសនានៃព្រះគោតម

រុងរឿង បុគ្គល ( អ្នកថ្វាយផ្កា ) នោះ នឹងទៅកាន់អត្តភាព ជាមនុស្ស ឈ្មោះឧបសេនៈ នឹងបានជាសាវ័ក របស់ព្រះសាស្តា ព្រះនាមគោតមនោះ ។

គុណវិសេស ជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ កពទាំង អស់ ខ្ញុំបានដកចោលហើយ ខ្ញុំបានឈ្នះមារ ព្រមទាំងសេនា របស់មារ ហើយទ្រទ្រង់នូវរាងកាយជាទីបំផុត ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបសេនវង្គន្តបុត្តត្ថេរមានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឧបសេនវង្គន្តបុត្តត្ថេរាបទាន ចប់**

**ភាណវារទី ៣ ចប់**

# អដ្ឋកថា

## ឧបសេនវង្គន្តបុត្តត្ថេរាបទាន

[ ១៩ ] *អបទានរបស់ព្រះឧបសេនវង្គន្តបុត្តត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរំ ភគវន្តំ** *ដូច្នេះ ។*

*ព្រះថេរៈរូបនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ចម្រើនវ័យហើយ ទៅកាន់សម្នាក់ព្រះសាស្ដា ស្ដាប់ធម៌ ឃើញព្រះសាស្ដាទ្រង់តាំងភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុដែលនាំសេចក្ដីជ្រះថ្លាមកឲ្យបុគ្គលដោយជុំវិញ ធ្វើកម្មដ៏ធំក្រៃលែងក្នុងព្រះសាស្ដា ហើយប្រាថ្នាតំណែងនោះ បំពេញកុសលជាបជល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់នាងរូបសារីព្រាហ្មណីក្នុងនាលកគាម មានឈ្មោះថា* **ឧបសេន** *។ កុលបុត្តនោះចម្រើនវ័យហើយ រៀនចប់ត្រៃវេទ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា បានទូវសទ្ធាចេញបួស ឧបសម្បទាបានវស្សា ១ គិតថា អញនឹងញុំាងគភ៌ព្រះអរិយៈឲ្យចម្រើន ទើបឲ្យកុលបុត្តម្នាក់បួសក្នុងសម្នាក់របស់ខ្លួន ហើយទៅគាល់ព្រះសាស្ដាជាមួយកុលបុត្តនោះ កាលព្រះសាស្ដាទ្រង់ជ្រាបថា ភិក្ខុនោះ ជាសទ្ធិវិហារិករបស់ព្រះឧបសេន ដែលមិនទាន់មានវស្សាគ្រប់គ្រាន់ ទើបទ្រង់តិះដៀលថា ម្នាលមោឃបុរស ហេតុអ្វី អ្នកវិលមក*

ដើម្បីភាពជាអ្នកមានបរិស័ទឆាប់រហ័ស ទើបគិតថា ឥឡូវនេះ អញត្រូវព្រះសាស្ដាទ្រង់តិះដៀលព្រោះបរិស័ទម្នាក់ ណ្ហើយចុះ អញនឹងអាស្រ័យបរិស័ទនោះឯង ធ្វើឲ្យព្រះសាស្ដាទ្រង់ពេញព្រះហឫទ័យ ដូច្នេះហើយ ទើបបំពេញវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។ លោកជាព្រះអរហន្តសមាទានធុតង្គទាំងអស់ដោយខ្លួនឯងផង ណែនាំអ្នកដទៃ ឲ្យសមាទានធុតង្គធម៌នោះផង ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់តាំងលោកក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុទាំងឡាយដែលនាំសេចក្ដីជ្រះថ្លា មកឲ្យបុគ្គលដោយជុំវិញ ។ ព្រះថេរៈត្រូវភិក្ខុមួយរូប បំណាងចៀសវាងនូវការវិវាទគ្នាសួរថា ឥឡូវនេះ ជម្លោះកើតឡើងហើយ ភិក្ខុសង្ឃ បែកគ្នាជាពីរពួក យើងគប្បីបដិបត្តិដូចម្ដេចហ្ន៎ ទើបសម្ដែងបដិបទាដល់ភិក្ខុនោះ ចាប់ផ្ដើមអំពីការសេពសេនាសនៈស្ងាត់[១] ។ កាលព្រះថេរៈសម្ដែងការៈដែលខ្លួនបដិបត្តិយ៉ាងនោះ ការឲ្យឱវាទដល់ភិក្ខុនោះ ទើបស្មើគ្នានឹងបានព្យាករអរហត្តផលហើយ ។

លោកបានតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួនកាលនឹងប្រកាសប្រវត្តិដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចសោមនស្សទើបពោលពាក្យថា **បទុមុត្តរំ ភគវន្តំ** ដូច្នេះជាដើម ។ បទថា **បព្ភារម្ហិ និសីទន្តំ** សេចក្ដីថា ខ្ញុំចូលទៅគាល់ គឺចូលទៅកាន់ទីជិតព្រះមានព្រះភាគដែលឧត្តមជាងនរជនជាអ្នកប្រាថ្នាវិវេក ប្រថាប់គង់ត្រង់ញកភ្នំដែលលយមកខាងមុខ ជាភ្នំដែលកើតឯងកណ្ដាលព្រៃ ។

---

១- គាថានោះ មានក្នុងខុទ្ទកនិកាយ ថេរគាថា ។

បទថា **កណិការបុប្ផំ ទិស្វា** សេចក្តីថា កាលបុគ្គលនោះចូលទៅជិតដូច្នោះ ឃើញផ្កាកណិការរីកស្គុសស្គាយក្នុងប្រទេសនោះ ។ បទថា **វណ្ដេ ឆេត្វានហំ តទា** សេចក្តីថា ក្តិចផ្កាឈើនោះត្រង់ទង គឺត្រង់ទងឲ្យដាច់ក្នុងវេលាដែលព្រះតថាគតប្រថាប់នៅនោះ ។ ពាក្យថា **អលង្ករិត្វា ឆត្តម្ហិ** សេចក្តីថា ប្រក់ឆត្រដោយផ្កានោះ ។ បទថា **ពុទ្ធស្ស អភិរោបយឹ** សេចក្តីថា បានលើកឡើងបាំងអំពីខាងលើព្រះសិរសារបស់ព្រះពុទ្ធដែលគង់នៅ ។

បទថា **បិណ្ឌបាតញ្ច ទាទាសឹ** សេចក្តីថា បានថ្វាយបិណ្ឌបាតដល់ព្រះមានព្រះភាគដែលគង់នៅក្នុងទីនោះឯង ឲ្យសោយដោយប្រការទូទៅ ។ បទថា **បរមន្នំ សុភោជនំ** សេចក្តីថា ជាបាយផ្សំយ៉ាងល្អ គឺជាអាហារដ៏ឧត្តម ពោល គឺភោជនយ៉ាងល្អ ។ បទថា **ពុទ្ធេន នវមេ តត្ថ** សេចក្តីថា ខ្ញុំបាននិមន្តព្រះសមណៈដែលជាអ្នកបន្សាត់បាប បានដល់ ភិក្ខុដែលជាខីណាស្រព ៨ រូប មួយអន្លើដោយព្រះពុទ្ធជាគម្រប់ ៩ ឲ្យឆាន់ក្នុងទីស្ងាត់នោះ ។

បទថា **យំ វទន្តិ សុមេធោ** សេចក្តីថា បណ្ឌិតទាំងឡាយ ហៅនូវព្រះសម្មាសម្ពុទ្ធដែលជាគោតម អ្នកមានបញ្ញាដូចផែនដី គឺជាអ្នកមានបញ្ញាស្មើដោយផែនដី ជាអ្នកមានបញ្ញាល្អ ជាអ្នកមានសព្វញ្ញុតញ្ញាណជាដើម ព្រះអង្គណាអ្នកមានបញ្ញាល្អ មានបញ្ញាស្អាត ភ្ជាប់សេចក្តីថា បុគ្គលនេះ នឹងជាព្រះសម្មាសម្ពុទ្ធ ព្រះនាមគោតម ក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាឧបសេនវង្គន្តបុត្តត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## រដ្ឋបាលត្ថេរាបទានទី ៨

[ ២០ ] ខ្ញុំបានថ្វាយដំរីដ៏ប្រសើរ មានភ្លុក-ងដូចចន្ទោល មានភ្លៅដ៏មាំមួន ដល់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាធ្មេីមក្នុងលោក ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ។ ដំរីនោះ មានស្វេតច្ឆត្រសម្រាប់ប្រដាប់ មានពេទ្យសម្រាប់ព្យាបាល មានបុរសសម្រាប់រក្សា ខ្ញុំកាត់ថ្លៃរបស់ទាំងអស់នោះ ( លក់ចំណាយ ) ធ្វើអារាមរបស់សង្ឃ ។ ខ្ញុំបានធ្វើប្រាសាទអស់ប្រាក់ ៥៤ ពាន់ ធ្វើទានដូចជាទឹកជំនន់ដ៏ធំ ហើយវេរថ្វាយព្រះមហេសី ។ ព្រះសយម្ភូមានព្យាយាមធំ ជាបុគ្គលប្រសើរ ទ្រង់អនុមោទនា ញុំាងជនទាំងពួងឲ្យរីករាយ សម្តែងនូវអមតនិព្វាន ។ ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ គង់ក្នុងភិក្ខុសង្ឃ ទ្រង់ព្យាករទានរបស់ខ្ញុំនោះ ហើយសម្តែងគាថាទាំងឡាយនេះថា

កុលបុត្តនេះ បានធ្វើប្រាសាទអស់ប្រាក់ ៥៤ ពាន់ ( ថ្វាយតថាគត ) តថាគតនឹងសម្តែងនូវផលនៃទាន ( របស់កុលបុត្តនុ៎ះ ) អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ ផ្ទះមានកំពូលចំនួន ១៨ ពាន់ នឹងកើតឡើងសម្រាប់កុលបុត្តនេះ ផ្ទះមានកំពូលទាំងនោះ សុទ្ធតែជាវិការនៃមាសទាំងអស់ កើតឡើងក្នុងវិមានដ៏ឧត្តម ។ កុលបុត្តនេះ នឹងបានសោយទេវរាជ្យ ជាធំជាង

ទេវតាអស់ ៥០ ជង នឹងបានជាស្តេចចក្កពត្តិអស់ ៥៨ ជង ។ ក្នុងកប្បទីមួយសែន ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ ខណៈនោះ កុលបុត្តនេះ នឹងច្យុតចាកទេវលោក ត្រូវកុសលមូលជាស់តឿន នឹងកើតក្នុងត្រកូលស្តុកស្តម្ភ មានភោគៈច្រើន ។ កុលបុត្តនោះ ឈ្មោះរដ្ឋបាល លុះកាលជាខាងក្រោយមក ក៏ចេញបួស ត្រូវកុសលមូលជាស់តឿន នឹងបានជាសាវកនៃព្រះសាស្តា ព្រះនាមគោតមនោះ ។ កុលបុត្តនោះឯង មានចិត្តបញ្ជូនទៅកាន់ព្យាយាម ជាអ្នកមានចិត្តស្ងប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំក្រោកទៅសាងផ្នួស លះបោលភោគសម្បត្តិ ខ្ញុំមិនមានសេចក្តីស្រឡាញ់ភោគសម្ប័ទ ទុកដូចជាដុំទឹកមាត់ ។ សេចក្តីព្យាយាមរបស់ខ្ញុំ គួរនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ឥឡូវនេះ ខ្ញុំទ្រទ្រង់រាងកាយ ដែលជាទីបំផុតក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះរដ្ឋបាលត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## វដ្ឋបាលត្ថេរាបទាន

[ ២០ ] *អបទានរបស់ព្រះវដ្ឋបាលត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ មុនព្រះមានព្រះភាគព្រះនាមបទុមុត្តរៈកើតឡើង កុលបុត្តនេះ កើតក្នុងត្រកូលគហបតិមហាសាល ក្នុងហង្សវតីនគរ ចម្រើនវ័យហើយ កាលបិតាអនិច្ចកម្មទៅ កុលបុត្តនេះ នៅគ្រប់គ្រងផ្ទះ ឃើញទ្រព្យសម្បត្តិ ប្រមាណមិនបាន ដែលធ្លាក់មកតាមលំដាប់វង្សត្រកូល ដែលនាយឃ្លាំង ប្រាប់ឲ្យជ្រាបហើយ គិតថា បិយជន មានបិតា ជីតា ជីតាទួតជាដើមរបស់ អាត្មាអញ មិនអាចនាំយកគំនរទ្រព្យ មានប្រមាណប៉ុណ្ណេះ ទៅតាមខ្លួនបាន តែអញគួរនាំយកទៅ ដូច្នេះហើយ បានឲ្យមហាទានដល់មនុស្សកំព្រា និង អ្នកដំណើរជាដើម ។ កុលបុត្តនោះ ចូលទៅរកតាបសមួយរូប ដែលជាអ្នក បាននូវអភិញ្ញា ត្រូវតាបសទូន្មានក្នុងភាពជាធំក្នុងទេវលោក ទើបបំពេញ បុណ្យដរាបដល់អស់ជីវិត ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសម្បត្តិ តាំងនៅក្នុងទេវលោកដរាបដល់អស់អាយុ ចុតិអំពីទេវលោកនោះហើយ មកកើតក្នុងមនុស្សលោក ជាបុត្តទោល ក្នុងត្រកូលដែល អាចបង្រួបបង្រួមរដ្ឋដែលបែកគ្នា ។ សម័យនោះ ព្រះមានព្រះភាគព្រះនាម*

បទុមុត្តរៈ កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ ញ៉ាំងសព្វសត្វឲ្យដល់នូវភូមិដែលជាដែនក្សេម ពោល គឺនិព្វានមហានគរ ។ លំដាប់នោះ កុលបុត្តនោះ ដល់នូវភាពជាអ្នកដឹងក្តីដោយលំដាប់ ថ្ងៃមួយ ទៅកាន់វិហារជាមួយឧបាសកទាំងឡាយ ឃើញព្រះសាស្តាទ្រង់សម្តែងធម៌ មានចិត្តជ្រះថ្លា ទើបអង្គុយខាងចុងបរិស័ទ ។

សម័យនោះឯង ព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងដ៏ប្រសើរ ជាងបព្វជិតដែលបួសដោយសទ្ធា ។ កុលបុត្តនោះឃើញដូច្នោះ មានចិត្តជ្រះថ្លា ថ្វាយមហាទានដល់ព្រះមានព្រះភាគ ដែលចោមរោមទៅដោយភិក្ខុ ១ សែនរូប អស់ ៧ ថ្ងៃ ហើយប្រាថ្នាតំណែងនោះ ។ ព្រះសាស្តាទ្រង់ឃើញសេចក្តីប្រាថ្នា នឹងសម្រេចដោយមិនមានអន្តរាយ ទើបទ្រង់ព្យាករថា កុលបុត្តនេះ នឹងបានជាកំពូលជាងភិក្ខុអ្នកបួសដោយសទ្ធា ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធព្រះនាមគោតម ក្នុងអនាគត ។ កុលបុត្តនោះ ថ្វាយបង្គំព្រះសាស្តា និងភិក្ខុសង្ឃហើយ ក្រោកចាកអាសនៈ ចៀសចេញទៅ ។ កុលបុត្តនោះ បំពេញបុណ្យដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ ក្នុងកាលនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមផុស្សៈ កាលរាជបុត្តទាំង ៣ អង្គ មាតាដទៃរបស់ព្រះសាស្តា ឧបដ្ឋាកព្រះសាស្តាបានជាសម្លាញ់ ជួយខ្នះខ្នែងក្នុងបុញ្ញកិរិយារបស់រាជបុត្តទាំងនោះ កុលបុត្តនោះ សន្សំកុសលជាច្រើនក្នុងភពនោះៗ ដោយអាការយ៉ាងនេះ អន្ទោលទៅក្នុង

សុគតិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះរដ្ឋបាលសេដ្ឋី ក្នុងថុល្ល-កោដ្ឋិកនិគម ក្នុងកុរុរដ្ឋ មានឈ្មោះតាមវង្សត្រកូលនោះឯងថា រដ្ឋបាល ព្រោះកើតក្នុងត្រកូល ដែលអាចបង្រួបបង្រួមរដ្ឋដែលបែកគ្នាបាន កុលបុត្ត នោះចម្រើនដោយបរិវារជាច្រើន ដល់នូវភាពជាអ្នកដឹងក្តីដោយលំដាប់ មាតាបិតារៀបចំកិរិយាដែលសមគួរ ឲ្យតាំងនៅក្នុងយសធំ សោយសម្បត្តិដូចជាទិព្វ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ចារិកទៅក្នុងជនបទ ក្នុងកុរុរដ្ឋ ដល់ថុល្លកោដ្ឋិកនិគម ។ រដ្ឋបាលកុលបុត្តបានស្តាប់ដូច្នោះហើយ ចូលទៅគាល់ព្រះសាស្តា ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាហើយ បាននូវសទ្ធា បំណងនឹងបួស ធ្វើការអត់អាហារ ៧ ថ្ងៃ ឲ្យមាតាបិតាអនុញ្ញាតដ៏លំបាក ហើយចូលទៅគាល់ព្រះសាស្តា សូមបព្វជ្ជា បួសក្នុងសម្នាក់របស់ភិក្ខុមួយរូប តាមព្រះតម្រាស់របស់ព្រះសាស្តា ចម្រើនកម្មដ្ឋានដោយយោនិសោមនសិការ ចម្រើនវិបស្សនារហូតបានសម្រេចអរហត្ត ។

កាលសម្រេចអរហត្តហើយ ទូលសូមអនុញ្ញាតអំពីព្រះសាស្តា ទៅកាន់ថុល្លកោដ្ឋិកនិគម ដើម្បីសួរសុខទុក្ខមាតាបិតា ត្រាច់បិណ្ឌបាតតាមលំដាប់ប្រកក្នុងនិគមនោះ បានទំកុម្មាសដែលទុកកន្លងរាត្រីក្នុងនិវេសន៍របស់បិតា ឆាន់ទំកុម្មាសនោះ ដូចឆាន់អមតភោជន ត្រូវបិតានិមន្ត ទើបទទួលនិមន្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ក្នុងថ្ងៃទី ២ ឆាន់បិណ្ឌបាតក្នុងនិវេសន៍របស់បិតា កាលស្រីក្នុងផ្ទះ ( ភរិយាចាស់ ) ប្រដាប់តាក់តែងហើយ ចូលទៅរកពោល

ពាក្យថា បពិត្រអយ្យបុត្ត ស្រីទេពអប្សរដែលធ្វើឲ្យលោកប្រព្រឹត្តព្រហ្មចរិយៈដូចម្តេចជាដើម ហើយផ្តើមធ្វើការលួងលោម ទើបផ្លាស់ប្តូរបំណងរបស់នាង សម្តែងធម៌ដែលទាក់ទងនឹងអនិច្ចលក្ខណៈជាដើម ទើបពោលគាថាទាំងនេះ ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

អ្នកចូរមើលនូវអត្តភាព ដែលធ្វើឲ្យវិចិត្រ ជាទីប្រជុំនៃដំបៅ ដែលតាំងឡើងព្រមហើយ ( ដោយឆ្អឹង ៣០០ កំណាត់ ) ជាអត្តភាពក្តៅក្រហាយ ដែលជនពាលត្រិះរិះដោយច្រើន ជាអត្តភាពមិនទៀងទាត់ ស្ថិតស្ថេរ ។ អ្នកចូរមើលនូវរូប ដែលធ្វើឲ្យវិចិត្រដោយកែវមណី និងកុណ្ឌល ដែលឆ្អឹង និងស្បែករួបរឹតហើយ ( រូបនោះ ) រមែងល្អដោយសារសំពត់ទាំងឡាយ ។ ជើងទាំងឡាយ លាបដោយល័ក្តស្រស់ មុខ លាបដោយគ្រឿងលម្អិត អាចញុំាងជនពាលឲ្យវង្វេង តែមិនអាចញុំាងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានទេ ។ សក់ទាំងឡាយ ដែលគេរចនា ដូចជាក្រឡាចតុរង្គ ភ្នែកទាំងឡាយ លាបដោយថ្នាំសម្រាប់បន្តក់ភ្នែក អាចញុំាងជនពាលឲ្យវង្វេង តែមិនអាចញុំាងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានឡើយ ។ កាយស្អុយដែលគេតាក់តែងហើយ ដូចជានាឡិសម្រាប់ដាក់ថ្នាំបន្តក់ ដែលគេវិចិត្រហើយថ្មីៗ អាចញុំាងជនពាលឲ្យវង្វេង តែមិនអាចញុំាងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេង

បានឡើយ ។ ព្រានម្រឹគដាក់នូវអន្ទាក់ ម្រឹគក៏មិនបានប៉ះពាល់នូវអន្ទាក់ ហើយស៊ីនូវចំណី កាលដែលព្រានម្រឹគកំពុងកន្ទក់កន្ទេញ ( ក៏បោលចេញទៅយ៉ាងណាមិញ ) ពួកយើង ក៏ដើរចេញទៅ ( យ៉ាងនោះដែរ ) ។ អន្ទាក់របស់ព្រានម្រឹគដាច់ហើយ ម្រឹគក៏មិនប៉ះពាល់នូវអន្ទាក់ ហើយស៊ីនូវចំណី កាលព្រានម្រឹគកំពុងសោកស្ដាយ ( ក៏បោលចេញទៅយ៉ាងណាមិញ ) ពួកយើង ក៏ដើរចេញទៅ ( យ៉ាងនោះដែរ ) ដូច្នេះ ។

ព្រះថេរៈពោលគាថាទាំងនេះហើយ ហោះទៅកាន់នភាល័យ អង្គុយត្រង់ផ្ទាំងថ្មដែលជាមង្គល ក្នុងមិគាជិនវនឧទ្យានរបស់ព្រះបាទកោរព្យៈ ។ បានឮថា បិតារបស់ព្រះថេរៈ បានឲ្យគេខ្ទាស់គន្លឹះត្រង់ខ្លោងទ្វារទាំង ៧ ជាន់ រៀបចំអ្នកប្រដាល់ទាំងឡាយថា ពួកអ្នកកុំឲ្យកូនរបស់យើងចេញទៅ ចូរដោះសំពត់កាសាវៈ ហើយឲ្យស្លៀកសំពត់ស ។ ព្រោះហេតុនោះ ទើបព្រះថេរៈទៅតាមអាកាស ។ លំដាប់នោះ ព្រះបាទកោរព្យៈជ្រាបថា ព្រះថេរៈអង្គុយក្នុងទីនោះ ទើបយាងទៅរក កាលចប់សមោទនីយកថា និងសារាណីយកថាហើយ ត្រាស់សួរថា បពិត្រលោកម្ចាស់រដ្ឋបាល បុគ្គលបួសក្នុងលោកនេះជួបនូវការវិនាសព្រោះលោកខ្វះ ការវិនាសព្រោះជរាខ្វះ ការវិនាសចាកភោគៈខ្វះ និងការវិនាសញាតិខ្វះ ទើបបួស តែលោកម្ចាស់ មិនដល់នូវការវិនាសណាមួយ ហេតុអ្វីទើបបួស ។ លំដាប់នោះ ព្រះថេរៈបានសម្ដែងការៈដែលខ្លួនជ្រាបដល់ធម្មុទ្ទេស ៤ ដល់ព្រះរាជា គឺលោកត្រូវជរានាំចូលទៅ

ជិតមច្ចុ មិនស្ថិតស្ថេរ លោកមិនមានទីជ្រកកោន មិនជាធំចំពោះខ្លួន លោកមិនមានទីពឹង ត្រូវលះវត្ថុទាំងពួងហើយទៅ លោកខ្វះខាតជានិច្ច មិនឆ្អែតជាខ្ញុំនៃតណ្ហា កាលពោលតាមគន្លងទេសនានោះ ទើបពោលគាថាទាំងនេះ ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

អាត្មា បានឃើញនូវមនុស្សទាំងឡាយ បរិបូណ៌ដោយទ្រព្យសម្បត្តិក្នុងលោក ( ពួកមនុស្សទាំងនោះ ) លុះបានទ្រព្យគាប់ចិត្តហើយ មិនឲ្យ ( ដល់បុគ្គលណាមួយឡើយ ) ព្រោះតែសេចក្តីវង្វេង ។ ពួកមនុស្សបានទ្រព្យហើយ ក៏ធ្វើនូវការសន្សំទុក ទាំងប្រាថ្នាក្នុងកាមដ៏លើសលុប ។ ព្រះរាជាឈ្នះនូវផែនដីដែលព្រះអង្គរឹបជាន់បានហើយ នៅគ្រប់គ្រងផែនដី មានសាគរជាទីបំផុត មានសភាពមិនឆ្អែត នឹងត្រើយសមុទ្រខាងអាយ ក៏ប្រាថ្នានូវត្រើយសមុទ្រខាងនាយ ។ ព្រះរាជាក្តី ពួកមនុស្សដទៃច្រើននាក់ក្តី មិនទាន់ប្រាសចាកតណ្ហា រមែងដល់នូវសេចក្តីស្លាប់ គឺថា ជាអ្នកមានសេចក្តីខ្វះខាត លះបង់រាងកាយ ព្រោះថាសេចក្តីឆ្អែតដោយកាមទាំងឡាយ ក្នុងលោកមិនមាន ។ ពួកញាតិរំសាយសក់កន្ទក់កន្ទេញ ចំពោះបុគ្គលដែលស្លាប់ហើយនោះ ទាំងបាននិយាយថា ធ្វើម្តេចហ្ន៎ ញាតិរបស់យើងទាំងឡាយ កុំស្លាប់វិញ ក៏នាំខ្មោចនោះដែលរុំដោយសំពត់ ទៅកាន់ជើងថ្ករ ប្រជុំគ្នាដុតក្នុងទីនោះ ។ បុគ្គលដែលស្លាប់នោះ ត្រូវពួកអ្នកដុត

ចាក់ដោយឈើស្រួចជុត បុគ្គលនោះ លះបង់នូវភោគៈទាំងឡាយ មានតែសំពត់មួយស្លាប់ទៅ ញាតិទាំងឡាយក្តី មិត្រទាំងឡាយក្តី ឬសម្លាញ់ទាំងឡាយក្តី ជាទីពឹងមិនមានទេ ។ ពួកទាយាទ ( អ្នកត្រូវទទួលមត៌ក ) រមែងនាំទៅនូវទ្រព្យរបស់សត្វដែលស្លាប់នោះ ចំណែកសត្វដែលស្លាប់នោះ ក៏ទៅតាមយថាកម្ម ទ្រព្យតិចតួច កូន ប្រពន្ធ មាស ប្រាក់ និងដែន ក៏មិនមែនជាប់តាមសត្វដែលស្លាប់នោះទេ ។ បុគ្គលមិនមែនបាននូវអាយុវែង ដោយសារទ្រព្យទេ ទាំងមិនមែនកម្ចាត់បង់នូវជរា ដោយសារទ្រព្យបានទេ ព្រោះថា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវជីវិតនោះថា តិចមិនទៀង មានការប្រែប្រួលទៅជាធម្មតា ។ ជនទាំងឡាយ អ្នកស្តុកស្តម្ភ និងអ្នកទាល់ក្រ រមែងប៉ះពាល់នូវផស្សៈ ( មិនជាទីប្រាថ្នា ) បុគ្គលពាល និងអ្នកប្រាជ្ញ រមែងប៉ះពាល់ដូចគ្នា ប៉ុន្តែបុគ្គលពាល បើមានសេចក្តីទុក្ខបៀតបៀនហើយ រមែងដេក ( សោកស្តាយ ) ព្រោះភាវៈនៃខ្លួនពាល ឯអ្នកប្រាជ្ញ បើទុកជាប៉ះពាល់នូវផស្សៈ ក៏មិនបានញាប់ញ័រ ។ ព្រោះហេតុនោះ បុគ្គលបាននូវព្រះនិព្វាន ជាទីបំផុតនៃភពក្នុងលោកនេះ ដោយបញ្ញាណា បញ្ញានោះ ជាធម្មជាតប្រសើរជាងទ្រព្យ ដ្បិតបុគ្គលទាំងឡាយ មិនទាន់បានសម្រេចប្រយោជន៍ រមែងធ្វើនូវបាបកម្មទាំងឡាយ ក្នុងភពតូច និងភពធំ ព្រោះតែមោហៈ ។ បុគ្គលណា

( បានធ្វើបាបកម្ម ) ក៏ដល់នូវការអន្ទោលទៅមក រមែងចូលទៅកាន់គតិ និងបរលោក បុគ្គលអ្នកអប្បប្រាជ្ញា ( ឯទៀត ) កាលបើជឿបុគ្គលអ្នកធ្វើបាបកម្មនោះ ក៏ទៅកាន់គតិ និងបរ-លោក ។ ចោរអ្នកមានធម៌ដ៏លាមក ដែលគេចាប់បានត្រង់មុខតំណ ( នៃផ្ទះ ) រមែងក្តៅក្រហាយ ដោយកម្មរបស់ខ្លួន យ៉ាងណាមិញ សត្វអ្នកមានធម៌ដ៏លាមក លុះស្លាប់ទៅ រមែងក្តៅក្រហាយ ក្នុងលោកខាងមុខ ដោយកម្មរបស់ខ្លួន ក៏យ៉ាងនោះដែរ ។ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីរីករាយនៃចិត្តតែងញាំញីចិត្តដោយសភាពផ្សេងៗ បពិត្រមហារាជ ហេតុនោះអាត្មាភាព ឃើញទោសក្នុងកាមគុណទាំងឡាយ ទើបចេញទៅបួស ។ សត្វទាំងឡាយ ទោះក្មេងក្តី ចាស់ក្តី តែងបែកធ្លាយនូវសរីរៈ ដូចជាផ្លែឈើជ្រុះ ( ចាកដើម ) បពិត្រមហារាជ អាត្មាភាព បានឃើញនូវរបស់មិនទៀងនេះឯង បានជាចេញបួស ភាពជាសមណៈ មិនស្ងួវខុសក្លាត់ ជារបស់ប្រសើរលើសលុប ។

អាត្មាភាពបួសដោយសទ្ធា បានប្រកបសេចក្តីប្រតិបត្តិក្នុងសាសនានៃព្រះជិនស្រី បព្វជ្ជារបស់អាត្មាភាព មិនមានទោស អាត្មាភាព បរិភោគភោជន មិនមានបំណុលទេ ។ អាត្មាភាព ឃើញនូវកាមទាំងឡាយ ហាក់ដូចជាភ្លើងឆេះសព្វហើយ ឃើញនូវជាតរូប ហាក់ដូចជាគ្រឿងសស្រ្តាវុធ ឃើញហេតុនាំមកនូវទុក្ខ

តាំងតែអំពីការចុះចាប់បដិសន្ធិក្នុងគភ៌ ឃើញនូវភ័យធំ ក្នុងនរកទាំងឡាយ ។ អាត្មាភាព ឃើញនូវទោសនេះឯង ក៏បាននូវសេចក្ដីសំវេគ ក្នុងកាលនោះ អាត្មាភាពហ្នឹងឯង ជាអ្នកត្រូវសរមុតហើយ ក្នុងកាលនោះ ( ឥឡូវនេះ ) បានដល់ហើយនូវការអស់ទៅនៃអាសវៈ ។ ព្រះសាស្ដា អាត្មាភាពបានបម្រើហើយ ព្រះពុទ្ធសាសនា អាត្មាភាពក៏បានធ្វើហើយ ភារៈដ៏ធ្ងន់អាត្មាភាពបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពអាត្មាភាព បានដកចោលហើយ ។ កុលបុត្រគបានចេញចាកផ្ទះចូលមកកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំងពួង អាត្មាភាពបានដល់ហើយ ដូច្នេះ ។

ព្រះថេរៈសម្ដែងធម៌ដល់ព្រះបាទកោរព្យៈយ៉ាងនេះហើយ ទើបចូលទៅកាន់សម្នាក់ព្រះសាស្ដានោះឯង កាលខាងក្រោយ ព្រះមានព្រះភាគ គង់កណ្ដាលពួកព្រះអរិយៈ ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈ នៃភិក្ខុអ្នកបួសដោយសទ្ធា ។

ព្រះថេរៈនោះ បានទទួលតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្ម កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរស្ស ភគវតោ** ដូច្នេះជាដើម ។ បទថា **វរណាគោ មយា ទិន្នោ** សេចក្ដីថា ខ្ញុំជ្រះថ្លាក្នុងរូបកាយនៃព្រះមានព្រះភាគអង្គនោះ បានថ្វាយដំរីដ៏ប្រសើរឧត្តមថ្លៃថ្លា មានភ្លុកងទន្ទាំដូចចន្ទោល

នង្គ័ល និងចន្ទោលរថ ជាសត្វរឹងប៉ឹង គួរជារាជពាហនៈ ។ បទថា **សេតច្ឆត្តោ-បសោភិតោ** សេចក្តីថា ប៉ាំងដោយឆត្រពណ៌ស លើកឡើងលើ-កដំរី ជាដំរីដែលប្រដាប់ស្អាតហើយ ។ ដំរីដ៏ប្រសើរពិសេសអ្វីទៀត មួយអន្ទើដោយគ្រឿងប្រដាប់ គឺមួយអន្ទើដោយគ្រឿងអលង្ការដំរី ។ ខ្ញុំបានសាងសង្ឃារាមធ្វើវិហារដែលគួរត្រេកអរ ដើម្បីជាលំនៅរបស់ភិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ។

បទថា **ចតុបញ្ញាសសហស្សានិ** សេចក្តីថា កាលធ្វើវិហារនោះស្រេចហើយ ខ្ញុំបានធ្វើប្រាសាទ ៥ ម៉ឺន ៤ ពាន់ ក្នុងចន្លោះវិហារនោះ ។ បទថា **មហោឃទានំ ករិត្វាន** សេចក្តីថា ខ្ញុំបានចាត់ចែងមហាទានដែលប្រកបដោយសព្វបរិក្ខារ ដែលដូចគ្នានឹងជំនន់ទឹកធំ ហើយប្រគល់ថ្វាយដល់ព្រះមុនី ជាអ្នកស្វែងរកគុណធំ ។

បទថា **អនុមោទិ មហាវីរោ** សេចក្តីថា ឈ្មោះថា **មហាវីរ** ព្រោះសេចក្តីព្យាយាម ពោល គឺភាពឧស្សាហ៍ដែលមិនដាច់ខ្សែក្នុង ៤ អសង្ខេយ្យ និង ១ សែនកប្ប ជាព្រះសយម្ភូ គឺជាអ្នកត្រាស់ដឹងឯង បាននូវសព្វញ្ញុ-តញ្ញាណ ជាអគ្គបុគ្គល គឺបុគ្គលដ៏ប្រសើរ បានអនុមោទនា គឺទ្រង់ធ្វើអនុ-មោទនាវិហារទាន ។ បទថា **សព្វេ ជនេ ហាសយន្តោ** សេចក្តីថា ទ្រង់ធ្វើទេវតា និងមនុស្សរាប់មិនអស់ ក្នុងចក្កវាឡទាំងមូលឲ្យត្រេកអរហើយ ទ្រង់សម្តែង ប្រកាស បើកផ្សារ ធ្វើឲ្យរាក់ នូវព្រះធម្មទេសនា គឺអរិយសច្ច ៤ ដែលប្រកបដោយអមតនិព្វាន ។

បទថា **តំ មេ វិយាកាសិ** សេចក្តីថា ទ្រង់បានធ្វើនូវភាពជាបុគ្គលកតញ្ញូរបស់ខ្ញុំនោះឲ្យមានកម្លាំង គឺឲ្យប្រាកដជាពិសេស ។ បទថា **ជលជុត្តមនាមកោ** បានដល់ វត្ថុដែលកើតក្នុងទឹក ឈ្មោះថា **ជលជ** បានដល់ ផ្កាឈូក មានព្រះនាមថា **បទុមុត្តរ** ។ បាលីថា **ជលនុត្តមនាយកោ** ដូច្នេះក៏មាន ក្នុងបទនោះ ដែលឈ្មោះថា **ជលន** ព្រោះរុងរឿងដោយរស្មីរបស់ខ្លួន ។ បានដល់ ចន្ទទេវបុត្ត សុរិយទេវបុត្ត ទេវតា និងព្រហ្ម ។ ឈ្មោះថា **ជលនុត្តម** ព្រោះជាបុគ្គលឧត្តមជាងបុគ្គលដែលរុងរឿងទាំងនោះ ។ ឈ្មោះថា **នាយកោ** ព្រោះជានាយក ដ៏ឧត្តមជាងសត្វទាំងពួង ម្យ៉ាងទៀត ឈ្មោះថា **នាយកោ** ព្រោះនាំទៅ គឺញ៉ាំងសព្វសត្វដែលមានការៈ ឲ្យដល់នូវព្រះនិព្វាន ។ ព្រះអង្គជាបុគ្គលឧត្តមជាងបុគ្គលដែលរុងរឿងផង ទ្រង់ជាអ្នកនាំផង ព្រោះហេតុនោះ ទើបឈ្មោះថា **ជលនុត្តមនាយកោ** ។ បទថា **ភិក្ខុសង្ឃេ និសីទិត្វា** សេចក្តីថា គង់ត្រង់កណ្តាលនៃភិក្ខុសង្ឃ ហើយបានត្រាស់គាថាទាំងនេះ គឺទ្រង់សម្តែងធ្វើឲ្យប្រាកដ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

**អដ្ឋកថារដ្ឋបាលត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សោចាការត្ថាបទានទី ៩

[ ២១ ] កាលខ្ញុំកំពុងតែសម្អាតញកជិតភ្នំ ដ៏ឧត្តមប្រសើរ ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទ្រង់ស្តេចមកកាន់សម្នាក់ខ្ញុំ ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធស្តេចមកដល់ ក៏ក្រាលកម្រាល ហើយបូជាអាសនៈ ជាវិការនៃផ្កា ចំពោះព្រះសម្ពុទ្ធ ជាលោកជេដ្ឋ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ។ ព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ គង់លើបុប្ផសនៈ ហើយជ្រាបគតិរបស់ខ្ញុំ ទើបទ្រង់បន្លឺឡើងនូវអនិច្ចតាធម៌ថា សង្ខារទាំងឡាយ មិនទៀងទាត់ពិត មានការកើតឡើង និងការសូន្យទៅវិញជាធម្មតា លុះកើតឡើងហើយរមែងរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងឡាយនោះបាន ទើបនាំមកនូវសេចក្តីសុខ ។ ព្រះសព្វញ្ញុពុទ្ធ ព្រះអង្គជាធ្មើមក្នុងលោក ជានរាសភៈ ជាអ្នកប្រាជ្ញ លុះទ្រង់សម្តែងអនិច្ចតាធម៌នេះចប់ហើយ ទើបស្តេចហោះឡើងទៅឰដ៏អាកាស ដូចស្តេចហង្សកាលហើរទៅឰដ៏អាកាស ។ ខ្ញុំបានលះបង់នូវទិដ្ឋិរបស់ខ្លួន ហើយចម្រើននូវអនិច្ចសញ្ញា ខ្ញុំក៏បានចម្រើនអស់ ១ ថ្ងៃ ហើយធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំសោយសម្បត្តិទាំងពីរ ត្រូវកុសលមូលដាស់តឿន ក៏បានដល់នូវបច្ឆិមភព ខ្ញុំចូលទៅកាន់កំណើតប្រកបដោយផល ។ ខ្ញុំមានអាយុ ៧ ឆ្នាំ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស បានដល់អរហត្តផល ។ ខ្ញុំមានព្យាយាមតឹងរ៉ឹងណាស់

មានចិត្តបញ្ជូនទៅកាន់សមាធិ មានចិត្តតម្កល់ខ្ជាប់ល្អក្នុងសីល ញុំាងព្រះពុទ្ធជាមហានាគ ឲ្យប្រោសប្រាណ ហើយបានឧបសម្បទា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្កា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានចម្រើននូវអនិច្ចសញ្ញា ក្នុងកាលនោះ ការអស់អាសវៈ ក៏បានសម្រេចដល់ខ្ញុំ ដែលចម្រើនសញ្ញានោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោបាកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សោបាកត្ថេរាបទាន[១] ចប់

---

១- ព្រះសោបាកត្ថេរ ក្នុងអដ្ឋកថាថេរគាថា មាន ២ អង្គ មួយអង្គម្តាយស្លាប់ក្នុងព្រៃខ្មោច ក្នុងអតីត លោកបានប្រគេនផ្លែក្រូចព្រៃដល់ព្រះមានព្រះភាគកកុសន្ធៈ និងបានប្រគេនកត្តលាយទឹកដោះដល់ព្រះបច្ចេកពុទ្ធ ។ មួយអង្គទៀត កើតក្នុងត្រកូលចុងភៅ ម្តាយមិនស្លាប់ ក្នុងអតីត បានបូជាអាសនៈជាវិការនៃផ្កា ចំពោះព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ដូច្នេះ អបទាននេះ ជាអបទានរបស់ព្រះសោបាកត្ថេរ ដែលកើតក្នុងត្រកូលចុងភៅទេ តែក្នុងទីនេះលោកថា ជាអបទានរបស់ព្រះសោបាកត្ថេរ ដែលមានម្តាយស្លាប់ទៅវិញ បណ្ឌិតគប្បីពិចារណា ។

# អដ្ឋកថា

## សោបាកត្ថេរាបទាន

[ ២១ ] *អបទានរបស់ព្រះសោបាកត្ថេរ មានពាក្យផ្ដើមថា* **បព្ភារំ សោធយន្តស្ស** *ដូច្នេះ ។*

*ព្រះថេរៈសោបាកៈនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ[១] កើតជាបុត្តកុដុម្ពិកៈម្នាក់ ថ្ងៃមួយ ឃើញព្រះសាស្ដាហើយ បានបង្អោនផ្លែក្រូចព្រៃចូលទៅថ្វាយព្រះសាស្ដា ។ ព្រះសាស្ដា ទ្រង់សោយជាការអនុគ្រោះដល់កុលបុត្តនោះ ។ កុលបុត្តនោះ ជ្រះថ្លាក្រៃលែងក្នុងព្រះសាស្ដានិងក្នុងភិក្ខុសង្ឃ ផ្ដើមតាំងសាលាកកត្ត បានថ្វាយកត្តដែលលាយដោយទឹកដោះដល់ភិក្ខុ ៣ អង្គ ដែលចាត់មកអំពីសង្ឃ ដរាបដល់អស់ជីវិត ។ ដោយបុណ្យទាំងនោះ កុលបុត្តនោះ សោយសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ ឆ្លាស់គ្នាទៅ សម័យមួយ កើតក្នុងកំណើតមនុស្ស បានថ្វាយកត្តលាយដោយទឹកដោះ ដល់ព្រះបច្ចេកសម្ពុទ្ធមួយអង្គ ។*

*លោកបំពេញបុណ្យក្នុងភពនោះៗ យ៉ាងនេះ ត្រាច់ទៅក្នុងសុគតិភពនោះឯង ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងផ្ទៃរបស់ស្រីក្រីក្រម្នាក់ ក្នុងក្រុងសាវត្ថី ដោយផលដែលហូរមកនៃកម្មក្នុងកាលមុន ។ ស្រីនោះ រក្សា*

---

*១- ក្នុងថេរគាថា ជាព្រះកកុសន្ធៈ ។*

គភ៌អស់ ១០ ខែ កាលគភ៌ចាស់ ក្នុងពេលប្រសូតមិនអាចប្រសូត ក៏សន្ធប់ ដេកដូចស្លាប់អស់កាលយូរ ។ ពួកញាតិនាំនាងទៅកាន់ព្រៃខ្មោច ដោយសម្គាល់ថាស្លាប់ហើយ ទើបលើកឡើងកាន់ជើងថ្ករ កាលព្យុះ និងភ្លៀងតាំងឡើង ដោយអានុភាពរបស់ទេវតា ទើបមិនបានដុត នាំគ្នាចៀសចេញទៅ ។ ទារកមិនមានរោគ ចេញអំពីឧទរមាតា ដោយអានុភាពនៃទេវតានោះឯង ព្រោះកើតក្នុងភពចុងក្រោយ ។ ឯមាតាបានធ្វើកាលកិរិយាហើយ ទេវតាចូលក្នុងរាងកាយមនុស្ស នាំទារកនោះទៅដាក់ក្នុងផ្ទះរបស់អ្នកយាមព្រៃខ្មោច នាំអាហារដែលសមគួរមកឲ្យក្នុងវេលាដែលសមគួរ ។ បន្ទាប់អំពីនោះ អ្នកយាមព្រៃខ្មោចទទួលជាបុត្តចិញ្ចឹមរហូតមក ។ កុលបុត្តនោះ កាលធំឡើងយ៉ាងនោះ លេងជាមួយកុមារឈ្មោះសុប្បិយៈ ដែលជាកូនរបស់អ្នកយាមព្រៃខ្មោចនោះ ។ កុលបុត្តនោះ បានឈ្មោះថា សោបាកៈ ព្រោះធំធាត់ក្នុងព្រៃខ្មោច ។

ថ្ងៃមួយ ព្រះមានព្រះភាគ ទ្រង់ផ្សាយសំណាញ់ញាណក្នុងពេលទៀបភ្លឺ ប្រមើលមើលពួកវេនេយ្យសត្វ ឃើញកុលបុត្តនោះ ចូលក្នុងសំណាញ់ព្រះញាណ ទើបយាងទៅកាន់ព្រៃខ្មោច ។ ទារក កាលបុព្វហេតុដាស់តឿន មានចិត្តជ្រះថ្លា ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំ ហើយឈរ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់កុលបុត្តនោះ ។ កុលបុត្តនោះ ស្តាប់ធម៌ហើយ ទូលសូមបព្វជ្ជា ត្រូវព្រះសាស្តាត្រាស់សួរថា អ្នកជាបុគ្គលដែលបិតាអនុញ្ញាតហើយឬ ទើបបាននាំបិតាទៅកាន់សម្នាក់ព្រះសាស្តា ។ បិតារបស់

កុលបុត្តនោះ ថ្វាយបង្គំព្រះសាស្តាហើយ អនុញ្ញាតដោយពាក្យថា បពិត្រព្រះអង្គ សូមទ្រង់មេត្តាឲ្យនូវបព្វជ្ជាដល់ទារកនេះចុះ ។ ព្រះមានព្រះភាគទ្រង់ឲ្យកុលបុត្តនោះបព្វជ្ជាហើយ ទ្រង់ទូន្មានឲ្យចម្រើនមេត្តាភាវនា កុលបុត្តនោះកំណត់កម្មដ្ឋាន មានមេត្តាជាអារម្មណ៍ក្នុងព្រៃខ្មោច មិនយូរប៉ុន្មាន ធ្វើឈានមានមេត្តាជាអារម្មណ៍ឲ្យជាបាទ ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវអរហត្តក្នុងកាលមិនយូរឡើយ ។ ព្រះថេរៈ សូម្បីបានជាព្រះអរហន្តហើយ ដើម្បីសម្តែងមេត្តាភាវនាវិធីដល់ភិក្ខុ ដែលនៅក្នុងព្រៃស្មសានដទៃៗ ទើបពោលគាថាថា **យថាបិ ឯកបុត្តស្មឹ**[១] ដូច្នេះជាដើម ។ លោកអធិប្បាយថា មាតា និងបិតា គប្បីជាអ្នកមានមេត្តា គឺបំណងប្រយោជន៍ក្នុងបុត្តតូចតែមួយ ដែលជាទីស្រឡាញ់ពេញចិត្ត យ៉ាងណា គប្បីជាអ្នកមានមេត្តាដោយប្រាថ្នាប្រយោជន៍ដោយចំណែកមួយក្នុងសត្វទាំងពួង ដែលស្ថិតនៅក្នុងទិសទាំងពួង មានទិសខាងកើតជាដើម ឬក្នុងកពទាំងពួង មានកាមភពជាដើម ក្នុងវ័យទាំងពួង មានវ័យក្មេងជាដើម យ៉ាងនោះ មិនចែកជាមិត្ត ជាកណ្តាល ជាសត្រូវ គប្បីចម្រើនមេត្តាដែលមានរសតែមួយ ក្នុងទីគ្រប់ស្ថាន ដោយទម្លាយព្រំដែន កាលពោលគាថានេះហើយ បានឲ្យឱវាទថា បើអាវុសោទាំងឡាយចម្រើនមេត្តាយ៉ាងនេះសោត លោកទាំងឡាយ នឹងជាអ្នកមានចំណែកនៃអានិសង្សមេត្តា ១១ យ៉ាង ដែលព្រះមានព្រះភាគត្រាស់ដោយន័យថា ដេកលក់ជាសុខដូច្នេះជាដើមដោយចំណែក ។

---

១- ថេរគាថា ។

លោកបានសម្រេចផលយ៉ាងនេះហើយ ពិចារណាបុណ្យដែលខ្លួនធ្វើហើយកើតនូវសោមនស្ស កាលសម្តែងអបទានដែលខ្លួនប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បត្ថារំ សោធយន្តស្ស** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **បត្ថារំ** បានដល់ ទីដែលស្ងាត់នៃភ្នំថ្មី កុដុម្ពិកៈនោះធ្វើកំពែងឥដ្ឋត្រង់ញកភ្នំនោះ ដើម្បីឲ្យជាប់ហើយធ្វើជាសន្ទះទ្វារថ្វាយ ដើម្បីជាលំនៅរបស់ពួកភិក្ខុ ព្រោះជាទីកន្លែងសមគួរដល់បព្វជិត ។ ឈ្មោះថា **បត្ថារ** ព្រោះត្រូវទ្រទ្រង់នូវទម្ងន់ដោយជុំវិញ ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈយាងមក គឺយាងមកដល់សម្នាក់របស់ខ្ញុំ ដែលកំពុងជម្រះញកភ្នំនោះឲ្យស្អាត ។

បទថា **ពុទ្ធំ ឧបគតំ ទិស្វា** សេចក្តីថា ខ្ញុំឃើញព្រះពុទ្ធយាងមកកាន់សម្នាក់របស់ខ្ញុំយ៉ាងនេះហើយ ខ្ញុំក្រាលនូវកម្រាល គឺកម្រាលធ្វើអំពីស្មៅ និងស្លឹកឈើជាដើម កម្រាលមែកឈើ គឺរៀបចំព្រមហើយ ថ្វាយអាសនៈផ្កា គឺអាសនៈដែលសម្រេចដោយផ្កាដល់ព្រះពុទ្ធដែលជាលោកជេដ្ឋៈ ជាបុគ្គលប្រកបដោយតាទិគុណ ព្រោះជាបុគ្គលមានសភាពមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

បទថា **បុប្ផាសនេ និសីទិត្វា** សេចក្តីថា ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជាលោកនាយក គង់លើអាសនៈផ្កាដែលតាក់តែងនោះ ។ បទថា **មមញ្ច គតិមញ្ញាយ** សេចក្តីថា ទ្រង់ជ្រាប គឺទ្រង់ដឹងនូវគតិ គឺទីកើតតទៅរបស់ខ្ញុំ បានត្រាស់ គឺទ្រង់សម្តែងការមិនទៀង គឺភាវៈជារបស់មិនទៀង ។

បទថា **អនិច្ចា វត សង្ខារា** សេចក្តីថា សង្ខារទាំងពួងអាស្រ័យបច្ច័យ

តាក់តែងឡើងដោយចំណែកមួយ គឺជាធម៌ប្រព្រឹត្តទៅតាមបច្ច័យទាំងអស់ ឈ្មោះថា **អនិច្ចា** ព្រោះអត្ថថា មានហើយ ត្រឡប់ជាមិនមាន ។ បទថា **ឧប្បាទវយធម្មិនោ** សេចក្តីថា សង្ខារទាំងនោះកើតឡើងហើយ មានការវិនាសទៅជាសភាវៈ គឺកើតឡើងហើយ ប្រាកដហើយ រមែងរលត់ទៅ គឺរមែងវិនាសទៅ ។ បទថា **តេសំ វូបសមោ សុខោ** សេចក្តីថា ការចូលទៅស្ងប់នូវសង្ខារទាំងនោះដោយពិសេសជាសុខ អធិប្បាយថា ការធ្វើឲ្យសង្ខារទាំងនោះរលត់ គឺការរលត់ដោយឥតសេសសល់ជាសុខដោយចំណែកមួយ ។

បទថា **ឥទំ វត្វាន សព្វញ្ញូ** ក្លាប់សេចក្តីថា ព្រះមានព្រះភាគទ្រង់ដឹងនូវធម៌ទាំងពួង ជាបុគ្គលប្រសើរបំផុត គឺជាអ្នកចម្រើននៃលោក ជាអ្នកអង់អាច ជាអ្នកធំជាងនរជន ជាមហាវីរៈ ត្រាស់ គឺសម្តែងព្រះធម្មទេសនាដែលទាក់ទងដោយភាវៈមិនទៀងនេះហើយ ទ្រង់ហោះទៅកាន់វេហាស៍ គឺទៅកាន់អាកាស ដូចស្តេចហង្សក្នុងអម្ពរ គឺលើមេឃ ដូច្នោះ ។

ខ្ញុំលះ គឺចោលនូវទិដ្ឋិរបស់ខ្លួន គឺលទ្ធិ សេចក្តីត្រេកអរ ការគាប់ចិត្តបានដល់ អធ្យាស្រ័យរបស់ខ្លួន ។ បទថា **ភាវយានិច្ចសញ្ញហំ** សេចក្តីថា ខ្ញុំចម្រើន គឺធ្វើសញ្ញាដែលប្រព្រឹត្តក្នុងវត្ថុមិនទៀង ថាមិនទៀង ឲ្យកើតឡើងបានដល់ ធ្វើទុកក្នុងចិត្ត ។ បទថា **តត្ថ កាលំ កតោ អហំ** សេចក្តីថា ធ្វើកាលកិរិយាក្នុងទីនោះ គឺក្នុងជាតិនោះ បានដល់ ស្លាប់ទៅអំពីជាតិនោះ ។

បទថា **ទ្វេ សម្បត្តី អនុភោត្វា** សេចក្តីថា សោយនូវសម្បត្តិទាំងពីរ

*ពោល គឺមនុស្សសម្បត្តិ និងទិព្វសម្បត្តិ ។ បទថា* **សុក្កមូលេន ចោទិតោ** *សេចក្តីថា ដែលកុសលមូលក្នុងកាលមុន ឬដែលកុសលមូលខាងដើម ជាស់តឿនហើយ គឺរឭកហើយ ។ បទថា* **បច្ឆិមេ ភវេ សម្បត្តេ** *សេចក្តីថា កាលភពចុងក្រោយដល់ព្រមហើយ គឺមកដល់ហើយ ។ បទថា* **សធាក-យោនុបាគមិំ** *សេចក្តីថា ចូលដល់កំណើតជាន់ទាបដែលចម្អិនភត្តចំពោះខ្លួន គឺកើតក្នុងត្រកូលចណ្ឌាល ដែលចម្អិនភត្តសម្រាប់ខ្លួន មិនមានអ្នកដទៃបរិភោគជាមួយ អធិប្បាយថា ខ្ញុំកើតក្នុងត្រកូលចណ្ឌាលនោះ ។ ម្យ៉ាងទៀត ឆ្កែ លោកហៅថា* **សា** *អធិប្បាយថា កើតក្នុងត្រកូលចណ្ឌាលបរិភោគភត្តដែលសល់អំពីឆ្កែ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។៚*

**អដ្ឋកថាសោបាកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សុមង្គលត្ថេរាបទានទី ១០

[ ២២ ] ខ្ញុំមានប្រាថ្នានឹងបូជានូវគ្រឿងបូជា កំពុងតាក់តែងភោជន ទទួលពួកព្រាហ្មណ៍ បានស្ថិតនៅក្នុងរោងដ៏ធំ ។ គ្រានោះ ខ្ញុំបាន ឃើញព្រះសម្ពុទ្ធព្រះនាមបិយទស្សី ព្រះអង្គមានយសធំ ទ្រង់ទូន្មាន សត្វលោកទាំងពួង ព្រះអង្គជាព្រះសយម្ភូ ជាបុគ្គលដ៏ប្រសើរ ។ ព្រះអង្គមានជោគ មានរស្មីរុងរឿង មានពួកសាវកចោមរោម កំពុងស្តេចទៅក្នុងផ្លូវ រុងរឿងដូចជាព្រះអាទិត្យ ។ ខ្ញុំផ្គងអញ្ជលី ហើយ ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បាននិមន្តព្រះអង្គដោយចិត្តថា សូមព្រះមហាមុនី ស្តេចនិមន្តមក ។ ព្រះសាស្តា ប្រសើរក្នុង លោក ទ្រង់ជ្រាបបំណងរបស់ខ្ញុំ ហើយស្តេចចូលទៅកាន់ទ្វារផ្ទះ របស់ខ្ញុំ ( ជាមួយ ) នឹងព្រះខីណាស្រពមួយពាន់អង្គ ។ ( ខ្ញុំក្រាប ទូលថា ) បពិត្របុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រ បុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ សូមព្រះអង្គស្តេចឡើងកាន់ ប្រាសាទរបស់ខ្ញុំ ហើយគង់លើអាសនៈដ៏ប្រសើរ ។ ព្រះសម្ពុទ្ធ ព្រះនាមបិយទស្សី ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ ព្រះអង្គមាន ភិក្ខុព្រះខីណាស្រពជាបរិវារ ដែលមានឥន្ទ្រិយទូន្មានហើយដែរ ព្រះអង្គឆ្លងវដ្តសង្សារ ប្រសើរជាងពួកជនអ្នកឆ្លង ទ្រង់បាន ឡើងកាន់ប្រាសាទ ហើយគង់លើអាសនៈដ៏ប្រសើរ ។ អាមិស ណា ដែលខ្ញុំតាក់តែង បម្រុងទុកក្នុងផ្ទះរបស់ខ្លួន ខ្ញុំមានចិត្តជ្រះថ្លា

ថ្វាយអាមិសនោះ ចំពោះព្រះពុទ្ធដោយដៃទាំងពីររបស់ខ្លួន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ មានសេចក្តីត្រេកអរ ធ្វើអញ្ជលីនមស្ការនូវព្រះពុទ្ធដ៏ប្រសើរថា ឱហ្ន៎ ព្រះពុទ្ធមានអានុភាពថ្លៃថ្លា ។ បណ្តាភិក្ខុ ៨ អង្គ ដែលចូលមកកាន់ទីធាន់ មានព្រះខីណាស្រពច្រើនអង្គនេះ ជាអានុភាពរបស់ព្រះអង្គ ខ្ញុំសូមដល់នូវព្រះអង្គជាទីពឹង ។ ព្រះមានព្រះភាគ ព្រះនាមបិយទស្សី ជាច្បងក្នុងលោក ជានរាសភៈ គង់ក្នុងភិក្ខុសង្ឃហើយ សម្តែងគាថាទាំងនេះថា

កុលបុត្តណា បាននិមន្តព្រះសង្ឃ ជាអ្នកមានចិត្តត្រង់ មានចិត្តនឹងនួន ព្រមទាំងតថាគត ជាព្រះសម្ពុទ្ធ ឲ្យឆាន់ស្កប់ស្កល់ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្តនោះ នឹងសោយទេវរាជ្យ អស់ ២៧ ដង កុលបុត្តនោះ ប្រារព្ធនូវកុសលកម្មរបស់ខ្លួនហើយ នឹងរីករាយក្នុងទេវលោក ។ កុលបុត្តនោះ នឹងបានជាស្តេចចក្កពត្តិ ១៨ ដង នឹងបានសោយប្រឹថពីរាជ្យគ្រប់គ្រងផែនដី អស់ ៥០០ ដង ។

ខ្ញុំចូលទៅក្នុងព្រៃធំ ជាអរញ្ញវ័ន ដែលពួកខ្លាអាស្រ័យនៅក៏តាំងព្យាយាម ដុតបំផ្លាញនូវពួកកិលេស ។ ក្នុងកប្បទី ១១៨ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយភត្ត ។ បដិសម្ភិទា ៤ វិមោក្ខ ៨

និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមង្គលត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សុមង្គលត្ថេរាបទាន ចប់**

## ឧទ្ទាន

រឿងព្រះសីហាសនទាយកត្ថេរ ១ ព្រះឯកត្ថម្ភិកត្ថេរ ១ ព្រះនន្ទត្ថេរ ១ ព្រះចុល្លបន្ថកត្ថេរ ១ ព្រះបិលិន្ទវច្ឆត្ថេរ ១ ព្រះរាហុលត្ថេរ ១ ព្រះឧបសេនវង្គន្តបុត្តត្ថេរ ១ ព្រះរដ្ឋបាលត្ថេរ ១ ព្រះសោបាកត្ថេរ ១ ព្រះសុមង្គលត្ថេរ ១ ត្រូវជា ១០ រឿង ជាវគ្គគម្រប់ពីរ គាថាដែលលោកសម្តែងហើយ ក្នុងវគ្គនោះ មាន ១៣៧ គាថា ។

**សីហាសនិយវគ្គទី ២ ចប់**

# អដ្ឋកថា

## សុមង្គលត្ថេរាបទាន

[ ២២ ] អបទានរបស់ព្រះសុមង្គលត្ថេរ មានពាក្យផ្ដើមថា **អាហុតឹ យិដ្ឋុកាមោ** ដូច្នេះ ។

ព្រះសុមង្គលនេះ បានបំពេញបុញ្ញាធិការក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះដ៏មានព្រះភាគព្រះនាមបិយទស្សី កើតជារុក្ខទេវតា ។ ថ្ងៃមួយ លោកឃើញព្រះសាស្ដាស្រង់ទឹក មានចីវរមួយផ្ទាំងប្រថាប់ឈរ ដល់នូវសោមនស្ស ទះដៃ ។ ដោយបុណ្យនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលអ្នកក្រីក្រ ក្នុងស្រុកមួយកន្លែង មិនឆ្ងាយអំពីក្រុងសាវត្ថី ។ លោកមានឈ្មោះថា សុមង្គលៈ លុះចម្រើនវ័យហើយ ជាអ្នកមានកណ្ដៀវ មានទន្ទ័ល មានចបកាប់ជាសម្បត្តិរបស់ មនុស្សគមជាបរិក្ខារ ចិញ្ចឹមជីវិតដោយការធ្វើស្រែ ។ ថ្ងៃមួយ កាលព្រះបាទបសេនទិកោសល ទ្រង់បំពេញមហាទាន ដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ កុលបុត្តនោះ កាន់យកថ្នាំងទឹកដោះជូរ ដើរជាមួយមនុស្សទាំងឡាយ ដែលកាន់ទេយ្យទានមក ឃើញគ្រឿងសក្ការៈ និងការរាប់អានរបស់ព្រះមានព្រះភាគ និងរបស់ភិក្ខុទាំងឡាយ ទើបគិតថា សមណសក្យបុត្តទាំងនេះ ស្លៀកសំពត់សាច់ម៉ដ្ឋ ឆាន់ភោជនល្អៗ នៅក្នុងទីស្ងាត់ខ្យល់ បើដូច្នោះ អញគប្បីបួស ទើបចូលទៅរកព្រះថេរៈមួយរូប ប្រាប់ថា ខ្ញុំចង់បួស ។ ព្រះមហាថេរៈនោះមានសេចក្ដីករុណា ទើបឲ្យបួស ហើយប្រាប់

កម្មដ្ឋាន ។ លោកនៅក្នុងព្រៃ នឿយណាយក្នុងការនៅម្នាក់ឯង អផ្សុកប្រាថ្នានឹងសឹក ទើបទៅកាន់ផ្ទះញាតិ ឃើញមនុស្សក្នុងរោងផ្លូវចងក្បិនក្ដួរស្រែស្មៀកសំពត់ចាស់ៗ មានរាងកាយប្រឡាក់ដោយធូលីដោយជុំវិញ ស្គមស្គាំងដោយខ្យល់ និងកម្ដៅថ្ងៃ កំពុងក្ដួរស្រែ ទើបបានទូវសេចក្ដីសង្វេគថាសត្វទាំងនេះបានទទួលទុក្ខ ព្រោះត្រូវចិញ្ចឹមជីវិតពិត និងព្រោះលោកមានញាណចាស់ក្លា កម្មដ្ឋានដែលរៀនមក ក៏ប្រាកដដល់លោក ។ លោកចូលទៅកាន់គល់ឈើមួយកន្លែង បានទូវការស្ងាត់ ដាក់ចិត្តដោយឧបាយប្រាជ្ញាចម្រើនវិបស្សនាហើយបានសម្រេចអរហត្ត តាមលំដាប់នៃមគ្គ ។

លោកសម្រេចអរហត្តផលយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួនកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចសោមនស្ស ទើបពោលពាក្យថា **អាហុតឹ យិដ្ឋុកាមោហំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អាហុតឹ** បានដល់ គ្រឿងឧបករណ៍បូជា និងសក្ការៈមិនមែនតិច មានបាយ និងទឹកជាដើម ។ បទថា **យិដ្ឋុកាមោ** ប្រែថា ជាអ្នកប្រាថ្នាដើម្បីបូជា គឺខ្ញុំជាអ្នកប្រាថ្នាឲ្យទាន ។ បទថា **បដិយាទេត្វាន ភោជនំ** សេចក្ដីថា ចាត់ចែង គឺត្រៀមអាហារឲ្យសម្រេច ។ បទថា **ព្រាហ្មណោ បដិមានេន្តោ** សេចក្ដីថា ស្វែងរកបដិគ្គាហក គឺបព្វជិតដែលបរិសុទ្ធ ។ បទថា **វិសាលេ មាឡកេ ឋិតោ** សេចក្ដីថា ឈរក្នុងរោងដែលទូលាយ មានផ្ទៃរាបដោយខ្សាច់ពណ៌ស្អាត គួរត្រេកអរក្រៃលែង ។

បទថា **អថទ្ទសាសឹ សម្ពុទ្ធំ** ភ្ជាប់សេចក្ដីថា ខ្ញុំបានឃើញព្រះសម្ពុទ្ធ

ព្រះនាមបិយទស្សី ជាអ្នកមានយសធំ មានបរិវារច្រើន ជាអ្នកដឹកនាំលោកទាំងពួង គឺសត្វលោកទាំងមូលដោយវិសេស ឲ្យសត្វដល់នូវព្រះនិព្វាន ជាព្រះសយម្ភូ គឺជាអ្នកកើតឯងមិនមានអាចារ្យ ជាអគ្គបុគ្គល គឺជាបុគ្គលប្រសើរ ជាអ្នកចែកនូវធម៌ ប្រកបដោយគុណ មានភាពជាអ្នកមានភគ្យធម៌ជាដើម ជាអ្នករុងរឿង សម្បូរដោយរស្មី មានពណ៌ខៀវ និងពណ៌លឿងជាដើម ចោមរោមទៅដោយសាវ័កទាំងឡាយ រុងរឿងល្អ ដូចព្រះអាទិត្យត្រាច់ទៅក្នុងវិថី ។ បទថា **អញ្ជលឹ បគ្គហេត្វាន** សេចក្ដីថា ខ្ញុំផ្គងនូវក្រពុំម្រាមដៃលើក្បាល ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លាក្នុងគុណរបស់ព្រះមានព្រះភាគបែបនោះ អធិប្បាយថា ធ្វើចិត្តឲ្យជ្រះថ្លា ។ បទថា **មនសាវ និមន្តេសឹ** ប្រែថា ទូលអារាធនាដោយចិត្ត ។ បទថា **អាគច្ឆតុ មហាមុនិ** សេចក្ដីថា សូមព្រះមានព្រះភាគ ដ៏ជាមុនីគួរគោរព គឺគួរដល់ការបូជា ទ្រង់មកកាន់និវេសន៍របស់ខ្ញុំចុះ ។

បទថា **មម សង្កប្បមញ្ញាយ** សេចក្ដីថា ព្រះសាស្ដា ទ្រង់ជាអគ្គបុគ្គល គឺមិនមានបុគ្គលក្រៃលែងជាងក្នុងលោក គឺក្នុងសត្វលោក ទ្រង់ជ្រាបការត្រិះរិះក្នុងចិត្តរបស់ខ្ញុំហើយ ចោមរោមដោយព្រះខីណាស្រព ១ ពាន់អង្គ គឺព្រះអរហន្ត ១ ពាន់អង្គយាងមក គឺទ្រង់យាងដល់ទ្វាររបស់ខ្ញុំ គឺទ្វារផ្ទះរបស់ខ្ញុំ ។ ខ្ញុំបានធ្វើនមស្ការយ៉ាងនេះ ដល់ព្រះសាស្ដាអង្គនោះ ដែលយាងមកដល់ហើយថា បពិត្រព្រះអង្គជាបុរសអាជានេយ្យ ឧត្ដមប្រសើរជាងបុរសទាំងឡាយ ខ្ញុំសូមនមស្ការដល់ព្រះអង្គ បពិត្រព្រះអង្គ ជាឧត្ដម

បុរស គឺឧត្តមប្រសើរដោយគុណដ៏ក្រៃលែងរបស់បុរសទាំងឡាយ ការនមស្ការរបស់ខ្ញុំ សូមមានដល់ទ្រង់ អធិប្បាយថា ខ្ញុំសូមនិមន្តព្រះអង្គឡើងកាន់ប្រាសាទដែលនាំឲ្យកើតសេចក្តីជ្រះថ្លា បានដល់ និវេសន៍របស់ខ្ញុំ ហើយគង់លើអាសនៈដ៏ប្រសើរ គឺលើអាសនៈដ៏ឧត្តម ។

បទថា **ទន្តោ ទន្តបរិវារោ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ទូន្មានព្រះអង្គហើយដោយទ្វារទាំង ៣ ដោយព្រះអង្គឯង ចោមរោមទៅដោយបរិស័ទ ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ដែលទូន្មានហើយដោយវិធីដូចគ្នា ។ បទថា **តិណ្ណោ តារយតំ វរោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ឆ្លងឯងហើយ គឺផុតចេញចាកសង្សារហើយ ជាបុគ្គលប្រសើរ ឧត្តមជាងបុគ្គលដែលវិសេស ដែលកំពុងឆ្លង យាងឡើងប្រាសាទ ដោយការអារាធនារបស់ខ្ញុំហើយ ប្រថាប់គង់ គឺសម្រេចការគង់លើអាសនៈដ៏ប្រសើរ គឺលើអាសនៈដ៏ឧត្តម ។

បទថា **យំ មេ អត្ថិ សកេ គេហេ** សេចក្តីថា អាមិសណា ដែលខ្ញុំរៀបចំ គឺរួបរួម បានដល់ គរទុកក្នុងផ្ទះខ្លួន ។ បទថា **តាហំ ពុទ្ធស្ស ចាទាសឹ** សេចក្តីថា ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយនូវអាមិសនោះដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធានដោយគោរព ឬដោយអើពើ ។ បទថា **បសន្នោ សេហិ ចាណិភិ** សេចក្តីថា ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តផូរផង់ កាន់យកអាមិសប្រគេនដោយដៃទាំងពីររបស់ខ្លួន ។

ខ្ញុំមានចិត្តជ្រះថ្លា មានការត្រេកអរនៃចិត្តដ៏ផូរផង់ហើយ មានចិត្តល្អ មាន

ចិត្តស្អាត អធិប្បាយថា ខ្ញុំកើតនូវការត្រេកអរ កើតនូវសោមនស្ស ផ្គងអញ្ជលី គឺលើកអញ្ជលីដាក់លើសិរសា នមស្ការ គឺថ្វាយបង្គំដល់ព្រះពុទ្ធដ៏ប្រសើរ ។ បទថា **អហោ ពុទ្ធស្សុឡារតា** សេចក្តីថា ភាពជាធំក្រៃលែង គឺភាពជាធំក្រៃលែងរបស់ព្រះសាស្តា ដែលត្រាស់ដឹងអរិយសច្ច ៤ គួរអស្ចារ្យហ្ន៎ ។

បទថា **អដ្ឋន្នំ បយិរុបាសតំ** សេចក្តីថា ក្នុងរវាងព្រះអរិយបុគ្គល ៨ ដែលអង្គុយចាន់ មានព្រះអរហន្តខីណាស្រេពដ៏ច្រើន ។ បទថា **តុយ្ហេវេសោ អានុភាវោ** សេចក្តីថា ព្រះអង្គប៉ុណ្ណោះ មានអានុភាព ដូចជាការត្រាច់ទៅក្នុងអាកាស និងមុជដីជាដើម ។ បុគ្គលដទៃមិនមាន ។ បទថា **សរណំ តំ ឧបេមហំ** សេចក្តីថា ខ្ញុំសូមដល់ គឺដល់ ឬដឹងថា ទ្រង់ជាបុគ្គលបែបនោះ ជាទីពឹង ជាទីជ្រកកោន ជាទីពួន ជាទីទៅខាងមុខ អធិប្បាយថា ព្រះមានព្រះភាគព្រះនាមបិយទស្សី ជាបុគ្គលប្រសើរជាងសត្វលោក ជាអ្នកអង់អាចជាងនរៈ ប្រថាប់គង់ក្នុងកណ្តាលភិក្ខុសង្ឃ បានភាសិត គឺត្រាស់ព្យាករគាថាទាំងនេះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាសុមង្គលត្ថេរាបទាន ចប់**

**សីហាសនិយវគ្គ ចប់**

# សុត្តន្តបិដក

## សុភូតិវគ្គទី ៣

### សុភូតិត្ថេរាបទានទី ១

[ ២៣ ] មានភ្នំមួយឈ្មោះនិសភៈ នៅជិតព្រៃហិមពាន្ត អាស្រមរបស់ខ្ញុំ ទាំងបណ្ណសាលារបស់ខ្ញុំ គេសង់ល្អហើយ ក្បែរភ្នំនោះ ។ ក្នុងកាលនោះ ខ្ញុំជាជដិល ឈ្មោះកោសិយៈ មានតបៈដ៏ឧក្រិដ្ឋ ប្រព្រឹត្តតែម្នាក់ឯង ឥតមានបុគ្គលជាទីពីរ អាស្រ័យនៅនាភ្នំនិសភៈ ។ ខ្ញុំមិនបរិភោគផ្លែឈើ មើមឈើ និងស្លឹកឈើទេ ខ្ញុំចិញ្ចឹមជីវិតដោយផ្លែឈើជ្រុះឯងក្នុងវេលាព្រឹក ។ ខ្ញុំស៊ូលះបង់ជីវិត មិនញុំាងអាជីវៈឲ្យកម្រើក ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យរីករាយ ចៀសវាងនូវអនេសនៈ ។ ចិត្តរបស់ខ្ញុំ ប្រកបដោយរាគៈកើតឡើងក្នុងកាលណា ខ្ញុំពិចារណាដោយខ្លួនឯង ខ្ញុំតែម្នាក់ឯងទូន្មាននូវចិត្តនោះ ក្នុងកាលនោះថា អ្នកឯងនៅតែត្រេកអរក្នុងអារម្មណ៍ ដែលគប្បីត្រេកអរផង ប្រទូស្តក្នុងអារម្មណ៍ ដែលគប្បីប្រទូស្តផង វង្វេងក្នុងអារម្មណ៍ ដែលគប្បីវង្វេងផង អ្នកចូរចៀសចេញចាកព្រៃទៅ ។ ប្រទេសនេះ ជាលំនៅរបស់ពួកបុគ្គលជាអ្នកស្អាត ដែលមិនមានមន្ទិល មានតបធម៌ អ្នកកុំប្រទូស្តទីស្អាតនេះឡើយ អ្នកចូរចៀសចេញចាកព្រៃទៅ ។ បើអ្នកជាគ្រហស្ថ នឹងបាននូវ

គូប្រកបក្នុងកាលណា អ្នកកុំធ្វើជនទាំងពីរនាក់ ឲ្យអាក់អន់ឡើយ ( ក្នុងកាលនោះ ) អ្នកចូរចៀសចេញចាកព្រៃទៅ ។ ឧសដែលគេដុតសាកសពហើយ ជារបស់ធ្វើកិច្ចមិនបាន ក្នុងទីណាមួយ គឺមិនបានការក្នុងស្រុក ឬក្នុងព្រៃ ព្រោះថា ឧសនោះ គេមិនសន្មតថាជាឧសឡើយ យ៉ាងណាមិញ ។ អ្នកឯងទុកដូចជាឧសដែលគេដុតសាកសព គឺមិនមែនជាគ្រហស្ថ មិនមែនជាបព្វជិតសង្រ្គមទេ ជាមនុស្ស ផុតចាកភេទទាំងពីរ ក្នុងថ្ងៃនេះ អ្នកចូរចៀសចេញចាកព្រៃទៅ ។ ក្រែងអ្នកគប្បីមានអំពើទុ៎ះឬ ព្រោះអ្នកណានឹងដឹងនូវអំពើរបស់អ្នកនេះ អ្នកនឹងនាំទៅនូវធុរៈចាកភាពនៃយើង ដែលជាអ្នកច្រើនដោយសេចក្តីខ្ពិលច្រអូសយ៉ាងធាប់ ។ អ្នកប្រាជ្ញទាំងឡាយ នឹងខ្ពើមរអើមអ្នក ដូចអ្នកក្រុងខ្ពើមរអើមវត្ថុមិនស្អាត ឥសីទាំងឡាយ នឹងកោះហៅអ្នកមកចោទសព្វៗ កាល ។ អ្នកប្រាជ្ញទាំងឡាយ នឹងតិះដៀលអ្នកថា ជាមនុស្សប្រព្រឹត្តកន្លងសាសនា អ្នកកាលមិនបាននៅរួមជាមួយ ( នឹងអ្នកប្រាជ្ញទាំងឡាយ ) តើអ្នកនឹងរស់នៅដូចម្តេច ។ ដំរីមានកម្លាំងចូលទៅជិតដំរីដ៏ប្រសើរ មានអាយុ ៦០ ទើបថយកម្លាំង ចុះប្រេងដោយចំណែក ៣ ហើយ បណ្តេញដំរី ( ទុ៎ះ ) ចាកហ្វូង ។ ដំរីទុ៎ះកាលត្រូវដំរីមានកម្លាំង បណ្តេញចេញចាកហ្វូងហើយ រមែងស្ងប់ស្ងៀម មិនបានសុខស្រួលទេ ជាសត្វដល់នូវសេចក្តីទុក្ខ

ខូចចិត្ត សញ្ជប់សញ្ជឹង ញាប់ញ័រ យ៉ាងណា ។ ពួកជដិលនឹង បណ្តេញអ្នកឯង ដែលមានគំនិតអាក្រក់ចេញ អ្នកឯងត្រូវពួក ជដិលទាំងនោះ បណ្តេញចេញហើយ រមែងស្ងប់ស្ងៀម មិនបាន សុខស្រួលទេ ក៏យ៉ាងនោះឯង ។ អ្នកឯងកំពុងពោរពេញដោយ សរ គឺសេចក្តីសោក ឆេះរោលរាល ព្រោះសេចក្តីក្តៅក្រហាយ ទាំងថ្ងៃ ទាំងយប់ ដូចជាដំរីចុះប្រេង ដែលត្រូវដំរីមានកម្លាំង បណ្តេញចាកហ្វូង ។ ជាតរូបក្លែងក្លាយ ចាយមិនដាច់ក្នុងទីណា មួយ យ៉ាងណា អ្នកឯង ជាបុគ្គលសាបសូន្យចាកសីល នឹង ចាយមិនដាច់ក្នុងទីណាមួយ យ៉ាងនោះដែរ ។ អ្នកឯង កាលបើនៅ គ្រប់គ្រងផ្ទះ នឹងរស់នៅដូចម្តេចបាន ព្រោះទ្រព្យ ជារបស់នៃ មាតាក្តី ជារបស់នៃបិតាក្តី ដែលអ្នកបម្រុងទុកមិនមានទេ ។ អ្នក ឯងលុះតែធ្វើការងាររបស់ខ្លួន ហើយញ៉ាំងញើសក្នុងខ្លួនឲ្យហូរ ចេញ ទើបនឹងរស់នៅក្នុងផ្ទះបាន ហេតុនេះ ខ្ញុំសូមអង្វរអ្នក កុំ គាប់ចិត្តនឹងការងារនោះឡើយ ។ ខ្ញុំឃាត់នូវចិត្តដែលដល់នូវ សេចក្តីសៅហ្មង ក្នុងទីនោះ យ៉ាងនេះហើយ ខ្ញុំធ្វើនូវធម្មកថា ផ្សេងៗ ហើយឃាត់ចិត្តចាកអំពើអាក្រក់ ។ កាលបើខ្ញុំនៅដោយ សេចក្តីមិនប្រហែសយ៉ាងនេះ ៣០ ពាន់ឆ្នាំរបស់ខ្ញុំ កន្លងហើយ ក្នុងព្រៃ ។ ព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ឃើញខ្ញុំ ជាអ្នកស្វែងរកនូវ ប្រយោជន៍ដ៏ឧត្តម ដោយសេចក្តីមិនប្រហែស ហើយស្តេចមកកាន់

សម្នាក់នៃខ្ញុំ ។ កាលនោះ ព្រះពុទ្ធមានពន្លឺដូចជាសម្បុរនៃផ្លែទន្ទាប់ នឹងប្រមាណមិនបាន មិនមានគ្រឿងប្រៀប មិនមានរូបដទៃប្រាកដស្មើ ដោយព្រះរូប ( របស់ព្រះអង្គ ) ទ្រង់ចង្ក្រមព្ធដ៏អាកាស ។ កាលនោះ ព្រះពុទ្ធមិនមានអ្វីប្រាកដស្មើដោយញាណ ទ្រង់ចង្ក្រមព្ធដ៏អាកាស ដូចជាសាលព្រឹក្ស ដែលមានផ្ការីកល្អ ពុំនោះសោត ដូចផ្លេកបន្ទោរក្នុងចន្លោះនៃដុំពពក ។ កាលនោះ ព្រះពុទ្ធទ្រង់ចង្ក្រមព្ធដ៏អាកាស ដូចជាស្តេចសីហៈ មិនមានសេចក្តីព្រឺព្រួច ឬដូចស្តេចដំរី ដែលគេហាត់បានហើយ ពុំនោះសោត ដូចស្តេចខ្លា ដែលមិនមានសេចក្តីខ្លាច ។ គ្រានោះ ព្រះសម្ពុទ្ធមានរស្មីដូចមាសត្ពោរ ឈ្មោះសិង្គិ ឬដូចរងើកភ្លើងឧសគគីរ ពុំនោះសោត ដូចកែវមណី មានរស្មីដ៏រុងរឿង ទ្រង់ចង្ក្រមព្ធដ៏អាកាស ។ គ្រានោះ ព្រះសម្ពុទ្ធដូចភ្នំកៃលាសដ៏បរិសុទ្ធ ឬដូចព្រះចន្ទ ក្នុងថ្ងៃពេញបូណ៌មី ពុំនោះសោត ដូចព្រះអាទិត្យ តាំងនៅក្នុងទីពាក់កណ្តាល ( ថ្ងៃត្រង់ ) ទ្រង់ចង្ក្រមព្ធដ៏អាកាស ។ គ្រានោះ ខ្ញុំឃើញព្រះសម្ពុទ្ធ ដែលកំពុងចង្ក្រមព្ធដ៏អាកាស ក៏គិតយ៉ាងនេះថា សត្វនេះ ជាទេវតាឬ ឬថា សត្វនេះ ជាមនុស្ស ។ នរៈបែបនេះលើផែនដី ខ្ញុំមិនដែលឮ មិនដែលឃើញ ទំនងជាមានចំណែកនៃមន្ត សត្វនេះ ប្រហែលជាសាស្តា ។ ខ្ញុំលុះគិតយ៉ាងនេះហើយ ក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា គ្រានោះ ខ្ញុំប្រមូលផ្កា

ផ្សេងៗ និងគ្រឿងក្រអូប ។ ខ្ញុំក្រាលបុប្ផាសនៈដ៏វិចិត្រល្អ ដែលជាទីរីករាយនៃចិត្ត ហើយពោលពាក្យនេះ ទៅរកព្រះមានព្រះភាគជាសារថីនៃនរជន ដ៏ប្រសើរថា បពិត្រព្រះអង្គមានព្យាយាម អាសនៈដែលខ្ញុំព្រះអង្គក្រាលហើយនេះ សមគួរដល់ព្រះអង្គ សូមព្រះអង្គញ៉ាំងចិត្តខ្ញុំព្រះអង្គឲ្យរីករាយ ហើយគង់លើអាសនៈជាវិការនៃផ្កា ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ជាវិការនៃផ្កាដ៏ប្រសើរនោះ អស់ ៧ យប់ ៧ ថ្ងៃ ដូចជាកេសរ-រាជសីហ៍ ឥតតក់ស្លុតឡើយ ខ្ញុំបានឈរនមស្ការ អស់ ៧ យប់ ៧ ថ្ងៃ ។

ព្រះសាស្តា ព្រះអង្គប្រសើរក្នុងលោក ទ្រង់ចេញចាកសមាធិ កាលនឹងទ្រង់សម្តែងនូវអំពើរបស់ខ្ញុំ ទ្រង់ត្រាស់ដូច្នេះថា អ្នកចូរចម្រើននូវពុទ្ធានុស្សតិ ដែលជាគុណជាតដ៏ប្រសើរជាងការចម្រើននូវអនុស្សតិទាំងឡាយដទៃ ។ លុះអ្នកចម្រើននូវពុទ្ធា-នុស្សតិនេះហើយ នឹងបានញ៉ាំងចិត្តឲ្យពេញ នឹងរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប ។ អ្នកនឹងបានសោយទេវរាជ្យជាធំជាងទេវតា អស់ ៨០ ដង នឹងបានជាស្តេចចក្កពត្តិក្នុងដែនអស់មួយពាន់ដង ។ នឹងបានជាស្តេចក្នុងប្រទេសដ៏ធំទូលាយ សោយនូវសម្បត្តិទាំងអស់នោះ រាប់បានមួយអសង្ខេយ្យកប្ប នេះជាផលនៃពុទ្ធានុស្សតិ ។ អ្នកកាលបើអន្ទោលទៅក្នុងកពតូច

និងភពធំ នឹងបាននូវភោគៈដ៏ច្រើន ការខ្វះខាតដោយភោគៈទាំងឡាយ របស់អ្នកមិនមានឡើយ នេះជាផលនៃពុទ្ធានុស្សតិ ។ លុះកន្លងទៅមួយសែនកប្ប ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ អ្នកនឹងលះបោលនូវទ្រព្យ ៨០ កោដិ និងពួកទាសកម្មករជាច្រើន ហើយទៅបួសក្នុងសាសនា របស់ព្រះមានព្រះភាគព្រះនាមគោតមនោះ ។ អ្នកមានឈ្មោះថា សុក្ខុតិ នឹងញ៉ាំងព្រះសម្ពុទ្ធព្រះនាមគោតម ទ្រង់ប្រសើរជាងពួកសក្យៈឲ្យព្រោសប្រាណ ហើយនឹងបានជាសាវ័កនៃព្រះសាស្តា ។ ព្រះគោតមសម្ពុទ្ធ ទ្រង់គង់ក្នុងកណ្តាលនៃភិក្ខុសង្ឃហើយ ទ្រង់តាំងអ្នកថា ជាភិក្ខុប្រសើរក្នុងឋានៈទាំងពីរ គឺក្នុងពួកនៃទក្ខិណេយ្យបុគ្គល ១ ក្នុងការនៅមិនមានកិលេស ( ដោយធម្មទេសនា ) ១ ។

ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ជានាយក ព្រះនាមបទុមុត្តរៈ លុះត្រាស់នូវពាក្យនេះហើយ ទ្រង់ហោះឡើងកាន់អាកាស ដូចស្តេចហង្ស ហើរទៅឰដ៏អាកាស ។ ខ្ញុំដែលព្រះលោកនាថ ទ្រង់ប្រៀនប្រដៅហើយ ក៏មានចិត្តរីករាយ នមស្ការព្រះតថាគត ហើយចម្រើននូវពុទ្ធានុស្សតិដ៏ឧត្តម សព្វៗ កាល ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងតាវត្តិង្សទេវលោក ដោយសារកុសលកម្ម ដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតម្កល់

ចេតនានោះផង ។ ខ្ញុំបានសោយទេវរាជ្យ ជាធំជាងទេវតា អស់ ៨០ ដង បានជាស្តេចចក្កពត្តិ អស់មួយពាន់ដង ។ ខ្ញុំសោយរាជ្យ ក្នុងប្រទេសដ៏ធំទូលាយ ជាសម្បត្តិដ៏ប្រពៃ រាប់បានមួយ អសង្ខេយ្យជាតិ នេះជាផលនៃពុទ្ធានុស្សតិ ។ ខ្ញុំកាលអន្ទោលទៅ ក្នុងភពតូច និងភពធំ តែងបានទូវភោគៈដ៏ច្រើន ការខ្វះខាត ដោយភោគៈរបស់ខ្ញុំ មិនមានឡើយ នេះជាផលនៃពុទ្ធានុស្សតិ ។ ក្នុងកប្បទីមួយសែន អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវ កុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ ពុទ្ធានុស្សតិ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះសុភូតិត្ថេរមានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

## សុភូតិត្ថេរាបទាន ចប់

# អដ្ឋកថា

# សុភូតិវគ្គ

## សុភូតិត្ថេរាបទាន

[ ២៣ ] អបទានរបស់ព្រះសុភូតិត្ថេរ មានពាក្យផ្ដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។

ព្រះថេរៈរូបនេះ ក៏ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងទីបំផុតនៃកប្បទីមួយសែនអំពីភទ្ទកប្បនេះ ក្នុងកាលនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ជាទីពឹងរបស់សត្វលោកមិនទាន់កើតឡើង លោកកើតជាកូនទោលរបស់ព្រាហ្មណមហាសាលម្នាក់ ក្នុងហង្សវតីនគរ ។ ព្រាហ្មណ៍បានដាក់ឈ្មោះថា នន្ទមាណព ។ នន្ទមាណពនោះ ចម្រើនវ័យហើយ រៀនត្រៃវេទ កាលមិនឃើញវត្ថុដែលជាសារៈក្នុងត្រៃវេទនោះ ទើបបួសជាឥសីត្រង់ជើងភ្នំ មួយអន្លើដោយមាណព ៤ ម៉ឺន ៤ ពាន់ ជាបរិវាររបស់ខ្លួន ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ បានប្រាប់កម្មដ្ឋានដល់អន្តេវាសិកទាំងឡាយ ។ សូម្បីអន្តេវាសិកទាំងនោះ ក៏បានឈានក្នុងកាលមិនយូរឡើយ ។

សម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់កើតឡើងក្នុងលោក អាស្រ័យហង្សវតីនគរគង់នៅ ថ្ងៃមួយ ក្នុងពេលទៀបភ្លឺ ទ្រង់បាន

ប្រមើលមើលសត្វលោក ទ្រង់ឃើញឧបនិស្ស័យនៃអរហត្តរបស់ជដិលដែលជាអន្តេវាសិករបស់នទូតាបស និងការប្រាថ្នាតំណែងនៃសាវ័ក ដែលប្រកបទៅដោយអគ្គីរបស់នទូតាបស ទើបទ្រង់ធ្វើកិច្ចបដិបត្តិព្រះសរីរៈអំពីព្រលឹម ។ ក្នុងពេលព្រឹក ទ្រង់កាន់បាត្រ និងចីវរ ទ្រង់មិនបបួលភិក្ខុណាមួយ ដូចសីហៈយាងទៅតែមួយអង្គឯង កាលអន្តេវាសិករបស់នទូតាបសទៅរកផ្លែឈើ កាលនទូតាបសកំពុងឃើញនោះឯង យាងចុះអំពីអាកាស ប្រថាប់ឈរលើផែនដី ទ្រង់ត្រិះរិះថា នទូតាបស ចូរដឹងតថាគតថាជាព្រះពុទ្ធ ដូច្នេះ ។

នទូតាបសឃើញពុទ្ធានុភាព និងភាពបរិបូណ៌នៃព្រះលក្ខណៈ ពិចារណាមន្តសម្រាប់ទាយលក្ខណៈ ដឹងថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ កាលនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្កពត្តិ កាលចេញបួស នឹងបានជាព្រះសព្វញ្ញុពុទ្ធ ដែលកាត់វដ្តៈក្នុងលោកបានជាសមុច្ឆេទ បុរសអាជានេយ្យនេះ ពិតជាព្រះពុទ្ធដោយឥតសង្ស័យ ទើបធ្វើនូវការទទួល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយក្រាលអាសនៈថ្វាយ ។

ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដែលក្រាលហើយ ចំណែកនទូតាបស ជ្រើសរើសអាសនៈដែលសមគួរដល់ខ្លួនហើយ អង្គុយក្នុងចំណែកម្ខាង ។

សម័យនោះ ជដិល ៤ ម៉ឺន ៤ ពាន់ កាន់យកផ្លែឈើដែលមានឱជាប្រណីតមកកាន់សម្នាក់របស់អាចារ្យ សម្លឹងមើលអាសនៈដែលព្រះពុទ្ធ និងអាចារ្យអង្គុយហើយ ពោលថា បពិត្រលោកអាចារ្យ ពួកខ្ញុំទាំងឡាយ

យល់ថា ក្នុងលោកនេះ មិនមានអ្នកណាធំជាងលោក តែប្រហែលបុរសនេះ ធំជាងលោក ។

ននូតាបសពោលថា នែបា ពួកលោកនិយាយអ្វី ពួកលោកបំណាំងនឹងប្រៀបធៀបភ្នំសិនេរុរាជ ដែលមានកម្ពស់ ១៦៨ ពាន់យោជន៍ ជាមួយនឹងគ្រាប់ស្ពៃឬ ពួកលោកកុំយកខ្ញុំទៅប្រៀបនឹងព្រះសព្វញ្ញុពុទ្ធឡើយ ។ លំដាប់នោះ តាបសទាំងនោះគិតថា បើបុរសនេះជាបុគ្គលថោកថយ អាចារ្យរបស់ពួកយើងគង់មិននាំឧបមាប្រៀបធៀបយ៉ាងនេះ បុរសអាជានេយ្យនេះធំប៉ុនណាហ្ន៎ ដូច្នេះហើយ នាំគ្នាក្រាបទៀបបាទា នមស្ការដោយសិរសា គឺត្បូង ។

គ្រានោះ អាចារ្យពោលនឹងតាបសទាំងនោះថា បាទាំងឡាយ ទេយ្យធម៌ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយរបស់យើងមិនមាន ព្រះមានព្រះភាគយាងមកក្នុងពេលភិក្ខាចារ ព្រោះហេតុនោះ ពួកយើងនឹងថ្វាយទេយ្យធម៌តាមកម្លាំង ចូរពួកអ្នកនាំផលាផលដ៏ប្រណីត ដែលអ្នកទាំងឡាយនាំមកហើយមកចុះ ដូច្នេះហើយ ឲ្យនាំផ្លែឈើមក លាងដៃហើយ ដាក់ក្នុងបាត្ររបស់ព្រះតថាគតដោយខ្លួនឯង ។

គ្រាន់តែព្រះសាស្តាទទួលផ្លែឈើប៉ុណ្ណោះ ទេវតាទាំងឡាយ ក៏ដាក់នូវទិព្វឱជាចូល តាបសត្រងទឹកថ្វាយដោយខ្លួនឯងនោះឯង ។ លំដាប់នោះ កាលព្រះសាស្តាសោយស្រេចហើយ ទើបតាបសជាអាចារ្យ ហៅអន្តេវាសិកទាំងឡាយមក អង្គុយពោលសារាណីយកថាក្នុងសម្នាក់របស់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា ចូរភិក្ខុទាំងឡាយមក ។ ភិក្ខុទាំងឡាយ

ដែលជាព្រះទីណាស្រេចប្រមាណ ១ សែនរូប ដឹងព្រះតម្រិះរបស់ព្រះសាស្តា ហើយ នាំគ្នាមកថ្វាយបង្គំព្រះសាស្តា ហើយឈរក្នុងចំណែកម្ខាង ។

លំដាប់នោះ នន្ទតាបសហៅអន្តេវាសិកទាំងឡាយមកហើយ ពោលថា បាទាំងឡាយ អាសនៈដែលព្រះពុទ្ធគង់នៅទាបនៅឡើយ អាសនៈរបស់សមណៈ ១ សែនរូបក៏មិនមាន ថ្ងៃនេះ អ្នកទាំងឡាយ គួរធ្វើសក្ការៈដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃឲ្យឧឡារ អ្នកទាំងឡាយ ចូរនាំផ្កាដែលសម្បូរដោយពណ៌ និងក្លិនមកអំពីជើងភ្នំ ។ ព្រោះវិស័យរបស់លោកអ្នកមានឫទ្ធិជាអចិន្តេយ្យ ទើបតាបសទាំងឡាយនាំផ្កាដែលសម្បូរដោយពណ៌ និងក្លិនមកក្នុងរយៈកាលមួយភ្លែតប៉ុណ្ណោះ ក្រាលអាសនៈផ្កាកម្ពស់ប្រមាណ ១ យោជន៍ ថ្វាយព្រះពុទ្ធហើយ ។ សម្រាប់អគ្គសាវក កម្ពស់ប្រមាណ ៣ គាវុត សម្រាប់ភិក្ខុទាំងឡាយដ៏សេស មានកម្ពស់ប្រមាណកន្លះយោជន៍ជាដើម សម្រាប់ភិក្ខុដែលបួសថ្មីក្នុងសង្ឃ មានកម្ពស់ប្រមាណ ១ ឧសភៈ[១] ។

កាលតាបសទាំងឡាយក្រាលអាសនៈស្រេចហើយយ៉ាងនេះ នន្ទតាបសឈរផ្គងអញ្ជលីខាងមុខព្រះតថាគត ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់យាងឡើងកាន់អាសនៈផ្កានេះ គង់ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គអស់កាលយូរ ។ ព្រះមានព្រះភាគគង់លើអាសនៈផ្កាហើយ កាលព្រះសាស្តាគង់ហើយយ៉ាងនេះ ភិក្ខុ

---

១- ១ ឧសភៈ ស្មើនឹង ១៤០ ហត្ថ ៨០ ឧសភៈ ជា ១ គាវុត ៤ គាវុត ជា ១ យោជន៍ ។

ទាំងឡាយដឹងអាការរបស់ព្រះសាស្តាហើយ ទើបអង្គុយលើអាសនៈ ដែលត្រូវបានសម្រាប់ខ្លួន ។ នន្ទតាបសកាន់ឆត្រធំដែលធ្វើអំពីផ្កា ឈរបាំងលើសិរសាព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា សក្ការៈទាំងឡាយរបស់តាបសនេះ ចូរមានផលច្រើន ទើបចូលនិរោធសមាបត្តិ ។ ភិក្ខុទាំងឡាយដឹងថា ព្រះសាស្តាចូលសមាបត្តិហើយ ក៏នាំគ្នាចូលសមាបត្តិផងដែរ ។ ព្រះសាស្តាគង់ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ កាលដល់ពេលភិក្ខាចារ អន្តេវាសិកទាំងឡាយនាំគ្នាបរិភោគមើមឈើ ផ្លែឈើក្នុងព្រៃ ក្នុងកាលដ៏សេស ក៏ឈរផ្គងអញ្ជលីដល់ព្រះសម្ពុទ្ធ ។

ចំណែកនន្ទតាបសមិនព្រមទៅបរិភោគ បាំងឆត្រផ្កា ញុំាងពេលវេលាបញ្ជូនទៅដោយបីតិ និងសុខរហូត ៧ ថ្ងៃ ។ ព្រះសាស្តាចេញអំពីនិរោធហើយត្រាស់ឲ្យសាវកមួយរូបដែលប្រកបដោយអង្គ ២ គឺអង្គរបស់ភិក្ខុអ្នកនៅដោយមិនមានកិលេស ( អរណវិហារី ) និងអង្គនៃភិក្ខុដែលជាទក្ខិ-ណេយ្យបុគ្គលថា ចូរអ្នកធ្វើអនុមោទនាដល់អាសនៈ ដែលសម្រេចដោយផ្កាដល់ពួកឥសី ។ ភិក្ខុរូបនោះ មានចិត្តត្រេកអរហើយ ដូចមេទ័ពធំ បានទទួលព្រះរាជទានលាភធំអំពីសម្នាក់ស្តេចចក្រពត្តិ តាំងនៅក្នុងវិស័យរបស់ខ្លួនហើយ ពិចារណាព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ហើយធ្វើអនុមោទនា ក្នុងទីបំផុតនៃទេសនារបស់ភិក្ខុនោះ ទើបព្រះសាស្តាទ្រង់សម្តែងធម៌ដោយព្រះអង្គឯង ។

ក្នុងកាលចប់ទេសនា តាបស ៤ ម៉ឺន ៤ ពាន់នាក់ សម្រេចអរហត្ត

ទាំងអស់ ព្រះសាស្តាទ្រង់លាព្រះហស្ត ត្រាស់ថា អ្នកទាំងឡាយ ចូរជាភិក្ខុចុះ ។ សក់ និងពុកមាត់របស់តាបសទាំងនោះ ក៏អន្តរធានទៅក្នុងរំពេចនោះឯង ។ បរិក្ខារ ៨ ជណ្តប់ត្រង់កាយគ្រប់គ្រាន់ តាបសទាំងនោះ ដូចព្រះថេរៈមានវស្សា ៦០ ចោមរោមព្រះសាស្តា ។ ចំណែកនន្ទតាបសមិនបានសម្រេចគុណវិសេស ព្រោះមានចិត្តរាយមាយ ។ បានឮថា នន្ទតាបសនោះ ចាប់ផ្តើមពីស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈ ដែលនៅដោយមិនមានកិលេស បានកើតចិត្តប្បាទថា ឱហ្ន៎ អាត្មាអញ គប្បីបាននូវគុណ ដែលសាវកនេះបានហើយ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដែលនឹងកើតឡើងក្នុងអនាគតកាល ។

ដោយបរិវិតក្កនោះ ទើបនន្ទតាបសមិនអាចសម្រេចមគ្គផលបាន ។ តែលោកបានថ្វាយបង្គំព្រះតថាគត ឈរផ្គងអញ្ជលីចំពោះព្រះភក្ត្រ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអ្នកធ្វើអនុមោទនាដល់អាសនៈដែលធ្វើដោយផ្កា ចំពោះពួកឥសីនេះ មានឈ្មោះដូចម្តេច ក្នុងសាសនារបស់ព្រះអង្គ ព្រះសាស្តាត្រាស់ឆ្លើយថា ភិក្ខុនោះឈ្មោះថា ជាអ្នកដល់ហើយនូវតំណែងឯតទគ្គៈ ក្នុងអង្គនៃភិក្ខុដែលនៅដោយមិនមានកិលេស និងក្នុងអង្គនៃភិក្ខុដែលជាទក្ខិណេយ្យបុគ្គល ។ លោកបានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន សក្ការៈនេះ ខ្ញុំព្រះអង្គកាន់ឆត្រផ្កាអស់ ៧ ថ្ងៃ ធ្វើហើយដោយអធិការនោះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ តែក្នុងអនាគតកាល ខ្ញុំព្រះអង្គ គប្បីជាសាវកដែលប្រកបដោយអង្គ ២ ដូចព្រះថេរៈនេះ ក្នុង

សាសនារបស់ព្រះពុទ្ធអង្គណាមួយចុះ ។

ព្រះសាស្តាទ្រង់បញ្ជូនអនាគតំសញ្ញាណទៅ ពិចារណាមើលថា សេចក្តីប្រាថ្នារបស់តាបសនេះសម្រេចឬហ្ន៎ ទ្រង់ប្រមើលមើល ទ្រង់ឃើញសេចក្តីប្រាថ្នារបស់តាបសសម្រេច ក្នុងកាលកប្បកន្លងទៅហើយមួយសែន ទើបត្រាស់ថា ម្នាលតាបស សេចក្តីប្រាថ្នារបស់អ្នកមិនទទេឡើយ ក្នុងអនាគតកាលកន្លងទៅមួយសែនកប្ប ព្រះពុទ្ធព្រះនាមគោតម នឹងកើតឡើងក្នុងលោក សេចក្តីប្រាថ្នារបស់អ្នកនឹងសម្រេច ក្នុងសម្នាក់របស់ព្រះពុទ្ធ ព្រះនាមគោតមនោះ ត្រាស់ធម្មកថាហើយ មានភិក្ខុសង្ឃចោមរោម ហោះទៅកាន់អាកាស ។

នន្ទតាបសបានឈរផ្គងអញ្ជលី ឧទ្ទិសចំពោះព្រះសាស្តា និងភិក្ខុសង្ឃរហូតដល់ដាច់កន្ទុយភ្នែក ក្នុងកាលតមក លោកចូលទៅគាល់ព្រះសាស្តាស្តាប់ធម្មកថាតាមកាល មានឈានមិនសាបសូន្យ ធ្វើកាលកិរិយា ទៅកើតក្នុងព្រហ្មលោក ។ ចុតិចាកព្រហ្មលោកនោះហើយ បួសក្នុងព្រៃអស់ ៥០០ ជាតិទៀត ។ ក្នុងសាសនារបស់ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ក៏បានបួសនៅព្រៃជាវត្ត បំពេញគតបច្ចាគតវត្តឲ្យបរិបូណ៌ ។ បានឮថា បុគ្គលដែលមិនបានបំពេញវត្តនេះ មិនសម្រេចដល់ភាពជាមហាសាវកបានឡើយ ឯគត-បច្ចាគតវត្ត គប្បីជ្រាបដោយន័យដែលលោកពោលក្នុងអដ្ឋកថា នៃព្រះសូត្រទាំងឡាយហើយ លោកបំពេញគតបច្ចាគតវត្តអស់ ២០០០០ ឆ្នាំ កើតក្នុងស្ថានតាវត្តិង្សទេវលោក ។

នន្ទតាបសនោះ សោយទិព្វសម្បត្តិដោយអំណាចនៃការកើតផ្កាស់ប្ដូរគ្នា ក្នុងស្ថានតាវត្តិង្ស ដោយប្រការដូច្នេះ ចុតិចាកតាវត្តិង្សពិភពនោះហើយ បាន ជាស្ដេចចក្រពត្តិ និងជាស្ដេចបទេសរាជ្យ ក្នុងមនុស្សលោករាប់រយជង សោយមនុស្សសម្បត្តិដ៏ឧឡារ តមក ក្នុងសាសនារបស់ព្រះមានព្រះភាគ នៃយើងទាំងឡាយ កើតជាប្អូនប្រុសរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងផ្ទះសុមន-សេដ្ឋី ក្នុងក្រុងសាវត្ថី មានឈ្មោះថា សុភូតិ ។

សម័យនោះ ព្រះមានព្រះភាគនៃយើងទាំងឡាយ កើតឡើងហើយ ក្នុងលោក ទ្រង់ប្រកាសធម្មចក្រ យាងទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ទ្រង់ធ្វើនូវការអនុគ្រោះសត្វលោក ដោយការទទួលវិហារវេឡុវ័នជាដើម ក្នុង ក្រុងរាជគ្រឹះនោះ អាស្រ័យក្រុងរាជគ្រឹះ គង់នៅក្នុងព្រៃសីតវ័ន ។ កាល នោះ អនាថបិណ្ឌិកសេដ្ឋី នាំរបស់របរដែលកើតអំពីការធ្វើក្នុងនគរសាវត្ថី ទៅកាន់ផ្ទះរបស់រាជគហសេដ្ឋី ជាសម្លាញ់របស់ខ្លួន[1] ស្ដាប់ដំណឹងការកើត ឡើងនៃព្រះពុទ្ធ ទើបចូលទៅគាល់ព្រះសាស្ដា ដែលគង់នៅក្នុងព្រៃសីតវ័ន តាំងនៅក្នុងសោតាបត្តិផល ដោយការចូលគាល់លើកដំបូងនោះឯង ហើយ ទូលសូមឲ្យព្រះសាស្ដាយាងមកនគរសាវត្ថី ។ ឲ្យគេធ្វើព្រះវិហារមួយយោជន៍ ១ ក្នុងចម្ងាយផ្លូវ ៤៥ យោជន៍ ដោយការបរិច្ចាគទ្រព្យ មួយសែន មួយ កន្លែង អំពីក្រុងសាវត្ថីនោះ ។ ទិញឧទ្យានរបស់ព្រះរាជកុមារ ព្រះនាម ជេត ប្រមាណ ៨ ករីស ដោយមាត្រាសម្រាប់វាស់ ដោយយកប្រាក់រាប់

---

១- វិនយបិដក សេនាសនក្ខន្ធកៈថា អនាថបិណ្ឌិកសេដ្ឋីជាប្អូនថ្លៃរបស់រាជគហសេដ្ឋី។

កោជិក្រាលផែនដី ។ ក្នុងថ្ងៃដែលព្រះសាស្តាទទួលវិហារ សុភូតិកុដុម្ពិកៈនេះបានទៅជាមួយអនាថបិណ្ឌិកសេដ្ឋី ស្តាប់ធម្មទេសនាហើយ មានសទ្ធាបួស ។

លោកឧបសម្បទាហើយ ធ្វើមាតិកាពីរឲ្យស្ទាត់ ឲ្យអាចារ្យប្រាប់កម្មដ្ឋានបំពេញសមណធម៌ក្នុងព្រៃ ចម្រើនវិបស្សនា មានមេត្តាឈានជាបាទ សម្រេចអរហត្តហើយ ។ ព្រោះកាលលោកសម្តែងធម៌ រមែងមិនសម្តែងធម៌មិនចំពោះតាមទំនងដែលព្រះសាស្តាទ្រង់សម្តែង ហេតុនោះ ទើបលោកបានឈ្មោះថាជាកំពូលជាងភិក្ខុទាំងឡាយ ខាងមិនមានសត្រូវ ។ កាលត្រាច់បិណ្ឌបាតក៏ចូលឈានផ្សាយមេត្តាទៅគ្រប់ៗ ផ្ទះ ចេញអំពីឈានហើយ ទើបទទួលភិក្ខា ដោយគិតថា ដោយវិធីនេះ ទាយកទាំងឡាយ នឹងមានផលច្រើន ព្រោះហេតុនោះ ទើបព្រះថេរៈឈ្មោះថា ជាកំពូលជាងភិក្ខុទាំងឡាយ ខាងទក្ខិណេយ្យបុគ្គល ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់តាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈ ដែលប្រកបដោយអង្គពីរថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនៅដោយឥតកិលេស ដែលជាសាវ័ករបស់តថាគត ស្រេចនឹងសុភូតិប្រសើរជាងគេ ។ ពួកភិក្ខុអ្នកគួរដល់ទក្ខិណាទាន ស្រេចនឹងសុភូតិ ដូច្នេះ ។

ព្រះមហាថេរៈនេះ សម្រេចអរហត្តដែលជាទីបំផុត នៃផលរបស់បារមីដែលខ្លួនបានបំពេញមក ជាអ្នកឈ្មោសក្នុងលោក ត្រាច់ចារិកទៅតាមជនបទដើម្បីបំពេញប្រយោជន៍ដល់មហាជន ដល់ក្រុងរាជគ្រឹះហើយដោយលំដាប់ដោយប្រការដូច្នេះ ។

ព្រះបាទពិម្ពិសារ ទ្រង់ស្តាប់ការមករបស់ព្រះថេរៈហើយ យាងចូលទៅរក ទ្រង់ថ្វាយបង្គំហើយ ត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះឯង ខ្ញុំនឹងធ្វើលំនៅប្រគេន ដូច្នេះហើយ ក៏ចៀសចេញទៅ ហើយទ្រង់ក៏ភ្លេច ។ ព្រះថេរៈកាលមិនបានសេនាសនៈ ក៏ញុំាងកាលឲ្យកន្លងទៅក្នុងទីវាល ។ ដោយអានុភាពរបស់ព្រះថេរៈ ភ្លៀងមិនធ្លាក់ឡើយ ។

មនុស្សទាំងឡាយត្រូវភ្លៀងរាំងគំរាម ទើបនាំគ្នាទៅតវ៉ាត្រង់ទ្វាររាជវាំងរបស់ព្រះរាជាៗ ទ្រង់ពិចារណាថា ដោយហេតុអ្វីហ្ន៎ ទើបភ្លៀងមិនធ្លាក់ ហើយទ្រង់ព្រះតម្រិះថា ប្រហែលជាព្រះថេរៈនៅកណ្តាលវាល ទើបភ្លៀងមិនធ្លាក់ ហើយត្រាស់ឲ្យធ្វើកុដិ ប្រក់ដោយស្លឹកឈើប្រគេនព្រះថេរៈ ហើយត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងកុដិស្លឹកនេះចុះ ទ្រង់ថ្វាយបង្គំហើយ ចៀសចេញទៅ ។ ព្រះថេរៈទៅកាន់កុដិហើយ អង្គុយពត់ភ្នែនលើអាសនៈដែលក្រាលដោយស្មៅ ក្នុងកាលនោះ តំណក់ភ្លៀងតូចៗក៏ធ្លាក់មក បន្តិចបន្តួច មិនសើមទូទៅ ។

គ្រានោះ ព្រះថេរៈបំណងបំបាត់នូវភ័យ ដែលកើតអំពីភ្លៀងដល់សត្វលោក កាលប្រាប់ឲ្យដឹងថា លោកមិនមានអន្តរាយអំពីខាងក្នុង និងខាងក្រៅ ទើបពោលគាថាថា **ឆន្នា មេ កុដិកា** ដូច្នេះជាដើម ។ សេចក្តីនៃពាក្យជាគាថានោះ លោកពោលហើយ ក្នុងថេរគាថានោះឯង ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមហាថេរៈទាំងនោះ ប្រកាសនូវគុណរបស់ខ្លួន ឆ្លើយថា ព្រះអរិយៈទាំងឡាយប្រាថ្នាតិចក្រៃលែង ពិចារណា

ឃើញថា លោកុត្តរធម៌ដែលខ្លួនសម្រេចហើយ ជាធម៌ស្ងប់ ជាធម៌ប្រណីតក្រៃលែង ជ្រាលជ្រៅក្រៃលែង ដែលខ្លួនមិនធ្លាប់សម្រេចដោយកាលយូរនេះ ទើបប្រកាសគុណរបស់ខ្លួនដើម្បីសម្តែងឧទាន ដែលកម្លាំងបីតិជាស់តឿនឲ្យអាចហ៊ាន និងដើម្បីសម្តែងការៈដែលព្រះសាសនា ជាធម៌នាំសត្វចេញចាកទុក្ខ ។ ដូចព្រះលោកនាថ ទ្រង់ប្រកាសនូវគុណរបស់ព្រះអង្គ តាមអធ្យាស្រ័យរបស់សត្វ ដែលនឹងត្រាស់ដឹងដោយន័យថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយទសពលញ្ញាណ ជាអ្នកក្លៀវក្លាក្នុងវេសារជ្ជញ្ញាណ ដូច្នេះជាដើម យ៉ាងណា សូម្បីគាថាព្យាករអរហត្តផលរបស់ព្រះថេរនេះ ក៏យ៉ាងនោះ ។

លោកបានសម្រេចអរហត្តផល និងបានទទួលតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតសោមនស្ស កាលនឹងប្រកាសអបទានដែលខ្លួនប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យជាដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ហិមវន្តស្ស** សេចក្តីថា ក្នុងទីមិនឆ្ងាយ គឺក្នុងទីជិត បានដល់ ត្រង់ជើងនៃភ្នំហិមាល័យ អធិប្បាយថា ក្នុងទីសញ្ចរដែលសម្បូរដោយការទៅមករបស់មនុស្ស ។ បទថា **និសភោ នាម បព្វតោ** ក្លាប់សេចក្តីថា មានភ្នំឈ្មោះនិសភៈ ព្រោះប្រសើរជាងភ្នំទាំងឡាយ ។ បទថា **អស្សមោ សុកតោ មយ្ហំ** សេចក្តីថា បានសាងដោយល្អនូវអាស្រមគឺលំនៅក្នុងព្រៃ ដើម្បីជាលំនៅរបស់ខ្ញុំត្រង់ភ្នំនោះ អធិប្បាយថា សាងយ៉ាង

ល្អដោយ មានកុដិជាទីសម្រាកពេលយប់ និងពេលថ្ងៃ មានរបងព័ទ្ធដោយជុំវិញជាដើម ។ បទថា **បណ្ណសាលា សុមាបិតា** សេចក្តីថា មានសាលាដែលប្រក់ដោយស្លឹកឈើ សាង គឺសាងរៀបរយ ដើម្បីជាទីអាស្រ័យរបស់ខ្ញុំ ។

បទថា **កោសិយោ នាម នាមេន** សេចក្តីថា ដោយឈ្មោះដែលមាតាបិតាដាក់ឲ្យថា កោសិយៈ ។ ភ្ជាប់សេចក្តីថា មានតបៈដ៏ឧក្រិដ្ឋ គឺមានតេជះប្រាកដ បានដល់ មានតេជះខ្លាំងក្លា ។ ប្រព្រឹត្តតែម្នាក់ឯង គឺខ្ញុំម្នាក់ឯងប៉ុណ្ណោះ ឥតមានបុគ្គលជាទីពីរ គឺមិនមានតាបសជាគម្រប់ពីរ ជាជដិល គឺជាអ្នកចងជដា បានដល់ តាបសអាស្រ័យនៅ គឺស្នាក់នៅត្រង់ភ្នំឈ្មោះនិសភៈ ក្នុងកាលនោះ គឺក្នុងពេលនោះ ។

បទថា **ផលំ មូលញ្ច បណ្ណញ្ច ន ភុញ្ជាមិ អហំ តទា** សេចក្តីថា ក្នុងកាលនោះ គឺក្នុងកាលដែលខ្ញុំនៅត្រង់និសភបព៌តនោះ ខ្ញុំមិនបរិភោគផ្លែឈើ មើមដំឡូង និងស្លឹកឈើដែលបេះអំពីដើម កាលសម្តែងដល់សេចក្តីនោះថា បើដូច្នោះ តើរស់នៅបានដូចម្តេច ទើបពោលថា **បវត្តំវ សុបាតាហំ** ដូច្នេះ ។ ភ្ជាប់សេចក្តីថា គឺក្នុងកាលនោះ ខ្ញុំអាស្រ័យស្លឹកឈើជាដើមដែលមានក្នុងទីនោះៗ គឺកើតឯងជ្រុះឯង គឺជ្រុះតាមសភាវៈរបស់វា ជាអាហារចិញ្ចឹមជីវិត គឺតម្កល់ជីវិត ។ ម្យ៉ាងទៀត បាលីថា **បវត្តបណ្ឌុបណ្ណានិ** ដូច្នេះក៏មាន សេចក្តីថា ខ្ញុំអាស្រ័យស្លឹកឈើទុំដែលជ្រុះឯងចិញ្ចឹមជីវិត ។

បទថា **នាហំ កោបេមិ អាជីវំ** សេចក្តីថា ខ្ញុំកាលទឹងលះបង់ជីវិត គឺ

ទោះធ្វើការលះបង់ជីវិត ក៏មិនញុំាងសម្មាអាជីវៈឲ្យកម្រើក គឺឲ្យវិនាសព្រោះការស្វែងរកអាហារ មានមូលផលាផលជាដើម ដោយអំណាចតណ្ហា ។ បទថា **អារាធេមិ សកំ ចិត្តំ** សេចក្ដីថា រមែងញុំាងចិត្តរបស់ខ្លួនឲ្យត្រេកអរ គឺឲ្យជ្រះថ្លាក្នុងការប្រាថ្នាតិច និងសន្ដោស ។ បទថា **វិវជ្ជេមិ អនេសនំ** សេចក្ដីថា ខ្ញុំវៀរ គឺនៅឆ្ងាយអំពីអានេសនៈ គឺការស្វែងរកមិនសមគួរ ដោយអំណាចវេជ្ជកម្ម និងទូតកម្មជាដើម ។

បទថា **រាគូបសំហិតំ ចិត្តំ** សេចក្ដីថា កាលណា គឺក្នុងកាលណាចិត្តរបស់ខ្ញុំសម្បយុត្តដោយរាគៈ កើតឡើង ក្នុងកាលនោះ ខ្ញុំប្រាប់ខ្លួនឯង គឺពិចារណាដោយខ្លួនឯង គឺពិចារណាដោយញាណហើយ បន្ទោបង់ចោល ។ បទថា **ឯកគ្គោ តំ ទមេមហំ** សេចក្ដីថា ខ្ញុំជាអ្នកមានចិត្តឯក តាំងមាំក្នុងអារម្មណ៍នៃកម្មដ្ឋានណាមួយ ទូន្មាន គឺធ្វើនូវការទូន្មានចិត្តនោះ គឺចិត្តដែលប្រកបដោយរាគៈ ។

បទថា **រជ្ជសេ រជ្ជនីយេ ច** សេចក្ដីថា អ្នកមានតម្រេក គឺជាបុគ្គលដែលនៅក្នុងអារម្មណ៍ ជាទីតាំងនៃតម្រេក គឺក្នុងវត្ថុ មានរូបារម្មណ៍ជាដើម ។ បទថា **ទុស្សនីយេ ច ទុស្សសេ** សេចក្ដីថា អ្នកអាក់អន់ក្នុងអារម្មណ៍ ដែល

ជាទីអាក់អន់ គឺក្នុងវត្ថុដែលធ្វើឲ្យកើតទោសៈ ។ បទថា **មុយ្ហសេ មោហនីយេ** ៥ សេចក្តីថា អ្នកជាអ្នកវង្វេង គឺជាអ្នកវង្វេងក្នុងអារម្មណ៍ ដែលជាទីតាំងនៃការវង្វេង គឺក្នុងវត្ថុដែលធ្វើឲ្យកើតនូវការវង្វេង ភ្ជាប់សេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំទូន្មានខ្លួនយ៉ាងនេះថា ចូរអ្នកចេញអំពីព្រៃទៅ គឺចៀសចេញអំពីការនៅព្រៃ ។

បទថា **តិម្ពរុសកវណ្ណាភោ** សេចក្តីថា ព្រះពុទ្ធមានរស្មី ដូចផ្លែទន្លាប់ពណ៌មាស អធិប្បាយថា មានពណ៌ដូចមាសជម្ពូនទ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាសុភូតិត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឧបាសកាត្ថេរាបទានទី ២

[ ២៤ ] ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។ មហាជនមកជួបជុំគ្នា បូជាព្រះតថាគត ធ្វើជើងថ្ករដ៏វិចិត្រ ហើយលើកតម្កល់ព្រះសរីរៈ ។ ពួកមហាជនទាំងនោះ ព្រមទាំងទេវតានិងមនុស្ស លុះធ្វើព្រះសរីរកិច្ចរួចហើយ ប្រមូលព្រះធាតុត្រង់កន្លែងជើងថ្ករនោះ មកធ្វើព្រះពុទ្ធស្តូប ។ ជាន់ទី ១ ធ្វើដោយមាស ជាន់ទី ២ ធ្វើដោយកែវមណី ជាន់ទី ៣ ធ្វើដោយប្រាក់ ជាន់ទី ៤ ធ្វើដោយកែវផលិក ។ ជាន់ទី ៥ នៃព្រះស្តូបនោះ ធ្វើដោយកែវទទឹម ជាន់ទី ៦ ធ្វើដោយកែវមរកត ខាងលើធ្វើដោយរតនៈគ្រប់យ៉ាង ។ ទ្រនាប់ខ្សាច់ ( នៃព្រះស្តូប ) ធ្វើដោយកែវមណី បង្កាន់ដៃ ធ្វើដោយកែវ តួព្រះស្តូប ធ្វើដោយមាសសុទ្ធទាំងអស់ កម្ពស់ឡើងទៅលើ មួយយោជន៍ ។ កាលនោះទេវតាមកជួបជុំគ្នាត្រង់កន្លែងនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ជាតាទិបុគ្គល ។ ព្រះធាតុឥតមានបែកខ្ញែកចេញពីគ្នា ព្រះសរីរធាតុនៅជាដុំមួយ ( បើដូច្នោះ ) ពួកយើងនឹងធ្វើព្រះស្តូប ស្រោបលើព្រះពុទ្ធស្តូបនេះ ។ ពួកទេវតា បានបង្កើនកម្ពស់មួយយោជន៍ដទៃទៀត ដោយកែវ

ទាំង ៧ ប្រការ ព្រះស្តូបនោះទៅជាមានកម្ពស់ ២ យោជន៍ តែងកម្ចាត់បង់នូវងងឹត សព្វៗ កាល ។ គ្រានោះ ពួកនាគមក ជួបជុំគ្នា ត្រង់កន្លែងព្រះស្តូបនោះហើយ ប្រឹក្សាជាមួយគ្នាថា ពួក មនុស្ស និងទេវតា បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ។ ពួកយើង កុំប្រហែសឡើយ ព្រោះមនុស្ស និងទេវតា មិនប្រហែស បើ ដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គ ជាតាទិបុគ្គល ។ ពួកនាគទាំងនោះ ប្រមូលកែវឥន្ទនិល កែវ មហានិល ទាំងកែវមណី មានរស្មីរុងរឿង ក្នុងទីជាមួយគ្នាហើយ ស្រោបព្រះពុទ្ធស្តូប ។ ព្រះពុទ្ធចេតិយទាំងមូល ប្រដាប់ដោយកែវ មណី មានកម្ពស់ ៣ យោជន៍ តែងផ្សាយចេញនូវពន្លឺ ក្នុងកាល នោះ ។ កាលនោះ ពួកគ្រុឌមកជួបជុំគ្នាហើយ ប្រឹក្សាជាមួយគ្នា ថា ពួកមនុស្ស ទេវតា និងនាគទាំងឡាយ បានធ្វើព្រះស្តូបថ្វាយ ព្រះពុទ្ធ ។ ពួកយើងកុំប្រហែសឡើយ ព្រោះមនុស្ស និងទេវតា ទាំងឡាយ មិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។ គ្រុឌទាំងនោះបាន ធ្វើព្រះស្តូប ប្រដាប់ដោយកែវមណីសុទ្ធ ឲ្យជាគ្រឿងស្រោប មានទំហំប៉ុនគ្នា ពួកគ្រុឌទាំងនោះ បានធ្វើពុទ្ធចេតិយ ឲ្យមាន កម្ពស់កើនមួយយោជន៍ទៀត ។ ព្រះពុទ្ធស្តូបទៅជាមានកម្ពស់ ៤ យោជន៍ រុងរឿង ញុំាងទិសទាំងអស់ឲ្យភ្លឺដូចព្រះអាទិត្យ ដែលរះ

ឡើង ។ កាលនោះ ពួកកុម្ភណ្ឌមកជួបជុំគ្នា ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ និងគ្រុឌទាំងឡាយ បាននាំគ្នាធ្វើព្រះស្តូបដ៏ថ្លៃថ្លា ថ្វាយព្រះពុទ្ធដ៏ប្រសើរផ្សេងៗ គ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្ស និងទេវតាទាំងឡាយ មិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូប ថ្វាយព្រះលោកនាថព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយ ដោយកែវទាំងឡាយតទៅទៀត ។ ពួកកុម្ភណ្ឌទាំងនោះ បានធ្វើពុទ្ធចេតិយឲ្យកើនកម្ពស់មួយយោជន៍ទៅទៀត ព្រះស្តូបទៅជាមានកម្ពស់ ៥ យោជន៍ តែងរុងរឿង ក្នុងកាលនោះ ។ លំដាប់នោះ ពួកយក្ខមកជួបជុំគ្នា ត្រង់កន្លែងព្រះស្តូបនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ កុម្ភណ្ឌ និងគ្រុឌទាំងឡាយ បានធ្វើព្រះស្តូបដ៏ថ្លៃថ្លា ថ្វាយព្រះពុទ្ធដ៏ប្រសើរផ្សេងៗ គ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្ស និងទេវតាទាំងឡាយ មិនប្រហែស ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយ ដោយកែវផលិកតទៅទៀត ។ ពួកយក្ខទាំងនោះ បានធ្វើពុទ្ធចេតិយឲ្យកើនកម្ពស់មួយយោជន៍ទៅទៀត ព្រះស្តូបទៅជាមានកម្ពស់ ៦ យោជន៍ តែងរុងរឿង ក្នុងកាលនោះ ។ គ្រានោះ ពួកគន្ធព្វប្រជុំប្រឹក្សាក្នុងទីជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ គ្រុឌ កុម្ភណ្ឌ និងយក្ខ

ទាំងឡាយ ទាំងអស់គ្នា បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ឯពួកយើង មិនបានធ្វើព្រះស្តូបក្នុងទីនោះឡើយ បើដូច្នោះ ពួកយើងនឹងធ្វើ ព្រះស្តូប ថ្វាយព្រះលោកនាថ ព្រះអង្គជាតាទិបុគ្គល ។ ពួកគន្ធព្វ ទាំងនោះ បានធ្វើថ្នាក់ ៧ ជាន់ ដរាបតាំងពីទ្រនាប់ខ្សាច់ឡើងទៅ បានធ្វើព្រះស្តូបសុទ្ធតែជាវិការនៃមាសទាំងអស់ ក្នុងកាលនោះ ។ ព្រះស្តូបទៅជាមានកម្ពស់ ៧ យោជន៍ តែងរុងរឿង ក្នុងកាលនោះ គេឥតដឹងថា យប់ថ្ងៃ ព្រោះពន្លឺមាននៅសព្វៗ កាល ។ ព្រះចន្ទ្រ ព្រះអាទិត្យ ព្រមទាំងពួកផ្កាយ គ្របសង្កត់ពន្លឺព្រះស្តូបនោះមិន បាន ឯប្រទីប រុងរឿងតែក្នុងទីចម្ងាយ ១០០ យោជន៍ជុំវិញ ។ ក្នុងកាលនោះ មនុស្សទាំងឡាយណាមួយ បូជាព្រះស្តូប មនុស្ស ទាំងនោះ មិនឡើងកាន់ព្រះស្តូប មនុស្សទាំងនោះ តែងបោះទៅ ឰដ៏អាកាស ។ មានយក្ខមួយ ឈ្មោះអភិសម្មតៈ ដែលពួក ទេវតាតាំងទុកហើយ ចាំទទួលទង់ ឬកម្រងផ្កា ឰដ៏ខាងលើ ។ មនុស្សទាំងនោះ មិនឃើញយក្ខនោះទេ ឃើញតែកម្រងនៃផ្កា អណ្តែតទៅ លុះឃើញកម្រងផ្កាទាំងនោះហើយ ក៏ដើរទៅ ពួក មនុស្សទាំងអស់នោះឯង តែងទៅកាន់សុគតិ ។ ពួកមនុស្ស ទាំង អ្នកខុសក្នុងសាសនា ទាំងអ្នកជ្រះថ្លាក្នុងសាសនា ដែលចង់ ឃើញបាដិហារ តែងបូជាព្រះស្តូប ។ គ្រានោះ ខ្ញុំកើតជាអ្នកកម្សត់ នៅក្នុងក្រុងហង្សវតី បានឃើញជនរីករាយហើយ ក៏គិតយ៉ាងនេះ

ក្នុងកាលនោះថា ព្រះស្តូប ដែលបញ្ចុះព្រះសរីរធាតុ ប្រាកដដូច នេះ របស់ព្រះមានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនុ៎ះ មានបុណ្យដ៏លើសលុប ពួកជននេះ មានចិត្តត្រេកអរហើយ ចំពោះជនអ្នកធ្វើនូវសក្ការៈ រមែងមិនក្តៅក្រហាយ ។ អាត្មាអញ នឹងធ្វើសក្ការៈ ថ្វាយព្រះលោកនាថ ជាតាទិបុគ្គលដែរ នឹងបានជា ព្រះទាយាទក្នុងធម៌ របស់ព្រះលោកនាថអង្គនោះ ក្នុងកាលជា អនាគត ។ ខ្ញុំក៏លើកឡើងនូវសំពត់របស់ជាងជ្រលក់ ដែលបោក គក់យ៉ាងស្អាត ព្យួរនឹងចុងឫស្សី ហើយលើកឡើងជាទង់ ឰដ៏ អាកាស ។ អភិសម្មតយក្ស រីករាយកាន់ទង់របស់ខ្ញុំ ( បិតនៅ ) ឰដ៏អាកាស ខ្ញុំឃើញទង់ ដែលត្រូវខ្យល់បក់រវិចហើយ ក៏ញ៉ាំង សេចក្តីរីករាយ ឲ្យកើតដោយក្រៃលែង ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាចំពោះ ទង់នោះហើយ ក៏ចូលទៅរកព្រះសមណៈ ថ្វាយបង្គំ ទូលសួរនូវ ផលទង់នឹងភិក្ខុនោះ ។

ភិក្ខុនោះ សម្តែងនូវកិរិយាកើតឡើង នៃសេចក្តីត្រេកអរ និងបីតិរបស់ខ្ញុំ ប្រាប់ខ្ញុំថា អ្នកនឹងបានទទួលផលរបស់ទង់នោះ សព្វៗ កាល ។ សេនាមានអង្គ ៤ គឺដំរី សេះ រថ ពលថ្មើរ ជើង នឹងចោមរោមអ្នកអស់កាលជានិច្ច នេះជាផលនៃការថ្វាយ ទង់ ។ តូរ្យតន្ត្រី ៦០ ពាន់ និងស្គរ ដែលគេតាក់តែងយ៉ាងល្អ នឹង ចោមរោមអ្នក អស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។

ពួកនារី ៨៦ ពាន់ មានខ្លួនតាក់តែងយ៉ាងល្អ មានសំពត់ និង គ្រឿងអម្ពរដ៏វិចិត្រ ពាក់កែវមណី និងកុណ្ឌល ។ ពួកនារីទាំង នោះ មានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ មានជង្គង់ខ្លួនរៀវល្អ នឹងចោមរោមអ្នក អស់កាលជានិច្ច នេះជា ផលនៃការថ្វាយទង់ ។ អ្នកនឹងរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប នឹងបានសោយទេវរាជ្យ ជាធំជាងទេវតាអស់ ៨០ ដង ។ នឹងបានជាស្តេចចក្កពត្តិ អស់មួយពាន់ដង នឹងសោយប្រទេស-រាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ កន្លងទៅមួយ សែនកប្ប ព្រះសាស្តា ព្រះនាមគោតម ទ្រង់សម្ភពក្នុងឱក្កាក-ត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ អ្នកនឹងច្យុតចាកទេវលោកមក ត្រូវកុសលមូលដាស់តឿន ប្រកបដោយបុញ្ញកម្ម នឹងកើតជា ព្រាហ្មណ៍ ។ អ្នកនឹងលះបោលទ្រព្យ ៨០ កោដិ និងទាសកម្មករ ជាច្រើន ហើយបួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះ នាមគោតម ។ អ្នកនឹងមានឈ្មោះថាឧបវាណៈ ញុំាងព្រះសម្ពុទ្ធ ព្រះនាមគោតមដ៏ប្រសើរជាងពួកសក្យៈ ឲ្យប្រោសប្រាណ ហើយ នឹងបានជាសាវ័ក របស់ព្រះសាស្តា ។

កុសលកម្មដែលខ្ញុំធ្វើហើយ ក្នុងរវាងមួយសែនកប្ប បានឲ្យ ផលដល់ខ្ញុំ ក្នុងជាតិនេះ ខ្ញុំផុតស្រឡះហើយ ( ចាកអាសវធម៌ ) ដូចសម្ទុះនៃព្រួញ ( ដែលផុតស្រឡះចាកធ្នូ ) ខ្ញុំដុតបំផ្លាញនូវ

កិលេសទាំងឡាយរបស់ខ្ញុំហើយ ។ កាលដែលខ្ញុំកើតជាស្តេចចក្កពត្តិ ជាឥស្សរៈក្នុងទ្វីបទាំង ៤ ទង់ផុសឡើងក្នុងរវាង ៣ យោជន៍ដោយជុំវិញសព្វៗ កាល ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការថ្វាយទង់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបវាណត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឧបវាណត្ថេរាបទាន ចប់**

# អដ្ឋកថា

## ឧបវាណត្ថេរាបទាន

[ ២៤ ] *អបទានរបស់ព្រះឧបវាណត្ថេរ មានពាក្យផ្តើមថា* **បទុមុត្តរោ ណាម ជិនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលក្រីក្រ ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលព្រះមានព្រះភាគបរិនិព្វានហើយ កាលមនុស្ស ទេវតា នាគ គ្រុឌ កុម្ភណ្ឌ យក្ស និងគន្ធព្វទាំងឡាយ នាំយកព្រះធាតុរបស់ព្រះអង្គមកធ្វើព្រះស្តូប សម្រេចដោយរតនៈទាំង ៧ កម្ពស់ ៧ យោជន៍ កុលបុត្តនោះ បានយកសំពត់ដណ្តប់របស់ខ្លួន ដែលស្អាតបរិសុទ្ធ ចងត្រង់ចុងឫស្សីធ្វើជាទង់ ហើយធ្វើការបូជា ។ យក្សសេនាបតី ឈ្មោះថា អភិសម្មតកៈ ដែលទេវតាទាំងឡាយផ្តល់តំណែង ដើម្បីរក្សាត្រង់ទីបូជាព្រះចេតិយ មានកាយមិនប្រាកដ កាន់ទង់នោះក្នុងអាកាស ធ្វើប្រទក្សិណព្រះចេតិយ ៣ ជុំ ។ កុលបុត្តនោះឃើញដូច្នោះ មានចិត្តជ្រះថ្លាក្រៃលែង ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ បានឈ្មោះថា ឧបវាណៈ ចម្រើនវ័យហើយ ឃើញពុទ្ធានុភាព ក្នុងកាលទ្រង់ទទួលវត្តជេតពន ជាអ្នកបាននូវសទ្ធាបួសហើយ ធ្វើនូវការចម្រើនវិបស្សនា បានសម្រេចអរហត្ត ជាអ្នកមានអភិញ្ញា ៦ ។ ក្នុងកាលដែលព្រះមានព្រះភាគទ្រង់អាពាធ ព្រះថេរៈ*

បានបង្អោនទឹកក្តៅ ទឹកបាន និងភេសជ្ជៈដែលត្រូវជាមួយរោគ ចូលទៅថ្វាយព្រះមានព្រះភាគ ដោយហេតុនោះ ព្រះរោគរបស់ព្រះសាស្តាក៏ស្ងប់ ។ ព្រះសាស្តា ទ្រង់ធ្វើអនុមោទនាដល់ព្រះថេរៈ ។

ព្រះថេរៈសម្រេចអរហត្ត បានទទួលតំណែងឯតទគ្គៈ[១] យ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះជាដើម ។

ក្នុងសេចក្តីក្នុងគាថានោះថា ព្រះជិនស្រី គឺព្រះមានព្រះភាគ ទ្រង់ឈ្នះមារ ៥ ទ្រង់ព្រះនាមថា បទុមុត្តរៈ ជាអ្នកដល់នូវត្រើយ គឺលោកិយធម៌ និងលោកុត្តរធម៌ទាំងពួង សម្រេចដល់ទីបំផុត គឺព្រះនិព្វាន ទ្រង់បញ្ចេញព្រះពុទ្ធរង្សីដែលមានពណ៌ ៦ ឲ្យភ្លឺស្វាងដូចគំនរភ្លើង ទ្រង់ញុំាងសត្វលោកទាំងពួងឲ្យភ្លឺស្វាងដោយពន្លឺ គឺព្រះសទ្ធម្ម ជាព្រះសម្ពុទ្ធ គឺជាអ្នកត្រាស់ដឹងប្រពៃ ទ្រង់ជាស់ពួកសត្វដែលធ្លាក់ក្នុងការដេកលក់ គឺអវិជ្ជា ឲ្យក្រោកចាកកិលេសនិទ្ទា ព្រមទាំងវាសនា ទ្រង់មានព្រះនេត្រថ្លាល្អ ដូចផ្កាឈូករីក ទ្រង់បរិនិព្វាន គឺបរិនិព្វានដោយកិលេសនិព្វាន ដល់នូវទីដែលមារមិនឃើញ ។

---

១- ក្នុងអង្គុត្តរនិកាយ ឯកនិបាត ឯតទគ្គបាលី មិនមានឈ្មោះរបស់ព្រះថេរៈជាឯតទគ្គៈទេ ។

*បទថា* **ជង្ឃា** *សេចក្តីថា មានជណ្តើរចង ដើម្បីដាក់ឥដ្ឋដែលរៀបក្នុងវេលាធ្វើចេតិយ ។*

*បទថា* **សុភោតំ វេជកោឆាបាំ** *សេចក្តីថា ខ្ញុំបានចងសំពត់ដណ្តប់ដែលបោកល្អហើយ ត្រង់ចុងឫស្សីធ្វើជាទង់លើកឡើង គឺលើកឡើងក្នុងអាកាស គឺក្នុងលម្ហ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ៕*

## អដ្ឋកថាឧបវានត្ថេរាបទាន ចប់

# សុត្តន្តបិដក

## តីណិសរណាគមនិយត្ថេរាបទានទី ៣

[ ២៥ ] ខ្ញុំជាអ្នកបម្រើមាតាបិតា ក្នុងក្រុងចន្ទវតី មាតាបិតារបស់ខ្ញុំខ្វាក់ ខ្ញុំចិញ្ចឹមលោកទាំងនោះ ក្នុងកាលនោះ ។ កាលនោះខ្ញុំទៅក្នុងទីស្ងាត់ អង្គុយគិតយ៉ាងនេះថា អាត្មាអញ កាលចិញ្ចឹមមាតាបិតា ក៏មិនបាននូវបព្វជ្ជា ។ បុគ្គលទាំងឡាយ ដែលត្រូវងងឹតធំបិទបាំងហើយ រមែងឆេះដោយភ្លើង ៣ យ៉ាង គ្មានអ្នកណានីមួយ ជាអ្នកដឹកនាំ ក្នុងភពប្រាកដដូចនេះទេ ។ ឥឡូវនេះព្រះពុទ្ធត្រាស់ឡើងក្នុងលោកហើយ តែងញុំាងសាសនាឲ្យរុងរឿង សត្វអ្នកប្រាថ្នាបុណ្យ អាចនឹងរើខ្លួនបាន ។ ខ្ញុំដល់នូវត្រៃសរណគមន៍ ហើយរក្សាពេញលេញ មានមុខងាកចេញពីទុគ្គតិ ដោយសារអំពើដែលខ្ញុំធ្វើដោយប្រពៃនោះ ។ មានសមណៈមួយអង្គឈ្មោះ និសភៈ ជាអគ្គសាវករបស់ព្រះពុទ្ធ ខ្ញុំបានចូលទៅរកព្រះនិសភៈនោះហើយ ទទួលនូវសរណគមន៍ ។ ក្នុងសម័យនោះអាយុ ( របស់សត្វ ) មានប្រមាណមួយសែនឆ្នាំ ខ្ញុំបានរក្សាសរណគមន៍ឲ្យពេញលេញ អស់កាលប៉ុណ្ណោះដែរ ។ ក្នុងកាលជាទីបំផុតកំពុងប្រព្រឹត្តទៅ ខ្ញុំរឭករឿយៗ នូវសរណគមន៍នោះខ្ញុំបានទៅកាន់ស្ថានតាវត្តិង្ស ដោយសារកុសលកម្ម ដែលខ្ញុំបានធ្វើល្អហើយនោះ ។ ខ្ញុំកាលទៅកើតក្នុងទេវលោកដែលខ្ជាប់ខ្ជួនដោយបុញ្ញកម្ម បើចូលទៅកាន់ប្រទេសណាៗ រមែងបាននូវហេតុ

៨ ប្រការ ( ក្នុងប្រទេសនោះៗ ) ។ គឺគេតែងបូជាខ្ញុំ ក្នុងទិស ទាំងឡាយ ១ ខ្ញុំជាអ្នកមានប្រាជ្ញាមោះមុត ១ ពួកទេវតាទាំង អស់ រមែងប្រព្រឹត្តទៅ ( តាមខ្ញុំ ) ១ ខ្ញុំតែងបាននូវភោគៈ មានចំនួនរាប់មិនបាន ១ ។ ខ្ញុំមានសម្បុរដូចមាស ក្នុងទីទាំងពួង ១ មានបញ្ញាវាងវៃ ១ មិនកម្រើកចាកមិត្រទាំងឡាយ ១ យស របស់ខ្ញុំខ្ពង់ខ្ពស់ ១ ។ ខ្ញុំបានជាធំជាងទេវតា សោយទេវរាជ្យ មានពួកស្រីអប្សរចោមរោម សោយសេចក្តីសុខដ៏ជាទិព្វ អស់ ៨០ ដង ។ បានជាស្តេចចក្កពត្តិ អស់ ៧៥ ដង សោយប្រទេស-រាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ លុះដល់បច្ឆិមកព ខ្ញុំប្រកបដោយបុញ្ញកម្ម កើតក្នុងត្រកូលមហាសាល ដ៏ស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី ។ ខ្ញុំបរិបូរដោយល្បែង មានពួកទារកចោមរោម ចេញចាកទីក្រុងហើយ ចូលទៅកាន់អារាមរបស់សង្ឃ ក្នុងវេលា ល្ងាច ។ ក្នុងអារាមនោះ ខ្ញុំឃើញសមណៈ លោកផុតស្រឡះ ចាកកិលេស មិនមានឧបធិ លោកបានសម្តែងធម៌ដល់ខ្ញុំ ទាំង បានឲ្យសរណគមន៍ដល់ខ្ញុំ ។ ខ្ញុំបានស្តាប់សរណគមន៍ បានរឭក ឃើញនូវសរណគមន៍របស់ខ្ញុំ ខ្ញុំអង្គុយលើអាសនៈមួយ ហើយ បានដល់អរហត្ត ។ ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត បានដល់អរហត្ត ព្រះពុទ្ធមានចក្ខុ ជ្រាបនូវគុណ ( របស់ខ្ញុំ ) ហើយឲ្យឧប-សម្បទាជាភិក្ខុដល់ខ្ញុំ ។ ខ្ញុំបានដល់នូវសរណគមន៍ ក្នុងកប្ប

ប្រមាណមិនបាន អំពីកប្បនេះ ឯអំពើដែលខ្ញុំបានធ្វើហើយ ប៉ុណ្ណោះ បានឲ្យផលដល់ខ្ញុំ ក្នុងសាសនានេះ ។ សរណគមន៍ ខ្ញុំបានរក្សាល្អហើយ ចិត្តខ្ញុំបានតាំងទុកល្អហើយដែរ ខ្ញុំបានទទួលនូវយសទាំងពួង ហើយដល់នូវព្រះនិព្វាន ជាធម្មជាតមិនមានការញាប់ញ័រ ។ អ្នកទាំងឡាយណា មានការប្រុងត្រចៀកស្តាប់ អ្នកទាំងឡាយនោះ ចូរស្តាប់ខ្ញុំពោលចុះ ខ្ញុំនឹងសម្តែងប្រាប់អ្នកទាំងឡាយ នូវអត្ថ គឺ បទដែលខ្ញុំឃើញដោយខ្លួនឯង ។ ព្រះសម្ពុទ្ធត្រាស់ដឹងហើយក្នុងលោក សាសនាព្រះជិនស្រី កំពុងផ្សាយទៅ ស្គរ គឺ អមតនិព្វានជាគ្រឿងបន្ទោបង់នូវសរ គឺសោកព្រះអង្គទូងហើយ ។ អ្នកទាំងឡាយ គប្បីធ្វើនូវការកសាងក្នុងបុញ្ញក្ខេត្តដ៏ប្រសើរ គួរតាមកម្លាំងរបស់ខ្លួនចុះ អ្នកទាំងឡាយ នឹងឃើញនូវការរលត់ទុក្ខ ។ អ្នកទាំងឡាយ គួរទទួលត្រៃសរណគមន៍ រក្សាសីល ៥ ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ នឹងធ្វើទីបំផុតទុក្ខបាន ។ អ្នកទាំងឡាយ គួរធ្វើនូវខ្ញុំឲ្យជាគ្រឿងប្រៀបធៀប ហើយរក្សាសីលទាំងឡាយ មិនយូរប៉ុន្មាន អ្នកទាំងឡាយគ្រប់គ្នា នឹងបានដល់នូវព្រះអរហត្ត ។ ខ្ញុំជាអ្នកមានវិជ្ជា ៣ ជាអ្នកដល់នូវឫទ្ធិ ស្ទាត់ជំនាញក្នុងការកំណត់ដឹងនូវចិត្ត បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំជាសាវករបស់ព្រះអង្គ សូមថ្វាយបង្គំចំពោះព្រះបាទព្រះសាស្តា ។ ខ្ញុំព្រះអង្គបានដល់នូវព្រះពុទ្ធជាទីពឹង ក្នុង

កប្បប្រមាណមិនបានអំពីកប្បនេះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ ( នេះ ) ជាផលនៃការដល់នូវត្រៃសរណគមន៍ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណិសរណាគមនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តីណិសរណាគមនិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## តិណិសរណាគមនិយត្ថេរាបទាន

[ ២៥ ] អបទានរបស់ព្រះតិសរណគមនិយត្ថេរ មានពាក្យផ្ដើមថា **នគរេ ចន្ទវតិយា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលព្រះពុទ្ធព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ក្នុងចន្ទវតីនគរ បានចិញ្ចឹមមាតា និងបិតាដែលខ្វាក់ភ្នែក ។ ថ្ងៃមួយ លោកគិតថា អាត្មាអញចិញ្ចឹមមាតាបិតា ក៏នឹងមិនបានបួស បើដូច្នោះ អញនឹងកាន់យកសរណៈ ៣ ដោយវិធីនេះ អញនឹងផុតចាកទុគ្គតិ ទើបចូលទៅរកអគ្គសាវកឈ្មោះនិសភៈរបស់ព្រះមានព្រះភាគព្រះនាមវិបស្សី ហើយកាន់យកសរណៈ ៣ ។ លោករក្សាសរណៈ ៣ នោះ អស់ ១ សែនឆ្នាំ ដោយកម្មនោះ ទើបកើតក្នុងស្ថានតាវត្តិង្ស ខាងមុខអំពីនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយនូវសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមហាសាល ក្នុងក្រុងសាវត្ថី ដល់នូវភាពជាអ្នកដឹងក្ដីហើយ អាយុ ៧ ឆ្នាំប៉ុណ្ណោះ ចោមរោមទៅដោយកុមារទាំងឡាយ បានទៅកាន់សង្ឃារាមមួយកន្លែង ។ ក្នុងទីនោះ ព្រះថេរៈជាព្រះខីណាស្រពមួយរូប សម្ដែងធម៌ដល់កុលបុត្តនោះហើយ បានឲ្យសរណៈទាំងឡាយ ។ កុលបុត្តនោះ ទទួលសរណៈទាំងនោះហើយ រឭកដល់សរណៈដែលខ្លួនធ្លាប់រក្សា ចម្រើននូវវិបស្សនា សម្រេចអរហត្តហើយ ។ ព្រះមានព្រះភាគ ទ្រង់ឲ្យព្រះថេរៈដែល

សម្រេចអរហត្តហើយ ឧបសម្បទា ។

ព្រះថេរៈសម្រេចអរហត្ត បានឧបសម្បទាហើយ រឭកបុព្វកម្មរបស់ខ្លួន កាលនឹងប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចសោមនស្ស ទើបពោលពាក្យថា **នគរេ ពន្ធុមតិយា** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **មាតុ ឧបដ្ឋាកោ អហុំ** ក្លាប់សេចក្តីថា ខ្ញុំឧបដ្ឋាកមាតាបិតា ក្នុងពន្ធុមតីនគរ ។

បទថា **តមន្ធការបិហិតា** សេចក្តីថា ដែលងងឹត គឺមោហៈបិទបាំង ។ បទថា **តិវិធគ្គីហិ ឌយ្ហរេ** ក្លាប់សេចក្តីថា សត្វទាំងពួងត្រូវភ្លើង ៣ កង គឺ រាគគ្គិ ១ ទោសគ្គិ ១ មោហគ្គិ ១ ដុតហើយ ។

បទថា **អដ្ឋ ហេតូ លភាមហំ** សេចក្តីថា ខ្ញុំបានហេតុ ៨ ប្រការ គឺ ហេតុដែលជាបច្ច័យនៃសេចក្តីសុខ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថាតិសរណាគមនិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បញ្ញាសីលសមាទានិយត្ថេរាបទានទី ៤

[ ២៦ ] គ្រានោះ ខ្ញុំកើតជាបុរសអ្នកស៊ីឈ្នួល ក្នុងក្រុងចន្ទវតី ខ្ញុំរវល់តែនឹងការងាររបស់ជនដទៃ មិនបាននូវបព្វជ្ជា ។ ខ្ញុំគិតថា បុគ្គលទាំងឡាយ ដែលត្រូវងងឹតជំបិទបាំងហើយ រមែងឆេះដោយភ្លើង ៣ យ៉ាង អញគប្បីគេចចេញដោយឧបាយណាហ្ន៎ ។ អញជាមនុស្សកំព្រា ធ្វើនូវការឈ្នួល ទាំងទេយ្យធម៌ របស់អញក៏មិនមាន បើដូច្នោះ គួរតែអញរក្សាសីល ៥ ឲ្យពេញលេញ ។ មានព្រះថេរៈមួយអង្គឈ្មោះនិសភៈ ជាសាវករបស់ព្រះមុនី ព្រះនាមអនោមទស្សី ខ្ញុំក៏ចូលទៅរកព្រះថេរៈអង្គនោះ ហើយទទួលនូវសិក្ខាបទទាំង ៥ ។ ក្នុងសម័យនោះ អាយុ ( របស់សត្វ ) មានប្រមាណមួយសែនឆ្នាំ ខ្ញុំរក្សាសីល ៥ ឲ្យបរិបូណ៌ អស់កាលប៉ុណ្ណោះដែរ ។ លុះមរណកាលមកដល់ព្រមហើយ ទេវតាទាំងឡាយលួងលោមខ្ញុំថា នែអ្នកនិទ្ទុក្ខ រថដែលទឹមដោយសេះមួយពាន់នេះ មកប្រាកដដល់អ្នកហើយ ។ កាលបើចិត្តជាខាងក្រោយ កំពុងប្រព្រឹត្តទៅ ខ្ញុំបានរឭកនូវសីលរបស់ខ្ញុំ ខ្ញុំបានទៅកាន់ស្ថានតាវត្តិង្ស ដោយសារអំពើដែលខ្ញុំធ្វើល្អហើយនោះ ។ ខ្ញុំបានជាធំជាងទេវតា សោយទេវរាជ្យ មានពួកស្ត្រីអប្សរចោមរោម សោយសេចក្តីសុខដ៏ជាទិព្វ អស់ ៣០ ដង ។ ខ្ញុំបានជាស្តេចចក្កពត្តិអស់ ៧៥ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយ

រាប់បានមួយអសង្ខេយ្យជាតិ ។ ខ្ញុំច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន ក៏មកកើតក្នុងត្រកូលមហាសាល ដ៏ស្តុកស្តម្ភ ក្នុងក្រុងវេសាលី ។ កាលសាសនា របស់ព្រះជិនស្រីកំពុងរុងរឿង មាតា និងបិតារបស់ខ្ញុំ បានទទួលនូវសិក្ខាបទទាំង ៥ ក្នុងកាលជិតចូលវស្សា ។ ខ្ញុំបានទទួលសីលជាមួយ ( នឹងមាតា ) ហើយបានរព្រកឃើញនូវសីលរបស់ខ្ញុំ ខ្ញុំអង្គុយលើអាសនៈមួយហើយ បានដល់នូវអរហត្ត ។ ខ្ញុំមានអាយុ ៥ ឆ្នាំអំពីកំណើតបានដល់នូវអរហត្ត ព្រះពុទ្ធមានចក្ខុ ទ្រង់ជ្រាបនូវគុណ ( របស់ខ្ញុំ ) ហើយទ្រង់ឲ្យឧបសម្បទាជាភិក្ខុដល់ខ្ញុំ ។ ខ្ញុំរក្សានូវសិក្ខាបទទាំង ៥ ពេញលេញ ខ្ញុំមិនដែលទៅកាន់កំណើតអសុរកាយអស់កប្ប នឹងប្រមាណមិនបាន អំពីកទ្ទកប្បនេះ ។ ខ្ញុំនោះបានទទួលនូវយស ព្រោះហេតុនៃសីលទាំងនោះ ខ្ញុំកាលសម្តែងនូវកោដិនៃកប្ប គប្បីសម្តែងជាឯកទេស ( មួយចំណែកៗ ) ។ ខ្ញុំរក្សាសីលទាំង ៥ ហើយបាននូវត្រៃហេតុ គឺខ្ញុំជាអ្នកមានអាយុវែង ១ មានទ្រព្យច្រើន ១ មានប្រាជ្ញាមោះមុត ១ ។ មួយទៀតខ្ញុំសម្តែងនូវភាពនៃខ្លួន ជាបុរសដ៏ក្រៃលែង ជាងជនទាំងពួងអន្ទោលទៅក្នុងភពតូច និងភពធំ ហើយតែងបាននូវឋានៈទាំងនុ៎ះ ។ សាវកទាំងឡាយរបស់ព្រះជិនស្រី កាលប្រព្រឹត្តក្នុងសីលនឹងប្រមាណមិនបាន បើលោកនៅត្រេកអរក្នុងភព តើនឹងបាន

ផលដូចម្តេចទៅ ។ សីល ៥ ដែលខ្ញុំជាអ្នកស៊ីឈ្នួលគេ មានព្យាយាមប្រព្រឹត្តល្អហើយ ខ្ញុំបានរួចចាកចំណងទាំងពួង ក្នុងថ្ងៃនេះ ដោយសារសីលនោះ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំរក្សាសីល ៥ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសីល ៥ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចសីលសមាទានិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## បញ្ចសីលសមាទានិយត្ថេរាបទាន ចប់

# អដ្ឋកថា

## បញ្ចសីលសមាទានិយត្ថេរាបទាន

[ ២៦ ] *អបទានរបស់ព្រះបញ្ចសីលសមាទានិយត្ថេរ មានពាក្យផ្ដើមថា* **ឆគរេ ចន្ទវតិយា** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអនោមទស្សី កើតក្នុងត្រកូលមួយ ជាអ្នកក្រីក្រ តាមសមគួរដល់កុសលកម្ម ដែលខ្លួនធ្វើក្នុងភពមុន ទើបមានបាយទឹក និងភោជនតិច ធ្វើការស៊ីឈ្នួលអ្នកដទៃចិញ្ចឹមជីវិត ដឹងដល់ទោសក្នុងសង្សារ បំណងនឹងបួស តែមិនបានបួស ទើបសមាទានសីល ៥ ក្នុងសម្នាក់របស់ព្រះនិសភត្ថេរ សាវ័ករបស់ព្រះមានព្រះភាគព្រះនាមអនោមទស្សី ។ ព្រោះកើតក្នុងសម័យដែលមនុស្សមានអាយុវែង រក្សាសីលអស់ ១ សែនឆ្នាំ ដោយកម្មនោះ កុលបុត្តនោះ ក៏អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមហាសាល ក្នុងក្រុងវេសាលី ឃើញមាតាបិតាសមាទានសីល រឭកដល់សីលរបស់ខ្លួន ចម្រើនវិបស្សនាសម្រេចអរហត្ត ហើយបួស ។*

*លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចឧទាន ទើបពោលពាក្យថា* **ឆគរេ ចន្ទវតិយា** *ដូច្នេះជាដើម ។*

*បទថា* **ភតកោ អាសហំ តទា** *សេចក្ដីថា ក្នុងកាលនោះ គឺក្នុងកាល*

ដែលខ្ញុំបំពេញបុណ្យ ខ្ញុំជាអ្នកស៊ីឈ្នួល គឺជាអ្នកធ្វើការងារដើម្បីថ្លៃឈ្នួល ។ បទថា **បរកម្មាយនេ យុត្តា** សេចក្តីថា ខ្ញុំប្រកប គឺខ្វល់ខ្វាយក្នុងការធ្វើការងាររបស់អ្នកដទៃដើម្បីថ្លៃឈ្នួល ព្រោះមិនមានឱកាស ទើបមិនបានបួសដើម្បីឲ្យផុតចាកសង្សារ ។

បទថា **មហន្ធការបិហិតា** សេចក្តីថា ជាបុគ្គលដែលងងឹត គឺកិលេសដ៏ធំបិទបាំងហើយ រឹតរុំ រារាំងហើយ ។ បទថា **តិវិធគ្គិហិ ឌយ្ហរេ** សេចក្តីថា ដែលភ្លើង ៣ កង ពោល គឺភ្លើងនរក ភ្លើងប្រេត ភ្លើងសង្សារកំពុងឆេះ អធិប្បាយថា ខ្ញុំគប្បីជាអ្នកដោះខ្លួនចេញដោយឧបាយអ្វី គឺដោយហេតុអ្វី ។ ទេយ្យធម៌ គឺវត្ថុដែលគួរឲ្យ ដូចជាបាយ និងទឹកជាដើមរបស់ខ្ញុំមិនមាន ព្រោះជាអ្នកក្រីក្រ ទុគ៌ត ត្រូវធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិត ។ ពាក្យថា **យន្នូនាហំ បញ្ចសីលំ រក្ខេយ្យំ បរិបូរយំ** សេចក្តីថា បើដូច្នោះ ខ្ញុំគប្បីសមាទានសីល ៥ ឲ្យបរិបូណ៌ អធិប្បាយថា ខ្ញុំគប្បីរក្សាឲ្យល្អ ឲ្យបម្រើនល្អ ។

បទថា **ស្វាហំ យសមនុភវឹ** សេចក្តីថា ខ្ញុំនោះ សោយនូវយសធំក្នុងទេវតា និងមនុស្សទាំងឡាយ ដោយកម្លាំង គឺដោយអានុភាពនៃសីលទាំងនោះ អធិប្បាយថា សូម្បីសរសើរនៃសីលទាំងនោះ អស់កោដិកប្ប ក៏ប្រកាស គឺធ្វើឲ្យប្រាកដត្រឹមតែចំណែកមួយប៉ុណ្ណោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាបញ្ចសីលសមាទានិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អន្ធសំសាវកត្ថេរាបទានទី ៩

[ ២៧ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថៈ មានព្រះវណ្ណៈដូចមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ប្រាកដស្មើដោយចេតិយមាស ដែលកំពុងស្តេចទៅក្នុងចន្លោះវានផ្សារ ព្រះអង្គជាប្រទីបបំភ្លឺសត្វលោក មានគុណនឹងប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹម មានឥន្ទ្រិយទូន្មានហើយ ទ្រទ្រង់នូវស្មើដ៏រុងរឿង ហើយក៏បាននូវបីតិដ៏ឧត្តម ។ ខ្ញុំបានថ្វាយបង្គំព្រះសម្ពុទ្ធជាមហាមុនី ហើយនិមន្តព្រះអង្គឲ្យឆាន់ គ្រានោះ ព្រះមុនីប្រកបដោយសេចក្តីករុណា ចំពោះសត្វលោក ទ្រង់អនុមោទនាទានរបស់ខ្ញុំ ។ ខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះព្រះសម្ពុទ្ធអង្គនោះ ព្រះអង្គប្រកបដោយមហាករុណា ទ្រង់ជាអ្នកធ្វើនូវសេចក្តីរីករាយដ៏ក្រៃលែង ហើយខ្ញុំត្រេកអរក្នុងស្ថានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយចង្ហាន់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអន្ធសំសាវកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## អន្នសំសាវកត្ថេរាបទាន

[ ២៧ ] *អបទានរបស់ព្រះអន្នសំសាវកត្ថេរ មានពាក្យផ្ដើមថា* **សុវណ្ណវណ្ណំ សម្ពុទ្ធំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ឃើញព្រះមានព្រះភាគល្អដោយមហាបុរិសលក្ខណៈ ៣២ និងមណ្ឌលនៃព្រះរស្មី ប្រមាណ ១ ព្យាម កំពុងត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា និមន្តព្រះមានព្រះភាគចូលទៅកាន់ផ្ទះ ឲ្យឆាន់ស្កប់ស្កល់ដោយបាយ និងទឹកដ៏ប្រសើរ ។ ដោយចិត្តជ្រះថ្លានោះឯង កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសម្បត្តិ បន្ទាប់អំពីនោះ សោយទេវសម្បត្តិ និងមនុស្សសម្បត្តិរឿយៗ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ជ្រះថ្លាក្នុងព្រះសាសនា ហើយបួស ចម្រើនវិបស្សនា ហើយសម្រេចអរហត្ត ។ លោកមាននាមប្រាកដថា អន្នសំសាវកត្ថេរ តាមឈ្មោះនៃបុណ្យដែលខ្លួនធ្វើក្នុងកាលមុន ។*

*ក្រោយមក លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលនឹងប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចឧទានថា ខ្ញុំសម្រេចអរហត្តដោយអានុភាពនៃបុញ្ញសម្ភារៈនេះ ដោយប្រការដូច្នេះ ទើបពោលពាក្យថា* **សុវណ្ណវណ្ណំ** *ដូច្នេះជាដើម ។*

*ក្នុងគាថានោះមានអធិប្បាយថា ព្រះមានព្រះភាគអង្គណា មានសម្បុរដូចមាស ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា* **សុវណ្ណវណ្ណ** *។ នូវព្រះសម្មាសម្ពុទ្ធសិទ្ធត្ថៈ ដែលមានវណ្ណៈដូចវណ្ណៈនៃមាសអង្គនោះ ។ បទថា* **គច្ឆន្តំ អន្តរាបណេ** *សេចក្តីថា ដែលយាងទៅក្នុងវាំងផ្លូវនៃរានផ្សាររបស់ឈ្មួញទាំងឡាយ ។ បទថា* **កញ្ចនគ្ឃិយសង្កាសំ** *ក្លាប់សេចក្តីថា ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ដូចគ្នានឹងសសរខឿនមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ គឺទ្រង់បរិបូរដោយព្រះលក្ខណៈដ៏ប្រសើរ ៣២ ប្រការ បំភ្លឺលោកឲ្យរុងរឿង គឺដូចប្រទីបនៃលោកទាំងមូល មានគុណប្រមាណមិនបាន គឺមិនមានប្រមាណមិនមានបុគ្គលប្រៀបផ្ទឹម គឺមិនមានបុគ្គលប្រៀបធៀប ទ្រទ្រង់នូវរស្មីដ៏រុងរឿង គឺទ្រទ្រង់នូវព្រះរស្មី គឺទ្រទ្រង់នូវព្រះពុទ្ធរស្មីដែលមានពណ៌ ៦ ខ្ញុំឃើញហើយ បានទូវបីតិដ៏ឧត្តម គឺក្រៃលែង ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។៚*

## អដ្ឋកថាអន្នសំសាវកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ធូបទាយកត្ថេរាបទានទី ៦

[ ២៨ ] ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយធូប សម្រាប់អុជក្នុងកុដិ ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រ ដោយលោកធម៌ ។ ខ្ញុំចាប់កំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំរមែងជាទីស្រឡាញ់របស់ជនទាំងពួង នេះជាផលនៃការថ្វាយធូប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយធូប ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយធូប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធូបទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ធូបទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ធូបទាយកត្ថេរាបទាន

[ ២៨ ] អបទានរបស់ព្រះធូបទាយកត្ថេរ មានពាក្យផ្ដើមថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូល ធ្វើចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ធ្វើនូវការបូជាដោយធូប ( ផ្សែងក្រអូប ) ជាច្រើន ដែលធ្វើដោយខ្លឹមចន្ទន៍ក្រស្នា និងក្ដាំពាក់ជាដើម ក្នុងព្រះគន្ធកុដិ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយសម្បត្តិក្នុងលោកទាំងពីរ គឺក្នុងទេវតា និងមនុស្ស កុលបុត្តនោះ បានទទួលការបូជាក្នុងភពដែលខ្លួនកើតហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែងដោយអានុភាពនៃកុសលសម្ភារ ទើបបួសក្នុងសាសនា ចម្រើនវិបស្សនាហើយ បានសម្រេចអរហត្ត ព្រោះបុណ្យដែលបូជាដោយធូប ដែលធ្វើឯងទើបលោកគេស្គាល់ក្នុងទីគ្រប់កន្លែងថា ធូបទាយកត្ថេរ ។ លោកបានសម្រេចអរហត្តផលហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស

កាលសម្តែងអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះជាដើម ។

អធិប្បាយថា ប្រយោជន៍ ពោល គឺព្រះសព្វញ្ញុតញ្ញាណរបស់ព្រះមានព្រះភាគអង្គណាសម្រេចបរិបូណ៌ហើយ ព្រះមានព្រះភាគអង្គនោះ ព្រះនាមថា សិទ្ធត្ថៈ អធិប្បាយថា ( ខ្ញុំបានថ្វាយធូបក្នុងព្រះគន្ធកុដិ ) របស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈអង្គនោះ ដែលទ្រទ្រង់នូវគុណ មានភាពជាអ្នកចែកធម៌ជាដើម ដែលជាបុរសប្រសើរបំផុតក្នុងលោក គឺឧត្តមក្នុងលោកទាំងមូល ទ្រង់មិនញាប់ញ័រដោយលោកធម៌ គឺមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាធូបទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បុឡិនបូជកត្ថេរាបទានទី ៧

[ ២៩ ] ខ្ញុំកើបខ្សាច់ចាស់ចោល ហើយរោយរាយនូវខ្សាច់ថ្មីដ៏ស្អាត ត្រង់ខឿននៃពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយខ្សាច់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយខ្សាច់ ។ ក្នុងកប្បទី ៥៣ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ជាធំជាងជន មានកម្លាំងច្រើន ព្រះនាមមហាបុឡិនៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុឡិនបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បុឡិនបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## បុឡិនបូជកត្ថេរាបទាន

[ ២៩ ] *អបទានរបស់ព្រះបុឡិនបូជកត្ថេរ មានពាក្យផ្តើម* **វិបស្សិស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងត្រកូលមួយ មានចិត្តជ្រះថ្លាក្នុងព្រះសាសនា នាំខ្សាច់ចាស់ៗ ត្រង់ទៀនព្រះចេតិយ និងត្រង់ទៀនពោធិព្រឹក្សចេញ ហើយរោយខ្សាច់ពណ៌ស ដូចកម្ទេចកែវមុក្តាថ្មីៗ ជំនួស ហើយប្រដាប់ដោយកម្រងផ្កា ។ ដោយកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក សោយទិព្វសម្បត្តិក្នុងវិមានមាសកម្ពស់ច្រើនយោជន៍ រុងរឿងដោយកែវដែលជាទិព្វ ក្នុងទេវលោកនោះ ចុតិចាកអត្តភាពនោះហើយ កើតជាស្តេចចក្រពត្តិ សម្បូរដោយកែវ ៧ ប្រការ ក្នុងមនុស្សលោក សោយមនុស្សសម្បត្តិ អន្ទោលទៅមក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ដែលសម្បូរដោយសម្បត្តិ ជ្រះថ្លាក្នុងព្រះសាសនា បួសហើយ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ ។ លោកគេតែងស្គាល់ថា បុលិនបូជកត្ថេរ ដូចគ្នានឹងឈ្មោះបុណ្យដែលលោកធ្វើ ។*

*លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលសម្តែងអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **វិបស្សិស្ស ភគវតោ** *ដូច្នេះជាដើម ។ ក្នុងគាថានោះ ឈ្មោះថា* **វិបស្សី** *ព្រោះឃើញផ្សេងៗ ឬឈ្មោះថា* **វិបស្សី** *ព្រោះឃើញច្បាស់ ឬឈ្មោះថា* **វិបស្សី** *ព្រោះឃើញប្រយោជន៍ផ្សេងៗ មានប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃជាដើម ឬឈ្មោះថា* **វិបស្សី** *ព្រោះឃើញសភាវធម៌ផ្សេងៗ មានបញ្ញត្តិ និងបរមត្ថជាដើម ខ្ញុំជញ្ជូនខ្សាច់ចាស់ៗ ចោល រោយនូវខ្សាច់ថ្មី ស្អាតបរិសុទ្ធ ត្រង់មណ្ឌលពោធិព្រឹក្សដ៏ឧត្តម គឺត្រង់ខឿនពោធិព្រឹក្សដ៏ឧត្តមរបស់ព្រះពុទ្ធវិបស្សីអង្គនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕*

**អដ្ឋកថាបុឡិនបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឧត្តិយត្ថេរាបទានទី ៨

[ ៣០ ] គ្រានោះ ខ្ញុំកើតជាក្រពើ នៅនាឆ្នេរស្ទឹង ឈ្មោះចន្ទភាគា ខ្ញុំកំពុងខ្វល់ខ្វាយរកចំណីដើម្បីខ្លួន ហើយបានទៅកាន់កំពង់ស្ទឹង ។ សម័យនោះ ព្រះសយម្ភូព្រះនាមសិទ្ធត្ថៈ ជាបុគ្គលប្រសើរ ព្រះអង្គមានប្រាថ្នានឹងឆ្លងស្ទឹង ទ្រង់ស្តេចចូលទៅកាន់កំពង់នៃស្ទឹងនោះ ។ កាលព្រះសម្ពុទ្ធ ស្តេចមកដល់ហើយ ខ្ញុំក៏ចូលមកដល់ត្រង់កំពង់នោះដែរ លុះចូលមកដល់ហើយ បានពោលវាចានេះនឹងព្រះសម្ពុទ្ធថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គឡើងកាន់ ( ខ្នងរបស់ខ្ញុំ ) ចុះ ខ្ញុំនឹងចម្លងព្រះអង្គ បពិត្រព្រះមហាមុនី សូមព្រះអង្គអនុគ្រោះនូវវិស័យជារបស់នៃបិតាដល់ខ្ញុំ ឲ្យទាន ។ ព្រះមហាមុនិ ទ្រង់ព្រះសណ្តាប់នូវសម្រែករបស់ខ្ញុំហើយ ស្តេចឡើងកាន់ ( ខ្នងរបស់ខ្ញុំ ) ខ្ញុំមានចិត្តរីករាយស្រស់ស្រាយ ចម្លងព្រះលោកនាយក ។ ព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ ញុំាងខ្ញុំឲ្យស្រស់ស្រាយ ព្ធដ៏ត្រើយខាងនាយនៃស្ទឹងនោះថា អ្នកនឹងដល់នូវព្រះនិព្វានឈ្មោះអមតៈ ។ ខ្ញុំច្យុតចាកកាយនោះ បានទៅកាន់ទេវលោក មានពួកស្រីអប្សរចោមរោម ដោយសេចក្តីសុខដ៏ជាទិព្យ ។ ខ្ញុំបានជាធំជាងទេវតា ដោយទេវរាជ្យ អស់ ៧ ដង ខ្ញុំបានជាស្តេចចក្កពត្តិ ជាធំលើផែនដី អស់ ៧ ដង ។ ខ្ញុំប្រកបរឿយៗ នូវវិវេក ជាអ្នកមាន

ប្រាជ្ញាចាស់ សង្រួមល្អ ទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងពុទ្ធ-សាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានចម្លងព្រះនរាសភៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧត្តិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឧត្តិយត្ថេរាបទាន ចប់

# អដ្ឋកថា

## ឧត្តិយត្ថេរាបទាន

[ ៣០ ] អបទានរបស់ព្រះឧត្តិយត្ថេរ មានពាក្យផ្តើមថា **ចន្ទភាគា-នទីតីរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតជាក្រពើក្នុងស្ទឹង ឈ្មោះចន្ទភាគា ឃើញព្រះមានព្រះភាគយាងមកក្បែរឆ្នេរស្ទឹង មានចិត្តជ្រះថ្លា បំណងនាំទៅកាន់ត្រើយ ទើបក្រាបក្បែរប្រាំងនោះឯង ។ ដើម្បីអនុគ្រោះ ទើបព្រះមានព្រះភាគដាក់ព្រះបាទលើខ្នង ក្រពើត្រេកអរ មានចិត្តផ្សាយឡើង កើតនូវឧស្សាហ៍ ដោយកម្លាំងនៃបីតិ ក៏ហែលកាត់ខ្សែទឹក ប្រញាប់នាំព្រះមានព្រះភាគចូងទៅត្រើយនាយដោយរហ័ស ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីជ្រះថ្លានៃចិត្តរបស់ក្រពើ ទើបទ្រង់ព្យាករថា ក្រពើនេះ ចុតិចាកអត្តភាពនេះហើយ នឹងកើតក្នុងទេវលោក ចាប់អំពីនោះ ក្រពើនេះ នឹងអន្ទោលទៅក្នុងសុគតិតែម្យ៉ាង ក្នុងកប្បទី ៩៤ បន្ទាប់អំពីកប្បនេះ នឹងសម្រេចអមតនិព្វាន ដូច្នេះហើយ ក៏យាងចៀសចេញទៅ ។

ក្រពើនោះ អន្ទោលទៅក្នុងសុគតិតែម្យ៉ាងប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ម្នាក់ ក្នុងក្រុងសាវត្ថី ។ ពួកញាតិបានដាក់ឈ្មោះថា ឧត្តិយៈ ។ កុលបុត្តនោះ ចម្រើនវ័យហើយ គិតថា អញនឹងស្វែងរកអមតធម៌ ទើបបួសជាបរិព្វាជក ថ្ងៃមួយ ឃើញព្រះមានព្រះភាគ

ទើបចូលទៅគាល់ ថ្វាយបង្គំហើយ ស្តាប់ធម៌ ជាអ្នកបាននូវសទ្ធា បួសក្នុងព្រះសាសនា ព្រោះភាពដែលខ្លួនមិនបានជម្រះសីល និងទិដ្ឋិឲ្យបរិសុទ្ធ ទើបមិនអាចធ្វើឲ្យគុណវិសេសកើតឡើងបាន ឃើញភិក្ខុមួយរូប ញុំាងគុណវិសេសឲ្យកើតឡើង ព្យាករអរហត្តផល ទើបចូលទៅគាល់ព្រះសាស្តា ទូលសូមឱវាទដោយសង្ខេប ។ ចំណែកព្រះសាស្តា បានប្រទានឱវាទដល់ព្រះថេរៈដោយសង្ខេបដូចគ្នា ដោយន័យ ( សំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលឧត្តិយៈ បើដូច្នោះ ក្នុងសាសនានេះ ចូរអ្នកជម្រះនូវដើមនៃកុសលធម៌ទាំងឡាយសិន ដូច្នេះជាដើម ។ ព្រះថេរៈតាំងនៅក្នុងឱវាទ ផ្តើមនូវវិបស្សនាហើយ ។ កាលព្រះថេរៈផ្តើមនូវវិបស្សនា អាពាធកើតឡើងហើយ កាលអាពាធកើតឡើង ព្រះថេរៈកើតនូវសង្វេគ គឺកាន់យកជាហេតុនៃការប្រារព្ធសេចក្តីព្យាយាម ទើបចម្រើនវិបស្សនា រហូតសម្រេចអរហត្ត ។

លោកសម្រេចអរហត្តផលតាមសមគួរដល់កុសលសម្ភារ ដែលបានបំពេញមក ដោយប្រការដូច្នេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ចន្ទភាគានទីតីរេ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ចន្ទភាគានទីតីរេ** សេចក្តីថា ឈ្មោះថា **ចន្ទភាគានទី** ព្រោះមានខ្សាច់សស្អាត និងព្រោះសម្បូរដោយរស្មី និងព្រោះទឹកថ្លាមានរសឆ្ងាញ់ ហូរបន្លឺសំឡេងទៅ បញ្ចេញរស្មីដ៏ស្រស់ត្រកាលប្រៀបដូចពន្លឺព្រះចន្ទ ។ ភ្ជាប់សេចក្តីថា ខ្ញុំបានជាក្រពើ អាស្រ័យត្រង់ឆ្នេរនៃស្ទឹងចន្ទភាគានោះ ។ បណ្តា

បទទាំងនោះ បទថា **សុសុមារោ** សេចក្តីថា ឈ្មោះថា **សុសុមារ** ព្រោះសម្លាប់ហ្វូងត្រីតូចៗ ធ្វើឲ្យជាកំណាត់តូចធំ សំដៅដល់ ត្រីកាច គឺក្រពើ ។ បទថា **សកោជឆបសុតោហំ** សេចក្តីថា ខ្ញុំខ្វល់ខ្វាយ គឺព្យាយាមក្នុងចំណីរបស់ខ្លួន គឺក្នុងនុយរបស់ខ្លួន ។ បទថា **ឆទីតិត្ថំ អគច្ឆហំ** សេចក្តីថា ក្នុងពេលដែលព្រះមានព្រះភាគយាងមក ខ្ញុំបានទៅដល់កំពង់នោះ ។

បទថា **សិទ្ធត្ថោ តម្ហិ សមយេ** សេចក្តីថា ក្នុងកាលដែលខ្ញុំទៅកាន់កំពង់នោះ ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ជាអគ្គបុគ្គល គឺបុគ្គលប្រសើរបំផុត ក្នុងពួកសត្វទាំងពួង ជាព្រះសយម្ភូ គឺជាអ្នកឧប្បត្តិកឯង កើតឯង ព្រះមានព្រះភាគប្រាថ្នាឆ្លងត្រើយ គឺឆ្លងនូវស្ទឹង ។

បទថា **បេត្តិកំ វិសយំ មយ្ហំ** សេចក្តីថា ការនាំបុគ្គលដែលមានអានុភាពច្រើន ដែលមកដល់គ្រប់អង្គឲ្យឆ្លងត្រើយ ជាវត្ថុដែលបិតា និងជីតាជាដើមរបស់ខ្ញុំព្រះអង្គធ្វើបន្តគ្នាមក ។

បទថា **មម ឧគ្គជ្ជនំ សុត្វា** ក្តាប់សេចក្តីថា ព្រះមានព្រះភាគ ដ៏ជាមហាមុនី ទ្រង់ស្តាប់ពាក្យអារាធនារបស់ខ្ញុំយាងឡើង ( កាន់ខ្នង ) ហើយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាឧត្តិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឯកញ្ជលិកត្ថេរាបទានទី ៩

[ ៣១ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមវិបស្សី មានព្រះវណ្ណៈដូចមាស ទ្រង់នាំនូវពួកដ៏ប្រសើរ ជានរៈដ៏ក្លៀវក្លា ជាអ្នកដឹកនាំនូវសត្វលោកយ៉ាងវិសេស កំពុងស្តេចទៅក្នុងចន្លោះផ្សារ ។ ខ្ញុំលុះឃើញព្រះសម្ពុទ្ធ ព្រះអង្គទូន្មាននូវបុគ្គលដែលមិនទាន់ទូន្មាន ជាតាទិបុគ្គល មានវាទៈដ៏ប្រសើរ មានយោបល់ច្រើនហើយ មានចិត្តជ្រះថ្លា សោមនស្ស បានធ្វើអញ្ជលិកម្មម្តង ( ចំពោះព្រះសម្ពុទ្ធនោះ ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអញ្ជលិ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអញ្ជលិ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកញ្ជលិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកញ្ជលិកត្ថេរាបទាន ចប់

# អដ្ឋកថា

## ឯកញ្ជលិកត្ថេរាបទាន

[ ៣១ ] *អបទានរបស់ព្រះឯកញ្ជលិកត្ថេរ មានពាក្យផ្ដើមថា* **សុវណ្ណវណ្ណំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះជីនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាធំហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ ឃើញព្រះមានព្រះភាគព្រះនាមវិបស្សី កំពុងត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា បានឈរផ្គងអញ្ជលី ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ជាអ្នកបានទទួលការបូជាក្នុងទីគ្រប់ស្ថាន សោយនូវសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិ ជ្រះថ្លាក្នុងព្រះសាសនា បួសហើយ ចម្រើនវិបស្សនា តាំងនៅក្នុងអរហត្តហើយ ។ លោកគេតែងស្គាល់ថា ឯកញ្ជលិកត្ថេរ តាមបុណ្យដែលធ្វើហើយក្នុងជាតិមុន ។*

*លោករឭកដល់បុព្វកម្មរបស់ខ្លួន ឃើញនូវបុព្វកម្មនោះ ដូចផ្លែកន្ទួតព្រៃក្នុងបាតដៃ កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សុវណ្ណវណ្ណំ** *ដូច្នេះជាដើម ។*

*បទថា* **វិបស្សឹ សត្ថវាហគ្គំ** *សេចក្ដីថា ឈ្មោះថា* **សត្ថវាហ** *ព្រោះនាំពួកឈ្មួញឲ្យឆ្លងនូវកន្តារ អធិប្បាយថា ឲ្យឆ្លង គឺឲ្យឆ្លងឡើង ឲ្យឆ្លង*

ចេញ ឲ្យឆ្លងផុតចាកវាឡុកន្តារ ( កន្តារព្រោះសត្វសាហាវ ) ចោរកន្តារ ( កន្តារព្រោះចោរ ) ទុព្ភិក្ខកន្តារ ( កន្តារព្រោះទុរ្ភិក្ស ) នរុទកកន្តារ ( កន្តារព្រោះមិនមានទឹក ) យក្ខកន្តារ ( កន្តារព្រោះមានអមនុស្ស ) អប្បភក្ខ-កន្តារ ( កន្តារព្រោះមានអាហារតិច ) ឲ្យដល់ទឹកដី ដែលជាដែនក្សេម ។ ជាប្រធាននៃឈ្មួញ គឺនរណា គឺព្រះមានព្រះភាគនេះឯង ទ្រង់ឈ្មោះថា **សត្ថវាហា** ព្រោះដូចអ្នកនាំពួក ។ ពិតហើយ ព្រះមានព្រះភាគ រមែងញុំាងពួកសត្វដែលប្រាថ្នាព្រះពោធិញ្ញាណ ៣ យ៉ាង ដែលបានសាងបុញ្ញ-សម្ភារ ឲ្យឆ្លង គឺឲ្យឡើង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញចាកជាតិកន្តារ ១ ចាកព្យាធិកន្តារ ១ ចាកមរណកន្តារ ១ ចាកកន្តារ គឺសោក បរិទេវៈ ទុក្ខទោមនស្ស និងឧបាយាស ១ ចាកសង្សារកន្តារទាំងពួង ១ អធិប្បាយថា ឲ្យដល់លើគោក គឺព្រះនិព្វាន ។ ឈ្មោះថា **សត្ថវាហគ្គោ** ព្រោះជាអ្នកនាំពួកដ៏កំពូល ដ៏ប្រសើរ និងជាប្រធាន ភ្ជាប់សេចក្តីថា នូវព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សី ដែលនាំពួកឈ្មួញដ៏ប្រសើរនោះ ។ បទថា **នរវរំ វិនាយកំ** សេចក្តីថា ដែលជានរៈដ៏ក្លៀវក្លា ព្រោះមានការប្រឹងប្រែងមិនធូរថយ ក្នុងរវាងនរៈជនទាំងឡាយ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដែលឈ្មោះថា **វិនាយក** ព្រោះនាំសត្វទាំងឡាយ ដែលសាងបុញ្ញសម្ភារហើយបានដោយវិសេស ឲ្យដល់នគរ គឺនិព្វាន ។

បទថា **អនន្តជមនំ តាទឹ** នូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដែលឈ្មោះថា **អនន្តជមនំ** ព្រោះទូន្មានពួកសត្វ ដែលមិនបានទទួលការទូន្មាន ដោយ

កាយទ្វារ វចីទ្វារ និងមនោទ្វារ ព្រោះប្រកបដោយកិលេស មានរាគៈ ទោសៈ និងមោហៈជាដើម ។ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដែលឈ្មោះថា **តាទី** ព្រោះប្រកបដោយគុណ មានភាពជាអ្នកមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម ។ បទថា **មហាវាទឹ មហាមតឹ** សេចក្ដីថា ឈ្មោះថា **មហាវាទឹ** ព្រោះមិនមានបុគ្គលដែលក្រៃលែងជាងព្រះអង្គ ក្នុងវាងអ្នកប្រៀនប្រដៅលទ្ធិរបស់ខ្លួន និងលទ្ធិរបស់អ្នកដទៃ ។ បញ្ញារបស់បុគ្គលណាធំស្មើដោយផែនដី និងស្មើដោយភ្នំសុមេរុ បុគ្គលនោះ ឈ្មោះថា មានបញ្ញាច្រើន ។ នូវព្រះសម្មាសម្ពុទ្ធដែលជាម្ចាស់លទ្ធិធំ ដែលមានបញ្ញាច្រើនអង្គនោះ ។ ដោយវិគ្គហៈ ( ញែកសព្ទ ) ដូច្នេះ ជាតុល្យាធិ-ករណពហុព្វិហិសមាស ។ ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ៕

## អដ្ឋកថាឯកញ្ញលិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ខោមទាយកត្ថេរាបទានទី ១០

[ ៣២ ] គ្រានោះ ខ្ញុំកើតជាអ្នកជំនួញ នៅក្នុងក្រុងឈ្មោះពន្ធុមតី តែងចិញ្ចឹមកិរិយាដោយរបរជំនួញនោះ តែងបណ្តុះសម្ប័ទ គឺពូជ ។ ខ្ញុំបានថ្វាយសំពត់សម្បកឈើ ១ ដើម្បីប្រយោជន៍ដល់កុសល ចំពោះព្រះសាស្តា ព្រះនាមវិបស្សី ព្រះអង្គស្វែងរកនូវគុណធំ ដែលកំពុងស្តេចទៅតាមថ្នល់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់សម្បកឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់សម្បកឈើ ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ១ អង្គ ឈ្មោះសិន្ធវសន្ទនៈ ជាឥស្សរៈក្នុងទ្វីបទាំង ៤ ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខោមទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*ខោមទាយកត្ថេរាបទាន ចប់*

## ឧទ្ទាន

រឿងព្រះសុភូតិ ១ ព្រះឧបវាណៈ ១ ព្រះតីណិសរណាគមនិយៈ ១ ព្រះបញ្ចសីលសមាទានិយៈ ១ ព្រះអន្នសំសាវកៈ ១ ព្រះធូបទាយកៈ ១ ព្រះបុឡិនបូជកៈ ១ ព្រះឧត្តិយៈ ១ ។ ព្រះឯកញ្ចលិកៈ ១ ព្រះខោមទាយកៈ ១ ត្រូវជា ១០ រឿង គាថាទាំងឡាយ ( ដែលព្រះថេរៈទាំងនោះ ) បានពោលហើយ ប្រមូលរួមទាំងអស់ ត្រូវជា ១៨៥ ក្នុងតតិយវគ្គ ។

សុភូតិវគ្គទី ៣ ចប់

ភាណវារទី ៤ ចប់

# អដ្ឋកថា

## ខោមទាយកត្ថេរាបទាន

[ ៣២ ] *អបទានរបស់ព្រះខោមទាយកត្ថេរ មានពាក្យផ្ដើមថា* **ឆគវេ ពន្ធុមតិយា** *ដូច្នេះ ។*

*ព្រះថេរៈនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង លុះចម្រើនវ័យហើយ ជ្រះថ្លាក្រៃលែងក្នុងព្រះសាសនារាប់អានព្រះរតនត្រ័យ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ហើយមានចិត្តជ្រះថ្លា បានធ្វើនូវការបូជាដោយសំពត់ថ្មី ។ កុលបុត្តនោះ កាន់យកការបូជានោះឯងឲ្យជាចំណុចចាប់ផ្ដើម ធ្វើបុណ្យដរាបដល់អស់ជីវិត បន្ទាប់អំពីនោះ ទៅកើតក្នុងទេវលោក សោយទិព្វសុខ អន្ទោលទៅមកក្នុងស្ថានសួគ៌ ៦ ជាន់ ចុតិចាកអត្តភាពនោះហើយ សោយមនុស្ស-សម្បត្តិក្នុងមនុស្សលោកច្រើនយ៉ាង មានជាស្ដេចចក្រពត្តិជាដើម កាលបុញ្ញសម្ភារដល់នូវភាពចាស់ក្លាជុំវិញហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បាននូវសទ្ធាហើយបព្វជ្ជា ចម្រើនវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្ត លោកប្រាកដដោយនាមនៃបុណ្យ ដែលខ្លួនបានធ្វើថា ខោមទាយ-កត្ថេរ ។*

*លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលនឹងសម្ដែងបុព្វចរិតាបទាន ទើបពោលពាក្យថា* **នគរេ ពន្ធុមតិយា** *ដូច្នេះជាដើម ។ ក្នុងគាថានោះ ញាតិ លោកហៅថា* **ពន្ធុ** *ខ្សែស្រឡាយបន្តគ្នាមកក្នុងនគរណា នគរនោះ លោកហៅថា* **ពន្ធុមតី** *។ បទថា* **រោបេមិ ពីជសម្បទំ** *សេចក្ដីថា ខ្ញុំបណ្ដុះ គឺផ្ដើមតាំងនូវពីជសម្បត្តិ គឺបុណ្យ មានទាន និងសីលជាដើម ។៚*

**អដ្ឋកថាខោមទាយកត្ថេរាបទាន ចប់**

**សុភូតិវគ្គទី ៣ ចប់**

**ចតុភាណវារ ចប់**

# សុត្តន្តបិដក

## កុណ្ឌធានវគ្គទី ៤

## កុណ្ឌធានត្ថេរាបទានទី ១

[ ៣៣ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបម្រើព្រះសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គជាព្រះសយម្ភូ ជាអគ្គបុគ្គល ទ្រង់គេចចេញចាកពួក សម្ងំនៅក្នុងកម្មដ្ឋានអស់ ៧ ថ្ងៃ ។ ខ្ញុំដឹងនូវកាលដែលទ្រង់ចេញអំពីទីសម្ងំ ហើយខ្ញុំកាន់ចេកមួយស្និតធំ នាំចូលទៅថ្វាយព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ។ ព្រះមានព្រះភាគជាសព្វញ្ញូ ជាលោកនាយក ទ្រង់បានទទួល ព្រះមហាមុនី ញុំាងចិត្តរបស់ខ្ញុំឲ្យជ្រះថ្លា ទ្រង់សោយ ( ចេកនោះ ) ។ លុះព្រះសម្ពុទ្ធទ្រង់ជាអ្នកដឹកនាំពួក ជាបុគ្គលប្រសើរបំផុត ទ្រង់សោយរួចហើយ គង់លើអាសនៈរបស់ព្រះអង្គ ហើយត្រាស់នូវគាថាទាំងឡាយនេះថា

ពួកយក្សណា ដែលមកជួបជុំនៅនាភ្នំនេះ និងពួកភូតទាំងពួង ដែលនៅអាស្រ័យក្នុងព្រៃនេះ ( ពួកយក្ស និងភូតទាំងនោះ ) ចូរស្តាប់ពាក្យរបស់តថាគតចុះ ។ កុលបុត្តណា បានបម្រើនូវព្រះពុទ្ធ ព្រះអង្គដូចជាកេសររាជសីហ៍ ជាស្តេចនៃម្រឹគ តថាគតនឹងសម្តែងសរសើរ នូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់

តថាគតសម្ដែង ។ កុលបុត្តនោះ នឹងបានជាស្ដេចនៃទេវតា អស់ ១១ ជង នឹងបានជាស្ដេចចក្កពត្តិ អស់ ៣៤ ជង ។ កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល ត្រាស់ដឹងក្នុងលោក ។ កុលបុត្តនោះ នឹងបាននូវនាម ( ថា កុណ្ឌធាន ) ដោយវិបាកនៃបាបកម្ម ព្រោះជេរនូវសមណៈទាំងឡាយ ជាអ្នកមានសីល មិនមានអាសវៈ ។ កុលបុត្តដែលឈ្មោះកុណ្ឌធាននោះ នឹងបានជាទាយាទក្នុងធម៌របស់ព្រះពុទ្ធព្រះនាមគោតមនោះ នឹងជាព្រះឱរស ជាធម្មនិម្មិត ទាំងបានជាសាវ័ករបស់ព្រះពុទ្ធអង្គនោះ ។

ខ្ញុំតែងប្រកបរឿយៗ នូវវិវេក ជាអ្នកមានឈាន ត្រេកអរក្នុងឈាន ញុំាងព្រះសាស្ដាឲ្យត្រេកអរ ជាអ្នកមិនមានអាសវៈ ។ ព្រះជិនស្រី មានសាវ័កចោមរោម និងពួកភិក្ខុចោមរោម ទ្រង់គង់ក្នុងកណ្ដាលភិក្ខុសង្ឃ ហើយញុំាងខ្ញុំឲ្យកាន់យកស្លាក ។ ខ្ញុំធ្វើនូវចីវរឆៀងស្មាម្ខាង ហើយថ្វាយបង្គំព្រះលោកនាយក កាន់យកនូវស្លាកជាដំបូង ក្នុងទីចំពោះព្រះភក្ត្រព្រះសម្ពុទ្ធ ដ៏ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ។ ព្រះមានព្រះភាគ ញុំាងលោកធាតុមួយម៉ឺនឲ្យញាប់ញ័រ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ដោយសារអំពើនោះ ។ សេចក្ដីព្យាយាមរបស់ខ្ញុំ គួរដើម្បីនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ខ្ញុំទ្រទ្រង់នូវ

រាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុណ្ឌធានត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## កុណ្ឌធានត្ថេរាបទាន ចប់

# អដ្ឋកថា
## កុណ្ឌធានវគ្គទី ៤

### កុណ្ឌធានត្ថេរាបទាន

[ ៣៣ ] អបទានរបស់ព្រះកុណ្ឌធានត្ថេរ មានពាក្យផ្ដើមថា **សត្តាហំ បដិសល្លីនំ** ដូច្នេះ ។

ព្រះថេរៈនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ចូលទៅគាល់ព្រះមានព្រះភាគ ដោយន័យដែលពោលហើយខាងដើមនោះឯង ស្ដាប់ធម៌ ឃើញព្រះសាស្ដាតែងតាំងភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុទាំងឡាយខាងចាប់ស្លាកបានជាដំបូង ក៏ប្រាថ្នានូវតំណែងនោះ ធ្វើបុណ្យសមគួរដល់ឋានន្តរនោះ សម័យមួយ កុលបុត្តនោះបានថ្វាយស្និតចេកធំ មានពណ៌លឿងដូចលម្អិតនៃមនោសិលា ដល់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ដែលចេញអំពីនិរោធសមាបត្តិ ប្រថាប់គង់ ព្រះមានព្រះភាគទ្រង់ទទួលស្និតចេកនោះ ហើយសោយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយទេវសម្បត្តិក្នុងទេវលោក ១១ ដង បានជាស្ដេចចក្រពត្តិ ២៤ ដង ។

កុលបុត្តនោះ ធ្វើបុណ្យរឿយៗ យ៉ាងនេះហើយ អន្ទោលទៅមកក្នុង

ទេវតា និងមនុស្សទាំងឡាយ ក្នុងកាលរបស់ព្រះពុទ្ធព្រះនាមកស្សបៈ កើតជាកុម្មទេវតា ។

ធម្មតាព្រះពុទ្ធដែលមានព្រះជន្មវែងទាំងឡាយ មិនមានឧបោសថរៀងរាល់កន្លះខែឡើយ ។ ពិតហើយ ព្រះមានព្រះភាគព្រះនាមវិបស្សី មានឧបោសថ ៦ ឆ្នាំម្តង ចំណែកព្រះទសពលព្រះនាមកស្សបៈ សូធ្យបាតិមោក្ខ ៦ ខែម្តង ក្នុងការសូធ្យបាតិមោក្ខនោះ ភិក្ខុស្រុកក្រៅជាសម្លាញ់នឹងគ្នាពីររូប ធ្វើដំណើរទៅ ( ក្នុងនគរ ) ដោយគិតថា នឹងធ្វើឧបោសថ ។ កុម្មទេវតានេះគិតថា ភិក្ខុពីររូបនេះស្រឡាញ់គ្នាស្និទ្ធស្នាលពន់ពេក បើមានអ្នកបំបែក តើបែកគ្នាឬហ្ន៎ សម្លឹងរកឱកាសរបស់ភិក្ខុទាំងពីរនោះ ដើរតាមក្រោយ មិនឆ្ងាយអំពីភិក្ខុទាំងពីរនោះ ។ កាលនោះ ព្រះថេរៈមួយរូប ឲ្យព្រះថេរៈមួយរូបកាន់បាត្រ និងចីវរ ខ្លួនឯងដើរទៅកាន់ទីដែលមានទឹក ដើម្បីបន្ទោបង់ឧច្ចារៈ លាងដៃ និងជើងហើយ ចេញអំពីគុម្ពឈើ ។ កុម្មទេវតា ក៏កាឡាខ្លួនជាស្រីស្អាត ដើរតាមក្រោយព្រះថេរៈនោះ ធ្វើជារំសាយសក់ ហើយចងជាថ្មី ធ្វើជាបោសធូលីក្រោយខ្នង ធ្វើជាស្លៀកសំពត់ឲ្យរៀបរយជាថ្មី ដើរតាមក្រោយព្រះថេរៈចេញអំពីគុម្ពឈើ ។ ព្រះថេរៈជាសម្លាញ់ឈរក្នុងចំណែកម្ខាង ឃើញហេតុនោះហើយ កើតទោមនស្ស គិតថា ឥឡូវនេះការស្និទ្ធស្នាលជាមួយនឹងភិក្ខុរូបនេះ ដែលជាប់តគ្នាមកអស់កាលយូរ វិនាសហើយ បើអញដឹងថា លោកជាអ្នកមានកិលេសយ៉ាងនេះ អញមិនធ្វើសេចក្តីស្និទ្ធស្នាលជាមួយភិក្ខុនេះ អស់កាលយូរមានប្រមាណប៉ុណ្ណោះឡើយ កាល

ព្រះថេរៈនិមន្តមកដល់ប៉ុណ្ណោះ ក៏ពោលថា នែអាវុសោ សូមទទួលយក បាត្រ និងចីវររបស់លោកទៅចុះ ខ្ញុំមិនប្រាថ្នាធ្វើដំណើររួមផ្លូវជាមួយបុគ្គល លាមកដូចលោក ។ ស្តាប់ពាក្យនោះហើយ ហទយៈរបស់ភិក្ខុដែលជាលជ្ជី នោះ ហាក់ដូចត្រូវលំពែងដ៏មុតចាក់ដោតហើយ ។ លំដាប់នោះ ទើបលជ្ជី-ភិក្ខុនោះពោលនឹងព្រះថេរៈជាសម្លាញ់ថា អាវុសោ លោកនិយាយអ្វីបែប នោះ អស់កាលមានប្រមាណប៉ុណ្ណេះ ខ្ញុំមិនដឹងថា ខ្ញុំត្រូវអាបត្តិសូម្បីត្រឹម ទុក្កដ ថ្ងៃនេះ លោកពោលខ្ញុំថាជាមនុស្សលាមក លោកឃើញអ្វីឬ ព្រះ ថេរៈជាសម្លាញ់ពោលថា រឿងឃើញមិនឃើញ មានប្រយោជន៍អ្វី លោក ចេញមកអម្បាញ់មិញជាមួយមាតុគ្រាមដែលប្រដាប់ហើយ តាក់តែងហើយ យ៉ាងនេះ មិនមែនឬ ។ ព្រះថេរៈដែលជាលជ្ជីពោលថា អាវុសោ រឿងនេះ មិនមានដល់ខ្ញុំឡើយ ខ្ញុំមិនឃើញមាតុគ្រាមបែបនោះឡើយ កាលព្រះថេរៈ លជ្ជីពោលយ៉ាងនេះដល់ទៅ ៣ ដង ព្រះថេរៈមួយអង្គទៀត ក៏មិនជឿពាក្យ ដែលប្រាប់ កាន់យកហេតុដែលខ្លួនឃើញហើយនោះឯងថា ពិត មិនធ្វើ ដំណើរផ្លូវមួយជាមួយភិក្ខុនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ដោយផ្លូវ ដទៃ ។

បន្ទាប់អំពីនោះមក ដល់ពេលដែលភិក្ខុសង្ឃ ចូលកាន់រោងឧបោសថ ភិក្ខុនោះ ឃើញលជ្ជីភិក្ខុនោះក្នុងរោងឧបោសថ ចាំបានហើយ ទើបចេញ ទៅឈរខាងក្រៅ ដោយគិតថា ភិក្ខុបាបបែបនេះមានក្នុងរោងឧបោសថនេះ អញមិនធ្វើឧបោសថជាមួយលោកឡើយ ដូច្នេះ ។ លំដាប់នោះ កុម្មទេវតា

គិតថា អញធ្វើកម្មធ្ងន់ហ្ន៎ ហើយការឡាខ្លួនជាឧបាសកចាស់ ទៅកាន់សម្នាក់របស់ភិក្ខុនោះ ពោលថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់មកឈរក្នុងទីនេះ ភិក្ខុនោះឆ្លើយថា អើឧបាសក ភិក្ខុបាបមួយរូប ចូលទៅកាន់រោងឧបោសថនេះ អាត្មាមិនធ្វើឧបោសថជាមួយលោកទេ អាត្មាគិតដូច្នេះ ទើបចេញមកឈរខាងក្រៅ ។ កុម្មទេវតាពោលថា បពិត្រលោកម្ចាស់ៗ កុំយល់យ៉ាងនោះឡើយ ភិក្ខុនេះមានសីលបរិសុទ្ធ ឈ្មោះថា មាតុគ្រាមដែលលោកម្ចាស់ឃើញហើយ គឺខ្ញុំនេះឯង ខ្ញុំសាកល្បងថា មេត្រីភាពរបស់លោកទាំងពីរនេះ មាំទាំ ឬមិនមាំទាំ ចង់មើលថា លោកទាំងពីរបែកមេត្រីគ្នាឬទេ ទើបធ្វើកម្មនោះ ។ ភិក្ខុនោះសួរថា នែសប្បុរស អ្នកជានរណា កុម្មទេវតាឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំជាកុម្មទេវតា ។ ខណៈពេលបែបនោះ ទេវបុត្តត្រឡប់ជាមានរាងកាយជាទេវតា ក្រាបទៀបជើងរបស់ព្រះថេរៈអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ ព្រះថេរៈមិនឃើញទោសនោះ សូមលោកម្ចាស់ធ្វើឧបោសថចុះ ដូច្នេះហើយនិមន្តឲ្យព្រះថេរៈចូលទៅកាន់រោងឧបោសថ ។ ព្រះថេរៈនោះបានធ្វើឧបោសថក្នុងទីជាមួយគ្នាត្រឹមតែម្តងនោះ តែមិននៅរួមគ្នាជាមួយភិក្ខុនោះ ដោយអំណាចមេត្រីភាពទៀត និងមិនពោលទោសព្រះថេរៈនេះថា មានកំហុស ( ទៀត ) ។ ក្រោយមក ព្រះថេរៈដែលត្រូវចោទ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ ។

ដោយផលនៃកម្មនោះ កុម្មទេវតាមិនរួចផុតចាកភ័យក្នុងអបាយអស់ ១ ពុទ្ធន្តរ ។ កាលណាមកកើតជាមនុស្ស ទោសដែលអ្នកដទៃណាមួយធ្វើ

ក៏ធ្លាក់មកលើកុលបុត្តនោះឯង ។ ក្នុងកាលនៃព្រះមានព្រះភាគនៃយើងទាំងឡាយ កុលបុត្តនោះកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរសាវត្ថី មនុស្សទាំងឡាយបានដាក់ឈ្មោះថា ធានមាណព ។ ធានមាណពចម្រើនវ័យហើយ រៀនត្រៃវេទ ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ក្នុងពេលខ្លួនចាស់មានសទ្ធាទើបចេញបួស ចាប់តាំងអំពីថ្ងៃដែលលោកឧបសម្បទាហើយ ក៏ប្រាកដមានស្រីម្នាក់ គាត់តែងស្អាតបាតដើរតាមលោកជានិច្ចយ៉ាងនេះ គឺ កាលលោកចូលស្រុក ក៏ចូលស្រុកជាមួយលោក កាលលោកចេញមក ក៏ចេញមកដែរ កាលលោកចូលវិហារ ក៏ចូលទៅដែរ កាលលោកឈរ ក៏ឈរដែរ ។

ព្រះថេរៈមិនឃើញស្រីនោះឡើយ តែដោយកម្មចាស់របស់លោក អ្នកដទៃមើលឃើញស្រីនោះក្នុងស្រុក កាលប្រគេនយាគូ ប្រគេនភិក្ខា តែងចំអន់ថា បពិត្រលោកម្ចាស់ បបរចំណែកនេះសម្រាប់លោក ចំណែកមួយទៀតសម្រាប់មិត្តស្រីរបស់ខ្ញុំនេះ ព្រះថេរៈមានសេចក្តីលំបាកក្រៃលែង ។ សាមណេរ និងភិក្ខុកំលោះទាំងឡាយ នាំគ្នាទៅកាន់វិហារ និយាយចំអន់ថា **ធានោ កោណ្ឌោ ជាតោ** លោកម្ចាស់ធានៈមានទទ្រងកើតហើយ ។

ក្នុងកាលតមក ទើបលោកកើតមានឈ្មោះបន្ថែមថា កុណ្ឌធានត្ថេរ ដោយហេតុនោះឯង លោកព្យាយាមហើយ ក៏មិនអាចអត់ធ្មត់ចំពោះពាក្យចំអន់ដែលមនុស្សទាំងនោះធ្វើ ក៏កើតមួម៉ៅឡើងពោលថា ពួកលោកនោះឯងជាទទ្រង ឧបជ្ឈាយ៍របស់ពួកលោកក៏ជាទទ្រង អាចារ្យក៏ជាទទ្រង ។ គ្រា

នោះ ភិក្ខុទាំងឡាយក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះកុណ្ឌធានពោលពាក្យគ្រោតគ្រាតយ៉ាងនេះ ជាមួយភិក្ខុកំលោះ និងសាមណេរទាំងឡាយ ។ ព្រះសាស្តាឲ្យហៅព្រះកុណ្ឌធានត្ថេរមក សួរថា ម្នាលធានបានឮថា អ្នកពោលពាក្យគ្រោតគ្រាតជាមួយភិក្ខុកំលោះ និងសាមណេរទាំងឡាយឬ កាលព្រះកុណ្ឌធានក្រាបទូលថា បពិត្រព្រះអង្គ ជាការពិត ទើបព្រះសាស្តាត្រាស់ថា ហេតុអ្វីក៏អ្នកពោលយ៉ាងនេះ ព្រះកុណ្ឌធានក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គអត់សង្កត់នូវសេចក្តីលំបាកជាប្រចាំមិនបាន ទើបពោលយ៉ាងនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកមិនអាចញុំាងកម្មដែលអ្នកធ្វើក្នុងកាលមុនឲ្យសាបសូន្យទៅបាន រហូតដល់ថ្ងៃនេះ អ្នកកុំពោលពាក្យគ្រោតគ្រាតបែបនេះទៀត ដូច្នេះហើយ ត្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថាការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយ គប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ ( រមែងមិនលាន់ឮសូរ ) ដូច្នោះ អ្នកនុ៎ះ ជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នក ដូច្នេះ ។

អ្នកនគរទាំងឡាយ ក៏ក្រាបទូលរឿងដែលព្រះធានត្ថេរត្រាច់ទៅជាមួយ

មាតុគ្រាមដល់ព្រះបាទកោសលផងដែរ ។ ព្រះរាជាទ្រង់បញ្ជូនរាជបុរសទៅដោយត្រាស់ថា នែអ្នក ចូរពួកអ្នកទៅ ចូរពិចារណាមើល ដូច្នេះហើយ សូម្បីព្រះអង្គឯង ក៏យាងទៅកាន់លំនៅរបស់ព្រះថេរៈជាមួយបរិវារបន្តិចបន្តួច ហើយទ្រង់ប្រថាប់ឈរមើលក្នុងចំណែកម្ខាង ។ ក្នុងខណៈនោះ ព្រះថេរៈអង្គុយដេរ ( ចីវរ ) ចំណែកស្រីនោះ ក៏ប្រាកដដូចឈរក្នុងទីមិនឆ្ងាយ ។ ព្រះរាជាទតឃើញហើយ ទ្រង់ព្រះតម្រិះថា ត្រូវមានហេតុម្យ៉ាង ទើបយាងទៅកាន់ទីដែលស្រីនោះឈរ កាលព្រះរាជាយាងមក ស្រីនោះ ក៏ធ្វើហាក់ដូចជាចូលទៅកាន់បណ្ណសាលាដែលជាលំនៅរបស់ព្រះថេរៈ ។

ព្រះរាជាក៏យាងចូលទៅកាន់បណ្ណសាលានោះ ជាមួយស្រីនោះមួយរំពេច ទ្រង់ពិនិត្យមើលគ្រប់កន្លែងក៏មិនឃើញ ទើបសន្និដ្ឋានថា នេះមិនមែនមាតុគ្រាម ជាកម្មវិបាកណាមួយរបស់ព្រះថេរៈ ក្នុងកាលមុន ទ្រង់យាងចូលទៅជិតព្រះថេរៈ មិនបានថ្វាយបង្គំព្រះថេរៈឡើយ កាលទ្រង់ជ្រាបថាហេតុនោះមិនពិត ត្រឡប់ចេញមកទើបទ្រង់ថ្វាយបង្គំព្រះថេរៈ ហើយប្រថាប់គង់ក្នុងទីសមគួរនាចំណែកម្ខាង ត្រាស់សួរថា បពិត្រលោកម្ចាស់ៗ មិនលំបាកដោយអាហារបិណ្ឌបាតទេឬ ព្រះថេរៈទូលថា ល្មមប្រព្រឹត្តទៅបានមហាបពិត្រ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំយល់ពាក្យសម្តីរបស់លោកម្ចាស់ កាលលោកម្ចាស់ត្រាច់ទៅជាមួយវត្ថុដែលធ្វើឲ្យសៅហ្មងបែបនេះ អ្នកណាគេនឹងជ្រះថ្លា ចាប់តាំងអំពីនេះទៅ លោកម្ចាស់ មិនមានកិច្ចដែលត្រូវទៅក្នុងទីដទៃឡើយ ខ្ញុំនឹងទំនុកបម្រុងលោកម្ចាស់ដោយបច្ច័យ ៤

សូមលោកម្ចាស់កុំប្រមាទក្នុងយោនិសោមនសិការ ដូច្នេះហើយ ទ្រង់ផ្ដើមថ្វាយនូវកិច្ចាជាប្រចាំ ព្រះថេរៈបានព្រះរាជាជាអ្នកឧបត្ថម្ភ ជាអ្នកមានឯកគ្គតាចិត្ត ព្រោះមានភោជនជាទីសប្បាយ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ចាប់តាំងអំពីនោះ ស្រីនោះ ក៏អន្តរធានទៅ ។

គ្រានោះ មហាសុភទ្ទាឧបាសិកា នៅក្នុងផ្ទះនៃត្រកូលដែលជាមិច្ឆាទិដ្ឋិ ក្នុងឧគ្គនគរ អធិដ្ឋានឧបោសថថា សូមព្រះសាស្ដាអនុគ្រោះអញ មិនលាបគ្រឿងក្រអូប ឈរលើប្រាសាទខាងលើធ្វើសច្ចកិរិយាថា សូមផ្កាទាំងនេះ កុំឈប់ក្នុងរវាងផ្លូវ ចូរជាពិដានខាងលើព្រះទសពលចុះ ដោយសញ្ញានេះ សូមព្រះទសពលទ្រង់ទទួលភិក្ខារបស់ខ្ញុំ មួយអន្លើដោយភិក្ខុ ៥០០ ក្នុងថ្ងៃស្អែកនេះ ហើយបាចផ្កាម្ដិះ ៨ ក្ដាប់ទៅ ។ ផ្កាទាំងឡាយអណ្ដែតទៅតាំងជាពិតានខាងលើព្រះសាស្ដា ក្នុងកាលដែលទ្រង់សម្ដែងព្រះធម្មទេសនា ព្រះមានព្រះភាគទតឃើញពិតានផ្កាម្ដិះនោះហើយ ទ្រង់ទទួលភិក្ខារបស់នាងសុភទ្ទាដោយចិត្តដូចគ្នា ។ ក្នុងថ្ងៃស្អែកឡើង កាលអរុណរះឡើងហើយ ទើបត្រាស់នឹងព្រះអានន្ទត្ថេរថា ម្នាលអានន្ទ ថ្ងៃនេះ ពួកយើងនឹងទៅទទួលភិក្ខាក្នុងទីឆ្ងាយ អ្នកកុំឲ្យស្លាកដល់ភិក្ខុដែលជាបុថុជ្ជន ចូរឲ្យស្លាកដល់ភិក្ខុដែលជាអរិយៈប៉ុណ្ណោះ ។ ព្រះថេរៈប្រាប់ដល់ភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ថ្ងៃនេះ ព្រះសាស្ដានឹងភិក្ខាចារក្នុងទីឆ្ងាយ ភិក្ខុដែលជាបុថុជ្ជន កុំទទួលស្លាក ភិក្ខុដែលជាព្រះអរិយៈប៉ុណ្ណោះ ចូរទទួលស្លាកដូច្នេះ ព្រះថេរៈកុណ្ឌធានលាដៃចេញទៅមុននោះឯង ដោយពោលថា អាវុសោ ចូរលោកនាំស្លាកមក ។

ព្រះអានន្ទពោលថា ព្រះសាស្តាត្រាស់មិនឲ្យប្រគល់ស្លាកដល់ភិក្ខុដូចលោកម្ចាស់ ត្រាស់ឲ្យប្រគល់ដល់ភិក្ខុដែលជាព្រះអរិយៈប៉ុណ្ណោះ ដូច្នេះហើយ ក៏កើតការរាវែកចិត្តឡើងទៅក្រាបទូលព្រះសាស្តាហើយ ព្រះសាស្តាត្រាស់ថា ចូរឲ្យស្លាកដល់បុគ្គលដែលសូម ។

ព្រះថេរៈគិតថា បើមិនគួរឲ្យស្លាកដល់ព្រះកុណ្ឌធាន ព្រះសាស្តាគង់ហាម ក្នុងរឿងនេះប្រហែលជាមានហេតុ ទើបត្រឡប់ទៅដោយគិតថា អញនឹងឲ្យស្លាកដល់ព្រះកុណ្ឌធាន ។ មុនព្រះអានន្ទមកនោះឯង ព្រះកុណ្ឌធានត្ថេរ ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ឈរក្នុងអាកាសដោយឫទ្ធិពោលថា អាវុសោអានន្ទ ព្រះសាស្តាទ្រង់ស្គាល់ខ្ញុំ ព្រះសាស្តាទ្រង់មិនឃាត់ភិក្ខុដូចខ្ញុំ ដែលចាប់ស្លាកមុនទេ ដូច្នេះហើយ លាដៃទៅចាប់ស្លាក ។ ព្រះសាស្តាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបតាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈ គឺជាកំពូលជាងភិក្ខុទាំងឡាយខាងចាប់ស្លាកបានជាលំដាប់ដំបូង ។ ព្រោះហេតុដែលព្រះថេរៈនេះមានព្រះរាជាជាអ្នកឧបត្ថម្ភ បានអាហារជាទីសប្បាយ ទើបមានចិត្តជាសមាធិ ធ្វើកម្មក្នុងវិបស្សនា បានអភិញ្ញា ៦ ព្រោះជាអ្នកសម្បូរដោយឧបនិស្ស័យ ។ ដើម្បីកម្ចាត់សេចក្តីសង្ស័យរបស់ភិក្ខុដែលជាបុថុជ្ជន ដែលមិនដឹងគុណរបស់ព្រះថេរៈនេះ ទាំងដែលមានគុណបែបនោះថា លោកម្ចាស់អង្គនេះ ចាប់ស្លាកមុនបានដូចម្តេច ទើបព្រះថេរៈហោះឡើងទៅកាន់អាកាស សម្តែងឥទ្ធិប្បាដិហារ្យ កាលព្យាករអរហត្តផលដោយអាងដល់អរហត្តផល ទើបពោលគាថាថា **បញ្ច ឆិន្ទេ** ដូច្នេះ

ជាដើម[១] ។

ព្រះថេរៈសម្រេចអរហត្ត ដោយសមគួរដល់បុញ្ញសម្ភារដែលបំពេញមកហើយយ៉ាងនេះ បានទទួលតំណែងឯតទគ្គៈហើយ រឭកដល់បុព្វកម្មកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សត្ថាហំ បដិសល្លីនំ** ដូច្នេះជាដើម ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាកុណ្ឌធានត្ថេរាបទាន ចប់**

១- សូមមើលក្នុង ខុទ្ទកនិកាយ ថេរគាថា ។

# សុត្តន្តបិដក

## សាគតត្ថេរាបទានទី ២

[ ៣៤ ] គ្រានោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសោភិតៈ មានពួកសិស្សហែហម ដើរទៅកាន់អារាម ។ សម័យនោះ ព្រះមានព្រះភាគជាបុរសឧត្តម មានពួកភិក្ខុចោមរោម ស្តេចចេញអំពីទ្វារអារាមហើយស្ថិតនៅ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធអង្គនោះ ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ មានសាវកដែលមានឥន្ទ្រិយទូន្មានហើយដែរជាបរិវារ ខ្ញុំក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយពោលសរសើរព្រះលោកនាយកថា ពួកឈើទាំងអស់ណាមួយ ពួកឈើទាំងនោះ រមែងដុះលូតលាស់លើផែនដី យ៉ាងណាមិញ សត្វទាំងឡាយ ជាអ្នកមានប្រាជ្ញា តែងចម្រើនលូតលាស់ឡើង ក្នុងសាសនារបស់ព្រះជិនស្រី ក៏យ៉ាងនោះ ។ ព្រះអង្គជាអ្នកដឹកនាំពួក ជាសព្វញ្ញូ ស្វែងរកនូវគុណធំ សូមស្រោចស្រង់នូវពួកជនជាច្រើន អំពីផ្លូវខុស ហើយប្រាប់ផ្លូវត្រូវ ។ ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ ទាំងមានសាវកដែលមានឥន្ទ្រិយទូន្មានហើយចោមរោម ព្រះអង្គមានឈាន មានពួកអ្នកត្រេកអរក្នុងឈានអ្នកមានព្យាយាម និងអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន អ្នកមានចិត្តស្ងប់រម្ងាប់ អ្នកមិនញាប់ញ័រដោយលោកធម៌ចោមរោម ។ ព្រះអង្គប្រដាប់ហើយដោយពួកបរិស័ទ ទ្រង់ល្អដោយបុណ្យ និងញាណរស្មីរបស់ព្រះអង្គ ផ្សាយចេញ ដូចព្រះអាទិត្យដែលទើប

នឹងរះឡើង ។ ព្រះមហេសីជាសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ស្ថិតនៅក្នុងភិក្ខុសង្ឃ ឃើញខ្ញុំមានចិត្តជ្រះថ្លាហើយ ត្រាស់នូវគាថាទាំងឡាយនេះថា

ព្រាហ្មណ៍ណា ញុំាំងសេចក្តីរីករាយឲ្យកើតឡើងហើយ ពោលសរសើរតថាគត ព្រាហ្មណ៍នោះ នឹងរីករាយក្នុងទេវលោក អស់សែន នៃកប្បទាំងឡាយ ។ ព្រាហ្មណ៍នោះ លុះច្យុតចាកស្ថានតុសិតមក ត្រូវកុសលមូលដាស់តឿន នឹងបួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ព្រាហ្មណ៍នោះ បួសក្នុងសាសនាហើយ នឹងបាននូវសេចក្តីត្រេកអររីករាយ មាននាមថា សាគតៈ នឹងបានជាសាវករបស់ព្រះសាស្តានោះ ។

លុះខ្ញុំបួសរួចហើយ ក៏វៀរចាកបាបកម្ម ដោយកាយ លះបង់នូវវចីទុច្ចរិត ជម្រះសម្អាតនូវអាជីវបារិសុទ្ធិសីល ។ ខ្ញុំកាលនៅយ៉ាងនេះ ជាអ្នកឈ្លាសវៃក្នុងតេជោធាតុ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសាគតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សាគតត្ថេរាបទាន ចប់

# អដ្ឋកថា

## សាគតត្ថេរាបទាន

[ ៣៤ ] *អបទានរបស់ព្រះសាគតត្ថេរ មានពាក្យផ្ដើមថា* **សោភិតោ នាម នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ មានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរ អង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភព នោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូល ព្រាហ្មណ៍មួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ សម្រេចក្នុងសិប្បៈទាំង ពួង មានឈ្មោះប្រាកដថា សោភិតៈ ជាអ្នកដល់នូវត្រើយនៃវេទ ៣ ជាអ្នក ចេះបទ ចេះវេយ្យាករណ៍ក្នុងគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈ ព្រមទាំងអក្ខរ-សាស្ត្រ មានឥតិហាសសាស្ត្រជាគម្រប់ ៥ ជាអ្នកជំនាញក្នុងលោកាយតន-សាស្ត្រ និងមហាបុរិសលក្ខណសាស្ត្រ ។ ថ្ងៃមួយ កុលបុត្តនេះ ឃើញព្រះ មានព្រះភាគព្រះនាមបទុមុត្តរៈ ជាអ្នកល្អដោយសិរីនៃមហាបុរិសលក្ខណៈ ៣២ យាងទៅតាមទ្វារព្រះរាជឧទ្យាន មានចិត្តជ្រះថ្លាក្រៃលែង បានធ្វើនូវការ សរសើរដោយឧបាយជាអនេក ដោយការសរសើរគុណជាអនេក ។ ក្នុងកាល នោះ ព្រះមានព្រះភាគទ្រង់ស្ដាប់ពាក្យសរសើរនោះ ទើបទ្រង់ប្រទានព្យាករ ថា ក្នុងអនាគតអ្នកនឹងបានជាសាវ័កឈ្មោះសាគតៈ ក្នុងសាសនារបស់ ព្រះមានព្រះភាគព្រះនាមគោតម ។ ចាប់តាំងអំពីនោះ កុលបុត្តនោះ សន្សំ បុណ្យទាំងឡាយដរាបដល់អស់អាយុ ចុតិអំពីអត្តភាពនោះហើយ កើតក្នុង ទេវលោក សោយទិព្វសម្បត្តិ និងមនុស្សសម្បត្តិក្នុងមនុស្សលោក អស់*

មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ។ មាតាបិតារបស់កុលបុត្តនោះដាក់ឈ្មោះថា សាគតៈ ព្រោះកើតមកល្អ នាំឲ្យកើតសោមនស្ស ។ កុលបុត្តនោះជ្រះថ្លាក្នុងសាសនា បួសហើយ ចម្រើនវិបស្សនា សម្រេចអរហត្តហើយ ។

កុលបុត្តនោះ សម្រេចអរហត្តផល ដោយសមគួរដល់បុញ្ញសម្ភារ ដោយប្រការដូច្នេះហើយ បានទទួលតំណែងឯតទគ្គៈ រឭកដល់បុព្វកម្មរបស់ខ្លួនហើយ កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សោភិតោ នាម នាមេន** ដូច្នេះជាដើម ។

ក្នុងគាថានោះ ភ្ជាប់សេចក្តីថា គ្រានោះ គឺក្នុងសម័យដែលបំពេញបុញ្ញសម្ភារ ខ្ញុំបានជាព្រាហ្មណ៍មានឈ្មោះថា សោភិតៈ ។

បទថា **វិបថា ឧទ្ធរិត្វាន** សេចក្តីថា ដឹកនាំ គឺនាំចេញចាកផ្លូវខុស ឬចេញចាកក្រៅផ្លូវ ហើយគ្រប់គ្រង ។ បទថា **បថំ អាចិក្ខសេ** សេចក្តីថា បពិត្រព្រះសព្វញ្ញូ ព្រះអង្គទ្រង់ប្រាប់ គឺត្រាស់សម្តែង បើកផ្សារ ចែក ធ្វើឲ្យរាក់នូវផ្លូវ គឺផ្លូវនៃសប្បុរស បានដល់ ឧបាយជាហេតុសម្រេចព្រះនិព្វាន ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាសាគតត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## មហាកច្ចាយនត្ថេរាបទានទី ៣

[ ៣៥ ] ខ្ញុំបានធ្វើចេតិយឈ្មោះបទុមៈ ជាវិការនៃថ្មផ្ទាំងថ្ម លាបដោយទឹកមាស ថ្វាយព្រះលោកនាថ ព្រះនាមបទុមុត្តរៈ ។ ខ្ញុំលើកឆត្រជាវិការនៃកែវ និងផ្លិតរោមសត្វ ថ្វាយព្រះពុទ្ធ ជាផៅពង្សនៃលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ គ្រានោះពួកភុម្មទេវតាទាំងអស់ទាំងប៉ុន្មាន បានមកប្រជុំគ្នាថា ព្រះលោកនាថ នឹងសម្តែងផលនៃអាសនៈ និងឆត្រជាវិការនៃកែវ ។ ពួកយើងនឹងស្តាប់នូវផលទាំងពួងនោះ កាលបើព្រះសាស្តាកំពុងសម្តែង ពួកយើងនឹងញ៉ាំងសេចក្តីរីករាយ ឲ្យកើតដោយក្រៃលែងក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ព្រះសយម្ភូ ជាអគ្គបុគ្គលមានភិក្ខុសង្ឃចោមរោម ទ្រង់គង់លើអាសនៈមាស ហើយត្រាស់នូវគាថាទាំងឡាយនេះថា

កុលបុត្តណា បានថ្វាយអាសនៈមាស ប្រដាប់ដោយកែវនេះ តថាគតនឹងសម្តែងសរសើរកុលបុត្តនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្តនោះនឹងបានជាធំជាងទេវតាសោយទេវរាជ្យ អស់ ៣០ កប្ប នឹងមានរស្មីគ្របសង្កត់ទី ១០០ យោជន៍ដោយជុំវិញ ។ កុលបុត្តនោះ លុះត្រឡប់មកកាន់មនុស្សលោកវិញ នឹងបានជាស្តេចចក្កពត្តិ មាននាមថាបភស្សរៈ នឹងមានតេជៈដ៏ខ្ពង់ខ្ពស់ ។ ព្រះបរមក្សត្រនោះ នឹងរុងរឿងអស់ទី ៨ ហត្ថ

ដោយជុំវិញ ទាំងថ្ងៃ ទាំងយប់ ដូចជាព្រះអាទិត្យរះឡើង ។ កន្លងទៅ មួយសែនកប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល ត្រាស់ដឹងក្នុងលោក ។ កុលបុត្តនោះច្យុត ចាកស្ថានតុសិតមក ត្រូវកុសលមូលជាស់តឿន នឹងបានជាព្រាហ្មណ៍ មាននាមកប្បានៈ ។ លុះកាលជាខាងក្រោយមក កប្បានៈនោះចេញបួស នឹងបានជាអ្នកប្រាជ្ញ មិនមានអាសវៈ ព្រះគោតមជាប្រទីបក្នុងលោក ទ្រង់នឹងតាំង ( កប្បានៈនោះ ) ក្នុងទីជាឯតទគ្គៈ ។ កប្បានៈនោះ នឹងសម្តែងនូវប្រស្នាដែលគេសួរយ៉ាងសង្ខេបដោយពិស្តារបាន មួយវិញទៀត កប្បានៈនោះ កំពុងសម្តែងនូវប្រស្នានោះ អាចនឹងបំពេញអធ្យាស្រ័យ ( របស់អ្នកសួរ ) បាន ។ កុលបុត្តនោះ កើតក្នុងត្រកូលស្តុកស្តម្ភ ជាព្រាហ្មណ៍ដល់នូវត្រើយនៃមន្ត្រ លះបង់ទ្រព្យ និងស្រូវចូលទៅកាន់ផ្នួស ។

កាលបើមានប្រស្នា ដែលជនទាំងឡាយសួរដោយបង្រួញ ខ្ញុំសម្តែងដោយពិស្តារ បំពេញអធ្យាស្រ័យនៃពួកជននោះ ខ្ញុំញុំាងព្រះសម្ពុទ្ធប្រសើរ ជាងសត្វជើងពីរឲ្យត្រេកអរ ។ ព្រះសយម្ភូជាអគ្គបុគ្គល ព្រះអង្គមានព្យាយាមធំ ដែលខ្ញុំធ្វើឲ្យរីករាយហើយ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិ-

សម្ថិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកច្ចាយនត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កច្ចាយនត្ថេរាបទាន ចប់**

# អដ្ឋកថា

## មហាកច្ចាយនត្ថេរាបទាន

[ ៣៥ ] អបទានរបស់ព្រះមហាកច្ចាយនត្ថេរ មានពាក្យផ្តើមថា **បទុមុត្តរនាថស្ស** ដូច្នេះ ។

ព្រះថេរៈរូបនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលគហបតីមហាសាល ចម្រើនវ័យហើយ ថ្ងៃមួយ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់តែងតាំងភិក្ខុមួយរូប ក្នុងតំណែងជាកំពូលនៃភិក្ខុទាំងឡាយអ្នកចែកអត្ថនៃពាក្យ ដែលទ្រង់ត្រាស់ដោយសង្ខេបឲ្យពិស្តារខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបតាំងនូវបណិធាន ហើយបំពេញបុណ្យមានទានជាដើម អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសុមេធៈ កើតជាពិទ្យាធរ ហោះទៅតាមអាកាស ឃើញព្រះសាស្តាប្រថាប់គង់មួយអង្គឯងក្នុងដងព្រៃ មានចិត្តជ្រះថ្លា បានធ្វើការបូជាដោយផ្កាកណិការ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅមកក្នុងសុគតិនោះឯងក្នុងកាលនៃព្រះទសពលព្រះនាមកស្សបៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរពារាណសី កាលព្រះមានព្រះភាគបរិនិព្វានហើយ បានធ្វើនូវការបូជាដោយឥដ្ឋដែលសម្រេចដោយមាស មានតម្លៃមួយសែន ត្រង់បល្ល័ង្កដែលសាងសុវណ្ណចេតិយ តាំងសេចក្តីប្រាថ្នាថា ដោយផលនៃបុញ្ញកម្មនេះ សូមសរីរៈ

របស់ខ្ញុំមានពណ៌ដូចមាសក្នុងទីដែលខ្ញុំកើតហើយ ។ បន្ទាប់អំពីនោះ កុល-បុត្តនោះ ធ្វើកុសលកម្មដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ អស់ ១ ពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះបុរោហិតរបស់ព្រះបាទចណ្ឌប្បជ្ជោត ក្នុងនគរឧជ្ជេនី ។ ក្នុងថ្ងៃដាក់ឈ្មោះរបស់លោក មាតាគិតថា កូនរបស់យើងមានសម្បុរដូចមាស នាំឈ្មោះរបស់ខ្លួនមក ទើបដាក់ឈ្មោះថា កញ្ចនមាណព តាមនោះ ។ កុលបុត្តនោះចម្រើនវ័យហើយ រៀនចប់ត្រៃវេទ អំណើះឥតអំពីបិតា ក៏បានតំណែងបុរោហិត ។ កុលបុត្តនោះបាននាមថា កច្ចាន: តាមគោត្ត ។ ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ស្តាប់ថា ព្រះពុទ្ធកើតឡើងហើយ ទ្រង់បញ្ជូនកុលបុត្តនោះទៅថា លោកអាចារ្យ ចូរលោកទៅក្នុងទីនោះ នាំព្រះសាស្ដាមកទីនេះចុះ កុលបុត្តនោះ មួយអន្លើដោយសម្លាញ់មានខ្លួនជាគម្រប់ ៨ ចូលទៅគាល់ព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់សម្ដែងធម៌ដល់កុលបុត្តនោះ ។ ក្នុងទីបំផុតនៃទេសនា កុលបុត្តនោះ និងជន ៧ នាក់ តាំងនៅក្នុងអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ លំដាប់នោះ ព្រះសាស្ដាទ្រង់លាព្រះហស្ដចេញត្រាស់ថា ចូរមកជាភិក្ខុចុះ ដូច្នេះ ។

ក្នុងខណៈនោះឯង ភិក្ខុទាំងនោះមានសក់ និងពុកមាត់ត្រឹម ២ ធ្នាប់ ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដូចជាព្រះថេរៈមានវស្សា ១០០ ។ ព្រះថេរៈសម្រេចប្រយោជន៍ខ្លួនហើយ ក្រាបទូលព្រះសាស្ដាយ៉ាងនេះថា បពិត្រព្រះអង្គ ព្រះបាទចណ្ឌប្បជ្ជោត ប្រាថ្នានឹងថ្វាយបង្គំព្រះបាទា

របស់ព្រះអង្គ និងស្តាប់ធម៌ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកនោះឯង មួយអន្លើដោយភិក្ខុជាទីជាគម្រប់ ៨ ចូរទៅក្នុងទីនោះ កាលអ្នកទៅហើយ ព្រះរាជានឹងជ្រះថ្លា ។ ព្រះថេរៈមានខ្លួនជាគម្រប់ ៨ ទៅក្នុងទីនោះ ញុំាង ព្រះរាជាឲ្យជ្រះថ្លា ឲ្យព្រះសាសនាប្រតិស្ឋានក្នុងអវន្តីជនបទហើយ ត្រឡប់ មកគាល់ព្រះសាស្តាម្តងទៀត ។

លោកសម្រេចអរហត្តផលយ៉ាងនេះហើយ ព្រះសាស្តាទ្រង់បានតែង តាំងក្នុងតំណែងឯតទគ្គៈ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តា ពួកភិក្ខុអ្នកចែកសេចក្តីធម៌ដែលតថាគតសម្តែងដោយសង្ខេប ឲ្យពិស្តារបាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងមហាកច្ចានៈ ដូច្នេះ ។ លោកបាន ទទួលតំណែងឯតទគ្គៈហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាលនឹងប្រកាស អបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរ-នាថស្ស** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **បទុមំ នាម ចេតិយំ** សេចក្តីថា ព្រោះបិទបាំងដោយផ្កាឈូកក្តី ព្រោះធ្វើដូចជាផ្កាឈូកក្តី លំនៅ គឺព្រះគន្ធកុដិ ជាទីគង់របស់ព្រះមានព្រះភាគនោះឯង បានជាចេតិយ ដោយ ជាទីគួរបូជា ទីគង់នៅរបស់ព្រះមានព្រះភាគអង្គនេះ លោកហៅថា ចេតិយ ព្រោះជាទីគួរបូជា ដូចស្ថានទីដែលហៅថា គោតមចេតិយ អាឡវកចេតិយ ជាទីលំនៅរបស់យក្សទាំងនោះ លោកហៅថា ចេតិយ ព្រោះជាទីដែលគួរ បូជា យ៉ាងណា ទីគង់របស់ព្រះមានព្រះភាគនេះ ហៅថា ចេតិយ ក៏យ៉ាង នោះ គប្បីជ្រាបថា មិនមែនចេតិយបញ្ចុះព្រះធាតុ ។ កុលបុត្តនោះ មិនបាន

*សាងធាតុចេតិយឡើយ ព្រោះព្រះមានព្រះភាគ មិនទាន់បរិនិព្វាន ទើបមិនមានព្រះសរីរិកធាតុ ។ បទថា* **សិលាសនំ ការយិត្វា** *សេចក្តីថា បានសាងផ្ទាំងថ្ម ដែលសម្រេចដោយកែវផលិក ខាងក្នុងនៃព្រះគន្ធកុដិ ដែលមានឈ្មោះថា បទុមនោះ ដើម្បីជាទីដាក់ផ្កា ។ បទថា* **សុវណ្ណេនាភិលេបយឹ** *សេចក្តីថា ខ្ញុំបានបូកលាបបិទបាំងផ្ទាំងសិលានោះ ដោយមាសជម្ពូនទឲ្យល្អក្រៃលែងឡើង ។*

*ខ្ញុំបានលើកឆត្រដែលធ្វើដោយរតនៈ គឺធ្វើដោយរតនៈ ៧ ប្រការ ហើយបាំងលើព្រះសិរសា ព័តដោយផ្ចិតវាលវីជនី និងផ្ចិតចាមរីពណ៌សយ៉ាងល្អថ្វាយព្រះពុទ្ធ ។ បទថា* **លោកពន្ធុស្ស តាទិនោ** *សេចក្តីថា ខ្ញុំបានបាំងថ្វាយព្រះពុទ្ធដែលជាផៅពង្សនៃលោកទាំងមូល ជាតាទិបុគ្គល គឺបុគ្គលដល់ព្រមដោយគុណ មានសតិជាដើម ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។*

## អដ្ឋកថាមហាកច្ចាយនត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ខុទ្ទកនិកាយ អបទានទី ៤

[ ៣៦ ] គ្រានោះ ព្រះបទុមុត្តរសម្ពុទ្ធ ព្រះអង្គជាច្បងក្នុងលោក មិនញាប់ញ័រដោយលោកធម៌ ស្តេចយាងតាមផ្លូវច្រាយ ត្រាច់ទៅកាន់ចារិក ។ ខ្ញុំកាន់ផ្កាឈូក ផ្កាឧប្បល ផ្កាម្លិះ ដែលរីកស្គុះស្គាយ ទាំងយកចង្ហាន់ដ៏ថ្លៃថ្លា បង្អោនទៅថ្វាយព្រះសាស្តា ។ ព្រះសម្ពុទ្ធព្រះអង្គមានព្យាយាមធំ ទ្រង់ឆាន់ចង្ហាន់ដ៏ប្រសើរ ជាភោជនដ៏ល្អរួចហើយ ទ្រង់កាន់នូវផ្កាទាំងនោះ បង្ហាញដល់ប្រជុំជនថា

បុរសនោះ បានថ្វាយផ្កាឈូកណា ដល់តថាគត ផ្កាឈូកនេះដ៏ឧត្តម ជាទីប្រាថ្នា ជាទីត្រេកអរ ( របស់ជន ) ក្នុងលោក អំពើដែលគេធ្វើ បានដោយកម្រ បុរសនោះ ក៏បានធ្វើហើយ ។ បុរសណា បានបូជាផ្កា ទាំងថ្វាយចង្ហាន់ដ៏ប្រសើរ ដល់តថាគត តថាគតនឹងសម្តែងសរសើរបុរសនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនោះ នឹងបានសោយទេវរាជ្យ អស់ ១៨ ដង ឯផ្កាឧប្បល ផ្កាឈូក ផ្កាម្លិះ និងផ្កាដទៃ ក្រៅពីនោះ ដែលប្រកបដោយក្លិនដ៏ជាទិព្វ នឹងអណ្តែត ធ្វើឲ្យជាគ្រឿងប្រក់ពួដ៏អាកាស ក្នុងខណៈនោះ ដោយផលនៃបុណ្យរបស់បុរសនោះ ។ បុរសនោះ នឹងបានជាស្តេចចក្កពត្តិ អស់ ២៥ ដង នឹងបានសោយរាជ្យ លើផែនដី គ្រប់គ្រងផែនដី អស់ ៥០០ ដង ។ កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តាព្រះនាមគោតម ទ្រង់

កើតក្នុងឱក្កាកត្រកូល ត្រាស់ដឹងក្នុងលោក ។ បុរសនោះ មានកម្មរបស់ខ្លួនប្រារព្ធហើយ មានកុសលមូលជាស់តឿនហើយ នឹងបានកើតជាព្រះញាតិផៅពង្ស ជាអ្នកញ៉ាំងពួកសក្យៈ ឲ្យកើតសេចក្តីត្រេកអរ ។ លុះកាលជាខាងក្រោយមក បុរសនោះ នឹងចេញបួស ត្រូវកុសលមូលជាស់តឿន កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះគោតម ព្រះអង្គជាផៅពង្សនៃសត្វលោក នឹងតាំងភិក្ខុនោះ ដែលដល់បដិសម្ភិទាហើយ មានសោឡសកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ ក្នុងទីជាឯតទគ្គៈ ។ ភិក្ខុនោះ តាំងព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានចិត្តស្ងប់រម្ងាប់ មិនមានឧបធិ មាននាមថាឧទាយិ នឹងបានជាសាវ័ក របស់ព្រះសាស្តាអង្គនោះ ។

ខ្ញុំកម្ចាត់បង់រាគៈ ទោសៈ មោហៈ មានះ និងមក្ខៈ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ មួយវិញទៀត ខ្ញុំមានព្យាយាម មានប្រាជ្ញាចាស់ បានញ៉ាំងព្រះសម្ពុទ្ធឲ្យត្រេកអរ ឯព្រះសម្ពុទ្ធ ដែលខ្ញុំបានធ្វើឲ្យជ្រះថ្លាហើយ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន

ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះកាឡុទាយិត្ថេរមានអាយុ បានសម្តែងនូវគាថា ទាំងនោះ ដោយប្រការដូច្នេះ ។

## កាឡុទាយិត្ថេរាបទាន ចប់

# អដ្ឋកថា

## កាឡុទាយិត្ថេរាបទាន

[ ៣៦ ] *អបទានរបស់ព្រះកាឡុទាយិត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងដ៏កំពូលជាងភិក្ខុទាំងឡាយ ដែលញុំាងត្រកូលឲ្យជ្រះថ្លា ទើបធ្វើនូវកម្មដ៏ធំដែលនឹងឲ្យបានតំណែងនោះ ហើយប្រាថ្នាតំណែងនោះ ។*

*កុលបុត្តនោះ បំពេញកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងថ្ងៃដែលព្រះពោធិសត្វនៃយើងបដិសន្ធិក្នុងផ្ទៃមាតា កុលបុត្តនោះ ក៏បដិសន្ធិក្នុងផ្ទះនៃអមាត្យក្នុងនគរកបិលពស្ដុ ហើយកើតក្នុងថ្ងៃតែមួយជាមួយព្រះពោធិសត្វនោះឯង ។ ក្នុងថ្ងៃនោះ កុលបុត្តនោះ ដេកលើរង្វើលសំពត់ទុកូលយ៉ាងល្អ ហើយទៅកាន់ទីគាល់របស់ព្រះពោធិសត្វ ។ ពិតហើយ សហជាតមាន ៧ គឺពោធិព្រឹក្ស ១ រាហុលមាតា ១ កំណប់ទ្រព្យទាំងបួន ១ សេះកណ្ឋកៈ និងដំរីអាកោហនៈ*[១] *១ ព្រះអានន្ទ ១ នាយឆន្ន ១ កាឡុទាយី ១ មួយអន្លើដោយព្រះពោធិសត្វ បានឈ្មោះថា*

---

**១- ក្នុងអដ្ឋកថាខ្វះ មិនមានដំរីអាកោហនៈនេះឡើយ ។**

សហជាត ព្រោះកើតក្នុងថ្ងៃតែមួយជាមួយព្រះពោធិសត្វ ។ ក្នុងថ្ងៃដាក់ឈ្មោះ ញាតិទាំងឡាយបានដាក់ឈ្មោះថា ឧទាយី ព្រោះកើតមក ធ្វើឲ្យអ្នកនគរមាន ការត្រេកអរ ។ តែព្រោះមានសម្បុរខ្មៅបន្តិច ទើបប្រាកដឈ្មោះថា កាឡុទាយី ។ កុលបុត្តនោះ លេងជាមួយព្រះពោធិសត្វមក តាំងអំពីកុមារ រហូតដល់ចម្រើនវ័យ ។

ក្រោយមក កាលព្រះលោកនាថចេញមហាភិនិស្ក្រមណ៍ សម្រេចនូវព្រះសព្វញ្ញុតញ្ញាណដោយលំដាប់ ប្រកាសព្រះធម្មចក្កដ៏បវរ ទ្រង់អាស្រ័យក្រុងរាជគ្រឹះ គង់នៅត្រង់វត្តវេឡុវ័ន ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ស្តាប់ដំណឹងនោះ ទើបបញ្ជូនអមាត្យម្នាក់ មានបុរសមួយពាន់ជាបរិវារទៅ ដោយត្រាស់ថា ចូរនាំកូនរបស់យើងមកទីនេះ ។ អមាត្យនោះ ទៅគាល់ព្រះសាស្តាក្នុងពេលសម្តែងធម៌ ឈរខាងចុងបរិស័ទស្តាប់ធម្មទេសនាហើយ សម្រេចអរហត្ត មួយអន្លើដោយបរិវារ ។

លំដាប់នោះ ព្រះសាស្តាទ្រង់លាព្រះហស្ត ត្រាស់នឹងកុលបុត្តនោះថា ចូរពួកអ្នកមកជាភិក្ខុចុះ ។ ក្នុងខណៈនោះឯង កុលបុត្តទាំងអស់នោះ ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដូចជាព្រះថេរៈដែលមានវស្សា ៦០ ។ ចាប់តាំងអំពីសម្រេចអរហត្តហើយ ព្រះអរិយៈទាំងឡាយ មានអារម្មណ៍ជាកណ្តាល ព្រោះហេតុនោះ ទើបមិនក្រាបទូលដំណឹងដែលព្រះរាជាបញ្ជូនទៅឲ្យព្រះទសពលទ្រង់ជ្រាប ។ ព្រះរាជាមិនបានដំណឹង ទើបទ្រង់បញ្ជូនអមាត្យដទៃទៅជាមួយបុរសមួយពាន់ កាលអមាត្យនោះបដិបត្តិ

ដូចគ្នា ទ្រង់ក៏បញ្ជូនអមាត្យ ៩ នាក់ទៅទៀត មួយអន្លើនឹងបុរស ៩ ពាន់ ដោយអាការយ៉ាងនេះ ។ មនុស្សទាំងនោះ សម្រេចអរហត្តហើយ បានជាអ្នកនៅស្ងៀម ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា មនុស្សមានប្រមាណប៉ុណ្ណេះ ព្រោះមិនស្រឡាញ់ក្នុងអញ ទើបមិនប្រាប់ពាក្យណាមួយ ដើម្បីឲ្យព្រះទសពលយាងមកទីនេះ ឧទាយីនេះឯង មានវ័យជំណាលព្រះទសពល ធ្លាប់ជាសម្លាញ់លេងដីជាមួយគ្នា និងមានសេចក្ដីស្រឡាញ់ក្នុងអញ អញនឹងបញ្ជូនគេទៅ ទើបត្រាស់ឲ្យហៅឧទាយីនោះមក ហើយត្រាស់ថា នែបា ចូរបា មួយអន្លើដោយបុរសមួយពាន់ជាបរិវារ ទៅកាន់នគររាជគ្រឹះ នាំព្រះទសពលមក ដូច្នេះហើយ ទ្រង់បញ្ជូនទៅ ។ ឧទាយិអមាត្យទូលថា បពិត្រព្រះសម្មតិទេព បើទូលបង្គំបានព្រះរាជានុញ្ញាតឲ្យបួសសោត ទូលបង្គំនឹងនាំព្រះមានព្រះភាគមកក្នុងទីនេះ កាលព្រះរាជាត្រាស់ថា អ្នកធ្វើយ៉ាងណាក៏បាន ឲ្យតែនាំកូនរបស់យើងមក ទើបទៅកាន់នគររាជគ្រឹះ គាប់ជួនជាពេលដែលព្រះសាស្ដាទ្រង់សម្ដែងធម៌ ទើបឈរខាងចុងបរិស័ទ ស្ដាប់ធម៌ហើយ សម្រេចអរហត្ត មួយអន្លើដោយបរិវារ តាំងនៅក្នុងភាពជាឯហិភិក្ខុ ។

កាលលោកសម្រេចអរហត្តហើយ ទើបរង់ចាំកាលថា ឥឡូវនេះ មិនជាកាលដែលព្រះទសពលយាងទៅកាន់នគរនៃត្រកូល តែកាលកៀករដូវភ្លៀង ដងព្រៃចេញផ្កាចេញផ្លែ ទើបជាកាលគួរយាងទៅលើភូមិភាគដ៏រាបស្មើ មានស្មៅពណ៌ខៀវស្រស់ កាលដល់រដូវភ្លៀង ពោលពណ៌នាសរសើរផ្លូវទៅកាន់នគរនៃត្រកូលដល់ព្រះសាស្ដា ទើបបានពោលគាថា ( ក្នុងខុទ្ទក-

និកាយ ថេរគាថា ) ទាំងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើក ភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះ រុងរឿង ដូចជាអណ្តាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ ជាកាលគួរបានចំណែកធម្មរសហើយ ។ ឈើទាំង ឡាយ ជាទីរីករាយនៃចិត្ត មានផ្លែ ផ្សាយក្លិនសព្វទិស ដោយ ជុំវិញ ជម្រុះស្លឹកចាស់ចោល ប្រុងនឹងចេញផ្លែថ្មីទៀត បពិត្រ ព្រះអង្គមានព្យាយាម កាលនេះ ជាកាលគួរដើម្បីចេញទៅ អំពី ទីនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិន ក្តៅពេក ជាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ពួកសក្យៈ និងពួកកោឡិយៈ សូមជួបព្រះអង្គ ដែលមានព្រះភក្ត្រ បែរ ត្រឡប់មកខាងក្រោយ កំពុងឆ្លងស្ទឹងរោហិណី ។

អ្នកស្រែភ្ជួរស្រែ ដោយសេចក្តីប្រាថ្នាព្រោះពូជ ដោយសេចក្តី ប្រាថ្នា ពួកឈ្មួញ អ្នករកទ្រព្យឆ្លងសមុទ្រ ដោយសេចក្តីប្រាថ្នា ។ ខ្ញុំព្រះអង្គស្ថិតនៅ ដោយសេចក្តីប្រាថ្នាណា សេចក្តីប្រាថ្នារបស់ខ្ញុំ ព្រះអង្គនោះ សូមឲ្យសម្រេច ។

រដូវនេះ មិនត្រជាក់ពេក មិនក្តៅពេក កិច្ចារកបានងាយ មិន លំបាក ភូមិភាគ ក៏ស្បូវភ្លាំងខៀវខ្ចី បពិត្រមហាមុនី ពេលនេះ ជាពេលសមគួរ ( ដើម្បីយាង ) ហើយព្រះអង្គ ។

អ្នកស្រែទាំងឡាយ ព្រោះពូជរឿយៗ ទេវរាជបង្អុរភ្លៀងក៏រឿយៗ ពួកអ្នកស្រែ ភ្ជួរស្រែរឿយៗ ពួកអ្នកស្រែនោះនាំស្រូវចូលទៅកាន់ដែនក៏រឿយៗ ។ ពួកស្មូមត្រាច់សូមរឿយៗ អ្នកម្ចាស់ទានតែងឲ្យក៏រឿយៗ ពួកម្ចាស់ទានលុះឲ្យរឿយៗ ហើយតែងទៅកាន់ស្ថានសួគ៌ក៏រឿយៗ ដែរ ។ អ្នកប្រាជ្ញមានបញ្ញាដូចផែនដី កើតក្នុងត្រកូលណា រមែងញ៉ាំងគូនៃបុរស ៧ ជួរ ក្នុងត្រកូលនោះឲ្យស្អាត ខ្ញុំព្រះអង្គសម្គាល់ថា ( ព្រះមានព្រះភាគ ) ជាទេវតាប្រសើរជាងទេវតា អាច ( ធ្វើសត្វដទៃឲ្យស្អាតបាន ) ព្រោះអ្នកប្រាជ្ញមានព្រះនាមដ៏ពិត កើតហើយអំពីព្រះអង្គ ។ ព្រះបាទសុទ្ធោទនៈ ជាបិតារបស់ព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ឯព្រះមហេសី ព្រះនាមមាយា ជាពុទ្ធមាតា ដែលរក្សាព្រះពោធិសត្វដោយផ្ទៃ លុះរំលាយខន្ធទៅ ត្រេកអរក្នុងតុសិត-ទេវលោក ។ ព្រះនាងទេវីនោះ ជាគោតមគោត្រ លុះទិវង្គតច្យុតចាកលោកនេះទៅ បានស្កប់ស្កល់ដោយកាម ជាទិព្វទាំងឡាយ ព្រះនាងទ្រង់រីករាយ ដោយកាមគុណទាំង ៥ មានពពួកទេវតាទាំងនោះ ចោមរោមហើយ ។

បណ្តាបទទាំងនោះ បទថា **អង្គារិនោ** ឈ្មោះថា **អង្គារ** ព្រោះដូចគ្នានឹងរងើកភ្លើង ។ ដើមឈើទាំងនោះ មានផ្កា និងផ្លែ មានពណ៌ ដូចកែវប្រពាលក្រហម ដូចអណ្តាតភ្លើង ព្រោះហេតុនោះ ទើបឈ្មោះថា **អង្គារ**

អធិប្បាយថា ដេរដាសដោយផ្កាជកគាំ និងផ្ការលួសផ្អុង មានពណ៌ក្រហម ដូចអណ្តាតភ្លើង ដូចភ្លៀងរងើកភ្លើង ។ បទថា **ធាធិ** ស្មើគ្នានឹង **ឥមស្មឹ កាលេ** ( ក្នុងកាលនេះ ) ។ បទថា **ទុមា** ប្រែថា ដើមឈើ ។ ដោយបទថា **ភទន្តេ** លោកពោលថា **ភទន្តេ** ព្រោះព្រះមានព្រះភាគមានសេចក្តីចម្រើន ដោយលុប **ទ** អក្ខរៈមួយតួចេញ ។ ព្រះសាស្តាជាបុគ្គលប្រកបដោយគុណវិសេស ជាបុគ្គលប្រសើរជាងបុគ្គលវិសេស ដោយគុណទាំងឡាយ ព្រោះហេតុនោះ ទើបពាក្យថា **ភទន្តេ** ជាពាក្យប្រើហៅព្រះសាស្តានោះឯង ។ បទថា **ភទន្តេ** នេះ ជាបឋមាវិភត្តិ **ឯ** ការន្ត ដូចក្នុងប្រយោគថា **សុគតេ បដិកម្មេ សុខេ ទុក្ខេ ជីវេ** ជាដើម តែក្នុងទីនេះ គប្បីឃើញថា ចុះក្នុងអត្ថនៃការត្រាស់ដឹង ព្រោះហេតុនោះ ទើបខ្ញុំពោលថា ពាក្យថា **ភទន្តេ** ជាអាលបនៈ ។ អាចារ្យពួកខ្លះពោលថា **ភទន្តេ** មួយសព្ទដែលនៅកណ្តាលពាក្យ មានអត្ថស្មើនឹង **ភទ្ទ** សព្ទ ។ ឈ្មោះថា **ផលេសិនោ** ព្រោះចេញផ្លែ ។ ពិតហើយ សូម្បីរបស់មិនមានចិត្ត លោកដាក់ពាក្យកិរិយារបស់វត្ថុមិនមានចិត្តចូលទៅក៏បាន ។

ព្រះមានព្រះភាគ កាលព្រះថេរៈទូលអារាធនាយ៉ាងនេះហើយ ទ្រង់ឃើញថា ក្នុងការយាងទៅក្នុងទីនោះ មនុស្សជាច្រើននឹងបានសម្រេចគុណវិសេស ទើបចោមរោមដោយព្រះខីណាស្រព ២ ម៉ឺនអង្គ ចេញអំពីនគររាជគ្រឹះ ទៅតាមផ្លូវទៅកាន់នគរកបិលពស្តុ ជាការយាងទៅដោយមិនប្រញាប់ប្រញាល់ ។ ព្រះថេរៈទៅកាន់នគរកបិលពស្តុដោយឫទ្ធិ ឈរលើអាកាសខាងមុខព្រះរាជា

កាលព្រះរាជាឃើញនូវភេទដែលមិនធ្លាប់ឃើញ ទើបត្រាស់សួរថា លោកជានរណា កាលទូលឲ្យទ្រង់ជ្រាបថា ទ្រង់មិនស្គាល់អាត្មាទេឬ អាត្មាជាបុត្តអមាត្យ ដែលទ្រង់បញ្ជូនទៅកាន់សម្នាក់ព្រះមានព្រះភាគនោះអី សូមទ្រង់ជ្រាបយ៉ាងនេះចុះ ទើបពោលគាថាថា

អាត្មាជាបុត្រនៃព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃគ្របសង្កត់បាន
ព្រះនាមអង្គីរសៈ មិនមានបុគ្គលដទៃប្រៀបបាន ប្រកបដោយ
តាទិគុណ បពិត្រព្រះអង្គជាសក្យៈ ព្រះអង្គជាបិតានៃបិតារបស់
អាត្មា បពិត្រព្រះគោតម ព្រះអង្គជាជីតារបស់អាត្មាដោយធម៌ ។

បណ្ដាបទទាំងនោះ បទថា **ពុទ្ធស្ស បុត្តោម្ហិ** សេចក្ដីថា អាត្មាជាបុត្តគឺអ្នកកើតអំពីទ្រូងរបស់ព្រះសព្វញ្ញុពុទ្ធ ។ បទថា **អសយ្ហសាហិនោ** សេចក្ដីថា ឈ្មោះថា **អសយ្ហសាហិនោ** ព្រោះនាំទៅ គឺនាំចេញនូវពោធិសម្ភារនិងមហាករុណាទិគុណទាំងពួង ដែលឈ្មោះថា **អសយ្ហសាហិនោ** ព្រោះមិនមានអ្នកដទៃអាចនាំទៅ គឺនាំចេញនូវព្រះមហាពោធិសត្វ ចាកការត្រាស់ដឹងមុននឹងបានត្រាស់ដឹង ក្រោយអំពីនោះ ព្រោះញាំញី គឺគ្របសង្កត់នូវមារ ៥ ដែលឈ្មោះថា ញាំញីមិនបាន ព្រោះអ្នកដទៃមិនអាចញាំញី គឺគ្របសង្កត់បាន និងព្រោះទ្រង់អត់ធន់ចំពោះពុទ្ធកិច្ច ដែលអ្នកដទៃអត់ធន់បានដោយក្រ ដែលបានដល់ការប្រៀនប្រដៅវេនេយ្យសត្វ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍តាមសមគួរ ដោយការឈមចុះដល់ការផ្សេងគ្នារបស់សត្វ តាមអាសយានុសយចរិត និងអធិមុត្តិជាដើម

ម្យ៉ាងទៀត ឈ្មោះថា **អសយ្ហសាហិនោ** ក្នុងទីនេះ ព្រោះទ្រង់ធ្វើល្អ ។

បទថា **អង្គីរសស្ស** បានដល់ ជាអ្នកមានសម្បត្តិ មានសីលជាដើម ដែលប្រកបឡើងជាព្រះអង្គ ។ តែអាចារ្យពួកខ្លះពោលថា ជាអ្នកមានរស្មី ផ្សាយចេញអំពីព្រះអវយវៈតូចធំ ដូច្នេះក៏មាន ។ អាចារ្យពួកខ្លះពោលថា ព្រះនាមពីរ គឺអង្គីរសៈ និងសុទ្ធោទនៈ ព្រះរាជបិតាទ្រង់ដាក់ឲ្យ ។ បទថា **អប្បដិមស្ស** ប្រែថា មិនមានបុគ្គលប្រៀប មិនមានបុគ្គលស្មើ ឈ្មោះថា **តាទិនោ** ព្រោះមានលក្ខណៈមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ បទថា **បិតុបិតា មយ្ហំ តុវំសិ** សេចក្តីថា ទ្រង់ជាបិតារបស់ព្រះពុទ្ធ តាមលោកវោហារ ដែលជាបិតារបស់អាត្មាតាមអរិយជាតិ ។ លោកហៅព្រះរាជាដោយអំណាចជាតិថា សក្យៈ ។ បទថា **ធម្មេន** សេចក្តីថា ដោយសភាវៈ គឺដោយរួមជាតិទាំងពីរ គឺអរិយជាតិ និងលោកិយជាតិ ចូលជាមួយគ្នា ។ ហៅព្រះរាជាដោយគោត្តថា គោតម ។ បទថា **អយ្យកោសិ** គឺទ្រង់ជាជីតា ។ ក្នុងគាថានេះ កាលព្រះថេរៈពោលថា អាត្មាជាបុត្រនៃព្រះពុទ្ធជាដើម ស្មើគ្នានឹងបានព្យាករអរហត្តផលហើយ ។

ព្រះថេរៈ កាលឲ្យព្រះរាជាស្គាល់យ៉ាងនេះហើយ កាលព្រះរាជាទ្រង់ពេញព្រះហឫទ័យ និមន្តឲ្យគង់លើបល្ល័ង្ក ដែលមានតម្លៃច្រើន ដាក់ភោជនមានរសដ៏ប្រសើរផ្សេងៗ ដែលគេរៀបចំដើម្បីព្រះអង្គរហូតពេញបាត្រ ហើយប្រគេន បានសម្តែងអាការនឹងទៅ កាលត្រូវសួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបលោកម្ចាស់ប្រញាប់នឹងទៅ សូមលោកម្ចាស់ ឆាន់សិនចុះ ទើប

ទូលថា អាត្មានឹងទៅគាល់ព្រះសាស្តា ទើបឆាន់ ។ ព្រះរាជាត្រាស់សួរថា ព្រះសាស្តានៅទីណា ក៏ពោលថា ព្រះសាស្តាមានភិក្ខុ ២ ម៉ឺនរូបជាបរិវារ កំពុងយាងមកតាមផ្លូវដើម្បីគាល់ព្រះអង្គ ។ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ឆាន់បិណ្ឌបាតនេះ សឹមនាំបិណ្ឌបាតដទៃទៅថ្វាយ ដល់ព្រះមានព្រះភាគ សូមនាំបិណ្ឌបាតអំពីទីនេះ ទម្រាំកូនរបស់ខ្ញុំមកដល់នគរនេះ ទើបព្រះថេរៈធ្វើកត្តកិច្ចហើយ សម្តែងធម៌ដល់ព្រះរាជា និងបរិស័ទ ។ មុនពេលព្រះសាស្តាយាងមកដល់ ព្រះថេរៈបានធ្វើឲ្យមនុស្សក្នុងព្រះរាជវាំងទាំងអស់ជ្រះថ្លាក្រៃលែងក្នុងព្រះតថាគត និងក្នុងព្រះរតនត្រ័យហើយ កាលមនុស្សទាំងអស់កំពុងឃើញនោះឯង ក៏បោះបាត្រដែលពេញដោយភត្ត ដែលខ្លួននាំមកថ្វាយព្រះសាស្តា ទៅក្នុងអាកាស ខ្លួនលោកក៏ហោះឡើងទៅកាន់អាកាស ហើយបង្អោនបិណ្ឌបាតក្នុងព្រះហស្តព្រះសាស្តា ។ ព្រះសាស្តាទ្រង់សោយបិណ្ឌបាតនោះ កាលព្រះមានព្រះភាគយាងទៅមួយថ្ងៃមួយយោជន៍ ជារយៈផ្លូវ ៦០ យោជន៍ អំពីនគររាជគ្រឹះ លោកបាននាំបិណ្ឌបាតមកប្រគេនដោយវិធីនេះ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់តម្រិះថា កាឡុទាយីនេះ ញុំាងអ្នករាជវាំងទាំងមូល នៃបិតារបស់តថាគតឲ្យជ្រះថ្លា ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈ នៃភិក្ខុទាំងឡាយ ដែលញុំាងត្រកូលឲ្យជ្រះថ្លាថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកញុំាងត្រកូលឲ្យជ្រះថ្លា ដែលជាសាវករបស់តថាគត ស្រេចនឹងកាឡុទាយី ដូច្នេះ ។

ព្រះថេរៈសម្រេចអរហត្ត ដោយសមគួរដល់បុញ្ញសម្ភារដែលធ្វើមក

បានទទួលតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចសោមនស្ស ទើបពោលពាក្យនេះថា **បទុមុត្តរស្ស ពុទ្ធស្ស** ដូច្នេះជាដើម ។ បទថា **អទ្ធានំ បដិបន្នស្ស** សេចក្តីថា កំពុងយាងទៅកាន់ផ្លូវឆ្ងាយទៅកាន់រដ្ឋដទៃ ។ បទថា **ចរតោ ចារិកំ តទា** សេចក្តីថា មណ្ឌលមាន ៣ គឺមណ្ឌលខាងក្នុង មណ្ឌលកណ្តាល និងមណ្ឌលខាងក្រៅ ។ ភ្ជាប់សេចក្តីថា កាលព្រះមានព្រះភាគព្រះនាមបទុមុត្តរៈត្រាច់ចារិក គឺកំពុងយាងទៅ ខ្ញុំកាន់យកផ្កាឈូកជាដើមដែលរីកស្គុសស្គាយ គឺរីកយ៉ាងល្អ រីកព្រម មិនមែនកាន់យកត្រឹមតែផ្កាឈូកតែម្យ៉ាង ថែមទាំងកាន់យកផ្កាឧប្បល និងផ្កាម្លិះ ដែលរីកហើយ ដោយដៃទាំងពីរបហូតពេញ ។ បទថា **បរមន្នំ គហេត្វាន** សេចក្តីថា ខ្ញុំបានកាន់យកបាយនៃស្រូវសាលីដែលឆ្អិនផ្សំយ៉ាងល្អ ដោយរសគ្រប់យ៉ាងដ៏ថ្លៃថ្លា គឺឧត្តមប្រសើរបំផុត ថ្វាយព្រះសាស្តាឲ្យទ្រង់សោយ ។

បទថា **សក្យានំ នន្ទិជននោ** សេចក្តីថា ឲ្យកើតនូវការត្រេកអរ គឺសេចក្តីត្រេកអរដល់សក្យត្រកូល គឺនៃព្រះញាតិរបស់ព្រះមានព្រះភាគ ព្រោះមានសរីរៈខ្ពស់ធំសង្ហារសមនឹងវ័យ ប្រាស្រ័យពីរោះ ។ បទថា **ញាតិពន្ធុ ភវិស្សតិ** សេចក្តីថា នឹងជាផៅពង្សដែលមានឈ្មោះ គឺជាអ្នកដែលគេស្គាល់ទូទៅ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថាកាឡុទាយិត្ថេរាបទាន ចប់

# សុត្តន្តបិដក

## មោឃរាជត្ថេរាបទានទី ៥

[ ៣៧ ] កាលនោះ ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាព្រះសយម្ភូ ឥតមានបុគ្គលផ្ចាញ់បាន មានភិក្ខុសង្ឃចោមរោមស្តេចយាងទៅតាមថ្នល់ ។ ខ្ញុំមានពួកសិស្សហែហមដើរចេញអំពីផ្ទះ លុះចេញទៅ ក៏បានឃើញព្រះលោកនាយក ត្រង់ទីនោះ ។ ខ្ញុំធ្វើអញ្ជលីលើសិរ្ស: ថ្វាយបង្គំព្រះសម្ពុទ្ធ ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយពោលសរសើរព្រះលោកនាយកថា ពួកសត្វមានរូបក្តី ឥតរូបក្តី ឥតសញ្ញាក្តី ទាំងប៉ុន្មាន ពួកសត្វទាំងអស់នោះ តែងប្រជុំចុះខាងក្នុងញាណរបស់ព្រះអង្គ ។ បុគ្គលណាបិទបាំងទឹកដោយសំណាញ់ មានក្រឡាញឹក ពួកសត្វណាមួយនៅក្នុងទឹក ពួកសត្វទាំងនោះ រមែងមាននៅខាងក្នុងសំណាញ់ ( របស់បុគ្គលនោះ ដូចម្តេចមិញ ) ។ សត្វទាំងឡាយណាដែលមានចេតនា ទោះបីមានរូបក្តី ឥតរូបក្តី ពួកសត្វទាំងអស់នោះ រមែងប្រជុំចុះខាងក្នុងញាណរបស់ព្រះអង្គ ( ដូច្នោះដែរ ) ។ ព្រះអង្គស្រោចស្រង់សត្វលោកនេះ ដែលច្រឡូកច្រឡំដោយងងឹត សត្វទាំងនោះ ស្តាប់នូវធម៌របស់ព្រះអង្គហើយ ឆ្លងនូវខ្សែទឹក គឺសេចក្តីសង្ស័យបាន ។ សត្វលោក មានអវិជ្ជារួបរឹត មានងងឹតគ្របសង្កត់ហើយ នឹងកម្ចាត់ងងឹតទាំងឡាយ ព្រោះញាណរបស់ព្រះអង្គដែលទ្រោលឡើង ។ ព្រះអង្គមានចក្ខុ បន្ទោបង់នូវ

ឧឝឹតធំរបស់សត្វទាំងពួង ជនជាច្រើន លុះស្តាប់ធម៌របស់ព្រះអង្គហើយ នឹងបានសម្រេចព្រះនិព្វាន ។ ខ្ញុំញ៉ាំងកោជនឲ្យពេញដោយឃ្មុំផ្អិត ដែលឥតមេ ហើយទ្រដោយដៃទាំងពីរ បង្អោនចូលទៅថ្វាយព្រះមហេសី ។ ព្រះពុទ្ធជាមហាឥសី ព្រះអង្គមានព្យាយាមធំ ទ្រង់ទទួលដោយព្រះហស្តរបស់ព្រះអង្គ ព្រះសព្វញ្ញូទ្រង់សោយនូវឃ្មុំនោះរួចហើយ ស្តេចហោះឡើងកាន់អាកាសវេហាស៍ ។ ព្រះសាស្តា ព្រះនាមអត្ថទស្សី ជានរាសភៈ ស្ថិតនៅឰដ៏អាកាស ទ្រង់ញ៉ាំងចិត្តរបស់ខ្ញុំឲ្យជ្រះថ្លា ហើយត្រាស់គាថាទាំងឡាយនេះថា

កុលបុត្តណា សរសើរញាណនេះផង សរសើរព្រះពុទ្ធដ៏ប្រសើរផង កុលបុត្តនោះ នឹងមិនទៅកាន់ទុគ្គតិ ដោយចិត្តដែលជ្រះថ្លានោះ ។ កុលបុត្តនោះ នឹងបានសោយទេវរាជ្យ អស់ ៦៤ ដង នឹងបានសោយប្រទេសរាជ្យ គ្រប់គ្រងផែនដី អស់ ៨០០ ដង នឹងបានជាស្តេចចក្កពត្តិ អស់ ៥០០ ដង ។ កុលបុត្តនោះ នឹងបានសោយប្រទេសរាជ្យលើផែនដី អស់មួយអសង្ខេយ្យ ជាអ្នកស្វាធ្យាយមន្ត ចងចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ។ កុលបុត្តនោះ នឹងបួសក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតម នឹងពិចារណានូវអត្ថដ៏ល្អិតជ្រាលជ្រៅ ដោយញាណបាន ។ កុលបុត្តនោះ មាននាមថាមោឃរាជ នឹងបានជាសាវ័ក

របស់ព្រះសាស្តាអង្គនោះ ជាអ្នកបរិបូរដោយវិជ្ជា ៣ មាន សោឡសកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ ។ ព្រះគោតម ជាអ្នកដឹកនាំពួកដ៏ប្រសើរ នឹងតាំងភិក្ខុនោះ ក្នុងទីជាឯតទគ្គៈ ។

ខ្ញុំលះបង់នូវយោគធម៌ ជារបស់នៃមនុស្ស កាត់ផ្តាច់នូវចំណងក្នុងភពហើយ កំណត់ដឹងនូវអាសវៈទាំងពួង ទាំងជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមោឃរាជត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## មោឃរាជត្ថេរាបទាន ចប់

# អដ្ឋកថា

## មោឃរាជត្ថេរាបទាន

[ ៣៧ ] *អបទានរបស់ព្រះមោឃរាជត្ថេរ មានពាក្យផ្តើមថា* **អត្ថទស្សី តុ ភគវា** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈជាងភិក្ខុដែលទ្រទ្រង់នូវសំពត់ចីវរសៅហ្មង ចង់បានតំណែងនោះ ទើបតាំងនូវសេចក្តីប្រាថ្នា ធ្វើបុណ្យសន្សឹកសន្សាប់ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវការសម្រេចក្នុងវិជ្ជា និងសិប្បៈទាំងឡាយ ។ ថ្ងៃមួយ ឃើញព្រះមានព្រះភាគព្រះនាមអត្ថទស្សី ចោមរោមទៅដោយភិក្ខុសង្ឃ យាងទៅតាមវិថី មានចិត្តជ្រះថ្លា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ផ្គងអញ្ជលីលើសិរសា សរសើរដោយគាថា ៦ គាថាថា* **យាវតា រូបិនោ សត្តា** *ជាដើម ហើយបង្អុរនទឹកឃ្មុំពេញភាជន៍ចូលទៅថ្វាយ ។ ព្រះសាស្តាទ្រង់ទទួលទឹកឃ្មុំហើយ បានធ្វើអនុមោទនា ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមកស្សបៈ កើតជាអមាត្យរបស់ព្រះរាជាព្រះនាមកដ្ឋវាហនៈ ត្រូវព្រះរាជានោះ បញ្ជូនទៅដើម្បីនាំព្រះសាស្តាមក*

ទៅគាល់ព្រះសាស្តា ស្តាប់ធម៌ហើយ បាននូវសទ្ធា បួសហើយ បំពេញសមណធម៌អស់ ២ ម៉ឺនឆ្នាំ ចុតិអំពីអត្តភាពនោះហើយ ត្រាច់ទៅកាន់សុគតិនោះឯង អស់ ១ ពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ បានឈ្មោះថា មោឃរាជ បានសិក្សាសិប្បៈក្នុងសម្នាក់ពាវរីព្រាហ្មណ៍ កើតសេចក្តីសង្វេគ បួសជាតាបស មានតាបស ១ ពាន់ជាបរិវារ បញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា មួយអន្លើដោយអជិតតាបសជាដើម ជាបុគ្គលទី ១៥ ក្នុងចំនួនតាបសទាំងនោះ ទូលសួរបញ្ហាក្នុងទីបំផុតនៃការវិសជ្ជនាបញ្ហា បានសម្រេចអរហត្ត ។ កាលសម្រេចអរហត្តហើយ ទ្រទ្រង់នូវសំពត់បង្សុកូលដែលមានការសៅហ្មង ៣ យ៉ាង គឺសៅហ្មងដោយសស្រ្តា ១ សៅហ្មងដោយអំបោះ ១ សៅហ្មងដោយគ្រឿងជ្រលក់ ១ យ៉ាងឧក្រិដ្ឋ ។ ដោយហេតុនោះ ទើបព្រះសាស្តាទ្រង់តែងតាំងលោក ក្នុងតំណែងជាកំពូលលើសភិក្ខុទាំងឡាយ ខាងទ្រទ្រង់ចីវរសៅហ្មង ។

លោកសម្រេចអរហត្តផល ដោយសមគួរដល់សេចក្តីប្រាថ្នាយ៉ាងនេះហើយ ជ្រាបសេចក្តីល្អក្នុងកាលមុនរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អត្ថទស្សី តុ ភគវា** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ។ ក្រឡ

*ឬថ្នាំង ហៅថា* **បុដក** *ក្នុងបទថា* **បុដកំ បូរយិត្វាន** *ភ្ជាប់សេចក្ដីថា កុលបុត្តនោះដាក់ទឹកឃ្មុំផ្អិតដែលប្រាសចាកមេ និងកូន មិនមានទោសបរិសុទ្ធ ពេញថ្នាំងហើយ ផ្គងថ្នាំងនោះដោយដៃទាំងពីរ កាន់ទៅយ៉ាងល្អ គឺដោយអើពើ បង្អោនចូលទៅថ្វាយដល់ព្រះមានព្រះភាគ អ្នកស្វែងរកគុណធំ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៚*

**អដ្ឋកថាមោឃរាជត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អធិមុត្តកត្ថេរាបទានទី ៦

[ ៣៨ ] កាលព្រះលោកនាថ ព្រះនាមអត្ថទស្សី ព្រះអង្គប្រសើរជាងពួកនរៈ បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា និមន្តភិក្ខុសង្ឃ លុះនិមន្តព្រះសង្ឃរត្ន ដែលមានសន្តានត្រង់ មានចិត្តតម្កល់មាំហើយ ខ្ញុំធ្វើមណ្ឌបដោយដើមអំពៅ បាននិមន្តព្រះសង្ឃដ៏ប្រសើរឲ្យឆាន់ ។ ខ្ញុំទៅចាប់កំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស ខ្ញុំគ្របសង្កត់នូវពួកសត្វទាំងអស់ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ១៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យអំពៅ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអធិមុត្តកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អធិមុត្តកត្ថេរាបទាន ចប់**

# អដ្ឋកថា

## អធិមុត្តត្ថេរាបទាន

[ ៣៨ ] *អបទានរបស់ព្រះអធិមុត្តត្ថេរ មានពាក្យផ្ដើមថា* **និព្វុតេ លោកនាថម្ហិ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះពុទ្ធព្រះនាមអត្ថទស្សីបរិនិព្វានហើយ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជ្រះថ្លាក្នុងព្រះរតនត្រ័យ និមន្តភិក្ខុសង្ឃ ឲ្យធ្វើបាកាំដោយដើមអំពៅទាំងឡាយ ហើយថ្វាយមហាទាន ក្នុងទីបំផុតបានប្រាថ្នាសន្និបទ ។ កុលបុត្តនោះ ចុតិអំពីអត្តភាពនោះហើយ សោយសម្បត្តិទាំងពីរ ក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជ្រះថ្លាក្នុងព្រះសាសនា ព្រោះលោកជ្រះថ្លាក្នុងព្រះសាស្ដា តាំងនៅក្នុងសទ្ធា ទើបប្រាកដនាមថា អធិមុត្តត្ថេរ ។*

*លោកសម្រេចអរហត្ត ដោយអំណាចបុញ្ញសម្ភារ ដែលធ្វើមកយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតទូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **និព្វុតេ លោក-នាថម្ហិ** *ដូច្នេះជាដើម ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។l៚*

### អដ្ឋកថាអធិមុត្តត្ថេរាបទាន ចប់

# សុត្តន្តបិដក

## លសុណទាយកត្ថេរាបទានទី ៧

[ ៣៩ ] គ្រានោះ ខ្ញុំកើតជាតាបស នៅជិតព្រៃហិមពាន្ត ចិញ្ចឹមជីវិត ( អាស្រ័យ ) នឹងការដាំខ្ទឹម ខ្ទឹមជាភោជនរបស់ខ្ញុំ ។ ខ្ញុំបានវែកខ្ទឹម ពេញមួយអម្រែក ទៅកាន់អារាមរបស់សង្ឃ ខ្ញុំមានចិត្តរីករាយ បានប្រគេនខ្ទឹមដល់សង្ឃ ដោយចិត្តរីករាយ ។ ខ្ញុំបានប្រគេនខ្ទឹមដល់ព្រះសង្ឃ ដែលមិនត្រេកអរនឹងកាម ក្នុងសាសនានៃព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់ប្រសើរជាងពួកនរៈ ខ្ញុំរីករាយក្នុងស្ថានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានប្រគេនខ្ទឹម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខ្ទឹមទាំងឡាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលសុណទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

លសុណទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## លសុណទាយកត្ថេរាបទាន

[ ៣៩ ] អបទានរបស់ព្រះលសុណទាយកត្ថេរ មានពាក្យផ្ដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។

ព្រះលសុណទាយកត្ថេរនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះ ទើបលះផ្ទះបួសជាតាបស អាស្រ័យហិមវន្តបព៌ត ជាអ្នកទៅព្រៃ ដាំនូវខ្ទឹមជាច្រើន ទំពាស៊ីនូវខ្ទឹមនោះ និងឫសឈើផ្លែឈើក្នុងព្រៃ រស់នៅ ។ កុលបុត្តនោះ រែកខ្ទឹមជាច្រើនមកកាន់ដែនដីមនុស្ស ជ្រះថ្លា ថ្វាយនូវទានដើម្បីជាភេសជ្ជៈដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយត្រឡប់ទៅ ។ លោកបំពេញបុណ្យដរាបដល់អស់ជីវិតយ៉ាងនេះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្ស សោយសម្បត្តិទាំងពីរ ដោយកម្លាំងនៃបុណ្យនោះឯង កើតក្នុងពុទ្ធុប្បាទកាលនេះ ដោយលំដាប់ បាននូវសទ្ធាបួសហើយ ចម្រើននូវវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត លោកប្រាកដនាមថា លសុណទាយិកត្ថេរ តាមកម្មក្នុងជាតិមុន ។

លោករឭកដល់បុព្វកម្មរបស់ខ្លួនកើតនូវសោមនស្ស កាលនឹងប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។ គាថានោះ ភ្ជាប់សេចក្ដីថា ក្នុងទីដែលជាទីសញ្ចរទៅនៃ

មនុស្សទាំងឡាយ ត្រង់ជើងភ្នំហិមល័យ ព្រះមានព្រះភាគព្រះនាមវិបស្សី ទ្រង់កើតឡើងក្នុងកាលណា ក្នុងកាលនោះ ខ្ញុំបានជាតាបស ។ បទថា **លសុណំ ឧបជីវាមិ** សេចក្តីថា ខ្ញុំបានដាំខ្ទឹមក្រហមនោះឯង ជាអាហារចិញ្ចឹមជីវិត ។ ដូចលោកពោលថា **លសុណំ មយ្ហភោជនំ** ខ្ទឹមជាភោជនរបស់ខ្ញុំ ដូច្នេះ ។

បទថា **ខារិយោ បូរយិត្វាន** សេចក្តីថា ដាក់កាជន៍របស់តាបសឲ្យពេញដោយខ្ទឹម រែកទៅកាន់សង្ឃារាម គឺ លំនៅរបស់សង្ឃ បានដល់ទៅកាន់វិហារដែលជាលំនៅ ដោយឥរិយាបថទាំង ៤ របស់សង្ឃ ក្នុង ៣ កាល មានហេមន្តរដូវជាដើម ។ បទថា **ហដ្ឋោ ហដ្ឋេន ចិត្តេន** សេចក្តីថា ខ្ញុំត្រេកអរបានថ្វាយខ្ទឹមដល់សង្ឃ ដោយចិត្តដែលប្រកបដោយសោមនស្ស ។

បទថា **វិបស្សិស្ស ។បេ។ ឆិរតស្សហំ** សេចក្តីថា ក្នុងសាសនាព្រះមានព្រះភាគព្រះនាមវិបស្សី ជាបុគ្គលក្រៃលែង គឺប្រសើរជាងមនុស្សទាំងឡាយ ។ បទថា **សង្ឃស្ស ។បេ។ មោទហំ** សេចក្តីថា ខ្ញុំថ្វាយខ្ទឹមជាទានដល់សង្ឃហើយ សោយទិព្វសម្បត្តិដរាបដល់អស់អាយុកប្ប ក្នុងសគ្គ គឺក្នុងទេវលោកដ៏ប្រសើរ ត្រេកអរ អធិប្បាយថា ខ្ញុំជាអ្នកត្រេកអរ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

**អដ្ឋកថាលសុណទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អាយាគទាយកត្ថេរាបទានទី ៨

[ ៤០ ] កាលព្រះលោកនាថ ព្រះនាមសិខី ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ បរិនិព្វានហើយ ខ្ញុំរីករាយ បានថ្វាយបង្គំព្រះស្តូបដ៏ប្រសើរ ដោយចិត្តរីករាយ ។ កាលនោះ ខ្ញុំបានឲ្យជាងឈើនិយាយកាត់ថ្លៃ ហើយឲ្យថ្លៃ ខ្ញុំរីករាយ ឲ្យជាងឈើធ្វើរោងសម្នាក់ ដោយចិត្តរីករាយ ។ ខ្ញុំទៅជាប់ មិនដាច់ក្នុងទេវលោកអស់ ៨ កប្ប ខ្ញុំអន្ទោលទៅរាត់រាយក្នុងកប្បដ៏សេស ។ ពិសមិនជ្រាបទៅក្នុងកាយ ទាំងគ្រឿងសស្ត្រាក៏មិនមុតខ្ញុំ ខ្ញុំមិនស្លាប់ក្នុងទឹក នេះជាផលនៃរោងសម្នាក់ ។ បើខ្ញុំប្រាថ្នាទឹកភ្លៀង មហាមេឃក៏បង្អុរភ្លៀងមក ទាំងពួកទេវតា តែងលុះអំណាចរបស់ខ្ញុំ នេះជាផលនៃបុញ្ញកម្ម ។ ខ្ញុំបរិបូណ៌ដោយកែវ ៧ ប្រការ អស់ ៣០ ដង ពួកជនណាមួយ មិនមើលងាយខ្ញុំឡើយ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យជាងធ្វើរោងសម្នាក់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃរោងសម្នាក់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអាយាគទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## អាយាគទាយកត្ថេរាបទាន

[ ៤០ ] *អបទានរបស់ព្រះអាយាគទាយកត្ថេរ មានពាក្យផ្តើមថា* **និព្វុតេ លោកនាថម្ហិ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលដែលព្រះមានព្រះភាគព្រះនាមសិខីបរិនិព្វានហើយ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជ្រះថ្លាក្នុងព្រះសាសនា បានជួលជាងឲ្យសាងនូវរោងឆាន់វែងគួរជាទីត្រេកអរក្រៃលែង និមន្តភិក្ខុសង្ឃឲ្យឆាន់អាហារដ៏ប្រណីត ថ្វាយមហាទានហើយ មានចិត្តឲ្យជ្រះថ្លា ។ កុលបុត្តនោះ បំពេញបុណ្យដរាបដល់អស់អាយុ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយនោះឯង សោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល បាននូវសទ្ធាបួសហើយ ព្យាយាមចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តលោកប្រាកដឈ្មោះថា អាយាគទាយកត្ថេរ តាមបុណ្យដែលបានធ្វើមកក្នុងកាលមុន ។*

*ព្រះថេរៈសម្រេចអរហត្ត ដោយអំណាចបុញ្ញសម្ភារដែលលោកបំពេញមកយ៉ាងនេះហើយ រឭកដល់កុសលកម្មដែលធ្វើក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **និព្វុតេ លោកនាថម្ហិ** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **និព្វុតេ** *សេចក្តីថា កាលព្រះមានព្រះភាគព្រះនាមសិខី ជាបុគ្គលប្រសើរ គឺ*

ឧត្តមក្នុងរវាងម្ចាស់លទ្ធិ គឺអ្នកដទៃដែលពោលថា ខ្ញុំជាព្រះពុទ្ធ ទ្រង់បរិនិព្វានហើយ ។ បទថា **ហដ្ឋោ ហដ្ឋេន ចិត្តេន** សេចក្តីថា ខ្ញុំត្រេកអរមានចិត្តរីករាយ ព្រោះមានចិត្តសម្បយុត្តដោយសោមនស្ស បានថ្វាយបង្គំ គឺនមស្ការព្រះស្តូបដ៏ឧត្តម គឺព្រះចេតិយដ៏ប្រសើរ ។

បទថា **វឌ្ឍកីហិ កថាបេត្វា** សេចក្តីថា ឲ្យប្រាប់ប្រមាណ ( តម្លៃ ) ថា រោងឆាន់នេះមានប្រមាណប៉ុន្មាន ។ បទថា **មូលំ ទត្វានហំ តទា** សេចក្តីថា ក្នុងកាលនោះ គឺក្នុងគ្រានោះ ខ្ញុំបានឲ្យថ្លៃឈ្នួលដល់ជាងឈើទាំងនោះ ដើម្បីឲ្យធ្វើការងារ ត្រេកអរ គឺមានចិត្តសម្បយុត្តដោយសោមនស្ស បានកសាងរោងឆាន់វែង ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

បទថា **អាយាគស្ស ឥទំ ផលំ** បានដល់ នេះជាផលនៃការសាងរោងឆាន់ ។៚

## អដ្ឋកថាអាយាគទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ធម្មចក្កិកត្ថេរាបទានទី ៩

[ ៤១ ] ធម្មចក្រដ៏វិចិត្រល្អ ដែលអ្នកប្រាជ្ញសរសើរហើយ ខ្ញុំបាន តម្កល់ទុកខាងមុខសីហាសនៈ របស់ព្រះមានព្រះភាគ ព្រះនាម សិទ្ធត្ថៈ ។ ខ្ញុំមានយាន និងពលពាហនៈ រមែងរុងរឿងដោយ វណ្ណៈ ៤ យ៉ាង ពួកជនដ៏ច្រើន ដើរតាមហែហមខ្ញុំជានិច្ច ។ ខ្ញុំ មានតូរ្យតន្ត្រី ៦០០០០ ហែហមសព្វកាល ខ្ញុំរមែងល្អដោយ បរិវារ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានតម្កល់ទុកនូវចក្ក ក្នុងកាលនោះ ខ្ញុំមិន ដែលស្គាល់ទុគ្គតិ នេះជាផលនៃធម្មចក្ក ។ ក្នុងកប្បទី ១១ អំពី កប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ៨ ដង ព្រះនាមសហស្សរាជ ដូចគ្នា ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មចក្កិកត្ថេរមានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

**ធម្មចក្កិកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ធម្មចក្កិកត្ថេរាបទាន

[ ៤១ ] *អបទានរបស់ព្រះធម្មចក្កិកត្ថេរ មានពាក្យផ្ដើមថា* **សុទ្ធត្ថស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ដល់ព្រមដោយបុត្ត និងភរិយា សម្បូរដោយសម្បត្តិមានភោគៈច្រើន ។ កុលបុត្តនោះ ជ្រះថ្លាក្នុងព្រះរតនត្រ័យ កើតនូវសទ្ធា បានសាងនូវធម្មចក្រ សម្រេចដោយរតនៈ បូជាខាងក្រោយធម្មាសនៈ ក្នុងធម្មសភា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយសក្កសម្បត្តិ និងចក្កវត្តិសម្បត្តិ ក្នុងទេវតា និងមនុស្ស ដែលកុលបុត្តនោះកើតហើយ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង សម្បូរដោយសម្បត្តិ កើតនូវសទ្ធា បួសហើយ ចម្រើននូវវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។ កុលបុត្តនោះ បានឈ្មោះថា ធម្មចក្កិកត្ថេរ ដូចគ្នានឹងកុសលដែលបានធ្វើមកក្នុងជាតិមុន ។*

*ព្រះថេរៈសម្រេចអរហត្តផលដោយសមគួរដល់បុញ្ញសម្ភារ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សិទ្ធត្ថស្ស ភគវតោ** *ដូច្នេះជាដើម ។ បទថា* **សីហាសនស្ស សម្មុខា** *សេចក្ដីថា ខាងមុខ គឺក្នុងទីចំពោះមុខ*

ពុទ្ធាសនៈរបស់ព្រះមានព្រះភាគ ដែលប្រៀបដូចរាជសីហ៍ ប្រថាប់គង់ ។ បទថា **ធម្មចក្កំ មេ ថបិតំ** ក្លាប់សេចក្តីថា ខ្ញុំបានសម្តែងរូបសីហៈ ទាំងសង់ខាងជាគ្រឿងសម្គាល់ទែនធម្មចក្រ សាងឲ្យដូចមានកញ្ចក់នៅត្រង់កណ្តាលតាំងធម្មចក្របូជា ។ ធ្វើដូចម្តេច ធ្វើឲ្យជាធម្មចក្រដែលសាងយ៉ាងល្អ រហូតវិញ្ញូជន គឺបុគ្គលមានបញ្ញាទាំងឡាយសរសើរ លើកតម្កើងថា ស្អាតពន់ពេក ។

បទថា **ចារុវណ្ណោវ សោភាមិ** សេចក្តីថា ខ្ញុំរមែងស្អាត គឺរុងរឿងមានពណ៌ដូចមាស បាលីថា **ចតុវណ្ណេហិ សោភាមិ** ដូច្នេះក៏មាន ។ ពាក្យនោះមានន័យថា ខ្ញុំរមែងស្អាត គឺរុងរឿងដោយវណ្ណៈ ៤ ពោល គឺកំណើតនៃក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ ។ បទថា **សយោគ្គពលវាហនោ** សេចក្តីថា ប្រកបដោយយាន មានវមាសជាដើម ដោយកម្លាំងពល គឺសេវកៈមានសេនាបតី និងអមាត្យជាដើម និងដោយវាហនៈ ពោល គឺរថទឹមដោយដំរី និងរថទឹមដោយសេះជាដើម ក្លាប់សេចក្តីថា ជនជាច្រើន គឺមនុស្សជាច្រើនដើរតាម គឺហែហមតាមខ្ញុំ បានដល់ ចោមរោមជានិច្ច គឺសព្វកាល ។ ពាក្យដ៏សេស ដឹងបានងាយហើយ ។

## អដ្ឋកថាធម្មចក្កិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## កប្បរុក្ខិយត្ថេរាបទានទី ១០

[ ៤២ ] ខ្ញុំបានដាំនូវដើមកប្បព្រឹក្សមួយដើម ព្រមទាំងព្យួរនូវសំពត់ដ៏វិចិត្រទាំងឡាយ នៅខាងមុខនៃព្រះស្តូបដ៏ប្រសើរ របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។ ខ្ញុំទៅចាប់កំណើតណាៗ ទោះជាទេវតា ឬមនុស្ស សឹងមានដើមកប្បព្រឹក្សដ៏ល្អ ប្រតិស្ឋានទៀបមាត់ទ្វារផ្ទះនៃខ្ញុំ ។ យើងទាំងឡាយ គឺខ្ញុំផង បរិស័ទផង ពួកជនណានីមួយ ដែលមានធ្នាំស្មើគ្នានឹងខ្ញុំផង តែងកាន់យកសំពត់អំពីដើមកប្បព្រឹក្សនោះ មកស្លៀកដណ្តប់ក្នុងកាលនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំដាំដើមឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដើមកប្បព្រឹក្ស ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រិយ៍ចក្កពត្តិ ៨ ដង ព្រះនាមសុចេលៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទាំងមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកប្បរុក្ខិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កប្បរុក្ខិយត្ថេរាបទាន ចប់

## ឧទ្ទាន

កុណ្ឌធានត្ថេរ ១ សាគតត្ថេរ ១ កច្ចាយនត្ថេរ ១ កាឡុទាយិត្ថេរ ១ មោឃរាជត្ថេរ ១ អធិមុត្តកត្ថេរ ១ លសុណទាយកត្ថេរ ១ អាយាគទាយកត្ថេរ ១ ធម្មចក្កិកត្ថេរ ១ កប្បរុក្ខិយត្ថេរ ១ ជាគម្រប់ ១០ មានគាថា ១១២ ។

## កុណ្ឌធានវគ្គទី ៤ ចប់

# អដ្ឋកថា
## កប្បរុក្ខិយត្ថេរាបទាន

[ ៤២ ] *អបទានរបស់ព្រះកប្បរុក្ខិយត្ថេរ មានពាក្យផ្តើមថា* **សិទ្ធត្ថស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏មានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលមួយដែលសម្បូរដោយសម្បត្តិ ឲ្យសាងដើមកប្បព្រឹក្សដែលសម្រេចដោយមាស វិចិត្រដោយរតនៈ ៧ ប្រការ ដាក់បូជាត្រង់មុខព្រះចេតិយនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ។ កុលបុត្តនោះបំពេញបុណ្យបែបនេះ តាំងនៅដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងសុគតិប៉ុណ្ណោះ តមកក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលតាមលំដាប់ ដល់នូវភាពជាអ្នកដឹងក្តីហើយ នៅគ្រប់គ្រងផ្ទះ ជ្រះថ្លាក្នុងព្រះរតនត្រ័យ ស្តាប់ធម៌ហើយ បាននូវសទ្ធាជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត លោកប្រាកដឈ្មោះថា កប្បរុក្ខិយត្ថេរ តាមឈ្មោះកុសលដែលធ្វើមកក្នុងកាលមុន ។*

ព្រះថេរៈសម្រេចអរហត្តផលយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចសោមនស្ស ទើបពោលពាក្យថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះជាដើម ។ បទថា **ថូបសេដ្ឋស្ស សម្មុខា** សេចក្តីថា សំពត់ដ៏វិចិត្រដាក់ត្រង់មុខព្រះចេតិយដែលជាព្រះស្តូបបញ្ចុះព្រះធាតុដ៏ប្រសើរបំផុត បានដល់ សំពត់ចីនៈ និងសំពត់សោមារៈជាដើម ដែលគួរត្រេកអរ លម្អដោយពណ៌ច្រើនយ៉ាង មិនមានពណ៌ណាដូច អធិប្បាយថា ខ្ញុំបានប្រតិស្ឋានដើមកប្បព្រឹក្ស ព្យួរសំពត់ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕៚

**អដ្ឋកថាកប្បរុក្ខិយត្ថេរាបទាន ចប់**

**កុណ្ឌធានវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## ឧបាលិវគ្គទី ៥

## ឧបាលិត្ថេរាបទានទី ១

[ ៤៣ ] ព្រះលោកនាយក ទ្រង់ព្រះនាមបទុមុត្តរៈ មានពួកព្រះខីណាស្រពមួយពាន់អង្គចោមរោម ទ្រង់ប្រកបរឿយៗ នូវវិវេក កំពុងពុទ្ធដំណើរទៅ ដើម្បីពួនសម្ងំ ។ ខ្ញុំស្លៀកស្បែកខ្លាឃ្មុំកាន់ឈើប្រត់ចម្ពាម ៣ ដើរទៅ បានឃើញព្រះលោកនាយកកុះករដោយភិក្ខុសង្ឃ ទើបខ្ញុំធ្វើស្បែកខ្លាឃ្មុំ ឆៀងស្មាម្ខាង រួចហើយ ធ្វើអញ្ជលីលើសិរ្សៈ ថ្វាយបង្គំព្រះសម្ពុទ្ធ សរសើរព្រះលោកនាយកថា សត្វទាំងឡាយ ដែលកើតអំពីពងក្តី ដែលកើតអំពីញើសក្តី ដែលជាឧបបាតិកក្តី ដែលកើតអំពីទឹកក្តី ពួកបក្សីទាំងអស់ មានក្អែកជាដើមក្តី នឹងត្រាច់ទៅតែក្នុងអាកាសសព្វៗកាល យ៉ាងណាមិញ ។ ពួកសត្វណាមួយ ដែលមានសញ្ញាក្តីឥតសញ្ញាក្តី សត្វទាំងអស់នោះ សឹងប្រជុំចុះ ក្នុងខាងក្នុងនៃព្រះញាណរបស់ព្រះអង្គ ក៏យ៉ាងនោះដែរ ។ មួយវិញទៀត ក្លិនឈើក្អំទាំងឡាយណា លើក្អំហិមពាន្តដ៏ឧត្តម ក្លិនទាំងអស់នោះមិនបានមួយចំណិតនឹងក្លិនសីលរបស់ព្រះអង្គ ។ លោកនេះ ព្រមទាំងទេវលោក តែងស្ទុះទៅក្នុងងងឹត គឺមោហៈ កាលបើញាណ

របស់ព្រះអង្គ ទ្រោលឡើងហើយ ងងឹតក៏ខ្ចាត់ចេញទៅ ។ កាលបើព្រះអាទិត្យអស្តង្គតហើយ ពួកសត្វក៏ដល់នូវសេចក្តីងងឹតយ៉ាងណា កាលព្រះពុទ្ធមិនទាន់បានត្រាស់ លោកក៏ដល់នូវសេចក្តីងងឹត យ៉ាងនោះដែរ ។ ព្រះអាទិត្យកាលរះឡើង តែងបន្ទោបង់នូវងងឹតសព្វកាល យ៉ាងណា បពិត្រព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គកម្ចាត់បង់នូវងងឹតសព្វកាល យ៉ាងនោះដែរ ។ ព្រះអង្គមានព្រះហឫទ័យបញ្ជូនទៅកាន់ព្យាយាម បានជាព្រះពុទ្ធក្នុងលោក ព្រមទាំងទេវលោក ទ្រង់ញ៉ាំងប្រជុំជនដ៏ច្រើនឲ្យត្រេកអរ ដោយការប្រារព្ធនូវអំពើរបស់ព្រះអង្គ ។ ព្រះបទុមុត្តរៈមហាមុនី ជាអ្នកប្រាជ្ញ បានទ្រង់ព្រះសណ្តាប់នូវពាក្យនោះហើយ ក៏ទ្រង់អនុមោទនា ហោះឡើងទៅឰដ៏អាកាស ដូចជាស្តេចហង្ស ហើរទៅឰដ៏អាកាស ដូច្នោះដែរ ។ ព្រះសម្ពុទ្ធជាមហេសី ព្រះនាមបទុមុត្តរៈជាសាស្តា លុះទ្រង់ហោះឡើងហើយ ក៏ស្ថិតនៅឰដ៏អាកាស ទើបសំដែងនូវគាថាទាំងនេះថា

បុគ្គលណា សរសើរញាណនេះ ប្រកបដោយឧបមាទាំងឡាយ តថាគតនឹងសម្តែងសរសើរនូវបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនោះនឹងបានជាទេវរាជអស់ ១៨ ជាតិ នឹងសោយរាជ្យលើផែនដី គ្រប់គ្រងផែនដី អស់ ៣០០ ជាតិ ។ នឹងបានជាស្តេចចក្កពត្តិ ២៥ ជាតិ ( បានគ្រប់គ្រង )

នូវប្រទេសរាជ្យដ៏ធំទូលាយ រាប់បានអសង្ខេយ្យជាតិ ។ កន្លងទៅមួយសែនកប្ប ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលក្សត្រិយ៍ឱក្កាកៈ នឹងទ្រង់កើតឡើងក្នុងលោក ។ បុគ្គលនោះ ច្យុតចាកតុសិតទេវលោកមក ត្រូវកុសលមូលជាស់តឿនទោះជាអ្នកថោកទាបដោយជាតិ ឈ្មោះថា ឧបាលិ ក៏ដោយ ។តែលុះដល់កាលជាខាងក្រោយ ឧបាលិនោះ នឿយណាយនឹងអំពើបាប ក៏ចេញបួស កំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះពុទ្ធព្រះនាមគោតម ជាសក្យបុត្ត ទ្រង់មានយសច្រើន ត្រេកអរហើយ ទ្រង់តាំងឧបាលិនោះ ដែលចេះដឹងនូវវិន័យ ក្នុងទីជាឯតទគ្គៈ ។

ខ្ញុំបួសដោយសទ្ធា មានសោឡសកិច្ច ធ្វើស្រេចហើយ ជាអ្នកមិនមានអាសវៈ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកអស់អាសវៈ ។ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះខ្ញុំ ខ្ញុំជាអ្នកក្លៀវក្លាក្នុងវិន័យ ប្រារព្ធនូវកម្មរបស់ខ្ញុំ ជាអ្នកមិនមានអាសវៈ ។ ខ្ញុំសង្រួមក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ទ្រទ្រង់នូវវិន័យទាំងអស់ ដែលជាទីកើតនៃរតនៈគ្រប់យ៉ាង ។ ព្រះសាស្តាប្រសើរ

ក្នុងលោក ទ្រង់ជ្រាបនូវគុណរបស់ខ្ញុំហើយ ទ្រង់តាំងខ្ញុំក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបាលិត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឧបាលិត្ថេរាបទាន ចប់

# អដ្ឋកថា

## ឧបាលិវគ្គទី ៥

### ឧបាលិត្ថេរាបទាន

[ ៤៣ ] អបទានរបស់ព្រះឧបាលិត្ថេរ ដែលជាក្មួយរបស់ព្រះឧបាលិត្ថេរ មានពាក្យផ្ដើមថា **ចីណាសវសមាសេ្ស្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងកពនោះៗ ក្នុងកាលនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលមួយកន្លែង ចម្រើនវ័យហើយ ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះ ទើបលះផ្ទះ ចេញបួសជាឥសី បាននូវអភិញ្ញា ៥ និងសមាបត្តិ ៨ សម្រេចការនៅក្នុងហិមវន្តប្បទេស ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ត្រូវវិវេក ទើបចូលទៅកាន់ព្រៃហិមពាន្ត តាបសឃើញព្រះមានព្រះភាគ ដែលរុងរឿងដូចព្រះចន្ទពេញបូណ៌មីអំពីចម្ងាយ មានចិត្តជ្រះថ្លា ទើបធ្វើស្បែកខ្លាធៀងស្មាម្ខាង ផ្គងអញ្ជលីថ្វាយបង្គំហើយ ទើបឈរផ្គងប្រជុំម្រាមដប់ ដាក់លើសិរសា សរសើរព្រះមានព្រះភាគ ឧបមាដោយការសរសើរច្រើនយ៉ាង ។ ព្រះមានព្រះភាគទ្រង់ស្ដាប់ដូច្នោះហើយ ទ្រង់ព្យាករថា ក្នុងអនាគត តាបសនេះនឹងបួសក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតម នឹងបានជាកំពូល

ជាឯកភិក្ខុអ្នកមានបញ្ញាមុតស្រួច ទ្រទ្រង់ព្រះវិន័យ ។

តាបសនោះ តាំងនៅដរាបដល់អស់អាយុ មានឈានមិនសាបសូន្យ កើតក្នុងព្រហ្មលោក ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយនូវសម្បត្តិទាំងឡាយ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាកូនរបស់ព្រះឧបាលិត្ថេរ ក្នុងនគរកបិលពស្តុ ដល់នូវភាពជាអ្នកចម្រើនវ័យដោយលំដាប់ បួសក្នុងសម្នាក់របស់ព្រះឧបាលិត្ថេរដែលជាអ៊ំ រៀនយកកម្មដ្ឋានហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត លោកជាអ្នកមានញាណមុតស្រួចខាងព្រះវិន័យ ព្រោះនៅជិតអាចារ្យ ។ លំដាប់នោះ ទើបព្រះសាស្តាតាំងលោកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកមានបញ្ញាមុតស្រួចក្នុងបញ្ហាព្រះវិន័យ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងភាគិនេយ្យឧបាលី ដូច្នេះ ។

លោកបានទទួលតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ខីណាសវសហស្សេហិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ ឈ្មោះថា **អាសវ** ព្រោះស្ទុះទៅ គឺផ្សាយទៅដោយជុំវិញ ទល់គ្នានឹងភវគ្គព្រហ្ម ។ អាសវៈ ៤ មានកាមាសវៈជាដើម អាសវៈទាំងនោះអស់ទៅហើយ រីងស្ងួតទៅហើយ ខះទៅហើយ ដែលភិក្ខុណាកម្ចាត់ហើយ ភិក្ខុនោះ ឈ្មោះថា **ខីណាសវ** អ្នកមានអាសវៈអស់ហើយ ព្រះខីណាស្រពទាំងនោះ មានចំនួន ១ ពាន់រូប ។ ដោយព្រះខីណាស្រពប្រមាណ ១ ពាន់រូបនោះ ។

*ភ្ជាប់សេចក្តីថា ព្រះលោកនាថ គឺបុគ្គលអ្នកនាំសត្វលោក ទៅកាន់ព្រះនិព្វាន ចោមរោមទៅដោយភិក្ខុជាព្រះខីណាស្រពទាំងនោះ ទ្រង់ខ្វល់ខ្វាយនូវវិវេកយានទៅដើម្បីពួនសម្ងំ គឺដើម្បីភាពជាបុគ្គលម្នាក់ឯង ។*

*បទថា* **អជិនេន និវត្ថោហំ** *សេចក្តីថា ខ្ញុំបិទបាំងដោយស្បែកខ្លា គឺស្លៀកស្បែកខ្លា ។ បទថា* **តិទណ្ឌបរិធារកោ** *សេចក្តីថា កាន់យកកំណាត់ឈើ ៣ កំណាត់ ដើម្បីដាក់កុណ្ឌីទឹក ភ្ជាប់សេចក្តីថា ខ្ញុំបានឃើញព្រះលោកនាយក ចោមរោមដោយភិក្ខុសង្ឃ ។ ពាក្យដ៏សេស មានអត្ថប្រាកដច្បាស់ហើយ ៕*

**អដ្ឋកថា ឧទាលិត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សោណកោដិយវេស្សត្ថេរាបទានទី ២

[ ៤៤ ] ខ្ញុំឲ្យគេធ្វើទីចង្ក្រម ធ្វើនូវការលាបដោយកំបោរ ថ្វាយព្រះមុនី ព្រះនាមអនោមទស្សី ទ្រង់ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំក្រាលទីចង្ក្រមដោយផ្កា មានពណ៌ផ្សេងៗ ធ្វើនូវពិតានក្នុងអាកាស និមន្តព្រះពុទ្ធដ៏ប្រសើរ ឲ្យឆាន់កត្ត ។ គ្រានោះ ខ្ញុំផ្គងអញ្ជលី ថ្វាយបង្គំព្រះសម្ពុទ្ធ ទ្រង់មានវត្តដ៏ល្អ ហើយថ្វាយទីយសាលា ចំពោះព្រះមានព្រះភាគ ។ ព្រះសាស្តា ទ្រង់ប្រសើរផុតក្នុងលោក ទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ព្រះមានព្រះភាគមានចក្ខុ ទ្រង់បានទទួល ( សាលានោះ ) ដោយអនុគ្រោះ ។ ព្រះសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គលក្នុងលោក ព្រមទាំងទេវលោក លុះទទួលរួចហើយ ទ្រង់គង់ក្នុងភិក្ខុសង្ឃហើយ សម្តែងនូវគាថាទាំងឡាយនេះថា

កុលបុត្តណា មានចិត្តរីករាយ បានថ្វាយទីយសាលា ចំពោះតថាគត តថាគតនឹងសម្តែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្តដែលបរិបូណ៌ដោយបុញ្ញកម្មនេះ នឹងមានរថទឹមដោយសេះមួយពាន់ កើតឡើងប្រាកដក្នុងមរណកាល ។ បុរសនេះ នឹងទៅកាន់ទេវលោកដោយយាននោះ ពួកទេវតារីករាយ ក្នុងភពជាកុសលដែលសម្រេចដល់បុរសនោះ ។ ទេវបុត្តនោះ នឹងនៅគ្រប់គ្រងវិមាន

ដ៏ប្រសើរ ដែលមានថ្លៃច្រើន លាបលាបដោយដីកែវ ជាវិមាន ប្រកបដោយកំពូលដ៏ប្រសើរ ។ ទេវបុត្តនោះ នឹងរីករាយក្នុងទេវលោក អស់ ៣០០០០ កប្ប នឹងបានជាទេវរាជ អស់ ២៥ កប្បទៀត ។ នឹងបានជាស្តេចចក្រពត្តិ អស់ ៧៧ ដង ស្តេចចក្កពត្តិទាំងអស់នោះ មាននាមតែមួយ គឺនាមថា យសោធរៈ ។ លុះកុលបុត្តនោះ សោយសម្បត្តិទាំងពីររួចហើយ សន្សំនូវបុណ្យ នឹងបានជាស្តេចចក្កពត្តិ ក្នុងកប្បទី ២៨ ។ ស្តេចចក្កពត្តិនោះ នឹងនៅគ្រប់គ្រងប្រាសាទដ៏ប្រសើរ ដែលវិស្សុកម្មនិម្មិតថ្វាយ ក្នុងទីនោះ ជាបុរី មិនស្ងាត់ចាកសំឡេង ១០ ប្រការ ។ ក្នុងកប្បច្រើនប្រមាណមិនបាន អំពីកប្បនេះ កុលបុត្តនោះ នឹងបានជាស្តេចក្នុងដែន គ្រប់គ្រងផែនដី មានឫទ្ធិធំ មាននាមថា ឱក្កាកៈ ។ អភិជាតខត្តិយានី ( របស់ស្តេចនោះ ) ដ៏ប្រសើរលើសជាងស្រីស្នំ ១៦ ពាន់ទាំងអស់ ព្រះនាងនឹងប្រសូតនូវព្រះរាជបុត្ត ៩ ព្រះអង្គ ។

នាងខត្តិយានី លុះប្រសូតបុត្ត ៩ ព្រះអង្គហើយ ក៏នឹងធ្វើកាលកិរិយាទៅ នឹងមាននាងកញ្ញា ( ដទៃទៀត ) ជាស្រ្តីក្មេង ជាទីគាប់ព្រះហឫទ័យ នឹងបានមកជាមហេសី ។ នាងកញ្ញាធ្វើក្សត្រឱក្កាកៈ ឲ្យត្រេកអរហើយ នឹងបាននូវពរ លុះនាងកញ្ញានោះ បានទទួលពរហើយ ក៏ញ៉ាំងព្រះរាជាឲ្យបំបរបង់ព្រះរាជបុត្ត

ដើមទាំងឡាយចោល ។ ព្រះរាជបុត្តទាំងអស់នោះ លុះព្រះបិតាបំបរបង់ហើយ ក៏នាំគ្នាទៅកាន់ភ្នំហិមពាន្ត ព្រះរាជបុត្តទាំងអស់ខ្លាចបែកធ្លាយជាតិ ក៏នៅរួមសង្វាសនឹងប្អូនស្រីទាំងឡាយរបស់ខ្លួន ។ ឯនាងកញ្ញាម្នាក់ នឹងកើតព្យាធិ៍ពេញខ្លួន ក្សត្រទាំងឡាយនឹងជីក ( រណ្ដៅឲ្យនៅ ដោយបំណងថា ) ជាតិរបស់យើងកុំធ្លាយឡើយ ។ មានក្សត្រ ( វង្សដទៃ ) មួយអង្គ នាំនាងកញ្ញានោះយកទៅនៅរួមសង្វាសជាមួយ ក្នុងការកើតត្រកូលក្សត្រឱក្កាកៈនឹងបែកធ្លាយក្នុងកាលនោះ ។ ព្រះរាជឱរសទាំងឡាយ របស់ក្សត្រទាំងពីរអង្គនោះ នឹងបានឈ្មោះថា កោលិយៈ ( ក្សត្រទាំងពីរអង្គនោះ ) នឹងសោយកោគៈជារបស់មនុស្ស ប្រមាណមិនបានក្នុងទីនោះ ។ លុះកុលបុត្ត នោះច្យុតចាកកាយនោះ នឹងទៅកើតក្នុងទេវលោក នឹងបានទូវប្រាសាទដ៏ប្រសើរ ដែលជាទីគាប់ចិត្តក្នុងទេវលោកនោះ ។ លុះច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន ទើបមកកាន់អត្តភាពជាមនុស្ស មាននាមថាសោណៈ ។ សោណមាណពប្រារព្ធព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានតាំងនៅក្នុងសាសនារបស់ព្រះសាស្ដា កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះអនន្តទស្សីមានព្រះភាគ ព្រះនាមគោតម ជាសក្យៈប្រសើរ ទ្រង់ជ្រាបវិសេសមានព្យាយាមធំ នឹងតាំង ( សោណៈនោះ ) ក្នុងឋានៈដ៏ប្រសើរ ។

កាលភ្លៀងធ្លាក់ លិចស្មៅអស់ ៤ ធ្នាប់ នៅសល់មួយធ្នាប់ ត្រូវខ្យល់បក់ទៀត ( នៅតែប្រឹងជុះ ) វៀរលែងតែតាទិបុគ្គល អ្នកមានព្យាយាម មិនមានអ្វីប្រឹងលើស ជាងស្មៅនោះទៀតទេ ។

ខ្ញុំមានខ្លួនទូន្មានហើយ ក្នុងការទូន្មានដ៏ឧត្តម ចិត្តរបស់ខ្ញុំ តម្កល់ស៊ប់ហើយ ភារៈទាំងអស់ ខ្ញុំដាក់ចុះហើយ ខ្ញុំជាអ្នកមិន មានអាសវៈ មានទុក្ខរលត់ហើយ ។ ព្រះមហានាគជាអង្គីរស មានជាតិដ៏ប្រសើរ ដូចជាកេសររាជសីហ៍ គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោណកោជិយវេស្សត្ថេរមានអាយុ បាន សម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សោណកោជិយវេស្សត្ថេរាបទាន ចប់

# អដ្ឋកថា

## សោណាកោដិយវេស្សត្ថេរាបទាន

[ ៤៤ ] *អបទានរបស់ព្រះកោដិយវេស្សត្ថេរមានអាយុ មានពាក្យផ្តើមថា* **អនោមទស្សិស្ស មុនិនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះពុទ្ធព្រះនាមអនោមទស្សី កើតក្នុងផ្ទះ មានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ដល់ព្រមដោយបុត្ត និងភរិយា សម្បូរដោយសម្បត្តិ បានសាងទីចង្ក្រមដ៏ស្អាត ដើម្បីឲ្យព្រះមានព្រះភាគទ្រង់ចង្ក្រម បូកលាបដោយបាយ-អ ធ្វើឲ្យរាបស្មើ ធ្វើឲ្យមានផ្ទៃដូចផ្ទៃកញ្ចក់ រៀបចំប្រទីប ធូប ក្រអូប និងផ្កាជាដើម វេរថ្វាយដល់ព្រះមានព្រះភាគ បូជាភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីត ។ កុលបុត្តនោះ បំពេញបុណ្យដរាបដល់អស់ជីវិត ដោយអាការយ៉ាងនេះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក ។ កុលបុត្តនោះ សោយទិព្វសម្បត្តិដោយន័យដែលពោលហើយ តាមព្រះបាលីក្នុងអបទាននោះ ជាអ្នកខ្វល់ខ្វាយដើម្បីកើតក្នុងរាជត្រកូលរបស់ព្រះបាទឱក្កាករាជ ក្នុងវរាងកភព ព្រោះហេតុនោះ រឿងទាំងអស់នោះ គប្បីជ្រាបតាមគន្លងដែលពោលក្នុងព្រះបាលី ។ ក្នុងភពចុងក្រោយ លោកកើតក្នុងកោលិយរាជវង្ស ចម្រើនវ័យហើយ ប្រាកដឈ្មោះថា កោដិកណ្ណៈ ឬឈ្មោះថា កុដិកណ្ណៈ ព្រោះទ្រទ្រង់នូវគ្រឿងប្រដាប់ត្រចៀក*

ដែលមានតម្លៃប្រមាណ ១ កោដិ[១] ។ កុលបុត្តនោះ ជ្រះថ្លាក្នុងព្រះមានព្រះភាគ ស្តាប់ធម៌ហើយមានសទ្ធា បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។

លោកបានជាព្រះអរហន្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អនោមទស្សិស្ស មុនិនោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **អនោមទស្សិស្ស** សេចក្តីថា ព្រះរូបដែលមិនថោកថយ មិនអាក្រក់ គឺល្អ និងព្រះសរីរៈដែលគួរសរសើរ ព្រោះប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងព្រោះលម្អដោយមណ្ឌលនៃព្រះរស្មី ១ ព្យាម របស់ព្រះមានព្រះភាគអង្គណាមាន ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អនោមទស្សី ។ ( ថ្វាយ ) ដល់ព្រះមានព្រះភាគព្រះនាមថា អនោមទស្សីនោះ ។ បទថា **តាទិនោ** សេចក្តីថា មានការមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ បទថា **សុធាយ លេបនំ កតា** សេចក្តីថា ធ្វើទីចង្រ្កមបូកលាបដោយបាយ-អ ប្រដាប់ដោយប្រទីប ផ្សែងក្រអូប ផ្កា ទង់ជ័យ និងទង់សំពត់ជាដើម ។ អត្ថនៃគាថាដ៏សេស មានអត្ថងាយយល់ តាមក្រសែនៃព្រះបាលី

---

១- ព្រះសោណកោឡិវិសត្ថេរ ជាព្រះថេរៈមួយអង្គ កូនសេដ្ឋីក្នុងកាលចម្បាកនគរ បាតជើងរបស់លោកមានដុះរោម ព្រះសោណកុដិកណ្ណៈ ជាព្រះថេរៈមួយអង្គ កូននាងកាឡី ក្នុងនគររាជគ្រឹះ ស្រុកកំណើតឪពុកនៅឯកុររឃរនគរ អវន្តីជនបទ តែព្រះសោណៈក្នុងទីនេះ ជាកោលិយរាជវង្ស ជាព្រះសោណៈអង្គទីបីទេដឹង ។

នោះឯង ។

ឈ្មោះថា **យសោធរ** ព្រោះទ្រទ្រង់នូវយស ពោល គឺបរិវារសម្បត្តិ និងទ្រព្យសម្បត្តិ ក្នុងសេចក្តីថា ព្រះរាជាទាំងអស់នោះ គឺព្រះរាជាដែលជាចក្រពត្តិទាំង ៧៧ អង្គ មានព្រះនាមដូចគ្នាតែមួយថា **យសោធរ** ។

បទថា **អង្គីរសោ** សេចក្តីថា រស្មីដែលផ្សាយចេញអំពីអវយវៈ គឺអំពីព្រះសរីរៈរបស់ព្រះពុទ្ធអង្គណា ព្រះពុទ្ធអង្គនោះ ឈ្មោះថា អង្គីរស ។ ឈ្មោះថា **នាគ** ព្រោះមិនទៅអបាយ ៤ ដោយឆន្ទាគតិ ទោសាគតិ មោហាគតិ និងភយាគតិ ឬដោយអំណាចការប្រព្រឹត្តអាក្រក់ ។ ឈ្មោះថា **មហានាគ** ព្រោះជានាគធំ និងជាបុគ្គលដែលគេបូជាធំ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយនោះឯង ។៚

## អដ្ឋកថាសោណកោដិយវេស្សត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទានទី ៣

[ ៨៥ ] ប្រជុំជនទាំងពួង បានចូលគាល់ព្រះសម្ពុទ្ធ ព្រះនាម បទុមុត្តរៈ ទ្រង់មានព្រះហឫទ័យប្រកបដោយមេត្តា ជាអ្នកប្រាជ្ញ ដ៏ប្រសើរ ទ្រង់ដឹកនាំសត្វដ៏វិសេស ក្នុងលោកទាំងមូល ។ ពួក ជនទាំងពួង តែងថ្វាយនូវសដូវផង នំឈ្មោះបវាកៈផង អាមិស ទឹក និងភោជនផង ដល់ព្រះសាស្តា ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ឯ ខ្ញុំក៏គិតថា នឹងនិមន្តព្រះពុទ្ធដ៏ប្រសើរផង ព្រះសង្ឃដ៏ប្រសើរផង ហើយនឹងថ្វាយទានដល់ព្រះសម្ពុទ្ធ ជាទេវតាដ៏ក្រៃលែងជាងទេវតា ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ពួកជនទាំងនុ៎ះ ដែលខ្ញុំបញ្ជូន ទៅឲ្យនិមន្ត ក៏បាននិមន្តព្រះតថាគតផង ភិក្ខុសង្ឃទាំងអស់ ជា បុញ្ញក្ខេត្តដ៏ប្រសើរផង ។ ខ្ញុំបានក្រាលបល្ល័ង្ក មានថ្លៃមួយសែន ជាវិការនៃមាស កម្រាលឈ្មោះគោណកៈ ព្រមដោយកម្រាល ញាត់គ កម្រាលធ្វើដោយរោមសត្វ ជាផ្កាចង្កោមផង កម្រាល ដែលធ្វើដោយសម្បកឈើ កម្រាលដែលត្បាញដោយអំបោះ ផង ។ ខ្ញុំក្រាលនូវអាសនៈ មានថ្លៃដ៏ច្រើនគួរដល់ព្រះពុទ្ធ ឯព្រះ បទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ជាទេវតាប្រសើរជាង ទេវតា ជានរាសភៈ ទ្រង់កុះករដោយភិក្ខុសង្ឃ ស្តេចចូលមក កាន់ទ្វារផ្ទះរបស់ខ្ញុំ ខ្ញុំក្រោកទទួលព្រះសម្ពុទ្ធ ជាលោកនាថ ដ៏ទ្រង់យស ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ញុំាងភិក្ខុសង្ឃ

មួយសែនអគ្គ ទាំងព្រះពុទ្ធជាលោកនាយក ឲ្យចូលមកកាន់ផ្ទះរបស់ខ្លួន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ( ញ៉ាំងព្រះសមុទ្ធ និងភិក្ខុសង្ឃ ) ឲ្យឆ្អែតស្កប់ស្កល់ ដោយចង្ហាន់ដ៏ថ្លៃថ្លា ព្រះបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយត្រាស់នូវគាថាទាំងនេះថា

កុលបុត្តណា ថ្វាយអាសនៈ ជាវិការនៃមាស ក្រាលដោយកម្រាលគោណកៈនេះ តថាគតនឹងសម្តែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្តនោះ នឹងសោយទេវរជ្ជសម្បត្តិ អស់ ៧៤ ដង នឹងសោយទិព្វសម្បត្តិ មានពួកស្រីអប្សរចោមរោម នឹងបានគ្រប់គ្រងផែនដី បានជាស្តេចក្នុងប្រទេសមួយពាន់ដង ។ នឹងកើតជាស្តេចចក្កពត្តិអស់ចំនួន ៥១ ដង នឹងបានជាអ្នកមានត្រកូលខ្ពស់ក្នុងកំណើតដែលមានក្នុងភពទាំងពួង ។ លុះកាលជាខាងក្រោយ កុលបុត្តនោះ ត្រូវកុសលមូលដាស់តឿន ក៏ចេញបួស មានទាមថា ភទ្ទិយៈ នឹងបានជាសាវករបស់ព្រះសាស្តា ។

ខ្ញុំប្រកបរឿយៗ នូវវិវេក អាស្រ័យនៅក្នុងសេនាសនៈដ៏ស្ងាត់ ផលទាំងអស់ ខ្ញុំបានសម្រេចហើយ ក្នុងថ្ងៃនេះ ខ្ញុំមានកិលេសលះបង់ហើយ ។ ព្រះសព្វញ្ញូជាលោកនាយក ទ្រង់ជ្រាបនូវហេតុសព្វគ្រប់របស់ខ្ញុំ ទើបទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំ

ក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកទ្ទិយកាឡិគោធាយបុត្តត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## កទ្ទិយកាឡិគោធាយបុត្តត្ថេរាបទាន ចប់

# អដ្ឋកថា

## ភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទាន

[ ៤៥ ] *អបទានរបស់ព្រះភទ្ទិយកាឡិគោធាយបុត្តត្ថេរ មានពាក្យផ្តើមថា* **បទុមុត្តរសម្ពុទ្ធំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលមួយ ដែលសម្បូរដោយសម្បត្តិ ចម្រើនវ័យហើយ ដល់ព្រមដោយបុត្ត និងភរិយា ឃើញអ្នកនគរនាំគ្នាធ្វើបុណ្យ ខ្លួនឯងក៏ចង់ធ្វើបុណ្យដែរ ទើបនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យក្រាលទីដេកដែលគួរដល់តម្លៃច្រើន កម្រាលមានរូបផ្កាជាប់គ្នាជាដើមជាច្រើន កាលព្រះមានព្រះភាគប្រថាប់គង់ក្នុងទីនោះមួយអន្លើដោយសង្ឃហើយ ទូលនិមន្តឲ្យសោយព្រះក្រយាហារដ៏ប្រណីតហើយបានថ្វាយមហាទាន កុលបុត្តនោះ បំពេញបុណ្យទាំងឡាយដរាបដល់អស់អាយុ ដោយអាការយ៉ាងនេះ សោយសម្បត្តិទាំងពីរ ក្នុងទេវតា និងមនុស្សទាំងឡាយ កាលតមក ក្នុងពុទ្ធុប្បាទកាលនេះ កើតជាបុត្តរបស់នាងកាឡិគោធាទេវី ។ ដល់នូវភាពជាអ្នកដឹងក្តីហើយ បានប្រាកដនាមថាភទ្ទិយកាឡិគោធាបុត្ត ព្រោះចម្រើនដោយរូបសម្បត្តិ គឺមានដៃ និងជើងវែងធំ និងព្រោះជាបុត្តរបស់នាងកាឡិគោធាទេវី ។ កុលបុត្តនេះ ជ្រះថ្លាក្នុងព្រះសាស្តា សូមឲ្យមាតាបិតាអនុញ្ញាតហើយ ចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

លោកបានជាព្រះអរហន្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរសម្ពុទ្ធំ** ជាដើម ។ ពាក្យនេះមានអត្ថដូចលោកពោលមកហើយ ។ បទថា **មេត្តចិត្តំ** សេចក្តីថា ឈ្មោះថា **មេត្តា** ព្រោះស្រឡាញ់ ជាប់ជំពាក់ ត្រេកអរ ក្នុងសត្វគ្រប់ជំពូក ចិត្តប្រកបដោយមេត្តានោះ ឈ្មោះថា **មេត្តាចិត្ត** ចិត្តប្រកបដោយមេត្តានោះ របស់ព្រះមានព្រះភាគនោះមាន ហេតុនោះ ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា ជាអ្នកមានចិត្តប្រកបដោយមេត្តា ។ នូវព្រះមានព្រះភាគ ដែលមានព្រះហឫទ័យមេត្តាអង្គនោះ ។ បទថា **មហាមុនឹ** គប្បីជ្រាបវិគ្គហសព្ទដូច្នេះថា ឈ្មោះថា **មហាមុនិ** ព្រោះជាធំជាងភិក្ខុទាំងអស់ ភ្ជាប់សេចក្តីថា នូវព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈអង្គនោះ ។ បទថា **ជនតា សព្វា** សេចក្តីថា ពួកជនទាំងអស់ បានដល់ អ្នកនគរទាំងមូល ។ បទថា **សព្វលោកគ្គនាយកំ** ភ្ជាប់សេចក្តីថា ប្រជុំជនរមែងចូលដល់ គឺចូលទៅជិតព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ជាកំពូលប្រសើរជាងសត្វទាំងមូល ឈ្មោះថា **នាយក** ព្រោះនាំទៅ គឺឲ្យទៅដល់ព្រះនិព្វាន ។

បទថា **សត្តុកញ្ច ពទ្ធកញ្ច** សេចក្តីថា បាននូវអាមិស ពោល គឺសដូវជុំ និងសដូវផង់ ។ម្យ៉ាងទៀត ភ្ជាប់សេចក្តីថា ជនទាំងឡាយរមែងកាន់យកអាមិស គឺទឹកផឹក និងអាហារដែលជាយាវកាលិក មានកត្ត នំរបស់ទំពា របស់បរិភោគ និងបបរជាដើម ហើយថ្វាយដល់ព្រះសាស្តាដែល

ជាបុញ្ញខេត្តដ៏កំពូល ។

បទថា **អាសនំ ពុទ្ធយុត្តកំ** សេចក្តីថា នូវអាសនៈដែលសម្រេចដោយរតនៈ ៧ ប្រការ ដែលគួរដល់ព្រះពុទ្ធ គឺដែលសមគួរដល់ព្រះពុទ្ធ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាភទ្ទិយកាឡិគោធាយបុត្តត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សន្និដ្ឋាបកត្ថេរាបទានទី ៤

[ ៤៦ ] ខ្ញុំធ្វើខ្ទមក្នុងព្រៃ ត្រង់ចន្លោះភ្នំ ហើយនៅ ជាអ្នកសន្តោស ដោយលាភ និងឥតលាភផង ដោយយស និងឥតយសផង ។ ព្រះសម្ពុទ្ធបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលនូវគ្រឿងបូជា ទ្រង់ធ្វើពុទ្ធដំណើរមកក្នុងសម្នាក់របស់ខ្ញុំ ជាមួយនឹងភិក្ខុសង្ឃ ប្រមាណមួយសែនអង្គ ។ ព្រះសម្ពុទ្ធ ជាមហានាគ ព្រះនាមបទុមុត្តរៈ ស្តេចយាងមកដល់ហើយ ខ្ញុំក្រាលកម្រាលស្មៅ ថ្វាយព្រះសាស្តា ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែល្មុងប្រេងផង ទឹកផង ចំពោះព្រះសាស្តា ទ្រង់មានសន្តានត្រង់ ដោយចិត្តដែលជ្រះថ្លា ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែល្មុងប្រេង ។ ក្នុងកប្បទី ៤១ ខ្ញុំបានជាស្តេចមួយព្រះអង្គ ឈ្មោះអរិន្ទមៈ ជាស្តេចចក្កពត្តិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសន្និដ្ឋាបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សន្និដ្ឋាបកត្ថេរាបទាន ចប់**

# អដ្ឋកថា

## សន្និដ្ឋាបកត្ថេរាបទាន

[ ៤៦ ] *អបទានរបស់ព្រះសន្និដ្ឋាបកត្ថេរ មានពាក្យផ្ដើមថា* **អរញ្ញេ កុដិកំ កត្វា** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ត្រូវរៀបចំឲ្យមានគ្រួសារ ឃើញទោសក្នុងការគ្រប់គ្រងផ្ទះ ទើបលះវត្ថុកាម និងកិលេសកាម ចូលកាន់ព្រៃត្រង់ចន្លោះភ្នំ មិនឆ្ងាយអំពីហិមវន្តបព៌ត ។ ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់យាងដល់ទីនោះ ព្រោះទ្រង់ត្រូវការវិវេក ។ គ្រានោះតាបសនោះ ឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ថ្វាយបង្គំហើយ បានលាតស្មៅថ្វាយដើម្បីប្រថាប់គង់ ។ តាបសនោះ ថ្វាយផ្លែឈើតូចធំច្រើនប្រភេទដែលមានរសឆ្ងាញ់ មានផ្លែទន្លាប់ជាដើម ឲ្យព្រះមានព្រះភាគគង់លើអាសនៈនោះ សោយរហូតស្កប់ស្កល់ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះចុតិចាកអត្តភាពនោះហើយ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់ព្រមដោយសទ្ធា បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ប្រាកដនាមថា សន្និដ្ឋាបកត្ថេរ ព្រោះតាំងនៅដោយល្អក្នុងព្រះនិព្វាន ពោល គឺសន្តិបទ ដោយមិនចាំបាច់ព្យាយាម ( ខ្លាំង ) នោះឯង*

ដូចក្នុងការសម្រេចអរហត្ត ខណៈកាំបិតកោរដល់ក្បាល ។ កាលសម្រេចអរហត្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អរញ្ញេ កុដិកំ កត្វា** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អរញ្ញេ** គប្បីជ្រាបវិគ្គហសព្ទថា ឈ្មោះថា **អរញ្ញ** ព្រោះមិនមែនទីកន្លែងដែលមនុស្សត្រេកអរពេញចិត្តនៅអាស្រ័យ ព្រោះមានភ័យអំពីរាជសីហ៍ និងខ្លាធំជាដើម អំពីព្រៃនោះ ។ បទថា **កុដិកំ** សេចក្ដីថា ខ្ញុំធ្វើនូវខ្ទមប្រក់ដោយស្មៅ គឺសម្រេចការនៅក្នុងរោងភ្នំ ភ្ជាប់សេចក្ដីថា ខ្ញុំសន្ដោសដោយលាភ និងការមិនមានលាភ ដោយយស និងដោយការមិនមានយស ។

បទថា **ជលជុត្តមនាមកំ** សេចក្ដីថា វត្ថុដែលកើតក្នុងទឹក ឈ្មោះថា **ជលជ** គឺផ្កាឈូក ។ ផ្កាឈូកដែលកើតក្នុងទឹកដ៏ឧត្តម ឈ្មោះថា **ជលជុត្តម** ។ ព្រះពុទ្ធអង្គណា មានព្រះនាមស្មើដោយផ្កាឈូកដ៏ឧត្តម ព្រះពុទ្ធអង្គនោះ ព្រះនាមថា **ជលជុត្តម** ។ ព្រះនាមថា បទុមុត្តរៈអង្គនោះ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ព្រោះប្រកបដោយន័យដែលមកហើយ ក្នុងព្រះបាលីនោះឯង ។៚

## អដ្ឋកថាសន្និដ្ឋាបកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បញ្ចហត្ថិយត្ថេរាបទានទី ៥

[ ៤៧ ] ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ទ្រង់សង្រួមចក្ខុ ពោលពាក្យល្មមកំណត់ មានស្មារតី សង្រួមឥន្ទ្រិយ ទ្រង់និមន្តទៅក្នុងចន្លោះរានផ្សារ ។ ពួកជនធ្វើផ្កាឧប្បល ៥ ក្ដាប់ ឲ្យជាគ្រឿងប្រដាប់ក្បាលសម្រាប់ខ្ញុំ ខ្ញុំមានចិត្តជ្រះថ្លា បានយកគ្រឿងប្រដាប់ក្បាលនោះ បូជាព្រះពុទ្ធដោយដៃរបស់ខ្លួន ។ ផ្កាទាំងនោះ ដែលខ្ញុំលើកឡើងហើយ ក៏ទៅជាគ្រឿងបិទបាំង ថ្វាយព្រះសាស្ដានោះ ( ហោមរោម ) ព្រះមហានាគក្នុងសមាធិ ដូចជាសិស្ស ( ហោមរោម ) អាចារ្យដូច្នោះដែរ ។ ក្នុងកប្បទី ៣០០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២០០០ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ៥ ដង ព្រះនាមហត្ថិយៈដូចគ្នា ជាស្ដេចចក្កពត្តិ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចហត្ថិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បញ្ចហត្ថិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បញ្ចហត្ថិយត្ថេរាបទាន

[ ៤៧ ] អបទានរបស់ព្រះបញ្ចហត្ថិយត្ថេរ មានពាក្យផ្ដើមថា **សុមេធោ នាម សម្ពុទ្ធោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមសុមេធៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ ។ សម័យនោះ ជនទាំងឡាយបាននាំផ្កាឧប្បល ៥ ក្ដាប់មក ។ កុលបុត្តនោះ បូជាព្រះមានព្រះភាគព្រះនាមសុមេធៈ ដែលកំពុងត្រាច់ទៅលើវិថី ដោយផ្កាឧប្បល ៥ ក្ដាប់នោះ ។ ផ្កាឧប្បលទាំងនោះ បានអណ្ដែតទៅជាពិតាន ធ្វើជាស្រមោលនៅក្នុងអាកាស ទៅព្រមជាមួយព្រះតថាគតនោះឯង ។ កុលបុត្តនោះឃើញដូច្នោះ កើតនូវសោមនស្ស ជាអ្នកមានសរីរៈផ្សាយទៅដោយបីតិ ញុំាងចិត្តឲ្យជ្រះថ្លា ញុំាងបុណ្យនោះឯង នៅដរាបដល់អស់ជីវិត ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោលទៅមក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ បាននូវសទ្ធា ចេញបួសចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត លោកប្រាកដដោយឈ្មោះថា បញ្ចហត្ថិយត្ថេរ តាមឈ្មោះកុសលដែលបានធ្វើមក ។

លោករឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្ត មកក្នុងកាលមុន ដែលឃើញច្បាស់ដោយបញ្ញា ទើបពោលពាក្យថា **សុមេធោ នាម សម្ពុទ្ធោ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **សុមេធោ** ក្ឌប់សេចក្ដីថា មេធាល្អ គឺបញ្ញា មានបញ្ញាជាគ្រឿងចាក់ធ្លុះនូវសច្ចៈ ៤ និងបដិសម្ភិទាជាដើម មានដល់ព្រះ មានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **សុមេធ** ។ ព្រះ សម្មាសម្ពុទ្ធយាងទៅរវាងផ្លូវ ក្នុងរវាងភនផ្សារ ។ បទថា **ឱក្ខិត្តចក្ខុ** គឺមាន ព្រះនេត្រដាក់ចុះ ។ បទថា **មិតភាណី** សេចក្ដីថា មានប្រក្រតីត្រាស់ ដោយទ្រង់ដឹងប្រមាណ អធិប្បាយថា ទ្រង់សម្ដែងធម៌ ដោយស្គាល់ ប្រមាណ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ៕

## អដ្ឋកថាបញ្ចហត្ថិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បទុមច្ឆទនិយត្ថេរាបទានទី ៦

[ ៤៨ ] កាលព្រះលោកនាថ ជាអគ្គបុគ្គល ព្រះនាមវិបស្សី ទ្រង់បរិនិព្វានហើយ ខ្ញុំយកផ្កាឈូកដែលរីកល្អ លើកតម្កល់លើជើងថ្ករ ។ លុះខ្ញុំលើកជើងថ្ករឡើង ផ្កាក៏អណ្តែតត្រសែតទៅឯអាកាស ជាទីរីករាយនៃពួកសត្វស្លាប ធ្វើជាជំបូល បិទបាំងកម្តៅថ្ងៃនាអាកាស ខ្ញុំក៏បានទ្រនូវជើងថ្ករនោះ ។ ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់នូវទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤៧ អំពីភទ្ទកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ មាននាមថាបទុមិស្សរៈ ទ្រង់ឈ្នះសង្គ្រាម មានទីបំផុតទល់នឹងសមុទ្ទទាំង ៤ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមច្ឆទនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បទុមច្ឆទនិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បទុមច្ឆទនិយត្ថេរាបទាន

[ ៤៨ ] *អបទានរបស់ព្រះបទុមច្ឆទនិយត្ថេរ មានពាក្យផ្ដើមថា* **ឆិត្វាន លោកជាជេដ្ឋំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ កាលព្រះមានព្រះភាគព្រះនាមវិបស្សីបរិនិព្វានហើយ បានបូជាជើងថ្ករ ដោយផ្កាឈូកទាំងឡាយ ។*

*កុលបុត្តនោះ តាំងនៅដោយចិត្តជ្រះថ្លាដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងសុគតិប៉ុណ្ណោះ សោយសម្បត្តិទាំងពីរ គឺទិព្វសម្បត្តិ និងមនុស្សសម្បត្តិច្រើនដង ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធនៃយើងនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសក្នុងព្រះសាសនា ព្យាយាមមិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត ។ កាលលោកស្នាក់នៅក្នុងទីផ្សេងៗ ដូចជាទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃជាដើម វិហារបានត្រូវប្រក់បាំងដោយផ្កាឈូក ដោយកុសលនោះ ទើបលោកបានឈ្មោះថា បទុមច្ឆទនិយត្ថេរ ។*

លោករឭកដល់បុព្វកម្មរបស់ខ្លួនហើយ កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចសោមនស្ស ទើបពោលពាក្យថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **និព្វុតេ** សេចក្ដីថា កាលព្រះសាស្ដាបរិនិព្វាន ដោយខន្ធបរិនិព្វាន កាលព្រះសរីរៈរបស់ព្រះសម្មាសម្ពុទ្ធ ព្រះនាមថា វិបស្សី ត្រូវនាំឡើងកាន់ជើងថ្ករដ៏វិចិត្រ ខ្ញុំបានកាន់យកត្របកឈូក ដែលរីកល្អហើយ លើកដាក់លើជើងថ្ករបូជា ។ ក្នុងគាថាដ៏សេស មានអត្ថងាយយល់ហើយ ព្រោះមានន័យ ដូចខ្ញុំពោលមកហើយខាងដើមនោះឯង ៕

**អដ្ឋកថាបទុមច្ឆទនិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សយនទាយកត្ថេរាបទានទី ៧

[ ៤៩ ] ខ្ញុំថ្វាយទីព្រះបន្ទំដ៏ប្រសើរ ដែលក្រាលដោយសំពត់ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទ្រង់មានមេត្តាចិត្ត មិនញាប់ញ័រ ដោយលោកធម៌ ។ ព្រះមានព្រះភាគ ទ្រង់ទទួលកប្បិយសយនាសនៈហើយ ព្រះជិនស្រី ទ្រង់ក្រោកឡើងអំពីទីព្រះបន្ទំនោះហើយ ទ្រង់ហោះឡើងទៅឯអាកាស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទីសយនៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទីសយនៈ ។ ក្នុងកប្បទី ៥១ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ ព្រះនាមវរុណទេវៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសយនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សយនទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## សយនទាយកត្ថេរាបទាន

[ ៤៩ ] *អបទានរបស់ព្រះសយនទាយកត្ថេរ មានពាក្យផ្តើមថា* **សិទ្ធត្ថស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលមួយ ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាស្តា សាងគ្រែដេក មានមាសជាដើម ដែលគេផែមានសណ្ឋានដូចកូបនៃដំរី ក្រាលដោយកម្រាលដ៏វិចិត្រ មានតម្លៃរាប់មិនបាន បូជាព្រះមានព្រះភាគ ។ ព្រះមានព្រះភាគអង្គនោះទ្រង់ទទួលហើយ ទ្រង់ប្រើប្រាស់ដើម្បីជាការអនុគ្រោះ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយទិព្វសម្បត្តិ និងមនុស្សសម្បត្តិជាច្រើន ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាសនារបស់ព្រះសាស្តា បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត លោកជាអ្នកប្រាកដនាមថា សយនទាយកត្ថេរ តាមឈ្មោះបុណ្យដែលធ្វើមកក្នុងកាលមុន ។*

*ថ្ងៃមួយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សិទ្ធត្ថស្ស ភគវតោ** *ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ដោយគន្លងដែលមកក្នុងព្រះបាលីនោះឯង ។៚*

# សុត្តន្តបិដក

## ចន្ទមទាយកត្ថេរាបទានទី ៨

[ ៥០ ] ខ្ញុំបានឲ្យជាងធ្វើទីចង្រ្កមក្រាលឥដ្ឋ ( ថ្វាយ ) ចំពោះព្រះមុនី ព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ទីចង្រ្កមនោះ មានកម្ពស់ ៥០ ហត្ថក្រពុំបណ្តោយ ១០០ ហត្ថ ជាទីគួរសរសើរ គួររីករាយនៃចិត្ត ខ្ញុំបានកសាងហើយដោយប្រពៃ ។ ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សីដ៏ប្រសើរជាងពួកនរៈ ទ្រង់បានទទួលហើយ ទ្រង់ចាប់យកខ្សាច់ដោយព្រះហស្ត ហើយសម្តែងនូវគាថាទាំងនេះថា

ដោយការឲ្យដីខ្សាច់នេះផង ដោយការធ្វើទីចង្រ្កមល្អនេះផង បុគ្គលនេះ នឹងបានទទួលនូវផ្ទះខ្សាច់ ដ៏បរិបូណ៌ដោយកែវ ៧ ប្រការ ។ កុលបុត្តនោះ នឹងគ្រប់គ្រងទេវរាជ្យ សោយទិព្វសម្បត្តិជាស្តេចនៃទេវតា ក្នុងទេវលោក មានពួកស្រ្តីអប្សរចោមរោមអស់ ៣ កប្ប ។ លុះត្រឡប់មកកាន់មនុស្សលោក នឹងបានជាស្តេចក្នុងដែន កុលបុត្តនោះ នឹងបានជាស្តេចចក្កពត្តិលើផែនដីអស់ ៣ ដង ។

ក្នុងកប្បទី ១៨០០ ព្រោះហេតុដែលខ្ញុំធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទីចង្ក្រម ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចង្កមទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចង្កមទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ចន្ទមទាយកត្ថេរាបទាន

[ ៥០ ] *អបទានរបស់ព្រះចន្ទមទាយកត្ថេរ មានពាក្យផ្តើមថា* **អត្ថទស្សិស្ស មុនិនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយក្នុង ព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាសនា បានសាងទីចង្ក្រមដែលខ្ពស់ដ៏ល្អ ដូចគ្នានឹងគំនរប្រាក់ បូកលាបដោយបាយ-អ ហើយក្រាលដោយខ្សាច់ពណ៌ស ដូចគ្នានឹងកម្រងគជ់ ថ្វាយដល់ព្រះមានព្រះភាគ ។*

*ព្រះមានព្រះភាគទ្រង់ទទួលហើយ កាលទ្រង់ទទួលទីចង្ក្រម ទ្រង់ចូលសមាធិដែលធ្វើឲ្យកាយ និងចិត្តជាសុខ ហើយទ្រង់ព្យាករថា ក្នុងអនាគតកុលបុត្តនេះ នឹងបានជាសាវ័កក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ដល់ព្រមដោយសទ្ធា បួសក្នុងព្រះសាសនា មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត លោកបានប្រាកដនាមថា ចន្ទមទាយកត្ថេរ តាមឈ្មោះបុណ្យដែលបានធ្វើមកហើយ ។*

ថ្ងៃមួយ លោករឭកដល់បុញ្ញកម្ម ដែលធ្វើក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តក្នុងកាលមុន ទើបពោលពាក្យថា **អត្ថទស្សិស្ស មុនិនោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អត្ថទស្សិស្ស** សេចក្ដីថា ឈ្មោះថា **អត្ថទស្សី** ព្រោះទ្រង់ឃើញនូវប្រយោជន៍ គឺការចម្រើនដុះដាល បានដល់ព្រះនិព្វាន ម្យ៉ាងទៀត ឈ្មោះថា **អត្ថទស្សី** ព្រោះមានប្រក្រតីឃើញប្រយោជន៍ គឺព្រះនិព្វាន ភ្ជាប់សេចក្ដីថា ខ្ញុំបានសាងទីចង្ក្រមដែលគួរជាទីត្រេកអរ ជាទីពួនសម្ងំ ជាទីចម្រើនភាវនា ជាទីទាញចិត្ត ថ្វាយដល់ព្រះមានព្រះភាគ ជាអ្នកមានប្រក្រតីឃើញប្រយោជន៍នោះ ជាមុនី គឺប្រកបដោយញាណ គឺមោនៈ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ តាមគន្លងន័យដែលពោលហើយនោះឯង ៕

## អដ្ឋកថាចង្កមទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សុភទ្ទត្ថេរាបទានទី ៩

[ ៥១ ] ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវត្រៃលោក គួរទទួលគ្រឿងបូជា មានយសច្រើន ទ្រង់ស្រោចស្រង់នូវប្រជុំជន ហើយទ្រង់បរិនិព្វាន ។ កាលព្រះសម្ពុទ្ធបរិនិព្វាន លោកធាតុមួយហ្មឺន ក៏ញាប់ញ័រ ពួកជនច្រើន និងពួកទេវតា ក៏ប្រជុំគ្នា ក្នុងកាលនោះ ។ ខ្ញុំបានញុំាងទីនោះឲ្យពេញដោយខ្លឹមចន្ទន៍ ខ្លឹមក្រស្នា និងខ្លឹមក្លាំពាក់ ខ្ញុំមានចិត្តត្រេកអររីករាយ បានលើកឡើងនូវព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងពួកនរៈ ។ ព្រះសាស្តា ជាបុគ្គលប្រសើរផុតក្នុងលោក ទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ព្រះសម្ពុទ្ធទ្រង់ផ្ទំសម្តែងនូវគាថាទាំងនេះថា

ក្នុងកាលជាទីបំផុតនៃជន្មាយុ របស់តថាគត បុរសណាបានបិទបាំងតថាគត ដោយថ្មមានក្លិនក្រអូប តថាគតនឹងសម្តែងសរសើរនូវបុរសនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនោះ លុះច្យុតចាកអត្តភាពនេះ នឹងទៅកាន់ពួកទេវតា ក្នុងស្ថានតុសិត សោយរាជសម្បត្តិ ក្នុងស្ថានតុសិតនោះ ហើយនឹងទៅកាន់ស្ថាននិម្មានរតីទៀត ។ បុរសនោះ បានឲ្យថ្មដ៏ឧត្តមប្រសើរ ដោយឧបាយទុំះឯង ជាអ្នកប្រារព្ធនូវកម្មរបស់ខ្លួន នឹងទទួលនូវសម្បត្តិ ។ នរជននេះ នឹងកើតក្នុងពួកទេវតា ក្នុងស្ថានតុសិតម្តងទៀត លុះច្យុតចាកពួកទេវតា ក្នុងស្ថានតុសិតនោះ

នឹងមកកាន់អត្តភាពជាមនុស្ស ។ ព្រះសក្យបុត្ត ជាមហានាគ ជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ទ្រង់មានបញ្ញាចក្ខុ បានញ៉ាំងពួកសត្វច្រើន ឲ្យត្រាស់ដឹងហើយ នឹងបរិនិព្វាន ។ ក្នុងកាលនោះ បុរសនោះ បានចូលទៅ មានចិត្តស្ងប់រម្ងាប់ មានកុសលមូលជាស់តឿន ហើយក៏ចូលទៅគាល់ព្រះសម្ពុទ្ធ នឹងសួរនូវប្រស្នា ក្នុងកាលនោះ ។ ព្រះសម្ពុទ្ធជាសព្វញ្ញូ លោកនាយក ទ្រង់ធ្វើឲ្យរីករាយហើយ នឹងបើកនូវសច្ចធម៌ទាំងឡាយ ព្រោះទ្រង់ជ្រាបនូវបុព្វកម្ម ។ បុរសនោះ ប្រារព្ធប្រស្នានេះហើយ ជាអ្នកត្រេកអរ មានចិត្តខ្ពស់ឯក នឹងថ្វាយបង្គំព្រះសាស្តា ហើយសូមផ្នួស ។ ព្រះពុទ្ធនោះ ទ្រង់ជាបុគ្គលឈ្លាសក្នុងធម៌ដ៏ប្រសើរ ទ្រង់ឃើញបុរសនោះ មានចិត្តជ្រះថ្លា ត្រេកអរដោយកម្មរបស់ខ្លួនហើយ នឹងទ្រង់បំបួស ។ បុរសនេះ ព្យាយាមក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

## ភាណវារទី ៥ ចប់

ខ្ញុំប្រកបព្រមហើយ ដោយបុព្វកម្មរបស់ខ្លួន មានចិត្តមូលតែមួយ មានចិត្តតាំងមាំ ជាធម្មនិម្មិត ជាបុត្តកើតអំពីទ្រូងរបស់ព្រះសម្មា-សម្ពុទ្ធ ។ ខ្ញុំចូលទៅអង្គុយជិតព្រះពុទ្ធ ជាធម្មរាជ ហើយសួរប្រស្នាដ៏ប្រសើរ ឯព្រះអង្គ កាលនឹងសម្តែងនូវប្រស្នាដល់ខ្ញុំ ទ្រង់

នាំមកនូវធម្មសោតៈ ។ ខ្ញុំដឹងនូវធម៌របស់ព្រះធម្មរាជនោះហើយ ត្រេកអរនឹងសាសនា កំណាត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទីមួយសែន អំពីភទ្ទកប្បនេះ ព្រះនាយកព្រះនាមបទុមុត្តរៈ ទ្រង់បរិនិព្វាន មិនមានឧបាទាន ដូចប្រទីបដែលរលត់ ព្រោះអស់ប្រេង ។ ព្រះស្តូបជាវិការនៃកែវ ប្រកបដោយយោជន៍ ៧ ណា ខ្ញុំបានបូជាទង់ដ៏ល្អ ជាទង់ទាំងអស់ជាទីរីករាយនៃចិត្ត ចំពោះព្រះស្តូបនោះ ។ កូនដែលកើតអំពីទ្រូងរបស់ខ្ញុំ ឈ្មោះតិស្សៈ ជាអគ្គសាវករបស់ព្រះពុទ្ធ ព្រះនាមកស្សបៈ ជាទាយាទក្នុងសាសនានៃព្រះជិនស្រី ។ ខ្ញុំមានចិត្តថោកទាប បានពោលពាក្យមិនពីរោះ ដល់ព្រះតិស្សៈនោះ ព្រោះតែផលកម្មប៉ុណ្ណោះ ទើបខ្ញុំមានសេចក្តីល្អ ក្នុងកាលជាខាងក្រោយបំផុត ។ ព្រះមុនីទ្រង់មានព្យាយាមធំ ស្វែងរកប្រយោជន៍មានសេចក្តីករុណា ទ្រង់ឈ្នះកិលេស បានបំបួសខ្ញុំ ក្នុងបច្ឆិម-សយនៈ ក្នុងសាលវ័ន ជាទីសម្រាប់ចេញចូល ។ ឥឡូវនេះ បព្វជ្ជា ( របស់ខ្ញុំ ) មានក្នុងថ្ងៃនេះ ឧបសម្បទា ក៏មានក្នុងថ្ងៃនេះ បរិនិព្វាន ក៏មានក្នុងថ្ងៃនេះ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះ

សម្ពុទ្ធ ទ្រង់ឧត្តមជាងសត្វជើងពីរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុភទ្ទត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សុភទ្ទត្ថេរាបទាន ចប់

# អដ្ឋកថា

## សុភទ្ទត្ថេរាបទាន

[ ៥១ ] *អបទានរបស់ព្រះសុភទ្ទត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរោ លោកវិទូ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជាអ្នកបរិបូណ៌ដោយទ្រព្យសម្បត្តិ ដល់ព្រមដោយសទ្ធា ដល់នូវភាពជាអ្នកដឹងក្ដីហើយ ត្រូវរៀបចំឲ្យមានគ្រួសារ ជ្រះថ្លាក្នុងព្រះរតនត្រ័យ ឃើញព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ផ្ទំលើព្រះទែនដែលជាទីបរិនិព្វាន និងឃើញទេវតាក្នុងមឺនចក្រវាលប្រជុំគ្នា មានចិត្តជ្រះថ្លា បូជាដោយផ្កាមានក្លិនក្រអូប មានផ្កាគុណ្ឌី-ស ផ្ការំចេក ផ្កាអសោកខៀវ និងអសោក-ស ជាដើមជាច្រើន ដោយបុញ្ញកម្មនោះ កុលបុត្តនោះ តាំងនៅដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ សោយទិព្វសម្បត្តិក្នុងស្ថានតុសិតជាដើម បន្ទាប់អំពីនោះ សោយសម្បត្តិមនុស្សក្នុងមនុស្សលោក បានជាបុគ្គលដែលគេបូជាដោយផ្កាទាំងឡាយ ដែលមានក្លិនក្រអូបគ្រប់ទី ដែលកុលបុត្តនោះកើត ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញទោសក្នុងកាមទាំងឡាយ មិនបានឃើញព្រះពុទ្ធដរាបដល់កាលដែលព្រះមានព្រះភាគទ្រង់បរិនិព្វាន បួសក្នុងពេលដែលព្រះមានព្រះភាគ ទ្រង់ផ្ទំលើព្រះទែនជាទី*

បរិនិព្វាននោះឯង សម្រេចអរហត្តហើយ លោកបានប្រាកដនាមថា សុកន្ទ តាមបុណ្យដែលធ្វើមកក្នុងកាលមុន ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្ត មកក្នុងកាលមុន ដោយអំណាចសោមនស្ស ទើបពោលពាក្យថា **បទុមុត្តរោ លោកវិទូ** ដូច្នេះជាដើម ។ ពាក្យ ២ បទនេះ មានអត្ថងាយយល់ហើយ ។ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ផ្ទំលើព្រះទែនដែលជាទីបរិនិព្វាន នោះឯង បានព្យាករពាក្យនេះថា **សុណាថ មម ភាសតោ ។បេ។ និព្វាន-យិស្សតិនាសវោ** ដូច្នេះ ។

## ភាណវារទី ៥ ចប់

ព្រះថេរៈកាលសម្តែងបដិបទារបស់ខ្លួន ទើបពោលពាក្យថា **បុព្វ-កម្មេន សំយុត្តោ** ដូច្នេះជាដើម ។ បទថា **ឯកគ្គោ** សេចក្តីថា ជាអ្នកមាន អារម្មណ៍មួយ ។ បទថា **សុសមាហិតោ** ប្រែថា ជាអ្នកមានចិត្តតាំងមាំ ដោយល្អ អធិប្បាយថា ជាអ្នកមានកាយ និងចិត្តស្ងប់ ។ បទថា **ពុទ្ធស្ស ឱរសោ បុត្តោ** សេចក្តីថា លោកស្តាប់ឱវាទានុសាសនីដែលចេញចាកទ្រូង គឺព្រះហឫទ័យ សម្រេចអរហត្តផលហើយ ។ បទថា **ធម្មជោម្ហិ សុនិម្មិតោ** សេចក្តីថា កើតអំពីធម៌ គឺចាកការបំពេញកម្មដ្ឋាន អធិប្បាយថា បានទទួល និម្មិតមកដោយអរិយជាតិ គឺជាអ្នកមានកិច្ចទាំងពួងសម្រេចហើយដោយល្អ ។

បទថា **ធម្មរាជំ ឧបគម្ម** សេចក្តីថា ខ្ញុំចូលទៅគាល់ គឺចូលទៅក្បែរ

ព្រះមានព្រះភាគដែលជាព្រះរាជា ជាធំជាងសត្វទាំងពួងដោយធម៌ ។ បទថា **អបុច្ឆឹ បញ្ហាមុត្តមំ** សេចក្តីថា ខ្ញុំបានសួរបញ្ហាដ៏ឧត្តម ដែលទាក់ទងដោយការកើតឡើងនៃខន្ធ អាយតនៈ ធាតុ និងសច្ចៈជាដើម ។ បទថា **កថយន្តោ ច មេ បញ្ហំ** សេចក្តីថា ព្រះមានព្រះភាគនៃយើងអង្គនោះ កាលត្រាស់ គឺកាលព្យាករបញ្ហាដល់ខ្ញុំ ។ បទថា **ធម្មសោតំ ឱតារយិ** សេចក្តីថា ទ្រង់នាំខ្ញុំចូល គឺនាំចូលដល់ក្រសែធម៌ គឺជំនន់នៃធម៌ ពោល គឺអនុបាទិសេសនិព្វានធាតុ ។

បទថា **ជលជុត្តមនាយកោ** គឺ **បទុមុត្តរនាមកោ** ជាពាក្យផ្លាស់ ម អក្ខរៈជា **យ** អក្ខរៈ[១] ។ បទថា **និព្វាយិ អនុបាទានោ** សេចក្តីថា រម្ងត់ហើយ គឺមិនប្រាកដ ព្រោះមិនប្រកាន់ខន្ធ ៥ ដែលជាអារម្មណ៍របស់ឧបាទាន បានដល់ ទៅកាន់ទីដែលមិនឃើញ អធិប្បាយថា មិនតាំងនៅក្នុងទីណា ដូចជាក្នុងមនុស្សលោកជាដើម ។ បទថា **ទីបោវ តេលសង្ខយា** ក្អាប់សេចក្តីថា រលត់ទៅដូចប្រទីបដែលរលត់ទៅ ព្រោះអស់ទៅ គឺការមិនមានប្រេះ និងប្រេង ។

បទថា **សត្តយោជនិកំ អាសិ** សេចក្តីថា ព្រះស្តូបដែលសម្រេចដោយរតនៈរបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ដែលបរិនិព្វានហើយនោះ មានកម្ពស់ដល់ ៧ យោជន៍ ។ បទថា **ធជំ តត្ថ អបូជេសឹ** សេចក្តីថា ខ្ញុំបានបូជាទង់ដ៏ល្អជាងទង់ទាំងពួង គឺល្អដោយប្រការទាំងពួង គួរត្រេកអរ

---

១- សូមមើលសេចក្តីអធិប្បាយ របស់ព្រះសទ្ទិដ្ឋបកត្តោបទានផង ។

នៃចិត្តដោយប្រការទាំងពួងត្រង់ចេតិយនោះ ។ បទថា **កស្សបស្ស ច ពុទ្ធស្ស** ក្លាប់សេចក្តីថា ចាប់តាំងអំពីកាលបរិនិព្វាននៃព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ ខ្ញុំអន្ទោលទៅក្នុងទេវតា និងមនុស្ស ឱរស គឺកូនរបស់ខ្ញុំឈ្មោះថា តិស្សៈ បានជាអគ្គសាវករបស់ព្រះសម្ពុទ្ធព្រះនាមកស្សបៈ គឺជាទាយាទក្នុងសាសនារបស់ព្រះជិនស្រី ។

បទថា **តស្ស ហីនេន មនសា** សេចក្តីថា ខ្ញុំជាអ្នកមានមានះ គឺមានចិត្តអាក្រក់លាមក បានពោល គឺសម្តែងពាក្យថា **អន្តកោ បច្ឆិមោ** មនុស្សចុងជួរ មនុស្សចុងក្រោយ ដូច្នេះ ជាពាក្យមិនចម្រើន មិនល្អ មិនសមគួរចំពោះអគ្គសាវកឈ្មោះតិស្សៈ ជាបុត្តរបស់ខ្ញុំនោះ ។ បទថា **តេន កម្មវិបាកេន** សេចក្តីថា ដោយវិបាកនៃអកុសលកម្ម គឺការពោលទោសព្រះអរហន្តនោះ ។ បទថា **បច្ឆិមេ អទ្ទសំ ជិនំ** សេចក្តីថា ខ្ញុំបានឃើញព្រះជិនស្រី គឺព្រះឈ្នះមារ បានដល់ ព្រះគោតមសម្មាសម្ពុទ្ធ នៃយើងដែលផ្ទំលើព្រះទែនជាទីបរិនិព្វាន ដែលជាទីសម្រាកនៃមល្លក្សត្រទាំងឡាយ ក្នុងកាលចុងក្រោយ គឺក្នុងកាលដែលបរិនិព្វាន ។ បាលីថា **បច្ឆា មេ អាសិ ភទ្ទកំ** ដូច្នេះក៏មាន អធិប្បាយថា ខ្ញុំនោះ មានការបាក់ធ្លុះសច្ចៈ ៤ ដែលចម្រើន គឺដែលល្អក្នុងកាលជាខាងក្រោយ នៃព្រះសម្មាសម្ពុទ្ធ ព្រះនាមគោតមនោះ គឺក្នុងកាលជាទីបំផុត បានដល់ ក្នុងកាលជិតបរិនិព្វានរបស់ព្រះមានព្រះភាគអង្គនោះ ។

បទថា **បព្វាជេសិ មហាវីរោ** ក្លាប់សេចក្តីថា ព្រះមហាវីរៈជាប្រយោជន៍

ដល់សត្វគ្រប់ពួកដែលប្រកបដោយព្រះករុណា ជាអ្នកឈ្នះមារ ជាមុនី ទ្រង់ផ្ទំក្នុងទីបន្ទំ គឺលើព្រះទែនដែលជាទីបរិនិព្វាន ឲ្យខ្ញុំបព្វជ្ជាក្នុងបច្ឆិមកាល ក្នុងព្រៃសាលវនោទ្យាន ដែលជាទីសម្រាកនៃមល្លក្សត្រ ។

បទថា **អជ្ជេវ ធានិ បព្វជ្ជា** សេចក្តីថា ថ្ងៃនេះឯង គឺក្នុងថ្ងៃព្រះមានព្រះភាគបរិនិព្វាន ខ្ញុំបានបព្វជ្ជា ម្យ៉ាងទៀត ថ្ងៃនេះឯង ខ្ញុំបានឧបសម្បទាភ្ជាប់សេចក្តីថា ថ្ងៃនេះខ្ញុំបានបរិនិព្វានក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសម្មាសម្ពុទ្ធឧត្តមជាងសត្វជើងពីរ ។ ពាក្យដ៏សេសងាយបានងាយហើយ ៕

**អដ្ឋកថាសុភទ្ទត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចុម្ពិតោ្តាបទានទី ១០

[ ៥២ ] ខ្ញុំធ្វើចេតិយ ស្រោបដោយផ្កាម្លិះទាំងឡាយ បូជាចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រ ដោយលោកធម៌ ។ លុះខ្ញុំរៀបចំស្រេចហើយ ទើបបង្អោនថ្វាយផ្កានោះចំពោះព្រះពុទ្ធ ហើយយកផ្កាដ៏សេសបង្អោនថ្វាយទៀត ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ នាំចេតិយផ្កាទៅថ្វាយចំពោះព្រះពុទ្ធ ជាអគ្គនាយកក្នុងលោក ព្រះអង្គប្រាកដស្មើដោយចេតិយមាស ។ ព្រះសម្ពុទ្ធ មានសេចក្តីសង្ស័យកន្លងបង់ហើយ មានពួកព្រះខីណាស្រព ដែលមានអន្ទង់ធ្លងផុត ចោមរោមហើយ ព្រះអង្គគង់នៅក្នុងភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

កុលបុត្តណា បានថ្វាយដល់តថាគត នូវចេតិយដែលធ្វើដោយផ្កា មានក្លិនដូចជាទិព្វផ្សាយទៅ តថាគតនឹងសម្តែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនេះ លុះច្យុតចាកអត្តភាពនេះទៅ នឹងទៅកើតក្នុងទេវលោក មានពួកទេវតាចោមរោម ជាអ្នកបរិបូណ៌ដោយផ្កាម្លិះ ។ ទីនៅរបស់កុលបុត្តនោះ ដ៏ខ្ពស់ជាវិការនៃមាស និងកែវមណី ប្រាសាទទាំងឡាយ ដែលបុញ្ញកម្មតាក់តែងហើយ នឹងកើត

ប្រាកដ ។ កុលបុត្តនោះ នឹងសោយទេវរាជ្យ នឹងសោយទិព្វ-សម្បត្តិ មានពួកស្ត្រីអប្សរចោមរោម អស់ ៧៤ ជង ។ នឹងបាន សោយរាជសម្បត្តិលើផែនដី គ្រប់គ្រងផែនដី អស់ ៣០០ ជង នឹងបានជាស្តេចចក្កពត្តិអស់ ៧៥ ជង ។ កុលបុត្តនោះ នឹងកើត ជាក្សត្រ ជាអធិបតីនៃមនុស្ស មានទាមថា ទុជ្ជយៈ អាស្រ័យ នូវបុញ្ញកម្មរបស់ខ្លួន ហើយរងនូវផលបុណ្យនោះ ។ កុលបុត្តនោះ នឹងមិនទៅយកកំណើតជាវិនិបាតឡើយ ទៅយកអត្តភាពតែជា មនុស្ស កុលបុត្តនោះ បានសន្សំប្រាក់ទុកច្រើនរាប់រយកោដិ ។ កុលបុត្តនោះ នឹងកើតក្នុងកំណើតជាព្រាហ្មណ៍ ជាអ្នកចេះដឹង មាន ប្រាជ្ញា ជាឱរសជាទីស្រឡាញ់នៃវច្ឆគុត្តព្រាហ្មណ៍ និងនាងសារី-ព្រាហ្មណី ។ លុះកាលជាខាងក្រោយ កុលបុត្តនោះ មានទាម ថា ចូឡបុន្ថុះ នឹងបានបួសក្នុងសាសនារបស់ព្រះសម្ពុទ្ធ ជាអង្គីរស នឹងបានជាសាវ័ករបស់ព្រះសាស្តា ។ ចូឡបុន្ថុះនោះ ជាសាមណេរ មានសន្តានស្ងប់ស្ងាត់ បានជាព្រះខីណាស្រព កំណត់ដឹងនូវ អាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំបានបម្រើព្រះសម្ពុទ្ធ មានព្យាយាមធំផង បម្រើពួកភិក្ខុ អ្នកមានសីលជាទីស្រឡាញ់ដទៃច្រើនអន្លេផង បម្រើព្រះថេរៈជាបង នៃខ្ញុំផង ដើម្បីសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ខ្ញុំបម្រើព្រះថេរៈ ជាបងរបស់ខ្ញុំ រួចហើយ រើសព្រះធាតុដាក់ក្នុងបាត្រ នាំមកថ្វាយ

ព្រះសម្ពុទ្ធ ជាច្បងក្នុងលោក ដ៏ប្រសើរជាងនរៈ ។ ព្រះពុទ្ធ ( ព្រះអង្គប្រសើរ ) ក្នុងលោក ព្រមទាំងទេវលោក ទ្រង់ទទួលដោយព្រះហស្តទាំងពីរ ហើយបង្ហាញនូវព្រះធាតុនោះ ទើបប្រកាស តាំងខ្ញុំជាអគ្គសាវក[១] ។ ឯចិត្តរបស់ខ្ញុំ រួចស្រឡះហើយ សទ្ធារបស់ខ្ញុំតម្កល់ខ្ជាប់ហើយ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចុន្ទត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចុន្ទត្ថេរាបទាន ចប់

## ឧទ្ទាន

ឧបាលិត្ថេរាបទាន ១ សោណកោដិវេស្សត្ថេរាបទាន ១

---

១- គួរប្រែថា ហើយទើបប្រកាសបង្ហាញនូវព្រះធាតុនោះ ថាជាអគ្គសាវក ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

កទ្ទិយកាឡិគោធាយបុត្តត្ថេរាបទាន ១ សន្និដ្ឋាបកត្ថេរា-
បទាន ១ បញ្ចហត្ថិយត្ថេរាបទាន ១ បទុមច្ឆទនិយត្ថេ-
រាបទាន ១ សយនទាយកត្ថេរាបទាន ១ ចង្កមទាយ-
កត្ថេរាបទាន ១ សុភទ្ទត្ថេរាបទាន ១ ចុន្ទត្ថេរាបទាន ១
ក្នុងវគ្គនោះ មានគាថា ១៤៤ ។

ឧបាលិវគ្គទី ៥ ចប់

# អដ្ឋកថា

## ចុន្ទត្ថេរាបទាន

[ ៥២ ] *អបទានរបស់ព្រះចុន្ទត្ថេរ មានពាក្យផ្តើមថា* **សិទ្ធត្ថស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលដែលសម្បូរដោយទ្រព្យសម្បត្តិ ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាស្តា បានសាងវត្ថុដែលមានតម្លៃច្រើនដោយមាស សម្រេចហើយដោយរតនៈ ៧ បិទដោយផ្កាម្លិះ បូជាព្រះមានព្រះភាគ ផ្កាទាំងនោះ បានអណ្តែតឡើងជាពិតានលើអាកាស ។*

*លំដាប់នោះ ព្រះមានព្រះភាគត្រាស់ព្យាករថា ក្នុងអនាគត កុលបុត្តនេះ នឹងបានជាសាវកឈ្មោះចុន្ទ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមគោតម ដោយបុញ្ញកម្មនោះ កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយសុខក្នុងកាមាវចរទេវលោក ៦ ជាន់ តាមលំដាប់ និងសោយចក្រពត្តិសម្បត្តិជាដើម ក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតជាបុត្តរបស់នាងរូបសារី ក្នុងត្រកូលព្រាហ្មណ៍ ជាប្អូនប្រុសរបស់ព្រះសារីបុត្តមហាថេរៈ កាលដល់នូវភាពជាអ្នកដឹងក្តីហើយ ព្រោះមានរូបធំខ្ពស់ស្អាត ( សុន្ទរតាយ ) ដោយផ្លាស់* **ស** *អក្ខរៈ ជា* **ច** *អក្ខរៈ ទើបបានឈ្មោះថា ចុន្ទ ។ កុលបុត្តនោះ ចម្រើនវ័យហើយ ឃើញទោសក្នុងការ*

គ្រប់គ្រងផ្ទះ និងឃើញអានិសង្សក្នុងបព្វជ្ជា បួសក្នុងសម្នាក់របស់ព្រះថេរៈដែលជាបងប្រុស ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។

លោកសម្រេចអរហត្តផលហើយ ថ្ងៃមួយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះជាដើម ។ ពាក្យនោះមានន័យដូចលោកពោលខាងដើមនោះឯង សូម្បីបទថា **អត្ថិយំ** ជាដើម ក៏មានអត្ថងាយយល់ហើយ ។

បទថា **វិតិណ្ណកង្ខោ សម្ពុទ្ធោ** ក្លាប់សេចក្តីថា ទ្រង់ឆ្លងសេចក្តីសង្ស័យបាន គឺជាព្រះសម្មាសម្ពុទ្ធដោយឥតសង្ស័យ ព្រោះទ្រង់ធ្វើសេចក្តីសង្ស័យឲ្យអស់ទៅ ដោយបានសម្រេចមគ្គដ៏ពិសេស ។ បទថា **តិណ្ណោឃេហិ បុរក្ខតោ** សេចក្តីថា ចោមរោម គឺហែហមដោយព្រះខីណាស្រព ដែលឈ្មោះថា មានអន្លង់ឆ្លងផុតហើយ ព្រោះលោកឆ្លង គឺឈានកន្លងឱឃៈ ៤ បានហើយ ។ គាថាព្យាករមានអត្ថងាយយល់ហើយ ។

បទថា **ឧបដ្ឋហឹ មហាវីរំ** សេចក្តីថា ខ្ញុំបានបម្រើ គឺបានទំនុកបម្រុងព្រះពុទ្ធដែលបាននាមថា មហាវីរៈ ទ្រង់ធ្វើសេចក្តីព្យាយាមដោយបំពេញបារមីមក ៤ អសង្ខេយ្យ និង ១ សែនកប្ប ដើម្បីសម្រេចនិព្វាន ដែលជាប្រយោជន៍ដ៏ឧត្តម ។ បទថា **អញ្ញេ ច បេសលេ ពហូ** ក្លាប់សេចក្តីថា ខ្ញុំបម្រើព្រះពុទ្ធតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ខ្ញុំបានបម្រើលោកអ្នកមានសីល និងសាវកពួកដទៃ ដែលសម្រេចធម៌ដ៏ប្រសើរជាច្រើន និងបានបម្រើព្រះសារីបុត្ត

ដែលជាបងប្រុសរបស់ខ្ញុំផងដែរ ។

បទថា **ភាតរំ មេ ឧបដ្ឋហិត្វា** សេចក្ដីថា ខ្ញុំបានបម្រើបងប្រុសរបស់ខ្ញុំ ហើយធ្វើវត្តបដិបត្តិក្នុងកាលដែលបងប្រុសបរិនិព្វាន ព្រោះលោកបរិនិព្វានមុនព្រះមានព្រះភាគ ខ្ញុំបានកាន់យកព្រះធាតុរបស់លោកដាក់ក្នុងបាត្រ ហើយបង្អោនចូលទៅថ្វាយព្រះពុទ្ធជាច្បងនៃបុរសក្នុងលោក ។

បទថា **ឧភោ ហត្ថេហិ បគ្គយ្ហ** សេចក្ដីថា ព្រះមានព្រះភាគអង្គនោះទ្រង់ទទួលយកព្រះធាតុ ដែលខ្ញុំថ្វាយហើយនោះដោយព្រះហស្តទាំងពីររបស់ព្រះអង្គ កាលឲ្យស្គាល់ធាតុនោះដោយល្អ ទើបទ្រង់ប្រកាស គឺប្រារព្ធថាជាព្រះសារីបុត្តត្ថេរអគ្គសាវក ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។l៚

## អដ្ឋកថាចុន្ទត្ថេរាបទាន ចប់

## ឧបាលិវគ្គទី ៥ ចប់

# សុត្តន្តបិដក
# វីជនីវគ្គទី ៦

## វិធូបនទាយកត្ថេរាបទានទី ១

[ ៥៣ ] ខ្ញុំថ្វាយផ្ចិតមួយ ចំពោះព្រះបទុមុត្តរៈ ជាច្បងក្នុងលោក មិនញាប់ញ័រដោយលោកធម៌ ទ្រង់ជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ខ្ញុំញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយផ្គងអញ្ជលីថ្វាយបង្គំព្រះសម្ពុទ្ធ ហើយបែរមុខទៅទិសខាងជើង ដើរចេញទៅ ។ ព្រះសាស្តា ជាអគ្គនាយកក្នុងលោក លុះទ្រង់ទទួលយកផ្ចិតហើយ ក៏ស្ថិតនៅក្នុងភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

ព្រោះការថ្វាយផ្ចិតនេះផង ព្រោះការតម្កល់ចិត្តនេះផង កុលបុត្តនេះ នឹងមិនទៅយកកំណើតជាវិនិបាត អស់មួយសែនកប្ប ។

ខ្ញុំអាយុ ៧ ឆ្នាំ បានប្រារព្ធព្យាយាម បញ្ជូនចិត្តទៅកាន់ព្រះនិព្វាន តម្កល់ខ្ជាប់ក្នុងចេតោគុណ ក៏បានដល់ព្រះអរហត្ត ។ ក្នុងកប្បទី ៦០០០០ ខ្ញុំបានជាស្តេចចក្កពត្តិ ២៦ ដង ព្រះនាមពិជ្ជមានៈដូចៗ គ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤

វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិធូបនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## វិធូបនទាយកត្ថេរាបទាន ចប់

# អដ្ឋកថា
# វីជនិវគ្គទី ៦

## វិធូបនទាយកត្ថេរាបទាន

[ ៥៣ ] *អបទានរបស់ព្រះវិធូបនទាយកត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ សម្បូរដោយទ្រព្យសម្បត្តិ កើតនូវសទ្ធាជ្រះថ្លាក្នុងព្រះមានព្រះភាគ ក្នុងរដូវក្ដៅ បានធ្វើផ្លិតវាលវីជនី ដែលសម្រេចដោយមាស ប្រាក់ កែវមុក្ដា និងកែវមណី ថ្វាយដល់ព្រះមានព្រះភាគ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ ក្នុងកាលដែលព្រះសម្មាសម្ពុទ្ធរបស់យើងទាំងឡាយទ្រង់កើតឡើងហើយ កុលបុត្តនោះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង មានក្រុមគ្រួសារហើយ ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះ និងឃើញអានិសង្សក្នុងបព្វជ្ជា ដល់ព្រមដោយសទ្ធា បួសក្នុងសាសនា ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត ។*

លោករឭកដល់បុព្វកម្មរបស់ខ្លួនថា ព្រោះបុញ្ញកម្មនោះ ទើបអញបាននូវលោកុត្តរសម្បត្តិនេះ ដឹងកម្មនោះដោយប្រចក្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរពុទ្ធស្ស** ដូច្នេះជាដើម ។ ពាក្យនោះ ខ្ញុំអធិប្បាយអត្ថហើយខាងដើមនោះឯង ។ បទថា **ពីជនិកា មយា ទិន្នា** សេចក្តីថា ឈ្មោះថា **វីជនី** ព្រោះអត្ថថា ញុំាងការក្តៅរបស់សត្វដែលក្តៅ ឲ្យរលត់ដោយវិសេស គឺញុំាងខ្យល់ដែលមានភាពត្រជាក់ឲ្យកើត ។ ផ្ចិតនោះ ឈ្មោះថា **ពីជនិកា** ។ ខ្ញុំបានធ្វើផ្ចិតវាលវីជនីនោះ ដែលសម្រេចដោយរតនៈ ៧ មានពន្លឺ ហើយថ្វាយ ។

## អដ្ឋកថាវិធូបនទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សតរំសិយត្ថេរាបទានទី ២

[ ៥៤ ] ព្រះបទុមុត្តរសម្ពុទ្ធ ជាបុរសដ៏ប្រសើរ ទ្រង់ឡើងគង់លើភ្នំ ខ្ញុំជាព្រាហ្មណ៍ដល់ត្រើយនៃមន្ត នៅក្នុងទីជិតភ្នំខ្ពស់នោះ ។ ខ្ញុំផ្គងអញ្ជលី សរសើរព្រះលោកនាយក ជាមហាវីរបុរស ជាទេវតាក្រៃលែងជាងទេវតា ទ្រង់ជានរាសភៈ ដែលស្តេចចូលមកជិត ដោយពាក្យថា ព្រះពុទ្ធនេះ មានព្យាយាមធំ ទ្រង់ប្រកាសធម៌ដ៏ប្រសើរ មានភិក្ខុសង្ឃចោមរោម តែងរុងរឿងដូចគំនរភ្លើង ។ ព្រះសម្ពុទ្ធមានបញ្ញាចក្ខុ ទ្រង់ដូចមហាសមុទ្រ មិនរំភើប ឬដូចអន្លង់ដែលគេឆ្លងបានដោយក្រ ឬក៏ដូចស្តេចម្រឹគដែលមិនតក់ស្លុតតែងសម្តែងធម៌ ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ស្តេចស្ថិតនៅក្នុងភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

កុលបុត្តណា ថ្វាយអញ្ជលីនេះផង សរសើរព្រះពុទ្ធដ៏ប្រសើរផង កុលបុត្តនោះ នឹងសោយទេវរជ្ជសម្បត្តិ អស់ ៣០ ពាន់កប្ប ។ កន្លងទៅមួយសែនកប្ប ព្រះសម្ពុទ្ធជាអង្គីរស មានគ្រឿងប្រក់ គឺកិលេសបើកហើយ នឹងបានត្រាស់ដឹង ( ក្នុងលោក ) ។ កុលបុត្តនោះ បានមកកើតជាបុរសមានទាមថា សតរំសី នឹងជា

ធម្មទាយាទ ជាធម្មនិម្មិត ជាឱរសរបស់ព្រះសម្ពុទ្ធនោះ នឹងបាន ជាព្រះអរហន្ត ។

ខ្ញុំមានអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក បានបួសក្នុង ព្រះពុទ្ធសាសនា មាននាមថា សតរំសី រស្មីរបស់ខ្ញុំ តែងផ្សាយ ចេញ ។ ខ្ញុំត្រេកអរនឹងឈាន ចម្រើនឈាន ក្នុងមណ្ឌល ឬជិត គល់ឈើ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះ សម្មាសម្ពុទ្ធ ។ ខ្ញុំបានជាក្សត្រចក្កពត្តិ ៤ ដង ព្រះនាមរោមៈ ដូចគ្នា បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន អស់ ៦០០០០ កប្ប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះសតរំសិយត្ថេរមានអាយុ បានសម្ដែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សតរំសិយត្ថេរាបទាន ចប់

# អដ្ឋកថា

## សតរំសិយត្ថេរាបទាន

[ ៥៤ ] *អបទានរបស់ព្រះសតរំសិយត្ថេរ មានពាក្យផ្ដើមថា* **ឧច្ចិយំ សេលមារុយ្ហ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ សិក្សាចប់ក្នុងវិជ្ជាសក្កដវេយ្យាករណ៍ និងក្នុងត្រៃវេទ លះនូវការគ្រប់គ្រងផ្ទះ ចូលកាន់ព្រៃ បួសជាឥសី សម្រេចការនៅក្នុងហិមវន្តប្បទេស ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ឡើងកាន់ភ្នំខ្ពស់មួយ ព្រោះទ្រង់ប្រាថ្នាវិវេក ប្រថាប់គង់ដូចគំនរភ្លើងដែលឆេះសន្ធោសន្ធៅ ។ តាបសឃើញព្រះមានព្រះភាគអង្គនោះ ប្រថាប់គង់បែបនោះ កើតនូវសោមនស្ស ផ្គងអញ្ជលីសរសើរដោយហេតុច្រើនយ៉ាង ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ សោយទិព្វសម្បត្តិក្នុងកាមាវចរទេវលោក ៦ ជាន់ បន្ទាប់អំពីនោះមក កើតក្នុងមនុស្សលោក ជាស្ដេចចក្រពត្តិ ព្រះនាមថា សតរំសី ។ លោកសោយសម្បត្តិនោះច្រើនដង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង មានអាយុ ៧ ឆ្នាំ បួសហើយ សម្រេចអរហត្ត ដោយអំណាចបុញ្ញសម្ភារក្នុងកាលមុន ។ លោករឭកថា ព្រោះកម្មអ្វីហ្ន៎ អញមានអាយុ ៧ ឆ្នាំប៉ុណ្ណោះ ក៏សម្រេចសន្តិបទតាមលំដាប់ បានឃើញបុព្វកម្មដោយញាណដោយប្រចក្ស*

កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចឧទ្ទាន ទើបពោលពាក្យថា **ឧច្ចិយំ សេលមារុយ្ហ** ដូច្នេះ ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឧច្ចិយំ** ក្លាប់សេចក្ដីថា ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ឡើងកាន់ភ្នំខ្ពស់ដែលសម្រេចហើយអំពីថ្ម ហើយប្រថាប់គង់ ។ បទថា **បព្វតស្សាវិទូរម្ហិ** សេចក្ដីថា ក្នុងទីមិនឆ្ងាយអំពីភ្នំដែលព្រះមានព្រះភាគប្រថាប់គង់ ។ បទថា **ព្រាហ្មណោ មន្តបារគូ** សេចក្ដីថា ( ខ្ញុំជា ) ព្រាហ្មណ៍ម្នាក់ដល់នូវត្រើយ គឺទីបំផុតនៃវេទ ពោល គឺមន្ត ។ ព្រាហ្មណ៍នេះ អាចដល់ខ្លួនដូចអ្នកដទៃថា ជាអ្នកដល់នូវត្រើយនៃមន្ត ។ បទថា **ឧបវិដ្ឋំ មហាវីរំ** សេចក្ដីថា នូវព្រះជិនស្រី ដែលមានសេចក្ដីព្យាយាមដែលគង់លើភ្នំនោះ ។ មានគុណវិសេសដូចម្ដេចខ្លះ ក្លាប់សេចក្ដីថា ខ្ញុំបានផ្គងអញ្ជលី គឺផ្គុំនូវម្រាម ១០ លើសិរសា សរសើរដោយល្អនូវព្រះមានព្រះភាគ ជាទេវតាក្រៃលែងជាងទេវតា គឺជាទេវតាលើទេវតា គឺទេវតាជាន់កាមាវចរ ៦ ជាន់ និងព្រហ្មទាំងអស់ ឈ្មោះថា **នរាសភ** គឺជាអ្នកអង់អាចជាងនរៈទាំងឡាយដ៏ប្រសើរ ជាលោកនាយក គឺជាអ្នកនាំសត្វលោកទាំងមូល ឲ្យដល់ព្រះនិព្វាន ។

បទថា **អភាសថ** សេចក្ដីថា បានព្យាករថា កុលបុត្តណាថ្វាយអញ្ជលីនេះផង ។បេ។ នឹងបានជាព្រះអរហន្ត ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាសតរំសិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សយនទាយកត្ថេរាបទានទី ៣

[ ៥៥ ] ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនទីព្រះបន្ទំ ដល់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ដែលទ្រង់អនុគ្រោះសព្វសត្វលោក ។ ភោគ-សម្បត្តិ តែងកើតឡើងសម្រាប់ខ្ញុំ ព្រោះការឲ្យនូវទីព្រះបន្ទំនោះ ព្រោះបរិបូណ៌ដោយពូជ ក្នុងស្រែដ៏ល្អនោះ នេះជាផលនៃសយនៈនោះ ។ ខ្ញុំអាចដេក ក្នុងអាកាសបាន ខ្ញុំអាចទ្រទ្រង់ផែនដីនេះបាន ឥស្សរិយយសរបស់ខ្ញុំ ផ្សាយទៅក្នុងពួកសត្វ នេះជាផលនៃសយនៈ ។ ក្នុងកប្បទី ៥ ពាន់ ខ្ញុំបានជាមហា-វីរក្សត្រ ៨ ដង ក្នុងកប្បទី ៣៤០០ ខ្ញុំបានជាក្សត្រ មានកម្លាំងច្រើន ៤ ដង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសយនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សយនទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## សយនទាយកត្ថេរាបទាន

[ ៥៥ ] *អបទានរបស់ព្រះសយនទាយកត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ នៅគ្រប់គ្រងផ្ទះ សោយសុខ ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ជ្រះថ្លាក្នុងព្រះសាស្ដា ឲ្យមនុស្សធ្វើគ្រែដែលមានតម្លៃច្រើន សម្រេចដោយភ្លុក មាស ប្រាក់ កែវមុក្តា និងកែវមណី ក្រាលដោយសំពត់ចីនៈ និងសំពត់រោមសត្វជាដើម ថ្វាយដល់ព្រះមានព្រះភាគដើម្បីទ្រង់ផ្ទំ ព្រះមានព្រះភាគកាលទ្រង់ធ្វើសេចក្ដីអនុគ្រោះដល់កុលបុត្តនោះ ទើបទ្រង់ផ្ទំលើគ្រែនោះ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសុខក្នុងការទៅ និងសុខក្នុងការដេកជាដើមក្នុងអាកាស ដែលគួរបានអំពីបុញ្ញកម្មនោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ដែលសម្បូរដោយទ្រព្យសម្បត្តិ ដល់នូវភាពជាធំហើយ ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា មានចិត្តជ្រះថ្លាបួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរ–**

**ពុទ្ធស្ស** *ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយខាងដើម នោះឯង ។*

*បទថា* **សុខេត្តេ ពីជសម្បទា** *សេចក្ដីថា ពូជដែលបុគ្គលព្រោះក្នុងស្រែល្អ ដែលប្រាសចាកស្មៅ និងសំរាម សម្បូរដោយកក់ជាដើម រមែងញុំាងផលល្អឲ្យសម្រេច យ៉ាងណា ទានដែលបុគ្គលសាបព្រោះក្នុងស្រែបុណ្យដែលមានសន្តានបរិសុទ្ធ ប្រាសចាកស្មៅ និងសំរាម ពោល គឺ កិលេស ១៥០០ មានរាគៈ ទោសៈជាដើម សូម្បីមានប្រមាណតិច ក៏រមែងមានផលស្មើ គឺមានផលច្រើន ក៏យ៉ាងនោះ ។ ពាក្យដ៏សេស មានអត្ថដឹងងាយហើយ ។៚*

## អដ្ឋកថាសយនទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## គណ្ឋោទកទាយកត្ថេរាបទានទី ៤

[ ៥៦ ] កាលគេធ្វើពិធីធ្ងន់មហាពោធិព្រឹក្ស របស់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ខ្ញុំបានយកទឹកក្រអូបមួយក្អមដ៏វិចិត្រហើយ ស្រោចទឹកក្រអូបនោះ លើដើមពោធិនោះ ។ ក្នុងកាលដែល កំពុងតែស្រោចដើមពោធិ មហាមេឃ ក៏បន្លឺរភ្លៀង ផ្គរលាន់ គឹកកងយ៉ាងខ្លាំង ព្រមទាំងរន្ទះបាញ់ ក៏កើតឡើង ។ ខ្ញុំក៏បាន ធ្វើមរណកាល ត្រង់កន្លែងនោះ ដោយកម្លាំងនៃរន្ទះនោះបាញ់ត្រូវ ខ្ញុំបានទៅស្ថិតនៅក្នុងទេវលោក ហើយសម្តែងនូវគាថានេះថា ឱហ្ន៎ ព្រះពុទ្ធ ឱហ្ន៎ ព្រះធម៌ ឱហ្ន៎ សម្បទានៃព្រះសាស្តារបស់ខ្ញុំ ឱ សាកសពរបស់ខ្ញុំ ធ្លាក់ចុះហើយ ខ្ញុំបានមកត្រេកអរក្នុងទេវលោក នេះ ។ ភពជាទីនៅរបស់ខ្ញុំ មានជាន់ ៧ ខ្ពស់ត្រដែតត្រដឹម ពួកនាងកញ្ញាមួយសែន តែងចោមរោមខ្ញុំសព្វៗ កាល ។ ខ្ញុំមិន មានអាពាធ ខ្ញុំមិនមានសោក ខ្ញុំមិនជួបសេចក្តីក្រហល់ក្រហាយ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ២៨០០ ខ្ញុំបានជាស្តេចចក្កពត្តិ គ្រប់គ្រងផែនដី បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធោទកទាយកត្ថេរមានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## គន្ធោទកទាយកត្ថេរាបទាន

[ ៥៦ ] *អបទានរបស់ព្រះគន្ធោទកទាយកត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល កាលព្រះមានព្រះភាគបរិនិព្វានហើយ ឃើញអ្នកស្រុកធ្វើការបូជាពោធិព្រឹក្ស ទើបយកថ្លាំងដ៏វិចិត្រដាក់ទឹកក្រអូបដែលផ្សំអំពីចន្ទន៍ក្រអូប កប្បូរ និងក្លាំពាក់ជាដើមរហូតពេញ ស្រោចពោធិព្រឹក្ស ។ ខណៈនោះ ភ្លៀងធ្លាក់យ៉ាងធំ ក្នុងកាលនោះ កុលបុត្តធ្វើកាលកិរិយាដោយអសនីបាត ( រន្ទះបាញ់ ) ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងទេវលោក ខណៈនៅក្នុងទេវលោកនោះឯង បានពោលគាថាថា* **អហោ ពុទ្ធោ អហោ ធម្មោ** *ដូច្នេះជាដើម កុលបុត្តនោះ សោយសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ ដោយអាការយ៉ាងនេះ ជាអ្នកប្រាសចាកការក្ដៅក្រហាយទាំងពួង ចូលដល់ភាពជាអ្នកត្រជាក់ ជាសុខក្នុងទីដែលខ្លួនកើតហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយផ្ដើមកម្មដ្ឋាន ចម្រើននូវវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តប្រាកដឈ្មោះថា គន្ធោទកទាយកត្ថេរ តាមបុណ្យដែលបានធ្វើមក ។*

*ថ្ងៃមួយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរ-ពុទ្ធស្ស** *ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយ នោះឯង ។ បទថា* **មហាពោធិមហោ អហុ** *សេចក្តីថា មានការបូជាដើមពោធិព្រឹក្សធំហើយ ។ បទថា* **វិចិត្តំ ឃដមាទាយ** *សេចក្តីថា កាន់យកក្អមដែលពេញដោយទឹកក្រអូប ដែលវិចិត្រដោយចិត្តកម្ម និងសុវណ្ណកម្មដ៏ច្រើន ។ បទថា* **គន្ធោទកមទាសហំ** *បានដល់ បានឲ្យទឹកក្រអូប អធិប្បាយថា ខ្ញុំបានស្រោចដោយទឹកក្រអូប ។*

*បទថា* **ន្ហានកាលេ ច ពោធិយា** *សេចក្តីថា ក្នុងសម័យដែលជាទីធ្វើការបូជាដើមពោធិ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថា គន្ធោទកិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឱបវុយ្ហត្ថេរាបទានទី ៥

[ ៥៧ ] ខ្ញុំបានថ្វាយសេះអាជានេយ្យ ដល់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ លុះប្រគល់ចំពោះព្រះសម្ពុទ្ធហើយ ក៏ទៅកាន់ផ្ទះរបស់ខ្លួន ។ ព្រះថេរៈឈ្មោះទេវិលៈ ជាអគ្គសាវករបស់ព្រះសាស្តា ជាធម្មទាយាទដ៏ប្រសើរ បានមកកាន់សម្នាក់របស់ខ្ញុំហើយ ( មានថេរវាចា ) នឹងខ្ញុំថា ព្រះមានព្រះភាគ ព្រះអង្គនាំមកនូវប្រយោជន៍ទាំងពួង ទ្រង់ជាអាជានេយ្យ មិនញាប់ញ័រ ព្រះចក្ខុមសម្ពុទ្ធទ្រង់ទទួលហើយ ព្រោះទ្រង់ជ្រាបនូវតម្រិះរបស់អ្នក ។

ខ្ញុំកាត់ថ្លៃសេះសិន្ធវៈ ជាវាហនៈដ៏លឿន មានសម្ទុះដូចខ្យល់ ជាវាហនៈចេះអត់ធន់ ហើយថ្វាយដល់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ខ្ញុំចូលទៅកាន់កំណើតណាៗ ទោះបីជាទេវតា ឬជាមនុស្ស សេះអាជានេយ្យទាំងឡាយ មានសម្ទុះដូចខ្យល់ ជាសម្បត្តិជាទីត្រេកអរ រមែងកើតសម្រាប់ខ្ញុំ ។ មួយទៀត លាភ កុលបុត្តទាំងឡាយនោះ បានល្អហើយ ព្រោះបាននូវឧបសម្បទា ប្រសិនបើព្រះពុទ្ធកើតមានក្នុងលោក ខ្ញុំសូមចូលទៅអង្គុយជិតព្រះអង្គទៀត ។ ខ្ញុំបានជាស្តេច មានកម្លាំងច្រើន ជាស្តេចឈ្នះសឹកសង្គ្រាម មានសមុទ្ទទាំង ៤ ជាព្រំប្រទល់ ទ្រង់ជាឥស្សរៈ ក្នុងជម្ពូទ្វីប អស់ ២៨ ជន្ម ។ ( ខ្ញុំទ្រទ្រង់ ) នូវរាងកាយនេះ ជាទីបំផុត ភពជាទីបំផុត កំពុងប្រព្រឹត្តទៅ ខ្ញុំលះបង់នូវការឈ្នះ និងការចាញ់

ហើយ បានដល់នូវទីមិនកម្រើក គឺព្រះនិព្វាន ។ ក្នុងកប្បទី ៣៨០០០ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ជាក្សត្រ មានតេជះច្រើន ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឱបវុយ្ហត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឱបវុយ្ហត្ថេរាបទាន ចប់

# អដ្ឋកថា

## ឱបវយ្ហត្ថេរាបទាន

[ ៥៧ ] *អបទានរបស់ព្រះឱបវយ្ហត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរ-ពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ប្រាកដក្នុងលោកហើយ កុលបុត្តនោះកើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិមួយកន្លែង ចម្រើនវ័យហើយ មានទ្រព្យច្រើន មានភោគៈច្រើន នៅគ្រប់គ្រងផ្ទះ ជ្រះថ្លាក្នុងព្រះសាសនា មានការជ្រះថ្លា និងការរាប់អានច្រើនក្នុងព្រះសាស្ដា បានធ្វើការបូជាដោយសេះសិន្ធពអាជានេយ្យ កាលបូជាហើយ គិតថា ដំរី និងសេះជាដើម មិនគួរដល់សមណៈទាំងឡាយ មានព្រះពុទ្ធជាដើម អញនឹងថ្វាយវត្ថុដែលសមគួរដល់សមណៈ ទើបឲ្យវាយតម្លៃសេះនោះ ហើយបានថ្វាយចីវរ ដែលសម្រេចដោយកប្បាស សំពត់កម្ពល និងសំពត់កោជវៈជាដើម និងថ្វាយភេសជ្ជបរិក្ខារ មានកប្បូរ និងតក្កៈជាដើម ដែលសមគួរដោយកហាបណៈដែលមានតម្លៃស្មើនឹងសេះនោះ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ តាំងនៅដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ ទោះជាកើតក្នុងទេវតា និងមនុស្ស ជាអ្នកសម្បូរដោយពាហនៈជាច្រើន មានដំរី និងសេះជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ដល់ព្រមដោយសទ្ធា បួសក្នុងព្រះសាសនា រៀនព្រះកម្មដ្ឋាន*

ចម្រើនវិបស្សនាតាំងនៅក្នុងអរហត្ត តាមលំដាប់នៃមគ្គ លោកប្រាកដឈ្មោះថា ឧបវាឡត្ថេរ តាមបុញ្ញសម្ភារដែលធ្វើក្នុងកាលមុន ។

លោកពិចារណាថា ព្រោះកម្មអ្វីហ្ន៎ ទើបអញបានសម្រេចសន្តិបទនេះ ដឹងនូវបុព្វកម្មយ៉ាងប្រចក្សដោយញាណ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរពុទ្ធស្ស** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយនោះឯង ។ បទថា **អាជានីយមទាសហំ** សេចក្តីថា ខ្ញុំបានបូជាដោយសេះអាជានេយ្យ គឺសេះសិន្ធពដែលមានកំណើតខ្ពស់ ។

បទថា **សបត្តភារោ** សេចក្តីថា បរិក្ខារ ៨ ដែលដល់ខ្លួន ជាភារៈរបស់បុគ្គលណា បុគ្គលនោះឈ្មោះថា មានភារៈដល់ខ្លួន អធិប្បាយថា ជាអ្នកប្រកបដោយបរិក្ខារ ៨ ។

បទថា **ទមនីយមទាសហំ** សេចក្តីថា បរិក្ខារដែលជាកប្បិយៈ មានចីវរជាដើម ដែលសមគួរដល់ការទំនុកបម្រុងអត្តភាព ។ បទថា **ចរិមោ** បានដល់ ភពចុងក្រោយ គឺភពទីបំផុត ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ។៚

**អដ្ឋកថា ឧបវាឡត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សបរិវារាសនត្ថេរាបទានទី ៦

[ ៥៨ ] ខ្ញុំដើរទៅកាន់ទីសៅហ្មង ដែលគេគ្របដោយផ្កាមល្លិកាទាំងឡាយ ហើយបានថ្វាយចង្ហាន់បិណ្ឌបាត ដល់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ព្រះសម្ពុទ្ធអគ្គនាយកក្នុងលោក ទ្រង់មានសន្តានត្រង់ មានព្រះហឫទ័យខ្ជាប់ខ្ជួន ទ្រង់គង់លើអាសនៈនោះ ហើយសម្តែងសរសើរ នូវចង្ហាន់បិណ្ឌបាតថា

ពូជសូម្បីបន្តិច ដែលគេសាបព្រោះហើយ ក្នុងស្រែដ៏ល្អទាំងក្លៀង ក៏បង្ហូរទ-ទឹកដោយស្រួល ផលរមែងញុំាងអ្នកម្ចាស់ស្រែឲ្យត្រេកអរ យ៉ាងណាមិញ ។ ចង្ហាន់បិណ្ឌបាតនេះ ដែលអ្នកតម្កល់ទុកហើយ ក្នុងបុញ្ញក្ខេត្តដ៏ល្អ ផលនឹងធ្វើអ្នកឲ្យត្រេកអរក្នុងភពដែលអ្នកកើត ក៏យ៉ាងនោះដែរ ។

លុះព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ បានត្រាស់នូវពាក្យនេះហើយ ទ្រង់ទទួលចង្ហាន់បិណ្ឌបាត បែរព្រះភក្ត្រឆ្ពោះទៅកាន់ឧត្តរទិស ទ្រង់ចៀសចេញទៅ ។ ខ្ញុំសង្រួមល្អក្នុងបាតិមោក្ខផងក្នុងឥន្ទ្រិយទាំង ៥ ផង ប្រកបរឿយៗ នូវវិវេក ជាអ្នកមិនមានអាសវៈ គឺកិលេសជាគ្រឿងត្រាំក្នុងចិត្ត ។ បដិសម្ភិទា ៤ វិមោក្ខ

៨ និងអភិញ្ញា ៦ នេះ ខ្ញុំ បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសបរិវាសនត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សបរិវាសនត្ថេរាបទាន ចប់

# អដ្ឋកថា

## សបរិវារាសនត្ថេរាបទាន

[ ៥៨ ] *អបទានរបស់ព្រះសបរិវារាសនត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដែលសម្បូរដោយទ្រព្យសម្បត្តិ ចម្រើនវ័យហើយ កើតនូវសទ្ធាជ្រះថ្លាក្នុងព្រះសាសនា ជឿផលនៃទាន បានថ្វាយបិណ្ឌបាតដល់ព្រះមានព្រះភាគ ដោយភោជនមានរសដ៏ប្រសើរផ្សេងៗ កាលថ្វាយហើយ បានប្រដាប់អាសនៈ គឺទីអង្គុយធាន់ត្រង់រោងធាន់ដោយផ្កាម្លិះ និងផ្កាម្លិះរួតជាដើម ព្រះមានព្រះភាគ ទ្រង់បានធ្វើកត្តានុមោទនាហើយ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយនូវសម្បត្តិមានបែបផ្សេងៗ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង សម្បូរដោយទ្រព្យសម្បត្តិ ចម្រើនវ័យហើយ មានសទ្ធា មានសេចក្ដីជ្រះថ្លា បព្វជ្ជាហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ព្រះថេរៈសម្រេចសន្តិបទយ៉ាងនេះហើយ ពិចារណាដោយញាណថា ព្រោះបុណ្យអ្វីហ្ន៎ ទើបអាត្មាអញសម្រេចសន្តិបទនេះ ឃើញនូវបុព្វកម្មហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះជាដើម ។ ពាក្យនេះ មានអត្ថ*

ដូចពោលហើយ ។ បទថា **បិណ្ឌទានំ អទាសហំ** សេចក្ដីថា អាហារឈ្មោះថា បិណ្ឌបាត ព្រោះធ្វើដុំបាយដែលបានអំពីទីផ្សេងៗ ឲ្យជាពំនូតទើបទំពាលេបចូលទៅ គឺបរិភោគ ខ្ញុំបានថ្វាយបិណ្ឌបាតនោះ ដល់ព្រះមានព្រះភាគ អធិប្បាយថា ឲ្យព្រះមានព្រះភាគសោយ ។

បទថា **អកិត្តយិ បិណ្ឌទានំ** សេចក្ដីថា ព្រះអង្គបានប្រកាសគុណានិសង្សនៃបិណ្ឌបាតដែលខ្ញុំថ្វាយហើយ ។

បទថា **សំវុតោ បាតិមោក្ខស្មឹ** សេចក្ដីថា ខ្ញុំជាអ្នកសង្រួមហើយ គឺបិទហើយដោយបាតិមោក្ខសំវរសីល ។ បទថា **ឥន្ទ្រិយេសុ ច បញ្ចសុ** សេចក្ដីថា ខ្ញុំគ្រប់គ្រងហើយចាករូបារម្មណ៍ជាដើមក្នុងឥន្ទ្រិយ ៥ មានចក្ខុន្ទ្រិយជាដើម និងគ្រប់គ្រងនូវឥន្ទ្រិយសំវរសីល ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ។៚

**អដ្ឋកថា សបរិវារាសនត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បញ្ចទីបកត្ថេរាបទានទី ៧

[ ៥៩ ] ខ្ញុំជឿស៊ប់ ក្នុងព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់អនុគ្រោះដល់សព្វសត្វ ទ្រង់មានទិដ្ឋិត្រង់ ។ ខ្ញុំបានថ្វាយប្រទីបជាទាន ព័ទ្ធជុំវិញដើមពោធិព្រឹក្ស កាលខ្ញុំជឿហើយ បានថ្វាយប្រទីបទាំងឡាយ ក្នុងវេលានោះ លុះខ្ញុំទៅកើតក្នុងកំណើតណាៗ ទោះបីជាទេវតា ឬជាមនុស្ស ពួកទេវតាតែងទ្រោលបំភ្លឺគប់ភ្លើងព្រួដ៏អាកាស នេះជាផលនៃការថ្វាយប្រទីប ។ ខ្ញុំបានទទួលនូវទស្សនកិច្ច ( ឃើញរូបទាំងពួង ) ចម្ងាយ ១០០ យោជន៍ ដោយជុំវិញ ឃើញធ្លុះទៅខាងក្រៅជញ្ជាំង ខាងក្រៅផែនថ្ម និងភ្នំបាន ។ ដោយសេសផលនៃកុសលកម្មនោះ ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈ ខ្ញុំទ្រទ្រង់នូវរាងកាយ ជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ជាធំជាងសត្វជើងពីរ ។ ក្នុងកប្បទី ៣៤០០ ខ្ញុំបានជាស្តេចចក្កពត្តិច្រើនជាតិ មាននាមថា សតចក្ខុដូចគ្នា មានតេជះច្រើន ទាំងមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចទីបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បញ្ចទីបកត្ថេរាបទាន ចប់**

# អដ្ឋកថា

## បញ្ចទីបកត្ថេរាបទាន

[ ៥៩ ] អបទានរបស់ព្រះបញ្ចទីបកត្ថេរ មានពាក្យផ្តើមថា **បទុមុត្តរ-ពុទ្ធស្ស** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ ស្តាប់ធម៌របស់ព្រះមានព្រះភាគ តាំងនៅក្នុងសម្មាទិដ្ឋិ មានសទ្ធាជ្រះថ្លា ឃើញមហាជនធ្វើនូវការបូជាពោធិ-ព្រឹក្ស ខ្លួនឯងក៏ព័ទ្ធដើមពោធិ ( ដោយរបង ) អុជប្រទីបបូជាដែរ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិ មានចក្កពត្តិសម្បត្តិជាដើម ក្នុងភពដែលខ្លួនកើត កុលបុត្តនោះ មានពន្លឺក្នុងវិមានជាដើម ដែលផល់ព្រមដោយពន្លឺ ។ ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដែលបរិបូណ៌ដោយទ្រព្យសម្បត្តិ ចម្រើនវ័យហើយ បាននូវសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ប្រាកដឈ្មោះថា ទីបកត្ថេរ ដោយផលបុណ្យដែលបូជាប្រទីប ។

ថ្ងៃមួយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលនឹងប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរពុទ្ធស្ស** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយ

នោះឯង ។ បទថា **ឧជុទិដ្ឋិ អហោសហំ** សេចក្ដីថា ខ្ញុំបានលះបង់នូវភាពវៀច គឺមិច្ឆាទិដ្ឋិ បានជាអ្នកមានសម្មាទិដ្ឋិ ដោយធ្វើទិដ្ឋិឲ្យត្រង់ គឺមិនវៀចបានដល់ ឲ្យបែរមុខចំពោះព្រះនិព្វាន ។

ក្នុងបទថា **បទីបទានំ ទាទាសឹ** មាននិច្ឆ័យថា ឈ្មោះថា ប្រទីប ព្រោះរុងរឿងទូទៅ ការឲ្យប្រទីបនោះ ឈ្មោះថា **បទីបទាន** សេចក្ដីថា ខ្ញុំបានថ្វាយប្រទីបនោះ គឺបានធ្វើការបូជាដោយប្រទីប ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាបញ្ចទីបកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ជជនាយកត្ថេរាបទានទី ៨

[ ៦០ ] ខ្ញុំមានចិត្តរីករាយ បានលើកឡើងនូវទង់ ជិតគល់ពោធិព្រឹក្សដ៏ឧត្តមរបស់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ។ ខ្ញុំរើសស្លឹកពោធិ ដែលជ្រុះមក យកទៅចោលខាងក្រៅខឿន ខ្ញុំបានថ្វាយបង្គំពោធិព្រឹក្សដ៏ប្រសើរ ដូចថ្វាយបង្គំព្រះសម្ពុទ្ធ ចំពោះព្រះភក្ត្រ ទ្រង់ស្អាតខាងក្នុង ស្អាតខាងក្រៅ ទ្រង់មានព្រះហឫទ័យផុតស្រឡះ ទាំងមិនមានអាសវៈ ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់ស្ថិតនៅក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

កុលបុត្តនោះ នឹងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្បដោយផលទាំង ២ យ៉ាង គឺការថ្វាយទង់ និងការបម្រើនេះ ។ កុលបុត្តនោះ នឹងទទួលនូវភាពជាទេវតា មានជោគល្អ ជាច្រើនជាតិរាប់មិនអស់ ក្នុងស្ថានទេវលោក ។ នឹងបានជាស្តេចក្នុងដែនអស់ច្រើនរយជាតិ នឹងបានជាស្តេចចក្កពត្តិ ព្រះនាមឧគ្គតៈ ។ កុលបុត្តនោះ លុះទទួលសម្បត្តិហើយ មានកុសលមូលជាស់តឿន នឹងបានត្រេកអរក្នុងសាសនា របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។

ខ្ញុំមានចិត្តបញ្ជូនទៅកាន់ព្យាយាម មានចិត្តស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស ទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៥១ ពាន់ ខ្ញុំបានជាក្សត្រច្រើនជាតិ ព្រះនាមឧគ្គតៈដូចគ្នា ក្នុងកប្បទី ៥០ ពាន់ ខ្ញុំបានជាក្សត្រប្រមុខសេនាច្រើនជាតិ ព្រះនាមខេមៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធជទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ធជទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ធជទាយកត្ថេរាបទាន

[ ៦០ ] *អបទានរបស់ព្រះធជទាយកត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែងចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាសនា បានធ្វើទង់ដោយសំពត់សាច់ល្អៗ ជាច្រើន គឺបានធ្វើការបូជាដោយទង់ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ កើតក្នុងត្រកូលខ្ពស់ មានអ្នកបូជា ជាបុគ្គលគួរបូជា ក្នុងភពដែលកើត ។ ក្នុងកាលតមក ក្នុងពុទ្ធុប្បាទកាលនេះ កុលបុត្តនោះកើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ចម្រើនដោយបុត្ត និងភរិយា ជាអ្នកមានភោគៈច្រើន មានយស មានសទ្ធាជ្រះថ្លាក្នុងព្រះសាសនា លះនូវការគ្រប់គ្រងផ្ទះ បួសមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*លោកបានសម្រេចអរហត្តផលហើយ រឭកដល់បុព្វកម្មហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះជាដើម ។ សេចក្តីនៃពាក្យនោះ មានអត្ថដូចពោលក្នុងកាលមុននោះឯង ។ បទថា* **ហដ្ឋោ ហដ្ឋេន ចិត្តេន** *សេចក្តីថា ឈ្មោះថា* **ហដ្ឋោ** *គឺជាអ្នកមានកាយបរិបូណ៌ ព្រោះប្រកបដោយចិត្តដែល*

កើតព្រមដោយសោមនស្ស ឈ្មោះថា **ហដ្ឋេន** គឺមានចិត្តរីករាយ ព្រោះមានចិត្តប្រកបដោយសទ្ធា ។ បទថា **ធជមារោបយឹ អហំ** សេចក្តីថា ឈ្មោះថា **ធជ** ព្រោះអត្ថថា រលាស់ គឺកម្រើក បានដល់ ញ៉ុរ ។ ខ្ញុំបានលើកទង់នោះឡើងពាក់ត្រង់ចុងឫស្សី ហើយបូជា ។

បទថា **បតិតបត្តានិ គណ្ហិត្វា** សេចក្តីថា ខ្ញុំកាន់យកស្លឹកពោធិដែលជ្រុះហើយ ទៅចោលខាងក្រៅ ។ បទថា **អន្តោសុទ្ធំ ពហិសុទ្ធំ** សេចក្តីថា ខ្ញុំបានថ្វាយបង្គំ គឺបានធ្វើការនមស្ការដើមពោធិដ៏ឧត្តម ក្នុងទីចំពោះមុខ ដូចចំពោះព្រះភក្ត្រព្រះសម្ពុទ្ធ ជាអ្នកបរិសុទ្ធខាងក្នុង គឺចិត្តសន្តាន និងនាមកាយ និងខាងក្រៅ គឺរូបកាយ មានចក្ខុបសាទ និងសោតបសាទជាដើម ដែលរួចផុតវិសេសក្រៃលែង គឺរួចផុតចាកកិលេសដែលមិនមានអាសវៈ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា ធជទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បទុមត្ថេរាបទានទី ៩

[ ៦១ ] ព្រះបទុមុត្តរសម្ពុទ្ធ កំពុងទ្រង់ប្រកាសសច្ចៈ ៤ ញ៉ាំងធម៌ដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ទ្រង់បង្អុរនូវភ្លៀង គឺអមតៈ ញ៉ាំងមហាជនឲ្យរលត់ទុក្ខ ។ ខ្ញុំកាន់យកផ្កាឈូក ព្រមទាំងទង ស្ថិតនៅក្នុងទីកន្លះកោសៈ មានចិត្តរីករាយ ចំពោះព្រះមុនី ព្រះនាមបទុមុត្តរៈ ហើយព្រោច ( ផ្កាឈូក ) ឰដ៏អាកាស ។ កាលដែលផ្កាឈូកអណ្តែតមក មានសេចក្តីអស្ចារ្យ ក្នុងខណៈនោះ ព្រះពុទ្ធប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំហើយ ទ្រង់ទទួល ។ ព្រះសាស្តា ទ្រង់ទទួលយកជលជាតជាផ្កាដ៏ឧត្តម ដោយព្រះហស្តដ៏ប្រសើរ ទ្រង់ស្ថិតនៅក្នុងភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា

កុលបុត្តណា ព្រោចផ្កាឈូកនេះ ថ្វាយព្រះសព្វញ្ញូ ជានាយកប្រសើរ តថាគតនឹងសម្តែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្តនេះ នឹងបានជាធំជាងទេវតា សោយទេវរជ្ជសម្បត្តិ អស់ ៣០ កប្ប នឹងសោយប្រឹថពីរជ្ជសម្បត្តិ គ្រប់គ្រងផែនដី អស់ ៧០០ កប្ប ។ នឹងបានជាស្តេចចក្រពត្តិ គ្រប់គ្រងសត្វក្នុងភពនោះ ភ្លៀងផ្កានឹងបង្អុរចុះអំពីអាកាស ក្នុងកាលនោះ ។ កន្លងទៅមួយសែនកប្ប ព្រះបរមសាស្តា ព្រះនាមគោតម កើតក្នុងត្រកូលក្សត្រឱក្កាកៈ

នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្តនោះ នឹងកើតជាឱរស ជាធម្មទាយាទ ជាធម្មនិម្មិតរបស់ព្រះគោតមនោះ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំប្រសូតចេញអំពីផ្ទៃនៃមាតា ជាអ្នកមានសម្បជញ្ញៈ មានសតិ លុះដល់ខ្ញុំអាយុ ៥ ឆ្នាំ បានសម្រេចព្រះអរហត្ត ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## បទុមត្ថេរាបទាន ចប់

# អដ្ឋកថា

## បទុមត្ថេរាបទាន

[ ៦១ ] *អបទានរបស់ព្រះបទុមត្ថេរ មានពាក្យផ្តើមថា* **ចតុសច្ចំ បកាសេន្តោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ កាលព្រះបទុមុត្តរមុនី ធ្វើនូវកាពុរងរឿងនៃព្រះសទ្ធម្មឲ្យភ្លឺស្វាង កើតក្នុងផ្ទះនៃត្រកូលមួយកន្លែង តាំងនៅក្នុងការគ្រប់គ្រងផ្ទះ ប្រាកដថា ជាអ្នកដល់ព្រមដោយភោគទ្រព្យ កុលបុត្តនោះជ្រះថ្លាក្នុងព្រះសាស្តា បានឈរកាន់ផ្កាឈូក មួយអន្ទើដោយទង ស្តាប់ធម៌ជាមួយមហាជន ។ បាច់ផ្កាឈូកនោះមួយអន្ទើដោយទង បានអណ្តែតឡើងទៅលើអាកាស កុលបុត្តនោះ ឃើញអស្ចារ្យនោះ ទើបកើតសោមនស្សយ៉ាងក្រៃលែង ។ កុលបុត្តនោះ បំពេញកុសលជរាបដល់អស់ជីវិត ក្នុងទីបំផុតនៃជីវិត កើតក្នុងស្ថានសួគ៌ បានប្រាកដ និងបានទទួលការបូជាដូចទង សោយនូវទិព្វសម្បត្តិ ក្នុងឆកាមាវចរសួគ៌ និងសោយចក្កពត្តិសម្បត្តិក្នុងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង សម្បូរដោយសម្បត្តិ ដល់ព្រមដោយសទ្ធា ចម្រើនវ័យហើយ កើតនូវសទ្ធា បានបព្វជ្ជាក្នុងកាលអាយុ ៥ ឆ្នាំ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ប្រាកដនាមថា បទុមត្ថេរ តាមឈ្មោះបុណ្យដែលធ្វើមកហើយ ។*

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ចតុសច្ចំ បកាសេន្តោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **សច្ចំ** សេចក្ដីថា ដែលឈ្មោះថា **សច្ច** ព្រោះពិត មិនខុស មិនឃ្លៀងឃ្លាត ដែលឈ្មោះថា **ចតុសច្ច** ព្រោះរួមហើយ មាន ៤ ប្រការ គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច និងមគ្គសច្ច កំពុងប្រកាស គឺទ្រង់កំពុងធ្វើសច្ចៈ ៤ នោះ ឲ្យប្រាកដក្នុងលោក ។ បទថា **វរធម្មប្បវត្តកោ** សេចក្ដីថា ញ៉ាំងធម៌ដ៏ឧត្ដមឲ្យប្រព្រឹត្តទៅ គឺប្រកាស ។ បទថា **អមតំ វុដ្ឋឹ** សេចក្ដីថា ទ្រង់ញ៉ាំងផ្គរភ្លៀង គឺអមតមហានិព្វានឲ្យធ្លាក់ គឺហូរចុះ ញ៉ាំងលោកនេះ ព្រមទាំងទេវលោក ឲ្យសើមត្រជាក់ គឺញ៉ាំងកម្ដៅ គឺកិលេសទាំងពួងឲ្យរលត់ ឈ្មោះថា ញ៉ាំងភ្លៀង គឺធម៌ឲ្យធ្លាក់ចុះ ។

បទថា **សធជំ បទុមំ គយ្ហ** សេចក្ដីថា គឺកាន់ផ្កាឈូក គឺបាច់ផ្កាបទុមរួមចូលជាមួយទង់ ។ បទថា **អឌ្ឍកោសេ ឋិតោ អហំ** សេចក្ដីថា បានឈរកាន់ផ្កាឈូក និងទង់ពីរយ៉ោជន៍ទុក ។ ពាក្យដ៏សេស ក្នុងទីទាំងពួងមានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា បទុមត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អសនពោធិយត្ថេរាបទានទី ១០

[ ៦២ ] ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត បានឃើញព្រះលោកនាយក ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ហើយចូលទៅគាល់ព្រះសម្ពុទ្ធ ជាបុគ្គលប្រសើរជាងពួកនរៈ ។ ខ្ញុំជាអ្នកមានចិត្តរីករាយ បានដាំ ( ដើមធ្នង់ ) ជាពោធិព្រឹក្សដ៏ឧត្តម ថ្វាយព្រះមានព្រះភាគព្រះនាមតិស្សៈ ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ លុះដើមធ្នង់នោះ ដុះឡើងផុតអំពីផែនដី ខ្ញុំក៏បានថែទាំដើមធ្នង់ ជាពោធិដ៏ឧត្តមនោះអស់ ៥ ឆ្នាំ ។ ខ្ញុំបានឃើញដើមធ្នង់ មានផ្កាល្អចម្លែក គួរព្រឺរោមហើយ ក៏ប្រកាសនូវកម្មរបស់ខ្លួន ទើបចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ គ្រានោះឯង ព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជាសយម្ភូអគ្គបុគ្គលនោះ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយទ្រង់សម្តែងនូវគាថាទាំងនេះថា

កុលបុត្តណា ដាំដើមឈើជាពោធិព្រឹក្សនេះផង ធ្វើពុទ្ធបូជាដោយគោរពផង តថាគតនឹងសម្តែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្តនោះ នឹងបាននូវទេវសម្បត្តិ ក្នុងទេវលោក អស់ ៣០ កប្ប នឹងបានជាស្តេចចក្កពត្តិ អស់ ៦៤ ដង ។ លុះច្យុតចាកតុសិតទេវលោក មានកុសលមូលជាស់តឿន នឹងបាននូវសម្បត្តិទាំងពីរ ហើយនឹងត្រេកអរក្នុងអត្តភាពជាមនុស្ស ។ កុលបុត្តនោះ មានចិត្តបញ្ជូន

ទៅកាន់ព្យាយាម មានចិត្តស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិ-និព្វាន ។

ខ្ញុំប្រកបរឿយៗ ក្នុងទីស្ងាត់ មានចិត្តស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស ជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ផ្តាច់នូវទន្ទឹង ។ ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំដាំដើមពោធិ ( ថ្វាយព្រះសម្ពុទ្ធព្រះនាមតិស្សៈ ) ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការដាំដើមពោធិ ។ ក្នុងកប្បទី ៧៤ អំពីភទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ មានព្រះនាមប្រាកដថាទណ្ឌសេនៈ ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ប្រការ ក្នុងកាលនោះ ។ ក្នុងកប្បទី ៧៣ អំពីភទ្ទកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិជាធំលើផែនដី ៧ ដង មានព្រះនាមថាសមន្តនេមិដូចគ្នា ។ ក្នុងកប្បទី ២០ គត់ អំពីភទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិមួយព្រះអង្គ ទ្រង់ព្រះនាមបុណ្ណកៈ បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអសនពោធិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ឧទ្ទាន

វិធូបនទាយកត្ថេរាបទាន ១ សតរំសិយត្ថេរាបទាន ១ សយនទាយកត្ថេរាបទាន ១ គន្ធោទកទាយកត្ថេរាបទាន ១ ឱបវុយ្ហត្ថេរាបទាន ១ បរិវារកសនត្ថេរាបទាន ១ បញ្ចទីបកត្ថេរាបទាន ១ ធជទាយកត្ថេរាបទាន ១ បទុមបូជកត្ថេរាបទាន ១ អសនពោធិយត្ថេរាបទាន ១ ជាគម្រប់ ១០ ឯគាថាមាន ៩២ ដែលលោកពោលទុកហើយ ។

### វីជនីវគ្គទី ៦ ចប់

# អដ្ឋកថា

## អសនពោធិយត្ថេរាបទាន

[ ៦២ ] *អបទានរបស់ព្រះអសនពោធិយត្ថេរ មានពាក្យផ្ដើមថា* **ជាតិយា សត្តវស្សោហំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ មានសេចក្ដីសុខ ជ្រះថ្លាក្នុងព្រះសាសនា កាន់យកផ្លែអំពីដើមធ្នង់ដែលជាឈើត្រាស់ដឹងទៅបណ្ដុះ ហើយនាំដើមខ្ចីដែលដុះអំពីគ្រាប់ ទៅដាំជាដើមពោធិព្រឹក្ស ។ កុលបុត្តនោះ រក្សាបូជាដោយកម្ម មានការស្រោចទឹកជាដើម មិនឲ្យស្លាប់ ។ ដោយបុណ្យនោះ កុលបុត្តនោះសោយសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ព្រោះលោកមានបុញ្ញសម្ភារចាស់ក្លា អាយុបាន ៧ ឆ្នាំ បព្វជ្ជាហើយ បានសម្រេចអរហត្តខណៈកោរសក់នោះឯង ។ លោកប្រាកដដោយឈ្មោះថា អសនពោធិយត្ថេរ តាមឈ្មោះបុណ្យដែលបានបំពេញហើយក្នុងកាលមុន ។ លោករឭកដល់បុញ្ញសម្ភារក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **ជាតិយា សត្តវស្សោហំ** *ដូច្នេះជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **ជាតិយា** *សេចក្ដីថា ចាប់តាំងពីកាលដែលខ្ញុំចេញចាកផ្ទៃមាតា ភ្ជាប់សេចក្ដីថា ខ្ញុំមានអាយុ ៧ ឆ្នាំ គ្រប់សរទរដូវ*

៧ ឆ្នាំ បានឃើញព្រះមានព្រះភាគព្រះនាមតិស្សៈ ជាលោកនាយក ។ បទថា **បសន្នចិត្តោ សុមនោ** សេចក្តីថា ជាអ្នកមានចិត្តផូរផង់មិនល្អក់ មិនញាប់ញ័រដោយសភាវៈណាមួយ អធិប្បាយថា ជាអ្នកមានចិត្តល្អ មានចិត្តស្អាត បានដល់ ជាអ្នកមានចិត្តប្រកបដោយសោមនស្ស ។

បទថា **តិស្សស្សាហំ ភគវតោ** សេចក្តីថា ឈ្មោះថា តិស្សៈ ព្រោះកើត ៣ ដង គឺកើតជាមនុស្សជាតិអំពីផ្ទៃមាតា ១ កើតដោយផុតចាកបញ្ចក្ខន្ធ ១ កើតជាព្រះពុទ្ធ ១ ភ្ជាប់សេចក្តីថា ខ្ញុំដាំដើមអសនពោធិដ៏ឧត្តមដើម្បីព្រះមានព្រះភាគព្រះនាមតិស្សៈនោះ ជាតាទិបុគ្គល ជាលោកជេដ្ឋ ។

បទថា **អសនោ ឆាមដេយ្យេន** សេចក្តីថា ដើមពោធិ ឈ្មោះថា **អសន** បានជាដើមពោធិដោយនាមបញ្ញត្តិ គឺដោយសន្មត ។ បទថា **ធរណីរុហបាទបោ** សេចក្តីថា ឈ្មោះថា **ធរណី** ព្រោះទ្រទ្រង់នូវវល្លិ ដើមឈើ ភ្នំ ស្មៅ និងសមុទ្ទជាដើម ធរណីនោះ គឺអ្វី គឺផែនដី ។ ឈ្មោះថា **ធរណីរុហា** ព្រោះដុះឡើង គឺតាំងនៅលើផែនដីនោះ ។ ឈ្មោះថា **បាទបោ** ព្រោះផឹកដោយជើង អធិប្បាយថា ផឹកទឹកដែលស្រោចតាមឫស ពោលគឺជើង គឺទទួលរសអាបោធាតុដែលសើម ។ ដើមឈើនោះផង ដុះលើផែនដីផង ព្រោះហេតុនោះ ទើបឈ្មោះថា **ធរណីរុហបាទប** ។ ខ្ញុំបានបម្រើ

គឺបានដាំដើមធ្នង់ដែលជាឈើគ្រាស់ដ៏ឧត្តម ៥ ឆ្នាំ ។ បទថា **បុប្ផិតំ ចាគបំ ធិស្វា** សេចក្តីថា ឃើញដើមឈើគ្រាស់ដឹង គឺដើមធ្នង់ដែលខ្ញុំដាំនោះរីកហើយ ជាទីគួរអស្ចារ្យ គឺធ្វើឲ្យកើតព្រឺរោមព្រឺស្បែក ព្រោះមានផ្កាដែលគួរអស្ចារ្យ កាលប្រារព្ធកម្ម គឺកាលក្រាបទូលឲ្យទ្រង់ជ្រាបការធ្វើរបស់ខ្លួន ទើបទៅកាន់សម្នាក់របស់ព្រះពុទ្ធដ៏ប្រសើរ ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថា អសនពោធិយត្ថេរាបទាន ចប់**

**វិជនីវគ្គទី ៦ ចប់**

# សុត្តន្តបិដក

# សកចិត្តនិយវគ្គទី ៧

## សកចិត្តនិយត្ថេរាបទានទី ១

[ ៦៣ ] ខ្ញុំបានឃើញព្រៃផ្សៃ មិនមានសូរសព្ទ ជាទីមិនល្អក់ចិត្ត គួរទទួលនូវគ្រឿងបូជា ដែលពួកឥសីធ្លាប់សន្សំហើយ ។ ខ្ញុំរោយផ្កាផ្សេងៗ ឲ្យជាគំនរ ធ្វើជាព្រះស្តូបហើយ ថ្វាយបង្គំព្រះស្តូបដែលខ្ញុំកសាងនោះ ហាក់ដូចជាថ្វាយបង្គំព្រះសម្ពុទ្ធ គង់ក្នុងទីចំពោះមុខ ។ ខ្ញុំបានជាស្តេចជាធំក្នុងដែន បរិបូណ៌ដោយរតនៈ ៧ ប្រការ ប្រារព្ធនូវកម្មរបស់ខ្លួន នេះជាផលនៃការបូជា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨០ ខ្ញុំបានជាស្តេចចក្កពត្តិ ព្រះនាមអនន្តយស ជាអ្នកបរិបូណ៌ដោយរតនៈ ៧ ប្រការ ជាស្តេចធំក្នុងទ្វីបទាំង ៤ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសកចិត្តនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*សកចិត្តនិយត្ថេរាបទាន ចប់*

# អដ្ឋកថា
# សកចិន្តនិយវគ្គទី ៧

## សកចិន្តនិយត្ថេរាបទាន

[ ៦៣ ] អបទានរបស់ព្រះសកចិន្តនិយត្ថេរ មានពាក្យផ្តើមថា **បវនំ កាននំ ទិស្វា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមវិបស្សី កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ កើតឡើងក្នុងកាលអស់ព្រះជន្មាយុរបស់ព្រះមានព្រះភាគអង្គនោះ មិនទាន់បានចូលគាល់ព្រះមានព្រះភាគក្នុងកាលទ្រង់គង់ព្រះជន្មនៅ ។ កាលព្រះសាស្តាបរិនិព្វានហើយ បានបួសជាឥសី ក្នុងហិមវន្តប្បទេស ដល់ព្រៃមួយកន្លែង ដែលជាទីស្ងាត់ គួរជាទីត្រេកអរ ពូនចេតិយខ្សាច់ត្រង់ញកភ្នំមួយកន្លែង ដាក់ចិត្តដូចក្នុងព្រះមានព្រះភាគ យកចិត្តទុកដាក់ដូចជាតុរបស់ព្រះអង្គ បូជាដោយផ្កាក្នុងព្រៃ ប្រតិបត្តិនមស្ការ ។ ដោយបុញ្ញកម្មនោះ ទើបលោកត្រាច់ទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសគ្គសម្បត្តិ និងចក្កពត្តិសម្បត្តិដ៏ប្រសើរក្នុងភពពីរ ក្នុង

ពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង សម្បូរដោយទ្រព្យសម្បត្តិ ដល់ព្រមដោយសទ្ធាជ្រះថ្លាក្នុងព្រះសាស្តា បួសបានជាព្រះអរហន្តជាអ្នកមានអភិញ្ញា ៦ ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បវនំ កាននំ និស្សា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បវនំ** សេចក្តីថា ឈ្មោះថា **បវន** ព្រោះអត្ថថា ជាព្រៃទូទៅ ជាព្រៃធំទូលាយ ជាព្រៃស្តុក ។ ឈ្មោះថា **កានន** ព្រោះអត្ថថា ជាព្រៃជ្រៅ ព្រៃក្រាស់ កុះករដោយសត្វសាហាវ មានសីហៈ ខ្លាធំ យក្ស អារក្សទឹក ដំរីកាច សេះកាច គ្រុឌ និងពស់ ឬច្រើនដោយសំឡេងនៃពួកបក្សី មានមាន់ តាវ៉ៅជានិច្ច ជាព្រៃធំ ពោល គឺព្រៃនោះ ស្ងាត់សំឡេង គឺមិនមានសំឡេង ព្រោះវៀរចាកសំឡេងមនុស្ស ។ បទថា **អជ្ឈោគាហិលំ** បាន ដល់ មិនល្អក់ អធិប្បាយថា ប្រាសចាកអន្តរាយ ។ បទថា **ឥសីនំ អនុចិណ្ណំ** សេចក្តីថា ដែលឥសីទាំងឡាយ ពោល គឺព្រះពុទ្ធ ព្រះបច្ចេកសម្ពុទ្ធ និងព្រះអរហន្តខីណាស្រពសេពគប់រឿយៗ គឺប្រើប្រាស់ជានិច្ច ។ បទថា **អាហុតីនំ បដិគ្គហំ** សេចក្តីថា គ្រឿងបូជា និងគ្រឿងសក្ការៈ លោកហៅថា **អាហុន** បានដល់ វត្ថុសម្រាប់ទទួល ដូចជាផ្ទះ ។

*បទថា* **ថូបំ កត្វាន វេឡុជា** *សេចក្តីថា ធ្វើចេតិយដោយចម្រៀកឫស្សី ។ បទថា* **នានាបុប្ផំ សមោកិរឹ** *សេចក្តីថា ខ្ញុំរោយ គឺបូជាដោយផ្កាជាច្រើន មានផ្កាចម្ប៉ាជាដើម ។ បទថា* **សម្មុក្ខា វិយ សម្ពុទ្ធំ** *សេចក្តីថា ខ្ញុំបានថ្វាយបង្គំ គឺធ្វើនមស្ការនូវព្រះចេតិយដែលសាងឡើង គឺឲ្យកើតឡើងដូចនៅចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ដែលទ្រង់គង់ព្រះជន្មនៅដោយវិសេសក្រៃលែង ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ។*

**អដ្ឋកថា សកចិន្តនិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អាចោបុប្ផិយត្ថេរាបទានទី ២

[ ៦៤ ] កាលព្រះសិខីសម្ពុទ្ធ ទ្រង់ចេញអំពីវត្ត ស្តេចទៅសណ្ឋិតក្នុងទីចង្ក្រម ទ្រង់ប្រកាសនូវសច្ចៈ ៤ សំដែងនូវផ្លូវនៃអមតៈ ។ ខ្ញុំដឹងច្បាស់នូវព្រះវាចារបស់ព្រះពុទ្ធ ព្រះនាមសិខីជាបុគ្គលប្រសើរ មានព្រះហឫទ័យនឹងធឹងហើយ ក៏បេះយកផ្កាផ្សេងៗ បាចសាចទៅនាអាកាស ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាចម្បងក្នុងលោក ប្រសើរជាងពួកជន ខ្ញុំលះបង់នូវការឈ្នះ និងការចាញ់ ហើយដល់នូវទីមិនកម្រើក គឺនិព្វានដោយសារបុញ្ញកម្មនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការបូជាផ្កា ។

ក្នុងកប្បទី ២០ អំពីកប្បនេះ ខ្ញុំបានកើតជាមហាក្សត្រចក្កពត្តិព្រះនាមសុមេធៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអាបោបុប្ផិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អាបោបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## អាកាសុក្ខិយត្ថេរាបទាន

[ ៦៤ ] អបទានរបស់ព្រះអាកាសុក្ខិយត្ថេរ មានពាក្យផ្ដើមថា **វិបាកា អភិនិក្ខមា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ដល់ព្រមដោយសទ្ធា ស្ដាប់ព្រះធម៌ កើតនូវការជ្រះថ្លា កាន់យកផ្កាដោយដៃទាំងពីរ បាចទៅខាងលើព្រះសម្មាសម្ពុទ្ធ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសគ្គសម្បត្តិ និងចក្កពត្តិសម្បត្តិ បានទទួលការបូជាក្នុងទីគ្រប់ស្ថាន ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាសនា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ ឈ្មោះថា **អាកាស** ព្រោះអត្ថថា រុងរឿង គឺភ្លឺដោយជុំវិញ ។ ព្រះថេរៈប្រាកដនាមថា អាកាសុក្ខិយត្ថេរ ព្រោះលោកបានរោយផ្កាលើអាកាសនោះ ។

លោកសម្រេចសន្តិបទយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វិបាកា អភិនិក្ខមា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **វិហារា** សេចក្ដីថា ឈ្មោះថា **វិហារ** ព្រោះជាទីនាំមកដោយវិសេស គឺជាទីនាំទៅ បានដល់ រក្សាអត្តភាពដែលនឿយហត់ ដោយឥរិយាបថ ៤ ។ ចេញអំពីវិហារនោះ ដោយវិសេសក្រៃលែង ។ បទថា **អព្ភុដ្ឋាសិ ច ចង្កមេ** សេចក្ដីថា បានឈរ គឺឡើងទៅក្នុងទីចង្ក្រម ដើម្បីចង្ក្រមដោយពិសេស ។ បទថា **ចតុសច្ចំ បកាសេន្តោ** ក្អាប់សេចក្ដីថា កាលទ្រង់ចង្ក្រមក្នុងទីចង្ក្រមនោះ ទ្រង់ប្រកាសសច្ចៈ ៤ ពោល គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច និងមគ្គសច្ច គឺធ្វើឲ្យប្រាកដ បានដល់ សម្ដែង បែក ធ្វើឲ្យរាក់នូវអមតបទ គឺព្រះនិព្វាន ។

បទថា **សិខិស្ស គិរមញ្ញាយ ពុទ្ធសេដ្ឋស្ស តាទិនោ** សេចក្ដីថា ដឹង គឺជ្រាបពាក្យដែលគប្បីបន្ទឺ គឺសំឡេងប្រកាសរបស់ព្រះពុទ្ធ ព្រះនាមសិខី ជាបុគ្គលប្រសើរ គឺប្រកបដោយគុណ គឺការមិនញាប់ញ័រ ។ បទថា **នានា-បុប្ផំ គហេត្វាន** សេចក្ដីថា កាន់យកផ្កាច្រើនយ៉ាង មានផ្កាបុសនាគ ដ៏ប្រសើរជាដើម ។ បទថា **អាកាសម្ហិ សមោកិរឹ** សេចក្ដីថា ខ្ញុំបានបាចផ្កា បូជាក្នុងអាកាសលើសិរសាព្រះមានព្រះភាគ ដែលកំពុងចង្ក្រម ។

បទថា **តេន កម្មេន ទ្វិបទិន្ទ** សេចក្ដីថា បពិត្រព្រះអង្គ ជាកំពូល គឺជាប្រធាននៃសត្វជើងពីរ គឺទេវតា ព្រហ្ម និងមនុស្ស បពិត្រព្រះអង្គ ទ្រង់អង់អាចជាងនរៈ គឺទ្រង់ប្រសើរជាងនរជន ។ បទថា **បត្តោម្හි អចលំ ឋានំ**

*សេចក្តីថា ខ្ញុំបួសក្នុងសម្នាក់ព្រះអង្គ សម្រេចឋានៈដែលមិនញាប់ញ័រ គឺព្រះនិព្វាន ។ បទថា* **ហិត្វា ជយបរាជយំ** *សេចក្តីថា ខ្ញុំព្រះអង្គលះ គឺបោះបង់ជ័យជម្នះ ពោល គឺ ទិព្វសម្បត្តិ និងមនុស្សសម្បត្តិ និងការចាញ់ ពោល គឺទុក្ខក្នុងអបាយ ៤ សម្រេចនិព្វាន ។ ពាក្យដ៏សេស មានអត្ថដ៏ងាយហើយ ៕*

## អដ្ឋកថា អាទោបុប្ផិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បច្ចាគមនិយត្ថេរាបទានទី ៣

[ ៦៥ ] កាលនោះ ខ្ញុំជាបក្សីចាក្រពាក នៅនាឆ្នេរស្ទឹងសិន្ធុ ខ្ញុំមានសារាយសុទ្ធ ជាអាហារផង ខ្ញុំសង្រួមល្អក្នុងសត្វទាំងឡាយផង ។ ខ្ញុំបានឃើញព្រះពុទ្ធ ជាបុគ្គលប្រាសចាកធូលី គឺកិលេស កំពុងនិមន្តទៅឰដ៏អាកាស ខ្ញុំពាំនូវផ្កាវាំងដោយចំពុះ បង្អោនមកថ្វាយព្រះពុទ្ធ ព្រះនាមវិបស្សី ។ សទ្ធាមិនញាប់ញ័រ ដែលបុគ្គលណាតម្កល់ល្អហើយ ចំពោះព្រះតថាគត បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ ដោយសេចក្ដីជ្រះថ្លានៃចិត្តនោះ ។

ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធ ព្រះអង្គជាបុគ្គលប្រសើរ ឱ ! ពូជដ៏ល្អ គឺបុណ្យ ខ្ញុំជាបក្សីបណ្ដុះទុកល្អហើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ៨ ដង មានព្រះនាមដូចគ្នា គឺព្រះនាមថាសុចារុទស្សនៈ ជាស្ដេចចក្កពត្តិ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបច្ចាគមនិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បច្ចាគមនិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បច្ចាគមនិយត្ថេរាបទាន

[ ៦៥ ] អបទានរបស់ព្រះបច្ចាគមនិយត្ថេរ មានពាក្យផ្ដើមថា **សិន្ធុយា នទិយា តីរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងកំណើតសត្វចាក្រពាក ក្បែរឆ្នេរស្ទឹងសិន្ធុ មិនស៊ីសត្វមានជីវិត ស៊ីតែសារាយព្រោះមានបុញ្ញសម្ភារមកអំពីមុន ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមថាវិបស្សី កាលទ្រង់ធ្វើអនុគ្រោះដល់សត្វ បានយាងទៅក្នុងទីនោះ ។ ខណៈនោះ សត្វចាក្រពាកនោះ ឃើញព្រះមានព្រះភាគរុងរឿង មានចិត្តជ្រះថ្លា ទើបយកចំពុះចឹកផ្ការាំងអំពីដើមរាំង នាំមកបូជា ។ ដោយសេចក្ដីជ្រះថ្លានៃចិត្តនោះឯង ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយសម្បត្តិក្នុងឆកាមាវចរស្ួគ៌ទៅមក ចុតិចាកអត្តភាពនោះហើយ កើតក្នុងមនុស្សលោកសោយសម្បត្តិ មានចក្កពត្តិសម្បត្តិជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកហើយ ជ្រះថ្លាក្នុងព្រះសាស្ដាបួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត លោកប្រាកដនាមថាបច្ចាគមនិយត្ថេរ តាមបុណ្យក្នុងកាលមុន ព្រោះធ្លាប់ជាសត្វចាក្រពាកឃើញព្រះមានព្រះភាគ ហើរទៅកាន់ទីមួយកន្លែង ហើយនាំផ្កាមកបូជា ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាស

អបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សិន្ធុយា ឆនិយា តីរេ** ជាដើម សេចក្តីថា ឈ្មោះថា **សិន្ធុ** ព្រោះធ្វើសំឡេងថា **សិសិ** ឲ្យកម្រើក ឲ្យញាប់ញ័រ ។ ឈ្មោះថា **ឆនិ** ព្រោះធ្វើសំឡេង គឺបន្លឺសំឡេងហូរទៅ ។ បទថា **ចក្កវាកោ អហំ តទា** សេចក្តីថា ឈ្មោះថា **ចក្កវាក** ព្រោះហើរទៅ គឺទៅក្នុងទឹក លើគោក ឬហើរទៅក្នុងអាកាសលឿន ដូចចក្រដែលវិលទៅយ៉ាងរហ័ស ដូច្នោះ អធិប្បាយថា ក្នុងកាលនោះ គឺក្នុងកាលដែលបានឃើញព្រះមានព្រះភាគព្រះនាមវិបស្សី ខ្ញុំបានជាសត្វចាក្រពាក ។ បទថា **សុទ្ធសេវាលភក្ខោហំ** សេចក្តីថា ខ្ញុំស៊ីតែសារាយដែលបរិសុទ្ធ ព្រោះមិនមានចំណីដទៃផ្សំ ។ បទថា **ចាបេសុ ច សុសញ្ញតោ** សេចក្តីថា ខ្ញុំព្រះអង្គជាអ្នកសង្រួមដោយល្អ គឺសង្រួម សិក្សាដោយល្អក្នុងកាលធ្វើបាបដោយអំណាចវាសនាក្នុងកាលមុន ។ បទថា **អទ្ទសំ វិរជំ ពុទ្ធំ** សេចក្តីថា ខ្ញុំបានឃើញ គឺបានគាល់ព្រះពុទ្ធ ដែលប្រាសចាកធូលី គឺមិនមានកិលេស ព្រោះវៀរចាករាគៈ ទោសៈ មោហៈ ។ បទថា **គច្ឆន្តំ អនិលញ្ជសេ** សេចក្តីថា ដែលទ្រង់យាងទៅលើអាកាស គឺតាមផ្លូវអាកាស អធិប្បាយថា ខ្ញុំបានពាំ គឺផ្គងយកផ្កាពាំងដោយចំពុះរបស់ខ្ញុំ បានបណ្តុះនូវការគ្រេកអរក្រៃលែងចំពោះព្រះមានព្រះភាគព្រះនាមវិបស្សី គឺបានបូជាដល់ព្រះមានព្រះភាគ ។ ពាក្យដ៏សេស មានអត្ថដ៏ងាយហើយ ៕

**អដ្ឋកថាបច្ចាគមនិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បរប្បសាទកត្ថេរាបទានទី ៤

[ ៦៦ ] បុគ្គលណា ឃើញព្រះសម្ពុទ្ធ មានសម្បុរដូចមាស ជាឧសភបុរស ជាវីរបុរសប្រសើរ ទ្រង់ស្វែងរកនូវគុណធម៌ដ៏ធំ មានជ័យជម្នះហើយ នឹងខានជ្រះថ្លាម្ដេចបាន ។ ភ្នំហិមពាន្ត មានប្រមាណមិនបាន និងសមុទ្ទសាគរ គេឆ្លងបានដោយក្រ យ៉ាងណាមិញ ឈានរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលឃើញហើយ នឹងខានជ្រះថ្លាម្ដេចបាន ។ ផែនដី មានប្រមាណមិនបាន របៀបផ្កាឈើក្នុងព្រៃដ៏ត្រកាល យ៉ាងណាមិញ សីលរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលណាឃើញហើយ នឹងខានជ្រះថ្លាម្ដេចបាន ។ អាកាសមិនញាប់ញ័រដោយផ្លូវខ្យល់ បុគ្គលរាប់មិនបាន យ៉ាងណាមិញ ញាណរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលណាឃើញហើយ នឹងខានជ្រះថ្លាម្ដេចបាន ។ ព្រាហ្មណ៍ឈ្មោះសោនៈ សរសើរនូវព្រះសិទ្ធត្ថៈ ជាព្រះពុទ្ធប្រសើរ ព្រះអង្គឈ្នះកិលេសមារ ដោយគាថាទាំង ៤ នេះហើយ មិនទៅកាន់ទុគ្គតិអស់ ៩៤ កប្ប ។

ខ្ញុំបានទទួលសម្បត្តិដ៏ល្អ ក្នុងសុគតិទាំងឡាយ មិនមែនតិចឡើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំសរសើរព្រះសម្ពុទ្ធ ជានាយកនៃសត្វលោក ហើយមិនស្គាល់នូវទុគ្គតិ នេះជាផលនៃការសរសើរព្រះពុទ្ធ ។ ក្នុងកប្បទី ១៤ ខ្ញុំបានជាស្ដេចចក្កពត្តិ

៤ ជង់ ព្រះនាមឧគ្គតៈដូចគ្នា ទ្រង់បរិបូរដោយរតនៈ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះបរប្បសាទកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

បរប្បសាទកត្ថេរាបទាន ចប់

# អដ្ឋកថា

## បរប្បសាទកត្ថេរាបទាន

[ ៦៦ ] *អបទានរបស់ព្រះបរប្បសាទកត្ថេរ មានពាក្យផ្ដើមថា* ***ឧសភំ បវរំ វីរំ*** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលព្រាហ្មណ៍ ប្រាកដនាមថា សេលព្រាហ្មណ៍ ជាអ្នកដល់នូវត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទ ដែលមានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នកយល់បទ ជាអ្នកយល់វេយ្យាករណ៍ ជំនាញក្នុងគម្ពីរលោកាយតៈ និងមហាបុរិសលក្ខណៈ ឃើញព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ដល់ព្រមដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងដោយអនុព្យញ្ជនៈ ៨០ ប្រការ មានចិត្តជ្រះថ្លា ទើបប្រកាសសរសើរដោយហេតុច្រើនយ៉ាង ដោយឧបមាច្រើនយ៉ាង ដោយបុញ្ញកម្មនោះ កុលបុត្តនោះសោយសម្បត្តិជាន់កាមាវចរ ៦ មានកើតជាសក្កៈ និងជាមារជាដើម ក្នុងទេវលោក សោយចក្កពត្តិសម្បត្តិក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង សម្បូរដោយទ្រព្យសម្បត្តិ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះខីណាស្រព ជាអ្នកដល់ព្រមដោយបដិសម្ភិទា ៤ អភិញ្ញា ៦ ។ លោកប្រាកដនាមថា បរប្បសាទកត្ថេរ ព្រោះការសរសើរព្រះពុទ្ធ ជាហេតុ*

ឲ្យសត្វទាំងពួងមានចិត្តជ្រះថ្លា ។

ថ្ងៃមួយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឧសភំ បវរំ វីរំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឧសភំ** គប្បីជ្រាបពាក្យអធិប្បាយយ៉ាងនេះថា គោឧសភៈមាន ៤ ប្រភេទ គឺវសភៈ ១ និសភៈ ១ វិសភៈ ១ អាសភៈ ១ ។ ក្នុងគោឧសភៈ ៤ ប្រភេទនោះ គោវសភៈ ជាមេហ្វូងនៃគោ ១០០ គោនិសភៈជាមេហ្វូងនៃគោ ១០០០ គោវិសភៈជាមេហ្វូងនៃគោ ១ សែន គោអាសភៈជាមេហ្វូងនៃគោ ១ សែនកោដិ ។ម្យ៉ាងទៀត ព្រាហ្មណ៍និងបណ្ឌិតដែលជាពហូសូត ទោះពោលសរសើរបុគ្គលណាម្នាក់ ក៏សរសើរបានស្មើនឹងបញ្ញារបស់ខ្លួនឯងមានប៉ុណ្ណោះ ទើបមិនមានបុគ្គលណាម្នាក់ដែលពោលសរសើរព្រះពុទ្ធទាំងឡាយ អស់គ្រប់គ្រាន់បាន ។ ព្រះពុទ្ធមានគុណប្រមាណមិនបាន សមដូចពាក្យដែលលោកពោលថា

ព្រះពុទ្ធគប្បីពណ៌នាគុណ ព្រះពុទ្ធផងគ្នា មិនត្រាស់ពាក្យដទៃ
សូម្បីអស់កប្ប កប្បក៏អស់ទៅមុន ក្នុងរវាងចន្លោះ គុណរបស់
ព្រះតថាគតមិនទាន់អស់ទៅឡើយ ។

ព្រាហ្មណ៍នេះ កាលគួរពោលថា **អាសភំ** បែរជាពោលថា **ឧសភំ** ជាដើម ដោយអំណាចរត់មាត់ ដោយការជ្រះថ្លាដោយចំណែកមួយ ឈ្មោះថា **វរោ** ព្រោះអត្ថថា គប្បីប្រាថ្នា គឺគប្បីចង់បាន ។ ឈ្មោះថា **វីរោ** ព្រោះ

បានបំពេញព្យាយាមមក អស់ច្រើនសែនកប្ប ។ ឈ្មោះថា **មហេសី** ព្រោះស្វែងរក គឺស្វែងរកគុណធំ មានសីលក្ខន្ធជាដើម ។ នូវព្រះពុទ្ធអ្នកស្វែងរកគុណធំអង្គនោះ ។ ឈ្មោះថា **វិជិតាវិ** ព្រោះឈ្នះមារ មានកិលេសមារ និងខន្ធមារជាដើម ដោយពិសេស ។ នូវព្រះសម្ពុទ្ធអ្នកឈ្នះពិសេសអង្គនោះ ។ វណ្ណៈរបស់ព្រះពុទ្ធអង្គណា មានពណ៌ដូចពណ៌នៃមាសព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **សុវណ្ណវណ្ណំ** ។ សត្វប្រភេទណា ឃើញព្រះសម្ពុទ្ធមានពណ៌ដូចមាសនោះ មិនជ្រះថ្លាដូចម្តេចកើត ដូច្នេះ ៕

## អដ្ឋកថាបរប្បសាទកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ភិសទាយកត្ថេរាបទានទី ៩

[ ៦៧ ] ព្រះពុទ្ធព្រះនាមវេស្សភូ ជាបុរសដ៏ឧត្តម ជាព្រះពុទ្ធទី ៣ របស់ពួកព្រះពុទ្ធ ទ្រង់ស្វែងរក ( នូវគុណធំ ) ស្តេចទៅគង់នៅក្នុងព្រៃផ្សៃ ។ ខ្ញុំមានចិត្តជ្រះថ្លា បានកាន់ក្រអៅឈូក ហើយដើរទៅក្នុងទីជិតនៃព្រះពុទ្ធ ថ្វាយក្រអៅឈូកនោះចំពោះព្រះពុទ្ធ ដោយដៃរបស់ខ្លួន ។ ព្រះពុទ្ធព្រះនាមវេស្សភូ មានព្រះប្រាជ្ញាដ៏ប្រសើរ ទ្រង់បានទទួលដោយព្រះហស្ត ខ្ញុំមិនដែលស្គាល់សុខណាដ៏ស្មើ ឬលើសជាងសុខដែលកើតអំពីបុណ្យនោះសោះឡើយ ។ កពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ កពទាំងពួង ខ្ញុំគាស់រម្លើងចោលហើយ ខ្ញុំផ្តាច់ចំណងដូចជាដំរី ( ផ្តាច់ទន្ទឹង ) ហើយជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយក្រអៅឈូក ។ ក្នុងកប្បទី ១៣ ខ្ញុំបានជាស្តេចចក្កពត្តិ ១៦ ដង ព្រះនាមសមោធានៈដូចគ្នា ជាធំក្នុងពួកមនុស្ស មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ

ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះភិសទាយកត្ថេរមានអាយុ បានសម្ដែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ភិសទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ភិសទាយកត្ថេរាបទាន

[ ៦៧ ] អបទានរបស់ព្រះភិសទាយកត្ថេរ មានពាក្យផ្ដើមថា **វេស្សភូ នាម នាមេន** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមវេស្សភូ កើតក្នុងកំណើតដំរី ក្នុងព្រៃហិមពាន្ត នៅអាស្រ័យក្នុងទីនោះ ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមវេស្សភូ ទ្រង់ត្រូវការទីស្ងាត់ ទើបយាងទៅកាន់ហិមវន្តប្បទេស ។ ដំរីដ៏ប្រសើរនោះឃើញព្រះមានព្រះភាគនោះហើយ មានចិត្តជ្រះថ្លា ទើបនាំក្រអៅឈូកមកថ្វាយព្រះមានព្រះភាគឲ្យទ្រង់សោយ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះចុតិចាកដំរីនោះហើយ កើតក្នុងទេវលោក សោយឆកាមាវចរសម្បត្តិក្នុងទេវលោកនោះ ហើយមកកើតជាមនុស្ស សោយសម្បត្តិ មានចក្កពត្តិ-សម្បត្តិជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយដែលមានភោគៈច្រើន ជ្រះថ្លាក្នុងព្រះសាស្ដា ដោយកម្លាំងនៃវាសនាក្នុងកាលមុន បួសហើយមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ លោកបានប្រាកដឈ្មោះថា ភិសទាយកត្ថេរ តាមកុសលដែលធ្វើមកក្នុងកាលមុន ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វេស្សភូ នាម នាមេន** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **វេស្សភូ** សេចក្ដីថា ឈ្មោះថា វេស្សភូ ព្រោះគ្របសង្កត់ គឺឈ្នះកន្លងពួកវេស្សៈ ។ម្យ៉ាងទៀត ឈ្មោះថា វេស្សភូ ព្រោះសង្កត់ គឺគ្របសង្កត់វេស្សៈ គឺពាណិជ្ជកម្ម ឬកិលេស មានកាមរាគៈជាដើម ឬកម្ម មានកុសលកម្មជាដើម ឬវត្ថុកាម និងកិលេសកាម ទើបព្រះមានព្រះភាគអង្គនោះព្រះនាមថា វេស្សភូ ។ បទថា **ឥសីនំ តតិយោ អហុ** សេចក្ដីថា ឈ្មោះថា **ឥសិ** ព្រោះស្វែងរក គឺស្វែងរកកុសលធម៌ទាំងឡាយ អធិប្បាយថា ព្រះមានព្រះភាគជាអ្នកស្វែងរកគុណ ( ឥសី ) អង្គទី ៣ ព្រោះគេតែងស្គាល់មកថា ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ។ បទថា **កាននំ វនមោគ្គយ្ហ** សេចក្ដីថា ឈានចូលទៅកាន់ព្រៃ ពោលគឺព្រៃធំ ។

បទថា **ភិសមុឡាលំ គណ្ហិត្វា** សេចក្ដីថា ឈ្មោះថា **ភិស** ព្រោះញាំញី គឺបៀតបៀន បានដល់ ទម្លាយនូវការឃ្លានរបស់សត្វជើងពីរ និងសត្វជើង ៤ ។ **ភិស** នោះ គឺអ្វី បានដល់ ក្រអៅឈូក ។ មើមឈូក និង

ក្រអៅឈូក ឈ្មោះថា **ភិសមុឡាល** អធិប្បាយថា កាន់យកមើមឈូក និងក្រអៅឈូកនោះ ។

បទថា **ករេន ច បរាមដ្ឋោ** សេចក្តីថា ទានដែលខ្ញុំឲ្យហើយនោះ ដែលព្រះមានព្រះភាគព្រះនាមវេស្សភូ ជាអ្នកមានបញ្ញាដ៏ឧត្តម ស្ទាបអង្អែល ហើយដោយព្រះហស្ត គឺដោយបាតព្រះហស្ត បានដល់ បានទទួលនូវសម្ផស្ស ។ បទថា **សុខាហំ ឆាភិជានាមិ សមំ តេន កុតោត្តរី** សេចក្តីថា ខ្ញុំមិនដឹងសេចក្តីសុខ ( ដទៃ ) ស្មើគ្នានឹងសេចក្តីនោះ អធិប្បាយថា សុខដទៃដែលក្រៃលែងជាងសុខនោះ នឹងមានអំពីទីណា ។ ពាក្យដ៏សេសមានអត្ថដឹងបានងាយ តាមគន្លងអត្ថនោះឯង ។l៚

**អដ្ឋកថាភិសទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សុចិន្តិតត្ថេរាបទានទី ៦

[ ៦៨ ] ខ្ញុំបានកើតជាកេសររាជសីហ៍[១] មានជាតិដ៏ខ្ពង់ខ្ពស់ ត្រាច់ទៅតាមជ្រោះភ្នំ សម្លាប់នូវពួកម្រឹគ ចិញ្ចឹមជីវិតក្នុងចន្លោះភ្នំ ។ គាប់ជួន ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ព្រះអង្គជាសព្វញ្ញូ ទ្រង់ប្រសើរជាងពួកអ្នកប្រាជ្ញ ព្រះអង្គប្រាថ្នាស្រោចស្រង់ខ្ញុំ ទើបស្តេចមកកាន់ភ្នំដ៏ឧត្តម ។ ក្នុងសម័យនោះ ខ្ញុំសម្លាប់នូវបសុទម្រឹគ យកមកបម្រុងបរិភោគ ព្រះមានព្រះភាគ ប្រព្រឹត្តបិណ្ឌបាត ស្តេចចូលមកជិតខ្ញុំ ។ ខ្ញុំរើសយកសាច់ដ៏ល្អ ថ្វាយព្រះសាស្តាអង្គនោះ ឯព្រះសាស្តាជាមហាវីរបុរស ( សម្តែងធម៌ ) ញុំាងខ្ញុំឲ្យរលត់ទុក្ខ ហើយទ្រង់អនុមោទនា ក្នុងកាលនោះ ។ ខ្ញុំចូលទៅកាន់ជ្រោះភ្នំ ញុំាងបីតិឲ្យកើតឡើង ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ខ្ញុំក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ១៥០០ ខ្ញុំបានរីករាយក្នុងទេវលោក ដោយទានសាច់នុ៎ះផង ដោយសេចក្តីតម្កល់ចិត្តនុ៎ះផង ។ ដោយអំណោយនៃទានសាច់នោះផង ដោយការរឭកនូវព្រះពុទ្ធផង

---

១- គួរប្រែថា ខ្ញុំកើតជាព្រាន ដូចកេសររាជសីហ៍ ទើបមិនខ្វាស់សេចក្តីជាមួយនឹងអដ្ឋកថា ។

កុសល ខ្ញុំក៏បានធ្វើថែមទៀត ក្នុងកប្បដ៏សេស ។ ក្នុងកប្បទី ៣៨ ខ្ញុំបានកើតជាស្តេចមាននាមថា ទីឃាយុ ៨ ដង ក្នុងកប្បទី ៦០០០ អំពីកប្បនេះ ខ្ញុំបានជាស្តេចពីរដង ព្រះនាមសរណៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុចិន្តិតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សុចិន្តិតត្ថេរាបទាន ចប់

# អដ្ឋកថា

## សុចិន្តិតត្ថេរាបទាន

[ ៦៨ ] *អបទានរបស់ព្រះសុចិន្តិតត្ថេរ មានពាក្យផ្តើមថា* **គិរិ-ទុគ្គចរោ អាសឹ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងហិមវន្តប្បទេស សម្លាប់ម្រឹគ និងជ្រូកជាដើមបរិភោគ ។ ក្នុងកាលនោះ ព្រះលោកនាថទ្រង់សង្គ្រោះសត្វលោក មានព្រះហឫទ័យករុណាសត្វ ទើបយាងទៅកាន់ព្រៃហិមពាន្ត ។ ក្នុងកាលនោះ នាយព្រាននោះ ឃើញព្រះមានព្រះភាគ មានចិត្តជ្រះថ្លា បានថ្វាយសាច់ដែលល្អដែលរកមកសម្រាប់បរិភោគឯង ។ ព្រះមានព្រះភាគទ្រង់ទទួលដើម្បីអនុគ្រោះកុលបុត្តនោះ ទ្រង់សោយសាច់នោះហើយអនុមោទនា ហើយយាងចៀសចេញទៅ ។ ដោយបុញ្ញកម្មនោះឯង កុលបុត្តនោះចុតិចាកអត្តភាពនោះ ដោយសោមនស្សនោះឯង អន្ទោលទៅក្នុងសុគតិ សោយសម្បត្តិក្នុងកាមាវចរសួគ៌ ៦ ជាន់ សោយចក្កពត្តិសម្បត្តិជាដើមក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

លោកដល់នូវការបែកធ្លាយក្នុងបដិសម្ភិទា ៤ និងអភិញ្ញា ៦ ហើយ រឭកដល់បុព្វកម្មរបស់ខ្លួនកើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **គិរិទុគ្គចរោ អាសឹ** ដូច្នេះជាដើម ។

ឈ្មោះថា **គិរិ** ព្រោះអត្ថថា បន្លឺ គឺធ្វើសំឡេង ។ **គិរិ** នោះ គឺអ្វី គឺភ្នំថ្ម និងភ្នំដី ។ ផ្លូវដែលបុគ្គលដើរទៅដោយក្រ គឺលំបាក ឈ្មោះថា **ទុគ្គ** ផ្លូវដែលទៅលំបាក ព្រោះ ( មាន ) ភ្នំ ឈ្មោះថា **គិរិទុគ្គ** បានដល់ ផ្លូវដែលបុគ្គលដើរទៅដោយលំបាក ។ ខ្ញុំជាព្រានត្រាច់ទៅ គឺមានប្រក្រតីត្រាច់ទៅក្នុងភ្នំដែលទៅលំបាក គឺក្នុងចន្លោះភ្នំនោះ ។ បទថា **អភិជាតោវ កេសរី** សេចក្តីថា ខ្ញុំកើតដោយពិសេសក្រៃលែង ត្រាច់ទៅត្រង់ញកភ្នំ ដូចកេសរ-រាជសីហ៍ ដូច្នោះ ។

បទថា **គិរិទុគ្គំ បវិសឹ អហំ** សេចក្តីថា ក្នុងកាលនោះ ខ្ញុំកើតនូវបីតិសោមនស្ស ព្រោះបានថ្វាយសាច់នោះហើយ បានចូលទៅកាន់ចន្លោះភ្នំ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាសុចិន្តិតត្ថេរាបទាន ចប់

# សុត្តន្តបិដក

## វគ្គនាយកត្ថេរាបទានទី ៧

[ ៦៩ ] ក្នុងកាលនោះ ខ្ញុំកើតជាបក្សីក្រុឌ ជាធំលើពួកក្រុឌ បាន ឃើញព្រះពុទ្ធ ព្រះអង្គមានធូលី គឺកិលេស ប្រាសចេញហើយ កំពុងស្តេចទៅកាន់ភ្នំគន្ធមាទន៍ ។ ខ្ញុំបានលះបង់ភេទជាក្រុឌ ហើយ ប្រែងខ្លួនជាមាណព ខ្ញុំបានថ្វាយសំពត់មួយចំពោះព្រះពុទ្ធ ព្រះអង្គ ជាបុគ្គលនឹងធឹង ទ្រង់ជាធំជាងសត្វជើងពីរ ចំណែកខាងព្រះពុទ្ធ ជាអគ្គនាយកនៃសត្វលោក ជាសាស្តា ទ្រង់ឈរទទួលនូវសំពត់ នោះ នៅលើអាកាស ហើយសម្តែងនូវគាថាទាំងនេះថា បក្សីក្រុឌ នេះ លុះលះបង់នូវកំណើតក្រុឌហើយ នឹងទៅត្រេកអរក្នុងទេវលោក ព្រោះទាននៃសំពត់នេះផង ព្រោះការតម្កល់ ចិត្តនេះផង ។ ចំណែក ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាចម្បងក្នុងលោក ជា នរាសភៈ ទ្រង់សរសើរទានសំពត់ហើយ ទ្រង់ងាកព្រះភក្រ្ត ឆ្ពោះទៅទិសខាងជើង ទ្រង់ស្តេចចៀសចេញទៅ ។ កាលខ្ញុំកើត ក្នុងភព ខ្ញុំតែងមានការបរិបូណ៌ដោយសំពត់ តែងមានគ្រឿង ប្រក់បាំងពួដ៏អាកាស នេះជាផលនៃទានសំពត់ ។ ក្នុងកប្បទី ៣៦ ខ្ញុំបានជាស្តេចចក្កពត្តិ ៧ ជង ព្រះនាមអរុណសៈ មានកម្លាំង

ច្រើន ជាអធិបតីលើពួកមនុស្ស ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវត្តទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

វត្តទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## វត្តទាយកត្ថេរាបទាន

[ ៦៩ ] អបទានរបស់ព្រះវត្តទាយកត្ថេរ មានពាក្យផ្តើមថា **បក្កិជាតោ តទា អាសឹ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងកំណើតគ្រុឌ ឃើញព្រះមានព្រះភាគព្រះនាមអត្ថទស្សី កំពុងយាងទៅកាន់ភ្នំគន្ធមាទន៍ មានចិត្តជ្រះថ្លា លះនូវភេទជាគ្រុឌ និម្មិតភេទជាមាណព នាំយកសំពត់ទិព្វ ដែលមានតម្លៃច្រើន មកបូជាព្រះមានព្រះភាគ ចំណែកព្រះមានព្រះភាគទ្រង់ទទួល ត្រាស់អនុមោទនាហើយយាងទៅ ។ កុលបុត្តនោះ ឲ្យកាលកន្លងទៅដោយសោមនស្សរឿយៗ តាំងនៅដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវលោកនោះ សោយនូវបុណ្យទាំងឡាយ បន្ទាប់អំពីនោះ សោយមនុស្សសម្បត្តិក្នុងពួកមនុស្ស គឺកុលបុត្តនោះបាននូវគ្រឿងប្រដាប់ គឺសំពត់ ទោះកើតក្នុងភពណា ទៅក្នុងទីណា ក៏នៅខាងក្រោមម្លប់នៃសំពត់ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចអភិញ្ញា ៦ ជាព្រះខីណាស្រព លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទាន

ដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បក្ខិជាតោ តទា អាសឹ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បក្ខិជាតោ** សេចក្តីថា ឈ្មោះថា **បក្ខ** ព្រោះជាគ្រឿងស្ទុះទៅ គឺហើរទៅនៃបក្សី ។ ឈ្មោះថា **បក្ខី** ព្រោះជាអ្នកមានស្លាប អធិប្បាយថា កើត គឺកើតក្នុងកំណើតរបស់បក្សី ។ បទថា **សុបណ្ណោ** សេចក្តីថា ស្លាបរបស់បក្សីណាល្អ បក្សីនោះ ឈ្មោះថា មានស្លាបល្អ អធិប្បាយថា បក្សីនោះ មានស្លាបមានទម្ងន់ច្រើន មានពណ៌ដូចមាសសម្រាប់ទទះខ្យល់ ។ បទថា **គរុឡាធិបោ** សេចក្តីថា ឈ្មោះថា គ្រុឌ ព្រោះលេបនូវដុំថ្មដ៏ធ្ងន់ ដើម្បីចាប់នាគ ។ ឈ្មោះថា **គរុឡាធិបោ** ព្រោះជារាជាធិបតីនៃគ្រុឌទាំងឡាយ ភ្ជាប់សេចក្តីថា ខ្ញុំបានឃើញព្រះពុទ្ធ ដែលប្រាសចាកធូលី គឺកិលេស ។l៙៚

**អដ្ឋកថាវត្ថុទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អម្ពទាយកត្ថេរាបទានទី ៨

[ ៧០ ] ព្រះមានព្រះភាគព្រះនាមអនោមទស្សី ទ្រង់គង់នៅក្នុងទីចង្ក្រមភ្នំ ព្រះអង្គមិនមានឧបធិក្កិលេស ( មានព្រះហឫទ័យ ) ផ្សាយមេត្តាទៅក្នុងលោក មិនមានប្រមាណ ។ គ្រានោះ ខ្ញុំបានកើតជាស្វា លើភ្នំដ៏ឧត្តម ឈ្មោះហិមពាន្ត បានឃើញព្រះពុទ្ធមានគុណមិនថោកថយ មានគុណដ៏ក្រៃលែង ក៏ញុំាងចិត្តឲ្យជ្រះថ្លា ចំពោះព្រះពុទ្ធ ។ ក្នុងគ្រានោះ មានដើមស្វាយមានផ្លែក្នុងទីមិនឆ្ងាយអំពីភ្នំហិមពាន្ត ខ្ញុំក៏បានបេះផ្លែស្វាយទុំ មានរសផ្អែមអំពីដើមស្វាយនោះ ព្រមទាំងទឹកឃ្មុំ ហើយថ្វាយព្រះសម្ពុទ្ធ ។ ព្រះពុទ្ធព្រះនាមអនោមទស្សី ជាមហាមុនី ទ្រង់ព្យាករខ្ញុំនោះដោយទានរបស់ខ្ញុំទាំង ២ គឺទានទឹកឃ្មុំនេះ និងទានទឹកផ្លែស្វាយនេះថា

ស្វានេះ នឹងរីករាយក្នុងទេវលោក អស់ ៥៧ កប្ប នឹងអន្ទោលទៅកាន់ភពដ៏ច្រឡូកច្រឡំក្នុងកប្បដ៏សេស ។ លុះអស់បាបកម្ម មកអំពីអបាយភូមិ មានអសុរកាយជាដើម ( បានមកជាមនុស្ស ) ហើយញុំាំងកិលេសឲ្យរីងស្ងួត ដោយសេចក្តីចម្រើនដ៏ចាស់ក្លា ។

ខ្ញុំដែលព្រះពុទ្ធស្វែងរកនូវគុណដ៏ធំ ទូន្មានហើយ ដោយការទូន្មានដ៏ឧត្តម ក៏បានលះបង់នូវការឈ្នះ និងការចាញ់ ហើយដល់នូវទីមិនញាប់ញ័រ គឺព្រះនិព្វាន ។ ក្នុងកប្បទី ៧៧០០ ខ្ញុំបាន

ជាស្តេចចក្កពត្តិ ១៤ ដង ព្រះនាមអម្ពដ្ឋជ័យ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## អម្ពទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## អម្ពទាយកត្ថេរាបទាន

[ ៧០ ] អបទានរបស់ព្រះអម្ពទាយកត្ថេរ មានពាក្យផ្តើមថា **អនោមទស្សី ភគវា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអនោមទស្សី កើតក្នុងកំណើតនៃពានរ បានជាស្តេចស្វាអាស្រ័យនៅក្នុងព្រៃហិមពាន្ត ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមអនោមទស្សី បានយាងទៅព្រៃហិមពាន្ត ដើម្បីអនុគ្រោះដល់ពានរនោះ ។ លំដាប់នោះ ស្តេចស្វានោះឃើញ ព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា បានថ្វាយផ្លែស្វាយមានរសឆ្ងាញ់ មួយអន្លើដោយទឹកឃ្មុំផ្អិត ។ លំដាប់នោះ ព្រះមានព្រះភាគ កាលពានរនោះកំពុងមើលនោះឯង បានសោយរបស់ទាំងអស់នោះ ត្រាស់អនុមោទនាហើយ យាងចៀសចេញទៅ ។ លំដាប់នោះ ពានរមានហទយៈដល់ព្រមដោយសោមនស្ស តាំងនៅដរាបដល់អស់អាយុ ព្រោះមានបីតិ និងសោមនស្សនោះឯង ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសុខក្នុងទេវលោកនោះ និងសោយមនុស្សសម្បត្តិក្នុងពួកមនុស្ស ត្រឡប់ទៅ ត្រឡប់មក ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដែលសម្បូរដោយទ្រព្យសម្បត្តិ ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ មិនយូរប៉ុន្មាន ក៏សម្រេចអភិញ្ញា ៦ ប្រាកដឈ្មោះថា អម្ពទាយកត្ថេរ តាមបុណ្យដែលធ្វើទុកក្នុងកាលមុន ។

ក្នុងកាលតមកលោកបានឃើញពូជនៃកុសលដែលខ្លួនបំពេញមក កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អនោមទស្សី ភគវា** ដូច្នេះជាដើម ។ បទថា **មេត្តាយ អផរិ លោកេ អប្បមាណេ និរូបធិ** សេចក្ដីថា ព្រះមានព្រះភាគ មិនមានឧបធិនោះ ទ្រង់ផ្សាយ គឺទ្រង់ផ្សព្វផ្សាយមេត្តា មានព្រះហឫទ័យប្រកបដោយមេត្តាផ្សាយទៅកាន់សត្វលោកទាំងពួង គឺផ្សាយទៅរកសត្វមិនមានប្រមាណឲ្យវៀរចាកឧបធិក្កិលេស ដោយន័យជាដើមថា ចូរសត្វទាំងឡាយ មានសេចក្ដីសុខ ។

បទថា **កបិ អហំ តទា អាសឹ** សេចក្ដីថា ក្នុងកាលនោះ គឺក្នុងកាលដែលព្រះសាស្ដាយាងមក ខ្ញុំបានកើតជាស្ដេចស្វា ។ល។

## អដ្ឋកថាអម្ពទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សុមនត្ថេរាបទានទី ៩

[ ៧១ ] ក្នុងគ្រានោះ ខ្ញុំជានាយមាលាការ ( អ្នកធ្វើកម្រងផ្កា ) ឈ្មោះសុមនៈ បានឃើញព្រះពុទ្ធ មានធូលី គឺកិលេស ប្រាសចេញហើយ ព្រះអង្គជាអ្នកទទួលនូវគ្រឿងបូជារបស់សត្វលោក ។ ខ្ញុំលើកផ្គង នូវផ្កាម្លិះដ៏ឧត្តម ដោយដៃទាំងពីរ បង្អោនថ្វាយព្រះពុទ្ធព្រះនាមសិខី ព្រះអង្គជាផៅពង្សនៃលោក ។ ខ្ញុំមិនដែលស្គាល់ទុគ្គតិ ដោយការបូជាផ្កានេះផង ដោយការតម្កល់ចេតនានេះផង នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៦ ខ្ញុំបានជាស្តេចចក្កពត្តិ ៤ ដង ព្រះនាមមហាយសៈ ទ្រង់បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*សុមនត្ថេរាបទាន ចប់*

# អដ្ឋកថា

## សុមនត្ថេរាបទាន

[ ៧១ ] *អបទានរបស់ព្រះសុមនត្ថេរ មានពាក្យផ្ដើមថា* **សុមនោ នាម នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះនៃត្រកូលនាយមាលាការ ចម្រើនវ័យហើយ បាននូវសទ្ធា មានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគ កាន់យកបាច់ផ្កាម្លិះបូជាដោយដៃទាំងទ្វេ ដោយបុញ្ញកម្មនោះ កុលបុត្តនោះសោយសម្បត្តិទាំងពីរ ក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់ព្រមដោយបុត្តនិងភរិយា ជាអ្នកប្រាកដនាមថា សុមនៈ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ព្រះថេរៈបានជាព្រះអរហន្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សុមនោ នាម នាមេន** *ដូច្នេះជាដើម ។* **មន** *គឺចិត្តរបស់បុគ្គលណាល្អ បុគ្គលនោះឈ្មោះថា* **សុមន** *ក្នុងកាលនោះ ខ្ញុំជាអ្នកក្រងផ្កាដោយឈ្មោះ មានឈ្មោះថា សុមនៈ ជាអ្នកប្រកបដោយសទ្ធា និងមានសេចក្ដីគោរពច្រើន ( ក្នុងព្រះពុទ្ធ ) ។*

*បទថា* **សិខិនោ លោកពន្ធុនោ** *សេចក្តីថា ឈ្មោះថា* **សិខី** *ព្រោះមានសេចក្តីព្យាយាម និងរុងរឿង ម្យ៉ាងទៀត ឈ្មោះថា* **សិខី** *ព្រោះសន្តត់សន្ថិន គឺកម្ចាត់វត្ថុដែលមកពាល់ត្រូវ សិខីនោះ គឺអ្វី គឺអណ្តាតភ្លើង ឈ្មោះថា* **សិខី** *ព្រោះរុងរឿងដូចអណ្តាតភ្លើងៗ រមែងរុងរឿង គឺមើលឃើញអណ្តាតភ្លើងរមែងឆេះស្លឹកឈើ ស្មៅ ឈើ និងចំបើងជាដើមយ៉ាងណា ព្រះមានព្រះភាគអង្គនេះក៏យ៉ាងនេះ រមែងរុងរឿង ដោយរស្មីមានពណ៌ខៀវ និងពណ៌លឿងជាដើម ប្រាកដក្នុងលោកសន្និវាសទាំងមូល ។ ព្រះមានព្រះភាគមាននាមបញ្ញត្តិ នាមកម្ម នាមធេយ្យ ព្រោះអត្ថថា ធ្វើកិលេសទាំងពួងដែលនៅក្នុងសន្តានរបស់ព្រះអង្គ ឲ្យវិនស្សូត គឺកម្ចាត់ បោល ដុតបោល ។ ញាតិដែលជាផៅពង្សរបស់លោកទាំងអស់ ឈ្មោះថា* **លោកពន្ធុ** *អធិប្បាយថា ខ្ញុំបានលើកឡើងនូវផ្កាម្ទិះបូជាព្រះមានព្រះភាគ ដែលជាលោកពន្ធុព្រះនាមថាសិខីអង្គនោះ ។៚*

**អដ្ឋកថាសុមនត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ខុទ្ទកនិកាយ អបទាន ទី ១០

[ ៧២ ] ( ខ្ញុំបានឃើញ ) ព្រះពុទ្ធព្រះនាមសិខី ព្រះអង្គមានសភាពមិនខ្វះខាត ដូចសីហៈ ដូចគ្រុឌប្រសើរជាងពួកបក្សី ដូចខ្លាធំដ៏ល្អប្រសើរ ដូចកេសររាជសីហ៍ មានជាតិខ្ពង់ខ្ពស់ ព្រះអង្គជាសរណៈនៃលោកទាំង ៣ មិនញាប់ញ័រ ទ្រង់ឈ្នះមារ ប្រសើរជាងពួកសមណៈ ទ្រង់គង់នៅ ដោយមានភិក្ខុសង្ឃចោមរោម ។ ខ្ញុំបានដាក់ផ្កានទោង ដ៏ប្រសើរក្នុងប្រអប់ ហើយថ្វាយទាំងប្រអប់ធំ ចំពោះព្រះពុទ្ធ ជាបុគ្គលប្រសើរ ។ បពិត្រព្រះអង្គ ជាធំជាងសត្វជើងពីរ ជានរាសភៈ ខ្ញុំលះបង់នូវការឈ្នះ និងការចាញ់ហើយ ដល់នូវទីមិនកម្រើក គឺព្រះនិព្វាន ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣០ គត់ ខ្ញុំបានជាស្តេចចក្រពត្តិ ៥ ដង ព្រះនាមទេវភូតិសៈ ទ្រង់បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផចង្កោជិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បុប្ផចង្កោជិយត្ថេរាបទាន ចប់

## ឧទ្ទាន

សកចិត្តនិយត្ថេរាបទាន ១ អាបោបុប្ផិយត្ថេរាបទាន ១ បច្ចាគមនិយត្ថេរាបទាន ១ បរប្បសាទកត្ថេរាបទាន ១ ភិសទាយកត្ថេរាបទាន ១ វត្ថទាយកត្ថេរាបទាន ១ អម្ពទាយកត្ថេរាបទាន ១ សុមនត្ថេរាបទាន ១ បុប្ផ-ចង្កោជិយត្ថេរាបទាន ១ ឯគាថាទាំងឡាយ ជាគ្រឿងសម្តែងនូវអត្ថ ដែលលោកពោលហើយ រាប់ទៅឃើញ ៧១ គាថា ។

សកចិត្តនិយវគ្គទី ៧ ចប់

# អដ្ឋកថា

## បុប្ផចង្កោដិយត្ថេរាបទាន

[ ៧២ ] អបទានរបស់ព្រះបុប្ផចង្កោដិយត្ថេរ មានពាក្យផ្តើមថា **អភីតរូបំ សីហាំវ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ សម្បូរដោយទ្រព្យសម្បត្តិជាច្រើន ជ្រះថ្លាក្នុងព្រះសាស្តា កាលសម្តែងថា មានសេចក្តីជ្រះថ្លា ទើបបេះផ្កានោងមានពណ៌ដូចមាស ដាក់ពេញប្រអប់ បូជាព្រះមានព្រះភាគ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ដោយផលរបស់ទាន សូមឲ្យខ្ញុំព្រះអង្គជាអ្នកមានពណ៌សម្បុរដូចមាស បានទទួលការបូជាគ្រប់ទីដែលទៅកើត និងសូមបានសម្រេចព្រះនិព្វានផងចុះ ។

ដោយបុព្វកម្មនោះ កុលបុត្តនោះ ទោះកើតក្នុងទេវតា និងមនុស្សទាំងឡាយ ជាបុគ្គលដែលបានទទួលការបូជាក្នុងទីគ្រប់ស្ថាន ជាអ្នកមានសម្បុរល្អដូចមាស ។ ក្នុងកាលតមក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមាន

ត្រកូលមួយកន្លែង សម្បូរដោយទ្រព្យសម្បត្តិ ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានជាអរហន្ត ។

លោកសម្រេចអរហត្តផលហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អភីតរូបំ សីហំវ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **សីហំ** សេចក្តីថា ឈ្មោះថា **សីហ** ព្រោះគ្របសង្កត់ ញាំញីសត្វជើងពីរនិងសត្វជើង ៤ ជាដើម ទើបជាសត្វមិនតក់ស្លុត គឺមិនកោតញញើត ភ្ជាប់សេចក្តីថា ខ្ញុំបូជាព្រះមានព្រះភាគអង្គនោះ ដែលប្រថាប់គង់ដូចរាជសីហ៍មិនមានសេចក្តីខ្លបខ្លាច ដែលព្រះសម្មាសម្ពុទ្ធព្រះនាមសិខី ជាអ្នកអង់អាច គឺឧត្តមដូចស្តេចគ្រុឌ ដែលជាកំពូលនៃបក្សីសត្វ ជាអ្នកកើតដោយល្អ គឺវិសេស ដូចស្តេចខ្លាធំ ជាបុគ្គលប្រៀបដូចកេសរសីហៈ ដែលជាកំពូលជាងរាជសីហ៍គ្រប់ពួក ជាទីពឹងរបស់លោកទាំងបី ។ សេចក្តីនេះដូចម្តេចភ្ជាប់សេចក្តីថា នូវព្រះមានព្រះភាគព្រះនាមសិខី ដែលជាបុគ្គលមិនញាប់ញ័រ គឺជាអ្នកប្រាសចាកកិលេស ដែលខន្ធមារជាដើម ធ្វើឲ្យបាញ់មិនបាន ដែលប្រថាប់គង់ ។

*បទថា* **មារណានគ្គំ** *សេចក្តីថា ជាបុគ្គលប្រសើរក្នុងការញ៉ាំងកិលេសទាំងពួងឲ្យស្លាប់ ឲ្យវិនស្តួត និងកម្ចាត់បង់ អធិប្បាយថា បណ្តាព្រះបច្ចេកសម្ពុទ្ធ និងពុទ្ធសាវកទាំងឡាយ ដែលសម្លាប់កិលេសទាំងឡាយឲ្យស្លាប់សូម្បីមាន ទ្រង់ប្រសើរជាងលោកទាំងនោះ ភ្ជាប់សេចក្តីថា នូវព្រះមានព្រះភាគអង្គនោះ ដែលភិក្ខុសង្ឃចោមរោមហើយ គឺដែលភិក្ខុសង្ឃចោមរោម ប្រថាប់គង់ហើយ ។*

*បទថា* **ចង្កោដកេ ឋបេត្វាន** *សេចក្តីថា ខ្ញុំបានយកនូវផ្កានោងដែលល្អ ដាក់ក្នុងជបរហូតពេញ បូជាព្រះពុទ្ធព្រះនាមសិទ្ធិដ៏ប្រសើរ ។៚*

**អដ្ឋកថាបុប្ផចង្កោដិយត្ថេរាបទាន ចប់**

**សកចិត្តនិយវគ្គទី ៧ ចប់**

# សុត្តន្តបិដក

# នាគសមាលវគ្គទី ៨

## នាគសមាលត្ថេរាបទានទី ១

[ ៧៣ ] ខ្ញុំបានរើសផ្កា ដែលគេចោលក្នុងផ្លូវធំ ហើយបូជាព្រះស្តូបរបស់ព្រះសិខី ជាផៅពង្សនៃលោក ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់នូវទុគ្គតិ នេះជាផលនៃការបូជាចំពោះព្រះស្តូប ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ព្រះនាមបុប្ផិយៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគសមាលត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**នាគសមាលត្ថេរាបទាន ចប់**

# អដ្ឋកថា
# នាគសមាលវគ្គទី ៨

## នាគសមាលត្ថេរាបទាន

[ ៧៣ ] *អបទានរបស់ព្រះនាគសមាលត្ថេរ មានពាក្យផ្តើមថា* **អាថាដលឺ អហំ បុប្ផំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ នៅគ្រប់គ្រងផ្ទះ ព្រោះមិនមានកម្ម មានសភាពបែបនោះ មកដឹកនាំក្នុងកាលដែលព្រះសាស្តាទ្រង់គង់ព្រះជន្មនៅ ទើបមិនបានឃើញ មិនបានស្តាប់ធម៌ និងមិនបានធ្វើការបូជា ក្នុងកាលនៃព្រះសាស្តាបរិនិព្វានហើយ បានធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះចេតិយដែលគេសាង ដើម្បីបញ្ចុះព្រះសារីរិកធាតុរបស់ព្រះមានព្រះភាគអង្គនោះ បូជាដោយផ្កាប្រទៀង ញ៉ាំងសោមនស្សឲ្យកើតឡើង តាំងនៅដរាបដល់អស់អាយុដោយសោមនស្សនោះឯង តមក កាលអស់ជីវិតហើយ បានទៅសោយសុខក្នុងទេវលោក ៦ ជាន់ មានជាន់តុសិតជាដើម ហើយមកសោយសម្បត្តិក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល មានឈ្មោះដែលមាតាបិតាដាក់ឲ្យថា នាគសមាលៈ ព្រោះមានរាងកាយដូចគ្នានឹងត្រួយខ្ទឹង ជ្រះថ្លាក្នុង*

ព្រះមានព្រះភាគ បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ ក្នុងកាលជាខាងក្រោយ លោករឭកដល់បុព្វកម្មរបស់ខ្លួន ហើយកើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អាចាដលី អហំ បុប្ផំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អាចាដលី** សេចក្ដីថា ខ្ញុំបានកាន់យកផ្កាប្រទៀងដោយជុំវិញ ឬដោយអើពើ លើកឡើងបូជាព្រះស្តូប ។ បទថា **ឧឡ្លិតំ សុមហាបថេ** សេចក្ដីថា សាង គឺសាងឡើងក្នុងផ្លូវធំ គឺក្នុងផ្លូវកណ្ដាលនគរ ដើម្បីជាទីថ្វាយបង្គំ និងបូជារបស់អ្នកនគរទាំងពួង អធិប្បាយថា សាងរហូតសម្រេច ដោយការងារ មានកតដ្ឋ និងបូកលាបបាយ-អជាដើម ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ព្រោះមានន័យដូចពោលហើយខាងដើម និងមានអត្ថភក់ហើយ ។៚

## អដ្ឋកថានាគសមាលត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បទសញ្ញកត្ថេរាបទានទី ២

[ ៧៤ ] ខ្ញុំបានឃើញស្នាមព្រះបាទ របស់ព្រះតិស្សសម្មាសម្ពុទ្ធ ព្រះអង្គជាព្រះអាទិច្ចពន្ធុ ទ្រង់ជាន់ទុកហើយ ខ្ញុំមានចិត្តត្រេកអរ រីករាយ បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះស្នាមព្រះបាទនោះ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្តីសម្គាល់ក្នុងស្នាមព្រះបាទ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសម្គាល់ក្នុងស្នាមនៃព្រះបាទ ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ឈ្មោះសុមេធៈ ជាស្តេចចក្កពត្តិ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បទសញ្ញកត្ថេរាបទាន ចប់**

# អដ្ឋកថា

## បទសញ្ញកត្ថេរាបទាន

[ ៧៤ ] អបទានរបស់ព្រះបទសញ្ញកត្ថេរ មានពាក្យផ្ដើមថា **អក្កន្តញ្ច បទំ ទិស្វា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះនៃឧបាសក ដែលសម្បូរដោយសទ្ធាមួយកន្លែង ដល់នូវភាវៈជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ ឃើញព្រះចេតិយ គឺស្នាមព្រះបាទដែលព្រះមានព្រះភាគ ទ្រង់ប្រតិស្ឋានដើម្បីអនុគ្រោះ ទើបកុលបុត្តនោះកើតនូវការជ្រះថ្លាហើយ ត្រឹករោមត្រឹស្បែក បានសម្ដែងនូវការគោរពយ៉ាងខ្ពង់ខ្ពស់ ដោយការថ្វាយបង្គំ និងការបូជាជាដើម ដោយបុញ្ញកម្មដែលខ្លួនធ្វើល្អហើយ ក្នុងខេត្តដែលល្អនោះៗឯង កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងស្ថានសួគ៌ សោយទិព្វសុខក្នុងស្ថានសួគ៌នោះ ។ ក្នុងកាលជាខាងក្រោយ មកកើតក្នុងពួកមនុស្ស សោយមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះដែលសម្បូរដោយទ្រព្យសម្បត្តិ ចម្រើនវ័យហើយ កើតនូវសទ្ធា បួសហើយមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ លោកបានប្រាកដនាមថា បទសញ្ញកៈ តាមបុណ្យដែលធ្វើទុកក្នុងកាលមុន ។

ថ្ងៃមួយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អក្កន្តញ្ច បទំ ទិស្វា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អក្កន្តំ** បានដល់ ទ្រង់បានជាន់ទុក គឺបានប្រតិស្ឋាន ។ ការទៅរបស់ព្រះពុទ្ធទាំងពួងក្នុងទីគ្រប់ស្ថាន កម្ពស់អំពីផែនដី ៤ ធ្នាប់ តែព្រះមានព្រះភាគអង្គនេះ ទ្រង់ជ្រាបថា កុលបុត្តនេះ មានសទ្ធា ទើបទ្រង់ប្រតិស្ឋានព្រះចេតិយ គឺស្នាមព្រះបាទ ដោយព្រះតម្រិះថា កុលបុត្តនេះ ចូរឃើញចេតិយ គឺស្នាមជើងនេះ អធិប្បាយថា ព្រោះហេតុនោះ កុលបុត្តនោះ ជ្រះថ្លាក្នុងស្នាមព្រះបាទនោះហើយ ទើបបានធ្វើសក្ការៈ មានការថ្វាយបង្គំ និងបូជាជាដើម ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថាបទសញ្ញកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សុសញ្ញកត្ថេរាបទានទី ៣

[ ៧៥ ] ខ្ញុំឃើញសំពត់បង្សុកូល របស់ព្រះសាស្តា ដែលព្រះអង្គពាក់ទុកលើចុងមែកឈើ លំដាប់នោះ ខ្ញុំធ្វើនូវអញ្ជលី ថ្វាយបង្គំចំពោះសំពត់បង្សុកូល ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់នូវទុគ្គតិ នេះជាផលនៃការសម្គាល់នូវសំពត់បង្សុកូល ។ ក្នុងកប្បទី ៤ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រ ឈ្មោះទុមហរៈ ជាស្តេចចក្កពត្តិ មានកម្លាំងច្រើន មានសមុទ្ទទាំង ៤ ជាព្រំប្រទល់ ជាស្តេចមានជ័យជម្នះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុសញ្ញកត្ថេរាបទាន ចប់

# អដ្ឋកថា

## សុសញ្ញកត្ថេរាបទាន

[ ៧៥ ] អបទានរបស់ព្រះសុសញ្ញកត្ថេរ មានពាក្យផ្ដើមថា **ឧមគ្គេ បំសុកូលិកំ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ កើតនូវសទ្ធា ឃើញសំពត់បំសុកូលចីវររបស់ព្រះមានព្រះភាគដែលព្យួរទុកត្រង់ចុងឈើ មានចិត្តជ្រះថ្លា គិតថា នេះជាទង់ជ័យនៃព្រះអរហន្ត ទើបធ្វើសក្ការៈ មានការថ្វាយបង្គំ និងបូជាជាដើម ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះក៏សោយនូវទេវសម្បត្តិ និងមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដែលសម្បូរដោយទ្រព្យសម្បត្តិ កើតនូវសទ្ធាហើយ បព្វជ្ជា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

លោកបានសម្រេចជាព្រះអរហន្តហើយ រឭកដល់បុញ្ញកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឧមគ្គេ បំសុកូលិកំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ មានវិគ្គហៈដូចតទៅនេះ ឈ្មោះថា **ឧម** ព្រោះអត្ថថា កម្មាត់ គឺញាប់ញ័រ ។ម្យ៉ាងទៀត ឈ្មោះថា **ឧម** ព្រោះអត្ថថា ដុះឡើងធ្វើផ្ទៃអាកាសឲ្យពេញ ។

ឈ្មោះថា **ទុមគ្គ** ព្រោះជាទីបំផុត គឺចុងរបស់ដើមឈើ ។ ត្រង់ចុងនៃឈើនោះ ។ ឈ្មោះថា **បំសុក្កូល** ព្រោះអត្ថថា ទៅ គឺដល់ភាវៈដែលគួរខ្ពើម គឺភាវៈដែលមិនគួរពេញចិត្ត ដូចជាធូលី ។ បំសុកូលនោះឯង ជា **បំសុក្កូលិក** អធិប្បាយថា ខ្ញុំបានឃើញសំពត់បំសុកូលរបស់ព្រះសាស្តាដែលព្យួរត្រង់ចុងឈើ ទើបផ្គងអញ្ជលី ថ្វាយបង្គំ គឺនមស្ការសំពត់បំសុកូលនោះ ។ បទថា **តំ** ត្រឹមតែជានិបាត ។ ពាក្យដ៏សេសក្នុងបទទាំងពួងមានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា សុសញ្ញកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ភិសាលុវទាយកត្ថេរាបទានទី ៤

[ ៧៦ ] ខ្ញុំចូលទៅក្នុងព្រៃធំ ហើយនៅក្នុងព្រៃ បានឃើញព្រះពុទ្ធព្រះនាមវិបស្សី ព្រះអង្គគួរទទួលគ្រឿងបូជា ។ ខ្ញុំបានថ្វាយក្រអៅឈូក និងទឹកសម្រាប់លាងព្រះហស្ត ខ្ញុំថ្វាយបង្គំចំពោះព្រះបាទាដោយត្បូង ហើយបែរមុខទៅកាន់ទិសខាងជើង ដើរចៀសចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយក្រអៅឈូក ក្នុងកាលនោះ ខ្ញុំក៏មិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានជាក្សត្រឈ្មោះភិសសម្មតៈ ជាស្តេចចក្កពត្តិ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិសាលុវទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ភិសាលុវទាយកត្ថេរាបទាន ចប់

ភាណវារទី ៦ ចប់

# អដ្ឋកថា

## ភិសាលុវទាយកត្ថេរាបទាន

[ ៧៦ ] អបទានរបស់ព្រះភិសាលុវទាយកត្ថេរ មានពាក្យផ្ដើមថា **កាននំ វនមោគ្គយ្ហ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី នៅក្នុងព្រៃក្បែរហិមវន្តប្បទេស មានឫសឈើ និងផ្លែឈើជាអាហារ ឃើញព្រះមានព្រះភាគព្រះនាមវិបស្សី យាងមកដើម្បីវិវេក មានចិត្តជ្រះថ្លា បានថ្វាយក្រអៅឈូក ៥ ។ ព្រះមានព្រះភាគ បានសោយខណៈដែលកុលបុត្តនោះកំពុងមើលនោះឯង ដើម្បីញុំាងចិត្តរបស់កុលបុត្តនោះឲ្យជ្រះថ្លា ។ ដោយចិត្តជ្រះថ្លានោះ កុលបុត្តនោះអស់ជីវិតហើយ បានសោយសម្បត្តិក្នុងទេវតាជាន់តុសិតជាដើម ក្រោយអំពីនោះមកសោយមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង មានការដល់ព្រមដោយទ្រព្យសម្បត្តិ លះសម្បត្តិនោះហើយបួសក្នុងសាសនា មិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត ។

បន្ទាប់អំពីនោះ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **កាននំ វនមោគយ្ហ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ។

បទថា **វសាមិ វិបិនេ អហំ** ក្លាប់សេចក្តីថា ខ្ញុំបាននៅយ៉ាងស្ងាត់ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៙

**អដ្ឋកថាភិសាលុវទាយកត្ថេរាបទាន ចប់**

**ភាណវារទី ៦ ចប់**

# សុត្តន្តបិដក

## ឯកសញ្ញកត្ថេរាបទានទី ៩

[ ៧៧ ] ព្រះអគ្គសាវ័ក របស់ព្រះវិបស្សីសម្មាសម្ពុទ្ធ មាននាម ជាខណ្ឌត្ថេរ ជាអ្នកគួរទទួលនូវគ្រឿងបូជារបស់សត្វលោក ខ្ញុំបានថ្វាយភិក្ខាមួយមុខ ( ចំពោះអគ្គសាវ័កនោះ ) ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជានរាសភៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិ ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ នេះជាផលនៃការថ្វាយភិក្ខាមួយមុខ ។ ក្នុងកប្បទី ៤០ អំពីកប្បនេះ ខ្ញុំបានជាក្សត្រឈ្មោះវរុណៈ បានជាស្តេចចក្កពត្តិ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកសញ្ញកត្ថេរាបទាន ចប់

# អដ្ឋកថា

## ឯកសញ្ញកត្ថេរាបទាន

[ ៧៧ ] *អបទានរបស់ព្រះឯកសញ្ញកត្ថេរ មានពាក្យផ្ដើមថា* **ខណ្ឌោ នាមាសិ នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ មានចិត្តជ្រះថ្លាក្នុងព្រះរតនត្រ័យ ឃើញព្រះអគ្គសាវក ព្រះនាមខណ្ឌៈ របស់ព្រះសាស្ដាអង្គនោះ កំពុងត្រាច់បិណ្ឌបាត បានចាត់ចែងបិណ្ឌបាតប្រគេន ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយទេវសម្បត្តិ និងមនុស្សសម្បត្តិ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ក្នុងក្រុងសាវត្ថី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា បាននូវសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ លោកប្រាកដឈ្មោះថា ឯកសញ្ញកត្ថេរ ព្រោះហេតុដែលថ្ងៃមួយ លោកដាក់ចិត្តនូវសញ្ញាក្នុងបិណ្ឌបាត ហើយបាននូវគុណវិសេស ។*

*ក្នុងកាលជាខាងក្រោយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **ខណ្ឌោ នាមាសិ នាមេន** *ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា* **ខណ្ឌោ** *ជាឈ្មោះរបស់ព្រះអគ្គសាវកអង្គនោះ ព្រោះលោកទម្លាយកិលេស បានជាសមុច្ឆេទ ។ ពាក្យដ៏សេសក្នុងទីទាំងពួងមានអត្ថងាយយល់ហើយ ។*

# សុត្តន្តបិដក

## តិណសន្ថារទាយកត្ថេរាបទានទី ៦

[ ៧៨ ] មានស្រះកើតឯងធំមួយ នៅក្នុងទីជិតនៃព្រៃហិមពាន្ត ជាស្រះដេរដាសដោយឧប្បលជាត ឈ្មោះសត្តបត្ត: ជាលំនៅនៃបក្សីផ្សេងៗ ។ ខ្ញុំងូតផង ផឹកផង ក្នុងស្រះនោះ ហើយនៅក្នុងទីមិនឆ្ងាយ ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រសើររបស់ពួកសមណ: កំពុងស្តេចទៅក្នុងអាកាស ។ ព្រះសាស្តា ព្រះអង្គប្រសើរផុតក្នុងលោក បានជ្រាបបំណងរបស់ខ្ញុំហើយ ទ្រង់យាងចុះអំពីអាកាស មកស្ថិតលើផែនដី ក្នុងខណ:នោះ ។ ខ្ញុំបានយកកណ្តៀវប្រូតស្មៅមកថ្វាយ ជាគ្រឿងគង់ ឯព្រះមានព្រះភាគព្រះអង្គជាម្ចាស់នៃលោកទាំង ៣ ជានាយក គង់លើស្មៅនោះ ។ ខ្ញុំបានញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះលោក-នាយក រួចដើរថយក្រោយ សម្លឹងមើលព្រះពុទ្ធ ជាមហាមុនី ។ ខ្ញុំក៏បានទៅកើតឯស្ថាននិម្មានរតី ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាល ។ ក្នុងកប្បទី ២ អំពីកប្បនេះ ខ្ញុំបានជាក្សត្រ ឈ្មោះមិត្តសម្មត: ជាស្តេចចក្កពត្តិ

មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសន្ថារទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## តិណសន្ថារទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## តិណសន្ថារទាយកត្ថេរាបទាន

[ ៧៨ ] អបទានរបស់ព្រះតិណសន្ថារទាយកត្ថេរ មានពាក្យផ្ដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ព្រោះលោកកើតមុនពុទ្ធុប្បាទកាល ទើបលះបង់ការគ្រប់គ្រងផ្ទះ ចេញបួសជាតាបស អាស្រ័យនៅក្បែរស្រះមួយកន្លែង មិនឆ្ងាយអំពីព្រៃហិមពាន្ត ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមតិស្សៈ យាងទៅតាមអាកាស ដើម្បីអនុគ្រោះកុលបុត្តនោះ ។ កាលនោះឯង តាបសនោះឃើញព្រះមានព្រះភាគអង្គនោះ ចុះអំពីអាកាស ប្រថាប់ឈរ មានចិត្តជ្រះថ្លា ទើបប្រូតស្មៅធ្វើជាសន្ថត ថ្វាយព្រះសាស្ដាប្រថាប់គង់ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ដោយការរាប់អាន និងការអើពើយ៉ាងខ្ពង់ខ្ពស់ បង្អោនកាយហើយ ចៀសចេញទៅ កុលបុត្តនោះ តាំងនៅដរាបដល់អស់អាយុ ច្យុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិច្រើនយ៉ាង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

កាលខាងក្រោយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ។ ក្នុងបទថា **មហាជាតស្សរោ** នេះ មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា **ស្រះ** ព្រោះជាទីត្រាច់ទៅនៃសត្វជើងពីរ និងសត្វជើង ៤ ជាដើម ដែលត្រូវការទឹកផឹក ។ ម្យ៉ាងទៀត ឈ្មោះថា **ស្រះ** ព្រោះជាទីហូរមករួមគ្នានៃស្ទឹង និងជ្រោះជាដើម ។ ស្រះនោះធំផង កើតឯងផង ព្រោះហេតុនោះ ទើបឈ្មោះថា **មហាជាតស្រះ** ។ គប្បីឃើញថា លោកហៅថា **មហាជាត-ស្រះ** ព្រោះមិនប្រាកដឈ្មោះ ដូចអនោតត្តស្រះ និងស្រះឈ្មោះឆទ្ទន្តជាដើម ។ បទថា **សតបត្តេហិ សញ្ឆន្នោ** សេចក្តីថា មាន ១០០ ត្របក ព្រោះក្នុងផ្កាមួយ មានត្របក ១០០ ។ ដេរដាស គឺកុះករទៅដោយផ្កាឈូក-ស ១០០ ត្របក ។ បទថា **នានាសកុណមាលយោ** សេចក្តីថា សត្វច្រើនប្រភេទ ដូចជាហង្ស មាន់ លលក និងពស់ទឹកជាដើម សត្វនីមួយៗ យំ គឺធ្វើសំឡេង ព្រោះហេតុនោះ ទើបស្រះនោះ ជាទីនៅ គឺជាទីទទួលនូវបក្សីទាំងឡាយ ដែលបានឈ្មោះថា សកុណៈដូច្នេះ ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថាតិណសន្ថរទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សូចិទាយកត្ថេរាបទានទី ៧

[ ៧៩ ] ក្នុងកប្បទី ៣០០០០ ព្រះសម្ពុទ្ធជានាយកនៃលោក ព្រះនាមសុមេធៈ មានព្រះលក្ខណៈ ៣២ ប្រការ ដ៏ប្រសើរ ( ឧប្បត្តិឡើង ) ។ ខ្ញុំបានប្រគេនម្ជុល ៥ ចំពោះព្រះសុមេធៈ ជាធំជាងសត្វជើងពីរនោះ ព្រះអង្គមានសម្បុរដូចមាស មានព្រះហឫទ័យនឹងធឹង ដើម្បីប្រយោជន៍ដល់ការដេរចីវរ ។ ប្រាជ្ញាញាណដ៏មុតរហ័សផង ជាគ្រឿងឃើញច្បាស់នូវអត្ថដ៏ល្អិតផង ជាសុខសប្បាយផង បានកើតឡើងដល់ខ្ញុំ ព្រោះការថ្វាយនូវម្ជុលនោះឯង ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ។ ខ្ញុំបានជាព្រះរាជា ៤ ដង ឈ្មោះទិបទាធិបតីដូចគ្នា ជាស្តេចចក្កពត្តិ ទ្រង់មានកម្លាំងច្រើនបរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសូចិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សូចិទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## សូចិទាយកត្ថេរាបទាន

[ ៧៩ ] អបទានរបស់ព្រះសូចិទាយកត្ថេរ មានពាក្យផ្ដើមថា **តឹសកប្បសហស្សម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសុមេធៈ កើតក្នុងផ្ទះមានត្រកូលមួយ កន្លែង ចម្រើនវ័យហើយ បានថ្វាយម្ជុល ៥ ដើម្បីធ្វើចីវរកម្ម ដល់ព្រះមានព្រះភាគ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយបុណ្យក្នុងទេវតានិងមនុស្សទាំងឡាយត្រាច់ទៅ ប្រាកដជាជាអ្នកមានបញ្ញាមុតស្រួចក្នុងភពដែលខ្លួនកើតហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បព្វជ្ជាហើយ សម្រេចអរហត្ត ក្នុងខណៈកោរសក់នោះឯង ព្រោះលោកមានបញ្ញាមុតស្រួច ។ ក្នុងកាលជាខាងក្រោយ លោកពិចារណាឃើញនូវបុណ្យនោះ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **តឹសកប្បសហស្សម្ហិ** ដូច្នេះជាដើម ។ ពាក្យដែលជាលំដាប់ក្នុងគាថានេះ មានអត្ថដ៏ងាយហើយ ។ ក្នុងបទថា **បញ្ចសូចី មយា ទិន្នា** មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា **សូចិ** ព្រោះជាអ្នកដេរ គឺធ្វើប្រហោង បានដល់ចោះ អធិប្បាយថា ខ្ញុំថ្វាយម្ជុល ៥ ដើម គឺមានចំនួន ៥ ។ បទដ៏សេសមានអត្ថដ៏ងាយហើយ ៕

# សុត្តន្តបិដក

## ចាដលិបុប្ផិយត្ថេរាបទានទី ៨

[ ៨០ ] ( ខ្ញុំបានឃើញ ) ព្រះសម្ពុទ្ធ ព្រះអង្គមានសម្បុរដូចជាសម្បុរនៃមាស កំពុងយាងទៅក្នុងចន្លោះរានផ្សារ មានព្រះលក្ខណៈ ៣២ ប្រការដ៏ប្រសើរ ដូចជាចេតិយមាស ។ ក្នុងគ្រានោះ ខ្ញុំកើតជាសេដ្ឋិបុត្ត ជាសុខុមាលជាត ស្ថិតនៅក្នុងសេចក្តីសុខ បានដាក់ផ្កាប្រនៀងក្នុងថ្នក់ហើយ បង្អោនផ្កានោះ ( ថ្វាយព្រះអង្គ ) ។ ខ្ញុំជាអ្នកមានចិត្តរីករាយស្រស់ស្រាយ បានបូជាផ្កានោះ រួចខ្ញុំនមស្ការចំពោះព្រះពុទ្ធព្រះនាមតិស្សៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ទ្រង់ជាទីពឹង ជាវិសុទ្ធិទេពរបស់ពួកជន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ ក្នុងកប្បទី ៦៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មានព្រះនាមថា អភិសម្មតៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចាដលិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## ចាជលិបុប្ផិយត្ថេរាបទាន

[ ៨០ ] អបទានរបស់ព្រះចាជលិបុប្ផិយត្ថេរ មានពាក្យផ្តើមថា **សុវណ្ណវណ្ណំ សម្ពុទ្ធំ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតជាបុត្តនៃសេដ្ឋីក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជាអ្នកស្គាល់កុសល និងអកុសល ជ្រះថ្លាក្នុងព្រះសាស្តា កាន់យកផ្កាប្រទៀងទៅបូជាព្រះសាស្តា ដោយបុញ្ញកម្មនោះ កុលបុត្តនោះសោយសុខសម្បត្តិដ៏ច្រើន អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សុវណ្ណវណ្ណំ សម្ពុទ្ធំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អន្តរាបណេ** សេចក្តីថា ឈ្មោះថា **អាបណា**

ព្រោះជាទីដាក់ គឺលក់ ចំណាយនូវវត្ថុ មានប្រាក់ និងមាសជាដើម ឈ្មោះជា **អន្តរាបណា** ព្រោះមានផ្លូវច្នងទៅក្នុងរវាងរានផ្សារនោះ អធិប្បាយថា ខ្ញុំឃើញព្រះសម្ពុទ្ធ មានវណ្ណៈដូចពណ៌នៃមាស ដូចគ្នានឹងដុំមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ទើបបូជាដោយផ្កាប្រទៀង ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាចាដលិបុប្ផិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បិតញ្ញលិយត្ថេរាបទានទី ៩

[ ៨១ ] ក្នុងភពមុន ខ្ញុំជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធ មានព្រះគុណ ៣២ ដ៏ប្រសើរ ក្នុងទីនោះ ។ ខ្ញុំធ្វើអញ្ជលីចំពោះព្រះពុទ្ធ ព្រះអង្គគង់នៅលើកម្រាលស្លឹកឈើ ដែលខ្ញុំចាត់ចែងទុក ក្នុងទីមិនឆ្ងាយអំពីទីនោះ ហើយខ្ញុំបែរមុខឆ្ពោះទៅទិសខាងកើត ដើរចៀសចេញទៅ ។ លំដាប់នោះ ការធ្លាក់ចុះរន្ទះក៏ធ្លាក់ត្រូវក្បាលខ្ញុំ ក្នុងកាលនោះ ខ្ញុំក៏បានធ្វើអញ្ជលីម្តងទៀតក្នុងកាលទៀបស្លាប់ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវអញ្ជលីកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអញ្ជលិកម្ម ។ ក្នុងកប្បទី ៥៤ ខ្ញុំបានជាស្តេចចក្កពត្តិ ព្រះនាមមិគកេតុ មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិតញ្ញលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បិតញ្ញលិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បិតញ្ជលិយត្ថេរាបទាន

[ ៨១ ] អបទានរបស់ព្រះបិតញ្ជលិយត្ថេរ មានពាក្យផ្ដើមថា **មិគលុទ្ទោ បុរេ អាសឹ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពដែលខ្លួនកើតនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងកំណើតព្រាន ព្រោះកម្មណាមួយដែលខ្លួនធ្វើក្នុងកាលមុនកាត់ផ្ដាច់ ដល់នូវភាពជាអ្នកដឹងក្ដីហើយ សម្លាប់សត្វមានម្រឹគ និងជ្រូកជាដើម ចិញ្ចឹមជីវិតនៅក្នុងព្រៃ ដោយកម្មរបស់ព្រាន ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមតិស្សៈ បានយាងទៅកាន់ព្រៃហិមពាន្ត ដើម្បីអនុគ្រោះកុលបុត្តនោះ កុលបុត្តនោះឃើញព្រះមានព្រះភាគអង្គនោះ រុងរឿងដោយព្រះលក្ខណៈ ៣២ ប្រការ និងដោយព្រះរស្មីប្រមាណមួយព្យាម មួយអន្លើដោយអនុព្យញ្ជនៈ ៨០ ហើយកើតនូវសោមនស្ស ទើបថ្វាយបង្គំ ហើយអង្គុយលើកម្រាលស្លឹកឈើ ។ ខណៈនោះ ភ្លៀងធ្លាក់ រន្ទះក៏ធ្លាក់ចុះមក ។ បន្ទាប់អំពីនោះ ក្នុងសម័យដែលជិតស្លាប់ កុលបុត្តនោះ រឭកដល់ព្រះពុទ្ធ បានផ្គងអញ្ជលីម្ដងទៀត ។ ដោយបុញ្ញកម្មនោះ ទើបកុលបុត្តនោះ មិនបានទទួលផលរបស់បាបកម្ម ព្រោះធ្វើកុសលក្នុងស្រែដែលល្អ ទៅកើតក្នុងស្ថានសួគ៌ សោយសម្បត្តិក្នុងកាមាវចរសួគ៌ និងសោយមនុស្សសម្បត្តិក្នុងមនុស្សទាំងឡាយ តមក ក្នុង

ពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្តា ដោយវាសនាដែលខ្លួនធ្វើក្នុងកាលមុន បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **មិគលុទ្ធោ បុរេ អាសឹ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **មិគលុទ្ធោ** សេចក្តីថា ឈ្មោះថា **មិគលុទ្ធ** ព្រោះចូលដល់ការសម្លាប់ម្រឹគ ។ ឈ្មោះថា **មិគ** ព្រោះទៅ គឺស្ទុះទៅ រត់ទៅដោយរហ័ស គឺដោយកម្លាំងដ៏រហ័សដូចខ្យល់ ។ ឈ្មោះថា **មិគលុទ្ធ** ព្រោះជាបុគ្គលលោភ ឃោរឃៅ ឃើញតែខាងបានក្នុងការសម្លាប់ម្រឹគទាំងនោះ អធិប្បាយថា កាលមុន គឺក្នុងសម័យដែលបានឃើញព្រះមានព្រះភាគ ខ្ញុំនោះបានជាព្រាន ។

បទថា **អរញ្ញេ កាននេ** សេចក្តីថា ឈ្មោះថា **អរញ្ញ** ព្រោះជាទីទៅ គឺត្រាច់ទៅរបស់ពួកម្រឹគ ។ ម្យ៉ាងទៀត ឈ្មោះថា **អរញ្ញ** ព្រោះជាទីត្រេកអរដោយទូទៅ គឺដោយជុំវិញនៃសប្បុរស អ្នកដល់នូវធម៌ដែលជាមហាសារៈ មានព្រះពុទ្ធ និងព្រះបច្ចេកសម្ពុទ្ធជាដើម ដែលត្រេកអរក្នុងវិវេក ។ ឈ្មោះថា **កានន** ព្រោះជាទីដែលក្អែកទាំងឡាយបន្លឺសំឡេង គឺធ្វើសំឡេង បញ្ចេញសំឡេងយំដ៏គួរស្អប់ គួរខ្លាច ភ្ជាប់សេចក្តីថា កាលមុន ខ្ញុំកើតជាព្រាន នៅក្នុងព្រៃនោះ ។

បណ្ដាបទទាំងនោះ បទថា **អទ្ទសំ សមុទ្ទំ** សេចក្ដីថា ខ្ញុំឃើញ គឺបាន ឃើញព្រះសមុទ្ទដែលយាងចូលទៅក្នុងទីនោះ គឺព្រៃនោះ ។ បានឃើញ គឺ មាននៅខាងមុខមិនឆ្ងាយ ព្រោះហេតុនោះ ទើបបញ្ជូនចក្ខុវិញ្ញាណដែលដល់ ព្រមដោយកាយវិញ្ញាណឲ្យជាបុរេចារិក ទៅតាមក្រសែនៃមនោទ្វារ ។

បទថា **គតោ មេ អសនីចាតោ** សេចក្ដីថា ឈ្មោះថា **អសនី** ព្រោះ បន្ទឺ គឺគ្រហឹមធ្លាក់ចុះដោយជុំវិញ ការធ្លាក់ចុះនៃរន្ទះ ឈ្មោះថា **អសនីចាត** បានដល់ **ទេវទណ្ឌ** ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាបិតញ្ញលិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## តីណិបទុមិយត្ថេរាបទានទី ១០

[ ៨២ ] គ្រានោះ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់មានឥន្ទ្រិយទូន្មានហើយ ដែលសាវកមានឥន្ទ្រិយទូន្មានចោមរោម ទ្រង់ស្តេចចេញអំពីទីក្រុង ។ គ្រានោះ ខ្ញុំជានាយមាលាការ ក្នុងក្រុងហង្សវតី បានកាន់ផ្កាឈូក ៣ ដែលជាផ្កាដ៏ឧត្តម ក្នុងពួកផ្កានោះ ។ ក្នុងគ្រានោះ ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គមានធូលី គឺកិលេសប្រាសចេញហើយ ក្នុងចន្លោះផ្សារត្រង់ផ្លូវជួបគ្នានោះ លុះឃើញព្រះសម្ពុទ្ធហើយ បានគិតយ៉ាងនេះថា

អញមានប្រយោជន៍ដូចម្តេច ដោយផ្កានេះ ដែលអញថ្វាយដល់ព្រះរាជា ( ព្រោះបើថ្វាយ ) អញបានតែត្រឹមស្រុក ១ ឬខេត្តរបស់ស្រុក ១ ឬទ្រព្យមួយពាន់ប៉ុណ្ណោះ ។ បើអញបូជាព្រះលោកនាថ ជាវីរបុរស អ្នកទូន្មាននូវបុគ្គលដែលមិនទាន់ទូន្មាន ព្រះអង្គនាំមកនូវសុខ ដល់សត្វទាំងពួងវិញ រមែងបាននូវទ្រព្យឧត្តម គឺអមតៈ ។ លុះខ្ញុំគិតយ៉ាងនេះហើយ ក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា កាលនោះ ខ្ញុំក៏បានយកផ្កាឈូកក្រហម ៣ បោះឡើងទៅឰដ៏អាកាស ។ ផ្កាទាំងនោះ ដែលខ្ញុំគ្រាន់តែបោះឡើងទៅ ក៏ទើរនៅលើអាកាស មានទងឡើងលើ មានមុខសំយុងចុះមកក្រោម បាំងនៅខាងលើព្រះសិរ្សៈនៃព្រះពុទ្ធ ក្នុងទីនោះ ។ ពួកមនុស្សណាមួយ បានឃើញហើយ ក៏នាំគ្នាញុំាងសំឡេងហ៊ោ

គឺកកង ឲ្យប្រព្រឹត្តទៅ ទាំងពួកទេវតា ក៏ញ៉ាំងសាធុការឲ្យប្រព្រឹត្តទៅ ក្នុងអាកាសថា

ហេតុអស្ចារ្យ កើតហើយក្នុងលោក យើងទាំងអស់គ្នានឹងស្តាប់ព្រះធម៌ តាមហេតុភេទនៃព្រះពុទ្ធ ជាបុគ្គលប្រសើរ តាមហេតុភេទនៃផ្កាទាំងឡាយ ។ ឯព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់ឈរក្នុងថ្នល់ ត្រាស់នូវគាថាទាំងនេះថា

មាណពណា បានបូជាចំពោះព្រះពុទ្ធ ដោយផ្កាឈូកក្រហម តថាគតនឹងសម្តែងសរសើរនូវមាណពនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ មាណពនេះ នឹងរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប នឹងបានជាធំជាងទេវតា សោយទេវរាជសម្បត្តិ អស់ ៣០ ដង ។ វិមានឈ្មោះមហាវិត្ថារិកៈ មានកម្ពស់ ៣០០ យោជន៍ ទទឹង ១៥០ យោជន៍ នឹងផុសឡើង ( សម្រាប់មាណពនេះ ) ក្នុងខណៈនោះ ។ ផ្ទះប្រធានទាំងឡាយ មានប្រមាណ ៤ សែន ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ សឹងប្រដាប់ដោយសេយ្យាសនៈដ៏ប្រសើរ ដែលបុញ្ញកម្មនិម្មិតល្អហើយ ។ ពួកស្រីអប្សរប្រមាណមួយសែនកោដិ ជាអ្នកឈ្លាសក្នុងការរាំ និងការច្រៀងផង វាងវៃក្នុងការប្រគំផង រមែងចោមរោមត្រៀបត្រាជានិច្ច ។ ក្នុងគ្រានោះ ភ្លៀងជាវិការនៃ

ផ្កាទិព្វ មានពណ៌ក្រហម ក៏បង្អុរចុះលើវិមានដ៏ប្រសើរ ប្រាកដដូច្នោះ ដែលកុះករដោយពួកនារី ។ ផ្កាឈូកក្រហម ប៉ុនកង់រទេះ សំយុងចុះត្រង់សសរជញ្ជាំងផង ត្រង់ដៃកែវផង ត្រង់មេទ្វារផង ត្រង់ខ្លោងទ្វារផង ក្នុងខណៈនោះ ។ ផ្កាឈូកទាំងនោះ ក្រាលបិទបាំងនូវលំនៅ នេះជាវិមានប្រសើរ ដែលព្រោងព្រាតដោយស្លឹកឈើគ្រប់ពណ៌ វិលវង់នៅខាងក្នុងខណៈនោះ ។ ផ្កាឈូកក្រហមសុទ្ធទាំងនោះ ព័ទ្ធព័ន្ធនូវលំនៅមានប្រមាណ ១០០ យោជន៍ជុំវិញ ហើយផ្សាយនូវក្លិនជាទិព្វ ។ មាណពនេះ នឹងបានជាស្តេចចក្កពត្តិ អស់ ៧៥ ដង ( នឹងសោយ ) បទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ។ មាណពនោះ នឹងបានបរិភោគនូវសម្បត្តិទាំងពីរ មិនមានចង្រៃ ឧបទ្រព្យ លុះដល់ទីបំផុត នឹងបានដល់ព្រះនិព្វាន ។

ឱព្រះពុទ្ធ ខ្ញុំបានឃើញច្បាស់ហើយ ពាណិជ្ជកម្ម ខ្ញុំបានប្រកបហើយ ខ្ញុំបូជានូវផ្កាឈូក ៣ ហើយ ទើបបាននូវសម្បត្តិបីប្រការ ។ ក្នុងថ្ងៃនេះ ផ្កាឈូកក្រហមរីកល្អ បាំងលើក្បាលខ្ញុំ ដែលបាននូវធម៌ រូបស្រឡះ ដោយប្រការទាំងពួង ។ កាលព្រះសាស្តា ព្រះនាមបទុមុត្តរៈ កំពុងសម្តែងនូវបុព្វកម្មរបស់ខ្ញុំ ធម្មាភិសម័យ គឺមគ្គផល ក៏កើតមានដល់ពួកសត្វ មានប្រមាណច្រើន ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន

បូជាផ្កា ចំពោះព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្កាឈូក ៣ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រម្លើងចេញហើយ អាសវៈទាំងពួងក៏អស់រលីងហើយ ក្នុងកាលឥឡូវនេះ ភពថ្មីមិនមានទេ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណិបទុមិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តីណិបទុមិយត្ថេរាបទាន ចប់**

## ឧទ្ទាន

នាគសមាលត្ថេរាបទាន ១ បទសញ្ញកត្ថេរាបទាន ១ សុសញ្ញកត្ថេរាបទាន ១ ភិសាលុវទាយកត្ថេរាបទាន ១ ឯកសញ្ញកត្ថេរាបទាន ១ តិណាសន្ថារទាយកត្ថេរាបទាន ១ សូចិទាយកត្ថេរាបទាន ១ បាដលិបុប្ផិយត្ថេរាបទាន ១ ឋិតញ្ជលិយត្ថេរាបទាន ១ តីណិបទុមិយត្ថេរាបទាន ១ មានគាថា ៧៥ ។

**នាគសមាលវគ្គទី ៨ ចប់**

# អដ្ឋកថា

## តីណិបទុមិយត្ថេរាបទាន

[ ៨២ ] អបទានរបស់ព្រះតីណិបទុមិយត្ថេរ មានពាក្យផ្តើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះនៃត្រកូលរបស់នាយមាលាការ ក្នុងហង្សវតីនគរ ចម្រើនវ័យហើយ ធ្វើកម្មនៃនាយមាលាការ ។ ថ្ងៃមួយ កាន់យកផ្កាដែលកើតក្នុងទឹក និងកើតលើគោកសន្ធឹកសន្ធាប់ បំណងនឹងគាល់ព្រះរាជា គិតយ៉ាងនេះថា ព្រះរាជាឃើញផ្កានេះហើយ ជ្រះថ្លា គប្បីឲ្យទ្រព្យ ១ ពាន់ ឬស្រុកជាដើម ចំណែកអញបូជាព្រះលោកនាថ រមែងបានទ្រព្យ គឺអមតនិព្វាន ក្នុងពីរយ៉ាងនេះ អ្វីជាផលល្អដល់អញ ដូច្នោះ អញគួរបូជាព្រះមានព្រះភាគ ហើយញុំាងសគ្គសម្បត្តិនិងនិព្វានសម្បត្តិឲ្យសម្រេច ដូច្នេះហើយ ទើបកាន់យកផ្កាពណ៌ក្រហម ៣ ដែលមានពណ៌ល្អក្រៃលែងទៅបូជា ។ ផ្កាទាំងនោះ អណ្តែតទៅបាំងខាងលើអាកាស ។ អ្នកនគរ កើតអស្ចារ្យដែលមិនធ្លាប់មាន ទើបបោះផ្ទាំងសំពត់ ១ ពាន់ឡើងទៅ ។ ព្រះមានព្រះភាគទ្រង់ឃើញដូច្នោះ ទើបទ្រង់ធ្វើអនុមោទនា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយសម្បត្តិទាំងក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលគហបតី ចម្រើនវ័យហើយ ជ្រះថ្លា

ក្នុងព្រះសាស្តា ស្តាប់ធម៌ហើយ កើតនូវសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះជាដើម ។ សេចក្តីនៃពាក្យនោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។ បទថា **សព្វធម្មាន បារគូ** សេចក្តីថា លោកដល់នូវត្រើយនៃលោកុត្តរធម៌ ៩ គឺព្រះនិព្វាន បានដល់ ទ្រង់ធ្វើឲ្យប្រចក្សហើយ ។ បទថា **ទន្តោ ទន្តបរិវុតោ** សេចក្តីថា ទ្រង់ទូន្មានកាយ និងវាចាជាដើមដោយព្រះអង្គឯង ចោមរោមទៅដោយសាវកទាំងឡាយ ដែលព្រះសាស្តាទ្រង់តែងតាំងក្នុងតំណែងឯតទគ្គៈ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ព្រោះមានពាក្យសម្ពន្ធគ្នា ។៚

**អដ្ឋកថាតីណបទុមិយត្ថេរាបទាន ចប់**

**នាគសមាលវគ្គទី ៨ ចប់**

# សុត្តន្តបិដក

# តិមិរបុប្ផិយវគ្គទី ៩

## តិមិរបុប្ផិយត្ថេរាបទានទី ១

[ ៨៣ ] ខ្ញុំដើរទៅកាន់ទីបណ្ដោយខ្សែទឹក ក្បែរច្រាំងស្ទឹងចន្ទភាគា ក៏បានឃើញព្រះសមណសម្ពុទ្ធ ព្រះអង្គកំពុងគង់ មានព្រះកាយស្អាតថ្លា មិនមានសៅហ្មង ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គនោះ ក្នុងគ្រានោះ ខ្ញុំក៏គិតយ៉ាងនេះថា ព្រះពុទ្ធនេះ ព្រះអង្គឆ្លងរួចហើយ នឹងញុំាងសត្វឲ្យឆ្លងផង ព្រះពុទ្ធនេះ មានឥន្ទ្រិយទូន្មានហើយ នឹងទូន្មាន ( នូវពួកសត្វ ) ផង ។ ព្រះអង្គជាអ្នកស្រស់ស្រាយ នឹងញុំាងសត្វឲ្យស្រស់ស្រាយផង ព្រះអង្គជាអ្នកស្ងប់រម្ងាប់ នឹងញុំាងសត្វឲ្យស្ងប់រម្ងាប់ផង ព្រះអង្គរលត់ទុក្ខហើយ នឹងញុំាងសត្វឲ្យរលត់ផង ។ លុះខ្ញុំគិតយ៉ាងនេះហើយ ទើបកាន់យកនូវផ្កាតិមិរព្រឹក្ស ហើយព្រោចទៅលើព្រះសិរ្សៈនៃព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ក្នុងកាលនោះ ។ ខ្ញុំផ្គងអញ្ជលីធ្វើប្រទក្សិណ ចំពោះព្រះអង្គ ហើយថ្វាយបង្គំព្រះបាទារបស់ព្រះសាស្ដា រួចដើរចេញទៅកាន់ទិសដទៃ ។ ស្ដេចម្រឹគបាន

ដេញខាំខ្ញុំ ដែលកំពុងតែដើរទៅ អស់កាលមិនយូរប៉ុន្មាន ខ្ញុំកាល រត់ទៅតាមទីទៀបជ្រោះ ក៏ធ្លាក់ទៅក្នុងជ្រោះនោះឯង ។ ក្នុងកប្ប ទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាល នោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥៦ ខ្ញុំបានជាស្តេចចក្កពត្តិ ៧ ជង ព្រះនាមមហារហៈ ទ្រង់មាន កម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិមិរបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិមិរបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា
# តិមិរបុប្ផិយវគ្គទី ៩

## តិមិរបុប្ផិយត្ថេរាបទាន

[ ៨៣ ] អបទានរបស់ព្រះតិមិរបុប្ផិយត្ថេរ មានពាក្យផ្ដើមថា **ចន្ទភាគានទីតីរេ** ដូច្នេះ ។

អ្វីជាឧប្បត្តិហេតុ ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងកាមទាំងឡាយ ទើបលះនូវការគ្រប់គ្រងផ្ទះ បួសជាតាបស នៅក្បែរស្ទឹងចន្ទភាគា ។ ព្រោះលោកជាអ្នកប្រាថ្នាវិវេក ទើបទៅកាន់ព្រៃហិមពាន្ត ឃើញព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ប្រថាប់គង់ហើយ ទើបថ្វាយបង្គំ ជ្រះថ្លាក្នុងគុណរបស់ព្រះមានព្រះភាគអង្គនោះ ទើបនាំយកផ្កាតិមិរព្រឹក្ស ( ផ្កាប្រមាត់ខ្វាឃ្មុំ ) មកបូជា ។ ដោយបុព្វកម្មនោះ កុលបុត្តនោះ សោយនូវសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ អន្ទោលទៅ ( ក្នុងសង្សារ ) ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ចន្ទភាគានទីតីរេ** ដូច្នេះជាដើម ។ សេចក្តីនៃពាក្យនោះ ខ្ញុំពោលហើយខាងដើមនោះឯង ។ បទថា **អនុសោតំ វជាមហំ** សេចក្តីថា ខ្ញុំត្រាច់ទៅ គឺដើរទៅ បានដល់ នៅក្នុងទីនោះៗ តាមខ្សែទឹកដែលហូរទិសខាងត្បូង ព្រោះជិតស្ទឹង ជាទីគួរត្រេកអរ ក្នុងទីគ្រប់ស្ថាន ជាទីគួររីករាយ ។ បទថា **និសិន្នំ សមណំ និស្វា** សេចក្តីថា ខ្ញុំបានឃើញព្រះសម្មាសម្ពុទ្ធ ពោល គឺព្រះសមណៈ ព្រោះជាអ្នកស្ងប់បាប គឺព្រោះជាអ្នកធ្វើបាបឲ្យរីងស្ងួត ។

បទថា **ឯវំ ចិន្តេសហំ តទា** សេចក្តីថា ព្រះមានព្រះភាគអង្គនេះទ្រង់ឆ្លងផុតហើយ និងញុំាងសត្វទាំងពួងឲ្យឆ្លងផុតចាកសង្សារ ព្រះមានព្រះភាគអង្គនេះ ទ្រង់ទូន្មានព្រះអង្គដោយកាយទ្វារហើយ ទ្រង់ទូន្មានសត្វដទៃផងដែរ ។

អធិប្បាយថា ក្នុងកាលនោះ ខ្ញុំគិតយ៉ាងនេះថា ព្រះមានព្រះភាគអង្គនេះ ទ្រង់ស្រស់ស្រាយ គឺទ្រង់ល្ហែល្ហើយព្រះហឫទ័យ បានដល់ ទ្រង់ឆ្លងផុតចាកការក្តៅក្រហាយ គឺកិលេសហើយ ទ្រង់នាំសត្វទាំងពួងឲ្យល្ហែល្ហើយចិត្ត គឺឲ្យដល់នូវការស្ងប់ ។ ទ្រង់ស្ងប់ឯងហើយ គឺមានកាយចិត្តស្ងប់ហើយ នាំសត្វដទៃឲ្យដល់នូវការស្ងប់កាយ ស្ងប់ចិត្តផង ។ ទ្រង់ឆ្លងផុតហើយ គឺឆ្លងផុតចាកសង្សារហើយ នាំសត្វដទៃឲ្យផុតចាកសង្សារផង ។ ព្រះមានព្រះភាគ

អង្គនេះ ទ្រង់រម្ងាត់ឯងហើយ គឺរលត់ចាកភ្លើងកិលេសទាំងឡាយ នាំសត្វដទៃឲ្យរលត់ចាកភ្លើងកិលេសផង ។

បទថា **គហេត្វា តិមិរបុប្ផំ** សេចក្ដីថា ឈ្មោះថា ផ្កាតិមិរៈ ព្រោះធ្វើជាយព្រៃទាំងមូលឲ្យងងឹតដោយរស្មីពណ៌ខៀវ និងពណ៌ខ្មៅ ខ្ញុំបានកាន់យកផ្កាតិមិរព្រឹក្សហើយ កាន់ត្រង់ទងរោយចុះ គឺបូជាក្នុងអាកាស លើព្រះសិរសា គឺលើព្រះសីសៈ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាតិមិរបុប្ផិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## គតសញ្ញកត្ថេរាបទានទី ២

[ ៨៤ ] ខ្ញុំមានអាយុ ៧ ឆ្នាំ បានចូលទៅកាន់ផ្នួស បានថ្វាយបង្គំព្រះបាទានៃព្រះសាស្តា ដោយចិត្តជ្រះថ្លា ។ ខ្ញុំបោះផ្កាឈើឈ្មោះសត្តុទន្តលកី ទៅលើអាកាស ឧទ្ទិសចំពោះព្រះពុទ្ធ ព្រះនាមតិស្សៈ ព្រះអង្គមានគុណមិនមានទីបំផុត ប្រៀបដូចសាគរ ។ ខ្ញុំមានចិត្តត្រេកអរ បានបូជាផ្លូវដែលព្រះសុគតយាងមក ហើយមានចិត្តជ្រះថ្លា បានធ្វើអញ្ជលីកម្ម ដោយដៃទាំងពីរក្នុងគ្រានោះ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ៣ ដង ព្រះនាមអគ្គិសិខៈដូចគ្នា ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគតសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**គតសញ្ញកត្ថេរាបទាន ចប់**

# អដ្ឋកថា

## គតសញ្ញកត្ថេរាបទាន

[ ៨៤ ] អបទានរបស់ព្រះគតសញ្ញកត្ថេរ មានពាក្យផ្ដើមថា **ជាតិយា សត្តវស្សោហំ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង បាននូវសទ្ធា ដោយអំណាចវាសនាដែលធ្វើក្នុងកាលមុន បួសក្នុងកាលដែលខ្លួនមានអាយុ ៧ ឆ្នាំនោះឯងបានប្រាកដ ដោយការធ្វើនមស្ការដល់ព្រះមានព្រះភាគនោះឯង ។ ថ្ងៃមួយ លោកកាន់យកផ្កា ៧ ដែលកើតក្នុងទឹកខ្ជួរដោយទន្តិល មានពណ៌ខៀវដូចកែវមណី បូជាលើអាកាស ( បោះទៅក្នុងអាកាស ) ។ លោកធ្វើសមណធម៌ដរាបដល់អស់អាយុ ដោយបុញ្ញកម្មនោះ លោកអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ជាតិយា សត្តវស្សោហំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ជាតិយា សត្តវស្សោ** សេចក្តីថា មានអាយុ ៧ ឆ្នាំ រាប់អំពីប្រសូតចាកផ្ទៃមាតា ។ បទថា **បព្វជឹ អនគារិយំ** សេចក្តីថា ឈ្មោះថា **អនគារិយៈ** ព្រោះមិនមានការងារដែលទាក់ទងក្នុងផ្ទះ ដូចកសិកម្ម និងពាណិជ្ជកម្មជាដើម សេចក្តីថា ខ្ញុំបានបួសក្នុងព្រះពុទ្ធ-សាសនា ។

បទថា **សុគតានុគតំ មគ្គំ** សេចក្តីថា ផ្លូវដែលព្រះពុទ្ធទ្រង់យាងទៅហើយ ។ម្យ៉ាងទៀត ផ្លូវដែលទ្រង់សម្តែងហើយ ភ្ជាប់សេចក្តីថា ខ្ញុំមានចិត្តត្រេកអរ គឺមានចិត្តត្រេកអរបូជា ដោយអំណាចបំពេញបដិបទាដែលសមគួរដល់ធម៌ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាគតសញ្ញកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## និបន្នញ្ជលិកត្ថេរាបទានទី ៣

[ ៨៥ ] ខ្ញុំអន្ទយនៅទៀបគល់ឈើ ក្នុងព្រៃញាតស្បាតធំ ខ្ញុំត្រូវរោគដ៏ក្រៃលែងបៀតបៀន ហើយដល់នូវកាពគួរគេអាណិតក្រៃលែង ។ ព្រះសាស្តាព្រះនាមតិស្សៈ ទ្រង់ចូលមកជិតខ្ញុំ ដោយអាស្រ័យសេចក្តីអនុគ្រោះ ខ្ញុំនោះជាអ្នកដេកស្ងប់ស្ងៀម ហើយធ្វើអញ្ជលី ( ចំពោះព្រះសាស្តា ) ដោយត្បូង ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ បានថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គជាបុគ្គលឧត្តមជាងសត្វទាំងពួង ហើយធ្វើនូវកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំនូវព្រះសម្ពុទ្ធ ជាបុរសឧត្តម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ ក្នុងកប្បទី ៥ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ៥ ដង ព្រះនាមមហាសិខៈដូចគ្នា ទ្រង់បរិបូណ៌ដោយរតនៈ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនិបន្នញ្ជលិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**និបន្នញ្ជលិកត្ថេរាបទាន ចប់**

# អដ្ឋកថា

## និបន្នញ្ជលិកត្ថេរាបទាន

[ ៨៥ ] អបទានរបស់ព្រះនិបន្នញ្ជលិកត្ថេរ មានពាក្យផ្ដើមថា **រុក្ខមូលេ និសិន្នោហំ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពជាអនេក ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ បួសបំពេញរុក្ខមូលិកង្គធុតង្គនៅក្នុងព្រៃ ។ សម័យនោះ អាពាធខ្លាំងក្លាកើតឡើង លោកត្រូវអាពាធនោះបៀតបៀន ជាបុគ្គលគួរករុណាក្រៃលែង ។ ក្នុងកាលនោះ ព្រះមានព្រះភាគបានយាងទៅក្នុងទីនោះ ដោយមានសេចក្ដីករុណា ។ ខណៈកំពុងដេកនោះឯង កុលបុត្តនោះ មិនអាចក្រោកឡើងបាន ទើបផ្គងអញ្ជលីលើសិរសា ធ្វើការនមស្ការដល់ព្រះមានព្រះភាគ ។ កុលបុត្តនោះចុតិចាកអត្តភាពនោះហើយ ទៅកើតក្នុងជាន់តុសិត សោយសម្បត្តិក្នុងភពនោះ ហើយសោយសម្បត្តិក្នុងជាន់កាមាវចរសួគ៌ ៦ ជាន់ ដោយអាការយ៉ាងនេះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត លោកប្រាកដនាមថា និបន្នញ្ជលិកត្ថេរ តាមបុណ្យដែលធ្វើក្នុងកាលមុន ។

ក្នុងកាលខាងក្រោយ លោកពិចារណាមើលបុញ្ញសម្បត្តិរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **រុក្ខមូលេ និសិន្នោហំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **រុក្ខ** ព្រោះដុះ គឺលូតឡើង តាំងឡើងខាងលើ អធិប្បាយថា ត្រង់គល់ គឺជិតដើមឈើនោះ ។ បទថា **ព្យាធិតោ បរមេន ច** សេចក្តីថា ត្រូវរោគ គឺព្យាធិដ៏ខ្លាំងក្លាក្រៃលែងបៀតបៀន គឺខ្ញុំមានជំងឺ ។ បទថា **បរមការុញ្ញប្បត្តោម្හි** ក្លាប់សេចក្តីថា ជាអ្នកដល់នូវភាពគួរអាសូរ គួរករុណា ដល់នូវសេចក្តីទុក្ខក្រៃលែង ក្នុងព្រៃនោះ ។

បទថា **បញ្ចេវាសុំ មហាសិខា** សេចក្តីថា ផ្នួងសក់ លោកហៅថា **សិខា** ព្រោះអត្ថថា ជាគ្រឿងប្រដាប់ក្បាល អធិប្បាយថា **សិ១** ព្រោះមានមកុដរុងរឿងដោយកែវមណី លោកជាស្តេចចក្កពត្តិ ៥ ដង មានឈ្មោះតែមួយ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

## អដ្ឋកថានិបន្នញ្ជលិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## អធោបុប្ផិយត្ថេរាបទានទី ៤

[ ៨៦ ] មានភិក្ខុមួយរូប ព្រះនាមអភិភូ ជាអគ្គសាវ័ករបស់ព្រះពុទ្ធព្រះនាមសិខី លោកមានអានុភាពច្រើន មានត្រៃវិជ្ជា បានចូលមកកាន់ភ្នំហិមពាន្ត ។ កាលនោះ ខ្ញុំជាឥសី ជាអ្នកស្ទាត់ក្នុងអប្បមញ្ញា និងឫទ្ធិ នៅក្នុងអាស្រមជាទីគួរត្រេកអរ ទៀបភ្នំហិមពាន្តនោះ ។ ខ្ញុំប្រាថ្នារកផ្លែឈើ ក្នុងព្រៃភ្នំ ដូចជាបក្សីកាលហើរទៅក្នុងអាកាស ខ្ញុំកាន់យកនូវផ្កាអធោព្រឹក្ស ហើយត្រឡប់មកឯលំនៅជិតភ្នំនោះវិញ ។ ខ្ញុំបានយកផ្កា ៧ រោយលើព្រះសិរ្សៈ ( នៃអគ្គសាវ័កនោះ ) លុះដល់អគ្គសាវ័ក ជាវីរបុរសនោះក្រឡេកមើលមកចំខ្ញុំ ខ្ញុំក៏បែរមុខទៅទិសខាងកើត ហើយដើរចៀសចេញទៅ ។ ខ្ញុំបានទៅដល់អាស្រមហើយ ក៏បានចាត់ចែងនូវអាវាស រួចយកនូវអម្រែក ដើរទៅកាន់ចន្លោះភ្នំ ។ គាប់ជួនពស់ថ្លាន់មានរូបដ៏សម្បើម មានកម្លាំងច្រើន បៀតបៀន ( នូវខ្ញុំ ) ខ្ញុំក៏នឹកដល់បុព្វកម្ម ហើយធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ៣៩ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ

ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអជោបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អជោបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## អធោបុប្ផិយត្ថេរាបទាន

[ ៨៦ ] *អបទានរបស់ព្រះអធោបុប្ផិយត្ថេរ មានពាក្យផ្តើមថា* **អភិភូ នាម សោ ភិក្ខុ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពដ៏ច្រើន ក្នុងកាលនៃព្រះពុទ្ធព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ តមក ឃើញទោសក្នុងកាមទាំងឡាយ លះការនៅគ្រប់គ្រងផ្ទះនោះហើយ បួសជាឥសី បាននូវអភិញ្ញា ៥ សមាបត្តិ ៨ ដល់នូវភាពជាអ្នកជំនាញក្នុងឫទ្ធិទាំងឡាយ អាស្រ័យនៅក្នុងព្រៃហិមពាន្ត ។ អគ្គសាវកឈ្មោះអភិភូ របស់ព្រះមានព្រះភាគព្រះនាមសិខីនោះ ត្រេកអរក្រៃលែងក្នុងវិវេក ទើបបានទៅកាន់ព្រៃហិមពាន្ត ។ កាលនោះ តាបសនោះ ឃើញព្រះថេរៈដែលជាអគ្គសាវកនោះ ទើបតោងឡើងទៅកាន់ភ្នំដែលព្រះថេរៈឈរ បេះយកផ្កា ៧ ដែលសម្បូរដោយពណ៌ និងក្លិនក្រអូប អំពីខាងក្រោមនៃភ្នំឡើងមកបូជា ។ កាលនោះ ព្រះថេរៈនោះ បានធ្វើអនុមោទនាដល់តាបសនោះ ។ ចំណែកតាបសនោះ បានទៅកាន់អាស្រមរបស់ខ្លួន តាបសនោះត្រូវពស់ថ្លាន់មួយ ក្នុងទីនោះរួត តមក ត្រូវអន្តរាយនោះបៀតបៀន ជាអ្នកមានឈានមិនសាបសូន្យ ធ្វើកាលកិរិយាហើយ មានព្រហ្មលោកជាទីទៅខាងមុខ សោយព្រហ្មសម្បត្តិ និងឆកាមាវចរសម្បត្តិ និងសោយមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើន*

វ័យហើយ ស្តាប់ធម៌របស់ព្រះមានព្រះភាគ មានចិត្តជ្រះថ្លា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ក្រោយមក លោកប្រាកដនាមថា អធោបុប្ផិយត្ថេរ តាមបុណ្យដែលធ្វើមកហើយក្នុងកាលមុន ។ ថ្ងៃមួយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទាន ដែលប្រព្រឹត្តមក ទើបពោលពាក្យថា **អភិភូ នាម សោ ភិក្ខុ** ដូច្នេះជាដើម ។

ក្នុងបទទាំងនេះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **អភិភូ** ព្រោះគ្របសង្កត់ជនដទៃដោយសីល និងសមាធិ ម្យ៉ាងទៀត ឈ្មោះថា **អភិភូ** ព្រោះគ្របសង្កត់ គឺគ្របសង្កត់មារ មានខន្ធមារជាដើម ម្យ៉ាងទៀត ឈ្មោះថា **អភិភូ** ព្រោះគ្របសង្កត់ គឺកម្ចាត់កិលេសក្នុងសន្តានរបស់ខ្លួន និងរបស់អ្នកដទៃ ។ ឈ្មោះថា **ភិក្ខុ** ព្រោះមានប្រក្រតីសូម គឺមានការសូមជាប្រក្រតី ។ ម្យ៉ាងទៀត ឈ្មោះថា **ភិក្ខុ** ព្រោះស្លៀកដណ្តប់សំពត់ដែលកាត់ជាបន្ទះៗ អធិប្បាយថា ភិក្ខុជាព្រះអគ្គសាវកនោះ ឈ្មោះថា **អភិភូ** ភ្ជាប់សេចក្តីថា អគ្គសាវករបស់ព្រះមានព្រះភាគ ព្រះនាមសិខី ។

បទថា **អជគរោ មំ បីឡេសិ** សេចក្តីថា ពស់ថ្លាន់ធំ បៀតបៀននូវតាបស ដែលសម្បូរដោយសីលបែបនោះ ព្រោះបាប និងពៀរដែលធ្វើក្នុងជាតិមុន លោកត្រូវអន្តរាយនោះឯងបៀតបៀន មានឈានមិនសាបសូន្យ ធ្វើកាលកិរិយាហើយ មានព្រហ្មលោកជាទីទៅខាងមុខ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាអធោបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## រំសិសញ្ញិកត្ថេរាបទានទី ៥

[ ៨៧ ] ក្នុងកាលមុន ខ្ញុំសម្រេចការនៅក្បែរភ្នំហិមពាន្ត ខ្ញុំស្លៀកពាក់ឧត្តរាសង្គៈ ជាស្បែកខ្លា នៅត្រង់ចន្លោះភ្នំ ។ ខ្ញុំឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស មានរស្មីច្រើន ដូចព្រះអាទិត្យ ឬដូចសាលរាជព្រឹក្ស មានផ្ការីក ទ្រង់ធ្វើពុទ្ធដំណើរទៅក្នុងចន្លោះព្រៃ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងរស្មីរបស់ព្រះមហេសី ព្រះនាមវិបស្សី ទើបអន្ទុយប្រហោង ផ្គងអញ្ជលី ថ្វាយបង្គំដោយសិរ្សៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសម្គាល់នូវរស្មី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះរំសិសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**រំសិសញ្ញិកត្ថេរាបទាន ចប់**

# អដ្ឋកថា

## វំសិសញ្ញិកត្ថេរាបទាន

[ ៨៧ ] អបទានរបស់ព្រះវំសិសញ្ញកត្ថេរ មានពាក្យផ្តើមថា **បព្វតេ ហិមវន្តម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងកាមទាំងឡាយ លះនូវការគ្រប់គ្រងផ្ទះ បួសជាតាបស ស្លៀកដណ្តប់នូវស្បែកខ្លាដំបង សម្រេចការនៅក្នុងភ្នំហិមពាន្ត ។ សម័យនោះ ព្រះមានព្រះភាគ ព្រះនាមវិបស្សី យាងទៅកាន់ភ្នំហិមពាន្ត ។ លំដាប់នោះ តាបសឃើញព្រះមានព្រះភាគ យាងចូលភ្នំហិមពាន្ត ជ្រះថ្លាក្នុងព្រះពុទ្ធរង្សី មានពណ៌ ៦ ដែលផ្សាយចេញអំពីព្រះវរកាយនៃព្រះមានព្រះភាគអង្គនោះ ទើបផ្គងអញ្ជលី ថ្វាយបង្គំប្រកបដោយអង្គ ៥ ដោយបុញ្ញកម្មនោះឯង កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ សោយទិព្វសម្បត្តិក្នុងទេវតាជាន់តុសិតជាដើម តមក បានសោយមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះនោះ លះផ្ទះបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បព្ភតេ ហិមវន្តម្ហិ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **បព្ភតេ** សេចក្ដីថា ឈ្មោះថា **បព្ភត** ព្រោះចម្រើន គឺខ្ពស់ឡើងដោយជុំវិញ ឈ្មោះថា **ហិមវន្ត** ព្រោះភ្នំនោះ មានសន្សើម ភ្នំនោះផង មានសន្សើមផង ព្រោះហេតុនោះ ទើបឈ្មោះថា ភ្នំហិមពាន្ត ។ កាលគួរពោលថា **ហិមវន្តបព្ភតេ** លោកត្រឡប់ជាពោលថា **បព្ភតេ ហិមវន្តម្ហិ** ដើម្បីងាយស្រួលក្នុងការចងគាថា ភ្ជាប់សេចក្ដីថា ក្នុងកាលមុន ខ្ញុំសម្រេចការនៅនាភ្នំឈ្មោះហិមពាន្តនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕៚

**អដ្ឋកថាវំសិសញ្ញិកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វិសេសញ្ញិកត្ថេរាបទានទី ៦

[ ៨៨ ] ខ្ញុំស្លៀកសម្បកឈើ នៅក្បែរភ្នំហិមពាន្ត ខ្ញុំឡើងកាន់ទីចង្រ្កម រួចអង្គុយបែរមុខទៅទិសខាងកើត ។ ខ្ញុំបានឃើញព្រះសុគត ព្រះនាមផុស្សៈ ក្បែរភ្នំ ទ្រង់ត្រេកអរនឹងឈាន សព្វៗកាល ហើយខ្ញុំផ្គងអញ្ជលី ញុំាងចិត្តឲ្យជ្រះថ្លាក្នុងវេស្មី ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសម្គាល់វេស្មី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិសេសញ្ញិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វិសេសញ្ញិកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ទុតិយវំសិសញ្ញិកត្ថេរាបទាន

[ ៨៨ ] អបទានរបស់ព្រះទុតិយវំសិសញ្ញកត្ថេរ មានពាក្យផ្ដើមថា **បព្វតេ ហិមវន្តម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពដែលខ្លួនកើត ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមផុស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងការគ្រប់គ្រងផ្ទះនោះ ទើបលះនូវការគ្រប់គ្រងផ្ទះនោះ ចេញបួសជាតាបស នៅត្រង់ភ្នំហិមពាន្ត ស្លៀកដណ្ដប់សម្បកឈើ នៅដោយសេចក្ដីសុខ ដែលកើតអំពីវិវេក ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមផុស្សៈ ទ្រង់យាងដល់ប្រទេសនោះ ឃើញព្រះពុទ្ធរង្សីមានពណ៌ ៦ ដែលផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះអង្គ ផ្សាយទៅក្នុងទីផ្សេងៗ ដូចពន្លឺដែលចេញអំពីប្រទីបមានជង ជ្រះថ្លាក្នុងព្រះមានព្រះភាគ ផ្គងអញ្ជលីថ្វាយបង្គំ ញុំាងចិត្តឲ្យជ្រះថ្លា ធ្វើកាលកិរិយាដោយបីតិ និងសោមនស្សនោះៗ ឯង កើតក្នុងទេវតាជាន់តុសិតជាដើម សោយសម្បត្តិក្នុងកាមាវចរសួគ៌ ៦ ជាន់ ក្នុងភពទាំងនោះតមក កាលសោយមនុស្សសម្បត្តិហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ បានចេញបួស ដោយអំណាចនៃវាសនាក្នុងកាលមុន មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បព្ភតេ ហិមវន្តម្ហិ** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ។ល។

## អដ្ឋកថាទុតិយវំសិសញ្ញិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ផលទាយកត្ថេរាបទានទី ៧

[ ៨៩ ] ខ្ញុំស្លៀកស្បែកខ្លាទាំងក្រចក ( នៅ ) ជិតភ្នំហិមពាន្ត មានផ្លែឈើក្នុងដៃ បានឃើញព្រះជិនស្រីដ៏ប្រសើរ ព្រះនាមផុស្សៈ ហើយថ្វាយផ្លែឈើ ( ចំពោះព្រះពុទ្ធនោះ ) ។ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយផ្លែឈើណា កាលបើកពរបស់ខ្ញុំនៅមាន ផ្លែឈើនោះ តែងកើតដល់ខ្ញុំ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ផលទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ផលទាយកត្ថេរាបទាន

[ ៨៩ ] អបទានរបស់ព្រះផលទាយកត្ថេរ មានពាក្យផ្ដើមថា **បព្ភតេ ហិមវន្តម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមផុស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង បានទទួលសេចក្ដីសុខ លះវត្ថុទាំងពួង ចេញបួសជាតាបស ស្លៀកស្បែកសត្វដែលគ្រោតគ្រាត ។ សម័យនោះ កុលបុត្តនោះ ឃើញព្រះមានព្រះភាគព្រះនាមផុស្សៈ យាងមកក្នុងទីនោះ មានចិត្តជ្រះថ្លា កាន់យកផ្លែឈើមានរសឆ្ងាញ់ថ្វាយឲ្យសោយ ព្រោះកុសលនោះឯង ទើបកុលបុត្តនោះសោយបុញ្ញសម្បត្តិក្នុងទេវលោកជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បព្ភតេ ហិមវន្តម្ហិ** ដូច្នេះជាដើម ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយខាងដើមនោះឯង ៕

**អដ្ឋកថាផលទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សទ្ទសញ្ញកត្ថេរាបទានទី ៨

[ ៩០ ] ខ្ញុំនៅលើកម្រាលស្លឹកឈើ នាភ្នំហិមពាន្ត បានធ្វើចិត្តឲ្យជ្រះថ្លា ក្នុងសំឡេងរបស់ព្រះសម្ពុទ្ធ ព្រះនាមផុស្សៈ ដែលកំពុងសម្តែងធម៌ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុញ្ញកម្ម ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសទ្ទសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សទ្ទសញ្ញកត្ថេរាបទាន ចប់

# អដ្ឋកថា

## សទ្ទសញ្ញកត្ថេរាបទាន

[ ៩០ ] អបទានរបស់ព្រះសទ្ទសញ្ញកត្ថេរ មានពាក្យផ្ដើមថា **បព្ពតេ ហិមវន្តម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមផុស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ កើតនូវសទ្ធា បួសជាតាបស នៅក្នុងព្រៃហិមពាន្ត បានស្ដាប់ធម៌របស់ព្រះមានព្រះភាគ ដែលយាងទៅរកដើម្បីអនុគ្រោះខ្លួន ទើបធ្វើចិត្តឲ្យជ្រះថ្លាក្នុងធម៌ តាំងនៅដរាបដល់អស់អាយុ ក្រោយមកធ្វើកាលកិរិយាហើយ សោយកាមាវចរសម្បត្តិក្នុងស្ថានសួគ៌ ៦ ជាន់ មានជាន់តុសិតជាដើម និងសោយសម្បត្តិក្នុងពួកមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ កើតនូវសទ្ធា បួសហើយ ចម្រើនវិបស្សនា សម្រេចអរហត្តហើយ ។

ក្នុងកាលជាខាងក្រោយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បព្ពតេ ហិមវន្តម្ហិ** ដូច្នេះជាដើម ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ៗ៚

**អដ្ឋកថាសទ្ទសញ្ញកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ពោធិសិញ្ចកត្ថេរាបទានទី ៩

[ ៩១ ] មានពិធីឆ្លងព្រះមហាពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ក្នុងកាលនោះ ខ្ញុំជាអ្នកបួសមានចិត្តស្ងប់រម្ងាប់ ដើរចូលទៅ ( ជិតដើមពោធិព្រឹក្សនោះ ) ។ ខ្ញុំដងទឹកត្រពាំង ស្រោចដើមពោធិព្រឹក្ស ( ដោយគិតថា ) ព្រះវិបស្សីសម្ពុទ្ធ ទ្រង់រួចចាកទុក្ខហើយ នឹងញ៉ាំងយើងឲ្យរួចទុក្ខផង ទ្រង់រម្ងត់ទុក្ខ ហើយ នឹងញ៉ាំងយើងឲ្យរលត់ផង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានស្រោចស្រពដើមពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្រោចពោធិព្រឹក្ស ។ កាលកប្បទី ៣៣ កំពុងប្រព្រឹត្តទៅ ខ្ញុំបានជាស្តេចចក្កពត្តិ ៨ ដង ជាធំលើពួកជន ទ្រង់ព្រះនាមឧទកាសេចនៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិសិញ្ចកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ពោធិសិញ្ចកត្ថេរាបទាន ចប់

# អដ្ឋកថា

## ពោធិសិញ្ចកត្ថេរាបទាន

[ ៩១ ] *អបទានរបស់ព្រះពោធិសិញ្ចកត្ថេរ មានពាក្យផ្ដើមថា* **វិបស្សិស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានមកហើយច្រើនជាតិ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង បួសក្នុងព្រះសាសនា ញ៉ាំងព្រះសាសនាឲ្យល្អដោយវត្តបដិបត្តិ ឃើញមហាជនបូជាពោធិព្រឹក្ស ទើបឲ្យមនុស្សកាន់យកផ្កា គ្រឿងក្រអូប និងទឹកជាច្រើន ហើយធ្វើការបូជា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក សោយសម្បត្តិក្នុងកាមាវចរ ៦ ជាន់ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ កើតនូវសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*លោកបានជាព្រះអរហន្តហើយ ឲ្យកាលកន្លងទៅដោយសេចក្ដីសុខដែលកើតអំពីផលនៃឈាន រឭកដល់បុព្វកម្ម កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **វិបស្សិស្ស ភគវតោ** *ដូច្នេះជាដើម ។*

ក្នុងពាក្យទាំងនោះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **វិបស្សី** ព្រោះឃើញនូវគុណវិសេស គឺប្រយោជន៍ដ៏ក្រៃលែង បានដល់ ព្រះនិព្វាន ។ ម្យ៉ាងទៀត ឈ្មោះថា **វិបស្សី** ព្រោះឃើញជនដែលគួរ និងមិនគួរដល់ការត្រាស់ដឹងដោយវិសេស ។ ម្យ៉ាងទៀត ឈ្មោះថា **វិបស្សី** ព្រោះឃើញច្បាស់នូវសច្ចៈ ៤ ។ ក្នុបសេចក្តីថា បានចូលមហាពោធិព្រឹក្សរបស់ព្រះមានព្រះភាគព្រះនាមវិបស្សីអង្គនោះ ។ ក្នុងគាថានោះ ញាណក្នុងមគ្គទាំង ៤ លោកហៅថា **ពោធិ** ក្នុងបទថា **មហាពោធិ** នេះ ។ ព្រះមានព្រះភាគទ្រង់គង់នាដើមឈើនោះ ត្រាស់ដឹងសច្ចៈ ៤ នោះ ព្រោះហេតុនោះ សូម្បីដើមកណិការ លោកក៏ហៅថា **ពោធិ** ដោយដើមពោធិនោះ ដែលទេវតាព្រហ្ម មនុស្ស និងអសុរបូជាហើយ ព្រោះហេតុនោះ ទើបលោកហៅថា **មហាពោធិ** ។ ម្យ៉ាងទៀត លោកហៅថា **ពោធិ** ព្រោះជាទីត្រាស់ដឹងរបស់ព្រះពុទ្ធដ៏ធំក្រៃលែង អធិប្បាយថា មាននូវការបូជាធំដល់ព្រះមានព្រះភាគអង្គនោះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាពោធិសិញ្ចកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បទុមបុប្ផិយត្ថេរាបទានទី ១០

[ ៩២ ] ខ្ញុំចូលទៅក្នុងព្រៃ ដែលមានស្រះឈូក កំពុងកាច់ផ្កាឈូក បានឃើញព្រះសម្ពុទ្ធ ព្រះនាមផុស្សៈ ទ្រង់មានលក្ខណៈ ៣២ ប្រការដ៏ប្រសើរ ។ ខ្ញុំបានយកផ្កាឈូកបោះឡើងទៅនាអាកាស ( ថ្វាយព្រះអង្គ ) ខ្ញុំរឭកឃើញនូវបាបកម្មហើយ ក៏ចូលបួសក្នុងព្រះពុទ្ធសាសនា ។ លុះខ្ញុំបួសហើយ បានសង្រួមកាយ និងចិត្ត លះបង់នូវវចីទុច្ចរិត ជម្រះនូវអាជីវបារិសុទ្ធិ-សីល ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៨ ខ្ញុំបានកើតជាក្សត្រ ១៨ ដង និង ៤៨ ដង ( ៦៦ ) ជាធំលើផែនដី ទ្រង់ព្រះនាមបទុមកាសៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បទុមបុប្ផិយត្ថេរាបទាន ចប់**

## ឧទ្ទាន

តិមិរបុប្ផិយត្ថេរាបទាន ១ កតសញ្ញកត្ថេរាបទាន ១ និបន្នញ្ជលិកត្ថេរាបទាន ១ អធោបុប្ផិយត្ថេ-រាបទាន ១ រំសិសញ្ញកត្ថេរាបទាន ២ ផលទាយ-កត្ថេរាបទាន ១ សទ្ទសញ្ញកត្ថេរាបទាន ១ ពោធិសិញ្ចកត្ថេរាបទាន ១ បទុមបុប្ផិយត្ថេរាបទាន ១ ឯគាថាចំនួន ៥៦ លោកបានសម្តែងហើយ ។

**តិមិរបុប្ផិយវគ្គទី ៩ ចប់**

# អដ្ឋកថា

## បទុមបុប្ផិយត្ថេរាបទាន

[ ៩២ ] អបទានរបស់ព្រះបទុមបុប្ផិយត្ថេរ មានពាក្យផ្ដើមថា **ពោក្ខរវនំ បវិដ្ឋោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមផុស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ចុះទៅក្នុងស្រះបោក្ខរណីមួយកន្លែង ដែលសម្បូរដោយផ្កាឈូក ទំពាស៊ីក្រអៅឈូក ឃើញព្រះមានព្រះភាគព្រះនាមផុស្សៈ កំពុងយាងទៅក្នុងទីមិនឆ្ងាយអំពីស្រះបោក្ខរណី មានចិត្តជ្រះថ្លា ទើបបេះផ្កាឈូកអំពីស្រះ បោះទៅលើអាកាសបូជាព្រះមានព្រះភាគ ។ ផ្កាទាំងនោះ បានអណ្ដែតជាពិតានក្នុងអាកាស កុលបុត្តនោះ មានចិត្តជ្រះថ្លាក្រៃលែង ទើបចេញបួសបំពេញសមណធម៌ កាន់យកវត្តបដិបត្តិជាសារៈ ចុតិចាកអត្តភាពនោះហើយ ដូចធ្វើមន្ទិលក្នុងស្ថានតុសិត[១] ទើបទៅកើតក្នុងទីនោះ សោយកាមាវចរ ៦ ជាន់តាមលំដាប់ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង លុះចម្រើនវ័យហើយ បានទូវសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

---

១- បាលីថា តុសិតភវនមលំ កុរុមានោ វិយ ។

ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បោក្ខរវនំ បវិដ្ឋោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **បោក្ខរ** ព្រោះរីងប៉ឹងជាង ទង ស្លឹក នៃដើមបបុសដោយទូទៅ ។ ឈ្មោះថា **បោក្ខរវន** ព្រោះជាទីប្រជុំ ដោយអត្ថថា ជាទីកើតនៃដើមឈូក អធិប្បាយថា ខ្ញុំបានចូលទៅកណ្តាលស្រះ ដែលប្រដាប់ដោយគុម្ព និងព្រៃឈូក ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាបទុមបុប្ផិយត្ថេរាបទាន ចប់

## តិមិរបុប្ផិយវគ្គទី ៩ ចប់

# សុត្តន្តបិដក
# សុធាវគ្គទី ១០

## សុធាបិណ្ឌិយត្ថេរាបទានទី ១

[ ៩៣ ] កាលបុគ្គលបូជា ចំពោះបុគ្គលគួរបូជា ទោះបីព្រះពុទ្ធ ឬសាវក ដែលកន្លងផុតនូវធម៌ជាគ្រឿងយឺតយូរ ឆ្លងផុតនូវសេចក្តីសោក និងការខ្សឹកខ្សួល ។ កាលបុគ្គលបូជាចំពោះបុគ្គលទាំងនោះ ដែលមានសភាពដូច្នោះ មានទុក្ខរលត់ហើយ លោកមិនមានភ័យអំពីទីណា បុគ្គលណាមួយ មិនអាចនឹងរាប់បុណ្យថា បុណ្យនេះ មានប្រមាណប៉ុណ្ណេះ ឬមានប្រមាណប៉ុណ្ណោះឡើយ ។ ក្នុងលោកនេះ បុគ្គលណាមួយ ទទួលនូវភាពជាធំ ក្នុងទ្វីបទាំង ៤ ការទទួលនូវឥស្សរភាពនេះរបស់បុគ្គលនុ៎ះ មិនដល់មួយចំណែកទី ១៦ នៃការបូជានេះឡើយ ។ ខ្ញុំមានចិត្តជ្រះថ្លា បានបូកបាយ-អ ក្នុងចន្លោះឥដ្ឋចេតិយរបស់ព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថៈ ទ្រង់ប្រសើរជាងពួកនរៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ

នេះជាផលនៃការជួសជុលចេតិយ ។ ក្នុងកប្បទី ៣០ អំពីកប្ប
នេះ ខ្ញុំបានជាស្តេចចក្កពត្តិ ១៣ ដង មាននាមថា បដិសង្ខារសៈ
ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨
និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា
របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុធាបិណ្ឌិយត្ថេរមានអាយុ បានសម្តែងនូវ
គាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុធាបិណ្ឌិយត្ថេរាបទាន ចប់

# អដ្ឋកថា
# សុធាវគ្គទី ១០

## សុធាបិណ្ឌិយត្ថេរាបទាន

[ ៩៣ ] អបទានរបស់ព្រះសុធាបិណ្ឌិយត្ថេរ មានពាក្យផ្តើមថា **បូជារហេ បូជយតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កាលព្រះមានព្រះភាគទ្រង់គង់ព្រះជន្មនៅ មិនអាចបំពេញបុណ្យបាន កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ កាលមហាជននាំគ្នាសាងព្រះចេតិយ ដើម្បីដាក់ព្រះធាតុរបស់ព្រះមានព្រះភាគ កុលបុត្តនោះ បានថ្វាយបាយ-អ-កចេតិយនោះ ។ ដោយបុញ្ញកម្មនោះ តាំងអំពីកប្ប ៩៤ មក កុលបុត្តនោះ មិនធ្លាប់ជួបអបាយ ៤ សោយតែទេវសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បូជារហេ បូជយតោ** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ មានអធិប្បាយដូចតទៅនេះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវក អាចារ្យ ឧបជ្ឈាយ៍ មាតា បិតា និងគ្រូជាដើម ឈ្មោះថា **បូជារហបុគ្គល** បុគ្គលណាម្នាក់ សូម្បីមានអានុភាពធំ ក៏មិនអាចធ្វើការរាប់នូវចំណែកបុណ្យរបស់បុគ្គលដែលគួរបូជាទាំងនោះ ដោយសក្ការៈ មានកម្រងផ្កា ផ្កាឈូក សំពត់ គ្រឿងអាភរណៈ និងបច្ច័យ ៤ ជាដើម រាប់ពាន់ រាប់សែនជាដើម ។ មិនមែនបុណ្យរបស់បុគ្គលដែលបូជាព្រះពុទ្ធជាដើម ដែលទ្រង់គង់ព្រះជន្មនៅប៉ុណ្ណោះទេ សូម្បីបូជាក្នុងព្រះចេតិយ ព្រះបដិមា និងពោធិព្រឹក្សជាដើមរបស់ព្រះមានព្រះភាគ ដែលបរិនិព្វានទៅហើយ ក៏ន័យនេះដូចគ្នា ។

ដើម្បីសម្តែងរឿងនោះ ទើបព្រះថេរៈពោលពាក្យថា **ចតុន្នម្បិ ទីបានំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ចតុន្នម្បិ ទីបានំ** សេចក្តីថា គប្បីរួមទ្វីបទាំង ៤ ពោល គឺជម្ពូទ្វីប អបរគោយានទ្វីប ឧត្តរកុរុទ្វីប និងបុព្វវិទេហទ្វីប និងទ្វីបតូច ២ ពាន់ ដែលរួមក្នុងទ្វីបទាំង ៤ នោះ ចូលជាមួយគ្នា ហើយគ្រប់គ្រងភាពជាធំ គឺភាពជាស្តេចចក្រពត្តិ ក្នុងល្វែងនៃចក្កវាឡទាំងមូល ។ បទថា **ឯកិស្សា បូជនាយេតំ** សេចក្តីថា ទ្រព្យទាំងមូល មានរតនៈ ៧ ក្នុងជម្ពូទ្វីបទាំងមូលជាដើមនោះ មិនដល់ចំណែកទី ១៦ នៃការបូជាត្រឹមតែម្តង ដែលធ្វើក្នុងបន្ទប់ព្រះធាតុ គឺព្រះចេតិយ ។ បទថា **កលំ នាគ្ឃតិ សោឡសឹ** សេចក្តីថា មិនដល់ចំណែកទី ១៦ ដែលចៀកជា ១៦ ដងនៃការបូជាដែលធ្វើក្នុងព្រះចេតិយ ។

*បទថា* **សិទ្ធត្ថស្ស ។បេ។ ជលិតន្តរេ** *ភ្ជាប់សេចក្តីថា កាលមហាជននាំគ្នាបូកលាបបាយ-អ ត្រង់បន្ទប់បញ្ចុះព្រះធាតុ ក្នុងព្រះចេតិយរបស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ដែលជាបុគ្គលប្រសើរជាងនរៈ ខ្ញុំបានដាក់ដុំបាយ-អ ក្នុងចន្លោះទីតពីរចំណែក ឬក្នុងរវាងទីជាទីថ្វាយផ្កា ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚*

## អដ្ឋកថាសុធាបិណ្ឌិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សុបីបិយត្ថេរាបទានទី ២

[ ៩៤ ] ខ្ញុំមានចិត្តរីករាយ បានថ្វាយតាំងដ៏ស្អាត ចំពោះព្រះពុទ្ធ ព្រះនាមតិស្សៈ ជាលោកនាថ ជាផៅពង្សនៃព្រះអាទិត្យ ។ ក្នុងកប្បទី ៣៨ អំពីកប្បនេះ ខ្ញុំបានជាស្តេច ព្រះនាមមហារុចិ មានភោគៈច្រើន មានទីដេកច្រើន ។ ព្រោះតែខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយតាំងចំពោះព្រះសម្ពុទ្ធ ទើបខ្ញុំទទួលនូវផលកុសលកម្មជារបស់ខ្លួន ដែលខ្លួនបានសាងល្អហើយក្នុងភពមុន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយតាំង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយតាំង ។ ក្នុងកប្បទី ៣៨ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ៣ អង្គ ព្រះនាមរុចិ ១ ឧបរុចិ ១ មហារុចិ ១ ជាគម្រប់ ៣ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុបីបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុបីបិយត្ថេរាបទាន ចប់

# អដ្ឋកថា

## សុបីបិយត្ថេរាបទាន

[ ៩៤ ] *អបទានរបស់ព្រះសុចិន្តិកត្ថេរ*[១] *មានពាក្យផ្ដើមថា* **តិស្សស្ស លោកនាថស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដើម្បីជាឧបនិស្ស័យនៃព្រះនិព្វានក្នុងអនេកជាតិ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បានថ្វាយតាំងដែលមានតម្លៃច្រើន ជាតាំងដែលបរិសុទ្ធ ស្អាតល្អ ដើម្បីជាទីគង់របស់ព្រះសាស្ដា ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះសោយសុខក្នុងសុគតិ អន្ទោលទៅក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*លោកសម្រេចអរហត្តផលហើយ រឭកដល់បុព្វកម្ម កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **តិស្សស្ស លោកនាថស្ស** *ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ។*

### អដ្ឋកថាសុចិន្តិកត្ថេរាបទាន ចប់

---

១- *បាលីអបទានជា សុបីបិយត្ថេរ ។*

# សុត្តន្តបិដក

## អឌ្ឍចេលកត្ថេរាបទានទី ៣

[ ៩៥ ] ខ្ញុំជាបុគ្គលពេញទៅដោយសេចក្តីទ័លក្រ ដល់នូវភាពគួរគេអាណិតក្រៃពេក ខ្ញុំបានប្រគេនសំពត់ពាក់កណ្តាល ចំពោះព្រះមានព្រះភាគ ព្រះនាមតិស្សៈ ។ លុះខ្ញុំថ្វាយសំពត់ពាក់កណ្តាលរួចហើយ បានរីករាយក្នុងស្ថានសួគ៌ អស់មួយកប្ប មិនតែប៉ុណ្ណោះ ខ្ញុំបានធ្វើកុសលកម្ម ( ដទៃទៀត ) ក្នុងកប្បទាំងឡាយដ៏សេសផង ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់ ។ ក្នុងកប្បទី ៥១ ខ្ញុំបានជាក្សត្រចក្កពត្តិជាធំជាងពួកជន ព្រះនាមសមន្តាឱទនៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអឌ្ឍចេលកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អឌ្ឍចេលកត្ថេរាបទាន ចប់

# អដ្ឋកថា

## អឌ្ឍចេលកត្ថេរាបទាន

[ ៩៥ ] *អបទានរបស់ព្រះអឌ្ឍចេលកត្ថេរ មានពាក្យផ្ដើមថា* **តិស្សស្សាហំ ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះរបស់ត្រកូលអ្នកក្រីក្រ ព្រោះអកុសលកម្មឯណានីមួយ ចម្រើនវ័យហើយ ស្ដាប់ព្រះធម្ម-ទេសនា មានចិត្តជ្រះថ្លា បានថ្វាយសំពត់ពាក់កណ្ដាល ដើម្បីធ្វើចីវរ ដោយបីតិ និងសោមនស្សនោះៗ ឯង កុលបុត្តនោះអស់ជីវិតហើយ ទៅកើតក្នុងស្ថានសួគ៌ សោយសម្បត្តិក្នុងកាមាវចរសួគ៌ ៦ ជាន់ ចុតិចាកស្ថានសួគ៌នោះហើយ សោយចក្កពត្តិសម្បត្តិ ដែលជាកំពូលនៃមនុស្សសម្បត្តិ ក្នុងពួកមនុស្សច្រើនជាតិ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលស្ដុកស្ដម្ភមួយកន្លែង ចម្រើនវ័យហើយ ស្ដាប់នូវព្រះធម្មទេសនារបស់ព្រះសាស្ដា មានចិត្តជ្រះថ្លា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **តិស្សស្សាហំ ភគវតោ** *ដូច្នេះជាដើម ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ។ល។*

**អដ្ឋកថាអឌ្ឍចេលកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សូចិទាយកត្ថេរាបទានទី ៤

[ ៩៦ ] ក្នុងជាតិមុន ខ្ញុំកើតជាជាងដែក ក្នុងបុរីដ៏ប្រសើរ ឈ្មោះពន្ធុមៈ ខ្ញុំបានថ្វាយម្ជុលដល់ព្រះវិបស្សី ព្រះអង្គស្វែងរកនូវគុណដ៏ធំ ។ ញាណ ( របស់ខ្ញុំ ) ស្មើចុងនៃកែវវជីរ ប្រាកដដូច្នោះ កើតប្រាកដ ដោយកម្មនោះ ខ្ញុំមានរាគៈវិនាសហើយ មានចិត្តរួចស្រឡះហើយ ដល់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ។ អតីតភព បច្ចុប្បន្នភព អនាគតភពទាំងអស់ណា ខ្ញុំពិចារណាឃើញភពទាំងអស់នោះដោយញាណ នេះជាផលនៃការថ្វាយម្ជុល ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ៧ ដង ព្រះនាមវជីរសមៈដូចគ្នា បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសូចិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សូចិទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## សូចិទាយកត្ថេរាបទាន

[ ៩៦ ] អបទានរបស់ព្រះសូចិទាយកត្ថេរ មានពាក្យផ្ដើមថា **កម្មារោហំ បុរេ អាសឹ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សាងព្រោះនូវពូជ គឺកុសលក្នុងចន្លោះភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមវិបស្សី កើតក្នុងត្រកូលនៃជាងមាស ព្រោះត្រូវកម្មណាមួយដែលខ្លួនធ្វើក្នុងវេលាភពកាត់ផ្ដាច់ ។ ចម្រើនវ័យហើយ ដល់នូវភាពជាអ្នកសម្រេចក្នុងសិប្បៈរបស់ត្រកូល ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានចិត្តជ្រះថ្លា បានថ្វាយម្ជុលសម្រាប់ដេរចីវរ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះបានសោយទិព្វសម្បត្តិ តមក កើតក្នុងមនុស្ស សោយសម្បត្តិទាំងឡាយ មានចក្កពត្តិសម្បត្តិជាដើម ជាអ្នកមានបញ្ញាមុតស្រួច មានញាណដូចពេជ្រ ក្នុងភពដែលខ្លួនកើតហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតហើយចម្រើនវ័យដោយលំដាប់ មានទ្រព្យច្រើន បាននូវសទ្ធា មានបញ្ញាមុតស្រួច ។ ថ្ងៃមួយ ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា បញ្ជូនញាណទៅតាមក្រសែនៃធម៌ បានជាព្រះអរហន្តនៅលើអាសនៈដែលខ្លួនអង្គុយនោះឯង ។

លោកបានជាព្រះអរហន្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **កម្មារោហំ បុរេ អាសឹ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **កម្មារោ** សេចក្ដីថា ជាងមាស បានដល់អ្នកចិញ្ចឹមជីវិតដោយការងារលោហៈ មានដែកជាដើម ជាអ្នករស់នៅស្អាតដល់នូវការចម្រើនបរិបូណ៌ អធិប្បាយថា ក្នុងកាលមុន គឺក្នុងកាលបំពេញបុណ្យ ខ្ញុំបានជាជាងមាស ។ ពាក្យសេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។ល។

## អដ្ឋកថាសូចិនាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## គន្ធមាលិយត្ថេរាបទានទី ៩

[ ៩៧ ] ខ្ញុំបានកសាងព្រះស្តូប ប្រកបដោយគ្រឿងក្រអូប ស្រោបបិទបាំងដោយផ្កាម្លិះ ដ៏សមគួរដល់ព្រះពុទ្ធ ( ថ្វាយ ) ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។ ( ខ្ញុំថ្វាយបង្គំ ) ព្រះសម្ពុទ្ធជាអគ្គនាយកក្នុងលោក ប្រាកដស្មើដោយចេតិយ ជាវិការនៃមាសទ្រង់រុងរឿង ដូចផ្ការាជព្រឹក្ស ឬដូចភ្លើងកំពុងឆេះ ទ្រង់ប្រសើរដូចខ្លាធំ និងគោឧសភៈ ឬដូចកេសររាជសីហ៍ មានជាតិដ៏ខ្ពស់ទ្រង់គង់លើអាសនៈ ទ្រង់ជាកំពូលនៃពួកសមណៈ មានភិក្ខុសង្ឃចោមរោម ។ លុះខ្ញុំថ្វាយបង្គំព្រះបាទា របស់ព្រះសាស្តាហើយបែរមុខទៅឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះខ្ញុំបានថ្វាយគ្រឿងក្រអូប និងកម្រងផ្កា ក្នុងកាលណា ។ ( កាលនោះ ) ខ្ញុំមិនដែលស្គាល់ទុគ្គតិ ដោយផលនៃសក្ការៈ ដែលខ្ញុំធ្វើចំពោះព្រះពុទ្ធដោយវិសេស នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៩ ខ្ញុំបានជាក្សត្រចក្កពត្តិ ១៦ ដង ព្រះនាមទេវគន្ធៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធមាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**គន្ធមាលិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## គន្ធមាលិយត្ថេរាបទាន

[ ៩៧ ] អបទានរបស់ព្រះគន្ធមាលិយត្ថេរ មានពាក្យផ្ដើមថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជាអ្នកមានទ្រព្យច្រើន មានភោគៈច្រើន ។ កុលបុត្តនោះជ្រះថ្លាក្នុងព្រះសាស្ដា ប្រមូលនូវគ្រឿងក្រអូបជាច្រើន មានខ្លឹមចន្ទន៍ កំញាន កប្បិរ និងក្រស្នាជាដើម សាងព្រះស្ដូបក្រអូបថ្វាយព្រះសាស្ដា ។ ខាងលើព្រះស្ដូបប្រក់ដោយផ្កាម្លិះ ហើយធ្វើការថ្វាយបង្គំព្រះពុទ្ធដោយអង្គ ៨ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ សោយសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង សម្បូរដោយទ្រព្យសម្បត្តិ ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មានក៏បានជាព្រះអរហន្ត ។

ក្នុងកាលខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះជាដើម ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ។ល។

**អដ្ឋកថាគន្ធមាលិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## តិបុប្ផិយត្ថេរាបទានទី ៦

[ ៩៨ ] ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញដើមប្រទៀង ( ជាពោធិព្រឹក្ស ) មានពណ៌ខៀវបំព្រង ហើយខ្ញុំរោយផ្កា ៣ ទង ( ត្រង់គល់ប្រទៀងនោះ ) ។ កាលនោះ ខ្ញុំរើសស្លឹកស្ងួតៗ យកទៅចោលខាងក្រៅ ហើយថ្វាយបង្គំដើមប្រទៀងនោះ ដូចជាថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ទ្រង់ស្អាតខាងក្នុង ស្អាតខាងក្រៅ មានព្រះហឫទ័យផុតស្រឡះ ( ចាកកិលេស ) មិនមានអាសវៈ ក្នុងទីចំពោះមុខ ហើយធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាដើមពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាដើមពោធិព្រឹក្ស ។ ក្នុងកប្បទី ៣០ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ១៣ ដង ព្រះនាមសមន្តបាសាទិកៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## តិបុប្ផិយត្ថេរាបទាន

[ ៩៨ ] *អបទានរបស់ព្រះតិបុប្ផិយត្ថេរ មានពាក្យផ្តើមថា* **មិគលុទ្ទោ បុរេ អាសឹ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការបានធ្វើមកហើយក្នុងព្រះពុទ្ធអង្គមុនៗ ព្រោះអកុសលណាមួយក្នុងវាងភពកាត់ផ្តាច់ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងត្រកូលព្រាន ធ្វើជាព្រានម្រឹគនៅក្នុងព្រៃ ។ ក្នុងកាលនោះ នាយព្រាននោះ ឃើញដើមប្រទៀងដែលជាឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគព្រះនាមវិបស្សី មានស្លឹកទន់ ឃោនឃាន មានពណ៌ខៀវស្រស់ មានរស្មីខៀវ គួរជាទីត្រេកអរនៃចិត្ត ទើបបូជាដោយផ្កា ៣ បេះស្លឹកចាស់ៗ ចោល ថ្វាយបង្គំប្រទៀងពោធិព្រឹក្សនោះ ដូចថ្វាយបង្គំក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសម្បត្តិហើយក្នុងទេវលោកនោះ ចុតិចាកទេវលោកនោះហើយ កើតក្នុងមនុស្ស សោយចក្កពត្តិសម្បត្តិជាដើមក្នុងមនុស្សនោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាមានចិត្តប្រកបដោយសោមនស្ស លះនូវផ្ទះ ចេញបួសហើយ មិនយូរប៉ុន្មានក៏បានជាព្រះអរហន្ត ។*

*ព្រះថេរៈ កាលសម្រេចនូវការត្រាស់ដឹងយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **មិគលុទ្ធោ បុរេ អាសឹ** *ដូច្នេះជាដើម ។*

*ក្នុងបទទាំងនោះ ឈ្មោះថា* **មិគ** *ព្រោះទៅ គឺដល់នូវការស្លាប់ ។ម្យ៉ាងទៀត ឈ្មោះថា* **មិគ** *ព្រោះដើរទៅ ស្វែងរកទៅ ប្រព្រឹត្តទៅ ។ ឈ្មោះថា* **មិគលុទ្ធ** *ព្រោះចង់បាន ចង់បានច្រើន ជាប់ចិត្តក្នុងការសម្លាប់ម្រឹគ ភ្ជាប់សេចក្តីថា ក្នុងកាលមុន គឺក្នុងសម័យដែលខ្ញុំធ្វើបុណ្យ ខ្ញុំបានជាព្រានម្រឹគនៅក្នុងព្រៃធំដែលហៅថា* **កាននេ** ។

*បទថា* **ចាដលឹ ហរិតំ ទិស្វា** *សេចក្តីថា ឈ្មោះថា* **ចាដលិ** *ព្រោះក្នុងដើមឈើនោះ មានសម្បកពណ៌ក្រហមទូទៅ ។ ហៅថា* **ចាដលិ** *ព្រោះមានផ្កាពណ៌ក្រហម អធិប្បាយថា ឃើញដើមពោធិ គឺដើមប្រទៀងដែលមានពណ៌ខៀវស្រស់ គឺមានពណ៌ខៀវ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ហើយ ៕*

**អដ្ឋកថាតិបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## មធុបិណ្ឌិកត្ថេរាបទានទី ៧

[ ៩៩ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថៈ ប្រសើរជាងពួកឥសី គួរទទួលនូវគ្រឿងបូជាក្នុងព្រៃធំ ជាទីស្ងាត់មិនមានសំឡេង មិនមានការរឹករវ ទ្រង់ជាមហានាគ មានទុក្ខរលត់ហើយ ជាបុរសអាជានេយ្យដ៏ប្រសើរ ទ្រង់រុងរឿងដូចផ្កាយព្រឹក្ស មានពួកទេវតានមស្ការហើយ ។ សេចក្តីត្រេកអររបស់ខ្ញុំ មានប្រមាណច្រើនកើតឡើងមុន ញាណក៏កើតឡើងក្នុងវេលានោះដែរ ខ្ញុំថ្វាយទឹកឃ្មុំចំពោះព្រះសាស្តា ដែលទើបចេញអំពីសមាធិ ។ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះបាទារបស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ដោយសិរ្សៈ ហើយបែរមុខទៅទិសខាងកើត ដើរចេញទៅ ។ ក្នុងកប្បទី ៣៤ ខ្ញុំកើតជាស្តេចឈ្មោះសុទស្សនៈ មានទឹកឃ្មុំហូរចេញអំពីក្រអៅឈូក ( ស្រក់ចុះទៅ ) ក្នុងភោជន ក្នុងវេលានោះ ទាំងភ្លៀងទឹកឃ្មុំ ក៏បង្អុរចុះ នេះជាផលនៃបុព្វកម្ម ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំថ្វាយទឹកឃ្មុំ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទឹកឃ្មុំ ។ ក្នុងកប្បទី ៣២ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ៤ ដង ព្រះនាម

សុទស្សនៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមធុបិណ្ឌិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**មធុបិណ្ឌិកត្ថេរាបទាន ចប់**

# អដ្ឋកថា

## មធុបិណ្ឌិកត្ថេរាបទាន

[ ៩៩ ] អបទានរបស់ព្រះមធុបិណ្ឌិកត្ថេរ មានពាក្យផ្ដើមថា **វិវនេ កាននេ ធិស្វា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតជាព្រាន អាស្រ័យនៅក្នុងព្រៃធំ ។ ក្នុងកាលនោះ កុលបុត្តនោះ បានឃើញព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ដែលប្រកបដោយការត្រេកអរក្នុងវិវេក បានថ្វាយទឹកឃ្មុំ មានរសឆ្ងាញ់ ដល់ព្រះមានព្រះភាគអង្គនោះ ដែលចេញអំពីសមាធិហើយ កុលបុត្តនោះ មានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគ ថ្វាយបង្គំហើយ ចៀសចេញទៅ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះសោយសម្បត្តិ ត្រាច់ទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វិវនេ កាននេ ធិស្វា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វិវនេ** សេចក្តីថា ព្រៃដែលផ្សាយទៅដោយពិសេស ឈ្មោះថា **វិវន** បានដល់ ព្រៃដែលមិនមានសំឡេងដំរី សេះ រថ និងសំឡេងស្គរ និងប្រាសចាកវត្ថុកាម និងកិលេសកាម ភ្ជាប់សេចក្តីថា ក្នុងព្រៃធំ ពោល គឺព្រៃជ្រៅដែលឥតសំឡេង ។ បទថា **ឱសធីវ ឆិរោចន្តំ** សេចក្តីថា ឈ្មោះថា **ឱសធ** ព្រោះញុំាងនូវការចង់បាន ការប្រាថ្នារបស់ជនដែលសាងសេចក្តីចម្រើនឲ្យសម្រេច ។ ជនទាំងឡាយអាស្រ័យហេតុ គឺការកើតឡើងរបស់ឱជៈ កាលផ្កាយណារះឡើង ទើបទៅដកយកថ្នាំមក ផ្កាយនោះ ឈ្មោះថា **ឱសធិ** កាលគួរនឹងពោលថា **ឱសធិតារកា ឥវ វិរោចន្តិ** បែរជាពោលថា **ឱសធីវ វិរោចន្តំ** ដើម្បីងាយស្រួលក្នុងការចងគាថា ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាមធុបិណ្ឌិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សេនាសនទាយកត្ថេរាបទានទី ៨

[ ១០០ ] ខ្ញុំបានថ្វាយកម្រាលស្លឹកឈើ ចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទាំងបានរោយរាយផ្កាច្បា ជាឧបការៈ ( ដល់កម្រាលស្លឹកឈើ ) ដោយជុំវិញទៀត ។ ( ដោយកុសលកម្មនេះ ) ខ្ញុំបានសោយ ( គ្រប់គ្រង ) ប្រាសាទទាំងឡាយផង គុហាជាទីរីករាយ មានថ្លៃច្រើនផង ផ្កាទាំងឡាយមានថ្លៃច្រើន តែងបង្អុរចុះលើសយនៈរបស់ខ្ញុំផង ។ ខ្ញុំដេកនទៀលលើសយនៈដ៏វិចិត្រក្រាលដោយផ្កាឈើ ទាំងភ្លៀងជាវិការនៃផ្កាឈើ ក៏តែងបង្អុរចុះលើសយនៈ ( របស់ខ្ញុំ ) ក្នុងកាលនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកម្រាលស្លឹកឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃកម្រាលស្លឹកឈើ ។ ក្នុងកប្បទី ៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៧ ដង ព្រះនាមបិតាសន្ទារកៈដូចគ្នា ទ្រង់ជាធំជាងពួកជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសេនាសនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*សេនាសនទាយកត្ថេរាបទាន ចប់*

# អដ្ឋកថា

## សេនាសនទាយកត្ថេរាបទាន

[ ១០០ ] អបទានរបស់ព្រះសេនាសនទាយកត្ថេរ មានពាក្យផ្ដើមថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា កាលព្រះមានព្រះភាគយាងមកកាន់ជាយព្រៃដែលជាលំនៅរបស់ខ្លួន បានថ្វាយបង្គំ ហើយក្រាលកម្រាលធ្វើដោយស្មៅថ្វាយ ។ ជុំវិញទីគន្ធរបស់ព្រះមានព្រះភាគ បានបូជាដោយផ្កាបាំងជុំវិញដោយផ្កា ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះមានព្រះភាគបួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលខាងក្រោយ លោករឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សិទ្ធត្ថស្ស ភគវតោ** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលខាងដើមនោះឯង ។៚

**អដ្ឋកថាសេនាសនទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វេយ្យាវច្ចករត្ថេរាបទានទី ៩

[ ១០១ ] ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាមេគណៈ ខ្ញុំជាអ្នកបម្រើ ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ។ ឯទេយ្យធម៌របស់ខ្ញុំគ្មាន ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា ជាព្រះសុគត ស្វែងរកគុណដ៏ធំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើការខ្វល់ខ្វាយបម្រើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការខ្វល់ខ្វាយបម្រើ ។ ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ ព្រះនាមសុចិន្តិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវេយ្យាវច្ចកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

វេយ្យាវច្ចកត្ថេរាបទាន ចប់

# អដ្ឋកថា

## វេយ្យាវច្ចកត្ថេរាបទាន

[ ១០១ ] *អបទានរបស់ព្រះវេយ្យាវច្ចកត្ថេរ មានពាក្យផ្តើមថា* **វិបស្សិស្ស ភគវតោ** *ដូច្នេះ ។*

*អត្ថុប្បត្តិហេតុរបស់អបទាននេះ គប្បីជ្រាបដោយន័យដូចពោលហើយខាងដើមនោះឯង ។ល។*

**អដ្ឋកថាវេយ្យាវច្ចកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ពុទ្ធុបដ្ឋាកត្ថេរាបទានទី ១០

[ ១០២ ] ខ្ញុំកើតជាអ្នកផ្គុំស័ង្ខ ជាអ្នកប្រកបដោយការបម្រើ ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាព្រះសុគត ព្រះអង្គស្វែងរក នូវគុណដ៏ធំជានិច្ច ។ ខ្ញុំតែងជួបផលនៃការបម្រើ ព្រះលោកនាថ ទ្រង់ប្រកបដោយតាទិគុណ គឺតូរ្យតន្ត្រី ៦០ ពាន់ តែងចោមរោម ខ្ញុំសព្វៗ កាល ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុ ដែលខ្ញុំបានបម្រើព្រះពុទ្ធ ជាមហាឥសី ក្នុងកាលនោះ ខ្ញុំមិន ដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ១៦ ដង ព្រះនាមមហា-និគ្ឃោសៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធុបដ្ឋាកត្ថេរមានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ពុទ្ធុបដ្ឋាកត្ថេរាបទាន ចប់

## ឧទ្ទាន

សុធាបិណ្ឌិយត្ថេរាបទាន ១ សុចិន្តិយត្ថេរាបទាន ១ អឌ្ឍ-ចេលកត្ថេរាបទាន ១ សូចិទាយកត្ថេរាបទាន ១ គន្ធមាលិយ-ត្ថេរាបទាន ១ តិបុប្ផិយត្ថេរាបទាន ១ មធុបិណ្ឌិយត្ថេរាបទាន ១ សេនាសនទាយកត្ថេរាបទាន ១ វេយ្យាវច្ចកត្ថេរាបទាន ១ ពុទ្ធុ-បដ្ឋាកត្ថេរាបទាន ១ ឯគាថាមានចំនួន ៩០ គត់ ដែលលោកសម្តែងហើយ ក្នុងវគ្គនេះ ។

**សុធាវគ្គទី ១០ ចប់**

មួយទៀត ឧទ្ទាននៃវគ្គ

ពុទ្ធវគ្គជាបឋម ១ សីហាសនិយវគ្គ ១ សុភូតិវគ្គ ១ កុណ្ឌ-ធានវគ្គ ១ ឧបាលិវគ្គ ១ វីជនីវគ្គ ១ សកចិត្តនិយវគ្គ ១ នាគ-សមាលវគ្គ ១ តិមិរបុប្ផិយវគ្គ ១ ជាគម្រប់ ១០ និងសុធាវគ្គ មានគាថា ១៤៥៥ ។

**ពុទ្ធវគ្គទសកៈ ចប់**

**បឋមសតកៈ ចប់**

# អដ្ឋកថា

## ពុទ្ធុបដ្ឋាកត្ថេរាបទាន

[ ១០២ ] អបទានរបស់ព្រះពុទ្ធុបដ្ឋាកត្ថេរ មានពាក្យផ្ដើមថា **វិបស្សិស្ស ភគវតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងត្រកូលអ្នកផ្លុំស័ង្ខ ចម្រើនវ័យហើយ បានជាអ្នកឈ្លាសក្នុងសិប្បៈ គឺក្នុងការផ្លុំស័ង្ខ ។ កុលបុត្តនោះផ្លុំស័ង្ខថ្វាយព្រះមានព្រះភាគអស់កាលជានិច្ច បូជាដោយសំឡេងស័ង្ខនោះឯង ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ មានឈ្មោះល្បីល្បាញប្រាកដទៅក្នុងទីគ្រប់ស្ថាន ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលដែលមានកេរ្តិ៍ឈ្មោះមួយកន្លែង ចម្រើនវ័យហើយ ប្រាកដឈ្មោះថា មធុស្សរៈ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ ខាងក្រោយ លោកប្រាកដឈ្មោះថា មធុរស្សរត្ថេរ ដូច្នោះ ។

ថ្ងៃមួយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាល ប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វិបស្សិស្ស ភគវតោ** ដូច្នេះជាដើម ។ ពាក្យនោះ ខ្ញុំបានអធិប្បាយហើយខាងដើមនោះឯង ។ បទថា **អហោសឹ សង្ខធមកោ** គប្បីជ្រាបថា ឈ្មោះថា ស័ង្ខ ព្រោះជីក អធិប្បាយថា ត្រាច់ទៅត្រង់មាត់ច្រាំងក្នុងសមុទ្ទ ។ ឈ្មោះថា **សង្ខធមក** ព្រោះផ្លុំស័ង្ខនោះ គឺធ្វើសំឡេងឲ្យកងរំពង អធិប្បាយថា ខ្ញុំនោះបានជាអ្នកផ្លុំស័ង្ខនោះឯង ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាពុទ្ធុបដ្ឋាកត្ថេរាបទាន ចប់

## សុធាវគ្គទី ១០ ចប់

# សុត្តន្តបិដក
# ខុទ្ទកនិកាយ បអបទាន
# ទុតិយភាគ

## ភិក្ខាទាយិវគ្គទី ១១

### ភិក្ខាទាយកត្ថេរាបទានទី ១

[ ១ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ មានវណ្ណៈដូចមាស ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់ចេញចាកព្រៃធំ គឺតណ្ហាមកកាន់ព្រះនិព្វាន ។ ខ្ញុំទៅតាមស្នាមព្រះបាទានៃព្រះពុទ្ធ ទ្រង់ញ៉ាំងជនឲ្យរលត់ទុក្ខ ហើយបានថ្វាយភិក្ខាមួយវែក ដល់ព្រះមហេសីព្រះនាមសិទ្ធត្ថៈ ទ្រង់មានប្រាជ្ញា មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ទ្រង់មិនញាប់ញ័រដោយលោកធម៌ សេចក្តីត្រេកអររបស់ខ្ញុំ មានប្រមាណច្រើន ចំពោះព្រះពុទ្ធ ជាអាទិច្ចពន្ធុ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយភិក្ខា ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ

៧ ជាតិ ព្រះនាមមហាវេណុដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា ព្រះភិក្ខុទាយកត្ថេរមានអាយុ បានសម្ដែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ភិក្ខាទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា
# ភិក្ខុនាយិវគ្គទី ១១

## ភិក្ខាទាយកត្ថេរាបទាន

[ ១ ] *អបទានរបស់ព្រះភិក្ខាទាយកត្ថេរ មានពាក្យផ្ដើមថា* **សុវណ្ណវណ្ណំ សម្ពុទ្ធំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ដល់ព្រមដោយទ្រព្យសម្បត្តិ កើតនូវសទ្ធា ឃើញព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ចេញអំពីវិហារ យាងទៅបិណ្ឌបាត មានចិត្តជ្រះថ្លា បានថ្វាយអាហារ ។ ព្រះមានព្រះភាគទ្រង់ទទួលអាហារនោះហើយ ត្រាស់អនុមោទនាហើយចៀសចេញទៅ ។ ដោយកុសលនោះឯង កុលបុត្តនោះតាំងនៅដរាបដល់អស់អាយុ ក្នុងទីបំផុតនៃអាយុកើត ក្នុងទេវលោក សោយកាមាវចរសម្បត្តិ ៦ ជាន់ ក្នុងទេវលោកនោះ និងសោយមនុស្សសម្បត្តិក្នុងមនុស្សលោក ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ បាននូវសទ្ធា បួសហើយ មិនយូរប៉ុន្មានក៏បានជាព្រះអរហន្ត ។*

ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សុវណ្ណវណ្ណំ សម្ពុទ្ធំ** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានន័យដូចពោលហើយនោះឯង ។ បទថា **បវរា អភិនិក្ខន្តំ** សេចក្តីថា ឈ្មោះថា **បវរ** ព្រោះគប្បីត្រេកអរ គឺគប្បីប្រាថ្នា អធិប្បាយថា ចេញអំពីទីដែលជាទីត្រេកអរនៃចិត្ត គឺចេញអំពីទីដែលស្ងាត់ដោយពិសេស ។ តណ្ហា លោកហៅថា **វាន** ក្នុងបទថា **វានា និព្វានមាគតំ** នេះ ឈ្មោះថា **និព្វាន** ព្រោះចេញចាកតណ្ហាដែលជាវានៈនោះ អធិប្បាយថា ធ្វើតណ្ហាដែលជាវានៈឲ្យជាប្រធាន ហើយលះកិលេសទាំងពួង សម្រេចព្រះនិព្វាន ។ បទថា **កដច្ឆុភិក្ខំ ទត្វាន** សេចក្តីថា វែក ដែលប្រើដែចាប់ ហៅថា **កដច្ឆុ** ។ ឈ្មោះថា **ភិក្ខា** ព្រោះអត្ថថា ជាវត្ថុដែលគេសូម គឺដែលគេសូម ម្យ៉ាងទៀត ឈ្មោះថា **ភិក្ខា** ព្រោះដែលបុគ្គលគប្បីបរិភោគ គឺគប្បីទំពាដោយពិសេស ។ ភិក្ខាដែលបុគ្គលកាន់យកដោយវែក ឈ្មោះថា **កដច្ឆុភិក្ខា** អធិប្បាយថា ថ្វាយកត្តុដោយវែក ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕៙

## អដ្ឋកថាភិក្ខាទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ញាណសញ្ញិកត្ថេរាបទានទី ២

[ ២ ] ( ខ្ញុំបានឃើញ ) នូវព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស ទ្រង់ដូចអាជានេយ្យដ៏ប្រសើរ ឬទ្រង់ដូចដំរីឈ្មោះមាតង្គៈ ដែលចុះប្រេង ៣ យ៉ាង ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់ញ៉ាំងទិសទាំងពួងឲ្យភ្លឺច្បាស់ ទ្រង់ដូចដើមសាលរាជ មានផ្ការីកហើយ ទ្រង់ជាច្បងក្នុងត្រៃលោក ទ្រង់ឧត្តមជាងនរៈ ទ្រង់ស្តេចនិមន្តទៅតាមប្រក បានញ៉ាំងចិត្តខ្ញុំឲ្យជ្រះថ្លាក្នុងញាណ ( របស់ព្រះអង្គ ) ខ្ញុំបានផ្គងអញ្ជលី មានចិត្តជ្រះថ្លា មានចិត្តរីករាយ ហើយថ្វាយបង្គំព្រះសិទ្ធត្ថៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសម្គាល់ក្នុងញាណ ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ជាស្តេចឧត្តមជាងជន ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះញាណសញ្ញិកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ញាណសញ្ញិកត្ថេរាបទាន ចប់

# អដ្ឋកថា

## ញាណសញ្ញិកត្ថេរាបទាន

[ ២ ] អបទានរបស់ព្រះញាណសញ្ញិកត្ថេរ មានពាក្យផ្ដើមថា **សុវណ្ណវណ្ណំ សម្ពុទ្ធំ** ដូច្នេះ ។

អ្វីជាអត្ថុប្បត្តិហេតុក្នុងរឿងនេះ ព្រះថេរៈអង្គនេះ ក៏ជាអ្នកមានអធិការ បានធ្វើហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យ នៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ កើតនូវសទ្ធា មានចិត្តសាទរ មានការអាល័យក្នុងការស្ដាប់ព្រះសទ្ធម្ម បញ្ជូនញាណទៅតាមក្រសែព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ជ្រះថ្លាក្នុងញាណរបស់ព្រះសាស្ដា ព្រោះភាពដែលខ្លួនជាអ្នកឲ្យនូវការសម្គាល់ក្នុងសំឡេង ទើបធ្វើការថ្វាយបង្គំដោយអង្គ ៥ និងអង្គ ៨ ហើយចៀសចេញទៅ ។ កុលបុត្តនោះចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសម្បត្តិក្នុងឆកាមាវចរទេវលោកនោះ ចុតិចាកទេវលោកនោះហើយ កើតក្នុងមនុស្សលោក សោយចក្កពត្តិសម្បត្តិជាដើម ដែលជាសម្បត្តិដ៏ប្រសើរក្នុងមនុស្សលោកនោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដែលសម្បូរដោយទ្រព្យសម្បត្តិ ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្រោយមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា

**សុវណ្ណាវណ្ណំ សមុត្តុំ** *ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយនោះឯង ។ បទថា* **និសភាជានិយំ យថា** *សេចក្តីថា គោដែលជាមេហ្វូងរបស់គោ ១ សែន ហៅថា* **និសភ** *គោនិសភៈនោះផង ជាគោអាជានេយ្យផង ឈ្មោះថា* **និសភាជានិយ:** *ព្រោះប្រសើរបំផុត ឧត្តមបំផុត អធិប្បាយថា ព្រះមានព្រះភាគដូចគោអាជានេយ្យ ។ លោកពោលយ៉ាងនោះ ដោយអំណាចឈ្មោះដែលសន្មតតាមលោកវិស័យ ។ ព្រោះព្រះមានព្រះភាគ មិនមានបុគ្គលប្រៀប ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ហើយ ។៚*

## អដ្ឋកថាញាណសញ្ញិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឧប្បលហត្ថិយត្ថេរាបទានទី ៣

[ ៣ ] ក្នុងកាលនោះ ខ្ញុំកើតជាអ្នកក្រងផ្កា នៅអាស្រ័យក្នុងក្រុងឈ្មោះតិវរា បានឃើញព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ មានធូលី គឺរាគៈទៅប្រាសហើយ ដែលសត្វលោកបូជាហើយ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្កាមួយក្ដាប់ ខ្ញុំទៅកើតក្នុងភពណាៗ តែងសោយផលជាទីប្រាថ្នា ដែលខ្លួនធ្វើល្អហើយក្នុងកាលមុន ( ក្នុងភពនោះៗ ) ដោយអំណាចអានិសង្សនៃកម្មនោះ ខ្ញុំមានផ្កាម្ទិះព័ទ្ធព័ន្ធហើយ នេះជាផលនៃសេចក្ដីសម្គាល់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ អាស្រ័យកប្បគម្រប់ ៩៤ វៀរលែងកប្បបច្ចុប្បន្ននេះចេញ ខ្ញុំបានកើតជាស្ដេច ៥០០ ជាតិ ព្រះនាមនដ្ឋបមៈដូចគ្នាក្នុងកប្បនោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ ហើយ ។

បានឮថា ព្រះឧប្បលហត្ថិយត្ថេរមានអាយុ បានសម្ដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឧប្បលហត្ថិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## ឧប្បលហត្ថិយត្ថេរាបទាន

[ ៣ ] *អបទានរបស់ព្រះឧប្បលហត្ថិយត្ថេរ មានពាក្យផ្ដើមថា* **តិវរាយំ និវាសីហំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលមាលាការ ចម្រើនវ័យហើយ លក់ផ្កាជាច្រើនចិញ្ចឹមជីវិត ដោយការងារនៃមាលាការរស់នៅ ។ ក្រោយមក ថ្ងៃមួយ ឃើញព្រះមានព្រះភាគ មានរស្មីរុងរឿងកំពុងយាងទៅ ដូចកែវមណីមានតម្លៃច្រើន ទើបបូជាដោយផ្កាឧប្បលក្រហម ។ កុលបុត្តនោះចុតិចាកអត្តភាពនោះហើយ សោយបុញ្ញសម្បត្តិក្នុងសុគតិ ដោយបុញ្ញកម្មនោះឯង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ កើតនូវសទ្ធាបួសហើយ មិនយូរប៉ុន្មានក៏បានជាព្រះអរហន្ត ។ ក្នុងកាលខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **តិវរាយំ និវាសីហំ** *ដូច្នេះជាដើម ។*

បណ្ដាបទទាំងនោះ បទថា **តិវរា** បានដល់ នគរដែលសាងដោយបិទការសញ្ចរទៅមក ៣ ដង ខ្ញុំនៅក្នុងតិវរានគរនោះ ឬនៅក្នុងផ្ទះដែលជាលំនៅរបស់ខ្លួន ។ បទថា **អហោសឹ មាលិកោ តទា** សេចក្ដីថា ក្នុងកាលនោះ គឺក្នុងសម័យដែលបំពេញបុញ្ញសម្ភារ ដើម្បីប្រយោជន៍ដល់ព្រះនិព្វាន ខ្ញុំជានាយមាលាការ ធ្វើការលក់ផ្កាចិញ្ចឹមជីវិត ។

បទថា **ពុទ្ធមទ្ទសំ** សេចក្ដីថា ខ្ញុំឃើញព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ បានថ្វាយផ្កាឧប្បលមួយក្ដាប់ធ្វើការបូជា ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាឧប្បលហត្ថិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បទបូជកត្ថេរាបទានទី ៤

[ ៤ ] ខ្ញុំបានថ្វាយផ្កាម្ទិះ ដល់ព្រះមានព្រះភាគ ទ្រង់ព្រះនាមសិទ្ធត្ថៈ ខ្ញុំបានរោយរាយផ្កា ៧ ត្រង់ព្រះបាទ ដោយសេចក្តីរីករាយ ខ្ញុំគ្របសង្កត់ពួកជន និងទេវតាក្នុងថ្ងៃនេះ ដោយកុសលកម្មនោះ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ ក្នុងកប្បគម្រប់ ៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៣ ជាតិ ព្រះនាមសមន្តគន្ធៈដូចគ្នា ទ្រង់ផ្សាយអាណាចក្រទល់នឹងសមុទ្រទាំង ៤ ជាទីបំផុត ទ្រង់ជាធំជាងគណៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបទបូជកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បទបូជកត្ថេរាបទាន ចប់**

# អដ្ឋកថា

## បទបូជកត្ថេរាបទាន

[ ៤ ] *អបទានរបស់ព្រះបទបូជកត្ថេរ មានពាក្យផ្ដើមថា* **សិទ្ធត្ថស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បូជាបាទមូលរបស់ព្រះមានព្រះភាគដោយផ្កាម្លិះ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសក្កសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះមានព្រះភាគ បួសហើយ ចម្រើនវិបស្សនា តាំងនៅក្នុងអរហត្តផល ។ ក្នុងកាលខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សិទ្ធត្ថស្ស ភគវតោ** *ដូច្នេះជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **ជាតិបុប្ផមទាសហំ** *កាលគួរនឹងពោលថា* **ជាតិសុមនបុប្ផំ អទាសិ អហំ** *លោកលុប* **សុមន** *សព្ទចេញ ដើម្បីងាយ*

ស្រួលក្នុងការចងគាថា ។ ដើមឈើដែលកើតក្នុងពូជនោះ ខណៈដែលរីក ធ្វើឲ្យកើតសោមនស្ស ហេតុនោះ ទើបឈ្មោះថា **សុមន** ។ ឈ្មោះថា **បុប្ផ** ព្រោះអត្ថថា រីក គឺបើកនូវត្របកផ្កានោះផង ធ្វើឲ្យត្រេកអរផង ព្រោះហេតុនោះ ទើបឈ្មោះថា **សុមនបុប្ផ** ព្រោះជាផ្កាដែលរីកដោយល្អ អធិប្បាយថា ខ្ញុំបានយកផ្កាម្លិះទាំងនោះ មកបូជាដល់ព្រះមានព្រះភាគព្រះនាមថា **សិទ្ធត្ថ** ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាបទុប្ផជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## មុដ្ឋិបុប្ផិយត្ថេរាបទានទី ៥

[ ៥ ] ក្នុងកាលនោះ ខ្ញុំកើតជាអ្នកក្រងផ្កា ឈ្មោះសុទស្សនៈ បានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈ ។ ខ្ញុំកាន់យកផ្កាម្ជិះ បូជាចំពោះព្រះបទុមុត្តរៈ ខ្ញុំមានចក្ខុស្អាត មានចិត្តរីករាយ បានសម្រេចទិព្វចក្ខុ ។ ខ្ញុំមិនដែលទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ដោយពុទ្ធបូជានេះផង ដោយការតម្កល់ចិត្តផង ។ ក្នុងកប្បទី ៣៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមទេវុត្តរ ដូចគ្នា មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមុដ្ឋិបុប្ផិយត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មុដ្ឋិបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## មុដ្ឋិបុប្ផិយត្ថេរាបទាន

[ ៥ ] *អបទានរបស់ព្រះមុដ្ឋិបុប្ផិយត្ថេរ មានពាក្យផ្តើមថា* **សុទស្សនោ នាម នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលអ្នកក្រងផ្កា ចម្រើនវ័យហើយ ដល់នូវការសម្រេចក្នុងសិប្បៈប្រចាំត្រកូល ថ្ងៃមួយឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ទើបយកដៃទាំងពីរក្បង់ផ្កាម្លិះរួត រោយចុះទៀបបាទមូលរបស់ព្រះមានព្រះភាគបូជា ដោយកុសល-សម្ភារនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ហើយសោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្តា ដោយអំណាចវាសនាក្នុងកាលមុន បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្រោយមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា*

**សុទស្សនោ នាមេន** *ដូច្នេះជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **សុទស្សនោ** *សេចក្ដីថា ឈ្មោះថា* **សុទស្សន** *ព្រោះអត្ថថា ល្អដោយលម្អនៃរូបសណ្ឋាន មានកម្ពស់ និងទំហំជាដើម អធិប្បាយថា ខ្ញុំបានជាមាលាការឈ្មោះសុទស្សនៈ បានបូជាព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ដោយផ្កាម្ទិះរួត ។ ពាក្យដ៏សេសក្នុងទីទាំងពួង មាន អត្ថងាយយល់ហើយ ។៘*

**អដ្ឋកថាមុដ្ឋិបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឧទកបូជកត្ថេរាបទានទី ៦

[ ៦ ] ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស ស្តេចនិមន្តទៅឰដ៏អាកាស រុងរឿងដូចភ្លើងចេះឆ្នាំងខ្លាញ់ ឬដូចភ្លើងកំពុងចេះភ្លឺរន្ទាល ។ ខ្ញុំកាន់យកទឹកដោយដៃ សាចទៅនាអាកាស ព្រះពុទ្ធមានព្យាយាមធំ ប្រកបដោយសេចក្តីករុណាចំពោះខ្ញុំ ទ្រង់ក៏ទទួល ( នូវទឹកនោះ ) ព្រះសាស្តាព្រះនាមបទុមុត្តរៈ ស្ថិតនៅនាអាកាស ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ហើយទ្រង់សម្តែងគាថាទាំងនេះថា ក្នុង ១ សែនកប្ប អ្នកនឹងមិនទៅកាន់ទុគ្គតិ ដោយការថ្វាយទឹកនេះផង ដោយការញ៉ាំងបីតិឲ្យកើតឡើងផង ។ បពិត្រព្រះអង្គជាធំជាងសត្វជើង ២ ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈ ខ្ញុំព្រះអង្គលះបង់នូវការឈ្នះ និងការចាញ់ហើយ បានដល់នូវអចលដ្ឋាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ១៦៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ទ្រង់ព្រះនាមសហស្សរាជដូចគ្នា ទ្រង់ផ្សាយអាណាចក្រទល់នឹងសមុទ្ទទាំង ៤ ទ្រង់ជាធំជាងពួកជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកបូជកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## ឧទកបូជកត្ថេរាបទាន

[ ៦ ] *អបទានរបស់ព្រះឧទកបូជកត្ថេរ មានពាក្យផ្តើមថា* **សុវណ្ណវណ្ណំ សម្ពុទ្ធំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ដឹងដល់កុសលកម្ម និងអកុសលកម្ម ជ្រះថ្លាក្នុងរស្មីដែលមានពណ៌ ៦ ដែលផ្សាយចេញអំពីព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទើបយកដៃទាំងពីរក្បង់ទឹកបូជា ។ ទឹកដែលកុលបុត្តនោះបូជា ដូចជាពពុះប្រាក់អណ្តែតលើអាកាស កុលបុត្តនោះជ្រះថ្លាក្រៃលែង កើតក្នុងទេវលោកជាន់តុសិតជាដើម ដោយសោមនស្សនោះឯង សោយនូវទិព្វសម្បត្តិ ក្រោយមកសោយនូវមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលជាខាងក្រោយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សុវណ្ណ-វណ្ណំ សម្ពុទ្ធំ** *ដូច្នេះជាដើម ។ ពាក្យនោះ ខ្ញុំបានអធិប្បាយហើយខាងដើមនោះឯង ។ សប្បិ លោកហៅថា* **ឃត** *ក្នុងបទថា* **ឃតាសនំវ ជលិតំ** *នេះ ។*

ទីរម្ងាស់ គឺទីទ្រទ្រង់នូវយញ្ញៈ ព្រោះហេតុនោះ ទើបឈ្មោះថា **យញ្ញាសន** បានដល់ ភ្លើង ។ ម្យ៉ាងទៀត ធម្មជាតណាវមែងស៊ី គឺបរិភោគវត្ថុនោះ ហេតុនោះ វត្ថុនោះ ឈ្មោះថា **យញ្ញាសនំ** គឺភ្លើងនោះឯង អធិប្បាយថា ព្រះមានព្រះភាគរុងរឿងដូចគំនរភ្លើង ដូចភ្លើងឆេះក្រៃលែងឡើង អណ្តាតភ្លើងក៏រឹតតែរុងរឿងក្រៃលែងដូច្នោះ ។ បទថា **អាទិត្តំវ ហុតាសនំ** សេចក្តីថា គ្រឿងសក្ការបូជា លោកហៅថា **ហុត** ទីដែលទ្រទ្រង់វត្ថុដែលគេនាំមកបូជា គឺបូជាសក្ការៈ ព្រោះហេតុនោះ ទើបឈ្មោះថា **ហុតាសន** ភ្ជាប់សេចក្តីថា ខ្ញុំបានឃើញព្រះសម្មាសម្ពុទ្ធដែលមានពណ៌ដូចមាស រុងរឿងដោយមហាបុរិសលក្ខណៈ ៣២ មានមណ្ឌលនៃរស្មី ១ ព្យាម ដូចព្រះអាទិត្យរុងរឿងយាងទៅកណ្តាលអាកាស ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាឧទកបូជកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឆឡមាលិយត្ថេរាបទានទី ៧

[ ៧ ] ព្រះបទុមុត្តរសម្ពុទ្ធ ជាច្បងក្នុងលោក ជាតាទិបុគ្គល ទ្រង់គង់លើកម្រាលស្មៅ មានព្រះហឫទ័យស្ងប់រម្ងាប់ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំកាន់យកផ្កាបបុស ចងធ្វើជាផ្ចិត បង្អោនថ្វាយព្រះពុទ្ធ ទ្រង់ជាធំជាងសត្វជើង ២ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ។ ព្រះសព្វញ្ញូជាលោកនាយក ទ្រង់ទទួលផ្ចិតហើយ ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ទើបទ្រង់សម្តែងគាថានេះថា កាយរបស់តថាគតរលត់ទុក្ខហើយ សេចក្តីក្តៅក្រហាយ មិនមានឡើយ យ៉ាងណាមិញ ចិត្តរបស់អ្នក ចូររួចស្រឡះចាកភ្លើងទាំង ៣ ប្រការយ៉ាងនោះដែរ ។ ទេវតាណាមួយអាស្រ័យដើមឈើ ទេវតាទាំងអស់នោះ មកប្រជុំគ្នា ( ដោយបំណងថា ) ពួកយើងនឹងស្តាប់នូវពុទ្ធវចនៈ ដែលញ៉ាំងទាយកឲ្យរីករាយ ។ ឯព្រះមានព្រះភាគ មានពួកទេវតាចោមរោម ទ្រង់គង់លើកម្រាលនោះ ទ្រង់ញ៉ាំងទាយកឲ្យរីករាយ ហើយសម្តែងនូវគាថាទាំងនេះថា កុលបុត្តនេះ នឹងកើតជាស្តេចចក្កពត្តិ មាននាមថាសុព្វតរាជ ដោយការថ្វាយនូវផ្ចិតនេះផង ដោយការតម្កល់ចិត្តផង កុលបុត្តនោះ ជាបុគ្គលត្រូវកុសលមូលជាស់តឿនហើយនឹងបានជាស្តេចចក្កពត្តិទៀត មាននាមថា មាលុតរាជ ដោយសេសផលនៃកម្មនោះ ។ ក្នុង ១ សែនកប្ប កុលបុត្តនេះ

មិនដែលទៅកាន់ទុគ្គតិ ដោយការថ្វាយផ្ចិតនេះផង ដោយការរាប់អានដ៏ធំទូលាយផង ។ ក្នុង ៣ ហ្មឺនកប្ប នឹងបានជាក្សត្រ ៣៨ ជាតិ ក្សត្រទាំងនោះ ព្រះនាមថាសុពូតរាជ ក្នុង ២៩០០០ កប្ប បានជាក្សត្រ ៨ ជាតិ ទ្រង់ព្រះនាមមាលុតរាជ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទន្សមាលិយត្ថេរមានអាយុ បានសម្ដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

នទ្សមាលិយត្ថេរាបទាន ចប់

ភាណវារទី ៧ ចប់

# អដ្ឋកថា

## នឡមាលិយត្ថេរាបទាន

[ ៧ ] *អបទានរបស់ព្រះនឡមាលិយត្ថេរ មានពាក្យផ្តើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងជាតិជាអនេក ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងកាម លះផ្ទះ បួសជាតាបស នៅក្នុងព្រៃហិមពាន្ត ឃើញព្រះមានព្រះភាគយាងទៅក្នុងទីនោះ មានចិត្តជ្រះថ្លា ក្រាលនូវកម្រាលស្មៅ យកផ្កាបបុសធ្វើជាផ្ចិតព័តថ្វាយ ព្រះមានព្រះភាគដែលគង់លើកម្រាលនោះ ។ ព្រះមានព្រះភាគទ្រង់ទទួលហើយ បានធ្វើអនុមោទនាដើម្បីទ្រង់អនុគ្រោះដល់កុលបុត្តនោះ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ជាអ្នកប្រាសចាកការក្តៅក្រហាយ និងជួបតែសេចក្តីសុខកាយសុខចិត្ត គ្រប់ភពដែលខ្លួនកើតសោយសុខជាអនេក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្តា ដោយកម្លាំងវាសនាក្នុងកាលមុន បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្រោយមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរពុទ្ធស្ស***ដូច្នេះជាដើម ។ ពាក្យនោះខ្ញុំបានអធិប្បាយខាងដើមហើយ ។*

*បទថា* **ឆទ្ធ** *ក្នុងបទថា* **ឆទ្ធមាលំ គហេត្វាន** *ឈ្មោះថា* **ឆទ្ធ** *ព្រោះមិនមានក្លិន ជាឈើតូចស្តើងជាងដើមឫស្សី ។ បាច់ គឺផ្កានៃដើមបបុស ឈ្មោះថា* **ឆទ្ធមាលំ** *ក្តាប់សេចក្តីថា ខ្ញុំបានធ្វើផ្ចិតដោយបាច់បបុសនោះ ។ ឈ្មោះថា* **ពីជនី** *ព្រោះជាគ្រឿងបក់ឲ្យកើតខ្យល់ ។ ខ្ញុំបានបង្អោនផ្ចិតនោះចូលទៅថ្វាយព្រះពុទ្ធ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕*

## អដ្ឋកថាឆទ្ធមាលិយត្ថេរាបទាន ចប់

## ភាណវារៈទី ៧ ចប់

# សុត្តន្តបិដក

## អាសនុបដ្ឋាយកត្ថេរាបទានទី ៨

[ ៨ ] ខ្ញុំចូលទៅកាន់ព្រៃធំ ដ៏ស្ងាត់មិនមានសំឡេង មិនរឹករវរ ខ្ញុំថ្វាយសីហាសនៈ ដល់ព្រះសម្ពុទ្ធព្រះនាមអត្ថទស្សី ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំកាន់យកផ្កាមួយក្តាប់ ធ្វើប្រទក្សិណព្រះអង្គ ហើយចូលទៅអង្គុយជិតព្រះសាស្តា រួចដើរចេញទៅបែរមុខឆ្ពោះកាន់ឧត្តរទិស ។ បពិត្រព្រះអង្គ ជាធំជាងសត្វជើង ២ ទ្រង់ជាច្បងក្នុងលោក ទ្រង់ប្រសើរជាងនរៈ ខ្ញុំធ្វើខ្លួនឲ្យរលត់ផុតមានសេសសល់ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ដោយសារកម្មនោះ ។ ក្នុងកប្បទី ១៨០០ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសីហាសនៈ ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសន្និព្វាបកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាសនុបដ្ឋាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អាសនុបដ្ឋាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## អាសនុបដ្ឋាយកត្ថេរាបទាន

[ ៨ ] *អបទានរបស់ព្រះអាសនុបដ្ឋាយកត្ថេរ មានពាក្យផ្ដើមថា* **កាននំ វនមោគ្គយ្ហ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងផ្ទះមានត្រកូល នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះ លះនូវការគ្រប់គ្រងផ្ទះ ចេញបួសជាតាបស នៅក្នុងព្រៃហិមពាន្ត ឃើញព្រះមានព្រះភាគយាងទៅក្នុងទីនោះ មានសេចក្ដីជ្រះថ្លា បានថ្វាយសីហាសនៈ ហើយកាន់យកបាច់ផ្កាមកបូជាព្រះមានព្រះភាគ ដែលគង់លើអាសនៈនោះ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ដោយបុញ្ញកម្មនោះ លោកអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ជាអ្នកមានត្រកូលខ្ពស់ ដល់ព្រមដោយទ្រព្យសម្បត្តិក្នុងភពដែលខ្លួនកើតហើយ តមក គឺក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ លោកបានជាព្រះអរហន្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **កាននំ វនមោគ្គយ្ហ** *ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ៕*

**អដ្ឋកថាអាសនុបដ្ឋាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ពិឡាលិទាយកត្ថេរាបទានទី ៩

[ ៩ ] ខ្ញុំនៅជិតព្រៃហិមពាន្ត អង្គុយលើកម្រាលស្លឹកឈើ ក្នុងកាលនោះ ខ្ញុំមានសេចក្តីជាប់ជំពាក់ ក្នុងគ្រឿងទទួលទាន ដូចបុរសល្មោភជេក ។ ខ្ញុំកំពុងជីកមើមដំឡូងជ្វា និងដំឡូងវល្លិផង ដំឡូងដៃខ្លា និងដំឡូងជ្រូកផង ខ្ញុំនាំមកនូវផ្លែពុទ្រា ផ្លែក្រខុប និងផ្លែញ្ញៅ ដែលខ្ញុំតាក់តែងហើយ ។ ព្រះលោកវិទូ ទ្រង់ព្រះនាមបទុមុត្តរៈ គួរទទួលគ្រឿងបូជា ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ទើបនិមន្តមកកាន់សម្នាក់ខ្ញុំ ខ្ញុំបានឃើញនូវព្រះមហានាគជាទេវតាប្រសើរជាងទេវតា ជានរាសភៈ ទ្រង់ចូលមកជិត ខ្ញុំក៏យកដំឡូងដៃខ្លាដាក់ចុះក្នុងបាត្រ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធជាមហាវីរៈ ទ្រង់ញុំាងខ្ញុំឲ្យត្រេកអរហើយ ទ្រង់សោយ លុះព្រះសព្វញ្ញូសោយរួចហើយ ទើបសម្តែងគាថានេះថា អ្នកបូរញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយថ្វាយដំឡូងដៃខ្លាដល់តថាគត អ្នកនឹងមិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ។ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ភពទាំងអស់ខ្ញុំបានគាស់រំលើងហើយ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្ប

ទី ៥៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ឈ្មោះសុមេខ-លិរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពិឡាលិទាយកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ពិឡាលិទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ពិឡាលិទាយកត្ថេរាបទាន

[ ៩ ] *អបទានរបស់ព្រះពិឡាលិទាយកត្ថេរ មានពាក្យផ្តើមថា* **ហិមវន្តស្សាវិទូរេ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងការនៅគ្រប់គ្រងផ្ទះ ទើបលះនូវការគ្រប់គ្រងផ្ទះ ចេញបួសជាតាបសក្នុងព្រៃហិមពាន្ត ជាអ្នកប្រាថ្នាតិច សន្តោសក្រៃលែង ញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដោយមើមដំឡូងជាដើម ។ កាលនោះ ព្រះមានព្រះភាគបទុមុត្តរៈ បានយាងទៅកាន់ព្រៃហិមពាន្តនោះ ដើម្បីអនុគ្រោះកុលបុត្តនោះ កុលបុត្តនោះឃើញព្រះសាស្តាហើយ ជ្រះថ្លា ថ្វាយបង្គំហើយ កាន់យកមើមដំឡូងដាក់ក្នុងបាត្រ ។ ព្រះតថាគតកាលធ្វើឲ្យកុលបុត្តនោះកើតនូវសោមនស្ស ទើបសោយមើមដំឡូងនោះ ដើម្បីជាការអនុគ្រោះ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះចុតិចាកអត្តភាពនោះហើយ សោយសម្បត្តិទាំងពីរ ក្នុងទេវតា និងមនុស្សទាំងឡាយ*

ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា ទើបចេញបួសក្នុងសាសនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយខាងដើមនោះឯង ។ មើមជំឡូងនិងជំឡូងវល្លិជាដើម ជាឈ្មោះរបស់មើមផ្សេងៗ នោះឯង ។៚

**អដ្ឋកថាពិឡាលិទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វេណុបូជកត្ថេរាបទានទី ១០

[ ១០ ] ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស ទ្រង់ដូចព្រះអាទិត្យ មានរស្មីច្រើន ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង ឬដូចព្រះចន្ទ្រពេញវង់ ទ្រង់មានពួកសាវកចោមរោម ដូចផែនដីមានសមុទ្ទ ( ព័ទ្ធជុំវិញ ) ខ្ញុំយកលម្អងផ្កាខ្លឹងទាំងឡាយ បូជាចំពោះព្រះវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាលម្អងផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ទ្រង់ព្រះនាមវេណុរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវេណុបូជកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

វេណុបូជកត្ថេរាបទាន ចប់

## ឧទ្ទាន

ភិក្ខទាយកត្ថេរាបទាន ១ ញាណសញ្ញិកត្ថេរាបទាន ១ ឧប្បលហត្ថិយត្ថេរាបទាន ១ បទបូជកត្ថេរាបទាន ១ មុដ្ឋិបុប្ផិយត្ថេរាបទាន ១ ឧទកបូជកត្ថេរាបទាន ១ នឡមាលិយត្ថេរាបទាន ១ អាសនុបដ្ឋាយកត្ថេរាបទាន ១ ពិឡាលិទាយកត្ថេរាបទាន ១ រេណុបូជកត្ថេរាបទាន ១ មានគាថា ៦៦ ។

**ភិក្ខទាយិវគ្គទី ១១ ចប់**

# អដ្ឋកថា

## វេណុបូជកត្ថេរាបទាន

[ ១០ ] *អបទានរបស់ព្រះវេណុបូជកត្ថេរ មានពាក្យផ្ដើមថា* **សុវណ្ណវណ្ណំ សម្ពុទ្ធំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញព្រះមានព្រះភាគរុងរឿងដូចគំនរភ្លើង មានចិត្តជ្រះថ្លា កាន់យកកេសរផ្កាខ្ទឹងបូជាលំដាប់នោះ ព្រះមានព្រះភាគទ្រង់បានធ្វើអនុមោទនា ។*

*ដោយបុញ្ញកម្មនោះ កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ បានទទួលការបូជាគ្រប់ភពដែលខ្លួនកើត ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា ដោយកម្លាំងនៃវាសនារបស់ខ្លួនបួសក្នុងសាសនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ឃើញបុព្វកម្មរបស់ខ្លួនដោយទិព្វចក្ខុ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សុវណ្ណវណ្ណំ សម្ពុទ្ធំ** *ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ។*

*បទថា* **សតរំសឹវ ភាណុមំ** *សេចក្តីថា រង្សី គឺរស្មីមានប្រមាណ ១០០ គឺមានចំនួន ១០០ របស់ព្រះអាទិត្យណាមាន ព្រះអាទិត្យនោះ ឈ្មោះថា* **សតរំសិ** *។ លោកពោល* **សតរំសី** *ដើម្បីងាយស្រួលក្នុងការចងគាថា អធិប្បាយថា មានរស្មីច្រើនរយ ច្រើនសែន រស្មី លោកហៅថា* **ភាណុ** *។ ពន្លឺ គឺរស្មីរបស់បុគ្គលណាមាន បុគ្គលនោះ ឈ្មោះថា* **ភាណុម** *សេចក្តីថា ខ្ញុំបានឃើញព្រះមានព្រះភាគព្រះនាមវិបស្សី ជាបុគ្គលដូចព្រះអាទិត្យ ពោល គឺជាបុគ្គលមានរស្មី បានកាន់យកនូវកេសរផ្កាខ្ទឹងរោយធ្វើការបូជា ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថាវេណុបូជកត្ថេរាបទាន ចប់**

**ភិក្ខុទាយិវគ្គទី ១១ ចប់**

# សុត្តន្តបិដក
# មហាបរិវារវគ្គទី ១២

## មហាបរិវារត្ថេរាបទានទី ១

[ ១១ ] ក្នុងកាលនោះ ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ជានរាសភៈ ស្តេចចូលទៅឯក្រុងពន្ធុមៈ ជាមួយនឹងពួកភិក្ខុ ៦៨០០០ អង្គ ។ ខ្ញុំចេញទៅអំពីទីក្រុង ដើរសំដៅទៅកាន់ទីបចេតិយ បានឃើញព្រះសម្ពុទ្ធ មានធូលី គឺរាគៈទៅប្រាសហើយ ទ្រង់គួរទទួលនូវគ្រឿងបូជា ។ ពួកយក្ស ៨៤០០០ រូប តែងបម្រើខ្ញុំដោយគោរព ដូចពួកទេវតាបម្រើព្រះឥន្ទ្រ ។ គ្រានោះ ខ្ញុំដើរចេញអំពីលំនៅ កាន់យកសំពត់ រួចថ្វាយបង្គំដោយសិរសា ហើយថ្វាយសំពត់នោះ ដល់ព្រះមហេសីសម្ពុទ្ធ ( ដោយសេចក្តីជ្រះថ្លាថា ) ឱ ព្រះពុទ្ធទាំងឡាយ ឱ ព្រះធម៌ទាំងឡាយ ឱ សម្បទារបស់ព្រះសាស្តានៃយើង ផែនទេះញាប់ញ័រ ដោយអានុភាពរបស់ព្រះពុទ្ធ ។ ខ្ញុំឃើញនូវហេតុដ៏អស្ចារ្យចម្លែកគួរព្រឺរោមនោះ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ជាធំជាងសត្វជើង ២ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ លុះខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លា ក៏ថ្វាយសំពត់ដល់ព្រះសាស្តា ខ្ញុំព្រមទាំងអាមាត្យនិងជនជាបរិស័ទ ក៏បានដល់នូវព្រះពុទ្ធជាទីពឹង ។ ក្នុងកប្បទី ៩១

អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ទ្រង់ព្រះនាម វាហនៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មាន កម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំ បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះមហាបរិវារត្ថេរមានអាយុ បានសម្តែង ហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## មហាបរិវារត្ថេរាបទាន ចប់

# អដ្ឋកថា
# មហាបរិវារវគ្គទី ១២

## មហាបរិវារត្ថេរាបទាន

[ ១១ ] *អបទានរបស់ព្រះមហាបរិវារត្ថេរ មានពាក្យផ្ដើមថា* **វិបស្សី នាម ភគវា** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សីកើតឡើង កុលបុត្តនោះកើតក្នុងកំណើតយក្ស មានយក្សច្រើនសែនជាបរិវារ សោយទិព្វសុខក្នុងកោះតូចៗមួយកន្លែង ។ ត្រង់កោះនោះ មានវិហារប្រដាប់ដោយព្រះចេតិយមួយខ្នង ដ៏ស្អាត ។ ព្រះមានព្រះភាគ យាងទៅត្រង់វិហារនោះ ។ កាលនោះឯង សេនាបតីយក្សមើលឃើញព្រះមានព្រះភាគអង្គនោះ យាងទៅវិហារនោះ ទើបកាន់យកសំពត់ទិព្វច្រើនផ្ទាំង ថ្វាយបង្គំព្រះមានព្រះភាគ ដែលទ្រង់យាងទៅ ហើយបូជាដោយសំពត់ទិព្វទាំងឡាយ យក្ស មួយអន្លើដោយបរិវារ ក៏បានដល់ព្រះពុទ្ធជាសរណៈ ។ ដោយបុញ្ញកម្មនោះ យក្សនោះ មួយអន្លើដោយបរិវារ ចុតិអំពីទីនោះហើយ បានទៅកើតក្នុងទេវលោកខ្លះ មនុស្សលោកខ្លះ សោយសេចក្ដីសុខក្នុងកាមាវចរសួគ៌ ៦ ជាន់ ។ ក្នុងកាលតមក*

ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្តា ទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វិបស្សី ឆាម ភគវា** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ មានអធិប្បាយថា ឈ្មោះថា **វិបស្សី** ព្រោះអត្ថថា រមែងឃើញបរមត្ថធម៌យ៉ាងពិសេស គឺព្រះនិព្វាន ។ម្យ៉ាងទៀត ឈ្មោះថា **វិបស្សី** ព្រោះអត្ថថា រមែងឃើញពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិប្បដ្ឋានជាដើម គ្រប់យ៉ាងបានជាក់ច្បាស់ ម្យ៉ាងទៀត ឈ្មោះថា **វិបស្សី** ព្រោះអត្ថថា រមែងឃើញសត្វដែលគួរដល់ត្រាស់ដឹង មានប្រការផ្សេងៗ ច្រើន បែកជាពួកៗ ។ ព្រះមានព្រះភាគព្រះនាមថា **វិបស្សី** អង្គនោះ បានយាងទៅកាន់វិហារ ជាស្ថានទីដែលគួរដល់ការបូជាប្រចាំកោះ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្ទើ មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាមហាបរិវារត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សុមង្គលត្ថេរាបទានទី ២

[ ១២ ] ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ជានរាសភៈ ស្តេចចេញអំពីវិហារ ចូលសំដៅទៅកាន់ស្រះ ។ លុះព្រះសម្ពុទ្ធ ទ្រង់ស្រង់ និងសោយរួចហើយ ទ្រង់មានតែចីវរមួយ ស្តេចយាងឡើងមក ព្រះមានព្រះភាគទ្រង់ឈរក្រឡេកមើលទិសធំទិសតូច ក្នុងទីនោះ ។ ខ្ញុំចូលទៅក្នុងលំនៅបានឃើញព្រះលោកនាយក កាលនោះ ខ្ញុំជាអ្នករីករាយ ក៏ទះដៃដោយចិត្តរីករាយ ។ ទើបខ្ញុំប្រកបក្នុងការរាំច្រៀង និងប្រគំតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ( ថ្វាយ ) ចំពោះព្រះសម្ពុទ្ធ ទ្រង់រុងរឿងដូចព្រះអាទិត្យ ភ្លឺប្រាលដូចមាស ខ្ញុំទៅកើតក្នុងកំណើតណាៗ ទោះបីជាទេវតា ឬជាមនុស្ស ខ្ញុំតែងគ្របសង្កត់នូវសត្វទាំងពួងបាន ខ្ញុំរមែងមានយសដ៏ធំ ។ បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមព្រះនមស្ការចំពោះព្រះអង្គ បពិត្រព្រះមុនីព្រះអង្គទ្រង់ធ្វើព្រះអង្គឲ្យត្រេកអរ ហើយធ្វើអ្នកដទៃឲ្យត្រេកអរផង ។ ខ្ញុំអង្គុយកំណត់ធ្វើនូវសេចក្តីរីករាយ ជាអ្នកមានវត្តល្អ

បម្រើនូវព្រះសម្ពុទ្ធ ហើយបានទៅកើតក្នុងតុសិត ។ ក្នុងកប្បទី ១៦០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៨ ជាតិ ព្រះនាមឯកចិន្តិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមង្គលត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុមង្គលត្ថេរាបទាន ចប់

# អដ្ឋកថា

## សុមង្គលត្ថេរាបទាន

[ ១២ ] អបទានរបស់ព្រះសុមង្គលត្ថេរ មានពាក្យផ្ដើមថា **អត្ថទស្សី ជិនវរោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតជារុក្ខទេវតា ក្នុងទីជិតស្រះមួយកន្លែង សម័យនោះ ព្រះមានព្រះភាគយាងចេញអំពីវិហារ មានបំណងនឹងស្រង់ទឹក ទើបយាងទៅកាន់ច្រាំងនៃស្រះនោះ ទ្រង់ស្រង់ទឹកត្រង់ស្រះនោះហើយ មានចីវរមួយជាន់ ប្រថាប់ឈរដូចព្រហ្ម ល្អរុងរឿងដូចព្រះអាទិត្យបញ្ចេញពន្លឺ និងដូចបដិមាមាស ។ កាលនោះ ទេវបុត្តនោះកើតនូវសោមនស្ស ទើបលើកដៃប្រណម្យ ហើយពោលពាក្យសរសើរ និងយកតន្ត្រីទិព្វរបស់ខ្លួនលេងថ្វាយ ។ ដោយបុញ្ញកម្មនោះ ទេវបុត្តនោះ ក៏បានសោយសគ្គសម្បត្តិ និងមនុស្សសម្បត្តិដ៏ច្រើន ។ ក្នុងកាលតមក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បានចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្រោយមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អត្ថទស្សី ជិនវរោ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ មានអធិប្បាយថា ឈ្មោះថា **អត្ថទស្សី** ព្រោះអត្ថថា ជាអ្នកឃើញ គឺឃើញច្បាស់នូវ

បរមត្ថធម៌ បានដល់ ព្រះនិព្វាន ឬម្យ៉ាងទៀត ឈ្មោះថា **អត្ថទស្សី** ព្រោះអត្ថថា មានប្រក្រតីសម្លឹងឃើញប្រយោជន៍ គឺអរិយសច្ច ៤ ដែលមានដល់សត្វទាំងពួង ។ ឈ្មោះថា **ជិន** ព្រោះអត្ថថា បានឈ្នះហើយ កំពុងឈ្នះ នឹងឈ្នះ នូវកិលេសទាំងឡាយ ។ ឈ្មោះថា **វរ** ព្រោះអត្ថថា ដែលពួកសត្វចង់បាន គឺប្រាថ្នានឹងបាន ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **អត្ថទស្សី** ផង ឈ្មោះថា **ជិន** ផង ឈ្មោះថា **វរ** ផង ហេតុនោះ ទើបហៅថា **អត្ថទស្សីជិនវរ** ។ បទថា **លោកជេដ្ឋោ** មានវិគ្គហៈថា ឈ្មោះថា **លោក** ព្រោះអត្ថថា រមែងបែកធ្លាយ គឺវិនាសទៅ ។ ម្យ៉ាងទៀត ឈ្មោះថា **លោក** ព្រោះអត្ថថា ជាអ្នកសម្រេចដល់ត្រើយ ជារបស់ដែលព្រះពុទ្ធជាដើមទ្រង់ឃើញ គឺប្រាកដបានច្បាស់ ។ លោក ៣ បញ្ចូលគ្នាហៅថា **លោក** ។ កាលគួរពោលថា **លោកា** តែលោកហៅថា **លោកោ** ( ដោយអំណាចឯកសេសសមាស ) ព្រះពុទ្ធ ឈ្មោះថា **លោកជេដ្ឋ** ព្រោះជាបុគ្គលប្រសើររបស់សត្វលោក ព្រះពុទ្ធអង្គនោះ ជាបុគ្គលប្រសើររបស់សត្វលោក គឺជាអ្នកអង់អាចជាងនរៈ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាសុមង្គលត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សរណាគមនិយត្ថេរាបទានទី ៣

[ ១៣ ] សង្គ្រាមរបស់ពួកទេវរាជទាំង ២ ព្រះអង្គតាំងផ្ដើមឡើង មានកងទ័ពតាំងឡើងព្រម សំឡេងគឹកកងខ្លាំងប្រព្រឹត្តទៅ ។ ព្រះលោកវិទូ ព្រះនាមបទុមុត្តរៈ ព្រះអង្គគួរទទួលនូវគ្រឿងបូជា ជាព្រះសាស្ដា ទ្រង់ស្ថិតនៅនាអាកាស ហើយញុំាងមហាជនឲ្យកើតសង្វេគ ទេវតាទាំងអស់ មានចិត្តរីករាយ ក៏ទម្លាក់អាវក្រោះនិងអាវុធចុះ ហើយថ្វាយបង្គំព្រះសម្ពុទ្ធ ជាពួកទេព មានចិត្តមូលតែមួយ ក្នុងវេលានោះ ។ ព្រះលោកវិទូទ្រង់អនុគ្រោះ ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ ហើយទ្រង់បន្លឺឡើងនូវវាចាដ៏អង់អាច ទ្រង់ញុំាងមហាជនឲ្យរលត់ទុក្ខ ( ដោយព្រះពុទ្ធដីកាថា ) មនុស្សមានចិត្តប្រទូស្ត បៀតបៀនតែសត្វមួយ នឹងទៅកើតក្នុងអបាយដោយចិត្តប្រទូស្តនោះ ។ អ្នកទាំងឡាយ គួរញុំាងចិត្តរបស់ខ្លួនឲ្យរលត់ អ្នកទាំងឡាយ កុំបៀតបៀនសត្វរឿយៗ ឡើយ ដូចជាដំរីដ៏ប្រសើរដែលបៀតបៀនសត្វច្រើន ក្នុងប្រធាននៃសង្គ្រាមនោះឡើយ ។ ឯពួកសេនារបស់ស្ដេច នៃទេវតាទាំងសងខាង បានស្ងប់ហើយ បានដល់នូវព្រះលោកជេដ្ឋ ជាតាទិបុគ្គលដ៏ប្រសើរ ជាទីពឹង ។ ព្រះចក្ខុមសម្ពុទ្ធ ទ្រង់ធ្វើប្រជុំជនឲ្យយល់ច្បាស់ ទ្រង់ស្រោចស្រង់ប្រជុំជន ហើយទ្រង់ក្រឡេកមើល បែរព្រះភក្ត្រទៅកាន់ឧត្តរទិស ចៀសចេញទៅចាកពួកទេវតា ។ ខ្ញុំ

បានដល់នូវសរណគមន៍ជាដំបូង ចំពោះព្រះពុទ្ធ ជាធំជាងពួកសត្វជើង ២ ជាតាទិបុគ្គល ខ្ញុំមិនដែលទៅកាន់ទុគ្គតិ អស់ ១ សែនកប្ប ។ ក្នុងកប្បទី ៣០០០០ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ទ្រង់ព្រះនាមមហាចុន្ទកិដូចគ្នា ទ្រង់ប្រសើរក្នុងរថ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណគមនិយត្ថេរមានអាយុ បានសម្តែងហើយ ដូចគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សរណគមនិយត្ថេរាបទាន ចប់

# អដ្ឋកថា

## សរណាគមនិយត្ថេរាបទាន

[ ១៣ ] អបទានរបស់ព្រះសរណាគមនិយត្ថេរ មានពាក្យផ្ដើមថា **ឧភិន្នំ ទេវរាជូនំ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពដែលខ្លួនកើតហើយកើតទៀត ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់កើតឡើង កើតជាស្ដេចទេវតាក្នុងព្រៃហិមពាន្ត ។ សម័យមួយ កាលផ្ដើមធ្វើសង្គ្រាមជាមួយស្ដេចយក្ខដែលជាសត្រូវ ស្ដេចយក្ខទាំងពីរ មានយក្ខច្រើនពាន់ជាបរិវារ នាំគ្នាកាន់ខែល និងអាវុធជាដើម ចូលមកប្រឈមគ្នាដើម្បីធ្វើសង្គ្រាម ។ កាលនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់កើតសេចក្ដីករុណាក្នុងសត្វទាំងនោះ ទើបយាងទៅកាន់ទីនោះតាមអាកាស ហើយទ្រង់សម្ដែងធម៌ដល់ព្រះរាជាទាំងពីរចំណែក មួយអន្លើដោយបរិវារ ក្នុងកាលនោះ ព្រះរាជាទាំងពីរចំណែក មួយអន្លើយដោយបរិវារ បោះបង់ខែល និងអាវុធថ្វាយបង្គំព្រះមានព្រះភាគ ដោយសេចក្ដីគោរពរាប់អានច្រើន ហើយបានដល់នូវព្រះពុទ្ធជាសរណៈ ។ ក្នុងចំនួនពួកទេវតាទាំងនោះ ស្ដេចទេវតានេះ បានដល់នូវសរណៈជាដំបូង ។ ដោយបុណ្យនោះ ស្ដេចទេវតានោះអន្ទោលទៅក្នុងទេវលោក និងមនុស្សលោកច្រើនជង់ បានសោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាសនា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលក្នុងកាលមុន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឧភិន្នំ ទេវរាជូនំ** ដូច្នេះជាដើម ។ ក្នុងពាក្យផ្ដើមនោះ មានអធិប្បាយថា ស្ដេចយក្សទាំងពីរ មិនប្រាកដឈ្មោះ និងគោត្រ ដូចជាសុចិលោមយក្ស ខរលោមយក្ស អាឡវកយក្ស កុម្ភីរៈ និងកុវេរៈជាដើម ។ ព្រះថេរៈកាលសម្ដែងអាងដល់ដោយប្រារព្ធឈ្មោះ ទើបលោកពោលពាក្យថា **ឧភិន្នំ ទេវរាជូនំ** ដូច្នេះជាដើម ។

បទថា **សង្គាមោ សមុបដ្ឋិតោ** សេចក្ដីថា ឈ្មោះថា **សង្គាម** ព្រោះអត្ថថា ចូលទៅដោយល្អ គឺចូលទៅដើម្បីជម្លោះ សង្គ្រាមនោះមានការត្រៀមយ៉ាងល្អ គឺចូលទៅតាំងមាំក្នុងទីមួយកន្លែង ។ បទថា **អហោសិ សមុបព្យូឡ្ហោ** សេចក្ដីថា ជាពួកចូលទៅប្រកៀកគ្នាយ៉ាងព្រមព្រៀង ។

បទថា **សំវេជេសិ មហាជនំ** សេចក្ដីថា ព្រះមានព្រះភាគគង់ក្នុងអាកាស ហើយញ៉ាំងពួកយក្សទាំងនោះ ឲ្យកើតនូវសេចក្ដីសង្វេគ ដោយព្រះធម្មទេសនា គឺអរិយសច្ច ៤ បានដល់ ទ្រង់ឲ្យកាន់យក គឺឲ្យជ្រាប ឲ្យត្រាស់ដឹង ដោយទ្រង់ចង្អុលបង្ហាញដល់ទោស ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាសរណាគមនិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឯកាសនិយត្ថេរាបទានទី ៤

[ ១៤ ] គ្រានោះ ខ្ញុំកើតជាទេវរាជឈ្មោះវរុណៈ មានយានពលវាហនៈ បានចូលទៅបម្រើព្រះសម្ពុទ្ធ កាលព្រះអត្ថទស្សី ឧត្តមជាងសត្វជើងពីរ ជាលោកនាថ ទ្រង់បរិនិព្វានហើយ ខ្ញុំនាំយកតូរ្យតន្ត្រីទាំងពួង ទៅកាន់ពោធិព្រឹក្សដ៏ប្រសើរ ។ ខ្ញុំប្រមូលគ្រឿងដេញដំទាំងអស់ ចូលទៅបម្រើដើមពោធិព្រឹក្សដ៏ប្រសើរ ដោយការប្រគំ និងការរាំ ដូចជាបម្រើព្រះសម្ពុទ្ធ ក្នុងទីចំពោះព្រះភក្ត្រ ។ ខ្ញុំបម្រើដើមពោធិព្រឹក្សក្នុងទីនោះ ជាឈើដុះលើផែនដី ខ្ញុំអង្គុយផ្គត់ភ្នែន ធ្វើកាលកិរិយាក្នុងទីនោះ ។ ខ្ញុំប្រារព្ធនូវអំពើរបស់ខ្លួន មានចិត្តជ្រះថ្លាចំពោះពោធិព្រឹក្សដ៏ប្រសើរ ក៏បានទៅកើតក្នុងស្ថាននិម្មានរតី ដោយចិត្តជ្រះថ្លានោះ ។ តូរ្យតន្ត្រី ៦០០០០ តែងហែហមខ្ញុំសព្វៗ កាល ដែលកំពុងប្រព្រឹត្តទៅក្នុងពួកមនុស្ស និងទេវតា ក្នុងភពតូច និងភពធំ ។ ភ្លើង ៣ ប្រការរបស់ខ្ញុំរលត់ហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រ ៣៤ ជាតិ

មានព្រះនាមសុពាហុដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនិយត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ឯកាសនិយត្ថេរាបទាន ចប់

# អដ្ឋកថា

## ឯកាសនិយត្ថេរាបទាន

[ ១៤ ] *អបទានរបស់ព្រះឯកាសនិយត្ថេរ មានពាក្យផ្តើមថា* **វរុណោ នាម នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតជាស្តេចទេវតា ឈ្មោះវរុណៈ ។ វរុណទេវតានោះ ឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លាមួយអន្លើដោយបរិវារចូលមកគាល់ បូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម និងដោយចម្រៀង ។ ក្នុងកាលដទៃអំពីកាលនោះមក កាលព្រះមានព្រះភាគបរិនិព្វានហើយ ស្តេចទេវតា មួយអន្លើដោយបរិវារទាំងនោះ បាននាំគ្រឿងតន្ត្រីគ្រប់ប្រភេទ និងអ្នកសម្តែងតន្ត្រី មកធ្វើនូវការសម្តែងត្រង់ដើមមហាពោធិ៍របស់ព្រះមានព្រះភាគអង្គនោះ ដូចគ្នានឹងនៅក្នុងទីចំពោះព្រះភក្ត្រព្រះសម្ពុទ្ធដូច្នោះ ។ ដោយបុណ្យនោះ ស្តេចទេវតានោះ ចុតិអំពីទេវលោកនោះហើយ មកកើតក្នុងនិម្មានរតីទេវលោក ។ កាលស្តេចទេវតានោះបានសោយសគ្គសម្បត្តិយ៉ាងនេះហើយ ចំណេរតមក បានកើតជាមនុស្ស ក្នុងពួកមនុស្ស បានសោយចក្កពត្តិសម្បត្តិទៀត ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ទើបបួសក្នុងសាសនារបស់ព្រះសាស្តា ។ ក្នុងកាលមិនយូរក៏បានសម្រេចជាព្រះអរហន្ត ។ ក្រោយ*

មក ព្រះថេរៈបានរឭកដល់កម្មរបស់ខ្លួន ដឹងដល់កម្មនោះ តាមសេចក្ដីពិតហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វរុណោ នាម នាមេន** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ក្នុងសេចក្ដីថា ក្នុងពេលដែលខ្ញុំបូជាព្រះពុទ្ធ និងពោធិព្រឹក្ស ដើម្បីការត្រាស់ដឹងព្រមនោះ ខ្ញុំបានជាទេវតា ឈ្មោះវរុណៈ ។ គប្បីជ្រាបអត្ថវិគ្គហៈក្នុងបទថា **ធរណីរុហបាទបំ** ដូច្នេះថា ឈ្មោះថា **ធរណី** ព្រោះទ្រទ្រង់នូវដើមឈើ វល្លិ ភ្នំ និងរតនៈ ៧ ប្រការជាដើមបាន ។ ឈ្មោះថា **ធរណីរុហា** ព្រោះដុះដាលតាំងមាំនៅលើផែនដីនោះ ។ ឈ្មោះថា **បាទប** ព្រោះផឹកទឹកដោយជើង អធិប្បាយថា បឺតទឹកដែលស្រោចហើយដោយឫស បានដល់ រមែងផ្សាយសេនៃអាបោ តាមដើម មែក និងពាងជាដើម ក្នុងសេចក្ដីថា ( ខ្ញុំបម្រើ ) ដើមឈើ គឺដើមពោធិ៍នោះ ។ បទថា **សក្កកម្មាភិរតោ** ក្នុងសេចក្ដីថា ខ្ញុំត្រេកអរ ជ្រះថ្លាដោយកុសលកម្មរបស់ខ្លួន គឺជ្រះថ្លាក្នុងដើមពោធិ៍ដ៏ឧត្តម ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាឯកាសនិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សុវណ្ណបុប្ផិយត្ថេរាបទានទី ៩

[ ១៥ ] ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ជានាយកៈ ទ្រង់គង់សម្ដែងអមតបទដល់ពួកជន ។ ខ្ញុំស្ដាប់ធម៌ របស់ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាធំជាងសត្វជើងពីរ ជា តាទិបុគ្គល ហើយបានថ្វាយផ្កាជាវិការនៃមាស ៤ ទង ចំពោះ ព្រះសម្ពុទ្ធ ។ ក្នុងកាលនោះ បរិស័ទមានចំនួនត្រឹមណា ដំបូលជា វិការនៃមាស ក៏មានចំនួនត្រឹមនោះ ពន្លឺដ៏ធំទូលាយក៏កើតប្រាកដ ឡើង ព្រោះរស្មីព្រះពុទ្ធ និងរស្មីមាស ។ ខ្ញុំមានចិត្តខ្ពស់ឯក មានចិត្តរីករាយ មានសេចក្ដីត្រេកអរកើតឡើង ខ្ញុំធ្វើអញ្ជលី ញុំាងបីតិឲ្យកើតឡើង ចំពោះពន្លឺទាំងនោះ នាំមកនូវសេចក្ដីសុខ ក្នុងបច្ចុប្បន្ន ទើបថ្វាយបង្គំអាពធនាព្រះសម្ពុទ្ធ ទ្រង់មានវត្តល្អ ញុំាងប្រាមោទ្យឲ្យកើត ហើយចូលទៅកាន់លំនៅរបស់ខ្លួន ។ លុះខ្ញុំចូលទៅកាន់លំនៅហើយ ក៏រឭកនូវព្រះពុទ្ធដ៏ប្រសើរ ខ្ញុំក៏ បានទៅកើតក្នុងស្ថានតុសិត ដោយសេចក្ដីជ្រះថ្លានោះឯង ។ ក្នុង កប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិន ដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤៣ អំពី

កប្បនេះ ខ្ញុំបានកើតជាស្តេច ១៦ ជាតិ ព្រះនាមនេមិសម្មតៈ ដូចគ្នា ជាស្តេចចក្កពត្តិ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុវណ្ណបុប្ផិយត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុវណ្ណបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## សុវណ្ណបុប្ផិយត្ថេរាបទាន

[ ១៥ ] *អបទានរបស់ព្រះសុវណ្ណបុប្ផិយត្ថេរ មានពាក្យផ្តើមថា* **វិបស្សី នាម ភគវា** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតជាភុម្មដ្ឋកទេវបុត្ត ក្នុងទីមួយកន្លែង បានស្តាប់ធម៌របស់ព្រះមានព្រះភាគអង្គនោះហើយ មានចិត្តជ្រះថ្លាបូជាដោយផ្កា ៤ ទង ផ្កាទាំងនោះបានក្លាយជាពិតានមាស ផ្សាយទៅក្នុងអាកាស ។ រស្មីនៃមាស និងរស្មីនៃព្រះសរីរៈរបស់ព្រះពុទ្ធ រួមគ្នាជាពន្លឺតែមួយ ក្លាយជាពន្លឺដ៏មហាសាល ។ ទេវបុត្តនោះ មានសេចក្តីជ្រះថ្លាពន់ពេកត្រឡប់ទៅដល់វិមានរបស់ខ្លួនហើយ រឭកដល់ជានិច្ច ដោយបុញ្ញកម្មនោះ ទេវបុត្តនោះអន្ទោលទៅក្នុងសុគតិទាំងឡាយ មានស្ថានសួគ៌ជាន់តុសិតជាដើម សោយទិព្វសម្បត្តិហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បានបួសថ្វាយជីវិតក្នុងសាសនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលតមក ព្រះថេរៈបានរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **វិបស្សី នាម ភគវា** *ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថតាមដែលពោលហើយខាងដើមនោះឯង ។*

បទថា **ចាមោជ្ជំ ជនយិត្វាន** សេចក្តីថា ញ៉ាំងបីតិដែលមានកម្លាំងឲ្យកើតឡើងហើយ គឺឲ្យកើតនូវការពេញចិត្ត ការត្រេកអរ ដូចក្នុងប្រយោគថា សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល សេចក្តីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណរ ការអណ្តែតអណ្តូង សេចក្តីត្រេកអររបស់ចិត្តជាដើម ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាសុវណ្ណបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចិតកបូជកត្ថេរាបទានទី ៦

[ ១៦ ] ខ្ញុំ និងអាមាត្យ ព្រមទាំងជនជាបរិស័ទ នៅក្បែររាជាយតនៈ ( ដើមកែស ) កាលព្រះមានព្រះភាគទ្រង់បរិនិព្វាន ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ដើរទៅកាន់ជើងថ្ករបស់ព្រះសិខី ជាលោកពន្ធុ ខ្ញុំប្រគំតូរ្យតន្ត្រី ហើយបានរោយរាយគ្រឿងក្រអូប និងផ្កាកម្រងក្នុងទីនោះ ។ ខ្ញុំបូជាជើងថ្ករ រួចហើយ ថ្វាយបង្គំជើងថ្ករ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ទើបចូលទៅកាន់លំនៅរបស់ខ្លួន ។ លុះចូលទៅក្នុងលំនៅហើយ ក៏រឭកនូវការបូជាជើងថ្ករ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំសោយសម្បត្តិ ក្នុងទេវលោក និងមនុស្សលោក លះបង់នូវការឈ្នះ និងការចាញ់ ហើយបានដល់នូវអចលដ្ឋាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។ ក្នុងកប្បទី ២៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមឧគ្គតរាជដូចគ្នា ទ្រង់មានកម្លាំង

ច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរមានអាយុ បានសម្ដែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចិតកបូជកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ចិតកបូជកត្ថេរាបទាន

[ ១៦ ] *អបទានរបស់ព្រះចិតកបូជកត្ថេរ មានពាក្យផ្តើមថា* **វសាមិ រាជាយតនេ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពដែលខ្លួនកើត ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតជារុក្ខទេវតា ត្រង់ដើមកែស ក្នុងវាំងនោះ បានស្តាប់ធម៌រួមជាមួយពួកទេវតា ជ្រះថ្លាហើយ កាលព្រះមានព្រះភាគនិព្វានហើយ មួយអន្លើដោយបរិវារ នាំគ្នាកាន់គ្រឿងក្រអូប ប្រទីប ធូបក្រអូប ផ្កា និងស្គរជាដើម ទៅកាន់ឈាបនដ្ឋានរបស់ព្រះមានព្រះភាគ បូជាដោយប្រទីបជាដើម បូជាព្រះមានព្រះភាគអង្គនោះដោយតន្ត្រី និងគ្រឿងប្រគំច្រើនប្រភេទ ។ តាំងអំពីនោះមក កាលត្រឡប់ចូលទៅកាន់វិមានរបស់ខ្លួន ក៏រឭកដល់ព្រះមានព្រះភាគជានិច្ច ហាក់ដូចជាកំពុងថ្វាយបង្គំក្នុងទីចំពោះព្រះភក្ត្រ ។ ដោយបុណ្យនោះឯង រុក្ខទេវតានោះមានចិត្តជ្រះថ្លា ចុតិចាកដើមកែស ទៅកើតក្នុងជាន់តុសិតជាដើម សោយទិព្វសម្បត្តិហើយ បន្ទាប់អំពីនោះ កើតក្នុងមនុស្ស សោយមនុស្សសម្បត្តិក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយមានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគ ទើបបួសក្នុងសាសនារបស់ព្រះមានព្រះភាគ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វសាមិ រាជាយតនេ** ដូច្នេះជាដើម ។

បទថា **រាជាយតនេ** បានដល់ លំនៅរបស់ស្តេចទេវតា ។ម្យ៉ាង ទៀត ពាក្យថា **រាជាយតន** នោះ ជាឈ្មោះរបស់ដើមឈើ ។ បទថា **បរិនិព្វុតេ ភគវតិ** ក្លាប់សេចក្តីថា ក្នុងពេលរម្ងត់ខន្ធបរិនិព្វាន ដោយ មិនមានសេសសល់នៃព្រះមានព្រះភាគ ដ៏ជាលោកពន្ធុ ព្រះនាមសិខី បរិនិព្វានហើយ ។

បទថា **ចិតកំ អគមាសហំ** មានវិគ្គហៈថា ឈ្មោះថា **ចិត** ព្រោះជា គំនរ គឺទីប្រជុំនូវឈើក្រអូប មានចន្ទន៍ ក្រស្នា ទេពទារូ កប្បូរ និងក្រវាញ ជាដើម ។ **ចិត** នោះឯង ជា **ចិតក** អធិប្បាយថា ខ្ញុំបានទៅកាន់ទីជិតជើងថ្ករ ដើម្បីបូជាជើងថ្ករដោយគោរពក្នុងព្រះពុទ្ធ ។ កាលសម្តែងដល់កិច្ចដែលខ្លួន ទៅធ្វើក្នុងទីនោះ ទើបព្រះថេរៈពោលពាក្យថា **តុរិយំ តត្ថ វាទេត្វា** ដូច្នេះ ជាដើម ។ ពាក្យទាំងអស់នោះ ដឹងបានងាយហើយ ។

## អដ្ឋកថាចិតកបូជកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ពុទ្ធសញ្ញកត្ថេរាបទានទី ៧

[ ១៧ ] ព្រះវិបស្សីសម្ពុទ្ធ ជាកំពូលក្នុងលោក ទ្រង់ដាក់អាយុសង្ខារ ក្នុងកាលណា ផែនដី និងសមុទ្ទក៏កម្រើក ញាប់ញ័រ ក្នុងកាលនោះ ។ សូម្បីលំនៅរបស់ខ្ញុំដ៏វិចិត្រស្អាត ទូលាយ ប្រាកដដូចធ្លាក់ចុះ ឃ្លាតចេញ កម្រើក ញាប់ញ័រ ក្នុងកាលជាទីអស់ទៅនៃព្រះជន្មាយុរបស់ព្រះពុទ្ធ ។ កាលដែលលំនៅនៃខ្ញុំញាប់ញ័រហើយ ខ្ញុំក៏មានសេចក្តីតក់ស្លុតកើតឡើងថា ពន្លឺដ៏ធំបានកើតឡើងហើយ ដើម្បីអ្វីហ្ន៎ ឬក៏ព្រះបាទវេស្សវណស្តេចមកក្នុងទីនេះ ញុំាងមហាជនឲ្យរលត់ទុក្ខ ឱមែន ភ័យដែលកើតដល់ជីវិត មិនមានទេ ខ្ទួនអ្នកឯង ត្រូវតែមានសេចក្តីគោរព ត្រូវមានចិត្តនឹងតែមួយ ឱ ព្រះពុទ្ធ ឱ ព្រះធម៌ ឱ សម្បទារបស់ព្រះសាស្តានៃយើង ព្រោះកាលដែលព្រះអង្គត្រាស់ឡើង ( ក្នុងលោក ) មហាប្រឹថពី ក៏កម្រើក ញាប់ញ័រដែរ ។ ខ្ញុំសរសើរនូវពុទ្ធានុភាព ( យ៉ាងនេះ ) ក៏បានរីករាយ ក្នុងស្ថានសួគ៌អស់មួយកប្ប ថែមទាំងខ្ញុំធ្វើកុសលកម្ម ក្នុងកប្បដ៏សេសទាំងឡាយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវ

សេចក្ដីសម្គាល់ ខ្ញុំមិនដែលស្គាល់ទុក្ខ នេះជាផលនៃសេចក្ដីសម្គាល់ក្នុងព្រះពុទ្ធ ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ មានព្រះនាមសមិតរាជ ទ្រង់មានព្យាយាមមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធសញ្ញកត្ថេរមានអាយុ បានសម្ដែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ពុទ្ធសញ្ញកត្ថេរាបទាន ចប់

# អដ្ឋកថា

## ពុទ្ធសញ្ញកត្ថេរាបទាន

[ ១៧ ] អបទានរបស់ព្រះពុទ្ធសញ្ញកត្ថេរ មានពាក្យផ្ដើមថា **យទា វិបស្សី លោកគ្គោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតជាទេវបុត្ត ក្នុងកុម្ភជ្ឈកវិមានមួយកន្លែង ។ វេលានោះ ជាពេលដែលព្រះមានព្រះភាគព្រះនាមវិបស្សីទ្រង់ដាក់នូវអាយុសង្ខារ កាលនោះ មុឺននៃលោកធាតុទាំងមូល មួយអន្លើដោយសាគរ និងភ្នំ ក៏កើតការញាប់ញ័រខ្វល់ខ្វាយ ។ គ្រានោះ សូម្បីវិមានទេវបុត្តនោះក៏ញាប់ញ័រដែរ ។ ខណៈនោះ ទេវបុត្តកើតសេចក្ដីសង្ស័យ គិតថា ផែនដីកម្រើក ព្រោះអ្វីហេតុហ្ន៎ ក៏ដឹងថា ព្រះពុទ្ធទ្រង់ដាក់នូវអាយុសង្ខារ ក៏កើតសេចក្ដីសោក និងទោមនស្សដ៏ធំ ។ គ្រានោះ ស្ដេចវេស្សវណមហារាជក៏យាងមកលួងលោមទេវបុត្តនោះថា អ្នកកុំគិតថ្វីឡើយ ។ ដោយបុណ្យនោះ ទេវបុត្តនោះ ចុតិចាកភពនោះហើយ អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ទើបលះឃរាវាស បួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **យទា វិបស្សី លោកគ្គោ** ដូច្នេះជាដើម ។ បទថា **អាយុសង្ខារមោស្សជ្ជិ** មានវិគ្គហៈថា ឈ្មោះថា **អាយុ** ព្រោះគ្រប់គ្រងរក្សាសត្វទាំងឡាយដោយជុំវិញ ។ សង្ខាររបស់អាយុ គឺភាពជាគំនរ ឈ្មោះថា **អាយុសង្ខារ** ។ ព្រះមានព្រះភាគទ្រង់ដាក់ ទ្រង់លះបង់ ទ្រង់បោះបង់អាយុសង្ខារនោះ ។ ក្នុងការដាក់អាយុសង្ខារនោះ ។ ភ្ជាប់សេចក្តីថា ផែនដីក្នុងម៉ឺនចក្កវាឡទាំងមូលប្រកបដោយទឹក និងប្រដាប់ដោយសាគរ បានញាប់ញ័រហើយ ។

បទថា **ឱតតំ វិត្ថតំ មយ្ហំ** សេចក្តីថា វិមានរបស់ខ្ញុំខ្ពស់ ធំ ទូលាយ ល្អ វិចិត្រ ស្អាត បរិសុទ្ធយ៉ាងល្អ ស្រស់សោភា ប្រដាប់ដោយរតនៈ ៧ ប្រការជាច្រើន បានញាប់ញ័រហើយ គឺញាប់ញ័រទូទៅ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។ល។

**អដ្ឋកថាពុទ្ធសញ្ញកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## មគ្គសញ្ញកត្ថេរាបទានទី ៨

[ ១៨ ] ពួកសាវ័ករបស់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ជាអ្នកត្រាច់ទៅក្នុងព្រៃ វង្វេងគ្នាក្នុងព្រៃធំ ដូចជាមនុស្សខ្វាក់ ។ ពួកសាវ័កទាំងនោះ ជាបុត្តរបស់ព្រះមុនីនោះ វង្វេងក្នុងព្រៃធំ ក៏រឭកនូវព្រះសម្ពុទ្ធបទុមុត្តរៈជានាយក ។ ខ្ញុំក៏ចុះចាកលំនៅ ដើរមកក្នុងសម្នាក់របស់ភិក្ខុ ហើយប្រាប់ផ្លូវផង ប្រគេនភោជនផង ដល់សាវ័កទាំងនោះ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ទ្រង់ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត ក៏បានដល់នូវអរហត្ត ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១២ ជាតិ ព្រះនាមសចក្ខុរាជដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមគ្គសញ្ញកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**មគ្គសញ្ញកត្ថេរាបទាន ចប់**

# អដ្ឋកថា

## មគ្គសញ្ញកត្ថេរាបទាន

[ ១៨ ] *អបទានរបស់ព្រះមគ្គសញ្ញកត្ថេរ មានពាក្យផ្តើមថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតជាទេវបុត្ត ត្រង់ហិមវន្តប្បទេស កាលសាវករបស់ព្រះសម្ពុទ្ធទៅក្នុងព្រៃវង្វេងផ្លូវ កំពុងរកផ្លូវចេញអំពីព្រៃ បានប្រគេនអាហារឲ្យសាវកនោះឆាន់ ហើយប្រាប់ផ្លូវ ។ ដោយបុណ្យនោះ ទេវបុត្តនោះ បានសោយសគ្គសម្បត្តិ និងមនុស្សសម្បត្តិ ជាអ្នកមិនវង្វេងផ្លូវ ជាអ្នកពូកែខាងចាំក្នុងភពដែលខ្លួនកើត ក្នុងពុទ្ធុប្បាទកាលនេះ កុលបុត្តនោះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ មិនជាប់ចិត្តក្នុងឃរាវាស ទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរពុទ្ធស្ស** *ដូច្នេះជាដើម ។*

បទថា **សាវកា វនចារិនោ** ក្លាប់សេចក្តីថា ឈ្មោះថា **សាវក** ព្រោះតាំងចិត្តស្តាប់ពាក្យប្រៀនប្រដៅ ដែលព្រះមានព្រះភាគត្រាស់សម្តែង ដោយប្រពៃ គឺដោយអើពើ ម្យ៉ាងទៀត ឈ្មោះថា **សាវក** ព្រោះតាំងចិត្ត ស្តាប់ព្រះសទ្ធម្ម ដោយបញ្ជូនញាណទៅតាមគន្លងធម្មទេសនារបស់ព្រះមាន ព្រះភាគ សរុបសេចក្តីថា សាវកទាំងឡាយ ដែលត្រាច់ចារិកទៅក្នុងព្រៃ វង្វេងផ្លូវ គឺធ្វើដំណើរទៅក្នុងព្រៃ វង្វេងដូចមនុស្សខ្វាក់ប្រាសចាកភ្នែកត្រាច់ ទៅ ដូច្នោះ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាមគ្គសញ្ញកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បច្ចុបដ្ឋានសញ្ញកត្ថេរាបទានទី ៩

[ ១៩ ] កាលព្រះសុគតព្រះនាមអត្ថទស្សី ទ្រង់បរិនិព្វាន ខ្ញុំបាន ទៅកើតក្នុងកំណើតយក្សក្នុងលំដាប់ស្មើគ្នា កាលនោះ ខ្ញុំបានដល់ នូវយស ។ ខ្ញុំគិតថា អត្តភាពជាមនុស្ស អាត្មាអញបានមិនល្អ ភ្លឺស្វាងមិនល្អ តាំងឡើងមិនល្អ ព្រោះថា កាលដែលភោគៈរបស់ អាត្មាអញនៅមាន ព្រះសម្ពុទ្ធមានចក្ខុទ្រង់បរិនិព្វាន សាវកឈ្មោះ សាគរៈ ជ្រាបច្បាស់នូវតម្រិះរបស់ខ្ញុំ លោកប្រាថ្នានឹងស្រង់ខ្ញុំ ទើបនិមន្តមកក្នុងសម្នាក់ខ្ញុំ ( ហើយពោលថា ) នែបុរសអ្នកមាន ប្រាជ្ញាល្អ អ្នកយំសោកពីរឿងអ្វី អ្នកកុំខ្លាចឡើយ ចូរប្រព្រឹត្តធម៌ ចុះ ការបរិបូណ៌ដោយពូជ គឺកុសលរបស់សត្វទាំងអស់ ព្រះ ពុទ្ធជាម្ចាស់បានប្រគល់ឲ្យហើយ ។ បុគ្គលណា បូជាព្រះសម្ពុទ្ធ ជាលោកនាយក ដែលទ្រង់គង់ព្រះជន្មនៅក្តី បូជាព្រះសារីរិកធាតុ ប្រមាណប៉ុនគ្រាប់ស្ពៃ របស់ព្រះសម្ពុទ្ធដែលបរិនិព្វានហើយក្តី កាលបើចិត្តមានសេចក្តីជ្រះថ្លាស្មើ បុណ្យជាមហគ្គតកុសលស្មើ គ្នា ( គង់ចម្រើនដល់បុគ្គលនោះ ) ហេតុនោះ អ្នកចូរធ្វើព្រះស្តូប បញ្ចុះព្រះសារីរិកធាតុរបស់ព្រះជិនស្រីចុះ ។ ខ្ញុំបានស្តាប់វាចាព្រះ

សាគរត្ថេរហើយ ខ្ញុំកសាងនូវពុទ្ធស្តូប ថែទាំព្រះស្តូបដ៏ប្រសើរ របស់ព្រះមុនី អស់ ៥ ឆ្នាំ ។ បពិត្រព្រះអង្គ ជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំសោយសម្បត្តិ បានដល់នូវអរហត្ត ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៤ ជាតិ ទ្រង់មានប្រាជ្ញាក្រាស់ដូចផែនដី បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបច្ចុបដ្ឋានសញ្ញកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## បច្ចុបដ្ឋានសញ្ញកត្ថេរាបទាន ចប់

# អដ្ឋកថា

## បច្ចុបដ្ឋានសញ្ញកត្ថេរាបទាន

[ ១៩ ] អបទានរបស់ព្រះបច្ចុបដ្ឋានសញ្ញកត្ថេរ មានពាក្យផ្ដើមថា **អត្ថទស្សិម្ហិ សុគតេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងកំណើតយក្ស ព្រោះភាពដែលមិនបានចូលគាល់ ក្នុងកាលដែលព្រះមានព្រះភាគគង់ព្រះជន្មនៅ ក្រោយមក ព្រះមានព្រះភាគបរិនិព្វានហើយ យក្សនោះទទួលសេចក្ដីសោកដ៏ពន្លឹក ។ ពិតហើយ កាលនោះ អគ្គសាវករបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា សាគតៈ[១] កាលទូន្មានយក្ស ទើបពោលថា ការបូជាព្រះសារីរិកធាតុរបស់ព្រះមានព្រះភាគ រមែងមានផលច្រើន ដូចគ្នានឹងធ្វើការបូជាកាលព្រះមានព្រះភាគទ្រង់គង់ព្រះជន្មនៅ អំណាចនៃចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគ រមែងមានផលច្រើន ទើបដឹកនាំថា ចូរសាងព្រះស្តូបចុះ ទើបយក្សសាងព្រះស្តូប ។ កាលបូជាព្រះស្តូបនោះហើយ ចុតិចាកអត្តភាពនោះ បានសោយសគ្គសម្បត្តិក្នុងទេវលោក និងចក្កពត្តិសម្បត្តិ ក្នុងមនុស្សលោកហើយ ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ក្នុងសាវត្ថីនគរ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជា

---

១- ក្នុងគម្ពីរពុទ្ធវង្ស អគ្គសាវករបស់ព្រះមានព្រះភាគអត្ថទស្សី ឈ្មោះថា ព្រះសន្តៈ និងព្រះឧបសន្តៈ ។

ព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អត្ថទស្សិម្ហិ សុគតេ** ដូច្នេះជាដើម ។

ពាក្យទាំងអស់នោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។ ចំណែកក្នុងបទថា **យក្ខយោនឹ ឧបបជ្ជឹ** នេះ មានវិគ្គហៈថា ឈ្មោះថា **យក្ខ** ព្រោះរត់ដេញចាប់ស៊ីអ្នកស្រុករបស់ខ្លួន ឬសត្វទាំងឡាយដែលមកដល់ ។ កំណើតគឺជាតិរបស់ពួកយក្ខ ឈ្មោះថា **យក្ខយោនឹ** អធិប្បាយថា កើតក្នុងកំណើតយក្ខ ។ បទថា **ទុល្លទ្ធំ វត មេ អាសិ** សេចក្តីថា យសដែលខ្ញុំបានទទួលហើយ ឈ្មោះថា ជាយសដែលបានដោយលំបាក ខ្ញុំបានទទួលនូវភាពអាក្រក់ ព្រោះមិនបានធ្វើសក្ការៈដល់ព្រះសាស្តាដែលជាព្រះសម្ពុទ្ធ ។ បទថា **ទុប្បភាតំ** សេចក្តីថា រាត្រីនោះ ភ្លឺស្វាងបានដោយលំបាក គឺធ្វើរាត្រីឲ្យភ្លឺបានលំបាក អធិប្បាយថា ខ្ញុំធ្វើបញ្ញាឲ្យភ្លឺបានលំបាក ។ បទថា **ទុរុដ្ឋិតំ** ប្រែថា តាំងឡើងបានលំបាក អធិប្បាយថា ការរះនៃព្រះអាទិត្យ គឺការក្រោកឡើង ធ្វើសេចក្តីព្យាយាមរបស់ខ្ញុំលំបាក ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើមានអត្ថងាយយល់ហើយ ៗ។

## អដ្ឋកថាបច្ចុបដ្ឋានសញ្ញកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ជាតិបូជកត្ថេរាបទានទី ១០

[ ២០ ] កាលព្រះវិបស្សីទ្រង់ប្រសូត ពន្លឺដ៏ធំក៏កើតឡើង ទាំងផែនដី សមុទ្ទ និងភ្នំ ក៏ញាប់ញ័រ ។ ពួកជនអ្នកទាយនិមិត្ត ( ហោរ ) បានទាយថា ព្រះសម្ពុទ្ធនឹងកើតឡើងក្នុងលោក ទ្រង់ជាកំពូលសព្វសត្វ នឹងស្រង់ឡើងនូវប្រជុំជន ។ ខ្ញុំបានឮទំនាយពួកហោរហើយ ក៏ធ្វើនូវជាតិបូជា ( បូជាក្នុងថ្ងៃប្រសូត ) ជាតិបូជានេះ ឥតមានបូជាណាប្រហែលឡើយ ។ ខ្ញុំប្រមូលកុសល ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា លុះខ្ញុំធ្វើជាតិបូជាហើយ ក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ខ្ញុំចូលទៅកើតក្នុងកំណើតណាៗ ទោះបីជាទេវតា ឬជាមនុស្ស តែងកន្លងលើសពួកសត្វទាំងអស់ នេះជាផលនៃជាតិបូជា ។ ពួកស្រីមេនំ តែងបម្រើខ្ញុំ ទាំងជនដ៏សេសក៏លុះអំណាចចិត្តរបស់ខ្ញុំ ជនទាំងអស់នោះ មិនអាចនឹងធ្វើខ្ញុំឲ្យក្រោធឡើយ នេះជាផលនៃជាតិបូជា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើបូជា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃជាតិបូជា ។ ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣៤ ជាតិ ព្រះនាមសុបារិចរិយៈដូចគ្នា ទ្រង់ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះជាតិបូជកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ជាតិបូជកត្ថេរាបទាន ចប់**

## ឧទ្ទាន

មហាបរិវារត្ថេរាបទាន ១ សុមង្គលត្ថេរាបទាន ១ សរណាគមនិយត្ថេរាបទាន ១ ឯកាសនិយត្ថេរាបទាន ១ សុវណ្ណបុប្ផិយត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ពុទ្ធសញ្ញកត្ថេរាបទាន ១ មគ្គសញ្ញកត្ថេរាបទាន ១ បច្ចុបដ្ឋានសញ្ញកត្ថេរាបទាន ១ ជាតិបូជកត្ថេរាបទាន ១ ឯគាថា ៩០ គត់ ពួកអ្នកប្រាជ្ញបានរាប់ជាក់ច្បាស់ហើយ ។

**មហាបរិវារវគ្គទី ២ ចប់**

# អដ្ឋកថា

## ជាតិបូជកត្ថេរាបទាន

[ ២០ ] អបទានរបស់ព្រះជាតិបូជកត្ថេរ មានពាក្យផ្ដើមថា **ជាយំ តស្ស វិបស្សិស្ស** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កុលបុត្តនោះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានឮពួកហោរាទាយលក្ខណៈរបស់ព្រះវិបស្សីពោធិសត្វថា បានឮថា កុមារនេះនឹងបានជាព្រះពុទ្ធដ៏ប្រសើរជាងសត្វលោកទាំងអស់ នឹងជញ្ជូនសត្វចេញចាកសង្សារពិតប្រាកដ កាលបានឮហើយ ក៏បានធ្វើការបូជាព្រះមានព្រះភាគអង្គនោះ តាំងពីនៅកុមារ ដូចគ្នានឹងធ្វើការបូជាដល់ព្រះពុទ្ធ ដូច្នោះ ។ តមក ក្នុងកាលជាខាងក្រោយ កាលព្រះពោធិសត្វកន្លងវ័យ ៣ ជង គឺកាលជាទារក កាលជាកុមារ កាលបានគ្រងរាជសម្បត្តិហើយ បានជាព្រះពុទ្ធតាមលំដាប់ ក៏ធ្វើការបូជារហូតមក លុះចុតិចាកអត្តភាពនោះ បានកើតក្នុងស្ថានសួគ៌ជាន់តុសិតជាដើម សោយទិព្វសុខហើយ ខាងក្រោយ បានកើតក្នុងមនុស្សជាស្ដេចចក្កពត្តិជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងកាលមានអាយុបាន ៧ ឬ ៨ ឆ្នាំ ជ្រះថ្លាក្នុងព្រះមានព្រះភាគ បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ជាយំ តស្ស វិបស្សិស្ស** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។

ក្នុងបទថា **នេមិត្តានំ សុណិត្វាន** នេះ មានវិគ្គហៈថា ឈ្មោះថា **នេមិត្តា** ព្រោះដឹងនិមិត្ត គឺហេតុការណ៍ បានដល់ ហេតុដែលឲ្យកើតសេចក្តីសុខ និងសេចក្តីទុក្ខ អធិប្បាយថា បានឮពាក្យទាយរបស់ពួកហោរាទាំងនោះហើយ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាជាតិបូជកត្ថេរាបទាន ចប់**

**មហាបរិវារវគ្គទី ១២ ចប់**

# សុត្តន្តបិដក

# សេរេយ្យវគ្គទី ១៣

## សេរេយ្យកត្ថេរាបទានទី ១

[ ២១ ] ខ្ញុំជាអ្នកស្វាធ្យាយមន្ត អ្នកចងចាំមន្ត អ្នកដល់នូវត្រើយនៃវេទទាំង ៣ កំពុងឈរនៅក្នុងទីវាល បានឃើញព្រះលោកនាយក ទ្រង់ស្វែងរកនូវគុណដ៏ធំ ដូចជារាជសីហ៍ ត្រាច់ទៅក្នុងព្រៃ ឬដូចស្តេចខ្លាដែលមិនតក់ស្លុត ឬដូចដំរីឈ្មោះមាតង្គៈដែលកំពុងចុះប្រេង ៣ កន្លែង ។ ខ្ញុំកាន់យកផ្កាសិរមាន់បោះឡើង នាអាកាស ផ្កាទាំងនោះ ក៏ព័ទ្ធព័ន្ធជុំវិញដោយអានុភាពព្រះពុទ្ធ ។ ព្រះសព្វញ្ញូជាលោកនាយក មានព្យាយាមធំ ទ្រង់អធិដ្ឋានថា ផ្កាទាំងឡាយ ចូរពោយពាយជារបាំងផ្កាជុំវិញតថាគតដ៏ប្រសើរជាងនរៈ ។ លំដាប់នោះ សំណុំផ្កានោះ មានទងចូលក្នុងមានមុខចេញក្រៅ ធ្វើជារបាំង ប្រក់អស់ ៧ ថ្ងៃ តពីនោះមក ក៏បាត់អស់ទៅ ។ លុះខ្ញុំបានហេតុជាអស្ចារ្យចម្លែក គួរព្រឺរោមនោះបានញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ជាព្រះសុគត លោកនាយក ។ ខ្ញុំត្រូវកុសលមូលជាស់តឿន មិនដែលទៅកើតក្នុងទុគ្គតិ អស់ ១

សែនកប្ប ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ១៥០២៥ ខ្ញុំបាន កើតជាស្តេចចក្រពត្តិច្រើនជាតិ ព្រះនាមវិលាមាលៈដូចគ្នា ទ្រង់ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសេរេយ្យកត្ថេរមានអាយុ បានសម្តែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សេរេយ្យកត្ថេរាបទាន ចប់

# អដ្ឋកថា
# សេរេយ្យវគ្គទី ១៣

## សេរេយ្យកត្ថេរាបទាន

[ ២១ ] អបទានរបស់ព្រះសេរេយ្យកត្ថេរ មានពាក្យផ្តើមថា **អជ្ឈាយកោ មន្តធរោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានច្រើនពាន់អត្តភាព ក្នុងកាលមុន ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កុលបុត្តនោះ បានកើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្តីហើយ ចេះចប់ត្រៃវេទ ចប់នូវមន្តគ្រប់យ៉ាងរបស់ព្រាហ្មណ៍ មានឥតិហាសៈជាដើម ។ ថ្ងៃមួយ ឈរក្នុងទីវាល មួយអន្លើដោយបរិវារ បានជួបព្រះមានព្រះភាគ មានចិត្តជ្រះថ្លា ទើបចាប់យកផ្កាសិរមាន់បោះឡើងទៅលើអាកាសបូជា ។ ផ្កាទាំងនោះ ក្លាយជាពិតានលើអាកាស តាំងនៅ ៧ ថ្ងៃ ក៏អន្តរធានទៅ កុលបុត្តនោះ បានឃើញភាពអស្ចារ្យបែបនោះហើយ មានសេចក្តីជ្រះថ្លាពន់ពេក ស្លាប់ទៅដោយបីតិ និងសោមនស្សនោះឯង បានទៅកើតក្នុងស្ថានសួគ៌ជាន់តុសិតជាដើម បានសោយទិព្វសុខក្នុងស្ថានសួគ៌ជាន់នោះហើយ បន្ទាប់អំពីនោះ បានមកកើតជាមនុស្ស សោយសុខក្នុងមនុស្សហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុង

*ផុះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ ដោយកម្លាំងនៃវាសនាដែលបានសន្សំមកក្នុងកាលមុន មានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលកម្មដែលខ្លួនសន្សំមកក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **អជ្ឈាយកោ មន្តធរោ** *ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។*

*បទថា* **សេរេយ្យកំ គហេត្វាន** *មានវិគ្គហៈថា បុប្ផជាតិមានសិរ ឈ្មោះថា* **សេរេយ្យ** *។ សេរេយ្យៈនោះឯងជា* **សេរេយ្យក** *ភ្ជាប់សេចក្តីថា ខ្ញុំកាន់យកផ្កាសិរមាន់នោះ អធិប្បាយថា ខ្ញុំជ្រះថ្លាក្នុងព្រះមានព្រះភាគ គួរដាក់ផ្កា មានផ្កាម្លិះ និងផ្កាចម្ប៉ាក្រពុំជាដើមដើម្បីបូជា តែព្រោះផ្កាដូចពោលមិនមានសព្វកាល ទើបចាប់យកផ្កាសិរមាន់ ដែលប្រទះក្នុងទីនោះមកបូជា ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថាសេរេយ្យកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បុប្ផច្ឆត្តិយត្ថេរាបទានទី ២

[ ២២ ] មានភ្នំ ១ ឈ្មោះកុក្កុរៈ នៅជិតព្រៃហិមពាន្ត ព្រាហ្មណ៍អ្នកដល់នូវត្រើយនៃមន្ត ( គឺខ្ញុំនេះឯង ) តែងអាស្រ័យនៅចំកណ្តាលភ្នំនោះ ។ មានសិស្ស ៥០០០ នាក់ ចោមរោមខ្ញុំសព្វៗកាល សិស្សទាំងនោះ ក្រោកឡើងមុនផង ជាអ្នកក្លៀវក្លាក្នុងមន្តទាំងឡាយផង ( ប្រឹក្សាគ្នាថា ) ព្រះសម្ពុទ្ធត្រាស់ហើយក្នុងលោក អ្នកទាំងឡាយ ចូរដឹងច្បាស់នូវព្រះសម្ពុទ្ធនោះថា ជាបុគ្គលប្រសើររបស់យើងទាំងឡាយ ព្រះសម្ពុទ្ធនោះ ទ្រង់មានព្យញ្ជនៈ ៨០ មានលក្ខណៈដ៏ប្រសើរ ៣២ ព្រះជិនស្រីដ៏ប្រសើរមានរស្មីមួយព្យាម តែងរុងរឿងដូចព្រះអាទិត្យ ។ ព្រាហ្មណ៍អ្នកដល់នូវត្រើយនៃមន្ត គឺខ្ញុំនេះឯង លុះឮពាក្យរបស់សិស្សហើយ ក៏ចេញអំពីអាស្រម សួររកទិសថា ព្រះលោកនាយកមានព្យាយាមធំ ស្តេចគង់នៅក្នុងប្រទេសណា ។ លុះខ្ញុំបានឃើញព្រះជិនស្រីអង្គនោះ មិនមានបុគ្គលប្រៀបផ្ទឹមហើយ ក៏បាននមស្ការ ខ្ញុំមានចិត្តអណ្តែតឡើង មានចិត្តរីករាយ បូជាចំពោះព្រះតថាគតនោះ ។ ខ្ញុំបបួលសិស្សថា នែសិស្សទាំងឡាយ អ្នកចូរមក ពួកយើងនឹងទៅគាល់ព្រះតថាគត យើងនឹងថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះសាស្តា ហើយស្តាប់នូវពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ។ ខ្ញុំតែម្នាក់ឯង ចេញទៅ ខ្ញុំមានជំងឺ

ត្រូវជំងឺបៀតបៀន ក៏ដើរទៅ ប្រុងនឹងដេកក្រោមដើមឈើ ។ ខ្ញុំប្រជុំពួកសិស្សទាំងអស់ ហើយបានសួរអំពីព្រះតថាគតនឹងសិស្សទាំងនោះថា គុណរបស់ព្រះលោកនាថ ទ្រង់មានប្រាជ្ញាដ៏ក្រៃលែង តើដូចម្តេច ។ ពួកសិស្សទាំងនោះ ដែលខ្ញុំសួរហើយ ក៏ព្យាករសម្តែងអំពីព្រះពុទ្ធដ៏ប្រសើរនោះ ដោយគោរពចំពោះមុខខ្ញុំ តាមដែលគេបានឃើញ ។ លុះខ្ញុំបានស្តាប់ពាក្យរបស់ពួកសិស្សទាំងនោះហើយ ក៏ញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានសាងព្រះស្តូបដោយផ្កាទាំងឡាយ ហើយក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ពួកសិស្សទាំងនោះ ដុតសរីរៈរបស់ខ្ញុំរួចហើយ នាំគ្នាទៅក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ផ្គងអញ្ជលី ថ្វាយបង្គំព្រះសាស្តា ។ ខ្ញុំកសាងព្រះស្តូបដោយផ្កាទាំងឡាយ ថ្វាយព្រះសុគតមហេសី ខ្ញុំមិនដែលទៅកាន់សុគតិ អស់ ១ សែនកប្ប ដោយកុសលនេះ ។ ក្នុងកប្បទី ៤០០០០ ខ្ញុំបានកើតជាក្សត្រ ១៦ ជាតិ ព្រះនាមអគ្គិសមៈដូចគ្នា ដោយព្រះនាមជាស្តេចចក្កពត្តិ ទ្រង់មានកម្លាំងច្រើន ។ ក្នុងកប្បទី ២០០០០ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣៨ ជាតិ ជាម្ចាស់ផែនដី ព្រះនាមឃដាសនសមៈដូចគ្នា ។ បដិសម្ភិទា

៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផចូបិយត្ថេរមានអាយុ បានសម្ដែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បុប្ផចូបិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បុប្ផថូបិយត្ថេរាបទាន

[ ២២ ] អបទានរបស់ព្រះបុប្ផថូបិយត្ថេរ មានពាក្យផ្ដើមថា **ហិម-វន្តស្សាវិទូរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កុលបុត្តនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ សិក្សាសិប្បៈប្រចាំត្រកូល មិនឃើញសារៈក្នុងសិប្បៈនោះ ខ្លួនឯង មួយអន្លើដោយសិស្ស ៥០០០ នាក់ នាំគ្នាលះផ្ទះធ្វើដំណើរទៅកាន់ព្រៃហិមពាន្ត ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងហើយ សាងបណ្ណសាលាអាស្រ័យនៅក្បែរភ្នំ ឈ្មោះកុក្កុរៈ ។ កាលនោះ បានដឹងថា ព្រះពុទ្ធកើតឡើងហើយ មានបំណងនឹងគាល់ព្រះមានព្រះភាគ មួយអន្លើដោយពួកសិស្ស តែត្រូវព្យាធិឯណានីមួយបៀតបៀនទើបចូលទៅកាន់បណ្ណសាលា បានជ្រាបអានុភាព និងលក្ខណៈរបស់ព្រះពុទ្ធអំពីសម្នាក់របស់សិស្សហើយ មានចិត្តជ្រះថ្លា ឲ្យពួកសិស្សនាំយកផ្កាច្រើនប្រភេទ ដូចជាផ្កាចម្ប៉ា ផ្កាអសោក និងផ្កាតង្កៀបក្ដាមជាដើម មកអំពីហិមវន្តប្បទេស ហើយពូននូវព្រះស្តូប បូជានូវព្រះស្តូបដូចបូជាព្រះពុទ្ធ ធ្វើមរណកាលហើយ កុលបុត្តនោះ ក៏បានចូលដល់ព្រហ្មលោក ។

លំដាប់នោះ ពួកសិស្សទាំងនោះ ក៏នាំគ្នាធ្វើឈាបនកិច្ច ហើយទៅគាល់ព្រះពុទ្ធ ក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ។ លំដាប់នោះ ព្រះមាន

ព្រះភាគ ទ្រង់ប្រមើលមើលដោយពុទ្ធចក្ខុ ក៏ទ្រង់ជ្រាបច្បាស់ដោយអនាគតំសញ្ញាណ ។ ក្នុងកាលតមក ក្នុងពុទ្ធុប្បាទកាលនេះ កុលបុត្តនោះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរសាវត្ថី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ដោយកម្លាំងនៃវាសនាដែលខ្លួនបានសន្សំមកក្នុងកាលមុន ទើបជ្រះថ្លាក្នុងព្រះសាស្តាបួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលកម្មរបស់ខ្លួនក្នុងជាតិមុន មាននូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។ ពាក្យនោះទាំងអស់ខ្ញុំបានពោលហើយខាងដើមនោះឯង ។

បណ្ដាបទទាំងនោះ បទថា **កុក្កុរោ នាម បព្វតោ** សេចក្ដីថា កំពូលនៃភ្នំដែលហៅថា កុក្កុរបព៌ត ព្រោះមានកំពូល មានលក្ខណាការប្រដៀងនឹងសត្វឆ្កែ អធិប្បាយថា សាងបណ្ណសាលារួមជាមួយតាបស ៥០០០ នាក់ក្បែរភ្នំនោះ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថជាក់ច្បាស់ហើយ តាមគន្លងនៃពាក្យបរិយាយសេចក្ដីនោះឯង ។ល។

## អដ្ឋកថាបុប្ផច្ឆទនិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ទាយាសទាយកត្ថេរាបទានទី ៣

[ ២៣ ] ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានភិក្ខុសង្ឃចោមរោម ទ្រង់ចេញអំពីព្រៃធំ ខ្ញុំជួសបាយាសដាក់កាជន៍សំរឹទ្ធិ ដោយដៃរបស់ខ្លួន ខ្ញុំប្រាថ្នានឹងបូជានូវគ្រឿងបូជា ក៏ដើរសំដៅទៅកាន់ទីបូជា ។ ក្នុងសម័យនោះ ព្រះមានព្រះភាគ ជាច្បងក្នុងលោក ជានរាសភៈ ទ្រង់ឡើងកាន់ទីចង្រ្កមព្ទដ៏អាកាសជាផ្លូវខ្យល់ ។ ខ្ញុំឃើញហេតុដ៏អស្ចារ្យចម្លែកគួរព្រឺរោមនោះ ក៏ដាក់ចុះនូវកាជន៍សំរឹទ្ធិ ថ្វាយបង្គំព្រះវិបស្សី ( អាភាជនាថា ) បពិត្រព្រះមហាមុនី ព្រះអង្គជាសព្វញ្ញុពុទ្ធ ក្នុងមនុស្សលោក និងទេវលោក សូមព្រះអង្គអាស្រ័យសេចក្តីអនុគ្រោះ ទទួលយក ។ ព្រះមានព្រះភាគ ជាសព្វញ្ញូ លោក-នាយក ជាសាស្តាដ៏ប្រសើរក្នុងលោក ទ្រង់ជ្រាបតម្រិះរបស់ខ្ញុំ ហើយទ្រង់ទទួលយក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបាយាស ។ ក្នុងកប្បទី ៤១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ ជាតិ ព្រះនាមពុទ្ធរាជ ទ្រង់បរិបូណ៌

ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបាយាសទាយកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បាយាសទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ថាយសទាយកត្ថេរាបទាន

[ ២៣ ] អបទានរបស់ព្រះបាយាសទាយកត្ថេរ មានពាក្យផ្ដើមថា **សុវណ្ណវណ្ណោ សម្ពុទ្ធោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី បានកើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដែលសម្បូរដោយទ្រព្យសម្បត្តិ ដល់នូវភាពជាអ្នកដឹងក្ដីហើយ នៅគ្រប់គ្រងផ្ទះ សម្បូរដោយសម្បត្តិ ដូចជា ដីរ សេះ ប្រាក់ ធញ្ញជាតិ និងរតនៈ ៧ ប្រការជាដើម ដល់ព្រមដោយសទ្ធា ជឿកម្ម និងផលនៃកម្ម ប្រើឲ្យមនុស្សធ្វើនូវថាសមាសប្រមាណ ១ ពាន់ ហើយដាក់ទឹកដោះស្រស់ និងបាយាសរហូតពេញក្នុងថាស ១ ពាន់នោះ ហើយឲ្យកាន់យកថាសទាំងអស់ទៅកាន់ព្រៃរកា សម័យនោះ ព្រះមានព្រះភាគព្រះនាមវិបស្សី ទ្រង់បញ្ចេញរស្មីមានពណ៌ ៦ និម្មិតទីចង្ក្រមក្នុងអាកាសទ្រង់ចង្ក្រម ។ ចំណែកសេដ្ឋីនោះ ឃើញនូវភាពអស្ចារ្យនោះហើយ ជ្រះថ្លាក្រៃលែង ទើបដាក់ថាសទាំងអស់ចុះថ្វាយបង្គំហើយ ក្រាបទូលដើម្បីឲ្យទ្រង់ទទួល ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ទទួលដើម្បីជាការអនុគ្រោះ កាលទ្រង់ទទួលហើយ ដើម្បីឲ្យកុលបុត្តនោះកើតនូវសោមនស្ស ទើបទ្រង់សោយ មួយអន្លើដោយភិក្ខុសង្ឃប្រមាណ ១ ពាន់រូប ។ ភិក្ខុច្រើនពាន់រូបដទៃទៀត ឆាន់អាហារដែលសល់អំពីនោះ មិនមានសេសសល់ឡើយ ។ ដោយបុណ្យនោះ កុលបុត្តនោះ

បានអន្ទោលទៅក្នុងសុគតិភពទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ មានសទ្ធាបួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈពិចារណាដល់កុសលកម្មរបស់ខ្លួន រឭកដល់កុសលនោះ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សុវណ្ណវណ្ណោ សម្ពុទ្ធោ** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ ខ្ញុំបានពោលហើយក្នុងខាងដើមនោះឯង ។

បទថា **ចង្កមំ សុសមារុឡ្ហោ** មានវិគ្គហៈថា ឈ្មោះថា **ចង្កមំ** ព្រោះឈាន គឺធ្វើនូវការឈានជើង បោះជើងទៅ គឺដើរទៅ ។ ផែនដីត្រង់ទីដែលដាក់ជើងចុះ គឺការដាក់ជើង ឈ្មោះថា **ចង្កមំ** ភ្ជាប់សេចក្តីថា ទ្រង់ឈានឡើងកាន់ទីចង្ក្រមនោះដោយល្អ ។ បទថា **អម្ពរេ អនិលាយនេ** មានវិគ្គហៈថា ឈ្មោះថា **វរ** ព្រោះជាគ្រឿងបិទបាំង ឈ្មោះថា **អម្ពរ** ព្រោះមិនមានគ្រឿងរាំងបិទបាំង បានដល់ អាកាស ដែលដូចគ្នានឹងសំពត់ពណ៌ស ។ ឈ្មោះថា **អនិល** ព្រោះមិនមានទីពួន ទីការពារ ។ ឈ្មោះថា **អាយន** ព្រោះជាទីទៅដោយជុំវិញរបស់អ្នកមានឫទ្ធិ ។ **អនិល** ផង **អាយន** នោះផង ហៅថា **អនិលាយន** អធិប្បាយថា ទ្រង់និម្មិតទីចង្ក្រមក្នុងអាកាសដែលជាផ្លូវខ្យល់នោះ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថាចាយសទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## គន្ធោទកិយត្ថេរាបទានទី ៤

[ ២៤ ] ខ្ញុំអង្គុយក្នុងប្រាសាទដ៏ប្រសើរ បានឃើញព្រះជិនស្រី ព្រះនាមវិបស្សី ជាសព្វញ្ញូនាយកដ៏ឧត្តម ទ្រង់ល្វាសល្វន់ដូច ដើមថ្ងាន់ត្រូវខ្យល់ ។ ព្រះលោកនាយក ទ្រង់ធ្វើពុទ្ធដំណើរទៅ ជិតប្រាសាទ ពន្លឺរបស់ព្រះអង្គ ផ្សាយចេញក្នុងកាលព្រះអាទិត្យ អស្តង្គត ។ ខ្ញុំកាន់យកទឹកអប់មកប្រោះព្រំ ព្រះសម្ពុទ្ធដ៏ប្រសើរ ដោយចិត្តជ្រះថ្លានោះ ខ្ញុំក៏ធ្វើកាលកិរិយាក្នុងទីនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំប្រោះព្រំទឹកអប់ ខ្ញុំមិនដែល ស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩១ អំពីកប្ប នេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមគន្ធរាជ ទ្រង់បរិបូណ៌ ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធោទកិយត្ថេរមានអាយុ បានសម្តែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**គន្ធោទកិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## គន្ធោទកិយត្ថេរាបទាន

[ ២៤ ] អបទានរបស់ព្រះគន្ធោទកិយត្ថេរ មានពាក្យផ្តើមថា **និសជ្ជ ပាសាទវរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កុលបុត្តនេះ កើតក្នុងត្រកូលសេដ្ឋី ដល់នូវភាពជាអ្នកដឹងក្តីហើយ មានទ្រព្យច្រើន មានភោគសម្បត្តិច្រើន សោយសេចក្តីសុខក្នុងមនុស្សលោក ដូចគ្នានឹងសោយសេចក្តីសុខដែលជាទិព្វ ដូច្នោះ ។ ថ្ងៃមួយ អង្គុយក្នុងប្រាសាទដ៏ប្រសើរ ។ ក្នុងកាលនោះ ព្រះមានព្រះភាគយាងទៅតាមផ្លូវ ដូចភ្នំមាសធំ ។ កុលបុត្តនោះ បានឃើញព្រះមានព្រះភាគយាងទៅនោះហើយ មានចិត្តជ្រះថ្លា ចូលទៅថ្វាយបង្គំ ហើយយកទឹកក្រអូបយ៉ាងល្អ ប្រោះព្រំបូជាព្រះមានព្រះភាគ ដោយបុណ្យនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្តីហើយ មិនជាប់ក្នុងឃរាវាស បានបួសក្នុងសម្នាក់របស់ព្រះសាស្តា រៀនកម្មដ្ឋាន ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលកម្មក្នុងកាលមុនរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **និសជ្ជ ပាសាទវរេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **បាសាទោ** មានវិគ្គហៈថា ឈ្មោះថា **បាសាទ** ព្រោះឲ្យនូវការជ្រះថ្លា គឺឲ្យកើតការត្រេកអរ អធិប្បាយថា ធ្វើសេចក្ដីជ្រះថ្លា ឲ្យកើតឡើងដល់មហាជន ដែលចូលទៅឃើញភាពវិចិត្រផ្សេងៗ ដូចជា មាលាកម្ម ចិត្រកម្ម និងសុវណ្ណកម្ម ( ការលាបពណ៌មាស ) ជាដើម ។ ក្នុងប្រាសាទនោះ ។ ប្រាសាទនោះផង ភាពប្រសើរ ព្រោះអត្ថថា ដែលបុគ្គលគប្បីប្រាថ្នាផង ហេតុនោះ ទើបហៅថា ប្រាសាទដ៏ប្រសើរ ភ្ជាប់សេចក្ដីថា ខ្ញុំអង្គុយលើប្រាសាទដ៏ប្រសើរនោះ បានឃើញព្រះជិនវរពុទ្ធ ព្រះនាមវិបស្សី ។ ពាក្យដ៏សេសក្នុងទី គ្រប់អន្លើមាន អត្ថងាយយល់ហើយ ៕

## អដ្ឋកថាគវក្ខខកិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សម្មុខាថវិកត្ថេរាបទានទី ៩

[ ២៥ ] កាលដែលព្រះវិបស្សីទ្រង់ប្រសូត ខ្ញុំបានទាយនិមិត្តថា ព្រះពុទ្ធនឹងញុាំងប្រជុំជន ក្នុងលោកឲ្យរលត់ទុក្ខ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត លោកធាតុ ១ ម៉ឺន តែងញាប់ញ័រ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ពន្លឺដ៏ធំក៏កើតប្រាកដ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ស្ទឹងទាំងឡាយមិនហូរ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ភ្លើងអវិចីមិនឆេះ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ពួកសត្វស្លាបមិនហើរ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត គំនរខ្យល់ មិនបក់ផាត់ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញា-ចក្ខុ នឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ពួកកែវទាំងពួងក៏រុងរឿង ឥឡូវនេះ ព្រះមានព្រះភាគ

អង្គនោះ ជាសាស្តា ទ្រង់មានចក្ខុនឹងសម្តែងធម៌ ។ កាលព្រះមានព្រះភាគអង្គណា ទ្រង់ប្រសូត ទ្រង់ឈានដើរបាន ៧ ជំហាន ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តា ទ្រង់មានបញ្ញាចក្ខុ នឹងសម្តែងធម៌ ។ ព្រះសម្ពុទ្ធ គ្រាន់តែទ្រង់ប្រសូតរួចភ្លាម ទ្រង់រមិលមើលសព្វទិស ទ្រង់បន្លឺនូវវាចាដ៏អង់អាច នេះជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ។ ខ្ញុំញុំាងប្រជុំជនឲ្យកើតសង្វេគហើយ សរសើរព្រះលោកនាយក ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយបែរមុខទៅកាន់ទិសខាងកើត ដើរចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរព្រះសម្ពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ ក្នុងកប្បទី ៩០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ឈ្មោះសម្មុខាថវិករាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ឈ្មោះបឋវីទុន្ទុភិរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៨ អំពីកប្បនេះ ខ្ញុំកើតជាក្សត្រឈ្មោះឱភាសរាជ ជាស្តេចចក្កពត្តិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះសរិតច្ឆេទនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៦ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះអគ្គិ-

និព្វបនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៥ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះវាតសមរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៤ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះគតិបច្ចនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨៣ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះរតនបជ្ជលរាជ បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨២ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះបទវិក្កមនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨១ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះវិលោកនរាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ ក្នុងកប្បទី ៨០ ខ្ញុំកើតជាស្តេចចក្កពត្តិ ឈ្មោះគិរិសាររាជ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសម្មុខាថវិកត្ថេរមានអាយុ បានសម្តែងហើយនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សម្មុខាថវិកត្ថេរាបទាន ចប់**

# អដ្ឋកថា

## សម្មុខាថវិកត្ថេរាបទាន

[ ២៥ ] អបទានរបស់ព្រះសម្មុខាថវិកត្ថេរ មានពាក្យផ្ដើមថា **ជាយមានេ វិបស្សិម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កុលបុត្តនោះ កើតក្នុងត្រកូលព្រាហ្មណ៍ លុះមានអាយុ ៧ ឆ្នាំ បានរៀនសិប្បៈប្រចាំត្រកូល ហើយគ្រប់គ្រងផ្ទះ ។ កាលព្រះវិបស្សីពោធិសត្វកើតឡើងហើយ បានព្យាករលក្ខណៈរបស់ព្រះពុទ្ធគ្រប់ៗ អង្គ ដែលប្រាកដក្នុងគម្ពីរត្រៃវេទ និងលក្ខណៈរបស់ព្រះវិបស្សីពោធិសត្វថា ទ្រង់នឹងបានជាព្រះពុទ្ធដល់ពួកជន មានព្រះរាជាជាប្រធាន ធ្វើចិត្តមនុស្សទាំងឡាយឲ្យត្រេកអរ នឹងបានប្រកាសពាក្យសរសើរជាច្រើន ។ ដោយកុសលកម្មនោះ ទើបកុលបុត្តនោះ បានសោយកាមាវចរ-សម្បត្តិ ៦ ជាន់ នឹងបានសោយចក្កពត្តិសម្បត្តិក្នុងពួកមនុស្ស ក្នុងពុទ្ធុ-ប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ មាននូវសទ្ធា ទើបចេញបួស មិនយូរប៉ុន្មានក៏បាន ជាព្រះអរហន្ត ។

ព្រះថេរៈបានប្រាកដឈ្មោះថា សម្មុខាថវិកត្ថេរតាមឈ្មោះកុសលដែលធ្វើហើយ ។ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ជាយ-មានេ វិបស្សិម្ហិ** ដូច្នេះជាដើម ។

ក្នុងគាថានោះមានអធិប្បាយថា កាលព្រះវិបស្សីសម្មាសម្ពុទ្ធកើតឡើងហើយ គឺប្រសូតចាកគភ៌មាតា ខ្ញុំបានព្យាករ គឺប្រាប់និមិត្ត គឺហេតុដែលប្រាកដ គឺហេតុដែលនឹងបានជាព្រះពុទ្ធ បានដល់ បានធ្វើនូវភាពអស្ចារ្យជាច្រើនឲ្យប្រាកដ ។ ពាក្យដ៏សេស មានអត្ថដ៏ងបានងាយហើយ ព្រោះមានន័យតាមដែលអធិប្បាយហើយនោះឯង ។ល។

## អដ្ឋកថាសម្មុខាថវិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## កុសុមាសនិយត្ថេរាបទានទី ៦

[ ២៦ ] គ្រានោះ ខ្ញុំបានកើតជាព្រាហ្មណ៍ នៅក្នុងក្រុងធញ្ញវតី ជាអ្នកឈ្លាសក្នុងគម្ពីរលក្ខណសាស្រ្ត ឥតិហាសាស្រ្ត ព្រមទាំងនិឃណ្ឌុសាស្រ្ត និងកេដុភសាស្រ្ត ។ ជាអ្នកឈ្លាសក្នុងបទ ក្នុងវេយ្យាករណ៍ ក្នុងនិមិត្ត ចេះចប់ត្រៃវេទ បានបង្ហាញមន្តចំពោះពួកសិស្ស ។ ខ្ញុំតម្កល់ផ្កាឧប្បល ៥ កម្រងលើខ្នង ខ្ញុំមានប្រាថ្នាដើម្បីបូជានូវគ្រឿងបូជា ក្នុងការជួបជុំបិតា និងមាតា ។ វេលានោះ ព្រះមានព្រះភាគ ព្រះនាមវិបស្សី ទ្រង់ជានរាសភៈ មានកិក្ខុសង្ឃចោមរោម ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺ ហើយស្តេចនិមន្តមក ។ ខ្ញុំបានក្រាលអាសនៈ ហើយនិមន្តព្រះមហាមុនី បានក្រាលផ្កានោះហើយ នាំព្រះអង្គហួសទៅកាន់ផ្ទះរបស់ខ្លួន ។ អាមិសណា ដែលខ្ញុំបានតម្កល់ទុក មានក្នុងផ្ទះរបស់ខ្ញុំ ខ្ញុំជ្រះថ្លា បានថ្វាយអាមិសនោះ ចំពោះព្រះសម្ពុទ្ធ ដោយដៃរបស់ខ្លួន ។ ខ្ញុំដឹងនូវកាលដែលព្រះសម្ពុទ្ធទ្រង់សោយរួចហើយ ក៏បានថ្វាយផ្កាមួយក្តាប់ ព្រះសព្វញ្ញុពុទ្ធ ធ្វើអនុមោទនារួចហើយ ឈមព្រះភក្ត្រទៅកាន់ទិសឧត្តរ និមន្តចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាល

នោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផទាន ។ ក្នុងកប្បជាលំដាប់អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ឈ្មោះវរទស្សនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុសុមាសនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## កុសុមាសនិយត្ថេរាបទាន ចប់

# អដ្ឋកថា

## កុសុមាសនិយត្ថេរាបទាន

[ ២៦ ] អបទានរបស់ព្រះកុសុមាសនិយត្ថេរ មានពាក្យផ្តើមថា **នគរេ ធញ្ញវតិយា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី បានកើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្តីហើយ ជាអ្នកមានទ្រព្យច្រើន មានភោគសម្បត្តិច្រើន រៀនចប់ត្រៃវេទ និងចប់សិល្បសាស្ត្ររបស់ព្រាហ្មណ៍ ជាអ្នកឈ្លាសក្នុងលទ្ធិរបស់ខ្លួន និងរបស់អ្នកដទៃ មានបំណងបូជាមាតាបិតា ទើបដាក់បាច់ផ្កាឈូក ៥ ក្តាប់ដាក់ក្បែរខ្លួន ហើយអង្គុយ បានឃើញព្រះមានព្រះភាគ ព្រះនាមវិបស្សី មានពួកភិក្ខុសង្ឃចោមរោម កំពុងយាងចូលកាត់មក និងបានឃើញព្រះពុទ្ធរស្មីដ៏ក្រាស់ មានពណ៌ខៀវ និងពណ៌លឿងជាដើម មានចិត្តជ្រះថ្លា ទើបក្រាលអាសនៈ រោយនូវផ្កាទាំងនោះ លើអាសនៈនោះ ហើយនិមន្តព្រះមានព្រះភាគឲ្យគង់លើអាសនៈនោះ នាំយករបស់គួរទំពា និងគួរបរិភោគទាំងអស់ក្នុងផ្ទះរបស់ខ្លួន ដែលត្រៀមដើម្បីមាតា មកថ្វាយព្រះមានព្រះភាគ មួយអន្លើដោយបរិវារឲ្យទ្រង់ឆ្អែតហើយ ដោយដៃរបស់ខ្លួន ។ ក្នុងកាលព្រះមានព្រះភាគឆាន់ស្រេចហើយ បានថ្វាយផ្កាឧប្បល ១ ក្តាប់ ។ កុលបុត្តនោះមានសោមនស្ស ដោយទាននោះ ទើបតាំងនូវសេចក្តីប្រាថ្នា ។ ចំណែកព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។

ដោយបុណ្យនោះ កុលបុត្តនោះ បានសោយសម្បត្តិទាំងពីរយ៉ាង គឺសគ្គ-សម្បត្តិ និងមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ដែលសម្បូរដោយសម្បត្តិ ក្នុងក្រុងសាវត្ថី ដល់នូវភាពជាអ្នកដឹងក្តីហើយ ចម្រើនរុងរឿងដោយភោគសម្បត្តិ និងយស ឃើញទោសក្នុងកាមទាំងឡាយ ទើបលះឃរាវាស ចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលកម្មដែលធ្វើហើយក្នុងកាលមុនដោយបុព្វេនិវាសញ្ញាណ កើតនូវសោមនស្ស កាលប្រកាសដល់អបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឯគរេ ធញ្ញវតិយា** ដូច្នេះជាដើម ។

ពាក្យថា **ធញ្ញវតិយា** នោះ មានវិគ្គហៈថា ឈ្មោះថា **ធញ្ញវតី** ព្រោះជាទីកើតនៃត្រកូលខត្តិយមហាសាល ព្រាហ្មណមហាសាល និងគហបតិ-មហាសាលជាច្រើនត្រកូល ដែលជាត្រកូលមានធញ្ញជាតិ និងមានបុណ្យម្យ៉ាងទៀត ឈ្មោះថា **ធញ្ញវតី** ព្រោះជាប្រកបនៃរតនៈ ៧ ប្រការ មានកែវមុក្តា និងកែវមណីជាដើម នៃធញ្ញជាតិ ៧ យ៉ាង និងនៃគ្រឿងឧបភោគបរិភោគ ៧ យ៉ាង ។ ម្យ៉ាងទៀត ឈ្មោះថា **ធញ្ញវតី** ព្រោះជាប្រកបកើតនៃវត្តអារាមជាដើម ដែលជាលំនៅរបស់ព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកសម្ពុទ្ធ និងព្រះខីណាស្រពអ្នកមានបុណ្យសន្ទឹកសន្ធាប់ ។ ឈ្មោះថា **ឯគរ** ព្រោះជាទីប្រាថ្នាត្រូវការរបស់ពួកជន ដែលត្រូវការគ្រឿងឧបភោគ និងគ្រឿង

បរិភោគ ។ ម្យ៉ាងទៀត ឈ្មោះថា **ឆគ** ព្រោះមិនទៅណាឡើយ បានដល់ ទីប្រថាប់របស់ព្រះរាជា ព្រះឧបរាជ និងអមាត្យជាដើម ។ ឈ្មោះថា **ឆគរ** ព្រោះជាប់ ប្រកាន់ គ្រប់គ្រងនូវភ្នំ បានដល់ ស្ថានទីដែលមានព្រំដែនព័ទ្ធដោយកំពែងជាដើម ដែលជាទីរួមនៃទីប្រថាប់របស់ព្រះរាជាជាដើម ទើបបានឈ្មោះថា **ឆគរ** ភ្ជាប់សេចក្តីថា ក្នុងនគរនោះ ខ្ញុំបានទទួលព្យាករក្នុងសម្នាក់របស់ព្រះមានព្រះភាគព្រះនាមវិបស្សី ក្នុងកាលណា ក្នុងកាលនោះ ខ្ញុំបានជាព្រាហ្មណ៍នៅក្នុងនគរធញ្ញវតីនោះឯង ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើមានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថាកុសុមាសនិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ផលទាយកត្ថេរាបទានទី ៧

[ ២៧ ] ខ្ញុំជាអ្នកស្វាធ្យាយមន្ត ចងចាំមន្ត ចេះចប់ត្រៃវេទ នៅក្នុងអាស្រម ជិតព្រៃហិមពាន្ត ។ ការបូជាភ្លើងរបស់ខ្ញុំ តែងមានខ្ញុំដាក់ផ្លែឈើទាំងឡាយក្នុងកញ្ចប់ ហើយព្យួរលើចុងឈើ ។ ព្រះលោកវិទូ ព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលនូវគ្រឿងបូជា ទ្រង់មានប្រាថ្នានឹងស្រង់ខ្ញុំ ស្តេចនិមន្តទៅដើម្បីភិក្ខា ក៏ចូលមកកាន់សម្នាក់នៃខ្ញុំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានថ្វាយផ្លែឈើនោះចំពោះព្រះពុទ្ធ ព្រះសម្ពុទ្ធជាសាស្តា ទ្រង់មានវណ្ណៈដូចមាស ទ្រង់ញ៉ាំងបីតិខ្ញុំឲ្យកើត ទ្រង់នាំមកនូវសេចក្តីសុខដល់ខ្ញុំក្នុងបច្ចុប្បន្ន គួរទទួលនូវគ្រឿងបូជា ទ្រង់ស្ថិតនៅនាអាកាសហើយ សម្តែងគាថានេះថា កុលបុត្តនេះ នឹងមិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ដោយផលនៃការថ្វាយផ្លែឈើនេះផង ដោយផលនៃការតម្កល់ទុកនូវចេតនានេះផង ។ ព្រោះកុសលមូលនោះឯង ខ្ញុំបានសោយសម្បត្តិទាំងឡាយ ហើយបានដល់នូវព្រះនិព្វានជាស្ថានមិនញាប់ញ័រ ខ្ញុំលះបោលការឈ្នះ និងការចាញ់ ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ឈ្មោះ

សុមង្គលៈ ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ផលទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

# ផលទាយកត្ថេរាបទាន

[ ២៧ ] អបទានរបស់ព្រះផលទាយកត្ថេរ មានពាក្យផ្ដើមថា **អជ្ឈាយកោ មន្តធរោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពដ៏ច្រើន ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កុលបុត្តនោះ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ សិក្សាចប់សិប្បៈប្រចាំត្រកូលមានត្រៃវេទជាដើម ជាអាចារ្យរបស់ពួកព្រាហ្មណ៍ច្រើនពាន់នាក់ មើលមិនឃើញទីបំផុតនៃសិប្បៈទាំងឡាយរបស់ព្រាហ្មណ៍ និងមើលមិនឃើញសារៈក្នុងសិប្បៈនោះ ទើបលះឃរាវាស បួសជាឥសី ហើយសាងអាស្រមក្នុងទីមិនឆ្ងាយអំពីហិមវន្តប្បទេស ជាមួយពួកសិស្ស ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈយាងទៅភិក្ខាចារ ដល់ប្រទេសនោះ ដើម្បីទ្រង់អនុគ្រោះកុលបុត្តនោះ តាបសនោះបានឃើញព្រះមានព្រះភាគហើយមានចិត្តជ្រះថ្លា បានថ្វាយគ្រាប់ឈូកដែលមានរសឆ្ងាញ់ ដែលខ្ចប់ទុកក្នុងកញ្ចប់ ព្យួរត្រង់ចុងឈើដើម្បីខ្លួន មួយអន្លើដោយទឹកឃ្មុំ ។ ព្រះមានព្រះភាគ

ទ្រង់សោយក្នុងខណៈដែលកុលបុត្តនោះកំពុងមើលនោះឯង ដើម្បីឲ្យកើតសោមនស្ស ហើយប្រថាប់ឈរក្នុងអាកាស ត្រាស់សម្តែងអានិសង្សនៃផលទានហើយ ចៀសចេញទៅ ។ ដោយបុណ្យនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដែលសម្បូរដោយសម្បត្តិ លុះអាយុបាន ៧ ឆ្នាំ ក៏សម្រេចអរហត្ត រឭកដល់កុសលកម្មដែលខ្លួនធ្វើក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អជ្ឈាយកោ មន្តធរោ** ដូច្នេះជាដើម ។ គប្បីជ្រាបវិគ្គហៈក្នុងបទនោះដូច្នេះ ឈ្មោះថា **អជ្ឈាយិ** ព្រោះរមែងសិក្សា គឺរមែងគិត **អជ្ឈាយិ** នោះឯងជា **អជ្ឈាយកោ** ប្រែថា អ្នកស្វាធ្យាយមន្ត ។ ពិតហើយ **អ** អក្ខរៈ ក្នុងបទថា **អជ្ឈាយកោ** នេះ រមែងប្រព្រឹត្តទៅក្នុងអត្ថ ១០ ប្រការ ដូចលោកពោលយ៉ាងនេះថា **អ** អក្ខរៈ ប្រព្រឹត្តទៅក្នុងអត្ថបដិសេធ ក្នុងសេចក្តីចម្រើន ក្នុងភាព ដូច្នោះ ។បេ។ ក្នុងភាពទទេ និងក្នុងអត្ថថា បន្តិចបន្តួច ។ ម្យ៉ាងទៀត ឈ្មោះថា **អជ្ឈាយកោ** ព្រោះអត្ថថា រកគឺគិតដល់វត្ថុដែលជាប្រយោជន៍សម្រាប់សិស្ស ដោយវិធីស្តាប់ និងចងចាំជាដើមហើយ ធ្វើការស្វាធ្យាយ បានដល់ អ្នកគិត ។ ឈ្មោះថា **មន្តធរោ**

*ព្រោះអត្ថថា រមែងទ្រទ្រង់ចាំនូវមន្តទាំងអស់ ដែលសិក្សារៀនសូត្រក្នុងសម្នាក់របស់អាចារ្យ រហូតស្ទាត់ក្នុងចិត្ត ។ បទថា* **តិណ្ណំ វេទាន បារគូ** *សេចក្តីថាញាណ លោកក៏ហៅថា* **វេទ** *ដែលហៅថា* **វេទ** *ព្រោះគប្បីជ្រាប គឺគប្បីត្រាស់ដឹងបានដោយវេទ បានដល់ គម្ពីរទាំង ៣ គឺឥរុវេទ យជុវេទ សាម-វេទ ។ ឈ្មោះថា* **បារគូ** *ព្រោះសម្រេចដល់ត្រើយ គឺដល់នូវទីបំផុតនៃវេទទាំង ៣ នោះ ។ ពាក្យដ៏សេស មានអត្ថជាក់ច្បាស់ហើយនោះឯង ៕*

**អដ្ឋកថាផលទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ញាណសញ្ញកត្ថេរាបទានទី ៨

[ ២៨ ] ខ្ញុំនៅទាក្នុំហិមពាន្ត ឃើញផ្លូកខ្សាច់ដ៏ល្អក្នុងចន្លោះភ្នំ ខ្ញុំរឭកនូវព្រះសម្ពុទ្ធដ៏ប្រសើរថា ការប្រៀបធៀបក្នុងញាណ ( របស់ព្រះសាស្តា ) មិនមានឡើយ សង្គ្រាមរបស់ព្រះសាស្តា ក៏មិនមានដែរ ព្រះសាស្តាបានជ្រាបនូវធម៌ទាំងពួង ទ្រង់ស៊ប់សួនដោយញាណ ។ បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ សភាពដទៃ ស្មើដោយញាណរបស់ព្រះអង្គមិនមានឡើយ មានតែញាណរបស់ព្រះអង្គ ទើបឧត្តមជាកំណត់ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងញាណហើយ ក៏បានទៅរីករាយក្នុងស្ថានសួគ៌ អស់ ១ កប្ប ខ្ញុំបានកសាងកុសលក្នុងកប្បដ៏សេស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្តីសម្គាល់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសម្គាល់ក្នុងញាណ ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ ជាតិ ព្រះនាមបុឡិនបុប្ផិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា

៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះញាណសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ញាណសញ្ញកត្ថេរាបទាន ចប់

# អដ្ឋកថា

## ញាណសញ្ញកត្ថេរាបទាន

[ ២៨ ] អបទានរបស់ព្រះញាណសញ្ញកត្ថេរ មានពាក្យផ្ដើមថា **បព្វតេ ហិមវន្តម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានគ្រប់កាលដែលកើត ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ លះឃរាវាសចេញបួសជាតាបស សាងបណ្ណសាលា ក្នុងរវាងភ្នំមិនឆ្ងាយអំពីភ្នំហិមពាន្ត ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងហើយ ។ ថ្ងៃមួយ សម្លឹងឃើញគំនរខ្សាច់ដែលបរិសុទ្ធ សស្អាត ទើបនឹកគិតសរសើរព្រះសម្ពុទ្ធ និងព្រះញាណរបស់ព្រះអង្គថា ព្រះពុទ្ធទាំងឡាយក៏បរិសុទ្ធយ៉ាងនេះ ព្រះញាណរបស់ព្រះពុទ្ធ ក៏បរិសុទ្ធដូចគ្នា ។

ដោយបុណ្យនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ មកកើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានបួសក្នុងព្រះសាសនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត រឭកដល់បុណ្យដែលខ្លួនធ្វើក្នុងកាលមុន កើតសោម-

នស្ស កាលប្រកាសអបទាន ទើបពោលពាក្យថា **បញ្ចតេ ហិមវន្តម្ហិ** ដូច្នេះជាដើម ។

បទថា **បុលិនំ សោភនំ ទិស្វា** មានវិគ្គហៈថា ឈ្មោះថា **បុលិន** ព្រោះប្រព្រឹត្តទៅពេញ បរិសុទ្ធស្អាត ដូចមានមនុស្សពូនឡើង អធិប្បាយថា ខ្ញុំបានឃើញផ្នូកខ្សាច់ដ៏ស្អាតហើយ បានរឭកដល់ព្រះពុទ្ធដ៏ប្រសើរ ។ ពាក្យដ៏សេស មានអត្ថងាយស្រួលហើយ ។

**អដ្ឋកថាញាណសញ្ញកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## គន្ធបុប្ផិយត្ថេរាបទានទី ៩

[ ២៩ ] ព្រះមានព្រះភាគ ព្រះនាមវិបស្សី មានវណ្ណៈដូចមាស ទ្រង់គួរទទួលនូវទក្ខិណាទាន មានពួកសាវកចោមរោម ស្ដេចចេញអំពីអារាម ។ ខ្ញុំឃើញព្រះពុទ្ធដ៏ប្រសើរ ជាសព្វញ្ញូ មិនមានអាសវៈ ក៏មានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានបូជាផ្លូវដែលស្ដេចនិមន្តទៅ ។ ខ្ញុំជាអ្នករីករាយ មានចិត្តរីករាយ ចំពោះព្រះសម្ពុទ្ធជាតាទិបុគ្គល ប្រសើរជាងសត្វជើងពីរ ទើបថ្វាយបង្គំព្រះតថាគតម្ដងទៀត ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៤១ អំពីកប្បនេះ ខ្ញុំកើតជាក្សត្រចក្កពត្តិ ឈ្មោះវរុណៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**គន្ធបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## គណ្ឋបុប្ផិយត្ថេរាបទាន

[ ២៩ ] អបទានរបស់ព្រះគណ្ឋបុប្ផិយត្ថេរ មានពាក្យផ្ដើមថា **សុវណ្ណវណ្ណោ សម្ពុទ្ធោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ បានសន្សំបុណ្យទាំងឡាយហើយក្នុងជាតិជាច្រើន ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង សម្បូរដោយគ្រឿងឧបភោគ និងបរិភោគមិនខ្វះខាត ថ្ងៃមួយ បានឃើញព្រះមានព្រះភាគ ព្រះនាមវិបស្សី មួយអន្លើដោយគណៈសង្ឃ មានចិត្តជ្រះថ្លា បូជាដោយផ្កាទាំងឡាយ មានលាជជាគម្រប់ ៥ ។ ដោយចិត្តជ្រះថ្លានោះឯង កុលបុត្តនោះតាំងនៅដរាបដល់អស់អាយុ ស្លាប់អំពីមនុស្សលោក ទៅកើតក្នុងទេវលោក បានសោយទិព្វសម្បត្តិ ក្នុងជាតិតមក កើតជាមនុស្ស សោយសម្បត្តិក្នុងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង មានសទ្ធាបួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ថ្ងៃមួយ ព្រះថេរៈរឭកដល់បុណ្យដែលបានបំពេញមកក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយកុសលកម្មនេះ ទើបខ្ញុំបានដល់នូវព្រះនិព្វាន ទើបពោលពាក្យថា **សុវណ្ណវណ្ណោ សម្ពុទ្ធោ** ដូច្នេះជាដើម ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ព្រោះបានអធិប្បាយហើយខាងដើមនោះឯង ។ល។

**អដ្ឋកថាគណ្ឋបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បទុមប្ជូកត្ថេរាបទានទី ១០

[ ៣០ ] មានភ្នំ ១ ឈ្មោះគោតមៈ នៅព្រៃហិមពាន្ត ដេរដាស ដោយឈើផ្សេងៗ ជាទីអាស្រ័យនៅនៃពួកភូតច្រើន ។ ខ្ញុំបាន សាងអាស្រមត្រង់កណ្តាលភ្នំនោះ មានពួកសិស្សចោមរោម តែងនៅក្នុងអាស្រម ( ខ្ញុំបបួលពួកសិស្សថា ) សូមពួកសិស្ស មកកាន់សម្នាក់យើង សូមពួកសិស្សនាំផ្កាឈូកមកឲ្យយើងៗ នឹងធ្វើពុទ្ធបូជា ចំពោះព្រះពុទ្ធជាតាទិបុគ្គល ទ្រង់ប្រសើរជាងសត្វ ជើងពីរ ។ ពួកសិស្សទាំងនោះ ទទួលពាក្យខ្ញុំថា យ៉ាងហ្នឹង ហើយៗ បានយកផ្កាឈូកមកឲ្យខ្ញុំ ខ្ញុំធ្វើនិមិត្តតាមទំនងដូច្នោះ ហើយ បានបង្អោនថ្វាយដល់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងកាលនោះ ខ្ញុំបានប្រជុំពួកសិស្ស ហើយប្រៀនប្រដៅដោយប្រពៃថា អ្នកទាំង ឡាយ ចូរកុំប្រមាទ សេចក្តីមិនប្រមាទ ជាគុណនាំមកនូវសេចក្តី សុខ ។ ខ្ញុំនោះ បានប្រៀនប្រដៅពួកសិស្ស ដែលជាអ្នកគួរដល់ ពាក្យនេះហើយ ខ្ញុំប្រកបក្នុងអប្បមាទគុណ ក៏បានធ្វើមរណកាល ក្នុងពេលនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែល ខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះ នាមជលុត្តមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំង

ច្រើន ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា បទុមបូជកត្ថេរមានអាយុ បានសម្តែងគាថា ទាំងឡាយនេះ ដោយប្រការដូច្នេះ ។

**បទុមបូជកត្ថេរាបទាន ចប់**

## ឧទ្ទាន

សោរេយ្យកត្ថេរាបទាន ១ បុប្ផថូបិយត្ថេរាបទាន ១ បាយាសទាយកត្ថេរាបទាន ១ គន្ធោទកិយត្ថេរាបទាន ១ ថោមកត្ថេរាបទាន ឬសម្មុខាថវិកត្ថេរាបទាន ១ កុសុ-មាសនិយត្ថេរាបទាន ១ ផលទាយកត្ថេរាបទាន ១ ញាណសញ្ញិកត្ថេរាបទាន ១ គន្ធបុប្ផិយត្ថេរាបទាន ១ បទុមបុប្ផិយត្ថេរាបទាន ១ មានគាថា ១០៥ ពួកអ្នក ប្រាជ្ញបានរាប់ហើយ ។

**សោរេយ្យកវគ្គទី ១៣ ចប់**

# អដ្ឋកថា

## បទុមបូជកត្ថេរាបទាន

[ ៣០ ] *អបទានរបស់ព្រះបទុមបូជកត្ថេរ មានពាក្យផ្ដើមថា* **ហិមវន្តស្សាវិទូរេ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ សម្រេចការសិក្សាក្នុងសិប្បៈប្រចាំត្រកូល មើលមិនឃើញសារៈក្នុងសិប្បៈនោះ មិនបានទទួលការទូន្មានប្រៀនប្រដៅ ព្រោះភាពដែលខ្លួនកើតមុននៃការកើតឡើងរបស់ព្រះពុទ្ធ ទើបលះឃរាវាសកេទបួសជាឥសី សាងអាស្រមអាស្រ័យភ្នំឈ្មោះគោតមកៈ ដែលនៅមិនឆ្ងាយអំពីភ្នំហិមពាន្ត ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងហើយ នៅដោយសុខដែលកើតអំពីឈាននោះឯង ។ កាលនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ បានជាព្រះពុទ្ធហើយ ទ្រង់ជញ្ជូនសត្វទាំងឡាយចាកសង្សារ យាងទៅកាន់ហិមវន្តប្បទេស ដើម្បីអនុគ្រោះកុលបុត្តនោះ តាបសឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ទើបឲ្យសិស្សរបស់ខ្លួនទាំងអស់ មកប្រជុំព្រមគ្នាហើយ ឲ្យសិស្សទាំងនោះ នាំយកផ្កាឈូកទាំងឡាយ*

មកបូជា ។ ដោយបុណ្យនោះ តាបសនោះអន្ទោលទៅក្នុងទេវតា និងមនុស្ស ទាំងឡាយ បានសោយសម្បត្តិទាំងពីរហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុង ផ្ទះមានត្រកូល ក្នុងនគរសាវត្ថី មានសទ្ធាជ្រះថ្លា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។

បទថា **គោតមោ នាម បព្វតោ** សេចក្តីថា ភ្នំដែលប្រាកដឈ្មោះថា គោតម ព្រោះជាលំនៅរបស់ពួកយក្ខ និងទេវតាជាច្រើន និងព្រោះជាលំនៅ របស់គោតម ដោយកម្លាំងនៃអធិដ្ឋាន ។ ឈ្មោះថា **បព្វត** ព្រោះប្រព្រឹត្តទៅ តាំងនៅ ។ បទថា **នានារុក្ខេហិ សញ្ឆន្នោ** មានវិគ្គហៈថា ឈ្មោះថា **រុក្ខ** ព្រោះដុះឡើងតាំងនៅ ម្យ៉ាងទៀត ឈ្មោះថា **រុក្ខ** ព្រោះទម្លុះផែនដីដុះឡើង ។ ដើមឈើទាំងឡាយ ដូចជាចម្ប៉ា កប្បិរ ខ្នុរ ក្រស្នា និងដើមចន្ទន៍ជាដើម ច្រើនប្រភេទ ច្រើនយ៉ាង រួមហៅថា **នានារុក្ខ** ក្តាប់សេចក្តីថា ភ្នំគោតម នោះ ដេរដាសដោយដើមឈើច្រើនប្រភេទទាំងនោះ ។ បទថា **មហាភូត-គណាលយោ** មានវិគ្គហៈថា ឈ្មោះថា **ភូត** ព្រោះមានឡើង កើតឡើង ឧប្បត្តិកឡើង និងចម្រើនឡើង ។ សត្វទាំងនោះមានទំហំផង ជាកូតផង

ហេតុនោះ ទើបឈ្មោះថា **មហាភូត** ។ គណៈ គឺពួករបស់មហាភូតទាំងឡាយ ឈ្មោះថា **មហាភូតគណា** ទីនៅអាស្រ័យរបស់ពួកមហាភូត ឈ្មោះថា **មហាភូតគណាលយោ** ។ បទថា **វេមជ្ឈម្ហិ ច តស្សាសិ** សេចក្តីថា អាស្រមនោះសាងឡើង គឺធ្វើឲ្យកើត បានដល់ ធ្វើក្នុងវវាង គឺកណ្តាលភ្នំឈ្មោះគោតមនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាបទុមបុប្ផិយត្ថេរាបទាន ចប់**

**សេរេយ្យវគ្គទី ១៣ ចប់**

# សុត្តន្តបិដក
# សោភិតវគ្គទី ១៤

## សោភិតត្ថេរាបទានទី ១

[ ៣១ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ទ្រង់ជានាយកៈ ទ្រង់សម្តែងធម៌ ជាចំណែកព្រះនិព្វាន ដល់ពួកជនច្រើន ។ កាលនោះ ខ្ញុំបានស្តាប់នូវព្រះពុទ្ធដីកា របស់ព្រះអង្គនោះ ដែលទ្រង់ពោលដោយវាចាដ៏អង់អាច ខ្ញុំផ្គងអញ្ជលី មានចិត្តនឹងក្នុងអារម្មណ៍តែមួយ ។ សមុទ្រប្រសើរជាងស្ទឹងទាំងឡាយ ភ្នំព្រះសុមេរុ ប្រសើរជាងភ្នំទាំងឡាយ យ៉ាងណាមិញ ជនណាប្រព្រឹត្តដោយអំណាចចិត្ត ជននោះមិនដល់មួយចំណិតនៃពុទ្ធញាណឡើយ ក៏យ៉ាងនោះដែរ ។ លុះព្រះសម្ពុទ្ធជាឥសី ប្រកបដោយសេចក្តីករុណា ទ្រង់បញ្ឈប់នូវធម្មវិធី គង់ក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងឡាយនេះថា ជនណា បានសរសើរនូវញាណនៃព្រះពុទ្ធ ជាលោកនាយក ជននោះឯងរមែងមិនទៅកាន់ទុគ្គតិ អស់ ១ សែនកប្ប នឹងដុតបំផ្លាញកិលេសទាំងឡាយ មានចិត្តនឹងក្នុងអារម្មណ៍តែមួយ មានចិត្តតម្កល់មាំ នឹងបាននាមថាសោភិតៈ ជាសាវកនៃព្រះសាស្តា ។ ខ្ញុំបានដុត

បំផ្លាញកង្កិលេសហើយ ភពទាំងពួង ខ្ញុំបានដកចេញហើយ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។ ក្នុងកប្បទី ៥០០០០ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ៧ ជាតិ ព្រះនាមសមុគ្គតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសោភិតត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សោភិតត្ថេរាបទាន ចប់

# អដ្ឋកថា
# សោភិតវគ្គទី ១៤

## សោភិតត្ថេរាបទាន

[ ៣១ ] *អបទានរបស់ព្រះសោភិតត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរោ នាម ជិនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ តម្កល់ខ្លួនក្នុងភាពជាឃរាវាស ។ ថ្ងៃមួយ កាលព្រះសាស្ដាសម្ដែងព្រះធម្មទេសនា មានចិត្តជ្រះថ្លា សោមនស្ស ទើបសរសើរដោយប្រការផ្សេងៗ ។ ដោយសោមនស្សនោះឯង កុលបុត្តនោះធ្វើកាលកិរិយាហើយ កើតក្នុងទេវលោក សោយទិព្វសុខក្នុងទេវលោកនោះហើយ បានមកកើតក្នុងមនុស្សលោក សោយសេចក្ដីសុខក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរសាវត្ថី កុលបុត្តនោះមានអាយុ ៧ ឆ្នាំ ក៏ចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត មាន*

អភិញ្ញា ៦ ។ ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះជាដើម ។

ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយខាងដើមនោះឯង ។l៙

**អដ្ឋកថាសោភិតត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សុទស្សនត្ថេរាបទានទី ២

[ ៣២ ] ពួកឈើមិលក្ខុមានផ្លែ នៅក្បែរឆ្នេរស្ទឹងដ៏ធំ ខ្ញុំកំពុងស្វែងរកឈើនោះ បានឃើញព្រះលោកនាយក ។ ក្នុងកាលនោះ ខ្ញុំឃើញដើមកែស មានផ្ការីក ទើបកាច់ផ្កាទាំងទង នាំចូលទៅថ្វាយចំពោះព្រះពុទ្ធ ព្រះនាមសិខី ជាលោកពន្ធុ ក្រាបទូលថា បពិត្រព្រះសម្ពុទ្ធ ទ្រង់ប្រសើរ ជាមហាមុនី ព្រះអង្គដល់ហើយនូវអមតបទ ជាទីមិនឃ្លាត ដោយញាណណា ខ្ញុំបូជាចំពោះញាណនោះ ។ លុះខ្ញុំធ្វើការបូជាចំពោះញាណហើយ ទើបបានឃើញនូវឈើមិលក្ខុ ខ្ញុំជាបុគ្គលបាននូវការសម្គាល់នោះ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណ-បូជា ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១២ ជាតិ ព្រះនាមពលុគ្គតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុទស្សនត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុទស្សនត្ថេរាបទាន ចប់

# អដ្ឋកថា

## សុទស្សនត្ថេរាបទាន

[ ៣២ ] អបទានរបស់ព្រះសុទស្សនត្ថេរ មានពាក្យផ្ដើមថា **វិនតាយ ឆទីតីរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ ថ្ងៃមួយ កំពុងដើររកដើមមិលក្ខុដែលមានផ្ការីកក្បែរឆ្នេរស្ទឹងឈ្មោះវិន្តតា បានជួបព្រះសម្មាសម្ពុទ្ធ ព្រះនាមសិខី ទ្រង់ល្អប្រៀបដូចគំនរភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ គង់ក្បែរឆ្នេរស្ទឹងនោះ មានចិត្តជ្រះថ្លាបានកាច់ផ្កាកាកែស ព្រមទាំងទងមកបូជា ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ជាសព្វញ្ញុពុទ្ធ ទ្រង់មានអានុភាពដល់ម៉្លេះ ដោយព្រះញាណណាខ្ញុំព្រះអង្គសូមបូជានូវព្រះញាណនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បានធ្វើអនុមោទនា ។ ដោយបុណ្យនោះ កុលបុត្តនោះ កើតក្នុងទេវលោកនិងមនុស្សលោក បានសោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ព្រះថេរៈរឭកដល់កុសលកម្មដែលខ្លួនបានធ្វើ កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វិនតាយ ឆទីតីរេ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **វិនតាយ** មានវិគ្គហៈ

ថា ឈ្មោះថា **វិត្ថតា** ព្រោះជាស្នឹងដែលធំទូលាយផ្សាយទៅ ។ ឈ្មោះថា **ឆជី** ព្រោះបន្ទឺសំឡេង គឺបញ្ចូនសំលេងទៅ ហូរទៅ កួចទៅ ។ ឈ្មោះថា **តីរំ** ព្រោះមនុស្សដែលឆ្លងស្ទឹង ត្រូវទៅកាន់ទីនោះជាមុន ទើបឆ្លងទៅបាន អធិប្បាយថា ក្បែរច្រាំងដែលធំទូលាយនោះ ។

បទថា **កោតកិ បុប្ផិតំ ឆិស្វា** មានវិគ្គហៈថា ឈ្មោះថា **កោតំ** ព្រោះមានបន្ទាមុតដៃរបស់បុគ្គលដែលចាប់ដោយមិនត្រូវទំនង ភ្ជាប់សេចក្តីថា ឃើញផ្កាកាកែសរបស់ដើមកាកែសនោះ ទើបកាច់ទាំងទង ។ បទថា **សិខិនោ លោកពន្ធុនោ** មានវិគ្គហៈថា ភ្លើង លោកហៅថា **សិខី** ក្រុមនៃរស្មីដែលមានពណ៌ ៦ មានពណ៌ខៀវ និងលឿងជាដើម ដូចគ្នានឹងភ្លើង ភ្លឺរុងរឿងមានដល់បុគ្គលណា បុគ្គលនោះ គឺព្រះមានព្រះភាគ ព្រះនាមសិខី ទ្រង់ជាលោកពន្ធុ ព្រោះជាផៅពង្ស គឺជាញាតិរបស់សត្វលោក គឺរបស់លោក ៣ ទាំងមូល ភ្ជាប់សេចក្តីថា ខ្ញុំកាច់ផ្កាកាកែស ( រំចេក ) ទាំងទងមកបូជាព្រះមានព្រះភាគព្រះនាមសិខី ដែលជាផៅពង្សរបស់លោកអង្គនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាសុធស្សនត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចន្ទនបូជកត្ថេរាបទានទី ៣

[ ៣៣ ] គ្រានោះ ខ្ញុំកើតជាកិន្នរ នៅទៀបឆ្នេរស្ទឹងចន្ទភាគា ជាអ្នកទទួលទាននូវផ្កាឈើ ជាអ្នកស្លៀកនូវផ្កាឈើ ។ កាលនោះព្រះមានព្រះភាគព្រះនាមអត្ថទស្សី ជាច្បងក្នុងលោក ជានរាសភៈស្តេចហោះទៅតាមទីបំផុតនៃព្រៃធំ ដូចស្តេចហង្ស ( ហើរទៅ ) នាអាកាស ( ខ្ញុំសរសើរពុទ្ធគុណថា ) បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ ព្រះហឫទ័យរបស់ព្រះអង្គស្អាតល្អហើយ ព្រះអង្គមានសម្បុរព្រះភក្ត្រជ្រះថ្លា មានឥន្ទ្រិយ គឺព្រះភក្ត្រស្រស់បស់ ។ លុះព្រះអត្ថទស្សី មានបញ្ញាដូចផែនដី មានបញ្ញាជាគ្រឿងពុះពារ ស្តេចចុះអំពីអាកាសហើយក្រាលសង្ឃាដី ទ្រង់ចូលមកទាំងភ្នែន ។ ខ្ញុំបានយកខ្លឹមចន្ទន៍ដ៏ល្អិតផង់ ហើយដើរចូលមកក្នុងសម្នាក់ព្រះជិនស្រី ខ្ញុំមានចិត្តជ្រះថ្លាមានចិត្តសោមនស្ស បានបូជាចំពោះព្រះពុទ្ធ ។ ខ្ញុំថ្វាយបង្គំព្រះពុទ្ធ ជាច្បងក្នុងលោក ជានរាសភៈ ហើយក៏កើតបាមោទ្យឈមមុខទៅកាន់ឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ១១៨ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាខ្លឹមចន្ទន៍ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១១៤ អំពីកប្បនេះ

ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមរោហិណីដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចន្ទនបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចន្ទនបូជកត្ថេរាបទាន ចប់

ភាណវារទី ៨ ចប់

# អដ្ឋកថា

## ចន្ទនបូជកត្ថេរាបទាន

[ ៣៣ ] *អបទានរបស់ព្រះចន្ទនបូជកត្ថេរ មានពាក្យផ្ដើមថា* **ចន្ទភាគានទីតីរេ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតជាកិន្នរ នៅប្របច្នេរស្ទឹងចន្ទភាគា ក្នុងព្រៃហិមពាន្ត មានផ្កាជាអាហារ ស្លៀកដណ្ដប់ផ្កា អប់ដោយក្លិនចន្ទន៍ និងក្រស្នាជាដើម សោយសេចក្ដីសុខច្រើនប្រការ ដូចជាលេងក្នុងឧទ្យាន និងលេងទឹកជាដើម សម្រេចជីវិតរស់នៅដូចគ្នានឹងកុម្មទេវតា នៅក្នុងព្រៃហិមពាន្ត ។ ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី យាងទៅកាន់ព្រៃហិមពាន្ត ដើម្បីអនុគ្រោះកិន្នរនោះ ចុះអំពីអាកាសហើយ ឲ្យភិក្ខុក្រាលសំពត់សង្ឃាដី ហើយប្រថាប់គង់ ។ កិន្នរនោះ បានជួបព្រះមានព្រះភាគអង្គនោះ ជាបុគ្គលរុងរឿង ប្រថាប់គង់ក្នុងទីនោះ មានចិត្តជ្រះថ្លា ទើបបូជាដោយលម្អិតខ្លឹមចន្ទន៍ក្រអូប ។ ព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនាដល់កិន្នរនោះ ។*

*ដោយបុណ្យនោះ កុលបុត្តនោះ តាំងនៅដរាបដល់អស់អាយុ ដោយសោមនស្សនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយសម្បត្តិក្នុងកាមាវចរស្ទួគ៌ ៦ ជាន់ អន្ទោលទៅមក ហើយបានសោយចក្កពត្តិសម្បត្តិ និងបទេសរជ្ជសម្បត្តិក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ*

កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ចេញបួស មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ចន្ទភាគានទីតីរេ** ដូច្នេះជាដើម ។ ឈ្មោះថា **ចន្ទ** ក្នុងពាក្យនោះ សំដៅដល់ហាក់ដូចជាដឹងនូវចន្ទ គឺចិត្ត ការពេញចិត្ត និងអធ្យាស្រ័យ ។ ឈ្មោះថា **ចន្ទភាគា** ព្រោះប្រៀបដូច គឺដូចព្រះចន្ទ ព្រោះមានទឹកថ្លាស្អាតប្រាសចាកមន្ទិល ដូចមណ្ឌលព្រះចន្ទ ន័យទីពីរ សំដៅដល់ឆ្នេរមានដីខ្សាច់ពណ៌សដេរដាស ដូចក្រាលដោយកែវមុក្តា ។ ក្បែរឆ្នេរស្ទឹងចន្ទភាគានោះ ។ ពាក្យដ៏សេស មានអត្ថដឹងងាយហើយ ព្រោះមានន័យដូចពោលខាងដើមនោះឯង ។៚

## អដ្ឋកថាចន្ទនបូជនកត្ថេរាបទាន ចប់

## ភាណវារៈទី ៨ ចប់

# សុត្តន្តបិដក

## បុប្ផឆទនិយត្ថេរាបទានទី ៤

[ ៣៤ ] មានព្រាហ្មណ៍ម្នាក់ មាននាមសុនន្ទៈ ជាអ្នកចេះចប់មន្ត ស្វាធ្យាយមន្ត គួរគេសូមបាន បានបួងសួងនូវយញ្ញ ឈ្មោះវាជ-បេយ្យៈ ។ កាលនោះ ព្រះលោកវិទូ ជាអគ្គបុរស ព្រះនាមបទុមុត្តរៈ ទ្រង់ប្រកបដោយសេចក្តីករុណា ទ្រង់ស្វែងរកនូវគុណអនុគ្រោះដល់ពួកជន ស្តេចចង្ក្រមនាអាកាស ។ លុះព្រះសម្ពុទ្ធជាសព្វញ្ញូ ជាលោកនាយក ទ្រង់ចង្ក្រមរួចហើយ ក៏ផ្សាយមេត្តាចំពោះពួកសត្វ ( សព្វទិស ) មិនមានប្រមាណ មិនមានឧបធិ ។ ព្រាហ្មណ៍ជាអ្នកចេះចប់មន្ត បានបេះយកផ្កាទាំងទង ប្រជុំពួកសិស្សទាំងអស់ ហើយបោះទៅលើអាកាស ។ ក្នុងកាលនោះនគរក៏មានគ្រឿងប្រក់ដោយផ្កាជាកំណត់ ហេតុតែអានុភាពនៃព្រះពុទ្ធ ផ្កាមិនបានវិនាសអស់ ៧ ថ្ងៃ ។ ដោយកុសលមូលនោះឯង ខ្ញុំបានសោយសម្បត្តិ កំណត់ដឹងនូវអាសវៈទាំងពួង ឆ្លងនូវតណ្ហា ជាគ្រឿងចាក់ស្រែះក្នុងលោក ។ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣៥ ជាតិ មានព្រះនាមអម្ពរំសៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ

៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា បុប្ផឆទនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បុប្ផឆទនិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បុប្ផឆទនិយត្ថេរាបទាន

[ ៣៤ ] *អបទានរបស់ព្រះបុប្ផឆទនិយត្ថេរ មានពាក្យផ្ដើមថា* **សុនន្ទោ នាម នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ សម្រេចការសិក្សាក្នុងសិប្បៈប្រចាំត្រកូល ជាអ្នកមានភោគៈច្រើន មានយសក្រៃលែង ត្រេកអរក្នុងការបរិច្ចាគទាន ថ្ងៃមួយ លោកលះមហាទាន ដោយគិតថា ឈ្មោះថា ពួកយាចកទាំងនេះ ក្នុងជម្ពូទ្វីបទាំងមូល កុំបីប្រាប់ថា អញមិនបានទាន ( ប្រភេទនេះ ) ។ ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ យាងទៅតាមអាកាស មួយអន្លើដោយបរិវារ ។ ព្រាហ្មណ៍ឃើញព្រះមានព្រះភាគអង្គនោះហើយ មានចិត្តជ្រះថ្លា ឲ្យហៅសិស្សរបស់ខ្លួនមក ឲ្យរកផ្កាមកហើយ បោះឡើងបូជាក្នុងអាកាស ។ ផ្កាទាំងនោះ បានគ្របដណ្ដប់នគរទាំងមូល តាំងនៅបាន ៧ ថ្ងៃ ។*

ដោយបុញ្ញកម្មនោះ កុលបុត្តនោះបានសោយសេចក្ដីសុខក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង មានសទ្ធា ទើបបួស គ្រាន់តែដាក់កាំបិតកោរជល់ក្បាលប៉ុណ្ណោះ ក៏សម្រេចអរហត្ត រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សុនន្ទោ នាម នាមេន** ដូច្នេះជាដើម ។ ពាក្យដ៏សេស មានអត្ថដ៏ងបានងាយហើយ ព្រោះបានពោលខាងដើមនោះឯង ៕

**អដ្ឋកថាបុប្ផចង្កោដិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## រហោសញ្ញិកត្ថេរាបទានទី ៩

[ ៣៥ ] មានភ្នំមួយឈ្មោះវសភៈ នៅជិតព្រៃហិមពាន្ត ខ្ញុំសាងអាស្រមនៅនាជើងភ្នំនោះ ។ កាលនោះ ខ្ញុំជាព្រាហ្មណ៍ បានបង្រៀនសិស្ស ៣០០០ នាក់ លុះបង្រៀនសិស្សទាំងនោះរួចហើយ ក៏ចូលទៅកាន់ទីសមគួរ ។ លុះព្រាហ្មណ៍ គឺខ្ញុំនេះឯងជាអ្នកចេះចប់មន្ត្រ អង្គុយក្នុងទីសមគួរហើយ ស្វែងរកមើលកេទរបស់ព្រះពុទ្ធ ក៏បានញុំាងចិត្តឲ្យជ្រះថ្លាក្នុងញាណ ។ លុះខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងញាណនោះរួចហើយ ក៏អង្គុយលើកម្រាលស្លឹកឈើ ពែនភ្នែនធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានដល់នូវសេចក្តីសម្គាល់ ( ក្នុងញាណ ) ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណសញ្ញា ។ ក្នុងកប្បទី ២៧ អំពីនេះ ខ្ញុំកើតជាស្តេចចក្កពត្តិព្រះនាមសិរីធរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះរហោសញ្ញិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

រហោសញ្ញិកត្ថេរាបទាន ចប់

# អដ្ឋកថា

## រេហាសញ្ញិកត្ថេរាបទាន

[ ៣៥ ] *អបទានរបស់ព្រះរេហាសញ្ញិកត្ថេរ មានពាក្យផ្តើមថា* **ហិមវន្តស្សាវិទូរេ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលដែលទទេចាកព្រះពុទ្ធ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងមជ្ឈិមប្រទេស ចម្រើនវ័យហើយ សម្រេចការសិក្សាក្នុងសិប្បៈប្រចាំត្រកូល មើលមិនឃើញសារៈក្នុងសិប្បៈនោះ ឃើញថា ត្រឹមតែចម្អែតផ្ទៃ នាំឲ្យកើតអកុសល មានសេចក្តីក្រោធ សេចក្តីស្រេវឹង និងការតម្កើងខ្លួនជាដើម ទើបលះឃរាវាស ចូលព្រៃហិមពាន្ត បួសជាឥសី មានតាបសច្រើនរយជាបរិវារ សាងអាស្រម នៅក្បែរភ្នំវសភៈ នៅត្រង់ភ្នំហិមពាន្តប៉ុណ្ណោះ ដរាបអស់ ៣ ពាន់ឆ្នាំ គិតថា អញដែលគេសន្មតថាជាអាចារ្យរបស់សិស្សមានប្រមាណប៉ុណ្ណោះ បានទទួលនូវការគោរពរាប់អាន និងការក្រាបថ្វាយបង្គំ តែខ្លួនអញមិនមានអាចារ្យដល់នូវទោមនស្ស ទើបប្រជុំសិស្សទាំងអស់នោះ ហើយប្រាប់ឲ្យដឹងថា កាលមិនមានព្រះពុទ្ធ ក៏មិនមានការសម្រេចព្រះនិព្វានខ្លួនឯង ក៏បែកមកអង្គុយតែម្នាក់ឯងក្នុងទីស្ងាត់ ធ្វើនូវសញ្ញាក្នុងចិត្តថា មានព្រះពុទ្ធ ហាក់បីដូចអង្គុយក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធ ធ្វើនូវបីតិមានព្រះពុទ្ធជាអារម្មណ៍ឲ្យកើតឡើង បានស្លាប់ក្នុងខណៈអង្គុយពត់ភ្នែនក្នុងសាលាហើយ ទៅកើតក្នុងព្រហ្មលោក ។*

*កុលបុត្តនោះ នៅក្នុងព្រហ្មលោកអស់កាលយូរ ព្រោះសេចក្តីសុខក្នុងឈាន ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល នឿយណាយក្នុងកាមទាំងឡាយ លុះមានអាយុ ៧ ឆ្នាំក៏បួស គ្រាន់តែចុងកាំបិតកោរដល់ក្បាលប៉ុណ្ណោះ ក៏សម្រេចអរហត្ត ជាអ្នកបានអភិញ្ញា ៦ រឭកដល់បុព្វកម្មរបស់ខ្លួនដោយបុព្វេនិវាសញ្ញាណ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **ហិមវន្តស្សាវិទូរេ** *ដូច្នេះជាដើម ។ បទថា* **វសភោ នាម បព្វតោ** *សេចក្តីថា ភ្នំដែលគេតែងហៅថា* **វសភ** *ព្រោះខ្ពស់បំផុត ព្រោះជាភ្នំខ្ពស់ជាងភ្នំទាំងអស់ វៀរលែងតែភ្នំហិមពាន្ត ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ៕*

**អដ្ឋកថាវរហោសញ្ញកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចម្បកបុប្ផិយត្ថេរាបទានទី ៦

[ ៣៦ ] ( ព្រះសម្ពុទ្ធ ) ទ្រង់រុងរឿងដូចផ្កាកណិការ ទ្រង់គង់នៅនាចន្លោះភ្នំ ញុំាងទិសទាំងពួង ឲ្យភ្លឺដូចផ្កាយព្រឹក មាណព ៣ នាក់ ជាអ្នកសិក្សាជំនាញក្នុងសិល្បសាស្ត្ររបស់ខ្លួន នាំគ្នាវែកអម្រែក ដើរមកអំពីក្រោយខ្ញុំ ខ្ញុំបានយកផ្កាទាំង ៧ ដែលតាបសដាក់ក្នុងកញ្ចប់នោះ ហើយថ្វាយផ្កាទាំងនោះ ចំពោះព្រះញាណរបស់ព្រះវេស្សភូសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃញាណបូជា ។ ក្នុងកប្បទី ២៩ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ ព្រះនាមវិហតាភាសៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចម្បកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចម្បកបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## ចម្បកបុប្ផិយត្ថេរាបទាន

[ ៣៦ ] *អបទានរបស់ព្រះចម្បកបុប្ផិយត្ថេរ មានពាក្យផ្ដើមថា* **កណិការំវ ជោតន្តំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវេស្សភូ កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ សម្រេចការសិក្សាសិប្បៈប្រចាំត្រកូល តែមើលមិនឃើញសារៈក្នុងសិប្បៈនោះ ទើបលះឃរាវាសបួសជាឥសីក្នុងចន្លោះព្រៃ យកផ្កាចម្ប៉ាដែលពួកសិស្សនាំមក បូជាចំពោះព្រះមានព្រះភាគព្រះនាមវេស្សភូ ។ ព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនា ។ ដោយកុសលកម្មនោះឯង កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ មានការនឿយណាយក្នុងឃរាវាស ព្រោះកម្លាំងវាសនាក្នុងកាលមុន ទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលតមក ព្រះថេរៈរឭកដល់បុញ្ញកម្មក្នុងកាលមុនរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **កណិការំវ ជោតន្តំ** *ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ*

*បទថា* **កណិការំ** *សេចក្ដីថា ឈ្មោះថា* **កណិការ** *ព្រោះក្នុងពេលដែលជម្រុះស្លឹកចាស់អស់ហើយ ចេញផ្កាជាប់គ្នាជាផ្ទាំង កាលផ្កាក្រពុំហើយ ក៏ត្រឡប់ដូចជាផ្កាទូទៅ ។ គប្បីជ្រាបថា កាលគួរប្រើពាក្យថា* **កណ្ណិការ** *លោកបែរជាប្រើពាក្យថា* **កណិការ** *ព្រោះលុប* **ណ** *អក្ខរៈ ខាងមុខចោល តាមគោលរបស់ភាសា អធិប្បាយថា ខ្ញុំបានឃើញព្រះពុទ្ធ ដែលរុងរឿងដូចដើមកណិការដែលរីកហើយនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៗ*

## អដ្ឋកថាចម្បកបុប្ផិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## អត្ថសន្ទស្សកត្ថេរាបទានទី ៧

[ ៣៧ ] ខ្ញុំអង្គុយនៅក្នុងរោងធំ បានឃើញ ( ព្រះបទុមុត្តរៈ ) ជាលោកនាយក ទ្រង់អស់អាសវៈ ទ្រង់ដល់នូវពលធម៌ មានភិក្ខុសង្ឃចោមរោម ។ ( ខ្ញុំសរសើរថា ) ភិក្ខុទាំង ១ សែនអង្គសុទ្ធតែជាអ្នកបានវិជ្ជា ៣ អភិញ្ញា ៦ មានឫទ្ធិច្រើន តែងចោមរោមព្រះសម្ពុទ្ធ អ្នកណាឃើញហើយ នឹងមិនជ្រះថ្លាបាន ។ ( ក្នុងលោក ) ព្រមទាំងទេវលោក ឥតមានញាណណានឹងប្រៀបផ្ទឹមក្នុងញាណព្រះសម្ពុទ្ធបានឡើយ អ្នកណាឃើញព្រះសម្ពុទ្ធ មានញាណរកទីបំផុតគ្មានហើយ នឹងមិនជ្រះថ្លាបាន ។ ម្យ៉ាងទៀត សាវ័កទាំងឡាយ សម្តែងនូវធម្មកាយ ជាទីកើតនៃរតនៈតែប៉ុណ្ណោះ តែមិនអាចឲ្យព្រះសម្ពុទ្ធកម្រើកបានទេ អ្នកណាឃើញហើយ នឹងមិនជ្រះថ្លាបាន ។ នារទបុរស គឺខ្ញុំនោះ ដើរទៅពីខាងមុខហើយ ពោលសរសើរនូវព្រះបទុមុត្តរសម្មាសម្ពុទ្ធ ទ្រង់ឥតមានបុគ្គលផ្ចាលផ្ចាញ់បាន ដោយគាថាទាំង ៣ នេះ ។ ដោយចិត្តជ្រះថ្លានោះផង ដោយការស្និទ្ធស្នាលនឹងព្រះពុទ្ធជាម្ចាស់ផង ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ អស់ ១ សែនកប្ប ។ ក្នុងកប្បទី

១៣០ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រចក្កពត្តិ ព្រះនាមសុមិត្តៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអត្ថសន្ទស្សកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អត្ថសន្ទស្សកត្ថេរាបទាន ចប់

# អដ្ឋកថា

## អត្ថសន្ទស្សកត្ថេរាបទាន

[ ៣៧ ] *អបទានរបស់ព្រះអត្ថសន្ទស្សកត្ថេរ មានពាក្យផ្តើមថា* **វិសាលមាឡេ អាសីនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយក្នុងជាតិជាច្រើន ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ សម្រេចការសិក្សាក្នុងសិប្បៈប្រចាំត្រកូល តែមើលមិនឃើញសារៈក្នុងសិប្បៈនោះ ទើបលះផ្ទះទៅកាន់ហិមវន្តប្បទេស សាងបណ្ណសាលា អាស្រ័យនៅក្នុងទីដែលគួរត្រេកអរនៃចិត្ត ។ ក្នុងកាលនោះ កុលបុត្តនោះ បានជួបព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ យាងមកកាន់ហិមវន្តប្បទេស ដើម្បីអនុគ្រោះពួកសត្វ មានចិត្តជ្រះថ្លា ថ្វាយបង្គំប្រកបព្រមដោយអង្គ ៥ ធ្វើនូវការសរសើរដោយពាក្យសរសើរជាច្រើន ដោយបុណ្យនោះ កុលបុត្តនោះតម្កល់ជីវិតនៅដរាបដល់អស់អាយុ ធ្វើកាលកិរិយាហើយ បានទៅកាន់ព្រហ្មលោក ។ ក្នុងកាលតមក ក្នុងពុទ្ធុប្បាទកាលនេះ កុលបុត្តនោះបានកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បាននូវសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។*

*ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **វិសាលមាឡេ អាសីនោ** *ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា* **វិសាលមាឡេ** *សេចក្ដីថា មណ្ឌបដ៏ធំ គឺទូលាយ ខ្ញុំអង្គុយក្នុងមណ្ឌបធំ បានឃើញព្រះពុទ្ធ ជាលោកនាយក ។ ពាក្យដ៏សេស មានអត្ថដ៏ងាយហើយ ៕*

**អដ្ឋកថាអត្ថសន្ទស្សកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឯករំសិយត្ថេរាបទានទី ៨

[ ៣៨ ] ខ្ញុំឈ្មោះនារទៈ តែគេស្គាល់ខ្ញុំថា កេសវៈវិញ ខ្ញុំកំពុងស្វែងរកកុសលអកុសល ក៏បានទៅកាន់សម្នាក់ព្រះពុទ្ធជាម្ចាស់ ។ ព្រះអត្ថទស្សីមហាមុនី មានព្រះហឫទ័យ ប្រកបដោយមេត្តាករុណា ព្រះចក្ខុមសម្ពុទ្ធអង្គនោះ ទ្រង់ញ៉ាំងសត្វឲ្យស្រុះស្រួល ហើយទ្រង់តែងសម្តែងធម៌ ( ចំពោះសត្វ ) ។ ខ្ញុំបានញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយធ្វើអញ្ជលីលើសិរ្សៈ ថ្វាយបង្គំព្រះសាស្តា រួចឈមមុខទៅកាន់បាចីនទិស ចៀសចេញទៅ ។ ក្នុងកប្បទី ១១៧ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ជាម្ចាស់ផែនដី ព្រះនាមអមិត្តបនៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯករំសិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯករំសិយត្ថេរាបទាន ចប់

# អដ្ឋកថា

## ឯករំសិយត្ថេរាបទាន

[ ៣៨ ] អបទានរបស់ព្រះឯករំសិយត្ថេរ មានពាក្យផ្ដើមថា **ឆាវតោ ឥតិ មេ ឆាទំ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើកុសលមកក្នុងជាតិជាច្រើន ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងត្រកូលព្រាហ្មណ៍ មានឈ្មោះថា កេសវៈ ដល់នូវភាពជាអ្នកដឹងក្ដីហើយ លះបង់ការគ្រប់គ្រងផ្ទះ ចេញបួស ថ្ងៃមួយ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា មានចិត្តជ្រះថ្លា ផ្គងអញ្ជលី កើតនូវបីតិដ៏ខ្លាំងក្លាហើយ ចៀសចេញទៅ ។ កុលបុត្តនោះ តម្កល់ជីវិតនៅដរាបដល់អស់អាយុ ទើបធ្វើកាលកិរិយាហើយ អស់ជីវិតដោយសោមនស្សនោះឯង បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិក្នុងទេវលោកនោះហើយ បានកើតក្នុងមនុស្សលោក សោយសម្បត្តិក្នុងមនុស្សលោកនោះទៀត ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង លុះចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលកម្មដែលខ្លួនធ្វើ កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យ

ថា **នារទោ ឥតិ មេ នាមំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **នារទោ** មានវិគ្គហៈថា ឈ្មោះថា **នារទ** ព្រោះមិនមានល្អងធូលី មន្ទិល និងព្រោះមានរាងកាយស្អាតអំពីកំណើត ទើបបានទទួលឈ្មោះអំពីត្រកូលថា នារទៈ ព្រោះផ្លាស់ ឆ អក្ខរៈជា ឧ អក្ខរៈ ។ បទថា **កេសវោ** សេចក្តីថា ជនទាំងឡាយអ្នកដឹង រមែងស្គាល់ខ្ញុំថា កេសវៈ គឺនារទកេសវៈ ព្រោះខ្ញុំកើតមកក្នុងកិសវច្ឆគោត្រ ។ ពាក្យដ៏សេស ប្រាកដជាក់ច្បាស់ហើយនោះឯង ។l៙ល៚

## អដ្ឋកថាឯករំសិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សាលទាយកត្ថេរាបទានទី ៩

[ ៣៩ ] គ្រានោះ ខ្ញុំកើតជាកេសរមិគរាជ ជាអភិជាត កំពុងស្វែងរកភក្ស៍ដែលគេទៅបានដោយកម្រ ក៏បានឃើញព្រះលោកនាយក ( ទើបគិតថា ) ឱហ្ន៎ ព្រះមហាវីរៈនេះហើយ ទ្រង់ញ៉ាំងមហាជនឲ្យរលត់ទុក្ខ បើដូច្នោះ គួរអាត្មាអញ ចូលទៅអង្គុយជិតព្រះពុទ្ធនេះ ព្រះអង្គជាទេវតារបស់ទេវតា ជានរាសភៈ ។ ទើបខ្ញុំកាន់យកមែករាំង ព្រមទាំងចង្កោមផ្កា ចូលទៅគាល់ព្រះសម្ពុទ្ធ ហើយថ្វាយផ្កាដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផទាន ។ ក្នុងកប្បទី ៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមវិរោចនៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តហើយ ។

បានឮថា ព្រះសាលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សាលទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## សាលទាយកត្ថេរាបទាន

[ ៣៩ ] *អបទានរបស់ព្រះសាលទាយកត្ថេរ មានពាក្យផ្ដើមថា* **មិគរាជា តទា អាសឹ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលកម្មទុកក្នុងភពនោះៗ តែព្រោះកម្មឯណានីមួយកាត់ផ្ដាច់ ទើបកើតក្នុងកំណើតរាជសីហ៍ ក្នុងព្រៃហិមពាន្ត មានសីហៈជាច្រើនជាបរិវារ ។ ក្នុងកាលនោះ ព្រះមានព្រះភាគទ្រង់ព្រះនាមសិខី បានយាងទៅកាន់ព្រៃហិមពាន្ត ដើម្បីអនុគ្រោះដល់សីហៈនោះ ។ រាជសីហ៍នោះ លុះបានឃើញព្រះមានព្រះភាគយាងចូលទៅរក ក៏មានចិត្តជ្រះថ្លា បាននាំយកផ្កាសាលព្រឹក្សព្រមទាំងទងមកបូជា ដោយវិធីកាច់បំបាក់មែក ។ ព្រះមានព្រះភាគទ្រង់បានធ្វើអនុមោទនា ដល់រាជសីហ៍នោះ ។*

*ដោយបុណ្យនោះ កុលបុត្តនោះបានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ បានសម្រេចអរហត្ត រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **មិគរាជា តទា អាសឹ** *ដូច្នេះជាដើម ។ គប្បីជ្រាបវិគ្គហៈក្នុងពាក្យថា* **មិគរាជា** *នោះដូចតទៅនេះ ឈ្មោះថា* **មិគ** *ព្រោះដល់នូវការស្លាប់ ម្យ៉ាងទៀត ឈ្មោះថា* **មិគ** *ព្រោះរមែងស្វះស្វែង គឺស្វែងរកអាហារ ។*

ស្តេចនៃម្រឹគទាំងឡាយ ឈ្មោះថា **មិគរាជា** សត្វនេះ ជាស្តេចរបស់សត្វជើងបួនគ្រប់ប្រភេទ តែលោកប្រើពាក្យថា **ម្រឹគ** ជាគោលពោលថា **មិគរាជា** ដើម្បីងាយស្រួលក្នុងការចងគាថា អធិប្បាយថា ក្នុងកាលដែលខ្ញុំបានឃើញព្រះមានព្រះភាគហើយ កាច់មែករាំងភ្នំ ព្រមទាំងផ្កាមកបូជា ខ្ញុំបានជាស្តេចម្រឹគ ។

បទថា **សកោសំ បុប្ផមាហរឹ** សេចក្តីថា ខ្ញុំបាននាំយកផ្កាសាលព្រឹក្សព្រមទាំងទងមកបូជា ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាសាលទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ផលទាយកត្ថេរាបទានទី ១០

[ ៤០ ] គ្រានោះ ខ្ញុំកើតជាសត្វបរោធកៈ ជាសត្វបរោធកៈយ៉ាងតូចបំផុត ទទួលទានដំណោកនៅក្បែរញកភ្នំ ក្នុងទីជិតសម្នាក់ព្រះសាស្ដា ព្រះនាមសិខី ។ ខ្ញុំតែងឃើញព្រះពុទ្ធ ជាលោកគ្គនាយក ទាំងល្ងាចព្រឹក តែខ្ញុំនឹងរកទេយ្យធម៌ ថ្វាយព្រះសម្ពុទ្ធមានព្រះហឫទ័យនឹង ប្រសើរជាងសត្វជើងពីរពុំបាន ។ ខ្ញុំបានយកផ្លែទ្រយឹង ទៅកាន់សម្នាក់ព្រះពុទ្ធ ព្រះមានព្រះភាគ ជាច្បងក្នុងលោក ជានរាសភៈ ទ្រង់ក៏បានទទួលយក ។ លំដាប់តពីនោះខ្ញុំធ្វើមរណកាលក្នុងទីនោះ ដោយចិត្តជ្រះថ្លា អាស្រ័យព្រះវិនាយក ដែលខ្ញុំប្រាថ្នាហើយនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃផលទាន ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ បានកើតជាស្ដេចចក្កពត្តិ ៣ ជាតិ ព្រះនាមមាលកិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ផលទាយកត្ថេរាបទាន ចប់

## ឧទ្ទាន

សោភិតត្ថេរាបទាន ១ សុទស្សនត្ថេរាបទាន ១ ចន្ទនបូជកត្ថេរាបទាន ១ បុប្ផឆទនិយត្ថេរាបទាន ១ រហោសញ្ញិកត្ថេរាបទាន ១ ចម្បកបុប្ផិយត្ថេរាបទាន ១ អត្ថសន្ទស្សកត្ថេរាបទាន ១ ឯកវំសនិយត្ថេរាបទាន ១ សាលទាយកត្ថេរាបទាន ១ ផលទាយកត្ថេរាបទាន ជាគម្រប់ ១០ គាថា ៧២ ពួកអ្នកប្រាជ្ញ បានគណនាហើយ ។

សោភិតវគ្គទី ១៤ ចប់

# អដ្ឋកថា

## ផលទាយកត្ថេរាបទាន

[ ៤០ ] អបទានរបស់ព្រះផលទាយកត្ថេរ មានពាក្យផ្ដើមថា **បរោធកោ តទា អាសឹ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កុលបុត្តនេះ កើតក្នុងត្រកូលព្រានសម្លាប់ម្រឹគទាំងឡាយចិញ្ចឹមជីវិត អាស្រ័យនៅត្រង់ញកភ្នំមួយកន្លែង ក្នុងព្រៃហិមពាន្ត ក្នុងកាលនោះ ព្រានព្រៃនោះ បានឃើញព្រះមានព្រះភាគព្រះនាមសិខី យាងទៅកាន់ទីនោះ មានចិត្តជ្រះថ្លា នមស្ការទាំងល្ងាច ទាំងព្រឹក មើលមិនឃើញទេយ្យធម៌ណាមួយ ទើបបេះផ្លែទ្រយឹង ដែលមានរសផ្អែមទៅថ្វាយ ព្រះមានព្រះភាគសោយផ្លែឈើទាំងនោះហើយ ព្រានព្រៃនោះមានសរីរៈដែលបីតិ មានព្រះពុទ្ធជាអារម្មណ៍ពាល់ត្រូវសព្វកាល មានចិត្តឆ្ងាយចាកបាបកម្ម បរិភោគមើមឈើ និងផ្លែឈើជាអាហារ មិនយូរប៉ុន្មានក៏អស់ជីវិត ទៅកើតក្នុងទេវលោក ។

កុលបុត្តនោះ បានសោយទិព្វសម្បត្តិក្នុងទេវលោកនោះហើយ មកកើតក្នុងមនុស្សលោក សោយនូវសម្បត្តិយ៉ាងច្រើនក្នុងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កុលបុត្តនោះ បានកើតក្នុងត្រកូលគហបតី ដល់នូវភាពជា

អ្នកដឹងក្តីហើយ នៅគ្រប់គ្រងផ្ទះ តែមិនមានការត្រេកអរក្នុងការគ្រប់គ្រងផ្ទះនោះ ទើបលះផ្ទះចេញបួសក្នុងសម្នាក់ព្រះសាស្តា ចម្រើនវិបស្សនាហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត រឭកដល់កម្ម គឺការថ្វាយផ្លែឈើ ដែលខ្លួនបានបំពេញ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បរោធកោ តទា អាសឹ** ដូច្នេះជាដើម ។ ក្នុងអបទាននោះ ភ្ជាប់សេចក្តីថា ក្នុងកាលដែលខ្ញុំថ្វាយផ្លែទ្រយឹង ធ្វើចិត្តឲ្យជ្រះថ្លានោះ ខ្ញុំជាព្រានព្រៃ ។ បទថា **បរោធកោ** បានដល់ជាអ្នកសម្លាប់សត្វដទៃ គឺជាអ្នកបៀតបៀន ។ ក្នុងកាលគួរពោលថា **បររោធកោ** តែលោកពោលថា **បរោធកោ** ព្រោះធ្វើការលុប រ អក្ខរៈមួយតួចេញ ។

បទថា **បរិចារី វិធាយកំ** សេចក្តីថា ខ្ញុំបានថ្វាយ គឺនិមន្ត បានដល់អារាធនាព្រះសាស្តាដែលសម្រេចនិព្វាននោះដោយពាក្យថា បពិត្រព្រះអង្គ សូមទ្រង់ឆាន់ផ្លែឈើនេះចុះ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ។៚

**អដ្ឋកថាផលទាយកត្ថេរាបទាន ចប់**

**សោភិតវគ្គទី ១៤ ចប់**

# សុត្តន្តបិដក
# ជាតុវគ្គទី ១៥

## អធិចត្តិយត្ថេរាបទានទី ១

[ ៤១ ] កាលព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ទ្រង់ប្រសើរជាងពួកនរៈ ទ្រង់បរិនិព្វានហើយ ខ្ញុំបានឲ្យគេធ្វើឆត្ររួត ហើយឲ្យលើកឡើងត្រង់ព្រះស្តូប ។ ខ្ញុំបានមកនមស្ការព្រះលោកនាយក សព្វៗ កាល ហើយធ្វើគ្រឿងប្រក់ដោយផ្កា លើកឡើងតម្កល់ពីខាងលើឆត្រ ។ ក្នុងកប្បទី ១១៧ អំពីកប្បនេះ ខ្ញុំបានសោយជាទេវរាជ ខ្ញុំមិនដែលទៅកើតជាមនុស្សម្តងឡើយ នេះជាផលនៃថូបបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអធិចត្តិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*អធិចត្តិយត្ថេរាបទាន ចប់*

# អដ្ឋកថា
# ចត្តវគ្គទី ១៥

## អធិចត្តិយត្ថេរាបទាន

[ ៤១ ] *អបទានរបស់ព្រះអធិចត្តិយត្ថេរ មានពាក្យផ្ដើមថា* **បរិនិព្វុតេ ភគវតិ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ព្រោះមិនបានឃើញព្រះមានព្រះភាគ កាលទ្រង់នៅមានព្រះជន្ម ក្នុងកាលដែលទ្រង់បរិនិព្វានហើយ ទើបគិតថា ឱ ! អញសាបសូន្យហើយហ្ន៎ ទើបសម្រេចចិត្តថា អញនឹងធ្វើជាតិ គឺការកើតរបស់អញឲ្យមានផល ហើយឲ្យជាងធ្វើចត្រួតបូជាបន្ទប់បញ្ចុះព្រះបរមសារីរិកធាតុ របស់ព្រះមានព្រះភាគអង្គនោះ ក្នុងកាលតមក ឲ្យជាងធ្វើចត្រផ្កាបូជាបន្ទប់ព្រះធាតុនោះទៀត ។ ដោយបុញ្ញកម្មនោះឯង ទើបកុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ បានកើតក្នុងត្រកូលគហបតី ដល់នូវភាពជាអ្នកដឹងក្ដីហើយ មានសេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ រៀនកម្មដ្ឋាន ព្យាយាមមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។*

*ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បរិនិព្វុតេ ភគវតិ** *ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា* **ឆត្តាតិឆត្តំ** *សេចក្ដីថា ឈ្មោះថា* **ឆត្ត** *ព្រោះបិទបាំងការពារនូវកម្ដៅជាដើម ឆត្រត្រួតលើឆត្រ គឺឆត្រដែលធ្វើលើឆត្រ ឈ្មោះថា* **ឆត្តាតិឆត្តំ** *បានដល់ ឆត្តដែលត្រួតគ្នាជាជាន់ៗ ។ បទថា* **ថូបម្ហិ អភិរោបយឹ** *សេចក្ដីថា ឈ្មោះថា* **ថូប** *ព្រោះសាងឡើង គឺធ្វើឲ្យជាគំនរ ។ ម្យ៉ាងទៀត ឈ្មោះថា* **ថូប** *ព្រោះមាំទាំ គឺតាំងនៅដោយសេចក្ដីចម្រើន លូតលាស់ បរិបូណ៌ដោយភាពមាំទាំ អធិប្បាយថា ខ្ញុំសាងឡើងបូជាដោយពិសេស ដោយការត្រួតឆត្រជាជាន់ៗ ក្នុងព្រះស្តូប ។*

*បទថា* **បុប្ផច្ឆទនំ កត្វាន** *សេចក្ដីថា ខ្ញុំធ្វើគ្រឿងប្រក់ដោយផ្កាច្រើនប្រភេទ មានក្លិនក្រអូបយ៉ាងល្អដែលរីកហើយ ឲ្យជាពិតានខាងលើឆត្រ រួចបូជា ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ៕*

**អដ្ឋកថាអតិឆត្តិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ថម្ភារោបកត្ថេរាបទានទី ២

[ ៤២ ] កាលព្រះលោកនាថ ព្រះនាមធម្មទស្សី ជានរាសភៈ ទ្រង់បរិនិព្វាន ខ្ញុំបានលើកដងទង់ ត្រង់ចេតិយរបស់ព្រះសម្ពុទ្ធ ដ៏ប្រសើរ ។ ខ្ញុំបានធ្វើជណ្តើរ សម្រាប់ឡើងទៅកាន់ព្រះស្តូបដ៏ប្រសើរ បានទាំងយកផ្កាជាតិព្រឹក ទៅដោតលើព្រះស្តូប ដោយតាំងចិត្តថា ព្រះពុទ្ធជាបុគ្គលអស្ចារ្យ ព្រះធម៌ជាសភាពអស្ចារ្យ សម្បទារបស់ព្រះសាស្តានៃយើង ជារបស់អស្ចារ្យ ។ ដោយសារកុសលកម្មនេះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថូបបូជា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមថូបសិខៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះថម្ភារោបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ថម្ភារោបកត្ថេរាបទាន ចប់

# អដ្ឋកថា

## ថម្ភារោបកត្ថេរាបទាន

[ ៤២ ] *អបទានរបស់ព្រះថម្ភារោបកត្ថេរ មានពាក្យផ្ដើមថា* **និព្វុតេ លោកនាថម្ហិ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមធម្មទស្សី កើតក្នុងផ្ទះមានត្រកូល ជាអ្នកមានសទ្ធាជ្រះថ្លា កាលព្រះមានព្រះភាគបរិនិព្វានហើយ បានលើកទង់ត្រង់បន្ទប់ព្រះធាតុរបស់ព្រះមានព្រះភាគ បានក្រងផ្កាម្លិះជាច្រើន ឡើងលើជណ្ដើរហើយបូជា ។*

*កុលបុត្តនោះ តម្កល់ជីវិតដរាបដល់អស់អាយុ ធ្វើកាលកិរិយាហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែង ជាអ្នកបានទទួលការបូជាតាំងអំពីក្មេង មានសទ្ធាមាំមួនក្នុងសាសនា បួសហើយ បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **និព្វុតេ លោកនាថម្ហិ** *ដូច្នេះជាដើម ។*

បណ្ដាបទទាំងនោះ បទថា **និព្វុតេ លោកនាថម្ហិ** សេចក្ដីថា កាល ព្រះសាស្ដាទ្រង់ជានាថៈ ទ្រង់ជាប្រធាន ទ្រង់ជាទីពឹងអាស្រ័យរបស់សត្វលោកទាំងមូលបរិនិព្វានហើយ ដោយរលត់ខន្ធបរិនិព្វានទៅ មើលមិនឃើញ ដូចគ្មានឹងពន្លឺប្រទីបដែលរលត់ទៅហើយ ដូច្នោះ ។ បទថា **ធម្មទស្សីនរាសភេ** មានរូបវិគ្គហៈថា ឈ្មោះថា **ធម្មទស្សី** ព្រោះទ្រង់ឃើញសច្ចៈ ៤ ប្រការ ម្យ៉ាងទៀត ឈ្មោះថា **ធម្មទស្សី** ព្រោះមានប្រក្រតីឃើញ ឃើញប្រចក្សនូវពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិប្បដ្ឋានជាដើម ។ ឈ្មោះថា **នរាសភោ** ព្រោះអាចហ៊ាន ប្រសើរបំផុតជាងនរជនទាំងឡាយ **ធម្មទស្សី** សព្ទ ១ **នរាសភ** សព្ទ ១ រួមជា **ធម្មទស្សីនរាសភ** ។ កាលព្រះមានព្រះភាគព្រះនាមធម្មទស្សី ដែលជាបុគ្គលប្រសើរជាងនរជនអង្គនោះ ។ បទថា **អារោបេសឹ ធជំ ថម្ភេ** សេចក្ដីថា ខ្ញុំបានបោះសសរត្រង់បន្ទប់ព្រះចេតិយ លើកទង់ត្រង់សសរនោះ ប្រតិស្ឋានហើយ ។

បទថា **និស្សេណឹ មាបយិត្វាន** មានរូបវិគ្គហៈថា ជនទាំងឡាយអាស្រ័យលើវត្ថុនោះ រមែងទៅ រមែងដើរទៅ រមែងឡើងទៅ ហេតុនោះទើបវត្ថុនោះ ឈ្មោះថា **និស្សេណី** ( ជណ្ដើរ ) ភ្ជាប់សេចក្ដីថា ខ្ញុំបានសាងគឺធ្វើ បានដល់ ចងជណ្ដើរហើយ ឡើងទៅកាន់ស្តូបដ៏ប្រសើរ ហើយបូជា ។

បទថា **ជាតិបុប្ផំ គហេត្វាន** មានវិគ្គហៈថា ឈ្មោះថា **ជាតិសុមន** ព្រោះកាលផ្កាកើតមក រមែងធ្វើនូវការត្រេកអរឲ្យដល់ជនទាំងឡាយ គឺផ្កាម្លិះនោះឯង ។ ក្នុងកាលគួរពោលថា **ជាតិសុមនបុប្ផ** លោកបែរជាពោលថា **ជាតិបុប្ផ** ដោយលុប **សុមន** សព្ទចេញ ដើម្បីឲ្យងាយស្រួលក្នុងការចងគាថា សេចក្តីថា ខ្ញុំបេះផ្កាម្លិះនោះមកក្រងហើយ លើកឡើងដាក់លើព្រះស្តូប គឺលើកឡើងបូជា ។ ពាក្យដ៏សេស មានអត្ថងាយបានងាយហើយ ។

**អដ្ឋកថាជម្ពាបោបកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វេទិការកត្ថេរាបទានទី ៣

[ ៤៣ ] កាលព្រះលោកនាថ ព្រះនាមបិយទស្សី ជានរៈដ៏ឧត្តម ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បាន សាងខឿនចេតិយ សម្រាប់ជាពុទ្ធបូជា ។ ខ្ញុំព័ទ្ធខឿននោះ ដោយ កែវមណី ហើយរៀបចំធ្វើបុណ្យឆ្លងខឿនដ៏ប្រសើរ ហើយក៏ធ្វើ មរណកាល ក្នុងវេលានោះ ។ ខ្ញុំទៅកើតក្នុងកំណើតណាៗ ទោះ បីជាទេវតា ឬជាមនុស្ស ទេវតាទាំងឡាយ តែងបាំងកែវមណី ពួដ៏អាកាស ( ចំពោះខ្ញុំ ) នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ១១៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣២ ជាតិ ព្រះ នាមមណិប្បកាសដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវេទិការកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

វេទិការកត្ថេរាបទាន ចប់

# អដ្ឋកថា

## វេទិការកត្ថេរាបទាន

[ ៨៣ ] អបទានរបស់ព្រះវេទិការកត្ថេរ មានពាក្យផ្ដើមថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបិយទស្សី កើតក្នុងត្រកូលមួយកន្លែងដែលសម្បូរដោយសម្បត្តិ ដល់នូវភាពជាអ្នកដឹងក្ដីហើយ នៅគ្រប់គ្រងផ្ទះ កាលព្រះសាស្ដាបរិនិព្វានហើយ មានសេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា ទើបឲ្យធ្វើវេទិមូលត្រង់ចេតិយរបស់ព្រះមានព្រះភាគអង្គនោះ ដាក់នូវកែវមណី ៧ ប្រការរហូតពេញហើយ ធ្វើការបូជាដ៏មហោឡារ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ជាអ្នកបានទទួលការបូជា មានទ្រព្យច្រើន មានភោគសម្បត្តិច្រើន ច្រើនសែនជាតិ សោយសុខក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដែលសម្បូរដោយសម្បត្តិ កាលបួសហើយ ព្យាយាមមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ថ្ងៃមួយ ព្រះថេរៈរឭកដល់កុសលដែលខ្លួនធ្វើមកក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទាន ទើបពោលពាក្យថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ។ បទថា **បិយទស្សិនរុត្តមេ** មានវិគ្គហៈថា ព្រះមានព្រះភាគអង្គណា មាន

ព្រះរូបគួរជាទីស្រឡាញ់ គឺមានការនាំឲ្យកើតសោមនស្ស ព្រះមានព្រះភាគអង្គនោះព្រះនាមបិយទស្សី អធិប្បាយថា ព្រះអង្គជាបុគ្គលល្អដោយមហាបុរិសលក្ខណៈ ៣២ ប្រការ អនុព្យញ្ជនៈ ៨០ និងមណ្ឌលនៃរស្មីដែលផ្សាយចេញជុំវិញ ១ ព្យាម មានព្រះរូបដែលធ្វើឲ្យកើតការជ្រះថ្លាដល់មហាជន ឈ្មោះថា **នរុត្តម** ព្រោះឧត្តមជាងនរជនទាំងឡាយ ។ មានព្រះរូបគួរជាទីស្រឡាញ់ផង ឧត្តមជាងនរជនផង ព្រោះហេតុនោះ ទើបឈ្មោះថា **បិយ-ទស្សីនរុត្តម** ភ្ជាប់សេចក្ដីថា កាលព្រះមានព្រះភាគព្រះនាមបិយទស្សីឧត្តមជាងនរជនអង្គនោះបរិនិព្វានហើយ ខ្ញុំបានសាងវេទិកាត្រង់បន្ទប់បញ្ចុះព្រះធាតុ សេចក្ដីថា ខ្ញុំបានសាងទែនបូជារាងមូល ត្រង់ខាងចុងដើម្បីដាក់ផ្កា ។ បទថា **មណីហិ បរិវារេត្វា** មានវិគ្គហៈថា ឈ្មោះថា **មណិ** ព្រោះចែងចាំង រុងរឿង ភ្លឺស្រឡះ ម្យ៉ាងទៀត ឈ្មោះថា **មណិ** ព្រោះធ្វើចិត្តរបស់ជនទាំងឡាយឲ្យពេញ ធ្វើឲ្យកើតសេចក្ដីត្រេកអរប្រព្រឹត្តទៅ អធិប្បាយថា ខ្ញុំបាននាំមណីជាច្រើន ដូចជាមណីក្រហម និងកែវពិទូរ្យជាដើម មកព័ទ្ធជុំវិញទែនមូលធ្វើការបូជាដ៏ឧត្តម គឺធ្វើការបូជាធំក្រៃលែង ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាវេទិការកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សបរិវារិយត្ថេរាបទានទី ៤

[ ៤៤ ] ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ជានាយកៈ រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។ លុះព្រះមហាវីរៈ ទ្រង់បរិនិព្វានហើយ ព្រះស្តូបជារបស់ធំសម្បើម ក៏កើតមានឡើង ( ក្នុងកាលនោះ ) ពួកជន តែងនាំគ្នាចូលទៅបម្រើព្រះស្តូប ត្រង់ល្វែងតម្កល់ព្រះធាតុដ៏ប្រសើរឧត្តម ។ កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានសាងខឿនខ្ទឹមចន្ទន៍ បានថ្វាយធូប និងគ្រឿងប្រអប់ ដ៏សមគួរដល់ព្រះស្តូប ។ កាលខ្ញុំកើតក្នុងភព ( ណាៗ ) ទោះបីជាទេវតា ឬជាមនុស្ស ខ្ញុំមិនបានជួបភាពថោកទាបឡើយ នេះជាផលនៃបុព្វកម្ម ។ ក្នុងកប្បទី ១១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៨ ជាតិ ព្រះនាមសមត្ថៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសបរិវារិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សបរិវារិយត្ថេរាបទាន ចប់

# អដ្ឋកថា

## សបរិវារិយត្ថេរាបទាន

[ ៤៤ ] *អបទានរបស់ព្រះសបរិវារិយត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរោ នាម ជិនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងជាតិជាច្រើន ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជាអ្នកមានទ្រព្យច្រើន មានភោគសម្បត្តិច្រើន ។ កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈបរិនិព្វានហើយ មហាជនរក្សាព្រះបរមធាតុរបស់ព្រះអង្គហើយ នាំគ្នាសាងមហាចេតិយ ជាទីសក្ការបូជា ក្នុងកាលនោះ ឧបាសកនេះ បានសាងផ្ទះជាចេតិយដោយខ្លឹមចន្ទន៍លើចេតិយនោះ ហើយបានធ្វើការបូជាយ៉ាងធំក្រៃលែង ដោយបុណ្យនោះឯង កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ សាងតែកុសលកម្ម តមក បានបួសក្នុងសាសនាដោយសទ្ធា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរោ ណាម ជិនោ** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **ឱមត្តំ** *សេចក្តីថា ខ្ញុំមិនឃើញ គឺមិនស្គាល់នូវភាពថោកទាប ឬភាពជាអ្នកដល់នូវសេចក្តីទុក្ខឡើយ បានដល់ ខ្ញុំមិនធ្លាប់ឃើញថា ខ្ញុំថោកទាបឡើយ ។ ពាក្យដ៏សេស ប្រាកដច្បាស់ហើយនោះឯង ។*

## អដ្ឋកថាសបរិវារិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឧម្មាបុប្ផិយត្ថេរាបទានទី ៩

[ ៤៥ ] កាលព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ដែលពួកសត្វលោកបូជាហើយ គួរទទួលនូវគ្រឿងបូជា ទ្រង់បរិនិព្វានហើយ ក៏មានការឆ្លងព្រះស្តូបដ៏ធំ ។ កាលដែលកំពុងរៀបចំឆ្លងព្រះស្តូប ខ្ញុំក៏បានយកផ្កាទៅជោតលើព្រះស្តូប នៃព្រះសិទ្ធត្ថមហេសី ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផបូជា ។ ក្នុងកប្បទី ៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៨៥ ជាតិ ព្រះនាមសោមទេវៈ ដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧម្មាបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឧម្មាបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

# ឧម្មាបុប្ផិយត្ថេរាបទាន

[ ៤៥ ] *អបទានរបស់ព្រះឧម្មាបុប្ផិយត្ថេរ មានពាក្យផ្ដើមថា* **និព្វុតេ លោកមហិតេ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កុលបុត្តនេះ បានកើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ កាលព្រះមានព្រះភាគបរិនិព្វានហើយ ខណៈដែលគេកំពុងធ្វើនូវការឆ្លងចេតិយ បានយកផ្កាត្រកៀត ពណ៌កែវមរកតមកបូជា ដោយបុណ្យនោះ កុលបុត្តនោះ បានអន្ទោលទៅតែក្នុងសុគតិ បានសោយទិព្វសម្បត្តិ និងមនុស្សសម្បត្តិ ក្នុងភពដែលកើតដោយចំណែកច្រើន កុលបុត្តនោះ មានសម្បុរខៀវ សម្បូរដោយជាតិ ដល់ព្រមដោយសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលមួយកន្លែងដែលសម្បូរដោយសម្បត្តិ ដល់នូវភាពជាអ្នកដឹងក្ដីហើយ មានសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។*

*ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **និព្វុតេ លោកមហិតេ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **លោកមហិតេ** មានវិគ្គហៈថា ឈ្មោះថា **លោកមហិត** ព្រោះដែលសត្វលោកទាំងឡាយ សរសើរបូជាហើយ ភ្ជាប់សេចក្តីថា កាលព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ដែលសត្វលោកបូជាហើយ ស្តេចបរិនិព្វានហើយ ។ បទថា **អាហុតីនំបដិគ្គហេ** មានវិគ្គហៈថា គ្រឿងបូជា និងសក្ការៈ ហៅថា **អាហុតិយោ** ឈ្មោះថា **អាហុតីនំ បដិគ្គហោ** ព្រោះសមគួរដើម្បីទទួលគ្រឿងបូជា និងសក្ការៈទាំងឡាយនោះ សព្ទនេះ ជាអលុត្តសមាស សេចក្តីថា កាលព្រះមានព្រះភាគ ដែលគួរទទួលគ្រឿងបូជា និងសក្ការៈ ស្តេចបរិនិព្វានហើយ ។

បទថា **ឧម្មាបុប្ផំ** មានវិគ្គហៈថា ឈ្មោះថា **ឧម្មាបុប្ផ** ព្រោះរីកថែងចាំងដោយពណ៌ខៀវខាងលើ សេចក្តីថា ខ្ញុំបានបេះផ្កាត្រកៀតនោះមកធ្វើការបូជាត្រង់ចេតិយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាឧមាបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អនុលោមទាយកត្ថេរាបទានទី ៦

[ ៤៦ ] ខ្ញុំបានធ្វើខឿនពោធិព្រឹក្ស នៃព្រះមុនីព្រះនាមអនោមទស្សី បានដាក់ដុំបាយ-អ ហើយធ្វើនូវបាណិកម្ម ( បូក ) ។ ព្រះសាស្តា ព្រះនាមអនោមទស្សី ប្រសើរជាងនរៈ គង់ក្នុងកណ្តាលភិក្ខុសង្ឃ ឃើញអំពើដែលខ្ញុំធ្វើល្អនោះហើយ ទើបសម្តែងគាថានេះថា កុលបុត្តនេះ បានសោយសម្បត្តិ ដោយការបូកបាយ-អនេះផង ដោយការតម្កល់ទុកនូវចេតនាផង ហើយនឹងធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខ ។ ខ្ញុំមានសម្បុរមុខថ្លាស្រស់ មានចិត្តនឹងនៅក្នុងអារម្មណ៍តែមួយ មានចិត្តតម្កល់មាំល្អ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ១០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមសម្បស្សនៈ ទ្រង់បរិបូណ៌ មិនខ្វះខាត ( ដោយសម្បត្តិ ) មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុលោមទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អនុលោមទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## អនុលោមទាយកត្ថេរាបទាន

[ ៤៦ ] *អបទានរបស់ព្រះអនុលោមទាយត្ថេរ មានពាក្យផ្តើមថា* **អនោមទស្សីមុនិនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអនោមទស្សី កើតក្នុងផ្ទះមានត្រកូល ជាអ្នកមានទ្រព្យច្រើន មានភោគសម្បត្តិច្រើន បានឲ្យជាងធ្វើវង្វង់ទែនបូជារាងវង្វង់ ត្រង់ដើមពោធិ៍របស់ព្រះមានព្រះភាគអង្គនោះ និងឲ្យបូកលាបដោយបាយ-អ ហើយឲ្យរោយខ្សាច់ធ្វើឲ្យមានពន្លឺ ដូចគ្នានឹងវិមានប្រាក់ ។ ដោយបុញ្ញកម្មនោះ ទើបកុលបុត្តនោះបានជួបតែសេចក្តីសុខ ក្នុងភពដែលខ្លួនកើតបានសោយសុខក្នុងវិមានប្រាក់ ផ្ទះប្រាក់ និងប្រាសាទប្រាក់ជាច្រើន ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។*

*ក្នុងកាលតមក ព្រះថេរៈរឭកដោយបុព្វេនិវាសានុស្សតិញ្ញាណ តាមលំដាប់ថា អញបានដល់នូវគុណវិសេសនេះ ព្រោះធ្វើកុសលអ្វីហ្ន៎ បានជ្រាបកុសលដែលខ្លួនធ្វើក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **អនោមទស្សី-មុនិនោ** *ដូច្នេះជាដើម ។ ក្នុងបទនោះ មានវិគ្គហៈថា ព្រះរូបដែលមិន*

ថោកថយ មិនអាក្រក់ គឺព្រះសរីរៈដែលគួរមើល គួរសរសើរ មានដល់ព្រះមានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមអនោមទស្សី អធិប្បាយថា ទ្រង់ជាបុគ្គលគួរមើល ស្អាត ព្រោះមានសរីរៈ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០ មានព្រះរស្មីផ្សាយចេញមួយព្យាមដោយជុំវិញ ភ្លឺរុងរឿង ។ បទថា **សុធាយ បិណ្ឌំ ទត្វាន** សេចក្ដីថា ឲ្យជាងធ្វើទែនបូជាជុំវិញខឿនពោធិព្រឹក្ស ហើយធ្វើនូវការបូកលាបដោយបាយ-អ ត្រង់ខឿនពោធិព្រឹក្សទាំងមូល ។ បទថា **ចាណិកម្មំ អកាសហំ** សេចក្ដីថា ខ្ញុំបានធ្វើបន្ទះក្ដារមានសណ្ឋានដូចដៃ រួចយកដៃខាត់ឲ្យរលោង ។ ពាក្យដ៏សេស មានអត្ថដ៏ងាយហើយ ៕

## អដ្ឋកថាអនុលោមទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## មគ្គទាយកត្ថេរាបទានទី ៧

[ ៤៧ ] ព្រះសម្ពុទ្ធមានបញ្ញាចក្ខុ ព្រះនាមសិទ្ធត្ថៈ ទ្រង់ចូងស៊ីង ស្តេចពុទ្ធដំណើរទៅកាន់ព្រៃ ខ្ញុំបានឃើញព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈនោះ ទ្រង់មានលក្ខណៈដ៏ប្រសើរ ទើបខ្ញុំកាន់យកចបនិងកញ្ច្រែ ធ្វើផ្លូវនោះឲ្យរាបស្មើ ហើយថ្វាយបង្គំព្រះសាស្តា ហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លូវ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំនោះ បានកើតជាស្តេច ១ អង្គ ព្រះនាមសុប្បពុទ្ធ ជាធំជាងជន ជានាយក ជាឥស្សរៈលើពួកនរជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមគ្គទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មគ្គទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## មគ្គទាយកត្ថេរាបទាន

[ ៤៧ ] *អបទានរបស់ព្រះមគ្គទាយកត្ថេរ មានពាក្យផ្តើមថា* **ឧត្តរិត្វាន នទិកំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូល ដែលសត្វលោកគោរពរាប់អាន ចម្រើនវ័យហើយ ក៏តាំងនៅក្នុងយាវសនិស្ស័យ ថ្ងៃមួយ បានឃើញព្រះមានព្រះភាគទ្រង់ឆ្លងស្ទឹងមួយកន្លែងហើយ យាងចូលទៅក្នុងព្រៃ មានសេចក្តីជ្រះថ្លា គិតថា ពេលនេះ គួរអញធ្វើផ្លូវឲ្យរាបស្មើ ដើម្បីព្រះមានព្រះភាគ ដូច្នេះហើយ កាន់យកចបនិងកញ្ជើមកធ្វើផ្លូវ ដែលព្រះមានព្រះភាគយាងទៅឲ្យរាបស្មើ រោយនូវខ្សាច់ហើយ ចូលទៅថ្វាយបង្គំព្រះបាទារបស់ព្រះមានព្រះភាគ តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ដោយផលនៃការពង្រាបផ្លូវឲ្យល្អនេះ ខ្ញុំព្រះអង្គសូមបានទទួលនូវការបូជាសព្វទីដែលខ្ញុំកើតផងចុះ ម្យ៉ាងទៀត ខ្ញុំព្រះអង្គសូមបានសម្រេចនូវព្រះនិព្វានផងចុះ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនាថា* **យថាធិប្បាយំ សមិជ្ឈតុ** *អ្នកប្រាថ្នាយ៉ាងណា ចូរសម្រេចយ៉ាងនោះចុះ ហើយចៀសចេញទៅ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ ក៏បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានទទួលនូវការបូជាគ្រប់កពា ( ដែលខ្លួនកើត ) ក្នុងពុទ្ធុប្បាទកាលនេះ បានកើតក្នុងត្រកូលដែលមានកេរ្តិ៍ឈ្មោះមួយកន្លែង ជ្រះថ្លាក្នុងព្រះសាស្តា*

បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ជ្រាបដល់បុព្វកម្មរបស់ខ្លួនបានដោយប្រចក្ស កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឧត្តរិត្វាន នទិកំ** ដូច្នេះជាដើម ។ ក្នុងបទនោះ មានវិគ្គហៈថា ឈ្មោះថា **នទី** ព្រោះបន្ទឺសំឡេងបញ្ចេញសំឡេងហ៊ោទៅ នទីនោះឯង ជា **នទិក** អធិប្បាយថា ឡើង គឺឆ្លងស្ទឹងនោះ ។ បទថា **កុទាលបិដកមាទាយ** សេចក្តីថា ផែនដី លោកហៅថា **កុ** ឈ្មោះថា **កុទាល** ព្រោះជារបស់សមគួរក្នុងការទម្លាយ ជីក គាស់នូវផែនដីនោះ ។ វត្ថុសម្រាប់ជញ្ជូនដី និងខ្សាច់ជាដើម ហៅថា **បិដក** បានដល់ កាជន៍ដែលធ្វើដោយស្លឹកត្នោត ផ្តៅ និងវល្លិជាដើម ។ ចប និងកញ្ជើ ឈ្មោះថា **កុទាលបិដក** សេចក្តីថា កាន់យកចប និងកាជន៍ គឺកញ្ជើនោះមក ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាមគ្គទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ផលកទាយកត្ថេរាបទានទី ៨

[ ៤៨ ] កាលពីដើម ខ្ញុំជាអ្នកធ្វើយាន បានសិក្សាស្ទាត់ក្នុងការឈើ បានធ្វើផែនក្តារដោយខ្លឹមចន្ទន៍ ថ្វាយចំពោះលោកពន្ធុ ។ (ដោយកុសលកម្មនោះ) ទើបវិមាននេះ ដែលបុញ្ញកម្មតាក់តែងដោយមាស តែងភ្លឺរុងរឿង មានទាំងយានដំរី យានសេះ យានទិព្វ កើតប្រាកដឡើង (ដល់ខ្ញុំ) ។ ទាំងប្រាសាទ និងគ្រែស្នែងក៏កើតឡើង (ដល់ខ្ញុំដែរ) កែវជារបស់មិនរំភើប គួរតាមប្រាថ្នា (ក៏កើតឡើង) ដល់ខ្ញុំ នេះជាផលនៃផែនក្តារ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផែនក្តារ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផែនក្តារ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៤ ជាតិ ព្រះនាមភវនិម្មិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ផលកទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ផលកទាយកត្ថេរាបទាន

[ ៤៨ ] *អបទានរបស់ព្រះផលកទាយកត្ថេរ មានពាក្យផ្តើមថា* **យានការោ បុរេ អាសឹ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយក្នុងអត្តភាពមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលជាងឈើ ជ្រះថ្លាក្នុងព្រះរតនត្រ័យ បានធ្វើបន្ទះក្តារដោយខ្លឹមចន្ទន៍ ថ្វាយដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានធ្វើអនុមោទនាដល់កុលបុត្តនោះហើយ ។*

*ដោយបុញ្ញកម្មនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និង មនុស្សទាំងឡាយ ជាអ្នកមានសេចក្តីសុខ ឆ្អែតស្កប់ស្កល់គ្រប់វេលា បាន សោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមាន ត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា កើតសេចក្តីជ្រះថ្លាបួស ទើបចេញបួស ព្យាយាមមិនយូរប៉ុន្មាន ក៏បានសម្រេច អរហត្ត មួយអន្លើដោយបដិសម្ភិទា ហើយរឭកដល់បុព្វកម្មរបស់ខ្លួន កើត នូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោល ពាក្យថា* **យានការោ បុរេ អាសឹ** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទ ថា* **យានការោ** *មានវិគ្គហៈថា ឈ្មោះថា* **យាន** *ព្រោះជាគ្រឿងធ្វើឲ្យទៅ ដល់ទីដែលប្រាថ្នា ។ ឈ្មោះថា* **យានការោ** *ព្រោះជាអ្នកធ្វើនូវយាននោះ អធិប្បាយថា កាលមុន គឺក្នុងសម័យដែលបានឃើញព្រះពុទ្ធ ខ្ញុំជាជាងធ្វើ*

*យាន ។ បទថា* **ចន្ទនំ ផលកំ កត្វា** *មានវិគ្គហៈថា ឈ្មោះថា* **ចន្ទន** *ព្រោះធ្វើឲ្យកើតសេចក្ដីសុខ គឺស្ងប់រម្ងាប់នូវសេចក្ដីក្ដៅក្រហាយ ។ មយ៉ាងទៀត ឈ្មោះថា* **ចន្ទន** *ព្រោះជាគ្រឿងធ្វើឲ្យស្អាត គឺជាគ្រឿងប្រោះព្រំរាងកាយ អប់ឲ្យមានក្លិនក្រអូប ។ ខ្ញុំយកខ្លឹមចន្ទន៍នោះ ធ្វើជាបន្ទះក្ដារ ។ បទថា* **លោកពន្ធុនោ** *មានវិគ្គហៈថា ឈ្មោះថា* **លោកពន្ធុ** *ព្រោះទ្រង់ជាផៅពង្ស គឺទ្រង់ជាញាតិនៃលោកទាំងមូល អធិប្បាយថា ខ្ញុំបានថ្វាយដល់ព្រះសាស្ដាទ្រង់ជាផៅពង្សរបស់សត្វលោកអង្គនោះ ។ ពាក្យដ៏សេស មានអត្ថដ៏ងាយហើយ ។*

**អដ្ឋកថាផលកទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វដំសកិយត្ថេរាបទានទី ៩

[ ៤៩ ] ព្រះសយម្ភូ ព្រះនាមសុមេធៈ ឥតមានបុគ្គលផ្ចាញ់បាន ទ្រង់ចម្រើនវិវេក ស្តេចចូលទៅកាន់ព្រៃធំ ។ ខ្ញុំបានឃើញដើមស្រល់មានផ្ការីក ( ទើបកាន់យកមក ) ដោតក្រងធ្វើជាគ្រឿងប្រដាប់ក្បាល បង្អោនថ្វាយព្រះពុទ្ធ ជាលោកនាយក ចំពោះព្រះភក្ត្រ ។ ក្នុងកប្បទី ៣០០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១១៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមនិម្មិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវដំសកិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

វដំសកិយត្ថេរាបទាន ចប់

# អដ្ឋកថា

## វដំសកិយត្ថេរាបទាន

[ ៤៩ ] *អបទានរបស់ព្រះវដំសកិយត្ថេរ មានពាក្យផ្ដើមថា* **សុមេធោ នាម នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះមុនិន្ទសម្ពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសុមេធៈ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ នៅគ្រប់គ្រងផ្ទះ តែព្រោះមើលឃើញទោសក្នុងឃរាវាសនោះ ទើបលះបង់ផ្ទះចេញបួសជាឥសី នៅក្នុងព្រៃមហាវ័ន ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមសុមេធៈ បានយាងចូលទៅកាន់ព្រៃនោះ ដើម្បីបំណងនូវវិវេក ។ កាលនោះ តាបសបានឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា កាន់យកផ្កាស្រស់ដែលកំពុងរីក មកក្រងជាមាល័យដាក់បូជាត្រង់បាទមូលរបស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់បានធ្វើអនុមោទនា ដើម្បីឲ្យកុលបុត្តនោះមានចិត្តជ្រះថ្លា ។ ដោយបុណ្យនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិ ចម្រើនវ័យហើយ មានសទ្ធាជ្រះថ្លា ទើបចេញបួស មិនយូរប៉ុន្មានក៏បានជាព្រះអរហន្ត ។*

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សុមេធោ នាម នាមេន** ដូច្នេះជាដើម ។

បទថា **វិវេកមនុព្រូហន្តោ** សេចក្តីថា ទ្រង់លះនូវការប្រឡូកប្រឡំដោយពួកជន កាលនឹងផ្តើមចម្រើននូវការស្ងាត់ចាកពួកជន និងការស្ងាត់ចិត្ត ទើបបានចូលទៅកាន់ព្រៃធំ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាវជំសកិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បល្លង្កទាយកត្ថេរបទានទី ១០

[ ៥០ ] ខ្ញុំបានថ្វាយបល្ល័ង្ក ( គ្រែ ) ព្រមទាំងពិតាន ចំពោះព្រះមានព្រះភាគព្រះនាមសុមេធៈ ជាច្បងក្នុងលោក ទ្រង់ប្រកបដោយតាទិគុណ ។ ពេលនោះ បល្ល័ង្កដ៏បរិបូណ៌ដោយកែវ ៧ ប្រការនោះ ( ហាក់ដូចជា ) ដឹងតម្រិះរបស់ខ្ញុំ តែងកើតសម្រាប់ខ្ញុំសព្វៗ កាល ។ ក្នុងកប្បទី ៣០០០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយបល្ល័ង្ក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបល្ល័ង្ក ។ ក្នុងកប្បទី ២០០០០ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមសុវណ្ណាភា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបល្លង្កទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បល្លង្កទាយកត្ថេរាបទាន ចប់

## ឧទ្ទាន

អធិចត្តិយត្ថេរាបទាន ១ ថម្ភារោបកត្ថេរាបទាន ១ វេទិការកត្ថេរាបទាន ១ សបរិវារិយត្ថេរាបទាន ១ ឧម្មាបុប្ផិយត្ថេរាបទាន ១ អនុលោមទាយកត្ថេរាបទាន ១ អគ្គទាយកត្ថេរាបទាន ១ ផលកទាយកត្ថេរាបទាន ១ វដំសកិយត្ថេរាបទាន ១ បល្លង្កទាយកត្ថេរាបទាន ១ មានគាថា ៥៦ អ្នកប្រាជ្ញបានពោលទុកហើយ ។

**ឆត្តវគ្គទី ១៥ ចប់**

# អដ្ឋកថា

## បល្លង្កទាយកត្ថេរបទាន

[ ៥០ ] *អបទានរបស់ព្រះបល្លង្កទាយកត្ថេរ មានពាក្យផ្ដើមថា* **សុមេធស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសុមេធៈ កើតក្នុងត្រកូលគហបតី ចម្រើនវ័យហើយ សម្បូរដោយភោគសម្បត្តិជាច្រើន ជ្រះថ្លាក្នុងព្រះសាស្តា បានស្តាប់ធម៌ហើយ ឲ្យមនុស្សធ្វើបល្ល័ង្កដែលសម្រេចដោយរតនៈ ៧ ប្រការ ថ្វាយដល់ព្រះសាស្តាអង្គនោះហើយ បានធ្វើនូវការបូជាធំ ។ ដោយបុណ្យនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ជាបុគ្គលបានទទួលការបូជាក្នុងទីទាំងពួង ដោយលំដាប់ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ដែលសម្បូរដោយសម្បត្តិ ដល់នូវភាពជាអ្នកដឹងក្តីហើយ នៅគ្រប់គ្រងផ្ទះ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ កើតនូវសេចក្តីជ្រះថ្លា បួសហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត បានប្រាកដឈ្មោះថា បល្លង្កទាយកត្ថេរ តាមឈ្មោះនៃបុណ្យដែលខ្លួនបានធ្វើហើយក្នុងកាលមុន ។ ក្នុងរឿងខាងមុខ គប្បីជ្រាបថា ព្រះថេរៈទាំងឡាយ បាននាមតាមឈ្មោះបុណ្យដែលធ្វើក្នុងកាលមុន ដូចរឿងដែលកន្លងមកហើយនោះឯង ។*

*ថ្ងៃមួយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **សុមេធស្ស ភគវតោ** *ដូច្នេះជាដើម ។ បទថា* **បល្លង្កោ ហិ មយា ធិន្នោ** *សេចក្ដីថា ជនទាំងឡាយ រមែងចូលទៅអង្គុយក្នុងទីដែលធ្វើបល្ល័ង្ក គឺអាសនៈស្មើភ្លៅ ដែលលោកហៅថា* **បល្លង្ក** *អធិប្បាយថា បល្ល័ង្កនោះ ធ្វើដោយរតនៈ ៧ ប្រការ ខ្ញុំបានបូជាថ្វាយហើយ ។ បទថា* **សឧត្តរសបច្ឆទោ** *ឈ្មោះថា* **សឧត្តរសបច្ឆទោ** *គឺព្រមទាំងសំពត់សម្រាប់បិទខាងលើ និងខាងក្រោម សេចក្ដីថា បានចងជាពិតានខាងលើ ហើយយកសំពត់យ៉ាងល្អស្រោបអាសនៈ ។ ពាក្យដ៏សេស ប្រាកដច្បាស់ហើយ ។*

**អដ្ឋកថាបល្លង្កទាយកត្ថេរាបទាន ចប់**

**ចត្តវគ្គទី ១៤ ចប់**

# សុត្តន្តបិដក

# ពុទ្ធាបទានវគ្គទី ១៦

## ពន្ធុជីវកត្ថេរាបទានទី ១

[ ៥១ ] ( ខ្ញុំបានឃើញព្រះពុទ្ធព្រះនាមសិខី ) ទ្រង់បរិសុទ្ធ ប្រាសចាកមន្ទិល ដូចព្រះចន្ទ្រ មានព្រះហឫទ័យថ្លាស្អាត មិនល្អក់ មាននន្ទិរាគៈ និងភពអស់ហើយ ព្រះអង្គឆ្លងហើយនូវវិសត្តិកាតណ្ហាក្នុងលោក ព្រះអង្គញុំាងប្រជុំជនឲ្យរលត់ទុក្ខ ទ្រង់ឆ្លងហើយ ជាព្រះមុនីរបស់ពួកជនអ្នកឆ្លង កំពុងចម្រើនឈាន មានព្រះហឫទ័យនឹងក្នុងអារម្មណ៍តែមួយ តាំងមាំល្អក្នុងព្រៃ ។ ខ្ញុំពាក់នូវផ្កាច្បាលើខ្សែអំបោះ ហើយថ្វាយចំពោះពុទ្ធព្រះនាមសិខី ជាផៅពង្សនៃលោក ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ គ្រានោះព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមសមន្តចក្ខុ ទ្រង់មានយសច្រើន ជាធំក្នុងមនុស្ស មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា

៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពន្ធុជីវកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ពន្ធុជីវកត្ថេរាបទាន ចប់

# អដ្ឋកថា
# ពន្ធុជីវកវគ្គទី ១៦

## ពន្ធុជីវកត្ថេរាបទាន

[ ៥១ ] *អបទានរបស់ព្រះពន្ធុជីវកត្ថេរ មានពាក្យផ្ដើមថា* **ចន្ទំវ វិមលំ សុទ្ធំ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី បានកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ នៅគ្រប់គ្រងផ្ទះ បានឃើញព្រះរូបកាយសម្បត្តិរបស់ព្រះមានព្រះភាគព្រះនាមសិខីហើយ មានចិត្តជ្រះថ្លា បេះផ្កាច្បាជាច្រើនបូជាទៀបបាទមូលព្រះមានព្រះភាគ ដើម្បីធ្វើចិត្តរបស់កុលបុត្តនោះ ឲ្យកើតសេចក្ដីជ្រះថ្លា ទើបព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនា ។ កុលបុត្តនោះតាំងជីវិតនៅជរាបដល់អាយុក្ខ័យ ដោយបុណ្យនោះឯង ក៏ទៅកើតក្នុងទេវលោក សោយនូវកាមាវចរសម្បត្តិ ៦ ជាន់ ហើយបានសោយសម្បត្តិ មានចក្កពត្តិសម្បត្តិជាដើម ក្នុងមនុស្សលោកទៀត ក្នុងកាលដែលព្រះសម្មាសម្ពុទ្ធនៃយើងកើតឡើងហើយ កុលបុត្តនោះ បានកើតក្នុងត្រកូលគហបតី បានស្ដាប់ព្រះធម៌របស់ព្រះសាស្ដាហើយ កើតនូវសទ្ធា លះនូវផ្ទះចេញបួស ហើយបានសម្រេចអរហត្ត ព្រះថេរៈរឭកដល់កុសលកម្មដែលខ្លួនធ្វើក្នុងកាល*

មុន ដោយបុព្វេនិវាសញ្ញាណ កើតនូវសោមនស្ស កាលប្រកាសអបទាន ទើបពោលពាក្យថា **ចន្ទំវ វិមលំ សុទ្ធំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ចន្ទំវ វិមលំ សុទ្ធំ** ក្នុងសេចក្ដីថា នូវព្រះសម្មាសម្ពុទ្ធព្រះនាមសិខី ដែលឈ្មោះថា **វិមល** ព្រោះលះមន្ទិល គឺឧបក្កិលេស ១៥០០ ចេញបាន ដូចព្រះចន្ទផុតហើយចាកមន្ទិលអំពីឧបក្កិលេសទាំងនេះ គឺពពក សន្សើម ផ្សែង ធូលី និងរាហូ ។ ឈ្មោះថា **សុទ្ធ** ព្រោះមិនមានកិលេស ឈ្មោះថា **អនាវិលំ** ព្រោះមិនមានកក់ គឺកិលេស ឈ្មោះថា **នន្ទីភវបរិក្ខីណំ** ព្រោះសេចក្ដីស្នេហាដែលមានកម្លាំង គឺការត្រេកអរ និងភពអស់ទៅហើយដោយជុំវិញ ។ បទថា **តិណ្ណំ លោកេ** សេចក្ដីថា ឆ្លង គឺឆ្លងឡើង បានដល់ ផុតចាកលោកទាំង ៣ បានហើយ ។ បទថា **វិសត្តិកំ** សេចក្ដីថា តណ្ហា លោកហៅថា **វិសត្តិក** បានដល់មិនមានតណ្ហា ។

បទថា **និព្វាបយន្តំ ជនតំ** សេចក្ដីថា ទ្រង់បន្សូរនូវក្ដៅ គឺជម៌ ។ ទ្រង់ញុំាំងពួកជន គឺប្រជុំជនឲ្យត្រជាក់ គឺស្ងប់រម្ងាប់នូវការក្ដៅក្រហាយ គឺកិលេស ក្នុងសេចក្ដីថា នូវព្រះសម្មាសម្ពុទ្ធព្រះនាមសិខីព្រះអង្គ ទ្រង់ឆ្លងចាកសង្សារហើយ ទ្រង់ដឹកនាំសត្វទាំងពួងឲ្យឆ្លងផុតចាកសង្សារផង ទ្រង់ជាមុនី ព្រោះត្រាស់ដឹងអរិយសច្ច ៤ ។ បទថា **វនស្មឹ ឈាយមានំ** សេចក្ដីថា ទ្រង់សម្លឹង ទ្រង់ពិនិត្យ ទ្រង់អប់រំចិត្តដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈានក្នុងកណ្ដាលព្រៃ ក្នុងសេចក្ដីថា ខ្ញុំបានឃើញព្រះពុទ្ធព្រះ

នាមសិខី ទ្រង់ជាមុនី មានចិត្តជាឯកគ្គតា មានចិត្តតាំងមាំ ដោយល្អក្នុងអារម្មណ៍តែមួយ ។

បទថា **ពន្ធុជីវកបុប្ផានិ** គប្បីជ្រាបដូច្នេះថា បុគ្គលឲ្យជីវិត គឺឲ្យជីវិតអាស្រ័យនៅដល់ផៅពង្ស បានដល់ ញាតិទាំងឡាយ ( វត្ថុនោះ ) បានដល់ បេះដូង សាច់ និងឈាម ហៅថា **ពន្ធុជីវក** បានដល់ ផ្កាដែលមានពណ៌ដូចបេះដូង សាច់ និងឈាម សេចក្តីថា ខ្ញុំបេះផ្កាច្បាមកបូជាព្រះសម្មាសម្ពុទ្ធព្រះនាមសិខី ដែលជាព្រះលោកពន្ធុ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាពន្ធុជីវកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## តម្ពបុប្ផិយត្ថេរាបទានទី ២

[ ៥២ ] ខ្ញុំប្រកបក្នុងការងាររបស់ជនដទៃ បានធ្វើនូវកំហុស ជាអ្នកពេញប្រៀបដោយភ័យ និងវៀរ ហើយក៏ស្ទុះរត់ទៅពួន ក្នុងទីព្រៃ ។ ខ្ញុំឃើញដើមឈើ ដែលមានផ្ការីកស្កុះស្កាយ ចង ជាចង្កោម ដែលធម្មតានិម្មិតល្អហើយ កាន់យកនូវផ្កាក្រហម រោយរាយចុះទៀបពោធិព្រឹក្ស ។ ខ្ញុំបោសដើមប្រទៀង ជាឈើ ដ៏ឧត្តម ជាពោធិព្រឹក្សនោះ ហើយចូលទៅជិតគល់ពោធិព្រឹក្ស អង្គុយផ្គត់ភ្នែន ។ កាលពួកជនស្វែងរកផ្លូវដែលខ្ញុំទៅ ក៏មកកាន់ សម្នាក់ខ្ញុំ លុះខ្ញុំឃើញនូវពួកជនទាំងនោះ ក៏នឹកដល់ពោធិព្រឹក្ស ដ៏ឧត្តម ក្នុងទីនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំដើមពោធិព្រឹក្ស រួចហើយ ក៏ធ្លាក់ទៅក្នុងជ្រោះភ្នំ ដែលគួរខ្លាច មានជម្រៅច្រើន ជួរដើមត្នោត ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជា ពោធិព្រឹក្ស ។ ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេច ចក្កពត្តិ ព្រះនាមសម្មុសិតៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយ កែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦

នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតម្ពបុប្ផិយត្ថេរមានអាយុ បានសម្តែងហើយ នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## តម្ពបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## តម្ពបុប្ផិយត្ថេរាបទាន

[ ៥២ ] *អបទានរបស់ព្រះតម្ពបុប្ផិយត្ថេរ មានពាក្យផ្ដើមថា* **បរកម្មាយនេ យុត្តោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបិយទស្សី ព្រោះអកុសលកម្មណាមួយដែលលោកធ្វើក្នុងកាលមុន ទើបមកកើតក្នុងត្រកូលក្រីក្រ ចម្រើនវ័យហើយ ធ្វើការស៊ីឈ្នួលអ្នកដទៃចិញ្ចឹមជីវិត ។ កុលបុត្តនោះ រស់នៅដោយសេចក្ដីទុក្ខយ៉ាងនេះ ថែមទាំងបានធ្វើនូវកំហុសជាមួយមនុស្សដទៃទៀត ព្រោះការខ្លាចស្លាប់ ទើបរត់ចូលព្រៃ ។ កុលបុត្តនោះ បានឃើញដើមប្រទៀងដែលជាឈើត្រាស់ដឹង ក្នុងទីដែលគេចទៅនោះ ទើបថ្វាយបង្គំ ហើយបោស ឃើញផ្កាក្រហមត្រង់ដើមឈើមួយដើម ទើបជ្រើសរើសផ្កាអំពីផ្កាទាំងអស់ មកធ្វើការបូជាដើមពោធិ៍នោះ ។ កុលបុត្តនោះ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងដើមពោធិ៍នោះ ថ្វាយបង្គំហើយ អង្គុយពត់ភ្នែន ។ ខណៈនោះ ពួកមនុស្សទាំងនោះជាប់តាមស្នាមជើង រហូតដល់ទីនោះ ។ លុះបានឃើញមនុស្សទាំងនោះ កុលបុត្តនោះនឹកដល់ដើមពោធិព្រឹក្ស ហើយរត់ទៅធ្លាក់ក្នុងជ្រោះត្រង់ភ្នំដែលគួរខ្លាច ដល់នូវការស្លាប់ ។*

*ដោយបីតិ និងសោមនស្ស ព្រោះរឭកដល់ការបូជាដើមពោធិ៍នោះឯង ទើបកុលបុត្តនោះទៅកើតក្នុងស្ថានសួគ៌ មានជាន់តាវត្តិង្សជាដើម បានសោយ*

សម្បត្តិក្នុងកាមាវចរ ៦ ជាន់ហើយ មកកើតក្នុងមនុស្ស សោយសម្បត្តិមានចក្កពត្តិសម្បត្តិជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិ ចម្រើនវ័យហើយ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មានចិត្តជ្រះថ្លា ទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត រឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បរកម្មាយនេ យុត្តោ** ដូច្នេះជាដើម ។ គប្បីជ្រាបអត្ថក្នុងបទទាំងនោះថា ការងាររបស់មនុស្សដទៃឈ្មោះថា **បរកម្មាយនេ** ។ ខ្ញុំបានជាអ្នកខ្វល់ខ្វាយ គឺប្រកបក្នុងការធ្វើ គឺធ្វើរឿយៗ នូវការងាររបស់អ្នកដទៃ ។ ពាក្យដ៏សេស ប្រាកដច្បាស់ហើយ ។

**អដ្ឋកថាតម្ពបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វីថិសម្មជ្ជកត្ថេរាបទានទី ៣

[ ៥៣ ] ខ្ញុំបានឃើញព្រះពុទ្ធ ជានាយកនៃលោក កំពុងស្តេចទៅ ដូចព្រះអាទិត្យមានរស្មីដ៏ច្រើន កាលរះឡើងមានរស្មីពណ៌លឿង ឬដូចព្រះចន្ទ ក្នុងថ្ងៃទី ១៥ កើត ។ ពួកព្រះខីណាស្រពទាំងពួង មានប្រមាណ ៦៨០០០ ចោមរោមព្រះសម្ពុទ្ធ ព្រះអង្គជាធំជាង សត្វជើងពីរ ជានរាសភៈ ។ កាលព្រះលោកនាយក កំពុង យាងទៅ ខ្ញុំមានចិត្តជ្រះថ្លា បានបោសថ្នល់នោះ ហើយលើកនូវ ទង់ជ័យក្នុងទីនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុ ដែលខ្ញុំបានថ្វាយទង់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការ ថ្វាយទង់ ។ ក្នុងកប្បទី ៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេច ព្រះ នាមសុធជៈ ទ្រង់មានកម្លាំងច្រើន ទ្រង់បរិបូណ៌ដោយអាការ ទាំងពួង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំ បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា ព្រះវីថិសម្មជ្ជកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វីថិសម្មជ្ជកត្ថេរាបទាន ចប់**

# អដ្ឋកថា

## វីថិសម្មជ្ជកត្ថេរាបទាន

[ ៥៣ ] *អបទានរបស់ព្រះវីថិសម្មជ្ជកត្ថេរ មានពាក្យផ្ដើមថា* **ឧគ្គេន្តំ សតរំសឹវ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយជាច្រើនរយជាតិ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូល នៅគ្រប់គ្រងផ្ទះ បានរួមជាមួយអ្នកនគរ នាំគ្នាបោសផ្លូវ បានឃើញព្រះមានព្រះភាគយាងមក មានចិត្តជ្រះថ្លា ពង្រាបផ្លូវឲ្យស្មើហើយ លើកទង់ឡើងក្នុងទីនោះ ។*

*ដោយបុណ្យនោះឯង កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា មាននូវសទ្ធា មានចិត្តគោរពច្រើន ទើបបព្វជ្ជាឧបសម្បទា មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ កាលរឭកដល់បុព្វកម្មរបស់ខ្លួន ក៏បានជ្រាបដោយជាក់ច្បាស់ កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **ឧគ្គេន្តំ សតរំសឹវ** *ដូច្នេះជាដើម ។*

*ក្នុងបទនោះ មានសេចក្តីថា ព្រះអាទិត្យមានរស្មីមួយរយ កំពុងផុសឡើង គឺកំពុងរះឡើង ពាក្យថា* **សតរំសី** *នេះ ត្រឹមតែជាមាតិកាទេសនា ឯសេចក្តី គឺដូចព្រះអាទិត្យមានពន្លឺច្រើនសែន ។ បទថា* **បីតរំសីវ ភាណុមំ** *សេចក្តីថា បានឃើញព្រះសម្មាសម្ពុទ្ធទ្រង់ល្អដូចព្រះចន្ទ មានរស្មីភ្លឺស្វាង មានរស្មីពណ៌លឿង ចែងចាំងជាក្រុមៗ ។ ពាក្យដ៏សេស មានអត្ថដីងបានងាយហើយ ។៚*

## អដ្ឋកថាវិជិសម្មដ្ឋកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## កក្ការុបូជកត្ថេរាបទានទី ៤

[ ៥៤ ] ខ្ញុំជាទេវបុត្ត បានបូជាចំពោះព្រះពុទ្ធ ជានាយក ព្រះនាមសិខី ខ្ញុំកាន់យកផ្កាល្ពៅ អង្គ្រានថ្វាយព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្កពត្តិ ៧ ជាតិ ទ្រង់មានកម្លាំងច្រើន ទ្រង់ឧត្តមបរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកក្ការុបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កក្ការុបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## កក្ការុប្ជកត្ថេរាបទាន

[ ៥៤ ] អបទានរបស់ព្រះកក្ការុបូជកត្ថេរ មានពាក្យផ្ដើមថា **ទេវបុត្តោ អហំ សន្តោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតជាកុម្មជ្ឈកទេវតា បានឃើញព្រះសម្មាសម្ពុទ្ធព្រះនាមសិខី បានបេះនូវផ្កាត្រឡាចទិព្វ[១] មកបូជា ។

ដោយបុណ្យនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសេចក្ដីសុខក្នុងលោកទាំងពីរ ក្នុងរវាងកប្បទី ៣១ ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាស្ដា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ ជ្រាបបុព្វកម្មរបស់ខ្លួនដោយប្រចក្ស កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ទេវបុត្តោ អហំ សន្តោ** ដូច្នេះជាដើម ។

គប្បីជ្រាបវិគ្គហៈក្នុងបទនោះថា ឈ្មោះថា **ទេវា** ព្រោះលេងដោយកាមគុណ ៥ ដែលជាទិព្វ ។ បុត្តរបស់ទេវៈ ឬបុត្ត គឺទេវៈ ហៅថា **ទេវបុត្ត** សេចក្ដីថា ខ្ញុំជាទេវបុត្តផង គឺកាន់យកផ្កាត្រឡាចទិព្វ ទៅបូជាព្រះមានព្រះភាគព្រះនាមសិខី ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

---

១- បិដកខ្មែរ ជាផ្កាល្ពៅ ។

# សុត្តន្តបិដក

## មន្ទារវបុប្ផបូជកត្ថេរាបទានទី ៩

[ ៥៥ ] ខ្ញុំជាទេវបុត្ត បានបូជាចំពោះព្រះពុទ្ធ ជានាយក ព្រះនាមសិខី ខ្ញុំបានបូជាចំពោះព្រះពុទ្ធ ដោយផ្កាមន្ទារវៈ ។ ផ្កាកម្រងទិព្វ ជាគ្រឿងប្រក់លើព្រះតថាគតអស់ ៧ ថ្ងៃ ពួកជនទាំងអស់មកជួបជុំគ្នាហើយ នមស្ការព្រះតថាគត ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមជុតិន្ធរៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមន្ទារវបុប្ផបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មន្ទារវបុប្ផបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## មន្ទារវបុប្ផបូជកត្ថេរាបទាន

[ ៥៥ ] *អបទានរបស់ព្រះមន្ទារវបុប្ផបូជកត្ថេរ មានពាក្យផ្ដើមថា* **ទេវបុត្តោ អហំ សន្តោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតជាកុម្មដ្ឋកទេវបុត្ត បានជួបព្រះមានព្រះភាគព្រះនាមសិខី មានចិត្តជ្រះថ្លា បានបូជាដោយផ្កាមន្ទារវៈដែលទិព្វ ។*

*ពាក្យទាំងអស់ តាំងអំពីពាក្យថា* **សោ តេន បុញ្ញេន** *ដូច្នេះជាដើមទៅ បណ្ឌិតគប្បីជ្រាបតាមន័យដូចពោលហើយ ក្នុងអដ្ឋកថាអបទានរបស់ព្រះថេរៈបន្ទាប់មកនោះឯង ។*

**អដ្ឋកថាមន្ទារវបុប្ផបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## កទម្ពបុប្ផិយត្ថេរាបទានទី ៦

[ ៥៦ ] ភ្នំឈ្មោះកុក្កុដៈ មានក្នុងទីជិតភ្នំហិមពាន្ត ព្រះពុទ្ធ ៧ ព្រះអង្គនោះ តែងគង់នៅទៀបជើងភ្នំនោះ ខ្ញុំបានឃើញដើមកទម្ពៈ ដែលមានផ្ការីកស្គុះស្គាយ ដូចព្រះអាទិត្យរះឡើង ទើបកាន់យកដោយដៃទាំងពីរ ហើយរោយរាយថ្វាយព្រះពុទ្ធទាំង ៧ អង្គ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៧ ជាតិ ព្រះនាមបុប្ផៈ ដូចគ្នា ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកទម្ពបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កទម្ពបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## កទម្ពបុប្ផិយត្ថេរាបទាន

[ ៥៦ ] អបទានរបស់ព្រះកទម្ពបុប្ផិយត្ថេរ មានពាក្យផ្ដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ កាលលោកកំពុងសូន្យចាកព្រះសម្មាសម្ពុទ្ធ កុលបុត្តនោះកើតក្នុងត្រកូលមួយកន្លែង ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ សម្លឹងឃើញទោសក្នុងការគ្រប់គ្រងផ្ទះនោះ ទើបលះឃរាវាសបួសជាតាបស សាងអាស្រមត្រង់ភ្នំ ឈ្មោះកុក្កុដៈ ក្បែរភ្នំហិមពាន្ត កុលបុត្តនោះ បានឃើញព្រះបច្ចេកពុទ្ធ ៧ អង្គក្នុងទីនោះហើយ មានចិត្តជ្រះថ្លា ទើបជ្រើសរើសយកផ្កាកម្ពដែលរីកហើយ មកបូជាព្រះបច្ចេកពុទ្ធទាំងនោះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ក៏បានធ្វើអនុមោទនាដោយពាក្យថា **ឥច្ឆិតំ បត្ថិតំ** ដូច្នេះជាដើម ដោយបុណ្យនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលក្នុងនគរសាវត្ថី ចម្រើនវ័យហើយ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា មាននូវសទ្ធា បួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។

ពាក្យនោះមានអត្ថដូចពោលហើយខាងដើមនោះឯង ។ បទថា **កុក្កុដោ នាម បព្វតោ** សេចក្តីថា ភ្នំដែលហៅថា **កុក្កុដ** ព្រោះភ្នំនោះមានកំពូលដូចគ្នានឹងសិរមាន់ ត្រង់ទីទាំងសងខាងរបស់ភ្នំនោះ ។

ឈ្មោះថា **បព្វត** ព្រោះតាំងនៅទទឹងដោយជុំវិញ ។ បទថា **តម្ហិ បព្វតបាទម្ហិ** បានដល់ ក្នុងទីជិតភ្នំនោះ ។ បទថា **សត្ត ពុទ្ធា វសន្តិ** សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធទាំង ៧ អង្គនោះ អាស្រ័យនៅក្នុងបណ្ណសាលាក្បែរជើងភ្នំកុក្កុដៈនោះ ។

បទថា **ទីបរាជំវ ឧគ្គតំ** បានដល់ ព្រះរាជានៃទ្វីបទាំងឡាយ ឈ្មោះថា **ទីបរាជា** បានដល់ ព្រះចន្ទ ដែលជាស្តេចនៃពួកផ្កាយ និងវត្ថុមានពន្លឺទាំងអស់ ម្យ៉ាងទៀត ព្រះចន្ទ ហៅថា **ទីបរាជា** ព្រោះផ្សាយពន្លឺជាធំក្នុងទ្វីបទាំង ៤ គឺជម្ពូទ្វីប បុព្វវិទេហទ្វីប អបរគោយានទ្វីប និងឧត្តរកុរុទ្វីប និងទ្វីបតូចៗ ២ ពាន់ អធិប្បាយថា ខ្ញុំបានឃើញដើមកុម្ពដែលមានផ្ការីកស្គុសស្គាយ ដូចគ្នានឹងព្រះចន្ទអណ្តែតក្នុងអាកាស ទើបជ្រើសរើសផ្កាអំពីដើមកុម្ពនោះហើយ យកដៃទាំងពីរផ្គង គឺកាន់មកយ៉ាងនោះ បានបូជា គឺដាក់ចុះយ៉ាងល្អ ដល់ព្រះបច្ចេកសម្ពុទ្ធទាំង ៧ អង្គនោះ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។ល។

**អដ្ឋកថាកុម្ពបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## តិណសូលកត្ថេរាបទានទី ៧

[ ៥៧ ] ភ្នំឈ្មោះភូតគណៈ មានក្នុងទីជិតភ្នំហិមពាន្ត ព្រះជិនស្រី សយម្ភូ ទ្រង់រលាស់ចេញចាកលោក ទ្រង់គង់មួយអង្គឯងក្នុង ទីនោះ ។ ខ្ញុំយកផ្កាម្ទិះរួតទាំងឡាយ បូជាព្រះពុទ្ធ ខ្ញុំមិនដែលទៅ កើតជាវិនិបាតអស់ ៩៩ ពាន់កប្ប ព្រោះកុសលនេះ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាម ធរណីរុហៈ ទ្រង់មានកម្លាំងច្រើន ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំ បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសូលកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិណសូលកត្ថេរាបទាន ចប់**

# អដ្ឋកថា

## តិណសូលកត្ថេរាបទាន

[ ៥៧ ] អបទានរបស់ព្រះតិណសូលកត្ថេរ មានពាក្យផ្ដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំកុសលទាំងឡាយក្នុងភពដែលខ្ពង់ខ្ពស់ កើត ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូល នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងឃរាវាស ទើបលះឃរាវាសនោះ ហើយបួសជាតាបស ឃើញព្រះសម្មាសម្ពុទ្ធព្រះនាមសិខី ព្រះអង្គចម្រើនវិវេក គង់នៅមួយអង្គឯង ត្រង់ភ្នំឈ្មោះភូតគណៈ ក្បែរភ្នំហិមពាន្ត មានចិត្តជ្រះថ្លា កាន់យកផ្កាម្លិះរួតទៅបូជាត្រង់បាទមូល ។ ព្រះពុទ្ធក៏ទ្រង់ធ្វើអនុមោទនាដល់កុលបុត្តនោះ ។

ដោយបុណ្យនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែងដែលសម្បូរដោយសម្បត្តិ ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះសាសនា ទើបចេញបួស ព្រោះជាអ្នកសម្បូរដោយឧបនិស្ស័យ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។ រឭកដល់បុព្វកម្ម កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។

បទថា **ភូតគណោ នាម បព្វតោ** សេចក្ដីថា ភ្នំ ឈ្មោះថា **ភូតគណោ** ព្រោះជាលំនៅរបស់ពួកភូត គឺពួកនៃទេវតា និងយក្ខ ព្រោះដូចគ្នានឹងវិញ្ញាណ

និងព្រោះមិនមានដើមឈើច្រើន ។ ព្រះជិនស្រី គឺព្រះពុទ្ធទ្រង់ឈ្នះមារ មួយអង្គឯង គឺមិនមានបុគ្គលជាប់តាម ទ្រង់គង់ត្រង់ភ្នំនោះ គឺគង់នៅដោយទិព្វវិហារ ព្រហ្មវិហារ អរិយវិហារ និងឥរិយាបថវិហារ ។

បទថា **ឯកូនសតសហស្សំ កប្បំ ន វិនិបាតិកោ** សេចក្តីថា ដោយផលដែលធ្វើការបូជាព្រះពុទ្ធ ដោយផ្កាម្លិះរួតនោះ ទើបខ្ញុំមិនធ្លាក់ទៅក្នុងអបាយ គឺផុតចាកអបាយទាំង ៤ ចូលដល់កព គឺសគ្គសម្បត្តិតែម្យ៉ាង អស់ ៩៩៩៩៩ កប្ប[១] មិនមានវៀរ ។ ពាក្យដ៏សេស មានអត្ថដ៏ងបានងាយហើយ ៕

## អដ្ឋកថាតិណសូលកត្ថេរាបទាន ចប់

១- ពុទ្ធដីកាជា ៩៩ ពាន់កប្ប បាលីថា ឯកូនសតសហស្ស តែបើគិតតាមវេយ្យាករណ៍បាលី ចង់បទសមាសមិនត្រឹមត្រូវតាមបទវេយ្យាករណ៍ ឯច្បាប់ថា ៩៩៩៩៩ នេះត្រូវជាង សូមលោកអ្នកចេះបាលីពិចារណាផងចុះ ។

# សុត្តន្តបិដក

## នាគបុប្ផិយត្ថេរាបទានទី ៨

[ ៥៨ ] ព្រាហ្មណ៍ឈ្មោះសុវច្ឆៈ ជាអ្នកដល់នូវត្រើយនៃមន្ត មានពួកសិស្សចោមរោម តែងនៅក្នុងចន្លោះភ្នំ ។ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលនូវគ្រឿងបូជា ព្រះអង្គមានប្រាថ្នា ដើម្បីស្រោចស្រង់នូវខ្ញុំ ទើបស្តេចមកកាន់សម្នាក់ខ្ញុំ ។ ទ្រង់ចង្ក្រមលើអាកាស ដូចប្រទីបរុងរឿង ទ្រង់ជ្រាបច្បាស់នូវសេចក្តីត្រេកអររបស់ខ្ញុំ ហើយមានព្រះភក្ត្របែរទៅទិសខាងកើត ស្តេចចៀសចេញទៅ ។ ចំណែកខាងខ្ញុំ ឃើញហេតុអស្ចារ្យចម្លែកគួរជាទីព្រឺរោមនោះហើយ ក៏កាន់យកនូវផ្កាខ្ទឹង រោយរាយលើផ្លូវដែលព្រះអង្គស្តេចទៅ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានរោយរាយផ្កា ដោយចិត្តជ្រះថ្លានោះ ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមមហារថៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**នាគបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## នាគបុប្ផិយត្ថេរាបទាន

[ ៥៨ ] *អបទានរបស់ព្រះនាគបុប្ផិយត្ថេរ មានពាក្យផ្ដើមថា* **សុវណ្ណោ នាម នាមេន** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ សម្រេចការសិក្សាក្នុងសិប្បៈប្រចាំត្រកូល មានត្រៃវេទជាដើម មិនឃើញសារៈក្នុងសិប្បៈនោះ ទើបចូលទៅកាន់ព្រៃហិមពាន្ត បួសជាតាបស ឲ្យកាលវេលាកន្លងទៅដោយសេចក្ដីសុខក្នុងឈាន និងសមាបត្តិ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ បានយាងទៅកាន់ទីនោះ ដើម្បីអនុគ្រោះដល់កុលបុត្តនោះ ។ តាបសនោះឃើញព្រះមានព្រះភាគអង្គនោះហើយ ព្រោះភាពដែលខ្លួនជំនាញក្នុងតម្រាលក្ខណសាស្ត្រ ទើបមានសេចក្ដីជ្រះថ្លា ក្នុងការដល់ព្រមនៃព្រះរូបសម្បត្តិរបស់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ បានឈរផ្គងអញ្ជលី ព្រោះព្រះមានព្រះភាគមិនបានចុះអំពីអាកាស ទើបតាបសមិនបានធ្វើសក្ការៈ និងបូជា ទ្រង់យាងចៀសចេញទៅតាមអាកាសនោះឯង ។ លំដាប់នោះ តាបសនោះ មួយអន្លើដោយសិស្ស ក៏បេះផ្កាខ្ទឹង ហើយយកផ្កានោះបូជាផ្លូវ ក្នុងទិសដែលព្រះមានព្រះភាគយាងទៅ ។*

ដោយបុណ្យនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិក្នុងលោកទាំងពីរ បានទទួលការបូជា ក្នុងទីទាំងពួង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ជាអ្នកដល់ព្រមដោយសទ្ធា បួសហើយ ធ្វើព្រះសាសនាឲ្យដុះដាលដោយវត្តបដិបត្តិ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ កាលរឭកដល់កម្មក្នុងអតីតថា ដោយកុសលកម្មអ្វីហ្ន៎ ទើបអញបានទទួលលោកុត្តរសម្បត្តិនេះ ។ ក៏ជ្រាបបានជាក់ច្បាស់ដល់បុព្វកម្មនោះ ទើបកើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **សុវច្ឆោ នាម នាមេន** ដូច្នេះជាដើម ។

គប្បីជ្រាបវិគ្គហៈក្នុងបទនោះថា ឈ្មោះថា **វច្ឆោ** ព្រោះកើតក្នុងវច្ឆគោត្រ **វច្ឆ** នោះផង ល្អផង រួមជា **សុវច្ឆ** អធិប្បាយថា ព្រាហ្មណ៍ឈ្មោះថា **សុវច្ឆ** ដល់នូវត្រើយនៃមន្ត្រ គឺដល់នូវទីបំផុតក្នុងមន្តសាស្ត្រទាំងមូល មានត្រៃវេទជាដើម ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ព្រោះបានពោលអធិប្បាយខាងដើមហើយ ៕

## អដ្ឋកថានាគបុប្ផិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## បុន្នាគបុប្ផិយត្ថេរាបទានទី ៩

[ ៥៩ ] ខ្ញុំជានាយព្រាន បានចូលទៅនៅអាស្រ័យក្នុងព្រៃធំ បានឃើញដើមបុន្នាគព្រឹក្ស ដែលមានផ្ការីកស្គុះស្គាយ ហើយនឹករឭកចំពោះព្រះពុទ្ធ ជាបុគ្គលដ៏ប្រសើរ ។ ខ្ញុំបេះផ្កានោះ ដែលមានក្លិនក្រអូបយ៉ាងក្រៃលែង ហើយធ្វើជាព្រះស្តូបលើផ្នូកខ្សាច់ បូជាចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គព្រះនាមតមោនុទៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុន្នាគបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បុន្នាគបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## បុន្នាគបុប្ផិយត្ថេរាបទាន

[ ៥៩ ] *អបទានរបស់ព្រះបុន្នាគបុប្ផិយត្ថេរ មានពាក្យផ្ដើមថា* **កាននំ វនមោគ្គយ្ហ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមផុស្សៈ កើតក្នុងត្រកូលព្រានព្រៃ ចូលទៅកាន់ព្រៃធំ ឃើញផ្កាបុន្នាគដែលរីកស្គុះស្គាយក្នុងព្រៃនោះ ព្រោះហេតុដែលខ្លួនសម្បូរដោយហេតុ ទើបបង្អោនរឭកដល់ព្រះមានព្រះភាគ ដោយអំណាចបីតិមានព្រះពុទ្ធជាអារម្មណ៍ ទើបបេះផ្កានោះ មួយអន្លើដោយផ្កាដទៃៗ មកពូនចេតិយខ្សាច់បូជា ។*

*ដោយបុណ្យនោះ អស់កប្ប ៩២ មិនមានចន្លោះ កុលបុត្តនោះបានសោយសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិ ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ដោយកម្លាំងនៃបុណ្យដែលអប់រំមកក្នុងកាលមុន ទើបជ្រះថ្លាក្នុងព្រះសាសនា ចេញបួសហើយ ព្យាយាមមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ រឭកដល់កុសលកម្មដែលខ្លួនធ្វើក្នុងកាលមុន កើតសោមនស្ស កាលប្រកាសអបទាន ទើបពោលពាក្យថា* **កាននំ វនមោគ្គយ្ហ** *ដូច្នេះជាដើម ។ ពាក្យទាំងអស់មានអត្ថងាយយល់ហើយ ព្រោះបានពោលហើយខាងដើមនោះឯង ។៚*

**អដ្ឋកថាបុន្នាគបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## កុមុទទាយកត្ថេរាបទានទី ១០

[ ៦០ ] មានស្រះកើតឯងដ៏ធំ ក្នុងទីជិតភ្នំហិមពាន្ត ជាស្រះដេរដាសដោយឈូក និងឧប្បល ព្រោងព្រាតដោយផ្កាឈូកស ។ ក្នុងកាលនោះ ខ្ញុំកើតជាមាន់ ជាសកុណជាតិ នៅជិតស្រះនោះ ជាសត្វមានសីល បរិបូណ៌ដោយវត្ត ឈ្លាសវៃក្នុងអំពើបុណ្យ និងបាប ។ ព្រះពុទ្ធជាមហាមុនី ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលនូវគ្រឿងបូជា ត្រាច់ទៅក្នុងទីមិនឆ្ងាយអំពីជាតិស្រះនោះ ។ ខ្ញុំបានកាច់ផ្កាកុមុទ ដែលកើតក្នុងទឹក បង្អោនចូលមកថ្វាយព្រះមហេសី ។ ព្រះពុទ្ធជាមហាមុនី ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ទ្រង់ក៏ទទួលយក ។ ខ្ញុំត្រូវកុសលមូលដាស់តឿន ព្រោះបានឲ្យទាននោះ ខ្ញុំក៏មិនទៅកើតក្នុងទុគ្គតិ អស់ ១ សែនកប្ប ។ ក្នុងកប្បទី ១១៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៨ ជាតិ ព្រះនាមវរុណៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុមុទទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កុមុទទាយកត្ថេរាបទាន ចប់

## ឧទ្ទាន

ពន្ធុជីវកត្ថេរាបទាន ១ តម្ពបុប្ផិយត្ថេរាបទាន ១ វីថិសម្មជ្ជកត្ថេរាបទាន ១ កក្ការុបូជកត្ថេរាបទាន ១ មន្ទារវបុប្ផបូជកត្ថេរាបទាន ១ កទម្ពបុប្ផិយត្ថេរាបទាន ១ តិណសូលកត្ថេរាបទាន ១ នាគបុប្ផិយត្ថេរាបទាន ១ បុន្នាគបុប្ផិយត្ថេរាបទាន ១ កុមុទទាយកត្ថេរាបទាន ១ គាថា ( ទាំងនេះ ) មាន ៥៦ ដែលលោកសម្តែងទុកហើយ ។

ពន្ធុជីវកវគ្គទី ១៦ ចប់

# អដ្ឋកថា

## កុមុទទាយកត្ថេរាបទាន

[ ៦០ ] អបទានរបស់ព្រះកុមុទទាយកត្ថេរ មានពាក្យផ្ដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតជាមាន់ព្រៃនៅជិតស្រះធំក្បែរជើងភ្នំហិមពាន្ត ទោះកើតជាបក្សី ព្រោះអកុសលកម្មឯណានីមួយ តែព្រោះមានកុសលកម្ម ដែលខ្លួនធ្វើក្នុងកាលមុន ទើបជាបក្សីមានបញ្ញា ឈ្លាសក្នុងបុណ្យ និងបាប មានសីល វៀរចាកអាហារដែលទាក់ទងដោយជីវិតសត្វ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ យាងមកតាមអាកាស ចង្ក្រមក្បែរបក្សីនោះ ។ លំដាប់នោះ បក្សីនោះបានឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ទើបពាំយកផ្កាកុមុទមកបូជាត្រង់បាទមូលរបស់ព្រះមានព្រះភាគ ។ ដើម្បីឲ្យបក្សីកើតសេចក្ដីត្រេកអរ ព្រះមានព្រះភាគក៏ទទួលផ្កាកុមុទនោះ ហើយទ្រង់ធ្វើអនុមោទនា ។

ដោយបុណ្យនោះ បក្សីនោះសោយសុខ គឺសោយសម្បត្តិក្នុងលោកទាំងពីរ គឺក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ជាអ្នកមានទ្រព្យច្រើន មានភោគសម្បត្តិច្រើន ជ្រះថ្លាក្នុងព្រះរតនត្រ័យ បានស្ដាប់នូវព្រះធម្មទេសនា

*របស់ព្រះសាស្ដាហើយ មានទូវសទ្ធា ទើបចេញបួស មិនយូរប៉ុន្មាន ក៏បាន ជាព្រះអរហន្ត ជ្រាបដល់បុព្វកម្មរបស់ខ្លួនបានដោយប្រចក្ស កើតសោមនស្ស កាលប្រកាសអបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **ហិមវន្តស្សាវិទូរេ** *ដូច្នេះជាដើម ។*

*ក្នុងបទថា* **បទុមុប្បលសញ្ឆន្នោ** *នេះ ក្លាប់សេចក្ដីថា ផ្កាបទុម ពណ៌ស មានត្របកផ្កា ១០០ និងផ្កាឧប្បល ៣ ប្រភេទ គឺឧប្បលពណ៌ ខៀវ ពណ៌ក្រហម និងពណ៌ស រួមហៅថា* **បទុមុប្បល** *។ ស្រះធំនោះ ដេរដាស គឺជាព្រៃពេញដោយផ្កាឈូក និងផ្កាឧប្បលទាំងនោះ ។ បទថា* **បុណ្ឌរីកសមោត្ថដោ** *សេចក្ដីថា ដេរដាសដោយផ្កាឈូកស និងឈូក ក្រហម ។ ពាក្យដ៏សេស មានអត្ថដ៏ងបានងាយហើយ ។*

**អដ្ឋកថាកុមុទនាយកត្ថេរាបទាន ចប់**

**ពន្ធុជីវកវគ្គទី ១៦ ចប់**

# សុត្តន្តបិដក
# សុចារិចរិយវគ្គទី ១៧

## សុចារិចរិយត្ថេរាបទានទី ១

[ ៦១ ] ព្រះពុទ្ធព្រះនាមបទុមៈ ព្រះអង្គជាធំជាងសត្វជើងពីរ ជានរាសភៈ ទ្រង់មានបញ្ញាចក្ខុ ទ្រង់ចេញចាកព្រៃ គឺតណ្ហា តែងសម្តែងនូវធម៌ ។ ពួកយក្សបានប្រជុំគ្នាក្នុងទីជិត ព្រះពុទ្ធ-មហេសី ដោយកិច្ចដែលពួកយក្សទាំងនោះ មកជួបជុំគ្នា ហើយប្រាថ្នាមើល ( នូវព្រះសម្ពុទ្ធ ) ក្នុងខណៈនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ ដឹងច្បាស់នូវវាចារបស់ព្រះពុទ្ធ ជាគ្រឿងសម្តែងនូវព្រះនិព្វាន ឈ្មោះអមតៈ ទះដៃហើយ ចូរទៅបម្រើ ។ ខ្ញុំជួបនូវផលនៃការបម្រើ ដែលខ្ញុំសន្សំល្អហើយចំពោះព្រះសាស្តា ក្នុងកប្បទីបីម៉ឺន ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិឡើយ ។ ក្នុងកប្បទី ១២៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមសមលង្កតៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦

នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុបារិចរិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## សុបារិចរិយត្ថេរាបទាន ចប់

# អដ្ឋកថា

# សុចារិចរិយវគ្គទី ១៧

## សុចារិចរិយត្ថេរាបទាន

[ ៦១ ] *អបទានរបស់ព្រះសុបារិចរិយត្ថេរ មានពាក្យផ្តើមថា* **បទុមោ ឆាម ឆាមេឆ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះមុនីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងកំណើតយក្ខ ទៅកាន់សមាគមយក្ខ ក្នុងព្រៃហិមពាន្ត បានស្តាប់នូវព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ដែលទ្រង់សម្តែងដល់ពួកទេវតា យក្ខ គន្ធព្វ និងនាគហើយ មានចិត្តជ្រះថ្លា ផ្គងដើមដៃទាំងពីរប្រណម្យនមស្ការ ដោយបុណ្យនោះ កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោកខ្ពស់ឡើង សោយទិព្វសុខក្នុងទេវលោកនោះ កើតក្នុងមនុស្សលោក សោយសម្បត្តិមានចក្កពត្តិសម្បត្តិជាដើមក្នុងពួកមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលគហបតី ក្នុងព្រះនគរសាវត្ថី ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគសម្បត្តិច្រើន ជ្រះថ្លាក្នុងព្រះរតនត្រ័យ បានស្តាប់នូវព្រះធម្មទេសនារបស់ព្រះសាស្តាហើយ កើតនូវសទ្ធាបួសហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។*

ថ្ងៃមួយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមោ នាម នាមេន** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **បទុមោ** គប្បីជ្រាបសេចក្ដីដូច្នេះ ព្រះមានព្រះភាគអង្គណា កាលលើកព្រះបាទឡើង មានផ្កាឈូកជ្រែកផែនដីផុសឡើង ទទួលព្រះបាទព្រះមានព្រះភាគអង្គនោះ បានទទួលការថ្វាយព្រះនាមថា **បទុម** ដោយគ្រឿងសម្គាល់នោះ ។ ក្នុងអបទាននេះ លោកសំដៅដល់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ភ្ជាប់សេចក្ដីថា ព្រះមានព្រះភាគអង្គនោះ យាងចេញចាកព្រះវិហារជាទីគន់ យាងចូលទៅកាន់ព្រៃ ទ្រង់សម្ដែងធម៌ ។

បទថា **យក្ខានំ សមយោ** សេចក្ដីថា មានសមាគមនៃទេវតាទាំងឡាយ ។ បទថា **អជ្ឈាបេក្ខឹសុ តាវទេ** សេចក្ដីថា បានឃើញច្បាស់ក្នុងកាលសម្ដែងធម៌នោះ គឺមានប្រក្រតីឃើញច្បាស់ដោយពិសេស ។ ពាក្យដ៏សេស មានអត្ថប្រាកដច្បាស់ហើយនោះឯង ។៚

**អដ្ឋកថាសុចារិចរិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## កណវេរបុប្ផិយត្ថេរាបទានទី ២

[ ៦២ ] ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជាចម្បងក្នុងលោក ជានរាសភៈ មានពួកសាវ័កចោមរោមហើយ ទ្រង់ស្តេចមកកាន់ក្រុង ។ ខ្ញុំជាអ្នកគ្រប់គ្រងក្នុងខាងក្នុងបុរី របស់ស្តេចដែលស្តេចតែងតាំង ខ្ញុំចូលទៅក្នុងប្រាសាទ បានឃើញព្រះពុទ្ធ ជាលោកនាយក ។ ខ្ញុំយកផ្កាច្បារោយរាយចំពោះភិក្ខុសង្ឃ រោយរាយចំពោះព្រះពុទ្ធ ធ្វើឲ្យផ្សេងច្រើនក្រៃលែងជាងនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ឈ្មោះមហិទ្ធិកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកណវេរបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កណវេរបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## កណវេរបុប្ផិយត្ថេរាបទាន

[ ៦២ ] អបទានរបស់ព្រះកណវេរបុប្ផិយត្ថេរ មានពាក្យផ្ដើមថា **សិទ្ធត្ថោ នាម ភគវា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលសូទ្រៈ ចម្រើនវ័យហើយ បានជាភ្នាក់ងាររក្សាសន្តិសុខ ក្នុងព្រះរាជវាំង ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ មានពួកភិក្ខុសង្ឃចោមរោម ទ្រង់ព្រះរាជដំណើរទៅតាមផ្លូវធំ ។ លំដាប់នោះ អ្នករក្សាសន្តិសុខក្នុងព្រះរាជវាំងនោះ ឃើញព្រះមានព្រះភាគយាង កំពុងយាងទៅ មានចិត្តជ្រះថ្លា ទើបបូជាព្រះមានព្រះភាគដោយផ្កាច្បា ហើយឈរនមស្ការ ។

ដោយបុណ្យនោះ កុលបុត្តនោះ សោយសុគតិសម្បត្តិតែម្យ៉ាង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ចម្រើនវ័យហើយ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា មានទូវសទ្ធា ទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

លោកសម្រេចអរហត្តហើយ រឭកដល់កុសលកម្មដែលធ្វើក្នុងកាលមុន កើតនូវសោមនស្ស ទើបពោលពាក្យថា **សិទ្ធត្ថោ នាម ភគវា** ដូច្នេះជាដើម ។ ពាក្យទាំងនោះ មានអត្ថងាយយល់ហើយ ព្រោះបានពោលហើយខាងដើមនោះឯង ។l៚

# សុត្តន្តបិដក

## ខជ្ជទាយកត្ថេរាបទានទី ៣

[ ៦៣ ] ក្នុងកាលពីដើម ខ្ញុំបានថ្វាយផ្លែឈើ បានថ្វាយផ្លែដូង ដែលគេសន្មតថាជាបង្អែម ចំពោះព្រះមានព្រះភាគ ព្រះនាមតិស្សៈ ។ លុះថ្វាយផ្លែឈើនោះ ចំពោះព្រះពុទ្ធ ព្រះនាមតិស្សៈ ជាមហេសីហើយ ក៏រីករាយ ខ្ញុំមានសេចក្តីប្រាថ្នាក្នុងកាម ក៏បានទៅកើតតាមសេចក្តីប្រាថ្នា ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងគ្រានោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវផ្លែឈើ ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមឥន្ទសមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះខជ្ជទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ខជ្ជទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ខជ្ជកទាយកត្ថេរាបទាន

[ ៦៣ ] អបទានរបស់ព្រះខជ្ជទាយកត្ថេរ មានពាក្យផ្តើមថា **តិស្សស្ស ខោ ភគវតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងត្រកូលសូទ្រៈ ឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា បានថ្វាយផ្លែឈើតូចធំជាច្រើន ដែលមានរសឆ្ងាញ់ ដូចជា ស្វាយ ព្រីង និងនំដែលគួរទំពាជាដើម ។ ដើម្បីសេចក្តីជ្រះថ្លាដល់កុលបុត្តនោះ ព្រះមានព្រះភាគបានសោយ ក្នុងខណៈដែលកុលបុត្តនោះសម្លឹងមើលនោះឯង ដោយបុណ្យនោះ កុលបុត្តនោះ សោយសុគតិសម្បត្តិតែម្យ៉ាង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរសាវត្ថី ដល់នូវភាពជាអ្នកដឹងក្តីហើយ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ កើតនូវសទ្ធា មានការជ្រះថ្លា និងរាប់អានច្រើន ទើបចេញបួស ធ្វើសាសនាឲ្យល្អដោយវត្តបដិបត្តិ ស្អាតដោយអលង្ការ គឺសីល មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនថា អញបានធ្វើកុសលដ៏ល្អ ក្នុងខេត្តដែលល្អ ក្នុងកាលមុនជាការល្អពិត កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **តិស្សស្ស ខោ ភគវតោ** ដូច្នេះជាដើម ។

គប្បីជ្រាបអត្ថក្នុងបទនោះ ទ្រង់ព្រះនាមថា **តិស្ស** តាមដែលព្រះជនក និងព្រះជននីដាក់ឲ្យ ព្រោះកាលព្រះសូត ធ្វើឲ្យកើតសម្បត្តិក្នុងភពទាំង ៣ យ៉ាង ន័យម្យ៉ាងទៀត ទ្រង់ព្រះនាមថា **តិស្ស** ព្រោះទ្រង់ជាព្រះពុទ្ធហើយ ទ្រង់ញ៉ាំងមហាជនឲ្យត្រេកអរដោយត្រៃសរណគមន៍ ទ្រង់ទូន្មានប្រៀនប្រដៅ ឲ្យពួកគណៈដែលដល់ព្រមដោយហេតុ ឲ្យតាំងនៅក្នុងសម្បត្តិពីរ គឺសគ្គ-សម្បត្តិ និងនិព្វានសម្បត្តិ ឈ្មោះថា **ភគវា** ព្រោះទ្រង់ប្រកបដោយភគធម៌ ទាំងឡាយ មានសមាបត្តិគុណជាដើម អធិប្បាយថា ក្នុងកាលមុន ខ្ញុំបាន ថ្វាយផ្លែដូង និងផ្លែឈើដទៃនោះ ដល់ព្រះមានព្រះភាគព្រះនាមតិស្សៈអគ្គ នោះហើយ ។ បទថា **នាឡិកេរញ្ច បាទាសឹ** សេចក្តីថា ខ្ញុំបានថ្វាយផ្លែដូង ដែលជាផ្លែឈើមិនដូចផ្លែនាឡិកេ និងផ្លែឈើនោះ ។ បទថា **ខជ្ជកំ អភិ-សម្មតំ** សេចក្តីថា ខ្ញុំបានថ្វាយរបស់ដែលគួរទំពា ដែលសន្មត គឺបញ្ញត្តិ យ៉ាងល្អជាពិសេសថា ជារបស់គួរទំពាដែលល្អ ដែលឆ្ងាញ់ ជារបស់ដែល ផ្សំជាមួយទឹកឃ្មុំ និងស្ករក្រោមជាដើមយ៉ាងពិសេស ។ ពាក្យដ៏សេស មាន អត្ថដឹងបានងាយហើយ ។

**អដ្ឋកថាខជ្ជកទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ទេសបូជកត្ថេរាបទានទី ៤

[ ៦៤ ] ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាចម្បងក្នុងលោក ជានរាសភៈ ហោះទៅកាន់អាកាស ស្តេចទៅក្នុងផ្លូវអាកាស ។ ព្រះសាស្តា ជាមហាមុនី ស្ថិតនៅក្នុងប្រទេសណា ហើយទ្រង់ហោះទៅ ខ្ញុំប្រណម្យ (ក្រាបថ្វាយ) បានបូជាចំពោះប្រទេសនោះ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ១១៨ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឃើញព្រះមហាមុនី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាចំពោះប្រទេស ។ ក្នុងកប្បទី ១១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមគោសុជាត ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទេសបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ទេសបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## ទេសបូជកត្ថេរាបទាន

[ ៦៤ ] អបទានរបស់ព្រះទេសបូជកត្ថេរ មានពាក្យផ្ដើមថា **អត្ថទស្សី តុ ភគវា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ មានសទ្ធាជ្រះថ្លា បានជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី មានពួកភិក្ខុសង្ឃចោមរោមយាងទៅតាមអាកាស ដូចព្រះចន្ទ និងព្រះអាទិត្យ គោរចទៅក្នុងអាកាស ។ ឧបាសកនោះ បានយកគ្រឿងក្រអូប និងកម្រងផ្កាជាដើម មកបូជាត្រង់ទិសដែលព្រះមានព្រះភាគយាងទៅ ហើយឈរផ្គងអញ្ជលីនមស្ការ ។

ដោយបុណ្យនោះ កុលបុត្តនោះ បានទៅកើតក្នុងទេវលោក សោយនូវសគ្គសម្បត្តិ ហើយមកកើតក្នុងមនុស្សលោក សោយមនុស្សសម្បត្តិ ក្នុងពុទ្ធុប្បាទកាលនេះ មកកើតក្នុងត្រកូលមួយកន្លែង ចម្រើនវ័យហើយ ជាអ្នកសម្បូរដោយគ្រឿងឧបភោគ និងគ្រឿងបរិភោគ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានចិត្តជ្រះថ្លា មិនដាក់ចិត្តក្នុងឃរាវាស ទើបចេញបួស ជាអ្នកសម្បូរដោយវត្ត មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមក

ក្នុងកាលមុន ទើបពោលពាក្យថា **អត្ថនស្សី តុ ភគវា** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថតាមដែលពោលហើយខាងដើមនោះឯង ។

បទថា **អនិលញ្ជសេ** គប្បីជ្រាបវិគ្គហៈដូច្នេះ ព្រោះលោកពោលថា **មគ្គោ បន្ថោ បថោ បជ្ជោ អញ្ជសំ វដុមាយនំ** ជាពាក្យមានន័យដូចគ្នា ( ពាក្យទាំងអស់នេះ ប្រែថា ផ្លូវ ) ហេតុនោះ ផ្លូវ គឺទិសដែលជាទីទៅរបស់ខ្យល់ ទើបជា **អនិលញ្ជស** ( អាកាស ) សេចក្តីថា ក្នុងអាកាសនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាទេសបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## កណិការច្ឆទនិយត្ថេរាបទានទី ៥

[ ៦៥ ] ព្រះសម្ពុទ្ធ ព្រះនាមវេស្សភូ ជាចម្បងក្នុងលោក ជានរាសភៈ ជាអ្នកប្រាជ្ញ ទ្រង់ស្តេចចូលទៅកាន់មហាវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ក្នុងកាលនោះ ខ្ញុំកាច់ផ្កាកណិការធ្វើជាឆត្រ លុះខ្ញុំធ្វើឲ្យជាដំបូលដោយផ្ការួចហើយ ទើបបូជាចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្ប ទី ២០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៨ ជាតិ ព្រះនាមសោណ្ណាភៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកណិការច្ឆទនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កណិការច្ឆទនិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## កណិការច្ឆទនិយត្ថេរាបទាន

[ ៦៥ ] អបទានរបស់ព្រះកណិការច្ឆទនិយត្ថេរ មានពាក្យផ្ដើមថា **វេស្សភូ នាម សម្ពុទ្ធោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវេស្សភូ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជាអ្នកសម្បូរដោយសទ្ធា ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមវេស្សភូ ទ្រង់មានបំណងនឹងចម្រើននូវវិវេក ទើបយាងចូលទៅកាន់ព្រៃធំ ប្រថាប់គង់ ។ លំដាប់នោះ ឧបាសកនោះ ក៏ទៅកាន់ព្រៃធំនោះដោយការងារណាមួយ បានឃើញព្រះមានព្រះភាគ ប្រថាប់គង់ រុងរឿងដូចគំនរភ្លើង មានចិត្តជ្រះថ្លា បេះនូវផ្កាកណិការមកធ្វើជាឆត្រ ហើយបាំងជាពិតានបូជាខាងលើព្រះអង្គ ដែលព្រះមានព្រះភាគទ្រង់គង់ ដោយអានុភាពនៃព្រះមានព្រះភាគ ពិតានផ្កានោះតាំងនៅដដែលមិនស្វិតស្រពោនអស់កាល ៧ ថ្ងៃ ចំណែកព្រះមានព្រះភាគក៏ចូលផលសមាបត្តិ និងនិរោធសមាបត្តិ ។ កុលបុត្តនោះ ឃើញនូវភាពអស្ចារ្យនោះហើយ កើតសោមនស្ស ទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរផ្គងអញ្ជលី ។ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាបត្តិហើយ យាងទៅកាន់វិហារវិញនោះឯង ។

ដោយបុណ្យនោះ កុលបុត្តនោះ បានសោយសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរ

សាវត្ថី ចម្រើនវ័យហើយ ជាអ្នកសម្បូរដោយសទ្ធា បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មិនដាក់ចិត្តក្នុងការគ្រប់គ្រងផ្ទះ ទើបចេញបួស ធ្វើសាសនារបស់ព្រះជិនស្រីឲ្យល្អដោយវត្តបដិបត្តិ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត រឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វេស្សភូ នាម សម្ពុទ្ធោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **វេស្សភូ** មានវិគ្គហៈថា ឈ្មោះថា **វេស្សភូ** ព្រោះសង្កត់ គឺគ្របសង្កត់នូវពួកវេស្សៈបានដល់ បុគ្គលដែលជាឈ្មួញ មួយ៉ាងទៀត ឈ្មោះថា **វេស្សភូ** ព្រោះទ្រង់គ្របសង្កត់ពួកវេស្សៈ គឺមារទាំង ៥ បាន ។ ឈ្មោះថា **សម្ពុទ្ធ** ព្រោះទ្រង់ត្រាស់ដឹងនូវសច្ចៈទាំងឡាយដោយព្រះអង្គឯង បានដល់ ព្រះសម្ពុទ្ធដែលមានព្រះនាមថា វេស្សភូ ។ បទថា **ទិវាវិហារាយ មុនិ** មានវិគ្គហៈថា ឈ្មោះថា **ទិវា** ព្រោះរុងរឿងភ្លឺស្វាង គឺធ្វើវត្ថុនោះៗ ឲ្យឃើញច្បាស់ បានដល់ ពេលវេលាដែលកំណត់ តាំងអំពីព្រះអាទិត្យរះឡើង ដល់ព្រះអាទិត្យលិច ។ ការនៅ គឺកាលផ្លាស់ប្តូរដោយឥរិយាបថ ៤ ឈ្មោះថា **វិហារ** ការនៅក្នុងពេលថ្ងៃ ឈ្មោះថា **ទិវាវិហារ** អធិប្បាយថា ព្រះពុទ្ធមុនី ទ្រង់អង់អាចជាងនរៈ ប្រសើរបំផុតក្នុងលោក ចូលទៅកាន់ព្រៃធំដើម្បីសម្រាកក្នុងពេលថ្ងៃ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាកណវិការបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សប្បិទាយកត្ថេរាបទានទី ៦

[ ៦៦ ] ព្រះមានព្រះភាគ ព្រះនាមផុស្សៈ ទ្រង់គួរទទួលនូវគ្រឿងបូជា ព្រះអង្គជាវីរបុរស ស្តេចទៅតាមផ្លូវ ញុំាងមហាជនឲ្យរលត់ទុក្ខ ។ ព្រះមានព្រះភាគ ក៏ស្តេចមកកាន់សម្នាក់របស់ខ្ញុំតាមលំដាប់ ក្នុងកាលនោះ ខ្ញុំទទួលយកបាត្រ ហើយបានថ្វាយទឹកដោះថ្លា និងប្រេង ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទឹកដោះថ្លា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទឹកដោះថ្លា ។ ក្នុងកប្បទី ៥៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមសមោទកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសប្បិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សប្បិទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## សប្បិទាយកត្ថេរាបទាន

[ ៦៦ ] អបទានរបស់ព្រះសប្បិទាយកត្ថេរ មានពាក្យផ្ដើមថា **ផុស្សោ នាមាថ ភគវា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមផុស្សៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ។ ក្នុងកាលនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម យាងទៅតាមផ្លូវដល់ទ្វារផ្ទះរបស់ឧបាសកនោះ ។ លុះឧបាសកនោះ ឃើញព្រះមានព្រះភាគ មានចិត្តជ្រះថ្លា ថ្វាយបង្គំហើយ បានថ្វាយនូវសប្បិ និងប្រេងរបូតពេញបាត្រ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនាហើយ ចៀសចេញទៅ ។ កុលបុត្តនោះ តម្កល់ជីវិតនៅដោយសោមនស្សនោះឯង ដរាបដល់អាយុក្ខ័យ ហើយចុតិចាកអត្តភាពនោះ ។ ដោយបុណ្យនោះ ទើបបានទៅកើតក្នុងទេវលោក បានសោយទិព្វសុខ ហើយបានកើតក្នុងពួកមនុស្ស គ្រប់ភពដែលកុលបុត្តនោះកើត សោយតែសេចក្ដីសុខ ដល់ព្រមដោយអាហារដែលមានរសឆ្ងាញ់ ដូចជា សប្បិ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ មានសទ្ធា ដល់ព្រមដោយបញ្ញា ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានចិត្តជ្រះថ្លា ទើបចេញបួស ជាអ្នកបរិបូណ៌ដោយវត្តបដិបត្តិ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ផុស្សោ ឆាមាថ ភគវា** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ផុស្សោ** ជាព្រះនាមដែលព្រះមាតា និងព្រះបិតាដាក់ឲ្យ ព្រោះព្រះអង្គប្រសូតក្នុងឫក្សផុស្សៈ ។ម្យ៉ាងទៀត ឈ្មោះថា **ផុស្ស** ព្រោះព្រះអង្គពាល់ត្រូវ ឃើញច្បាស់ គឺបានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ម្យ៉ាងទៀត ឈ្មោះថា **ផុស្ស** ព្រោះព្រះអង្គពាល់ត្រូវ ឃើញច្បាស់ គឺបានជ្រាបហើយនូវព្រះបារមី ៣០ ពោធិបក្ខិយធម៌ ៣៧ និងព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកទាំងមូល ។ ឈ្មោះថា **ភគវា** ព្រោះទ្រង់ដល់ព្រមដោយចំណែកនៃបុណ្យ ដូចជា ជាអ្នកមានជោគ ជាអ្នកមានបុណ្យជាដើម ។ បទថា **អាហុតីនំ បដិគ្គហោ** សេចក្ដីថា គ្រឿងបូជា និងសក្ការៈ លោកហៅថា **អាហុតិ** ។ ឈ្មោះថា **អាហុតីនំ បដិគ្គហោ** ព្រោះទ្រង់សមគួរទទួលនូវគ្រឿងបូជា និងសក្ការៈទាំងនោះ ភ្ជាប់សេចក្ដីថា ខណៈនោះ គឺកាលនោះ ព្រះមានព្រះភាគព្រះនាមផុស្សៈ ជាអ្នកក្មៀវក្លា ទ្រង់ញុំាងមហាជនឲ្យត្រជាក់ យាងទៅក្នុងផ្លូវ ។ ពាក្យដ៏សេស មានអត្ថប្រាកដច្បាស់ហើយនោះឯង ៕

**អដ្ឋកថាសប្បិទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## យុធិកបុប្ផិយត្ថេរាបទានទី ៧

[ ៦៧ ] ខ្ញុំទៅតាមទីបណ្តោយខ្សែទឹក ទៀបឆ្នេរស្ទឹងឈ្មោះចន្ទភាគា ខ្ញុំបានឃើញព្រះពុទ្ធសយម្ភូ ដូចសាលរាជព្រឹក្ស ដែលមានផ្ការីកស្គុះស្គាយ ជិតស្ទឹងនោះ ។ ខ្ញុំកាន់យកផ្កាជកខិម ហើយចូលទៅគាល់ព្រះមហាមុនី ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមសាមុទ្ទរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះយុធិកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

យុធិកបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## យុធិកបុប្ផិយត្ថេរាបទាន

[ ៦៧ ] *អបទានរបស់ព្រះយុធិកបុប្ផិយត្ថេរ មានពាក្យផ្ដើមថា* **ចន្ទភាគានទីតីរេ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយក្នុងព្រះពុទ្ធទាំងឡាយមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងជាតិមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមផុស្សៈ កើតក្នុងត្រកូលសូទ្រៈ ចម្រើនវ័យហើយ ត្រាច់ទៅតាមក្រសែទឹក ក្បែរឆ្នេរស្ទឹងចន្ទភាគា ដោយការងារឯណានីមួយ បានឃើញព្រះមានព្រះភាគព្រះនាមផុស្សៈ ដែលមានបំណងនឹងស្រពស្រង់ ទ្រង់បញ្ចេញរស្មីរុងរឿងដូចគំនរភ្លើង កើតនូវសោមនស្ស បេះនូវផ្កាជកខិម ( ផ្កាម្លូ ) ដែលកើតក្នុងទីនោះ មកបូជាព្រះមានព្រះភាគ ព្រះអង្គទ្រង់ធ្វើអនុមោទនាដល់កុលបុត្តនោះ ។*

*ដោយចំណែកនៃបុណ្យនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ មានចិត្តជ្រះថ្លា ទើបចេញបួស ធ្វើព្រះសាសនាឲ្យល្អដោយវត្តបដិបត្តិ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **ចន្ទភាគានទីតីរេ** *ដូច្នេះជាដើម ។ ពាក្យដ៏សេសទាំងអស់មានអត្ថងាយយល់ហើយ ។៚*

# សុត្តន្តបិដក

## ទុស្សទាយកត្ថេរាបទានទី ៨

[ ៦៨ ] ក្នុងកាលនោះ ខ្ញុំជារាជបុត្តក្នុងបូរីឈ្មោះតិវរា ជាទីក្រុងគួររីករាយ ខ្ញុំបានទូវបណ្ណាការ ហើយថ្វាយព្រះពុទ្ធ ព្រះអង្គជាបុគ្គលស្ងប់រម្ងាប់ ។ ព្រះមានព្រះភាគ ទ្រង់ទទួលហើយ ទ្រង់ពាល់សំពត់ដោយព្រះហស្ត លុះព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ទទួលហើយ ក៏ហោះទៅកាន់អាកាសវេហាស៍ ។ កាលព្រះពុទ្ធស្តេចទៅ សំពត់ទាំងឡាយក៏អណ្តែតទៅតាមក្រោយ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះពុទ្ធនោះថា ព្រះពុទ្ធជាអគ្គបុគ្គលរបស់យើង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់ ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ក្នុងកាលនោះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមបរិសុទ្ធៈ ជាធំជាងមនុស្ស ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទុស្សទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ទុស្សទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ទុស្សទាយកត្ថេរាបទាន

[ ៦៨ ] អបទានរបស់ព្រះទុស្សទាយកត្ថេរ មានពាក្យផ្ដើមថា **តិវរាយំ បុរេ រម្មេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងរាជត្រកូល លុះចម្រើនវ័យហើយ បានតាំងណែងជាឧបរាជ ជាអ្នកមានកេរ្តិ៍ឈ្មោះ បានទទួលព្រះរាជទានជនបទមួយកន្លែងជាធំ ក្នុងជនបទនោះ សង្គ្រោះអ្នកនគរទាំងឡាយដោយសង្គហវត្ថុ ៤ ប្រការ គឺទាន បិយវាចា អត្ថចរិយា និងសមានត្តតា ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ទ្រង់បានយាងទៅកាន់ជនបទនោះហើយ កាលនោះ ព្រះឧបរាជអង្គនោះ បានទទួលគ្រឿងបណ្ណាការហើយ បូជាព្រះមានព្រះភាគ ដោយសំពត់សាច់ម៉ដ្ឋក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់យកព្រះហស្តអង្អែលសំពត់នោះហើយយាងទៅតាមអាកាស ។ សំពត់នោះក៏អណ្ដែតជាប់តាមព្រះមានព្រះភាគទៅមិនដាច់ កាលព្រះឧបរាជអង្គនោះទតឃើញនូវភាពអស្ចារ្យនោះហើយ ជ្រះថ្លាពន់ពេក បានប្រថាប់ឈរផ្គងអញ្ជលី ក្នុងទីដែលព្រះមានព្រះភាគយាងទៅដល់ហើយ មហាជនទាំងអស់ដែលនៅក្នុងទីនោះ ឃើញព្រះមានព្រះភាគនិងភាពអស្ចារ្យនោះហើយ កើតអស្ចារ្យក្នុងចិត្ត បានឈរផ្គងអញ្ជលីដូចគ្នាព្រះមានព្រះភាគយាងទៅកាន់វិហារនោះមួយរំពេច ដោយកុសលនោះឯង

ព្រះឧបរាជនោះ ចុតិចាកអត្តភាពនោះហើយ ទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិក្នុងទេវលោកនោះហើយ កើតក្នុងមនុស្សលោក សោយចក្កពត្តិ-សម្បត្តិជាដើម ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ដែលសម្បូរដោយសម្បត្តិជាច្រើន ដល់នូវភាពជាអ្នកដឹងក្តីហើយ នៅគ្រប់គ្រងផ្ទះ ជ្រះថ្លាក្នុងព្រះរតនត្រ័យ បានស្តាប់នូវព្រះធម្មទេសនារបស់ព្រះមានព្រះភាគហើយ មាននូវសទ្ធា ទើបចេញបួស ព្យាយាមមិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ថ្ងៃមួយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **តិវរាយំ បុរេ រម្មេ** ដូច្នេះជាដើម ។

អធិប្បាយថា ខ្ញុំជាព្រះរាជឱរស នៅក្នុងព្រះនគរដែលគួរជាទីត្រេកអរឈ្មោះថា **តិវរា** នោះ បាននាំយកសំពត់ទៅបូជាព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ។

## អដ្ឋកថាទុស្សទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សមាទបកត្ថេរាបទានទី ៩

[ ៦៩ ] ខ្ញុំជាអ្នកមានពួកគណៈច្រើនក្នុងក្រុងពន្ធុមតី ជាបុគ្គលប្រសើរជាងពួកជនទាំងនោះ ពួកជនទាំងនោះ សុទ្ធតែប្រព្រឹត្តតាមសេចក្តីប្រាថ្នារបស់ខ្ញុំ ។ ខ្ញុំប្រជុំពួកជនទាំងអស់នោះ ហើយបបួលក្នុងបុញ្ញកម្មថា យើងនឹងធ្វើនូវរោងសម្រាប់ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់ព្រះសង្ឃ ។ ពួកជនទាំងនោះ ក៏ទទួលស្តាប់ថាប្រពៃ ហើយប្រព្រឹត្តតាមអំណាចសេចក្តីប្រាថ្នារបស់ខ្ញុំ លុះធ្វើរោងនោះឲ្យសម្រេចហើយ ក៏ថ្វាយចំពោះព្រះពុទ្ធព្រះនាមវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយរោង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយរោង ។ ក្នុងកប្បទី ៥៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គ ព្រះនាមអាវេលៈ ទ្រង់ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសមាទបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*សមាទបកត្ថេរាបទាន ចប់*

# អដ្ឋកថា

## សមាទបកត្ថេរាបទាន

[ ៦៩ ] អបទានរបស់ព្រះសមាទបកត្ថេរ មានពាក្យផ្ដើមថា **ឆគរេ ពន្ធុមតិយា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានកុសលសម្ភារធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ បំពេញបុណ្យជានិច្ច មានសទ្ធាជ្រះថ្លា ប្រាប់ឲ្យប្រជុំពួកឧបាសកជាច្រើន ខ្លួនឯងជាប្រធានគណៈប្រឹក្សាគ្នាថា ពួកយើងនឹងនាំគ្នាសាងបារាំ ហើយបបួលមនុស្សទាំងអស់ពង្រាបដីឲ្យស្មើ រោយខ្សាច់ពណ៌សធ្វើបារាំមួយ ហើយវេរថ្វាយដល់ព្រះមានព្រះភាគ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះកើតក្នុងទេវលោក សោយសម្បត្តិក្នុងកាមាវចរ ៦ ជាន់ហើយ កើតក្នុងមនុស្សលោក បានសោយចក្កពត្តិសម្បត្តិជាដើមក្នុងពួកមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះមានព្រះភាគ បានស្ដាប់ធម៌ហើយ មានចិត្តជ្រះថ្លា កើតសទ្ធា ទើបចេញបួស ជាអ្នកបរិបូណ៌ដោយសីល ដល់ព្រមដោយវត្តបដិបត្តិ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់កុសលកម្មដែលខ្លួនធ្វើ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឆគរេ ពន្ធុមតិយា** ដូច្នេះជាដើម ។

គប្បីជ្រាបវិគ្គហៈក្នុងបទនោះថា ឈ្មោះថា **ពន្ធុ** ព្រោះអ្នកនគរទាំងមូល ជាប់ទាក់ទងគ្នាតែមួយ ដោយអំណាចញាតិ និងគោត្តជាដើម ។ ឈ្មោះថា **ពន្ធុមតី** ព្រោះជានគរដែលមានពន្ធុ អធិប្បាយថា ពួកឧបាសកជាច្រើន មានក្នុងនគរ ឈ្មោះថា **ពន្ធុមតី** នោះ ។ ក្នុងបទថា **មាឡំ កស្សាម សង្ឃស្ស** នេះ មានវិគ្គហៈថា ឈ្មោះថា **មាឡ** ព្រោះទាញគឺទាក់ចិត្តគ្រប់មនុស្សទាំងអស់ដែលមកដល់ ។ម្យ៉ាងទៀត ឈ្មោះថា **មាឡ** ព្រោះជាទីសមគួរក្នុងការធ្វើចិត្តឲ្យស្ងប់ សម្រាប់ពួកភិក្ខុដែលមកដល់ **មាឡ** នោះឯង ប្រើជា **មាឡក** អធិប្បាយថា ពួកយើងនឹងធ្វើបារាំដើម្បីការនៅជាផាសុករបស់ភិក្ខុសង្ឃ ។ ពាក្យដ៏សេស មានអត្ថប្រាកដហើយ ។l

**អដ្ឋកថាសមានបកាត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បញ្ចង្គុលិយត្ថេរាបទានទី ៧០

[ ៧០ ] ព្រះមានព្រះភាគ ព្រះនាមតិស្សៈ ជាទីពឹងនៃសត្វលោក ជានាយកៈ ខ្ញុំបានឃើញព្រះពុទ្ធមហាមុនី ព្រះអង្គជាអ្នកឈ្នះវេរ ក្នុងវិហារធម៌ កំពុងចូលគន្ធកុដិ ទើបកាន់យកនូវផ្កាកម្រងមានក្លិនប្រអប់ ហើយដើរទៅកាន់សម្នាក់ព្រះជិនស្រី ។ ខ្ញុំមានសទ្ធាតិចតួចសោះ បានថ្វាយនូវគ្រឿងប្រអប់ ប្រោះព្រំដោយម្រាមដៃ ៥ ចំពោះព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយគ្រឿងប្រអប់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃគ្រឿងប្រអប់ ដែលប្រោះព្រំដោយម្រាមដៃ ៥ ។ ក្នុងកប្បទី ៧២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសយម្បកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចង្គុលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បញ្ចង្គុលិយត្ថេរាបទាន ចប់**

## ឧទ្ទាន

សុបារិចរិយត្ថេរាបទាន ១ កណវេរបុប្ផិយត្ថេរាបទាន ១ ខជ្ជទាយកត្ថេរាបទាន ១ ទេសបូជកត្ថេរាបទាន ១ កណិការច្ឆទនិយត្ថេរាបទាន ១ សប្បិទាយកត្ថេរាបទាន ១ យូថិកបុប្ផិយត្ថេរាបទាន ១ ទុស្សទាយកត្ថេរាបទាន ១ សមាទបកត្ថេរាបទាន ១ បញ្ចង្គុលិយត្ថេរាបទាន ១ មានគាថា ៥៤ ។

### សុបារិចរិយវគ្គទី ១៧ ចប់

# អដ្ឋកថា

## បញ្ចង្គុលិយត្ថេរាបទាន

[ ៧០ ] *អបទានរបស់ព្រះបញ្ចង្គុលិយត្ថេរ មានពាក្យផ្ដើមថា* **តិស្សោ នាមាសិ ភគវា** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងត្រកូលមួយកន្លែង ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ សម្បូរដោយសម្បត្តិ មានសទ្ធាជ្រះថ្លា ឃើញព្រះមានព្រះភាគចេញចាកផ្លូវ យាងចូលទៅកាន់វិហារ បានកាន់យកផ្កាដែលមានក្លិនក្រអូបច្រើនប្រភេទ ដូចជាផ្កាម្លិះជាដើម និងគ្រឿងលាប មានខ្លឹមចន្ទន៍ជាដើម ទៅកាន់វិហារ យកផ្កាទាំងឡាយបូជាព្រះមានព្រះភាគ យកម្រាម ៥ ជ្រលក់គ្រឿងក្រអូបប្រោះព្រំត្រង់សរីរៈ របស់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ចៀសចេញទៅ ។*

*ដោយបុញ្ញកម្មនោះ កុលបុត្តនោះ បានសោយសម្បត្តិទាំងពីរ ក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ដែលសម្បូរដោយសម្បត្តិ ចម្រើនវ័យហើយ ស្ដាប់ព្រះធម្មទេសនា*

*របស់ព្រះសាស្តា មានចិត្តជ្រះថ្លា ទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត រឭកដល់បុព្វកម្មបានយ៉ាងជាក់ច្បាស់ថា អញបានលោកុត្តរសម្បត្តិនេះ ព្រោះធ្វើកុសលកម្មនេះឯង កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **តិស្សោ ឆាមាសិ ភគវា** *ដូច្នេះជាដើម ។ ពាក្យទាំងអស់ មានអត្ថងាយយល់ហើយ ៕*

**អដ្ឋកថាបញ្ចង្គុលិយត្ថេរាបទាន ចប់**

**សុចារិចរិយវគ្គទី ១៧ ចប់**

# សុត្តន្តបិដក

# កុមុទវគ្គទី ១៨

## កុមុទមាលិយត្ថេរាបទានទី ១

[ ៧១ ] មានស្រះកើតឯងដ៏ធំ នៅទៀបភ្នំហិមពាន្ត ខ្ញុំជាអារក្សទឹក កើតក្នុងស្រះនោះ មានរូបដ៏សម្បើម មានកម្លាំងច្រើន ។ កុមុទ មានផ្ការីកស្គុះស្គាយក្នុងស្រះនោះ ពួកផ្កាកុមុទប្រមាណប៉ុនកង់រទេះ កើតឡើងក្នុងស្រះនោះ ខ្ញុំតែងបេះផ្កាផង ផ្លែផង ជារឿយៗ ។ គាប់ជួន ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាធំជាងសត្វជើង ២ ជានរាសភៈ ទ្រង់ឃើញផ្កា ដែលខ្ញុំបេះគរទុក ក៏ស្តេចមកក្នុងសម្នាក់របស់ខ្ញុំ ។ លុះ ( ខ្ញុំឃើញ ) នូវព្រះសម្ពុទ្ធជាទេវតារបស់ទេវតា ជានរាសភៈហើយ ខ្ញុំក៏យកផ្កាទាំងអស់មកថ្វាយព្រះពុទ្ធ ។ ក្នុងកាលនោះ ផ្កាកម្រងទាំងប៉ុន្មាន ក៏ទៅជាគ្រឿងប្រក់ថ្វាយព្រះតថាគត ដែលស្តេចទៅទៀបភ្នំហិមពាន្ត ។ ក្នុងកប្បទី ១១៨ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៥

អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៧ ជាតិ ជាធំជាងជន ព្រះនាមសហស្សរថៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុមុទមាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កុមុទមាលិយត្ថេរាបទាន ចប់

# អដ្ឋកថា

# កុមុទវគ្គទី ១៨

## កុមុទមាលិយត្ថេរាបទាន

[ ៧១ ] *អបទានរបស់ព្រះកុមុទមាលិយត្ថេរ មានពាក្យផ្តើមថា* **បព្វតេ ហិមវន្តម្ហិ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតជាអារក្សទឹក ត្រង់ស្រះធំដែលកើតឯង ជិតភ្នំហិមពាន្ត ឃើញព្រះមានព្រះភាគព្រះនាមអត្ថទស្សី យាងទៅក្នុងទីនោះហើយ មានចិត្តជ្រះថ្លា បេះផ្កាកុមុទទៅបូជាព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនាហើយ យាងចៀសចេញទៅ ។*

*ដោយបុណ្យនោះ កុលបុត្តនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយសម្បត្តិក្នុងកាមាវចរសួគ៌ ៦ ជាន់ហើយ កើតក្នុងមនុស្សបានសោយសម្បត្តិ មានចក្កពត្តិសម្បត្តិជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ បួសហើយព្យាយាមបានសម្រេចអរហត្ត ដែលជាទីបំផុតនៃព្រហ្មចរិយៈ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បព្វតេ ហិមវន្តម្ហិ** *ដូច្នេះជាដើម ។*

បណ្ដាបទទាំងនោះ បទថា **តត្ថជោ រក្ខសោ អាសឹ** សេចក្ដីថា ខ្ញុំបានជាអារក្សទឹក កើតក្នុងស្រះធំដែលកើតឯងនោះ គឺបានជាយក្ខមិនមានមេត្តា បរិភោគឈាម និងសាច់អ្នកដទៃ មានរូបរាងគួរខ្លើម មានសភាពគួរខ្លាច មានកម្លាំងច្រើន មានថាមពលច្រើន ជាយក្ខរឹងរូស ។

បទថា **កុមុទំ បុប្ផិតេ តត្ថ** សេចក្ដីថា កាលមិនមានពន្លឺព្រះអាទិត្យចាំងទៅក្នុងស្រះនោះ លុះដល់ល្ងាចផ្កាក៏ក្ដោប មិនមានរស្មី មិនមានពណ៌ មានតែការស្ងួតស្រពោន ព្រោះហេតុនោះ ទើបផ្កានោះ បានឈ្មោះថា **កុមុទ** អធិប្បាយថា ផ្កាកុមុទដែលរីកហើយ គឺបើកត្របកហើយ ។ បទថា **ចក្កមត្តានិ ជាយរេ** សេចក្ដីថា ផ្កាទាំងនោះ មានទំហំប៉ុនកង់រថ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ៕

## អដ្ឋកថាកុមុទមាលិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## និស្សេណីទាយកត្ថេរាបទានទី ២

[ ៧២ ] ខ្ញុំបានឲ្យគេធ្វើជណ្តើរសម្រាប់ឡើងកាន់ប្រាសាទ ថ្វាយព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈ ជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយតាទិគុណ ។ ខ្ញុំបានបំពេញសម្បទា ( នៃបុណ្យ ) ដោយសេចក្តីជ្រះថ្លានៃចិត្តនោះ ទើបខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ១០៣១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមសម្ពហុលៈដូចគ្នា ទ្រង់មានកម្លាំងច្រើន បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនិស្សេណីទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**និស្សេណីទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## និស្សេណីទាយកត្ថេរាបទាន

[ ៧២ ] អបទានរបស់ព្រះនិស្សេណីទាយកត្ថេរ មានពាក្យផ្តើមថា **កោណ្ឌញ្ញស្ស ភគវតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងជាតិមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមកោណ្ឌញ្ញៈ កើតក្នុងត្រកូលជាងឈើ មានសទ្ធាជ្រះថ្លា បានស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា សាងជណ្តើរ ធ្វើដោយឈើខ្លឹមសម្រាប់ឡើងកាន់ប្រាសាទ ដែលជាទីប្រថាប់របស់ព្រះមានព្រះភាគ ហើយលើកឡើងតម្កល់ ។ ដើម្បីបន្ថែមសេចក្តីជ្រះថ្លាដល់កុលបុត្តនោះ ព្រះមានព្រះភាគយាងឡើងកាន់ប្រាសាទ ក្នុងខណៈដែលកុលបុត្តនោះកំពុងមើលឃើញនោះឯង ។ កុលបុត្តនោះ មានចិត្តជ្រះថ្លាក្រៃលែង អស់ជីវិតដោយបីតិ និងសោមនស្សនោះឯង បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិក្នុងទេវលោកនោះ កាលមកកើតក្នុងពួកមនុស្ស ក៏កើតក្នុងត្រកូលខ្ពស់ ព្រោះផលដែលបានសាងជណ្តើរ បានសោយសុខក្នុងមនុស្សហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ កើតនូវសទ្ធា ទើបចេញបួស មិនយូរប៉ុន្មានក៏បានជាព្រះអរហន្ត ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **កោណ្ឌញ្ញស្ស ភគវតោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **កោណ្ឌញ្ញស្ស** មានវិគ្គហៈថា ឈ្មោះថា **កោណ្ឌ** ព្រោះជាបុគ្គលគួរខ្ពើម ហូរចេញមក បានដល់ សត្វអាក្រក់ ។ ឈ្មោះថា **កោណ្ឌញ្ញ** ព្រោះជាបុគ្គលដទៃក្រៅអំពី **កោណ្ឌ** សេចក្ដីថា មិនជាបុគ្គលអាក្រក់ តែជាបុរសឧត្ដម ។ ម្យ៉ាងទៀត ពាក្យថា **កោណ្ឌ** ជាឈ្មោះរបស់ព្រះអង្គដោយគោត្ត ព្រោះប្រសូតក្នុងកោណ្ឌញ្ញគោត្ត ក្នុងបណ្ដាគោត្តរបស់ព្រាហ្មណ៍ទាំងឡាយ ។ ខ្ញុំថ្វាយដល់ព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈអង្គនោះ ។ ពាក្យដ៏សេស មានអត្ថប្រាកដច្បាស់ហើយ ៕

## អដ្ឋកថាថេរាបទាន ចប់

# សុត្តន្តបិដក

## វត្តិយបុប្ផិយត្ថេរាបទានទី ៣

[ ៧៣ ] ក្នុងជាតិមុន ខ្ញុំជាព្រានម្រឹគ នៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ជាទេវតារបស់ទេវតា ជានរាសភៈ ។ ខ្ញុំបានឃើញដើមឈើថ្លែងគង់ ដែលមានផ្ការីកស្គុះស្គាយ ប្រកបដោយសេចក្តីត្រេកអរ ហើយកាន់យកទាំងឫស មកថ្វាយព្រះពុទ្ធមហេសី ។ ក្នុងកប្បទី ៩១ អំពី កប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្កា ។ ក្នុងបក្សទី ៨ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិព្រះនាមសុប្បសន្នៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវត្តិយបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វត្តិយបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## រត្តិយបុប្ផិយត្ថេរាបទាន

[ ៧៣ ] *អបទានរបស់ព្រះរត្តិយបុប្ផិយត្ថេរ មានពាក្យផ្តើមថា*

**មិគលុទ្ទោ បុរេ អាសឹ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងត្រកូលរបស់នាយព្រានចូលព្រៃដើម្បីបរបាញ់ម្រឹគ បានឃើញព្រះមានព្រះភាគ ព្រះនាមវិបស្សី យាងមកត្រង់ព្រៃដោយសេចក្តីករុណា ដល់កុលបុត្តនោះ កុលបុត្តនោះមានចិត្តជ្រះថ្លា ទើបបេះផ្កាឈ្មោះរត្តិដែលរីកហើយ និងផ្កាអញ្ចូនទៀត ព្រមទាំងទងមកបូជា ដោយចិត្តដែលប្រកបដោយសោមនស្ស ព្រះមានព្រះភាគទ្រង់ធ្វើនូវអនុមោទនាហើយ ក៏យាងចៀសចេញទៅ ។ ដោយបុណ្យនោះឯងកុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មើលឃើញទោសក្នុងកាមទាំងឡាយ ក៏ចេញបួស មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត រឭកដល់បុព្វកម្មរបស់ខ្លួនកើតសោមនស្សថា ខ្ញុំជានាយព្រាន បានធ្វើកុសលកម្មល្អពិត កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **មិគលុទ្ទោ បុរេ អាសឹ** *ដូច្នេះជាដើម ។*

គប្បីជ្រាបវិគ្គហៈ ក្នុងពាក្យនោះថា ឈ្មោះថា **មិគលុទ្ទោ** ព្រោះជាមនុស្សឃោរឃៅ រឹងរូស សម្លាប់នូវម្រឹគទាំងឡាយ ម្យ៉ាងទៀត ឈ្មោះថា **មិគលុទ្ទោ** ព្រោះលោភលន់ក្នុងពួកម្រឹគ អធិប្បាយថា ក្នុងកាលមុន ខ្ញុំបានជានាយព្រាន ។

បទថា **រត្តិកំ បុប្ផិតំ ទិស្វា** សេចក្តីថា ផ្កាច្រើនប្រភេទ មានផ្កាឈូកជាដើម រមែងរីកក្នុងពេលថ្ងៃ ព្រោះត្រូវពន្លឺព្រះអាទិត្យ និងក្តោបក្នុងពេលរាត្រី តែផ្កាច្រើនប្រភេទ មានផ្កាម្លិះ និងផ្កាម្លិះរួតជាដើម ជាផ្ការីកក្នុងពេលយប់ មិនរីកក្នុងពេលថ្ងៃ អធិប្បាយថា ព្រោះហេតុនោះ ទើបខ្ញុំបេះផ្កាដែលមានក្លិនក្រអូបច្រើនប្រភេទ ដែលមានឈ្មោះថា ផ្ការត្តិ ព្រោះរីកក្នុងពេលយប់ និងបេះផ្កាអញ្ជើញមកបូជា ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថារត្តិយបុប្ផិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឧទបានទាយកត្ថេរាបទានទី ៤

[ ៧៤ ] ខ្ញុំបានធ្វើអណ្តូង ថ្វាយចំពោះព្រះមានព្រះភាគ ព្រះនាមវិបស្សី ក្នុងកាលនោះ ខ្ញុំយកចង្ហាន់បិណ្ឌបាតថ្វាយ ( ថែមទៀត )។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយអណ្តូង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទបានទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឧទបានទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ឧទបានទាយកត្ថេរាបទាន

[ ៧៤ ] អបទានរបស់ព្រះឧទបានទាយកត្ថេរ មានពាក្យផ្ដើមថា **វិបស្សិនោ ភគវតោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើ ហើយក្នុងព្រះមុនីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យក្នុងភពមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ គិតថា អញគួរថ្វាយទឹកផឹក និងគួរធ្វើឲ្យទឹកផឹកនោះមានសព្វកាល ដូច្នោះ ទើបជីកអណ្ដូងទឹកមួយកន្លែង ក្នុងវេលាដែលអណ្ដូងមានទឹកពេញ បានឲ្យរៀបឥដ្ឋការពារធ្វើឲ្យមាំ បានវេរថ្វាយអណ្ដូងទឹកនោះ ដែលមានទឹកពេញដល់ព្រះមានព្រះភាគព្រះនាមវិបស្សី ។ ព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនា សម្ដែងដល់អានិសង្សនៃការឲ្យទានទឹកផឹក ។ ដោយបុណ្យនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងទីដែលកុលបុត្តនោះកើតមានស្រះបោក្ខរណី អណ្ដូងទឹក និងទឹកផឹកជាដើមយ៉ាងបរិបូណ៌ កុលបុត្តនោះបានសោយតែសេចក្ដីសុខ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ចម្រើនវ័យហើយ មាននូវសទ្ធាជ្រះថ្លា ទើបចេញបួស មិនយូរប៉ុន្មានក៏បានជាព្រះអរហន្ត ។

ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្សកាលប្រកាសអបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វិបស្សិនោ ភគវតោ** ដូច្នេះជាដើម។ បណ្ដាបទទាំងនោះ បទថា **ឧទបានោ**

**ករោ មយា** មានវិគ្គហៈថា ឈ្មោះថា **ឧទធាន** ព្រោះជាទីផឹកទឹក ។ ពាក្យថា **ឧទធាន** នោះ ជាឈ្មោះរបស់អណ្តូងទឹក ស្រះបោក្ខរណី និងបឹង អធិប្បាយថា ខ្ញុំបានធ្វើការជីកអណ្តូងនោះ ដើម្បីព្រះមានព្រះភាគ ព្រះនាមវិបស្សី ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាឧទធានទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សីហាសនទាយកត្ថេរាបទានទី ៥

[ ៧៥ ] កាលព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ជានាយក ជាទីពឹង នៃលោក បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បាន ថ្វាយសីហាសនៈ ។ សេចក្តីពិត ជនមានប្រមាណច្រើននាក់ បាន នូវសេចក្តីសុខក្នុងបរលោក ហើយរម្ងត់ទុក្ខបាន ព្រោះធ្វើនូវការ បូជា ដោយគ្រឿងក្រអូប និងផ្កាកម្រងជាច្រើន ក្នុងទីបរិនិព្វាន នោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ថ្វាយបង្គំនូវពោធិព្រឹក្ស ដ៏ឧត្តម ខ្ញុំមិនទៅកើតក្នុងទុគ្គតិ អស់ ១ សែនកប្ប ព្រោះកុសល នេះ ។ ក្នុងកប្បទី ១៥០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេច ចក្កពត្តិ ៨ ជាតិ ព្រះនាមសីលុច្ចយៈដូចគ្នា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសីហាសនទាយកត្ថេរមានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សីហាសនទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## សីហាសនទាយកត្ថេរាបទាន

[ ៧៥ ] អបទានរបស់ព្រះសីហាសនទាយកត្ថេរ មានពាក្យផ្ដើមថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដើម្បីសម្រេចព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលគហបតី ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានស្ដាប់នូវព្រះធម្មទេសនារបស់ព្រះសាស្ដា ជ្រះថ្លាក្នុងព្រះរតនត្រ័យ កាលព្រះមានព្រះភាគអង្គនោះបរិនិព្វានហើយ បានឲ្យសាងសីហាសនៈដែលរំលេចដោយរតនៈ ៧ ប្រការ បូជាពោធិព្រឹក្ស និងបានបូជាដោយកម្រងផ្កា គ្រឿងក្រអូប ធូបក្រអូបជាច្រើន ។

ដោយបុណ្យនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ បានទទួលការបូជាក្នុងទីទាំងពួង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា មានចិត្តជ្រះថ្លា ទើបលះពួកញាតិចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត រឭកដល់កុសលសម្ភារដែលខ្លួនបានសន្សំក្នុងកាលមុន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **និព្វុតេ លោកនាថម្ហិ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **សីហាសនមទាសហំ** មានវិគ្គហៈថា អាសនៈដែលវិចិត្រទៅដោយរូបសីហៈ ប្រាក់ មាស និងរតនៈទាំងឡាយ ឈ្មោះថា អាសនសីហៈ ម្យ៉ាងទៀត អាសនៈដែលសមគួរប្រថាប់គង់របស់ព្រះមានព្រះភាគ ដែលមិនខ្លាចចំពោះរាជសីហ៍ ឈ្មោះថា **សីហាសន** ម្យ៉ាងទៀត **សីហាសន** គឺអាសនៈដែលប្រសើរបំផុត ហេតុនោះ ទើបឈ្មោះថា **សីហាសន** អធិប្បាយថា ខ្ញុំបានថ្វាយសីហាសនៈនោះ គឺខ្ញុំបានបូជាពោធិព្រឹក្ស ។ ពាក្យដ៏សេស មានអត្ថដ៏ងាយហើយ ៕

## អដ្ឋកថាសីហាសនទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## មគ្គទត្តិកត្ថេរាបទានទី ៦

[ ៧៦ ] ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាធំជាងសត្វជើង ២ ជានរាសភៈ ទ្រង់ចង្ក្រមក្នុងទីវាលស្រឡះ ដើម្បីប្រយោជន៍ដល់សេចក្ដីសុខ ក្នុងបច្ចុប្បន្ន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះបាទា ដែលទ្រង់លើកឡើង ហើយខ្ញុំបេះផ្កាទាំងឡាយដែលល្អ ស្ថិតលើកំពូលភ្នំ មករោយរាយថ្វាយ ។ ក្នុងកប្បទី ២០០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ៥ ជាតិ ព្រះនាមបុប្ផច្ឆទនិយៈដូចគ្នា មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមគ្គទត្តិកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មគ្គទត្តិកត្ថេរាបទាន ចប់

# អដ្ឋកថា

## មគ្គទត្តិកត្ថេរាបទាន

[ ៧៦ ] អបទានរបស់ព្រះមគ្គទត្តិកត្ថេរ មានពាក្យផ្ដើមថា **អនោមទស្សី ភគវា** ដូច្នេះ ។

លោកមានអាយុអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអនោមទស្សី កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ បានឃើញព្រះមានព្រះភាគព្រះនាមអនោមទស្សី កំពុងយាងចង្ក្រមក្នុងអាកាស បានឃើញភាពអស្ចារ្យដែលមានផ្កាជាច្រើន រាយរាយត្រង់ជំហានព្រះបាទ ក្នុងទីចង្ក្រម មានចិត្តជ្រះថ្លា បោះផ្កាទាំងឡាយឡើងទៅលើអាកាស ផ្កាទាំងនោះ ក៏បានក្លាយជាពិតានបាំង ។

ដោយបុណ្យនោះ ទើបកុលបុត្តនោះ អន្ទោលទៅតែក្នុងសុគតិទាំងឡាយប៉ុណ្ណោះ បានទទួលការបូជាក្នុងទីទាំងពួង បានសោយសេចក្ដីសុខ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយកន្លែង ដល់នូវភាពជាកំលោះ កើតនូវសទ្ធា ទើបចេញបួស ជាអ្នកសម្បូរដោយវត្តបដិបត្តិ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ប្រាកដឈ្មោះថា មគ្គទត្តិកត្ថេរ ព្រោះបានបូជាទីចង្ក្រម ។ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **អនោមទស្សី ភគវា** ដូច្នេះជាដើម ។ បទថា **ទិដ្ឋធម្មសុខត្ថាយ** សេចក្ដីថា កើតនូវសេចក្ដីសុខ

ដូចជាមានខ្ទនស្រោល ( ក្រោករហ័ស ) ជាដើម ដែលកើតឡើងដោយការចង្ក្រម ក្នុងអត្តភាពនេះ ។ បទថា **អព្ភោកាសម្ហិ ចង្កមិ** សេចក្តីថា បានយាងចង្ក្រមក្នុងទីវាល គឺទីស្រឡះ បានដល់ ធ្វើការឈានព្រះបាទយាងទៅ ។

បទថា **ឧទ្ធរតេ ចរណេ បុប្ផានិ** សេចក្តីថា កាលលើកព្រះបាទឡើងដោយការចង្ក្រម ផ្កាទាំងឡាយ មានផ្កាបទុម និងផ្កាឧប្បលជាដើម ផុសឡើងអំពីផែនដីរោយរាយហើយក្នុងទីចង្ក្រម ។ បទថា **សោភំ មុទ្ធនិ តិដ្ឋរេ** សេចក្តីថា ផ្កាទាំងឡាយនោះ អណ្តែតយ៉ាងល្អខាងលើព្រះសិរសារបស់ព្រះពុទ្ធ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ។៚

## អដ្ឋកថាមគ្គទត្តិកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឯកទីបិយត្ថេរាបទានទី ៧

[ ៧៧ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយប្រទីប ១ ដល់ព្រះមុនី ព្រះនាមបទុមុត្តរៈ ទៀបដើមស្រល់ ជាពោធិព្រឹក្សដ៏ប្រសើរ ។ កាលខ្ញុំកើតក្នុងភព កាលការសន្សំបុណ្យកើតហើយ ខ្ញុំក៏មិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយប្រទីប ។ ក្នុងកប្បទី ១៦០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៤ ជាតិ ព្រះនាមចន្ទាភៈដូចគ្នាទ្រង់មានកម្លាំង ច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទីបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកទីបិយត្ថេរាបទាន ចប់

ភាណវារទី ៩ ចប់

# អដ្ឋកថា

## ឯកទីបិយត្ថេរាបទាន

[ ៧៧ ] *អបទានរបស់ព្រះឯកទីបិយត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរស្ស មុនិនោ** *ដូច្នេះ ។*

*លោកមានអាយុអង្គនេះ ជាអ្នកមានកុសលសម្ភារបានធ្វើហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលគហបតី ចម្រើនវ័យហើយ មានសទ្ធាជ្រះថ្លា បានបូជាប្រទីបមួយត្រង់ដើមស្រល់ដែលជាពោធិព្រឹក្សរបស់ព្រះមានព្រះភាគ បានដាក់ប្រេងនិងប្រឆេះ ធ្វើជាថាវរវត្ថុដើម្បីបូជាដោយប្រទីបមួយសព្វកាល ។ ដោយបុណ្យនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ជាអ្នករុងរឿងក្នុងទីសព្វអន្លើ មានភ្នែកថ្លាល្អ បានសោយសុខក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ដែលសម្បូរដោយសម្បត្តិ ក្នុងនគរសាវត្ថី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ បួសហើយ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ប្រាកដឈ្មោះថាឯកទីបិយត្ថេរ ព្រោះបានសម្រេចគុណវិសេស ដោយការបូជាប្រទីប ។*

*ក្នុងកាលតមក ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរស្ស មុនិនោ** *ដូច្នោះជាដើម ។ ពាក្យដ៏សេសទាំងអស់មានអត្ថងាយយល់ហើយ ។*

# សុត្តន្តបិដក

## មណិបូជកត្ថេរាបទានទី ៨

[ ៧៨ ] ស៊ីងតែងហូរចេញអំពីខាងអាយក្នុំហិមពាន្ត គាប់ជួន គ្រានោះ ព្រះពុទ្ធសយម្ភូ ទ្រង់គង់នៅក្នុងខេត្តជាបន្ទាប់នៃស៊ីង នោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ យកបល្ល័ង្កកែវមណី ដែលគេរចនាដោយប្រពៃ ជាទីត្រេកអរនៃចិត្ត ថ្វាយចំពោះព្រះ ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយ បល្ល័ង្កកែវមណី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៨ ជាតិ ព្រះនាមសតរង្សីដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមណិបូជកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

មណិបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## មណិបូជកត្ថេរាបទាន

[ ៧៨ ] អបទានរបស់ព្រះមណិបូជកត្ថេរ មានពាក្យផ្ដើមថា **ឱរេន ហិមវន្តស្ស** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលមួយកន្លែង នៅគ្រប់គ្រងផ្ទះ ឃើញទោសក្នុងឃរាវាសនោះ ទើបលះឃរាវាសចេញបួសជាតាបស សាងបណ្ណសាលាក្បែរស្ទឹងមួយកន្លែង ក្នុងចំណែកខាងអាយនៃភ្នំហិមពាន្ត បានឃើញព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ដែលទ្រង់យាងចូលទៅក្នុងទីនោះ ព្រោះទ្រង់បំណងវិវេក និងដើម្បីអនុគ្រោះ បុគ្គលនោះ មានចិត្តជ្រះថ្លា បានយកបល្ល័ង្កកែវមណីបូជាដល់ព្រះមានព្រះភាគ ។ ដើម្បីបន្ថែមសេចក្ដីជ្រះថ្លាដល់កុលបុត្តនោះ ព្រះមានព្រះភាគក៏ប្រថាប់គង់លើបល្ល័ង្កនោះ កុលបុត្តនោះ មានចិត្តជ្រះថ្លាក្រៃលែង បានតាំងសេចក្ដីប្រាថ្នា ដើម្បីសម្រេចព្រះនិព្វាន ព្រះមានព្រះភាគទ្រង់ត្រាស់អនុមោទនាហើយ ក៏ចៀសចេញទៅ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានទទួលការបូជាក្នុងទីទាំងពួង សោយតែសេចក្ដីសុខ ក្នុងពុទ្ធុប្បាទកាលនេះ កើតនៅក្នុងត្រកូលដែលសម្បូរដោយសម្បត្តិ ក្នុងនគរសាវត្ថី នៅគ្រប់គ្រងផ្ទះ ថ្ងៃមួយ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានទូវសទ្ធាបួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ថ្ងៃមួយ ព្រះថេរៈរឭកដល់កុសលកម្មដែលខ្លួនធ្វើ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឧត្តរេន ហិមវន្តស្ស** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧត្តរេន** សេចក្តីថា ខាងអាយបន្ទាប់អំពីភ្នំហិមពាន្តមកបន្តិច ពាក្យថា **ឧត្តរេន** នោះ ជាតតិយវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ សេចក្តីថា ក្នុងភាគខាងអាយ ។ បទថា **នទិកា សម្បវត្តថ** សេចក្តីថា ស្ទឹងមួយខ្សែ ដែលមិនប្រាកដឈ្មោះហូរទៅ គឺបានហូរទៅ បានដល់ហូរច្រូងទៅ ។ បទថា **តស្សា ចានុបខេត្តម្ហិ** សេចក្តីថា ក្នុងខេត្តក្បែរស្ទឹងនោះ គឺជិតប្រាំង ។ បទថា **សយម្ភូ វសតេ តទា** សេចក្តីថា ក្នុងកាលណាខ្ញុំបានយកបល្ល័ង្កកែវមណីបូជា ក្នុងកាលនោះ ព្រះមានព្រះភាគមិនមានអាចារ្យ ទ្រង់ជាព្រះពុទ្ធដោយព្រះអង្គឯង ប្រថាប់នៅ ។

បទថា **មណី** ក្នុងបទថា **មណី បគ្គយ្ហ បល្លង្កំ** នេះ មានវិគ្គហៈថា ឈ្មោះថា **មណី** ព្រោះធ្វើឲ្យពេញចិត្ត គឺធ្វើនូវសោមនស្សឲ្យ ម្យ៉ាងទៀត ឈ្មោះថា **មណី** ព្រោះរាប់ គឺវាយតម្លៃថា ជាគ្រឿងអាភរណៈ ។ ម្យ៉ាងទៀត ឈ្មោះថា **មណី** ព្រោះព្រះរាជា និងឧបរាជជាដើម ទោះបីស្លាប់ ក៏មិនព្រមលះបង់កែវមណីនោះ គឺរមែងធ្វើសង្គ្រាមការពារ ដើម្បីបានកែវមណីនោះ អធិប្បាយថា ខ្ញុំបានផ្គងបល្ល័ង្កដែលធ្វើដោយកែវមណី ដែលគួរជាទីត្រេកអរនៃចិត្តវិចិត្រល្អនោះ បូជាដល់ព្រះពុទ្ធដ៏ប្រសើរ ។ ពាក្យដ៏សេសទាំងអស់នោះ មានអត្ថងាយយល់ហើយ ។ល។

# សុត្តន្តបិដក

## តិកិច្ឆកត្ថេរាបទានទី ៩

[ ៧៩ ] ខ្ញុំជាពេទ្យ មានវិជ្ជសាស្ត្រសិក្សាល្អហើយ នៅក្នុងនគរពន្ធុមតី ជាអ្នកនាំមកនូវសេចក្ដីសុខដល់មហាជន ពិសេសចំពោះពួកជនអ្នកមានជំងឺ មានទុក្ខខ្លាំង ។ ខ្ញុំឃើញសមណៈ អ្នកមានសីល មានសេចក្ដីរុងរឿងច្រើន ដែលកំពុងឈឺស្កាត់ ក្នុងកាលនោះ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានប្រគេនភេសជ្ជៈ ។ សមណៈនោះ ឈ្មោះអសោកៈ មានឥន្ទ្រិយសង្រួមល្អ ជាឧបដ្ឋាករបស់ព្រះវិបស្សីសម្ពុទ្ធ ក៏សះជារោគ ដោយភេសជ្ជៈនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនោះ ព្រោះហេតុដែលខ្ញុំបានប្រគេនឱសថ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ ក្នុងកប្បទី ៨ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ព្រះនាមសព្វោសថៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិកិច្ឆកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយ ប្រការដូច្នេះ ។

**តិកិច្ឆកត្ថេរាបទាន ចប់**

# អដ្ឋកថា
# តិកិច្ឆកត្ថេរាបទាន

[ ៧៩ ] អបទានរបស់ព្រះតិកិច្ឆកត្ថេរ មានពាក្យផ្ដើមថា **ឆគរេ ពន្ធុមតិយា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវិបស្សី កុលបុត្តនេះ កើតក្នុងត្រកូលគ្រូពេទ្យ ក្នុងនគរពន្ធុមតី ជាពហូសូត សិក្សាមកយ៉ាងល្អ ឈ្លាសក្នុងវេជ្ជកម្ម ព្យាបាលរោគបានច្រើនប្រភេទ បានព្យាបាលដល់ព្រះ ថេរៈឈ្មោះអសោក ជាឧបដ្ឋាករបស់ព្រះមានព្រះភាគព្រះនាមថាវិបស្សី ។ ដោយបុញ្ញកម្មនោះ ទើបកុលបុត្តនោះ បានសោយតែសេចក្ដីសុខ ផ្លាស់ប្ដូរ ទៅមក ក្នុងទេវតា និងមនុស្សទាំងឡាយ ជាអ្នកមិនមានរោគ មានអាយុវែង មានសរីរាង្គកាយស្អាតដូចមាស គ្រប់ភពដែលខ្លួនកើត ។

ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលគហបតី ក្នុងនគរសាវត្ថី ចម្រើន វ័យហើយ សម្រេចការសិក្សាក្នុងសិល្បសាស្ត្រគ្រប់យ៉ាង ជាអ្នកមិនមាន រោគ មានតែសេចក្ដីសុខ ដល់ព្រមដោយសម្បត្តិជាច្រើន ជ្រះថ្លាក្នុងព្រះ

រតនត្រ័យ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានទូវសទ្ធា លះនូវការគ្រប់គ្រងផ្ទះ ចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែល ប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឆគវេ ពន្ធុមតិយា** ដូច្នេះ ជាដើម ។ ពាក្យដ៏សេសទាំងអស់នោះ មានអត្ថងាយយល់ហើយ ព្រោះ មានន័យដូចពោលខាងដើមនោះឯង ។ល។

## អដ្ឋកថាតិកិច្ចកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សង្ឃុបដ្ឋាកត្ថេរាបទានទី ១០

[ ៨០ ] ខ្ញុំជាអារាមិកជន ( អ្នកទំនុកបម្រុងអារាម ឬញោមវត្ត ) ក្នុងសម្នាក់ព្រះមានព្រះភាគ ព្រះនាមវេស្សភូ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបម្រើព្រះសង្ឃដ៏ឧត្តម ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងគ្រានោះ ព្រោះហេតុដែលខ្ញុំបានធ្វើបុញ្ញកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើ ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៧ ជាតិ ព្រះនាមសមោត្ថកៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសង្ឃុបដ្ឋាកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សង្ឃុបដ្ឋាកត្ថេរាបទាន ចប់

## ឧទ្ទាន

កុមុទមាលិយត្ថេរាបទាន ១ និស្សេណីទាយកត្ថេរាបទាន ១ រត្តិយបុប្ផិយត្ថេរាបទាន ១ ឧទបានទាយកត្ថេរាបទាន ១ សីហាសនទាយកត្ថេរាបទាន ១ មគ្គទត្តិកត្ថេរាបទាន ១ ឯកទីបិយត្ថេរាបទាន ១ មណិបូជកត្ថេរាបទាន ១ តិកិច្ឆកត្ថេរាបទាន ១ សង្ឃុបដ្ឋាកត្ថេរាបទាន ១ មានគាថា ៤៩ ។

## កុមុទវគ្គទី ១៨ ចប់

# អដ្ឋកថា

## សង្ឃបដ្ឋាកត្ថេរាបទាន

[ ៨០ ] អបទានរបស់ព្រះសង្ឃុបដ្ឋាកត្ថេរ មានពាក្យផ្ដើមថា **វេស្សភុម្ហិ ភគវតិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានកុសលសម្ភារបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពមិនមែនតិច ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមវេស្សភូ កើតជាកូនប្រុសរបស់អ្នករក្សាវត្ត លុះដល់នូវភាពជាអ្នកដឹងក្ដីហើយ មានសទ្ធាជ្រះថ្លាបោសសម្អាតវត្តក្នុងវិហារច្រើនកន្លែង បានបម្រើព្រះសង្ឃ ដោយសេចក្ដីគោរព ។ ដោយកុសលកម្មនោះឯង ទើបកុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលគហបតីក្នុងនគរសាវត្ថី ចម្រើនវ័យហើយជាអ្នកដល់ព្រមដោយសម្បត្តិ សម្បូរដោយសេចក្ដីសុខ មាននូវកេរ្តិ៍ឈ្មោះបានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ ជ្រះថ្លាក្នុងព្រះសាស្ដាទើបចេញបួស ជាអ្នកបរិបូណ៌ដោយវត្តបដិបត្តិ ធ្វើព្រះសាសនាឲ្យស្អាតចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា បាននូវអភិញ្ញា ៦ ជាអ្នកប្រាកដឈ្មោះថា សង្ឃុបដ្ឋាកៈដូចគ្នាដោយអំណាចកុសលកម្ម ដែលលោកបានធ្វើក្នុងកាលមុន ។

ថ្ងៃមួយ ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួនថា ខ្ញុំបានធ្វើកម្មអ្វីក្នុងកាលមុនហ្ន៎ ទើបបានសម្រេចលោកុត្តរសម្បត្តិនេះ ក៏ជ្រាបច្បាស់ដោយប្រចក្ស

កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ឲ្យប្រាកដ ទើបពោលពាក្យថា **វេស្សភុម្ហិ ភគវតិ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អហោសារាមិកោ អហំ** សេចក្ដីថា ខ្ញុំបានជាបុគ្គលរក្សាវត្ត ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមវេស្សភូ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចបានពោលខាងដើមហើយ និងព្រោះមានអត្ថដឹងបានងាយនោះឯង ។

**អដ្ឋកថាសង្ឃុបដ្ឋាកត្ថេរាបទាន ចប់**

**កុមុទវគ្គទី ១៨ ចប់**

# សុត្តន្តបិដក
# កុដជបុប្ផិយវគ្គទី ១៩

## កុដជបុប្ផិយត្ថេរាបទានទី ១

[ ៨១ ] ( ខ្ញុំឃើញ ) នូវព្រះផុស្សសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស ទ្រង់ឧត្តមដូចព្រះអាទិត្យ ទ្រង់ក្រឡេកមើលទិស ទ្រង់ពុទ្ធដំណើរទៅឰដ៏អាកាស ។ ខ្ញុំបានឃើញដើមខ្ទឹងគង់មានផ្ការីក ហើយបេះផ្ការីក និងផ្កាក្រពុំអំពីដើម បូជាដល់ព្រះផុស្សសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមបុប្ផិតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុដជបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កុដជបុប្ផិយត្ថេរាបទាន ចប់

# ពន្ធុជីវកត្ថេរាបទានទី ២

[ ៨២ ] ព្រះសម្ពុទ្ធព្រះនាមសោភិតៈ ជាព្រះសយម្ភូ ដែលសប្បុរសសរសើរហើយ ព្រះអង្គស្តេចចូលសមាធិ គង់នៅត្រង់ចន្លោះភ្នំ ។ ខ្ញុំកំពុងស្វែងរកផ្កាដ៏ប្រសើរ ដែលកើតក្នុងទឹកនៃជាតិស្រះ ក៏បានឃើញផ្កាច្បា ក្នុងលំដាប់ស្មើ ។ ខ្ញុំកាន់យកដោយដៃទាំងពីរ ចូលទៅគាល់ព្រះមហាមុនី ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាដល់ព្រះសោភិតសម្ពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមសមុទ្ទកប្បៈ ជាធំជាងជន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពន្ធុជីវកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ពន្ធុជីវកត្ថេរាបទាន ចប់

# កោតុម្ពរិយត្ថេរាបទានទី ៣

[ ៨៣ ] ខ្ញុំមានចិត្តរីករាយ ចូលទៅរកព្រះសិខីសម្ពុទ្ធ ទ្រង់រុងរឿង ដូចផ្កាកណិការ ដែលគង់នៅត្រង់ចន្លោះភ្នំ ដូចជាសមុទ្រប្រមាណមិនបាន ឬដូចផែនដីដ៏ក្រាស់ ព្រះអង្គមានពួកទេវតាហែហមហើយ ទ្រង់ដូចជាអាជានេយ្យដ៏ប្រសើរ ទ្រង់ជានរៈដ៏ឧត្តម ។ ខ្ញុំយកផ្កា ៧ ទង និងសំពត់រោមសត្វដែលលាយល្អ បូជាដល់ព្រះសម្ពុទ្ធ ព្រះនាមសិខី ជាលោកពន្ធុ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមមហានេលៈ ទ្រង់មានតេជះច្រើន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកោតុម្ពរិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កោតុម្ពរិយត្ថេរាបទាន ចប់**

## បញ្ចហត្ថិយត្ថេរាបទានទី ៤

[ ៨៤ ] ព្រះមានព្រះភាគ ព្រះនាមតិស្សៈ ជាច្បងក្នុងលោក ជានាយកៈ ដែលពួកសាវ័កចោមរោម ស្តេចទ្រង់ពុទ្ធដំណើរទៅក្នុងថ្នល់ ។ ខ្ញុំតាំងទុកនូវផ្កាឧប្បល ៥ ក្តាប់ ឬ ៤ ក្តាប់ ខ្ញុំជាកូននៃមាតាឈ្មោះហិតសុទ្ធិ ប្រាថ្នានឹងថ្វាយគ្រឿងបូជា ។ ខ្ញុំដែលរស្មីព្រះពុទ្ធពាល់ត្រូវហើយ បានបូជាព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចជាមាស ទ្រង់ពុទ្ធដំណើរទៅក្នុងចន្លោះរានផ្សារ ព្រះអង្គឧត្តមជាងសត្វជើង ២ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៥ ជាតិ ព្រះនាមសុលកសម្មតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចហត្ថិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បញ្ចហត្ថិយត្ថេរាបទាន ចប់**

## ឥសិមុគ្គទាយកត្ថេរាបទានទី ៩

[ ៨៥ ] ខ្ញុំបានទិមន្តព្រះបទុមុត្តរៈជានាយក ទ្រង់មានរស្មីដូច ព្រះអាទិត្យដែលទើបនឹងរះឡើង ឬដូចព្រះអាទិត្យមានរស្មីលឿង ទ្រង់ល្វាសល្វន់ ដូចដើមថ្វាន់ត្រូវខ្យល់ ។ ខ្ញុំស្ថិតនៅលើប្រាសាទ បាននិមន្តព្រះអង្គជាឥសី ដ៏ខ្ពង់ខ្ពស់ហើយ ថ្វាយផ្ទិតឃ្មុំតូច ដែលមិនមានមេ ដល់ព្រះពុទ្ធជាលោកពន្ធុ ។ ពុទ្ធសាវកមានចំនួន ៨ សែន ខ្ញុំបំពេញបាត្ររបស់ពុទ្ធសាវកទាំងអស់ឲ្យពេញ ម្យ៉ាងទៀត ខ្ញុំប្រគេននូវវត្ថុច្រើន លើសជាងនោះទៀត ។ ខ្ញុំត្រូវកុសលមូលជាស់តឿន ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ អស់មួយសែនកប្ប ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៤០០៣៨ ខ្ញុំបានកើត ជាស្តេចចក្កពត្តិ[១] ព្រះនាមមហិសមន្តៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឥសិមុគ្គទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឥសិមុគ្គទាយកត្ថេរាបទាន ចប់

---

១- ក្នុងអបទាននេះ កាលបើមានបាលីថា ចត្តាឡីសម្ហិ សហស្សេ កប្បានំ អដ្ឋតឹសតេ យ៉ាងនេះ ដោយច្រើន លោកប្រែថា ក្នុងកប្បទី ៤០០០០ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣៨ ជាតិ ។

## ពោធិឧបដ្ឋាយកត្ថេរាបទានទី ៦

[ ៨៦ ] ខ្ញុំជាអ្នកវាយសម្ភោរ ក្នុងនគររម្មវតី បានទៅប្រកបការបម្រើជានិច្ច នូវដើមពោធិព្រឹក្សដ៏ប្រសើរ ។ ខ្ញុំបម្រើល្វាចព្រឹកត្រូវកុសលមូលជាស់តឿនហើយ ក្នុងកប្បទី ១៨០០ ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ ។ ក្នុងកប្បទី ១៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ជាធំជាងជន មានព្រះនាមទមថៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិឧបដ្ឋាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ពោធិឧបដ្ឋាយកត្ថេរាបទាន ចប់

# ឯកចិន្តិកត្ថេរាបទានទី ៧

[ ៨៧ ] កាលណា ទេវតាច្យុតចាកពួកទេវតា ព្រោះអស់អាយុ សំឡេង ៣ យ៉ាង របស់ពួកទេវតា កាលអនុមោទនា តែង លាន់ឮឡើងថា ម្នាលអ្នកដ៏ចម្រើន អ្នកច្យុតអំពីទេវលោកនេះ ហើយ ទៅកាន់សុគតិ នៅជាមួយនឹងពួកមនុស្ស លុះកើតជា មនុស្សហើយ ចូរបាននូវសទ្ធាដ៏ប្រសើរ ក្នុងព្រះសទ្ធម្មចុះ សទ្ធា របស់អ្នកដែលតាំងខ្ជាប់ខ្ជួនហើយនោះ នឹងកើតជាមូល តាំងនៅ ចំពោះ ជាសទ្ធាមិនកម្រើក ក្នុងព្រះសទ្ធម្មដែលព្រះសុគតសម្តែង ល្អហើយ ដរាបដល់អស់ជីវិត ។ អ្នកត្រូវធ្វើកុសលដោយកាយ ធ្វើកុសលឲ្យច្រើនដោយវាចា ធ្វើកុសល គឺមិនព្យាបាទ មិនមាន ឧបធិដោយចិត្ត ។ តពីនោះ អ្នកត្រូវធ្វើបុណ្យនោះ ដែលខ្ជួន សន្សំហើយឲ្យច្រើន ដោយការឲ្យទាន មួយវិញទៀត ត្រូវញុំាង ពួកសត្វដទៃឲ្យតាំងនៅក្នុងព្រះសទ្ធម្ម និងព្រហ្មចរិយធម៌ ។ ទេវតា ជាអ្នកប្រាជ្ញទាំងឡាយ តែងរីករាយនឹងអ្នកដ៏ចម្រើន ដែលជា ទេវតាវិសេសដោយសេចក្តីអនុគ្រោះនេះថា ម្នាលទេវតា អ្នកចូរ មករឿយៗ ។ កាលពួកទេវតាកំពុងប្រជុំគ្នា គ្រានោះ ខ្ញុំមានសេចក្តី សង្វេគថា អាត្មាអញច្យុតចាកអត្តភាពនេះ ហើយនឹងទៅកាន់ កំណើតអ្វីហ្ន៎ ។ មានសមណៈមួយរូប មានឥន្ទ្រិយស្រគត់ស្រគំ ជ្រាបសេចក្តីសង្វេគរបស់ខ្ញុំ លោកមានប្រាថ្នានឹងស្រង់ខ្ញុំ និមន្ត មកក្នុងសម្នាក់របស់ខ្ញុំ ។ ក្នុងកាលនោះ សមណៈនោះ មាននាម

ថា សុមនៈ ជាសាវ័ករបស់ព្រះបទុមុត្តរសម្ពុទ្ធ លោកបានប្រដៅអត្ថ និងធម៌ ធ្វើឲ្យខ្ញុំកើតសង្វេគ ។ ខ្ញុំបានស្តាប់ពាក្យរបស់សមណៈនោះហើយ ក៏ញុំាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ បានថ្វាយបង្គំព្រះសម្ពុទ្ធហើយ ធ្វើកាលកិរិយាក្នុងទីនោះ ។ ខ្ញុំនោះ ត្រូវកុសលមូលដាស់តឿន ក៏ចូលទៅកើតក្នុងទេវលោកនោះដដែល ខ្ញុំមិនដែលទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកចិន្តិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ឯកចិន្តិកត្ថេរាបទាន ចប់

# តិកណ្ណិបុប្ផិយត្ថេរាបទានទី ៨

[ ៨៨ ] ខ្ញុំកើតជាទេវតា មានពួកស្រីអប្សរចោមរោម រឭកនូវបុព្វកម្ម ( របស់ខ្លួន ) ហើយរឭកនូវព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំកាន់យកផ្កាតិកណ្ណិព្រឹក្ស ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានបូជាដល់ព្រះពុទ្ធ ព្រះនាមវិបស្សី ជានរាសភៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៤ ជាតិ ព្រះនាមរមុត្តមៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិកណ្ណិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិកណ្ណិបុប្ផិយត្ថេរាបទាន ចប់**

# ឯកចារិយត្ថេរាបទានទី ៩

[ ៨៩ ] ក្នុងកាលនោះ មានសំឡេងខ្លាំង ក្នុងពួកទេវតា ស្ថានតាវត្តិង្សថា ព្រះពុទ្ធបរិនិព្វានក្នុងលោកផង ពួកយើងនៅមានរាគៈផង ។ កាលទេវតាទាំងនោះ កើតសេចក្តីសង្វេគ ប្រកបដោយសរ គឺសេចក្តីសោក ខ្ញុំជាអ្នករឹងប៉ឹងដោយកម្លាំងរបស់ខ្លួន ក៏បានទៅក្នុងសម្នាក់នៃព្រះពុទ្ធ ។ ខ្ញុំយកផ្កាមន្ទារវៈ ដែលពួកទេវតានិម្មិតជាកម្រង បានបូជាដល់ព្រះពុទ្ធក្នុងកាលដែលទ្រង់បរិនិព្វាន ។ កាលនោះ ពួកទេវតាទាំងអស់ និងពួកទេពអប្សរ ក៏ត្រេកអរចំពោះខ្ញុំ ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ អស់មួយសែនកប្ប ។ ក្នុងកប្បទី ៦០០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមមហាមល្លជនៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកចារិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកចារិយត្ថេរាបទាន ចប់

# តិវណ្ដិបុប្ផិយត្ថេរាបទានទី ១០

[ ៩០ ] យើងទាំងអស់នោះ ដើរទៅសម្លឹងមើលនូវព្រះថេរៈ ឈ្មោះអភិភូ កាលយើងទាំងអស់នោះកំពុងសំឡឹងមើល សេចក្ដីក្ដៅក្រហាយក៏កើតឡើង ។ កាលនោះ ព្រះថេរៈឈ្មោះសុនន្ទៈ ជាសាវករបស់ព្រះសម្ពុទ្ធ ព្រះនាមធម្មទស្សី ជាមហាមុនី និមន្តមកក្នុងសម្នាក់របស់ខ្ញុំ ។ ក្នុងកាលនោះ ពួកជនណា ស្និទ្ធស្នាលនឹងខ្ញុំ ពួកជននោះ បានឲ្យផ្កាមកខ្ញុំៗ ក៏យកផ្កានោះ ទៅបូជាដល់សាវក ។ ខ្ញុំនោះធ្វើកាលកិរិយាហើយ ទៅកើតក្នុងទីដដែលនោះទៀត ខ្ញុំមិនដែលទៅកើតក្នុងវិនិបាត អស់ ១៨០០ កប្ប ។ ក្នុងកប្បទី ១៣០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ៨ ជាតិ ព្រះនាមធូមកេតុដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តហើយ ។

បានឮថា ព្រះតិវណ្ដិបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិវណ្ដិបុប្ផិយត្ថេរាបទាន ចប់**

## ឧទ្ទាន

កុដជបុប្ផិយត្ថេរាបទាន ១ ពន្ធុជីវកត្ថេរាបទាន ១ កោតុម្ពរិយត្ថេរាបទាន ១ បញ្ចហត្ថិយត្ថេរាបទាន ១ ឥសិមុគ្គទាយកត្ថេរាបទាន ១ ពោធិឧបដ្ឋាយកត្ថេរាបទាន ១ ឯកចិន្តិកត្ថេរាបទាន ១ តិកណ្ណិបុប្ផិយត្ថេរាបទាន ១ ឯកចារិយត្ថេរាបទាន ១ តិវណ្ណិបុប្ផិយត្ថេរាបទាន ១ មានគាថា ៦០ ដែលលោកសម្ដែងទុកហើយ ។

### កុដជបុប្ផិយវគ្គទី ១៩ ចប់

# អដ្ឋកថា
# កុដជបុប្ផិយវគ្គទី ១៩

## កុដជបុប្ផិយត្ថេរាបទាន

[ ៨១-៩០ ] *អបទានរបស់ព្រះថេរៈ ១០ រូប មានព្រះថេរៈឈ្មោះកុដជបុប្ផយត្ថេរជាដើម ក្នុងវគ្គទី ១៩ មិនមានរឿងជាលំនាំ ព្រោះឈ្មោះដែលប្រាកដតាមបុញ្ញសម្ភារដែលធ្វើក្នុងព្រះពុទ្ធអង្គមុនៗ ក្តី វត្ថុដទៃ ដូចជានគរជាដើមក្តី របស់ព្រះថេរៈទាំងនោះ សូមជ្រាបតាមលំនាំដែលពោលមកហើយខាងដើមនោះឯង ហេតុនោះ អបទានទាំងអស់ មានអត្ថដឹងបានងាយហើយ ។*

**អដ្ឋកថាកុដជបុប្ផិយវគ្គទី ១៩ ចប់**

# សុត្តន្តបិដក

# តមាលបុប្ផិយវគ្គទី ២០

## តមាលបុប្ផិយត្ថេរាបទានទី ១

[ ៩១ ] វិមានរបស់ខ្ញុំ មានសសរ ៨៤០០០ ជាវិការនៃមាស ដែលបុញ្ញកម្មនិម្មិតឲ្យហើយ មានចំណែកប្រៀបដូចលដ្ឋិវ័នឱទ្យានរបស់ទេវតា ។ ខ្ញុំមានចិត្តជ្រះថ្លាយកផ្កាស្វាតៀ បូជាដល់ព្រះពុទ្ធព្រះនាមសិខី ជាលោកពន្ធុ ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ ព្រះអង្គ ព្រះនាមចន្ទតិត្ថៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតមាលបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

តមាលបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

# តមាលបុប្ផិយវគ្គទី ២០

## តមាលបុប្ផិយត្ថេរាបទាន

[ ៩១ ] *អបទានរបស់ព្រះថេរៈអង្គទី ១ ក្នុងវគ្គទី ២០ នេះមានអត្ថាធិប្បាយងាយយល់ហើយ ។*

អដ្ឋកថាតមាលបុប្ផិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## តិណសន្ថារទាយកត្ថេរាបទានទី ២

[ ៩២ ] ក្នុងកាលដែលខ្ញុំកើតជាឥសី នៅអាស្រ័យក្នុងព្រៃ តែងប្រួតស្មៅថ្វាយព្រះសាស្តា ស្មៅទាំងអស់នោះ ធ្លាក់ចុះលើផែនដីវិលទៅខាងស្តាំ ។ ក្នុងកាលនោះ ខ្ញុំយកស្មៅនោះ ក្រាលលើធរណីដ៏ឧត្តម ហើយខ្ញុំយកស្លឹកត្នោត ៣ បានធ្វើជាដំបូល លើកំណាត់ឈើ ៣ ដើម ថ្វាយដល់ព្រះសិទ្ធត្ថសម្ពុទ្ធ ទេវតា និងមនុស្សទាំងឡាយ ទ្រថ្វាយព្រះសាស្តាអស់ ៧ ថ្ងៃ ក្នុងទីនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយស្មៅ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្មៅ ។ ក្នុងកប្បទី ៦៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៤ ជាតិ ព្រះនាមមហទ្ធនៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសន្ថារទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិណសន្ថារទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## តិណសន្ថារទាយកត្ថេរាបទាន

[ ៩២ ] គប្បីជ្រាបអបទានរបស់ព្រះថេរៈអង្គទី ២ ដូចតទៅនេះ បទថា **យំ ទាយវាសិកោ ឥសិ** សេចក្តីថា ព្រះថេរៈដែលហៅថា ឥសី អ្នកនៅក្នុងព្រៃ ព្រោះលោកបានបួសជាឥសីក្នុងព្រៃ បានប្រូត គឺកាត់ស្មៅ ដើម្បីប្រក់មណ្ឌប ដែលជាទីប្រថាប់របស់ព្រះសាស្តា ព្រះនាមសិទ្ធត្ថៈ ដែលយាងទៅចាំវស្សាក្នុងព្រៃនោះ ដើម្បីអនុគ្រោះកុលបុត្តនោះ អធិប្បាយថា ខ្ញុំបានធ្វើដំបូលដោយឈើ ហើយធ្វើមណ្ឌបដោយកំណាត់ឈើតូចៗ យកស្មៅប្រក់មណ្ឌបនោះ បានថ្វាយ គឺបូជាដល់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។

បទថា **សត្ថាហំ ធារយុំ តត្ថ** សេចក្តីថា ពួកទេវតា និងមនុស្ស ដែលស្ថិតនៅក្នុងទីនោះ នាំគ្នាផ្គង គឺទ្រមណ្ឌបនោះដើម្បីព្រះសាស្តា ទ្រង់គង់ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

### អដ្ឋកថាតិណសន្ថារទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ខណ្ឌផុល្លិយត្ថេរាបទានទី ៣

[ ៩៣ ] ព្រះស្តូបរបស់ព្រះមានព្រះភាគ ព្រះនាមផុស្សៈ នៅក្នុងព្រៃធំ ក្នុងកាលនោះ ( ព្រះស្តូបនោះ ) ត្រូវពួកដំរីកម្ទេចហើយ ដើមឈើដុះទ្រុបទ្រុលក្នុងទីនោះ ។ ខ្ញុំធ្វើកន្លែងរដិបរដុប ( ប្រេះឆា ) ឲ្យស្មើ ហើយលាបបាយ-អ ខ្ញុំត្រេកអរដោយគុណទាំងឡាយ របស់សត្ថុក្នុងត្រៃលោក ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដុំបាយ-អ ។ ក្នុងកប្បទី ៧៧ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមជិតសេនៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះខណ្ឌផុល្លិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ខណ្ឌផុល្លិយត្ថេរាបទាន ចប់

# អដ្ឋកថា

## ខណ្ឌផុល្លិយត្ថេរាបទាន

[ ៩៣ ] គប្បីជ្រាបអបទានរបស់ព្រះថេរៈអង្គទី ៣ ដូចតទៅនេះ បទថា **ខណ្ឌំ** ក្នុងបទថា **ខណ្ឌផុល្លិយត្ថេរោ** នេះសំដៅដល់ស្ថានទីដែលមិនរាបស្មើ បាក់បែក ព្រោះឈើពុក ។ បទថា **ផុល្លំ** សំដៅដល់ ត្រង់ទីដែលបែកចេញ ដូចជាត្រង់ជ្រុងដែលប្រដាប់ប្រដាផ្ទៃ ( ស្តូប ) និងធត្រជាដើម ក្នុងទីដែលឈើទាំងឡាយពុកផុយ ។ **ខណ្ឌ** និង **ផុល្ល** រួមគ្នាជា **ខណ្ឌផុល្លានិ** ( ពុកផុយ ) ការជួសជុលឈើដែលពុកផុយ គឺធ្វើឲ្យមាំទាំ ហៅថា ការជួសជុលវត្ថុដែលបាក់បែក ។ ក្នុងកាលដែលព្រះថេរៈរូបនេះ បំពេញបុញ្ញ-សម្ភារ លោកធ្វើការបូកលាបបាយ-អត្រង់ទីដែលបែកបាក់ ត្រង់ចេតិយរបស់ព្រះមានព្រះភាគព្រះនាមផុស្សៈ ឲ្យរឹងប៉ឹង ឈ្មោះថា ជួសជុលរបស់ដែលបែកបាក់ ព្រោះហេតុនោះ ទើបព្រះថេរៈប្រាកដនាមថា ខណ្ឌផុល្លិយត្ថេរ ។៚

**អដ្ឋកថាខណ្ឌផុល្លិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អសោកបូជកត្ថេរាបទានទី ៤

[ ៩៤ ] កាលនោះ មានរាជឧទ្យាន ១ ក្នុងតិបុរាបុរី ជាទីរីករាយ ខ្ញុំជាឧយ្យានបាល ជាអ្នកស្និទ្ធស្នាលនឹងស្តេចក្នុងក្រុងនោះ ។ ព្រះសយម្ភូព្រះនាមបទុមៈ ស្តេចមក ( ក្នុងឧទ្យាននោះ ) មួប់មិនលះបង់ព្រះមុនី ទ្រង់គង់នៅក្បែរដើមស្វាយ-ស ។ ខ្ញុំឃើញដើមអសោក មានផ្ការីក មានចង្កោមគួរមើលមើល ទើបខ្ញុំបូជាដល់ព្រះពុទ្ធ ព្រះនាមបទុមៈ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមអរណញ្ជហៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអសោកបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អសោកបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## អសោកបូជកត្ថេរាបទាន

[ ៩៤ ] គប្បីជ្រាបអបទានរបស់ព្រះថេរៈអង្គទី ៤ ដូចតទៅនេះ បទថា **រញ្ញោ ពន្ធុមតោ អហំ** សេចក្ដីថា ខ្ញុំបានជាអ្នកបម្រើ គឺជាអ្នកធ្វើការងាររបស់ព្រះរាជា ។

បទថា **ជលជុត្តមនាមិនោ** សេចក្ដីថា ផ្កាដែលកើតក្នុងទឹក ឈ្មោះថា **ជលជ** ។ ជលជៈនេះ គឺផ្កាអ្វី គឺផ្កាឈូក អធិប្បាយថា ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ មានព្រះនាមស្មើដោយផ្កាបទុម ។ ម្យ៉ាងទៀត មាន អធិប្បាយថា ( ខ្ញុំបូជា ) ព្រះមានព្រះភាគព្រះនាមថាបទុមៈដ៏ឧត្ដម ៕

**អដ្ឋកថាអសោកបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អង្កោលកត្ថេរាបទានទី ៥

[ ៩៥ ] ខ្ញុំឃើញដើមអង្កោលមានផ្ការីក សំយុងចុះជារបៀបដ៏ល្អ ហើយ បេះផ្កានោះយកទៅក្នុងសម្នាក់ព្រះសម្ពុទ្ធ ។ ក្នុងសម័យនោះ ព្រះសិទ្ធត្ថមហាមុនី ទ្រង់ពួនសម្ងំ ខ្ញុំរាប់អានមួយរំពេច ហើយរោយរាយផ្កាក្នុងគុហា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៦ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ ព្រះនាមអសេកទេវគជ្ជិតៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអង្កោលកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អង្កោលកត្ថេរាបទាន ចប់

# អដ្ឋកថា

## អង្កោលកត្ថេរាបទាន

[ ៩៥ ] *អបទានទី ៥ មានអត្ថងាយយល់ហើយ ។ល។*

## អដ្ឋកថាអង្កោលកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## កិសលយបូជកត្ថេរាបទានទី ៦

[ ៩៦ ] គុម្ពផ្ការបស់ខ្ញុំនៅក្នុងក្រុងទ្វារវតី ទាំងអណ្តូងទឹក និងដើមឈើ ក៏ដុះក្នុងក្រុងនោះដែរ ព្រះសិទ្ធត្ថសម្ពុទ្ធ ទ្រង់ឈ្នះមារ ទ្រង់រឹងប៉ឹងដោយកម្លាំងព្រះអង្គ ព្រះសិទ្ធត្ថសម្ពុទ្ធនោះ ទ្រង់អនុគ្រោះចំពោះខ្ញុំ និមន្តទៅឰដ៏អាកាស ។ ខ្ញុំគន់រករបស់អ្វីមួយដទៃដែលគួរបូជា ដល់ព្រះមហេសី ស្រាប់តែឃើញត្រួយអសោក ( ខ្ញុំកាច់ ) បោះឡើងទៅឰដ៏អកាស ។ ត្រួយអសោកទាំងនោះ អណ្តែតទៅតាមក្រោយព្រះសម្ពុទ្ធ ដែលកំពុងនិមន្តទៅ ខ្ញុំឃើញហេតុអស្ចារ្យនោះហើយ សង្វេគថា ឱហ្ន៎ ភាពនៃព្រះពុទ្ធ ជាឱឡារិកណាស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយត្រួយអសោក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមឯកិស្សរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកិសលយបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កិសលយបូជកត្ថេរាបទាន ចប់**

# អដ្ឋកថា

## កិសលយបូជកត្ថេរាបទាន

[ ៩៦ ] ក្នុងបទថា **ធញ្ញេ នគរេ ទ្វារវតិយា** ឈ្មោះថា **ទ្វារវតីនគរ** ព្រោះជានគរដែលសម្បូរដោយទ្វារធំ សន្ទះបង្អួច បន្ទះក្តារច្រើន និងសម្បូរដោយរបង កំពែង ខឿន ខ្លោងទ្វារ មានទឹក និងភក់ ។ ដែលហៅថា **នគរេ ទ្វារវតិយា** ព្រោះមហាជនទាំងឡាយ រមែងហៅថា នគរទ្វារវតី ព្រោះកំណត់ឈ្មោះនគរដោយប្រើទ្វារ និងរបងជាគោល អធិប្បាយថា ខ្ញុំមានសួនផ្កា ។ បទថា **តេ កិសលយា** បានដល់ ត្រួយរបស់ដើមអសោកទាំងនោះ ។ល។

**អដ្ឋកថាកិសលយបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## តិន្ទុកទាយកត្ថេរាបទានទី ៧

[ ៩៧ ] ខ្ញុំកើតជាស្វា ជាសត្វមានកម្លាំង និងសម្ទុះត្រាច់ទៅលើភ្នំ ដែលគេទៅបានដោយកម្រ ឃើញដើមទន្លាប់មានផ្លែ ក៏នឹកព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំចេញទៅបាន ២-៣ ថ្ងៃ ពិនិត្យមើលព្រះលោកនាយក ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ចំពោះព្រះសិទ្ធត្ថសម្ពុទ្ធ ទ្រង់ដល់ទីបំផុតនៃត្រៃកព ។ ព្រះសាស្តាព្រះអង្គប្រសើរក្នុងលោក ទ្រង់ជ្រាបតម្រិះរបស់ខ្ញុំ ទើបស្តេចមកក្នុងសម្នាក់របស់ខ្ញុំ ជាមួយនឹងព្រះខីណាស្រពមួយពាន់អង្គ ។ ខ្ញុំកើតប្រាមោទ្យកាន់យកនូវផ្លែឈើ ចូលទៅគាល់ព្រះមានព្រះភាគជាសព្វញ្ញូ ទ្រង់ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ទទួល ( នូវផ្លែឈើនោះ ) ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមឧបនន្ទៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិន្ទុកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# គិរិនេលមុដ្ឋិបូជកត្ថេរាបទានទី ៨

[ ៩៨ ] ព្រះជិនស្រីមានព្រះភាគ ព្រះនាមសុមេធៈ ជាច្បងក្នុងលោក ជានាយកៈ ទ្រង់តាំងព្យាយាម ដើម្បីអនុគ្រោះពួកសត្វជាន់ក្រោយ ។ ព្រះសុមេធៈអង្គនោះ ជាធំជាងសត្វជើង ២ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ស្តេចកំពុងចង្ក្រម ខ្ញុំបូជាផ្កាគិរិនេលព្រឹក្ស[1] មួយក្តាប់ ដល់ព្រះសម្ពុទ្ធ ។ ខ្ញុំត្រូវកុសលមូលជាស់តឿន ខ្ញុំមិនដែលទៅកាន់ទុគ្គតិអស់ ៣០០០០ កប្ប ដោយចិត្តជ្រះថ្លានោះ ក្នុងកប្បទី ២៣០០ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមសុនេលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគិរិនេលមុដ្ឋិបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**គិរិនេលមុដ្ឋិបូជកត្ថេរាបទាន ចប់**

---

១- ផ្កាអញ្ចាន់ខៀវ ។

# តិកណ្ណិបុប្ផិយត្ថេរាបទានទី ៩

[ ៩៩ ] ព្រះជិនស្រីសយម្ភូទ្រង់ឈ្នះមារ ព្រះនាមសុមង្គលៈ ស្តេចចេញអំពីព្រៃ ហើយចូលទៅកាន់ទីក្រុង ។ ព្រះមុនីស្តេចទៅបិណ្ឌបាត ហើយចេញអំពីទីក្រុង លុះព្រះសម្ពុទ្ធអង្គនោះទ្រង់ធ្វើភត្តកិច្ចរួចហើយ ក៏គង់ក្នុងចន្លោះព្រៃ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្កាតិកណ្ណិព្រឹក្ស បូជាដល់ព្រះពុទ្ធ-សយម្ភូ ទ្រង់ស្វែងនូវគុណដ៏ធំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៨៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមអបសេលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិកណ្ណិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិកណ្ណិបុប្ផិយត្ថេរាបទាន ចប់**

## យូថិកបុប្ផិយត្ថេរាបទានទី ១០

[ ១០០ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ ព្រះអង្គគួរទទួលគ្រឿងបូជា ទ្រង់ចេញអំពីព្រៃហើយ ស្តេចទៅកាន់វិហារ ។ ខ្ញុំកាន់ផ្កាយូថិកាដ៏ប្រសើរ ដោយដៃទាំងពីរ យកទៅបូជាដល់ព្រះសម្ពុទ្ធ ទ្រង់មានព្រះហឫទ័យ ប្រកបដោយមេត្តា មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំបានសម្បត្តិរៀយៗ មិនដែលទៅកាន់ទុគ្គតិអស់ ១ សែនកប្ប ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៥០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គជាធំជាងជន ព្រះនាមសមិតនន្ទនៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះយូថិកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**យូថិកបុប្ផិយត្ថេរាបទាន ចប់**

## ឧទ្ទាន

តមាលបុប្ផិយត្ថេរាបទាន ១ តិណសន្ថារទាយកត្ថេរាបទាន ១ ខណ្ឌផុល្លិយត្ថេរាបទាន ១ អសោកបូជកត្ថេរាបទាន ១ អង្កោលកត្ថេរាបទាន ១ កិសលយបូជកត្ថេរាបទាន ១ តិន្ទុកទាយកត្ថេរាបទាន ១ គិរិនេលមុដ្ឋិបូជកត្ថេរាបទាន ១ តិកណ្ណិបុប្ផិយត្ថេរាបទាន ១ យូថិកបុប្ផិយត្ថេរាបទានទី ១ មានគាថា ៥៨ ។

**តមាលបុប្ផិយវគ្គទី ២០ ចប់**

មួយទៀត ឧទ្ទាន នៃវគ្គ

ភិក្ខទាយិវគ្គ ១ មហាបរិវារវគ្គ ១ សេរេយ្យវគ្គ ១ សោភិតវគ្គ ១ ឆត្តវគ្គ ១ ពន្ធជីវកវគ្គ ១ សុបារិចរិយវគ្គ ១ កុមុទវគ្គ ១ កុដជវគ្គ ១ តមាលបុប្ផិយវគ្គ ១ ត្រូវជា ១០ វគ្គ មានគាថា ៦៦៦ ។

**ភិក្ខុវគ្គទសកៈ និងទុតិយសតកៈ ចប់**

# អដ្ឋកថា

## តិកនិបាតក្តាមនាងជាដើម

[ ៩៧-១០០ ] អបទានរបស់ព្រះថេរៈទី ៧ ទី ៨ ទី ៩ មានអត្ថងាយយល់ហើយ ។ ក្នុងអបទានទី ១០ ក៏មិនមានលំនាំរឿងដូចគ្នា ។

**អដ្ឋកថាតមាលបុប្ផិយវគ្គទី ២០ ចប់**

# សុត្តន្តបិដក

# កណិការបុប្ផិយវគ្គទី ២១

## កណិការបុប្ផិយត្ថេរាបទានទី ១

[ ១០១ ] ក្នុងកាលនោះ ខ្ញុំឃើញដើមកណិការមានផ្ការីក ទើបបេះយកទៅបូជាព្រះតិស្សសម្ពុទ្ធ ទ្រង់ឆ្លងអន្លង់ហើយ មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមអរុណបាលដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកណិការបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កណិការបុប្ផិយត្ថេរាបទាន ចប់

## មិនេលបុប្ផិយត្ថេរាបទានទី ២

[ ១០២ ] ព្រះមានព្រះភាគ ព្រះនាមសិខី ទ្រង់មានវណ្ណៈដូចមាស មានរស្មីច្រើន មានពន្លឺដ៏ប្រសើរ មានមេត្តាចិត្ត មានព្រះស្មារតី ស្តេចទៅកាន់ទីចង្ក្រម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ សរសើរនូវញាណដ៏ឧត្តម ហើយយកនូវផ្កាមិនេលព្រឹក្សទៅបូជាដល់ព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៩ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គព្រះនាមសុមេឃឃនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមិនេលបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**មិនេលបុប្ផិយត្ថេរាបទាន ចប់**

# កឹកណិកបុប្ផិយត្ថេរាបទានទី ៣

[ ១០៣ ] ព្រះសព្វញ្ញូ លោកនាយក ប្រាកដស្មើដោយគ្រឿងបូជា ជាវិការនៃមាស ព្រះលោកនាយក ស្តេចចុះកាន់ទឹកស្រះ ហើយទ្រង់ស្រង់ ។ ខ្ញុំមានចិត្តត្រេកអរ មានចិត្តរីករាយ កាន់យកនូវផ្កាកណ្ដឹង ទៅបូជាដល់ព្រះវិបស្សី ជាធំជាងសត្វជើងពីរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្ប ទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិព្រះនាមកិមរថៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកឹកណិកបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កឹកណិកបុប្ផិយត្ថេរាបទាន ចប់**

# តរណិយត្ថេរាបទានទី ៤

[ ១០៤ ] ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាធំជាងសត្វជើង ២ ជានរាសភៈ មានពួកសាវ័កហែហម ស្តេចចូលទៅកាន់ឆ្នេរទន្លេគង្គា ។ ឯទន្លេគង្គា មានទឹកពេញប្រៀប ល្មមក្អែកឱនផឹកបាន ជាស្ទឹងដែលគេឆ្លងបានដោយកម្រ ខ្ញុំបានចម្លងភិក្ខុសង្ឃផង ព្រះពុទ្ធដ៏ឧត្តមជាងសត្វជើងពីរផង ។ ក្នុងកប្បទី ១៨០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លង ។ ក្នុងកប្បទី ១៣០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៥ ជាតិ ព្រះនាមសព្វោភវៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតរណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តរណិយត្ថេរាបទាន ចប់**

## និគ្គុណ្ឌិបុប្ផិយត្ថេរាបទានទី ៤

[ ១០៥ ] ខ្ញុំជាអារាមិកជន របស់ព្រះមានព្រះភាគ ព្រះនាម វិបស្សី បានយកផ្កាឈើភ្លើងទៅបូជាដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៣៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំជាងជន ព្រះនាម មហាបតាបៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនិគ្គុណ្ឌិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ចប់

## ឧទកទាយកត្ថេរាបទានទី ៦

[ ១០៦ ] ខ្ញុំឃើញ ( នូវព្រះសិទ្ធត្ថសម្ពុទ្ធ ) ជាសមណៈកំពុងឆាន់ បានដងទឹកថ្វាមិនល្អក់ ១ ក្អម ថ្វាយដល់ព្រះសិទ្ធត្ថៈ ។ ក្នុងថ្ងៃនេះ ខ្ញុំមិនមានមន្ទិល ប្រាសចាកមន្ទិល អស់សេចក្តីសង្ស័យ ក្នុងភពដែលខ្ញុំកើតហើយ ផលរមែងកើតដល់ខ្ញុំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទឹក ។ ក្នុងកប្បទី ៦១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១អង្គ ព្រះនាមវិមលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឧទកទាយកត្ថេរាបទាន ចប់**

# សលឡមាលិយត្ថេរាបទានទី ៧

[ ១០៧ ] ( ខ្ញុំបានឃើញ ) ព្រះសិទ្ធត្ថសម្ពុទ្ធ ព្រះអង្គជាសារថីទូន្មាននូវនរៈ ទ្រង់រុងរឿងដូចផ្កាកណិការ គង់នៅត្រង់ចន្លោះភ្នំ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង កាលនោះ ខ្ញុំសៀតព្រួញ ធ្វើធ្នូមិនឲ្យបែកជាពីរ បានកាច់ផ្កាទាំងទងបូជាព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥១ អំពីនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមជុតិន្ធរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡមាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សលឡមាលិយត្ថេរាបទាន ចប់

# កោរណ្ឌបុប្ផិយត្ថេរាបទានទី ៨

[ ១០៨ ] ខ្ញុំឃើញស្នាមព្រះបាទ ដែលទ្រង់ជាន់ទុក ប្រដាប់ដោយគ្រឿងអលង្ការ គឺចក្ក ហើយដើរទៅតាមលំដាប់នៃស្នាមព្រះបាទរបស់ព្រះមហេសី ព្រះនាមវិបស្សី ។ ខ្ញុំបានឃើញផ្កាស្មៅកន្ទុយដំរីរីកល្អហើយ បូជាទាំងឫស ខ្ញុំជាអ្នកមានចិត្តរីករាយ បានថ្វាយបង្គំ នូវស្នាមព្រះបាទ ដ៏ប្រសើរ ដោយចិត្តរីករាយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥៧ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមវីតមលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកោរណ្ឌបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កោរណ្ឌបុប្ផិយត្ថេរាបទាន ចប់**

# អាធារទាយកត្ថេរាបទានទី ៩

[ ១០៩ ] ខ្ញុំបានថ្វាយជើងអាធារដល់ព្រះសិទ្ធិ ជាលោកពន្ធុ ( ដោយកុសលកម្មនេះ ) ខ្ញុំទ្រទ្រង់ផែនដីទាំងមូលនេះ ។ ខ្ញុំដុតបំផ្លាញកិលេសទាំងឡាយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៤ ជាតិ ព្រះនាមសមន្តវរុណដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាធារទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អាធារទាយកត្ថេរាបទាន ចប់

## ចាបនិវារិយត្ថេរាបទានទី ១០

[ ១១០ ] ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយឆត្រ ១ ដល់ព្រះមានព្រះភាគព្រះនាមតិស្សៈ ជាទេវតារបស់ទេវតា ជាតាទិបុគ្គល ។ ខ្ញុំបានឃាត់អំពើបាប ហើយបំពេញតែអំពើកុសល ទេវតាតែងបាំងឆត្រ ( ឲ្យខ្ញុំ ) ឰដ៏អាកាស នេះជាផលនៃបុញ្ញកម្ម ។ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានថ្វាយឆត្រ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រ ។ ក្នុងកប្បទី ៧២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៨ ជាតិ ជាធំជាងជន ព្រះនាមមហានិទាន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចាបនិវារិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចាបនិវារិយត្ថេរាបទាន ចប់**

## ឧទ្ទាន

កណិការបុប្ផិយត្ថេរាបទាន ១ មិនេលបុប្ផិយត្ថេរាបទាន ១ កឹកណិកបុប្ផិយត្ថេរាបទាន ១ តរណិយត្ថេរាបទាន ១ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ១ ឧទកទាយកត្ថេរាបទាន ១ សលឡមាលិយត្ថេរាបទាន ១ កោរណ្ឌបុប្ផិយត្ថេរាបទាន ១ អាធារទាយកត្ថេរាបទាន ១ បាបនិវារិយត្ថេរាបទាន ១ មានគាថា ៤៨ ។

## កណិការបុប្ផិយវគ្គទី ២១ ចប់

# សុត្តន្តបិដក
# ហត្ថិវគ្គទី ២២

## ហត្ថិទាយកត្ថេរាបទានទី ១

[ ១១១ ] ខ្ញុំបានថ្វាយដំរីដ៏ប្រសើរ មានភ្លុក-ង មានកម្លាំង ព្យាយាមក្លាហាន ដល់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជាធំជាងសត្វជើងពីរ ជាតាទិបុគ្គល ។ ខ្ញុំបាននូវប្រយោជន៍ដ៏ឧត្តម គឺសន្តិបទដ៏ប្រសើរនេះឯង ព្រោះខ្ញុំបានថ្វាយដំរីដល់ព្រះសម្ពុទ្ធទ្រង់ស្វែងរកនូវប្រយោជន៍ ដល់សត្វលោកទាំងពួង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយដំរី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយដំរី ។ ក្នុងកប្បទី ៧៨ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមសមន្តបាសាទិកៈ ដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះហត្ថិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ហត្ថិទាយកត្ថេរាបទាន ចប់

## ធានធិទាយកត្ថេរាបទានទី ២

[ ១១២ ] ខ្ញុំបានថ្វាយស្បែកជើងដល់ឥសី អ្នកមានមេត្តាចិត្ត មានតបធម៌ នៅក្នុងព្រៃ ចម្រើនឈាន ចម្រើនធម៌ ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានរាសភៈ ខ្ញុំតែងបានទទួលនូវយាន ជាទិព្វ ដោយកម្មនោះ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បែកជើង ។ ក្នុងកប្បទី ៧៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៨ ជាតិ ព្រះនាមសុយានៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបានធិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បានធិទាយកត្ថេរាបទាន ចប់**

## សច្ចសញ្ញកត្ថេរាបទានទី ៣

[ ១១៣ ] ព្រះមានព្រះភាគ ព្រះនាមវេស្សភូ មានភិក្ខុសង្ឃចោមរោម ទ្រង់សម្តែងអរិយសច្ច ញ៉ាំងមហាជនឲ្យរលត់ទុក្ខ ។ ខ្ញុំដល់នូវសេចក្តីករុណា បានទៅកាន់ទីប្រជុំ ខ្ញុំនោះ អង្គុយស្តាប់ធម៌របស់ព្រះសាស្តា ។ លុះខ្ញុំស្តាប់ធម៌របស់ព្រះសាស្តានោះហើយ ក៏បានទៅកាន់ទេវលោក ខ្ញុំនៅក្នុងបុរី ក្នុងទេវលោកនោះអស់ ៣០ កប្ប ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសច្ចសញ្ញា ។ ក្នុងកប្បទី ២៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំជាងជន ព្រះនាមឯកផុស្សិតៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសច្ចសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សច្ចសញ្ញកត្ថេរាបទាន ចប់

# ឯកសញ្ញកត្ថេរាបទានទី ៤

[ ១១៤ ] ខ្ញុំឃើញសំពត់បង្សុកូល ដែលទើរលើចុងឈើ ក៏ផ្គង អញ្ជលី ថ្វាយសំពត់បង្សុកូលដល់ព្រះសាស្តា ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំជាងជន ព្រះនាមអមិតាភៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកសញ្ញកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកសញ្ញកត្ថេរាបទាន ចប់

# រំសិសញ្ញកត្ថេរាបទានទី ៥

[ ១១៥ ] ( ខ្ញុំបានឃើញ ) ព្រះសុជាតសម្ពុទ្ធ ទ្រង់មានរស្មីច្រើនដូចព្រះអាទិត្យដែលទើបនឹងរះ ឬដូចព្រះចន្ទមានរស្មីលឿង ព្រះអង្គប្រសើរ ដូចខ្លាធំ និងគោឧសភៈ ត្រង់ចន្លោះនៃភ្នំ ។ អានុភាពរបស់ព្រះពុទ្ធនោះ រុងរឿង ក្នុងចន្លោះភ្នំ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាក្នុងរស្មីហើយ ក៏បានទៅរីករាយក្នុងស្ថានសួគ៌ អស់ ១ កប្ប ។ ក្នុងកប្បទាំងឡាយដ៏សេស ខ្ញុំបានធ្វើកុសល ដោយចិត្តជ្រះថ្លានោះផង ដោយការរឭកពុទ្ធគុណផង ។ ក្នុងកប្បទី ៣០០០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះផលនៃសេចក្តីសម្គាល់ក្នុងព្រះពុទ្ធ ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំជាងជន ព្រះនាមសុជាតៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះរំសិសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**រំសិសញ្ញកត្ថេរាបទាន ចប់**

## សន្ធិតត្ថេរាបទានទី ៦

[ ១១៦ ] ខ្ញុំមានស្មារតី បានទូវសញ្ញា ១ ដែលតាំងនៅក្នុងព្រះពុទ្ធ ត្រង់ដើមអស្សត្ថព្រឹក្ស ដែលមានរស្មីខៀវ ដុះឡើងទ្រុបទ្រុល ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានទូវសញ្ញា ខ្ញុំដល់នូវការអស់ទៅនៃអាសវៈ ដោយអំណាចនៃសញ្ញានោះ ។ ក្នុងកប្បទី ១៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមវនិទ្ធៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសន្ធិតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សន្ធិតត្ថេរាបទាន ចប់**

# តាលវណ្ដទាយកត្ថេរាបទានទី ៧

[ ១១៧ ] ខ្ញុំបានថ្វាយផ្ចិតស្លឹកត្នោត ដល់ព្រះសម្ពុទ្ធ ព្រះនាមតិស្សៈ ទ្រង់មានទិព្វចក្ខុ ដើម្បីរម្ងាត់កម្ដៅ និងរម្ងាប់សេចក្ដីក្រហល់ក្រហាយ ។ ខ្ញុំបានរម្ងត់ភ្លើងរាគៈផង ភ្លើងទោសៈផង រម្ងត់ភ្លើងមោហៈផង ដែលជាភ្លើងក្ដៅក្រៃលែងជាងនោះ នេះជាផលនៃផ្ចិតស្លឹកត្នោត ។ ខ្ញុំដុតបំផ្លាញកិលេសទាំងឡាយ គាស់រម្លើងភពទាំងអស់ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្ចិតស្លឹកត្នោត ។ ក្នុងកប្បទី ៦៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ១ អង្គ ព្រះនាមមហារាមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតាលវណ្ដទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

តាលវណ្ដទាយកត្ថេរាបទាន ចប់

# អក្កន្តសញ្ញកត្ថេរាបទានទី ៨

[ ១១៨ ] ខ្ញុំយកសាជកអាក្រក់ ( សាជកសាច់ក្រាស់ ) ហើយសិក្សាមន្ត ក្នុងខាងមុខនៃព្រះឧបជ្ឈាយ៍ ដើម្បីដល់នូវការទម្លាយពក ។ ខ្ញុំបានឃើញព្រះពុទ្ធព្រះនាមតិស្សៈ ទ្រង់ប្រាសចាកធូលីគឺកិលេស គួរទទួលនូវគ្រឿងបូជា ព្រះអង្គខ្ពង់ខ្ពស់ ប្រសើរលើសលុប ទ្រង់ត្រាស់ដឹងនូវសច្ចៈ ឧត្តមជាងគណៈ ។ លុះខ្ញុំបានឃើញព្រះមហាវីរៈ ជានរៈដ៏ឧត្តម ខ្ពង់ខ្ពស់បំផុត ជាច្បងក្នុងលោក ជានាសកៈ ទ្រង់ជាន់សំពត់ដ៏អាក្រក់ ដែលខ្ញុំក្រាលហើយ ព្រះអង្គបំភ្លឺលោក ដូចព្រះចន្ទ្រ ទ្រង់ប្រាសចាកមន្ទិលបានថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា ដោយចិត្តជ្រះថ្លា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសាជកអាក្រក់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសាជកអាក្រក់ ។ ក្នុងកប្បទី ៣៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំជាងជន ព្រះនាមសុនន្ទៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអក្កន្តសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អក្កន្តសញ្ញកត្ថេរាបទាន ចប់**

# សប្បិទាយកត្ថេរាបទានទី ៩

[ ១១៩ ] ខ្ញុំអង្គុយក្នុងប្រាសាទដ៏ប្រសើរ មានពួកនារីចោមរោម បានឃើញព្រះសមណៈ ជាមហាវីរៈ ជាទេវតាដ៏ក្រៃលែង ជានរាសភៈ ទ្រង់មានអាពាធ ស្តេចចូលមកជិត ខ្ញុំក៏នាំមកកាន់ផ្ទះ ខ្ញុំបានថ្វាយសប្បិ និងប្រេង ដល់ព្រះសិទ្ធត្ថមហេសី ។ ខ្ញុំឃើញ ( ព្រះអង្គ ) មានក្រវល់ក្រវាយរម្ងាប់ហើយ មានមុខិន្ទ្រិយស្រស់បស់ ក៏ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា ហើយដើរទៅខាងមុខ ។ ព្រះវីរៈសមណៈ ទ្រង់ដល់នូវត្រើយនៃឫទ្ធិ ទ្រង់ឃើញខ្ញុំនោះ មានសេចក្តីជ្រះថ្លាស្មោះ ក៏ហោះឡើងកាន់អាកាស ដូចស្តេចហង្សហើរទៅឰដ៏អាកាស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសប្បិ និងប្រេង ។ ក្នុងកប្បទី ១៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមទុតិទេវៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសប្បិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សប្បិទាយកត្ថេរាបទាន ចប់

## ចាបនិវារិយត្ថេរាបទានទី ១០

[ ១២០ ] ខ្ញុំជម្រះទីចង្ក្រម បិទបាំងដោយដើមបបុស ជាគ្រឿងការពារខ្យល់ និងកម្តៅថ្ងៃ ដើម្បីព្រះមានព្រះភាគ ព្រះនាមបិយទស្សី ។ ខ្ញុំតម្កល់ទុកនូវការបំពេញកុសល ដើម្បីប្រយោជន៍ដល់ការវៀរបង់នូវបាប ដើម្បីលះបង់នូវកិលេសទាំងឡាយ ក្នុងសាសនានៃព្រះសាស្តា ។ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមអគ្គិតេជះ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបាបនិវារិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បាបនិវារិយត្ថេរាបទាន ចប់**

## ឧទ្ទាន

ហត្ថិទាយកត្ថេរាបទាន ១ បានធិទាយកត្ថេរាបទាន ១ សច្ចសញ្ញកត្ថេរាបទាន ១ ឯកសញ្ញកត្ថេរាបទាន ១ រំសិសញ្ញកត្ថេរាបទាន ១ សន្ធិតត្ថេរាបទាន ១ តាលវណ្ដទាយកត្ថេរាបទាន ១ អក្កន្តសញ្ញកត្ថេរាបទាន ១ សប្បិទាយកត្ថេរបទាន ១ បាបនិវារិយត្ថេរាបទាន ១ មានគាថា ៥៤ ។

**ហត្ថិវគ្គទី ២២ ចប់**

# សុត្តន្តបិដក
# អាលម្ពនទាយកវគ្គទី ២៣

## អាលម្ពនទាយកត្ថេរាបទានទី ១

[ ១២១ ] ខ្ញុំបានថ្វាយបង្កាន់ដៃ ដល់ព្រះមានព្រះភាគ ព្រះនាម អត្ថទស្សី ជាច្បងក្នុងលោក ទ្រង់នឹងធឹង ជាធំជាងពួកសត្វជើងពីរ ជាតាទិបុគ្គល ។ ខ្ញុំគ្រប់គ្រងផែនដីធំទល់នឹងសាគរ ញុំាងឥស្សរិយយស ឲ្យប្រព្រឹត្តទៅក្នុងពួកសត្វផង លើផែនពសុធាផង ។ ខ្ញុំដុតបំផ្លាញកិលេសទាំងឡាយហើយ គាស់រម្លើងភពទាំងពួងចោលហើយ បានដល់វិជ្ជា ៣ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ព្រោះកុសលកម្មនេះ ។ ក្នុងកប្បទី ៦២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមឯកាទស្សិតៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាលម្ពនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អាលម្ពនទាយកត្ថេរាបទាន ចប់

# អជិនទាយកត្ថេរាបទានទី ២

[ ១២២ ] ក្នុងកប្បទី ៣១ អំពីកប្បនេះ ខ្ញុំបានកើតជាបុរស អ្នកក្រាលកម្រាលសម្រាប់គណៈ បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី គឺរាគៈ គួរទទួលនូវគ្រឿងបូជា ។ ខ្ញុំបានថ្វាយកំណាត់ស្បែកខ្លាដល់ព្រះសិខី ជាលោកពន្ធុ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ជានាយសកៈ ខ្ញុំបានទទួលនូវសម្បត្តិ ហើយដុតបំផ្លាញនូវពួកកិលេស ដោយកម្មនោះ ខ្ញុំទ្រទ្រង់រាងកាយជាទីបំផុត ក្នុងសាសានារបស់ព្រះសម្មាសម្ពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយស្បែកខ្លា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្បែកខ្លា ។ ក្នុងកប្បទី ៥០ អំពីកប្បនេះ ខ្ញុំ បានកើតជាស្ដេចចក្កពត្តិ ព្រះនាមសុទាយកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអជិនទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អជិនទាយកត្ថេរាបទាន ចប់**

## ទេវតនិយត្ថេរាបទានទី ៣

[ ១២៣ ] ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគ នៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធ ទ្រង់ប្រាសចាកធូលី គឺរាគៈ គួរទទួលនូវគ្រឿងបូជា ។ ខ្ញុំបានថ្វាយដុំសាច់ដល់ព្រះវិបស្សីមហេសី ខ្ញុំបាននូវឥស្សរភាពក្នុងលោក ព្រមទាំងទេវលោក ។ រតនៈតែងកើតឡើងសម្រាប់ខ្ញុំ ដោយការថ្វាយនូវសាច់នេះ រតនៈ ២ យ៉ាងក្នុងលោក កើតដល់ខ្ញុំ ដោយចំណែកនៃផលបច្ចុប្បន្ន ។ ខ្ញុំគ្របសង្កត់នូវសត្វលោកទាំងអស់នោះ ដោយចំណែកនៃការថ្វាយសាច់ ខ្លួនរបស់ខ្ញុំទន់ភ្លន់ផង ទាំងបញ្ញា ( របស់ខ្ញុំ ) ក៏ដឹងនូវហេតុដ៏ល្អិតផង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយសាច់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃមំសទាន ។ ក្នុងកប្បទី ៤ អំពីកប្បនេះ ខ្ញុំនោះ បានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំជាងជន ព្រះនាមមហារោហិត ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទេវតនិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ទេវតនិយត្ថេរាបទាន ចប់**

**ភាណវារទី ១០ ចប់**

# អារក្ខទាយកត្ថេរាបទានទី ៤

[ ១២៤ ] ខ្ញុំឲ្យគេធ្វើបង្កាន់ដៃ ថ្វាយព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ មួយទៀត ខ្ញុំថ្វាយការរក្សាចំពោះព្រះសុគតមហេសី ។ ហេតុតែកម្មដ៏វិសេសនោះ ខ្ញុំមិនដែលជួបភ័យ ដែលគួរខ្លាចទេ ខ្ញុំដែលកើតក្នុងទីណាៗ មិនចេះមានសេចក្តីតក់ស្លុតឡើយ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យគេធ្វើបង្កាន់ដៃ ថ្វាយព្រះពុទ្ធក្នុងភពមុន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបង្កាន់ដៃ ។ ក្នុងកប្បទី ៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមអបស្សេនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអារក្ខទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អារក្ខទាយកត្ថេរាបទាន ចប់**

# អព្យាធិកត្ថេរាបទានទី ៩

[ ១២៥ ] ខ្ញុំបានថ្វាយរោងភ្លើង ដល់ព្រះមានព្រះភាគ ព្រះនាមវិបស្សីផង បានប្រគេនអាវាសសម្រាប់ទទួលទឹកក្តៅ ដល់ភិក្ខុដែលមានជំងឺផង ។ អត្តភាពរបស់ខ្ញុំដែលបុញ្ញកម្មនិម្មិតល្អហើយ ដោយកម្មណា ខ្ញុំមិនដែលស្គាល់ជំងឺ ដោយកម្មនោះ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយរោងភ្លើង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃរោងភ្លើង ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គ ជាធំជាងពួកនរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអព្យាធិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អព្យាធិកត្ថេរាបទាន ចប់**

## វក្កុលបុប្ផិយត្ថេរាបទានទី ៦

[ ១២៦ ] ខ្ញុំឈ្មោះនារទៈ តែគេស្គាល់ខ្ញុំថាកស្សបៈ ខ្ញុំបានឃើញព្រះវិបស្សីសម្ពុទ្ធ ជាកំពូលនៃពួកសមណៈ ដែលទេវតាតែងធ្វើសក្ការៈហើយ ជាព្រះពុទ្ធ ទ្រទ្រង់នូវអនុព្យញ្ជនៈ គួរទទួលនូវគ្រឿងបូជា ខ្ញុំយកផ្កាពុលបូជាដល់ព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧៤ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រព្រះនាមរោមសៈ ពាក់កម្រងផ្កា និងគ្រឿងអម្ពរប្រកបដោយយាន និងពលពាហនៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវក្កុលបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វក្កុលបុប្ផិយត្ថេរាបទាន ចប់**

# សោវណ្ណវដំសកិយត្ថេរាបទានទី ៧

[ ១២៧ ] ខ្ញុំដើរទៅកាន់ទីឧទ្យាន បានឃើញព្រះលោកនាយក ក៏កាន់ផ្កាប្រដាប់ក្បាលធ្វើដោយមាស ដែលជាធនិម្មិតល្អហើយ ។ ខ្ញុំដើរទៅដោយរួសរាន់ ឡើងជិះលើ-កដំរីហើយ បូជាដល់ព្រះពុទ្ធ ព្រះនាមសិខី ជាលោកពន្ធុ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំជាងជន ព្រះនាមមហាបតាបៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសោវណ្ណវដំសកិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សោវណ្ណវដំសកិយត្ថេរាបទាន ចប់

# មិញ្ជវដំសកិយត្ថេរាបទានទី ៨

[ ១២៨ ] កាលព្រះលោកនាថ ព្រះនាមសិទ្ធត្ថៈប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់បរិនិព្វានហើយ ខ្ញុំបានធ្វើការបូជាដើមពោធិព្រឹក្ស ដេរដាសដោយផ្កាប្រដាប់ក្បាល ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើបូជាដោយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពោធិបូជា ។ ក្នុងកប្បទី ២៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមមេឃព្ភៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមិញ្ជវដំសកិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**មិញ្ជវដំសកិយត្ថេរាបទាន ចប់**

## សុកតាវេឡិយត្ថេរាបទានទី ៩

[ ១២៩ ] ក្នុងកាលនោះ ខ្ញុំកើតជាអ្នកក្រងផ្កា ឈ្មោះអសិតៈ កាន់កម្រងផ្កាប្រដាប់ក្បាលដើរទៅ ដើម្បីនឹងថ្វាយស្តេច ។ ខ្ញុំមិនទាន់ដល់ស្តេច ក៏បានឃើញព្រះសិខីនាយក ខ្ញុំមានចិត្តរីករាយ ក៏បូជាដល់ព្រះពុទ្ធ ដោយចិត្តរីករាយ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលទៅកាន់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមវេភារៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុកតាវេឡិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុកតាវេឡិយត្ថេរាបទាន ចប់

## ឯកវន្ទនិយត្ថេរាបទានទី ១០

[ ១៣០ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ព្រះនាមវេស្សភូ ជាឧសភៈដ៏ប្រសើរ ទ្រង់មានព្យាយាម ទ្រង់ឈ្នះមារ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ ក្នុងកប្បទី ២៤ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមវិគតានន្ទៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកវន្ទនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកវន្ទនិយត្ថេរាបទាន ចប់

## ឧទ្ទាន

អាលម្ពនទាយកត្ថេរាបទាន ១ អជិនទាយកត្ថេរាបទាន ១ ទ្វេរតនិយត្ថេរាបទាន ១ អារក្ខទាយកត្ថេរាបទាន ១ អព្យាធិកត្ថេរាបទាន ១ វកុលបុប្ផិយត្ថេរាបទាន ១ សោវណ្ណវដំសកិយត្ថេរាបទាន ១ មិញ្ជវដំសកិយត្ថេរាបទាន ១ សុកតាវេឡិយត្ថេរាបទាន ១ ឯកវន្ទនិយត្ថេរាបទាន ១ មានគាថា ៥៥ ដែលពួកអ្នកប្រាជ្ញឃើញនូវប្រយោជន៍ បានរាប់ហើយ ។

**អាលម្ពនទាយកវគ្គទី ២៣ ចប់**

# អដ្ឋកថា
# បុប្ផិយវគ្គទី ២១ ជាដើម

## កណិការបុប្ផិយត្ថេរាបទាន

[ ១០១-១៣០ ] តទៅនេះ គ្រប់អបទាន ខ្ញុំពណ៌នាចំពោះបទដែលមិនជាក់ច្បាស់ ព្រះថេរៈគ្រប់អង្គក្នុងវគ្គទី ២១ , ២២ , ២៣ មានឈ្មោះតាមបុណ្យដែលលោកធ្វើមកឯង ប្លែកគ្នាត្រឹមតែបុណ្យដែលធ្វើ ។ ព្រះនាមព្រះពុទ្ធដែលព្យាករឲ្យព្រះថេរៈទាំងនោះក្តី នគររបស់លោកក្តី ជាពាក្យងាយយល់ទាំងអស់ ព្រោះបានពោលមកហើយ ។ ម្យ៉ាងទៀត អត្ថនៃគាថាក្នុងអបទាន ដឹងបានងាយតាមគន្លងន័យដែលពោលមកហើយ ដូច្នេះ ៕

**អដ្ឋកថាកណិការបុប្ផិយត្ថេរាបទាន ចប់**

**អាលម្ពនទាយកវគ្គទី ២៣ ចប់**

# សុត្តន្តបិដក
# ឧទកាសនទាយិវគ្គទី ២៤

## ឧទកាសនទាយកត្ថេរាបទានទី ១

[ ១៣១ ] ខ្ញុំចេញទៅអំពីទ្វារអារាម បានក្រាលបន្ទះក្តារផង តម្កល់ទឹកទុកផង ដើម្បីសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ក្នុងកប្ប ទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើ កុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអាសនៈ និង ទឹក ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមអភិសាមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំង ច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកាសនទាយកត្ថេរមានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឧទកាសនទាយកត្ថេរាបទាន ចប់

# ភាជនទាយកត្ថេរាបទានទី ២

[ ១៣២ ] កាលនោះ ខ្ញុំកើតជានាយស្ទូនឆ្នាំង នៅក្នុងក្រុងពន្ធុមតី បានរក្សាភាជន៍របស់ភិក្ខុសង្ឃ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានរក្សាភាជន៍ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភាជន៍ ។ ក្នុងកប្បទី ៥៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមអនន្តជលិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះភាជនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ភាជនទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

# ឧទកាសនវគ្គទី ២៤

## ឧទកាសនទាយកត្ថេរាបទានជាដើម

[ ១៣១-១៣២ ] *អបទានរឿងទី ១ ទី ២ ក្នុងវគ្គទី ២៤ មានអត្ថងាយយល់ហើយ ។*

**ឧទកាសនទាយកត្ថេរាបទានជាដើម ចប់**

# សុត្តន្តបិដក

## សាលបុប្ផិយត្ថេរាបទានទី ៣

[ ១៣៣ ] កាលនោះ ខ្ញុំកើតជាអ្នកធ្វើនំ នៅក្នុងក្រុងអរុណវតី បានឃើញព្រះជិនស្រី ព្រះនាមសិខី ស្ដេចនិមន្តតាមទ្វាររបស់ខ្ញុំ ។ ខ្ញុំមានចិត្តជ្រះថ្លា បានទទួលបាត្ររបស់ព្រះពុទ្ធ ហើយថ្វាយផ្កាសាលព្រឹក្ស ដល់ព្រះសម្ពុទ្ធ ដែលកំពុងស្ដេចទៅតាមផ្លូវតែមួយព្រះអង្គ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្កាសាល-ព្រឹក្ស ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ព្រះនាមអមិតញ្ជលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសាលបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សាលបុប្ផិយត្ថេរាបទាន ចប់

# អដ្ឋកថា

## សាលបុប្ផិយត្ថេរាបទាន

[ ១៣៣ ] គប្បីជ្រាបអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះ បទថា **អរុណវតិយា នគរេ** មានវិគ្គហៈថា ឈ្មោះថា **អរុណា** ព្រោះផុស គឺផុសឡើង ធ្វើឲ្យកើតពន្លឺដោយជុំវិញ ឈ្មោះថា **អរុណវតី** ព្រោះក្នុងនគរនោះ មានអរុណ អធិប្បាយថា ព្រះអាទិត្យរះឡើង ធ្វើឲ្យកើតពន្លឺពេញព្រះនគរនោះ ក្នុងព្រះនគរដទៃៗ ក៏មានព្រះអាទិត្យរះដូចគ្នា តែគប្បីជ្រាបថា ជាពាក្យហៅចំពោះ ដូចពាក្យថា **មហឹស** ព្រោះដេកលើផែនដី ឯសត្វជើង ៤ ទាំងអស់ ក៏ដេកលើផែនដីដូចគ្នា តែគប្បីជ្រាបថា លោកហៅថា **មហឹស** ព្រោះអត្ថរបស់សព្ទពង្រីកចេញ ។ ម្យ៉ាងទៀត ពន្លឺ ដូចជាការរះឡើងនៃព្រះអាទិត្យ ពន្លឺនៃរតនៈ ៧ ប្រការ មានមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម បញ្ចេញពន្លឺទៅក្នុងទីផ្សេងៗ ដូចជាកំពែង ប្រាសាទ និងគុហាជាដើម ក៏ឈ្មោះថា **អរុណវតី** អធិប្បាយថា ខ្ញុំបានចិញ្ចឹមជីវិតដោយការធ្វើនំលក់នៅក្នុងនគរអរុណវតីនោះឯង ។ល។

**អដ្ឋកថាសាលបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## កិលញ្ជទាយកត្ថេរាបទានទី ៤

[ ១៣៤ ] ក្នុងកាលនោះ ខ្ញុំកើតជាអ្នកត្បាញផែង នៅក្នុងតិវរបុរី ជាទីរមណីយដ្ឋាន ឯប្រជុំជន បានជ្រះថ្លាចំពោះព្រះសិទ្ធត្ថសម្ពុទ្ធ ព្រះអង្គទ្រង់បំភ្លឺលោកក្នុងទីនោះ ។ ប្រជុំជនស្វែងរកកន្ទេល ដើម្បីបូជាព្រះលោកនាថ ខ្ញុំបានឲ្យកន្ទេលដល់ពួកជនអ្នកធ្វើពុទ្ធបូជា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកន្ទេល ។ ក្នុងកប្បទី ៧៧ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមជលន្ធរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកិលញ្ជទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កិលញ្ជទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## កិលញ្ជទាយកត្ថេរាបទាន

[ ១៣៤ ] គប្បីជ្រាបអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះ បទថា **តិវរាយំ បុរេ រម្មេ** មានវិគ្គហៈថា ឈ្មោះថា **តិវរា** ព្រោះហ៊ុមព័ទ្ធជុំវិញដោយកំពែង ៣ ជាន់ ។ ឈ្មោះថា **រម្មៈ** ព្រោះជាទីត្រេកអរនៃចិត្ត ដោយគ្រឿងឧបភោគ មានរបស់ទំពា និងរបស់បរិភោគជាដើម ដោយសំពត់ និងគ្រឿងអាភរណៈជាដើម និងដោយការរាំ ការច្រៀងជាដើម ភ្ជាប់សេចក្តីថា ខ្ញុំបានជាជាងផែងក្នុងនគរតិវរា ដែលគួរជាទីត្រេកអរនៃចិត្តនោះ ។

**អដ្ឋកថាកិលញ្ជទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វេទិកាទាយកត្ថេរាបទានទី ៥

[ ១៣៥ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឲ្យគេធ្វើវេទិកា ត្រង់ដើមពោធិព្រឹក្សដ៏ប្រសើរ របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យគេកសាងវេទិកា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃវេទិកា ។ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសុរិយស្សមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវេទិកាទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វេទិកាទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## វេទិនាយកត្ថេរាបទាន

[ ១៣៥ ] *អបទានទី ៥ មានអត្ថងាយយល់ហើយ ។ ៚*

## អដ្ឋកថាវេទិនាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## វណ្ណការកត្ថេរាបទានទី ៦

[ ១៣៦ ] ក្នុងកាលនោះ ខ្ញុំកើតជាជាងជ្រលក់ ក្នុងក្រុងអរុណវតី បានជ្រលក់គ្រឿងប្រដាប់ ដាក់សំពត់ក្នុងចេតិយ ឲ្យមានពណ៌ផ្សេងៗ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានប្រជក់ពណ៌ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃវណ្ណទាន ។ ក្នុងកប្បទី ២៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមចន្ទូសមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវណ្ណការកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វណ្ណការកត្ថេរាបទាន ចប់**

# អដ្ឋកថា

## វណ្ណការកត្ថេរាបទាន

[ ១៣៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះ បទថា **វណ្ណការោ អហំ តទា** មានវិគ្គហៈថា ឈ្មោះថា **វណ្ណការ** ព្រោះរមែងធ្វើ គឺជ្រលក់សំពត់ទាំងឡាយដោយពណ៌ មានពណ៌ខៀវ លឿង និងក្រហមជាដើម អធិប្បាយថា ខ្ញុំជាជាងជ្រលក់សំពត់ ក្នុងពេលដែលយកសំពត់ទាំងឡាយស្រោមព្រះចេតិយ បានជ្រលក់សំពត់ទាំងឡាយ ឲ្យមានពណ៌ផ្សេងៗ ៕៚

**អដ្ឋកថាវណ្ណការកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បិយាលបុប្ផិយត្ថេរាបទានទី ៧

[ ១៣៧ ] ក្នុងភពមុន ខ្ញុំបានកើតជាព្រានម្រឹគ នៅក្នុងព្រៃធំ បានឃើញដើមទ្រយឹងដែលមានផ្ការីក ក៏បាចសាចទៅត្រង់ផ្លូវដើរ ។ ខ្ញុំមានចិត្តជ្រះថ្លា បានកាន់យកបាត្ររបស់ព្រះពុទ្ធ ហើយថ្វាយផ្កាទ្រយឹងដល់ព្រះពុទ្ធ ដែលទ្រង់ពុទ្ធដំណើរក្នុងផ្លូវ ( នោះ ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបិយាលបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បិយាលបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បិយាលបុប្ផិយត្ថេរាបទាន

[ ១៣៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះ បទថា **បិយាលំ បុប្ផិតំ ទិស្វា** បានដល់ ឃើញដើមទ្រយឹងមានផ្ការីកល្អ ។ បទថា **គតមគ្គេ មិគេ អហំ** សេចក្តីថា ខ្ញុំជាព្រានម្រឹគ បេះយកផ្កាទ្រយឹងមករោយបូជាត្រង់ផ្លូវយានរបស់ព្រះសម្ពុទ្ធ ។ល។

**អដ្ឋកថាបិយាលបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អម្ពយាគទាយកត្ថេរាបទានទី ៨

[ ១៣៨ ] ខ្ញុំគ្មានសេចក្តីវៃឆ្លាត ក្នុងសិប្បៈរបស់ខ្លួន បានដើរទៅក្នុងព្រៃធំ ខ្ញុំឃើញព្រះសម្ពុទ្ធ កំពុងធ្វើពុទ្ធដំណើរទៅ ក៏ថ្វាយនូវការបូជាដោយផ្លែស្វាយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាដោយផ្លែស្វាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពយាគទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អម្ពយាគទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## អម្ពយាគទាយកត្ថេរាបទាន

[ ១៣៨ ] បទថា **សកេ សិប្បេ អបត្ថទ្ធោ** សេចក្តីថា ខ្ញុំជាបុគ្គល មិនរឹងត្អឹង ជាអ្នកតាំងមាំ ឈ្លាសក្នុងសិប្បៈរបស់ខ្លួន ដូចជាតក្កសាស្ត្រ និង ព្យាករណសាស្ត្រជាដើម បានទៅកាន់ព្រៃជ្រៅ ។ បទថា **សម្ពុទ្ធំ យន្តំ ទិស្វាន** បានដល់ ជួបព្រះសម្មាសម្ពុទ្ធ ព្រះនាមវិបស្សី កំពុងយាងទៅ កាន់ដងព្រៃ ។ បទថា **អម្ពយាគំ អទាសហំ** សេចក្តីថា ខ្ញុំបានថ្វាយ ផ្លែស្វាយ ៕

**អដ្ឋកថាអម្ពយាគទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ជគតិការកត្ថេរាបទានទី ៩

[ ១៣៩ ] កាលព្រះអត្ថទស្សី ជាលោកនាថ ទ្រង់ប្រសើរជាងពួកនរៈ ព្រះអង្គបរិនិព្វានហើយ ខ្ញុំបានឲ្យគេជម្រះផែនដី ត្រង់កន្លែងព្រះស្តូបដ៏ប្រសើរ របស់ព្រះពុទ្ធ ។ ក្នុងកប្បទី ១៨០០ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផែនដី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះជគតិការកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ជគតិការកត្ថេរាបទាន ចប់

# អដ្ឋកថា

## ជគតិការកត្ថេរាបទាន

[ ១៣៩ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះ បទថា **ជគតី ការិតា មយ្ហំ** សេចក្តីថា ខ្ញុំបានសាង គឺឲ្យគេធ្វើលានដី គឺរបៀងដែលដាក់ផ្កាដែលចាត់ជាចំណែក ត្រង់ចេតិយបញ្ចុះព្រះសារីរិកធាតុរបស់ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ។ល។

**អដ្ឋកថាជគតិការកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វាសិទាយកត្ថេរាបទានទី ១០

[ ១៤០ ] ក្នុងភពមុន ខ្ញុំកើតជាជាងដែក ក្នុងក្រុងតិវរា ជាបុរីដ៏ប្រសើរ ខ្ញុំបានថ្វាយកាំបិតព្រា ១ ដល់ព្រះសយម្ភូ ទ្រង់ឈ្នះកិលេស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយកាំបិតព្រា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយកាំបិតព្រា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវាសិទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វាសិទាយកត្ថេរាបទាន ចប់**

### ឧទ្ទាន

ឧទកាសនទាយកត្ថេរាបទាន ១ ភាជនទាយកត្ថេរាបទាន ១ សាលបុប្ផិយត្ថេរាបទាន ១ កិលញ្ជទាយកត្ថេរាបទាន ១ វេទិទាយកត្ថេរាបទាន ១ វណ្ណការកត្ថេរាបទាន ១ បិយាលបុប្ផិយត្ថេរាបទាន ១ អម្ពយាគទាយកត្ថេរាបទាន ១ ជគតិការកត្ថេរាបទាន ១ វាសិទាយកត្ថេរាបទាន ១ មានគាថា ៣៨ ។

**ឧទកាសនទាយិវគ្គទី ២៤ ចប់**

# អដ្ឋកថា

## វាសិទាយកត្ថេរបទាន

[ ១៤០ ] *អបទានទី ១០ មានអត្ថងាយយល់ហើយ ។ ១៚*

**អដ្ឋកថាវាសិទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

# តុវរធាយិវគ្គធី ២៥

## តុវរដ្ឋិទាយកត្ថេរាបទានទី ១

[ ១៤១ ] ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគ នៅក្នុងព្រៃធំ ខ្ញុំបាន ឃើញផ្លែកំញានោះ មានសម្បុរក្រហម ហើយនាំយកទៅ ប្រគេនដល់ព្រះសង្ឃ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាល នោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះ ជាផលនៃគ្រាប់កំញាន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតុវរដ្ឋិទាយកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

តុវរដ្ឋិទាយកត្ថេរាបទាន ចប់

# អដ្ឋកថា
# តុវទាយិវគ្គទី ២៥

## តុវដ្ឋិទាយកត្ថេរាបទាន

[ ១៤១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ ក្នុងវគ្គទី ២៥ ដូចតទៅនេះ បទថា **ភរិត្វា តុវរមាទាយ** សេចក្តីថា ខ្ញុំបេះគ្រាប់សណ្តែកក្រហម[១] ដែលដូចគ្នានឹងគ្រាប់សណ្តែកបាយ ស្មេហើយ យកភាជនៈដាក់ទៅប្រគេនដល់ព្រះសង្ឃដែលនៅក្នុងព្រៃ ។ល។

**អដ្ឋកថាតុវដ្ឋិទាយកត្ថេរាបទាន ចប់**

១- បិដកខ្មែរគ្រាប់កំញាន ។

# សុត្តន្តបិដក

## នាគកេសរិយត្ថេរាបទានទី ២

[ ១៤២ ] ខ្ញុំធ្វើធ្នូមិនឲ្យមុតហើយ ដើរចូលទៅក្នុងព្រៃ បានឃើញដើមខ្ទឹង មានផ្ការីកកញ្ចុំ ដែលតាំងឡើងខាងចុងថ្នាំង ខ្ញុំកាន់យកដោយដៃទាំងពីរ ធ្វើអញ្ជលីលើត្បូង បានបូជាដល់ព្រះពុទ្ធ ព្រះនាមតិស្សៈ ជាលោកពន្ធុ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧៧ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមសមោត្ថរណៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគកេសរិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**នាគកេសរិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## ឆាគកេសរិយត្ថេរាបទាន

[ ១៤២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះ បទថា **ឆន្នំ អច្ចេដ្ឋំ កត្វា** សេចក្ដីថា ដាក់ព្រួញ ( ក្នុងបំពង់ ) ត្រាច់ទៅដើម្បីសម្លាប់សត្វ មានម្រឹគជាដើម ។ បទថា **កេសរំ ឱគតំ ធិស្វា** សេចក្ដីថា ឃើញដើមបុសនាគ មានផ្ការីកស្គុះស្គាយជាកម្រង ។ បទថា **ពុទ្ធស្ស អភិរោបេសឹ** សេចក្ដីថា ខ្ញុំមានចិត្តជ្រះថ្លា លើកឡើងបូជាដល់ព្រះមានព្រះភាគ ព្រះនាមតិស្សៈ ដែលយាងមកត្រង់ព្រៃ ។

**អដ្ឋកថាឆាគកេសរិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឧឡិនកេសរិយត្ថេរាបទានទី ៣

[ ១៤៣ ] ក្នុងភពមុន ខ្ញុំកើតជាសត្វមាន់ទឹក នៅក្នុងកណ្ដាលជាតស្រះ កាលនោះ ខ្ញុំបានឃើញ ( ព្រះសម្ពុទ្ធ ) ជាទេវតាដ៏ប្រសើរ កំពុងស្ដេចធ្វើពុទ្ធដំណើរទៅក្នុងអាកាស ។ ខ្ញុំមានចិត្តជ្រះថ្លា បានពាំយកកេសរ ( ផ្កាឈូក ) ដោយចំពុះ ហើយបូជាដល់ព្រះពុទ្ធ ព្រះនាមតិស្សៈ ជាលោកពន្ធុ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧៣ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ព្រះនាមសត្តបត្តៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនឡិនកេសរិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**នឡិនកេសរិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## ឆឡិនកេសរិយត្ថេរាបទាន

[ ១៤៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះ បទថា **ជលកុក្កុជោ** បានដល់ មានទឹក ត្រាច់ទៅក្នុងជាតស្រះ ។ បទថា **តុណ្ឌេន កេសរឹ គយ្ហ** សេចក្តីថា ខ្ញុំបានយកចំពុះពាំផ្កាឈូកលើកឡើងបូជាដល់ព្រះមានព្រះភាគព្រះនាមតិស្សៈ ដែលទ្រង់យាងទៅតាមអាកាស ។

**អដ្ឋកថាឆឡិនកេសរិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## វិរវិបុប្ផិយត្ថេរាបទានទី ៤

[ ១៤៤ ] ព្រះលោកនាយក ទ្រង់ធ្វើពុទ្ធដំណើរ ជាមួយនឹងព្រះខីណាស្រព ១០០០ អង្គ ខ្ញុំកាន់យកផ្កាវិរវិព្រឹក្ស ទៅបូជាដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវិរវិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វិរវិបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## វិរវិបុប្ផិយត្ថេរាបទាន

[ ១៤៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះ បទថា **វិរវបុប្ផមាទាយ** ឈ្មោះថា **វិរវ** ព្រោះរងាវ គឺធ្វើសំឡេងច្រើនសំឡេង អធិប្បាយថា ខ្ញុំបានកាន់យកសំណុំផ្កាដែលបានឈ្មោះថា **វិរវ** ព្រោះរីកក្នុងវេលា ( បក្សី ) រងាវ លើកឡើងបូជាដល់ព្រះពុទ្ធព្រះនាមថា សិទ្ធត្ថៈ ។ល។

**អដ្ឋកថាវិរវិបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## កុដិធូបកត្ថេរាបទានទី ៥

[ ១៤៥ ] ខ្ញុំជាអ្នករក្សាកុដិ របស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ខ្ញុំជ្រះថ្លា បានបង្អុយផ្សែងអប់ដោយដៃរបស់ខ្លួន អស់កាលទាំងពួង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃធូបទាន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុដិធូបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

កុដិធូបកត្ថេរាបទាន ចប់

# អដ្ឋកថា

## កុដិធូបកត្ថេរាបទាន

[ ១៨៥ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះ បទថា **កុដិគោបកោ** គឺជាអ្នករក្សាសេនាសនៈ ។ បទថា **កាលេន កាលំ ធូបេសឹ** សេចក្តីថា ខ្ញុំបានអប់ព្រះគន្ធកុដិឲ្យក្រអូប តាមកាលដែលកំណត់ អធិប្បាយថា ខ្ញុំធ្វើព្រះគន្ធកុដិឲ្យមានក្លិនក្រអូបដោយធូប អធិប្បាយថា ខ្ញុំបានអប់ក្លិនក្រអូបដោយធូប ត្រង់ព្រះគន្ធកុដិរបស់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ដោយក្លិនធូបដែលជះក្លិនក្រអូបតាមកាល ៕

**អដ្ឋកថាកុដិធូបកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បត្តទាយកត្ថេរាបទានទី ៦

[ ១៨៦ ] ខ្ញុំមានចិត្តទូន្មានដ៏ក្រៃលែង បានប្រគេនបាត្រដល់ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានព្រះហឫទ័យត្រង់ មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបាត្រ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបត្តទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បត្តទាយកត្ថេរាបទាន ចប់

# ធាតុបូជកត្ថេរាបទានទី ៧

[ ១៤៧ ] កាលព្រះលោកនាថ ព្រះនាមសិទ្ធត្ថៈ ឧត្តមជាងពួកនរៈ ទ្រង់បរិនិព្វានហើយ ខ្ញុំបានព្រះធាតុ ១ អង្គ របស់ព្រះសិទ្ធត្ថៈ ព្រះអង្គប្រសើរជាងសត្វជើងពីរ ជាតាទិបុគ្គល ។ ខ្ញុំកាន់យកព្រះធាតុនោះ របស់ព្រះពុទ្ធ ជាផៅពង្សនៃព្រះអាទិត្យ ហើយបម្រើអស់ ៥ ឆ្នាំ ដូចកាលបម្រើព្រះអង្គ ជាបុគ្គលឧត្តមជាងពួកនរៈ កាលទ្រង់គង់ព្រះជន្មនៅឡើយដែរ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះធាតុ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើព្រះធាតុ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះធាតុបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ធាតុបូជកត្ថេរាបទាន ចប់**

# អដ្ឋកថា

## បត្តទាយកត្ថេរាបទានជាដើម

[ ១៤៧-១៤៨ ] *អបទានទី ៦ និងទី ៧ មានអត្ថងាយយល់ហើយ ។ល។*

## អដ្ឋកថាបត្តទាយកត្ថេរាបទានជាដើម ចប់

# សុត្តន្តបិដក

## សត្តសត្តលិបុប្ផបូជកត្ថេរាបទានទី ៨

[ ១៤៨ ] ក្នុងកាលនោះ ខ្ញុំបានក្រងផ្កាម្ទិះរួតទាំងឡាយ ៧ កម្រង ដាក់លើក្បាល ហើយបូជាដល់ព្រះពុទ្ធ ព្រះនាមវេស្សភូ ព្រះអង្គប្រសើរជាងពួកនរៈ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តសត្តលិបុប្ផបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សត្តសត្តលិបុប្ផបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## សត្តសត្តលិបុប្ផបូជកត្ថេរាបទាន

[ ១៤៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះ បទថា **សត្ត សត្តលិបុប្ផានិ** សេចក្តីថា ខ្ញុំបានដាក់ផ្កា ៧ ដែលហៅថាផ្កាម្លិះរួត លើសិរសា លើកឡើងបូជាដល់ព្រះមានព្រះភាគ ព្រះនាមថា វេស្សភូ ។

**អដ្ឋកថាសត្តសត្តលិបុប្ផបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ពិម្ពិជាលបុប្ផិយត្ថេរាបទានទី ៩

[ ១៤៩ ] ព្រះជិនស្រីសយម្ភូ ព្រះនាមបទុមុត្តរៈ ជាអគ្គបុគ្គល ទ្រង់ប្រកាសនូវសច្ចៈ ៤ សម្តែងនូវអមតបទ គឺព្រះនិព្វាន ។ ក្នុងកាលនោះ ខ្ញុំធ្វើផ្កាពិម្ពិជាលព្រឹក្ស មានប្រមាណច្រើន បូជាដល់ព្រះពុទ្ធ ទ្រង់ជាធំជាងសត្វជើងពីរ ជាតាទិបុគ្គល ។ ក្នុងកប្បទី ៦៨ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រះនាមកិញ្ជកេសរៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពិម្ពិជាលបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ពិម្ពិជាលបុប្ផិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## ពិម្ពិជាលបុប្ផិយត្ថេរាបទាន

[ ១៨៩ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះ បទថា **ពិម្ពិជាលកបុប្ផានិ** សេចក្តីថា ខ្ញុំបានយកផ្កាពិម្ពិជាលព្រឹក្ស បូជាព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ។ល។

**អដ្ឋកថាពិម្ពិជាលបុប្ផិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឧទ្ទាលទាយកត្ថេរាបទានទី ១០

[ ១៥០ ] ព្រះសយម្ភូ ទ្រង់ឈ្នះកិលេស មាននាមថា កកុធៈ ស្តេចចេញអំពីព្រៃធំ បានដល់នូវស្ទឹងធំ ។ ក្នុងកាលនោះ ខ្ញុំមានចិត្តជ្រះថ្លា កាន់យកផ្ការាជព្រឹក្ស ថ្វាយដល់ព្រះសយម្ភូ ទ្រង់ជាអ្នកសង្រួម មានព្រះហឫទ័យត្រង់ ។ ក្នុងទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបុប្ផទាន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទ្ទាលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឧទ្ទាលទាយកត្ថេរាបទាន ចប់

### ឧទ្ទាន

តុវរដ្ឋិទាយកត្ថេរាបទាន ១ នាគកេសរិយត្ថេរាបទាន ១ នឡិនទាយកត្ថេរាបទាន ១ វិរវិបុប្ផិយត្ថេរាបទាន ១ កុដិធូបកត្ថេរាបទាន ១ បត្តទាយកត្ថេរាបទាន ១ ធាតុបូជកត្ថេរាបទាន ១ សត្តសត្តលិបុប្ផិយត្ថេរាបទាន ១ ពិម្ពិជាលបុប្ផិយត្ថេរាបទាន ១ ឧទ្ទាលទាយកត្ថេរាបទាន ១ មានគាថា ៣៧ ដែលអ្នកប្រាជ្ញទាំងឡាយបានគណនាហើយ ។

តុវរទាយិវគ្គទី ២៥ ចប់

# អដ្ឋកថា

## ឧក្កាលទាយកត្ថេរាបទាន

[ ១៥០ ] *គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១០ ដូចតទៅនេះ បទថា* **ឧក្កាលកំ គហេត្វាន** *សេចក្តីថា ខ្ញុំបានបេះយកផ្កាវាជព្រឹក្ស ដែលដុះក្បែរជាតស្រះ មកបូជាព្រះមានព្រះភាគ ព្រះនាមកកុសន្ធៈ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយនោះឯង ។*

**អដ្ឋកថាឧក្កាលទាយកត្ថេរាបទាន ចប់**

**តុវរទាយិវគ្គទី ២៥ ចប់**

# សុត្តន្តបិដក
# ថេរាបទាន
# ថោមកវគ្គទី ២៦

## ថោមកត្ថេរាបទានទី ១

[ ១៥១ ] ខ្ញុំជាទេវតា ស្ថិតនៅក្នុងទេវលោក បានស្តាប់ធម៌របស់ព្រះពុទ្ធ ជាមហេសី ព្រះនាមវិបស្សី មានចិត្តរីករាយ ហើយបានពោលនូវវាចានេះថា បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គ ជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ព្រះអង្គសម្តែងនូវអមតបទ គឺព្រះនិព្វានតែងចម្លងជនច្រើន ( ឲ្យដល់នូវត្រើយ គឺព្រះនិព្វាន ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះដែលខ្ញុំបានពោលវាចា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះថោមកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ថោមកត្ថេរាបទាន ចប់

# អដ្ឋកថា

# ថោមកវគ្គទី ២៦

## ថោមកត្ថេរាបទាន

[ ១៥១ ] *អបទានទី ១ ក្នុងវគ្គទី ២៦ មានអត្ថងាយយល់ហើយ ៕*

### អដ្ឋកថាថោមកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឯកាសនទាយកត្ថេរាបទានទី ២

[ ១៥២ ] ខ្ញុំ ព្រមទាំងភរិយា បានលះបង់នូវភេទនៃទេវតា ហើយមកក្នុងមនុស្សលោកនេះ ប្រាថ្នានឹងធ្វើនូវការកសាង ក្នុងសាសនារបស់ព្រះពុទ្ធដ៏ប្រសើរ ។ មានសាវ័ករបស់ព្រះបទុមុត្តរៈ ឈ្មោះទេវលៈ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយភិក្ខាដល់ព្រះទេវលៈនោះ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបិណ្ឌបាត ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកាសនទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ឯកាសនទាយកត្ថេរាបទាន

[ ១៥២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះ បទថា **វិជហិត្វា ទេវវណ្ណំ** សេចក្តីថា លះនូវសរីរៈទេវតា កាឡាខ្លួនជាមនុស្ស ។ បទថា **អធិការំ កត្តុកាមោ** សេចក្តីថា ខ្ញុំជាទេវរាជ នាមថា ទេវរៈ មួយអន្លើដោយកិរិយា មានបំណងនឹងធ្វើអធិការ គឺបុញ្ញសម្ភារ ព្រោះមានសេចក្តីជ្រះថ្លា ក្នុងព្រះសាសនារបស់ព្រះពុទ្ធដ៏ប្រសើរ ទើបបានទាំគ្នាមកក្នុងមនុស្សលោកនេះ ។ បទថា **តស្ស ភិក្ខា មយា ទិន្នា** សេចក្តីថា ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយភិក្ខា គឺបិណ្ឌបាតដល់សាវ័ករបស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ដែលលោកមានឈ្មោះថា ទេវលៈ ។ល។

**អដ្ឋកថាឯកាសនទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចិតកបូជកត្ថេរាបទានទី ៣

[ ១៥៣ ] ព្រះសយម្ភូសម្ពុទ្ធ ទ្រង់ឈ្នះកិលេស ព្រះនាមអានន្ទ ទ្រង់បរិនិព្វានក្នុងព្រៃធំ ដែលមិនមានមនុស្ស ។ ក្នុងកាលនោះ ខ្ញុំចុះអំពីទេវលោក មកក្នុងទីនេះ ធ្វើជើងក្ដារបូជាសរីរៈផង ធ្វើសក្ការៈផង ក្នុងព្រៃនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចិតកបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## ចិតកបូជកត្ថេរាបទាន

[ ១៥៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះ បទថា **អានន្ទោ នាម សម្ពុទ្ធោ** សេចក្ដីថា ព្រះបច្ចេកសម្ពុទ្ធ ព្រះនាមអានន្ទៈ ព្រោះញ៉ាំងនូវការត្រេកអរ គឺការត្រេកអរឲ្យកើតឡើងដល់មហាជន ។ បទថា **អមនុស្សម្ហិ កាននេ** សេចក្ដីថា ទ្រង់បរិនិព្វានហើយក្នុងព្រៃ គឺក្នុងព្រៃធំ មានពួកអមនុស្សគ្រប់គ្រង គឺអន្តរធានទៅហើយ ដោយអនុបាទិ-សេសនិព្វានធាតុ បានដល់ ដល់នូវការមើលមិនឃើញ ។ បទថា **សរីរំ តត្ថ ឈាបេសឹ** សេចក្ដីថា ខ្ញុំមកអំពីទេវលោក ក្នុងមនុស្សលោកនេះ បានធ្វើជើងថ្ករហើយ ថ្វាយព្រះភ្លើងព្រះសរីរៈរបស់ព្រះបច្ចេកសម្ពុទ្ធអង្គនោះ ក្នុងព្រៃនោះ ។l៚

**អដ្ឋកថាចិតកបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចម្បកបុប្ផិយត្ថេរាបទានទី ៤

[ ១៥៤ ] មានភ្នំឈ្មោះវិកនៈ នៅជិតព្រៃហិមពាន្ត មានសមណៈ ១ អង្គ មានឥន្ទ្រិយស្រគត់ស្រគំ គង់នៅកណ្ដាលភ្នំនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា បានឃើញសេចក្ដីស្ងប់រម្ងាប់របស់សមណៈនោះ ទើបកាន់ផ្កាចម្ប៉ា ៣ ទង ចូលទៅរោយរាយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចម្បកបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចម្បកបុប្ផិយត្ថេរាបទាន ចប់

# សត្តបាដលិយត្ថេរាបទានទី ៩

[ ១៥៥ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ មានរស្មីរុងរឿង ដូចផ្កាកណិការ ទ្រង់គង់ត្រង់ចន្លោះភ្នំ ខ្ញុំបានថ្វាយផ្កាប្រទៀង ៧ ទង ដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តបាដលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

*សត្តបាដលិយត្ថេរាបទាន ចប់*

# អដ្ឋកថា

## ចម្បកបុប្ផិយត្ថេរាបទានជាដើម

[ ១៥៤-១៥៥ ] *អបទានទី៤ និងទី៥ មានអត្ថងាយយល់ហើយ ។*

## អដ្ឋកថាចម្បកបុប្ផិយត្ថេរាបទានជាដើម ចប់

# សុត្តន្តបិដក

## ឧបាហនទាយកត្ថេរាបទានទី ៦

[ ១៥៦ ] ក្នុងកាលនោះ ខ្ញុំឈ្មោះចន្ទនៈ ជាបុត្តរបស់ព្រះសម្ពុទ្ធ ខ្ញុំថ្វាយស្បែកជើងមួយសម្រាប់ ( ដោយបំណងថា ) សូមព្រះអង្គញុំាងពោធិញ្ញាណឲ្យសម្រេចដល់ខ្ញុំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយស្បែកជើង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បែកជើង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបាហនទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឧបាហនទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ឧទាហានទាយកត្ថេរាបទាន

[ ១៥៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះ បទថា **អហោសិ ចន្ទនោ នាម** បានដល់ ឈ្មោះថា ចន្ទនៈ ក៏ដោយអំណាចឈ្មោះតាមដែលដាក់ឲ្យ ។ បទថា **សម្ពុទ្ធស្សត្រជោ** សេចក្តីថា មុនពេលដែលលោកជាព្រះបច្ចេកសម្ពុទ្ធ ខ្ញុំកើត គឺជាកូនរបស់លោក ។ បទថា **ឯកោទាហានោ មយា ទិន្នោ** សេចក្តីថា ខ្ញុំបានប្រគេនស្បែកជើងមួយគូ ។ បទថា **ពោធឹ សម្បជ្ជ មេ តុវំ** សេចក្តីថា ដោយការដែលខ្ញុំបានប្រគេនស្បែកជើងមួយគូនោះ សូមលោកម្ចាស់ឲ្យខ្ញុំបានសម្រេចសាវកពោធិញ្ញាណចុះ ។ល។

**អដ្ឋកថាឧទាហានទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## មញ្ជរិបូជកត្ថេរាបទានទី ៧

[ ១៥៧ ] ខ្ញុំធ្វើនូវផ្កាមញ្ជរិព្រឹក្ស ( លើក្បាល ) ហើយដើរទៅកាន់ច្រក បានឃើញព្រះសម្ពុទ្ធដ៏ប្រសើរ លើសជាងពួកសមណៈមានពួកភិក្ខុសង្ឃចោមរោមហើយ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ដោយបីតិយ៉ាងក្រៃលែង ហើយកាន់យកដោយដៃទាំងពីរ បូជាចំពោះព្រះពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ ក្នុងកប្បទី ៧៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាធំលើផែនដី ព្រះនាមជោតិយៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមញ្ជរិបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មញ្ជរិបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## មញ្ចវិប្ជកត្ថេរាបទាន

[ ១៥៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះ បទថា **មញ្ចលិកំ ករិត្វាន** សេចក្ដីថា ខ្ញុំកាន់យកប្រអប់ផ្កា គឺប្រអប់ផ្កាស្រស់ ដើរទៅតាមផ្លូវនោះឯង ។ បទថា **ភិក្ខុ សង្ឃបុរក្ខតំ** បានដល់ ចោមរោមដោយពួកនៃភិក្ខុ ។ បទថា **សមណានគ្គំ** ភ្ជាប់សេចក្ដីថា ខ្ញុំបានឃើញព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ជាងសមណៈទាំងឡាយ គឺជាងភិក្ខុទាំងឡាយ ។ បទថា **ពុទ្ធស្ស អភិរោបយឹ** សេចក្ដីថា កាលខ្ញុំបានឃើញហើយ បានយកដៃទាំងពីរផ្គងលើកផ្កានោះឡើង បូជាដល់ព្រះមានព្រះភាគ ព្រះនាមថា ផុស្សៈ ។

**អដ្ឋកថាមញ្ចវិប្ជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បណ្ណទាយកត្ថេរាបទានទី ៨

[ ១៥៨ ] ខ្ញុំស្លៀកសំពត់សម្បកឈើ នៅជិតភ្នំហិមពាន្ត ជាអ្នកបរិភោគស្លឹកឈើ មិនមានរសប្រៃផង សង្រួមក្នុងការប្រព្រឹត្តទាំងឡាយផង ។ ក្នុងពេលបាយព្រឹក ព្រះសិទ្ធត្ថសម្ពុទ្ធ ស្តេចចូលមករកខ្ញុំ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយចង្ហាន់ស្លឹកឈើនោះដល់ព្រះសម្ពុទ្ធ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយស្លឹកឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្លឹកឈើ ក្នុងកប្បទី ២៧ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមយទត្ថិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបណ្ណទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បណ្ណទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## បណ្ណទាយកត្ថេរាបទាន

[ ១៥៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះ បទថា **អលោណបណ្ណភក្ខោម្හិ** សេចក្ដីថា ខ្ញុំនាំយកទឹកដោះ និងស្លឹកឈើជាដើម មកដើម្បីជាអាហាររស់នៅ ស្ងោរស្លឹកឈើដែលប្រាសចាករសប្រៃបរិភោគជាអាហារ អធិប្បាយថា ខ្ញុំមានស្លឹកឈើរសមិនប្រៃ ជាអាហារចិញ្ចឹមជីវិត ។ បទថា **និយមេសុ ច សំវុតោ** សេចក្ដីថា សង្រួមក្នុងសីល ៥ មានវៀរចាកបាណាតិបាតជាដើមជានិច្ច ដែលសត្វលោកនិយមសង្រួមហើយ ។ បទថា **បាតរាសេ អនុប្បត្តេ** គឺកាលដល់វេលាបរិភោគបាយអាហារព្រឹក ។ បទថា **សិទ្ធត្ថោ ឧបគច្ឆិ មំ** សេចក្ដីថា ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ យាងមករក គឺចូលមកជិតខ្ញុំហើយ ។ បទថា **តាហំ ពុទ្ធស្ស បាទាសិំ** សេចក្ដីថា ខ្ញុំបានថ្វាយស្លឹកឈើដែលមិនប្រៃនោះ ដល់ព្រះមានព្រះភាគអង្គនោះឯង ។ល។

**អដ្ឋកថាបណ្ណទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## កុដិទាយកត្ថេរាបទានទី ៩

[ ១៥៩ ] កាលនោះ ព្រះសម្ពុទ្ធស្តេចទៅក្នុងព្រៃ គង់នៅទៀបគល់ឈើ ខ្ញុំក៏បានធ្វើបណ្ណសាលាថ្វាយដល់ព្រះសម្ពុទ្ធ ទ្រង់ឈ្នះកិលេស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយបណ្ណកុដិ ( តូបស្លឹក ) ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយកុដិ ។ ក្នុងកប្បទី ៣៨ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១៦ ជាតិ ព្រះនាមអភិវស្សិដូចគ្នាក្នុងលោកទាំងមូល ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុដិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**កុដិទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## កុដិទាយកត្ថេរាបទាន

[ ១៥៩ ] *អបទានទី ៩ មានអត្ថងាយយល់ហើយ ។*

## អដ្ឋកថាកុដិទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## អគ្គបុប្ផិយត្ថេរាបទានទី ១០

[ ១៦០ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គង់នៅចន្លោះភ្នំ ទ្រង់ភ្លឺស្វាងដោយរស្មី ដូចអណ្តាតភ្លើង ។ ខ្ញុំកាន់យកផ្កាវក្ខជាតិ ដែលរីកមុនគេ ហើយចូលទៅរកព្រះសម្ពុទ្ធដ៏ប្រសើរជាងពួកនរៈ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិព្រះនាមមិត្តឃាតកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអគ្គបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អគ្គបុប្ផិយត្ថេរាបទាន ។

## ឧទ្ទាន

ថោមកត្ថេរាបទាន ១ ភិក្ខាទាយកត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ១ ចម្បកបុប្ផិយត្ថេរាបទាន ១ សត្តបាដលិយត្ថេរាបទាន ១ ឧបាហនទាយកត្ថេរា-បទាន ១ មញ្ជរិបូជកត្ថេរាបទាន ១ បណ្ណទាយ-កត្ថេរាបទាន ១ កុដិទាយកត្ថេរាបទាន ១ អគ្គបុប្ផិ-យត្ថេរាបទាន ១ មានគាថា ៤១ ដែលអ្នកប្រាជ្ញរាប់ហើយ ក្នុងវគ្គនេះ ។

### ថោមកវគ្គទី ២៦ ចប់

# អដ្ឋកថា

## អគ្គបុប្ផិយត្ថេរាបទាន

[ ១៦០ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១០ ដូចតទៅនេះ បទថា **សិទ្ធិំ សិទ្ធិំ យថា** សេចក្តីថា ខ្ញុំបានឃើញព្រះមានព្រះភាគព្រះនាមសិខី ទ្រង់រុងរឿងដោយព្រះឆព្វណ្ណរង្សី ដែលផ្សាយចេញអំពីព្រះសរីរៈ ដែលជាប្រធាននៃរស្មីក្រៃលែងជាងរស្មីទាំងឡាយ ដូចគ្នានឹងគំនរភ្លើងដែលឆេះសន្ធោសន្ធៅ ដូច្នោះ ។ បទថា **អគ្គជំ បុប្ផមាទាយ** សេចក្តីថា ខ្ញុំបានកាន់យកផ្កាព្រុក្ខជាតិរីកមុនគេ លើកឡើងបូជាដល់ព្រះពុទ្ធមានព្រះភាគព្រះនាមសិខី ។ល។

**អដ្ឋកថាអគ្គបុប្ផិយត្ថេរាបទាន ចប់**

**ជោមកវគ្គទី ២៦ ចប់**

# សុត្តន្តបិដក
# បន្ទុមុក្ខេបវគ្គទី ២៧

## អាកាសុក្ខិបិយត្ថេរាបទានទី ១

[ ១៦១ ] ខ្ញុំ ( បានឃើញ ) ព្រះសិទ្ធត្ថសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស កំពុងនិមន្តទៅត្រង់ចន្លោះរានផ្សារ ក៏កាន់យកផ្កាឈូក ២ ទង ចូលទៅរកព្រះពុទ្ធ ជានរាសភៈ ។ ខ្ញុំដាក់ចុះនូវផ្កា ១ ទង ទៀបព្រះបាទានៃព្រះពុទ្ធដ៏ប្រសើរ ហើយកាន់យកនូវផ្កា ១ ទង បោះឡើងទៅនាអាកាស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កា ។ ក្នុងកប្បទី ៣២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាម្ចាស់ផែនដី ព្រះនាមអន្តលិក្ខករៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាកាសុក្ខិបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អាកាសុក្ខិបិយត្ថេរាបទាន ចប់

# អដ្ឋកថា

# បទុមុក្ខេបវគ្គទី ២៧

## អាកាសុក្ខិបិយត្ថេរាបទាន

[ ១៦១ ] *គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ វគ្គទី ២៧ ដូចតទៅនេះ បទថា* **ជលជគ្គេ ទុវេ គយ្ហ** *សេចក្ដីថា ខ្ញុំបានកាន់យកផ្កាឈូកជាដើម ២ ផ្កា ដែលកើតក្នុងទឹក ជាផ្កាដ៏ប្រសើរ ទៅជិតព្រះពុទ្ធ ដាក់បូជាទៀបព្រះបាទា ១ ផ្កា មួយផ្កាទៀត បានបោះឡើងលើអាកាស ។*

**អដ្ឋកថាអាកាសុក្ខិបិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## គោលមក្ខិយត្ថេរាបទានទី ២

[ ១៦២ ] កាលព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជានាយកៈ បរិនិព្វានហើយ ក្នុងកាលនោះ ខ្ញុំបានលាបប្រេងត្រង់ខឿនពោធិព្រឹក្ស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានលាបប្រេង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការលាបប្រេង ។ ក្នុងកប្បទី ២៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមសុច្ឆវិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគោលមក្ខិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**គោលមក្ខិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## តេលមក្ខិយត្ថេរាបទាន

[ ១៦២ ] *អបទានទី ២ មានអត្ថប្រាកដច្បាស់ហើយ ។*

## អដ្ឋកថាតេលមក្ខិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## អឡ្ហចន្ទិយត្ថេរាបទានទី ៣

[ ១៦៣ ] ខ្ញុំបានថ្វាយក្បាច់អឡ្ហចន្ទ ចំពោះពោធិព្រឹក្សដ៏ឧត្តម របស់ព្រះមានព្រះភាគ ព្រះនាមតិស្សៈ ដែលជាឈើដុះលើធរណី ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយអឡ្ហចន្ទ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាពោធិព្រឹក្ស ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមតេវលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអឡ្ហចន្ទិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អឡ្ហចន្ទិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## អឌ្ឍចន្ទិយត្ថេរាបទាន

[ ១៦៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះ បទថា **ពោធិយា បាទបុត្តមេ** បានដល់ ដើមពោធិព្រឹក្សដ៏ប្រសើរ ។ បទថា **អឌ្ឍចន្ទំ មយា ទិន្នំ** សេចក្ដីថា ខ្ញុំបានយកផ្កាជាច្រើនបូជា ដោយធ្វើរូបព្រះចន្ទពាក់កណ្ដាល ត្រង់ពោធិព្រឹក្សនោះ ។ បទថា **ធរណីរុហបាទបេ** សេចក្ដីថា ឈ្មោះថា **ធរណី** ព្រោះទទួលនូវដើមឈើ ភ្នំ និងរតនៈជាដើមជាច្រើន បានដល់ ផែនដី ។ ឈ្មោះថា **ធរណីរុហ** ព្រោះដុះឡើង ហើយតាំងនៅលើផែនដី ។ ឈ្មោះថា **បាទប** ព្រោះផឹកទឹកដោយឫស គឺគល់ដើម ហើយផ្សាយទៅតាមដើម និងប្រគាបជាដើម **ធរណីរុហ** សព្ទ និង **បាទប** សព្ទ រួមជា **ធរណីរុហបាទប** អធិប្បាយថា ខ្ញុំបានយកផ្កាបូជាត្រង់ដើមពោធិព្រឹក្សនោះ ៕

**អដ្ឋកថាអឌ្ឍចន្ទិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ទីបទាយកត្ថេរាបទានទី ៤

[ ១៦៤ ] ក្នុងកាលនោះ ខ្ញុំកើតជាទេវតា ចុះមកកាន់ផែនដី មានចិត្តជ្រះថ្លា បានថ្វាយប្រទីប ៥ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយប្រទីប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយប្រទីប ។ ក្នុងកប្បទី ៥៥ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាម្ចាស់ផែនដី ព្រះនាមសមន្តចក្ខុ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះទីបទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ទីបទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ធីបទាយកត្ថេរាបទាន

[ ១៦៤ ] *អបទានទី ៤ មានអត្ថងាយយល់ហើយនោះឯង ។ល។*

## អដ្ឋកថាធីបទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## វិឡាលិទាយកត្ថេរាបទានទី ៩

[ ១៦៥ ] មានភ្នំមួយ ឈ្មោះរោមសៈ នៅជិតព្រៃហិមពាន្ត ព្រះពុទ្ធជាសមណៈមួយអង្គ មានឥន្ទ្រិយស្រគត់ស្រគំ ( គង់នៅ ) ក្បែរជើងភ្នំនោះ ។ ខ្ញុំយកដំឡូងដៃខ្លា ទៅប្រគេនព្រះសមណៈ ឯព្រះសយម្ភូ ជាមហាវីរៈ ទ្រង់ឈ្នះកិលេស បានអនុមោទនាថា អ្នកមានចិត្តជ្រះថ្លា បានថ្វាយដំឡូងដៃខ្លាដល់តថាគត ផលតែងកើតឡើងដល់អ្នក ក្នុងភពដែលអ្នកកើត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយដំឡូង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដំឡូងដៃខ្លា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិ ហើយ ។

បានឮថា ព្រះវិឡាលិទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**វិឡាលិទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## វិធុរាលិទាយកត្ថេរាបទាន

[ ១៦៥ ] *គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះ បទថា* **ហិមវន្តស្សាវិទូរេ** *បានដល់ ក្បែរហិមវន្តបព៌ត ។ បទថា* **រោមសោ នាម បព្វតោ** *សេចក្ដីថា មានភ្នំឈ្មោះរោមសៈ ព្រោះដេរដាសដោយស្បូវក្លាំងជាដើមសុទ្ធៗ មិនមានដើមឈើ និងវល្លិគ្របដណ្ដប់ ។ បទថា* **តម្ហិ បព្វតបាទម្ហិ** *បានដល់ ត្រង់ជើងភ្នំនោះ ។ បទថា* **សមណោ ភាវិតិន្ទ្រិយោ** *សេចក្ដីថា សមណៈដែលមានបាបស្ងប់រម្ងាប់ហើយ ជាអ្នកមានកិលេសស្ងប់ហើយ មានឥន្ទ្រិយចម្រើនហើយ គឺរក្សាឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើមបានយ៉ាងល្អ ។ម្យ៉ាងទៀត អធិប្បាយថា សមណៈអ្នកចម្រើនឥន្ទ្រិយ គឺចម្រើនឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើមបានយ៉ាងល្អ អធិប្បាយថា ខ្ញុំបានកាន់យកដំឡូងដៃខ្លា ថ្វាយដល់ព្រះសមណៈអង្គនោះឯង ។*

### អដ្ឋកថាវិធុរាលិទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## មច្ឆទាយកត្ថេរាបទានទី ៦

[ ១៦៦ ] ក្នុងកាលនោះ ខ្ញុំកើតជាសត្វអក នៅលើឆ្នេរស្ទឹងចន្ទភាគា ខ្ញុំបានយកត្រីដ៏ធំ ថ្វាយដល់ព្រះមុនី ព្រះនាមសិទ្ធត្ថៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយត្រី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយត្រី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមច្ឆទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មច្ឆទាយកត្ថេរាបទាន ចប់

# ជវហង្សកត្ថេរាបទានទី ៧

[ ១៦៧ ] កាលនោះ ខ្ញុំត្រាច់ទៅក្នុងព្រៃ ក្បែរឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈ និមន្តទៅឰដ៏អាកាស ។ ខ្ញុំផ្គងអញ្ជលី ហើយក្រឡេកមើលព្រះមហាមុនី ហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានថ្វាយបង្គំព្រះលោកនាយក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំនូវព្រះនរាសភៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះជវហង្សកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ជវហង្សកត្ថេរាបទាន ចប់

## សលឡបុប្ផិយត្ថេរាបទានទី ៨

[ ១៦៨ ] ក្នុងកាលនោះ ខ្ញុំកើតជាកិន្នរ នៅក្បែរឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់បរិបូណ៌ដោយបណ្ដាញ គឺរស្មី ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ដោយបីតិយ៉ាងក្រៃលែង បានកាន់យកផ្កាស្រល់ រោយរាយថ្វាយចំពោះព្រះវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សលឡបុប្ផិយត្ថេរាបទាន ចប់

## ឧបាគតហាសនិយត្ថេរាបទានទី ៩

[ ១៦៩ ] មានស្រះដែលធម្មតានិម្មិតល្អហើយ នៅកណ្តាលព្រៃហិមពាន្ត ឯខ្ញុំកើតជាអារក្ខទឹកក្នុងស្រះនោះ ជាអ្នកមានក្បាលសំយុងចុះ គួរខ្លាច ។ ព្រះលោកនាយក ព្រះនាមវិបស្សី ទ្រង់មានសេចក្តីអនុគ្រោះ មានសេចក្តីករុណា ប្រាថ្នានឹងស្រង់ខ្ញុំ ព្រះអង្គស្តេចនិមន្តមក ក្នុងសម្នាក់របស់ខ្ញុំ ។ ខ្ញុំ ( ឃើញ ) ព្រះមហាវីរៈ ជាទេវតាដ៏ក្រៃលែង ទ្រង់ជានរាសភៈ ស្តេចចូលមកហើយ ទើបខ្ញុំចេញអំពីលំនៅ បានថ្វាយបង្គំចំពោះព្រះសាស្តា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំព្រះសម្ពុទ្ធ ជាបុរសប្រសើរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបាគតហាសនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឧបាគតហាសនិយត្ថេរាបទាន ចប់**

# តរណិយត្ថេរាបទានទី ១០

[ ១៧០ ] ព្រះសម្ពុទ្ធលោកនាយក ជាសាស្តា ព្រះនាមវិបស្សី មានវណ្ណៈដូចមាស មានកិក្ខុសង្ឃចោមរោម ទ្រង់ស្ថិតនៅនាត្រើយស្ទឹង ។ ឯនាវាសម្រាប់ចម្លងក្នុងស្ទឹង ដែលមានអន្លង់ជំនោះ ក៏មិនមាន ទើបខ្ញុំចេញអំពីស្ទឹង មកចម្លងព្រះលោកនាយក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានចម្លងព្រះនរុត្តមសម្មាសម្ពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការចម្លង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតរណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តរណិយត្ថេរាបទាន**

## ឧទ្ទាន

អាកាសុក្ខិបិយត្ថេរាបទាន ១ តេលមក្ខិយត្ថេរាបទាន ១ អឌ្ឍចន្ទិយត្ថេរាបទាន ១ ទីបទាយកត្ថេរាបទាន ១ វិឡាលិទាយកត្ថេរាបទាន ១ មច្ឆទាយកត្ថេរា-បទាន ១ ជវហង្សកត្ថេរាបទាន ១ សឡលបុប្ផិយ-ត្ថេរាបទាន ១ ឧបាគតហាសនិយត្ថេរាបទាន ១ តរណិយត្ថេរាបទាន ត្រូវជា ១០ ឯគាថាមាន ៤១ លោកអ្នកប្រាជ្ញបានរាប់ហើយ ក្នុងវគ្គនេះ ។

### បទុមុក្ខេបវគ្គទី ២៧ ចប់

# អដ្ឋកថា

## មច្ចុនាយកត្ថេរាបទានជាដើម

*[ ១៦៦-១៧០ ] អបទានទី ៦ ទី ៧ ទី ៨ ទី ៩ ទី ១០*

*មានអត្ថងាយយល់ហើយ ។ល។*

**អដ្ឋកថាមច្ចុនាយកត្ថេរាបទានជាដើម ចប់**

**បន្ទុមុកេ្ខបវគ្គទី ២៧ ចប់**

# សុត្តន្តបិដក
# សុវណ្ណពិព្វោហនវគ្គទី ២៨

## សុវណ្ណពិព្វោហនិយត្ថេរាបទានទី ១

[ ១៧១ ] ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយអាសនៈ ១ ដោយដៃរបស់ខ្លួន គឺថ្វាយខ្នើយ ដើម្បីសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយខ្នើយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខ្នើយ ។ ក្នុងកប្បទី ៦៣ អំពីកប្បនេះ ខ្ញុំបានកើតជាក្សត្រចក្កពត្តិ ព្រះនាមអសមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសុវណ្ណពិព្វោហនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សុវណ្ណពិព្វោហនិយត្ថេរាបទាន ចប់

# អដ្ឋកថា

# សុវណ្ណពិព្ពោហានវគ្គទី ២៨

## សុវណ្ណពិព្ពោហានិយត្ថេរាបទាន

[ ១៧១ ] *អបទានទី ១ វគ្គទី ២៨ មានអត្ថងាយយល់ហើយ ។ល។*

អដ្ឋកថាសុវណ្ណពិព្ពោហានិយត្ថេរាបទាន ចប់

# សុត្តន្តបិដក

## តិលមុដ្ឋិយត្ថេរាបទានទី ២

[ ១៧២ ] ព្រះសាស្តា ជាអគ្គនាយកក្នុងលោក ទ្រង់ជ្រាបនូវតម្រិះរបស់ខ្ញុំ បានស្តេចមកដោយកាយឫទ្ធិ សម្រេចដោយចិត្ត ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ក៏ថ្វាយបង្គំព្រះសាស្តា ជាបុរសប្រសើរបំផុត ដែលកំពុងស្តេចចូលមក ហើយថ្វាយល្ង មួយក្តាប់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយល្ង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃល្ង ១ ក្តាប់ ។ ក្នុងកប្បទី ១៦ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមគន្ធិយៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិលមុដ្ឋិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តិលមុដ្ឋិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## តិលមុដ្ឋិយត្ថេរាបទាន

[ ១៧២ ] *គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះ បទថា* **មនោមយេន កាយេន** *សេចក្តីថា មានកាយដែលប្រព្រឹត្តទៅតាមអំណាចចិត្ត ។ល។*

**អដ្ឋកថាតិលមុដ្ឋិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចង្កោដកិយត្ថេរាបទានទី ៣

[ ១៧៣ ] ព្រះសម្ពុទ្ធទ្រង់គង់នៅត្រង់ចន្លោះភ្នំ អាស្រ័យមហាសមុទ្រ ខ្ញុំប្រាថ្នានូវបុណ្យ ក្រោកទៅទទួល ហើយបានប្រគេនប្រអប់ផ្កា លុះខ្ញុំបានប្រគេនប្រអប់ផ្កាដល់ព្រះសយម្ភូ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គស្វែងរកនូវគុណធំ ទ្រង់មានសេចក្តីអនុគ្រោះហើយ បានរីករាយក្នុងស្ថានសួគ៌ អស់ ១ កប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយប្រអប់ផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃប្រអប់ផ្កា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចង្កោដកិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចង្កោដកិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## ចង្កោដកិយត្ថេរាបទាន

[ ១៧៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះ បទថា **មហាសមុទ្ទំ និស្សាយ** សេចក្តីថា ប្រថាប់នៅក្នុងរវាងភ្នំដែលតាំងនៅក្បែរមហាសាគរ អធិប្បាយថា ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ទ្រង់ប្រថាប់ ព្រោះទ្រង់បំណងសេចក្តីស្ងប់ស្ងាត់ ។ បទថា **បច្ចុគ្គន្ត្វានកាសហំ** សេចក្តីថា ខ្ញុំបានទទួលចូលគាល់ព្រះមានព្រះភាគអង្គនោះ ហើយបានបំពេញបុណ្យ មានការក្រាបថ្វាយបង្គំជាដើម ។ បទថា **ចង្កោដកមទាសហំ** សេចក្តីថា ខ្ញុំបានបូជាដោយប្រអប់ពេញដោយផ្កា ដល់ព្រះមានព្រះភាគ ព្រះនាមថាសិទ្ធត្ថៈ ។ល។

**អដ្ឋកថាចង្កោដកិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អគ្គពន្ធនទាយកត្ថេរាបទានទី ៤

[ ១៧៤ ] ខ្ញុំបានថ្វាយថ្នាំបន្តក់ភ្នែក ដល់ព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈ ព្រះអង្គមានរាគៈទៅប្រាសហើយ ជាតាទិបុគ្គល មានព្រះហឫទ័យមិនអាក្រក់ មិនមានដំណើរយឺតយូរ គឺកិលេស ព្រះអង្គមានឈាន ប្រព្រឹត្តកន្លងនូវមោហៈទាំងពួង ទ្រង់ស្វែងរកប្រយោជន៍ ដល់សត្វលោកទាំងពួង ព្រះអង្គជាធំជាងសត្វជើង ២ ទ្រង់មិនញាប់ញ័រ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយថ្នាំបន្តក់ភ្នែក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថ្នាំបន្តក់ភ្នែក ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមវិប្បៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអគ្គពន្ធនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អគ្គពន្ធនទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## អព្ភញ្ជនទាយកត្ថេរាបទាន

[ ១៧៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះ បទថា **អកក្កសចិត្តស្សាជ** គឺមានព្រះហឫទ័យមិនគ្រោតគ្រាត **អជ** សព្ទត្រឹមតែជាបទបូរណៈ ។ល។

**អដ្ឋកថាអព្ភញ្ជនទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឯកញ្ជលិយត្ថេរាបទានទី ៥

[ ១៧៥ ] ខ្ញុំបានប្រគេនឱកាសជាទីនៅ លើកម្រាលស្លឹកឈើ ដែលខ្ញុំតាំងទុកដល់ព្រះសមណៈ ( ព្រះនាមតិស្សៈ ) ទ្រង់ស្វែងរកនូវគុណធំ កាលគង់នៅជិតដើមល្វា ។ ខ្ញុំផ្គងអញ្ជលី ហើយក្រាលកម្រាលផ្កា ថ្វាយព្រះតិស្សសម្ពុទ្ធ ជាធំជាងសត្វជើង ២ ជាទីពឹងនៃសត្វលោក ជាតាទិបុគ្គល ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកម្រាលផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាល ។ ក្នុងកប្បទី ១៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ជាធំជាងពួកមនុស្ស ព្រះនាមឯកអញ្ជលិកៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកញ្ជលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឯកញ្ជលិយត្ថេរាបទាន ចប់

# អដ្ឋកថា

## ឯកញ្ចលិយត្ថេរាបទាន

[ ១៧៥ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះ បទថា **ឧទុម្ពរេ វសន្តស្ស** សេចក្តីថា ដល់ព្រះមានព្រះភាគ ព្រះនាមតិស្សៈ ដែលប្រថាប់នៅត្រង់គល់ល្វា គឺត្រង់ម្លប់ដើមឈើ ។ បទថា **និយតេ បណ្ណ-សន្ថរេ** សេចក្តីថា ព្រះមានព្រះភាគទ្រង់គង់លើកម្រាលស្លឹកដែលជាប់គ្នា គឺគរលើគ្នា បានដល់ អាសនៈមែកឈើ ។ បទថា **វុត្ថោកាសោ មយា និដ្ឋោ** សេចក្តីថា ខ្ញុំបានប្រគល់ថ្វាយឱកាស ដែលជាមណ្ឌបដែលមានទ្វារជាដើមបិទបើកបានក្នុងទីវាល ។ល។

**អដ្ឋកថាឯកញ្ចលិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ពោត្ថទាយកត្ថេរាបទានទី ៦

[ ១៧៦ ] ខ្ញុំប្រារព្ធនូវព្រះសាស្តាផង ព្រះធម៌ផង ព្រះសង្ឃផង បានប្រគេនពោត្ថទាន ( សំពត់ស្លឹកឈើ ) ដល់ព្រះសម្ពុទ្ធមហេសី ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពោត្ថទាន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពោត្ថទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ពោត្ថទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ចោត្តទាយកត្ថេរាបទាន

[ ១៧៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះ បទថា **ចោត្តទានំ មយា ទិន្នំ** សេចក្ដីថា ខ្ញុំបានវាយសម្បកឈើ គឺចំណែកជុំវិញ ឲ្យជាបន្ទះៗ ធ្វើជាសំពត់ គឺប្រើអំបោះ ដោយយកឆ្អឹងគោខាត់ចំណែកដែលមិនរាបស្មើ ត្រៀមទុកហើយ យកមកតគ្នាប្រើអំបោះនោះដោតជាផ្ទាំងដើម្បីប្រើសម្រាប់អន្ទាយ ឬសម្រាប់ក្រាលផែនដី ។ ខ្ញុំថ្វាយសំពត់នោះ ដល់ព្រះរតនត្រ័យ ៕

**អដ្ឋកថាចោត្តទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ចិតកបូជកត្ថេរាបទានទី ៧

[ ១៧៧ ] ខ្ញុំដើរទៅកាន់ទីបណ្តោយខ្សែទឹក លើឆ្នេរស្ទឹងចន្ទភាគា ខ្ញុំបានយកផ្កាជ្រៃ ៧ ដាក់បូជាជើងថ្កូរ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាជើងថ្កូរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្កូរ ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមបដិជគ្គៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចិតកបូជកត្ថេរាបទាន ចប់

# អដ្ឋកថា

## ចិតកប្ជកត្ថេរាបទាន

[ ១៧៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះ បទថា **ចន្ទភាគានទីតីរេ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថនៃបញ្ចមីវិភត្តិ ប្រែថា អំពីច្រាំងនៃស្ទឹងឈ្មោះចន្ទភាគា ។ បទថា **អនុសោតំ** សេចក្តីថា ខ្ញុំត្រាច់ទៅតាមស្ទឹងចំណែកខាងក្រោមរបស់ក្រសែទឹក ( ដើរបណ្តោយទឹក ) ។ បទថា **សត្ត មាលុវបុប្ផានិ ចិតមារោបយឹ អហំ** សេចក្តីថា ខ្ញុំបេះផ្កាជ្រៃ ៧ ផ្កា យកខ្សែចពួនជាស្តូបហើយ ធ្វើនូវការបូជាត្រង់គំនរខ្សែដ៏វិចិត្រនោះ ៕

**អដ្ឋកថាចិតកប្ជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អាលុវទាយកត្ថេរាបទានទី ៨

[ ១៧៨ ] មានស្ទឹងធំ ១ ឈ្មោះសុទស្សនៈ នៅក្បែរភ្នំហិមពាន្ត ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះនាមសុទស្សនៈ មានរស្មីល្អ ទ្រង់ប្រាសចាករាគៈ គង់នៅក្បែរស្ទឹងនោះ ។ លុះខ្ញុំឃើញព្រះអង្គប្រកបក្នុងសេចក្តីស្ងប់រម្ងាប់ យ៉ាងក្រៃលែង ខ្ញុំមានចិត្តសង្វេគជ្រះថ្លា បានថ្វាយវល្លិកំ ជាខ្សែស្បៀងដល់ព្រះសុទស្សនៈអង្គនោះ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយវល្លិកំ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃវល្លិកំ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាលុវទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អាលុវទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## អាលុវទាយកត្ថេរាបទាន

[ ១៧៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះ បទថា **មហាសិន្ធុ សុទស្សនា** សេចក្ដីថា មានស្ទឹងឈ្មោះមហាសិន្ធុ ដែលល្អគួរជាទីត្រេកអរនៃចិត្ត ព្រោះមានទេសភាពគួរមើល មានទឹកថ្លា មានខ្សាច់សស្អាត អធិប្បាយថា ក្នុងទីជិតស្ទឹងសិន្ធុនោះ ខ្ញុំបានឃើញព្រះពុទ្ធ ដែលមានរស្មីផូរផង់ គឺមានព្រះរូបស្អាត មានការស្ងប់ស្ងៀមក្រៃលែង គឺទៅក្នុងភាពស្ងប់ដ៏ឧត្ដម បានដល់ ជាអ្នកដល់ព្រមសព្វយ៉ាង ជាអ្នកប្រាសចាករាគៈ ។ បទថា **ធិស្វាហំ វិម្ហិតាសយោ** សេចក្ដីថា មានចិត្តត្រេកអរ គឺកើតនូវភាពអស្ចារ្យថា ទ្រង់មកដល់ភ្នំហិមពាន្ត ដែលគួរខ្លាចពន្លឹក បានដូចម្ដេច ។

បទថា **អាលុវំ តស្ស ធាទាសឹ** សេចក្ដីថា ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយមើមដំឡូង[១] ដោយអើពើ ដល់ព្រះអរហន្តនោះ ។

### អដ្ឋកថាអាលុវទាយកត្ថេរាបទាន ចប់

---

១- បិដកខ្មែរ ជាវល្លិកន្ទំ ។

# សុត្តន្តបិដក

## បុណ្ឌរីកត្ថេរាបទានទី ៩

[ ១៧៩ ] ក្នុងកាលនោះ ព្រះសយម្ភូព្រះនាមរោមសៈ មានរស្មីល្អ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយផ្កាឈូក-ស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កាឈូក-ស ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឈូក-ស ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុណ្ឌរីកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បុណ្ឌរីកត្ថេរាបទាន ចប់

## តរណិយត្ថេរាបទានទី ១០

[ ១៨០ ] ខ្ញុំមានចិត្តជ្រះថ្លា បានស្ថាបនាស្ពាន ត្រង់ផ្លូវធំដែលមានជង្ហុក ដើម្បីប្រយោជន៍ដល់ការឆ្លងនៃសត្វលោក ដោយដៃរបស់ខ្លួន ។ ក្នុង កប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានស្ថាបនាស្ពាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យស្ពាន ។ ក្នុងកប្បទី ៥៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមសមោគតៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦

នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតរណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តរណិយត្ថេរាបទាន ចប់**

## ឧទ្ទាន

សុវណ្ណពិព្វោហនិយត្ថេរាបទាន ១ តិលមុដ្ឋិយត្ថេរាបទាន ១ ចង្កោដកិយត្ថេរាបទាន ១ អព្ភញ្ជនទាយកត្ថេរាបទាន ១ ឯកញ្ជលិយត្ថេរាបទាន ១ បោត្ថទាយកត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ១ អាលុវទាយត្ថេរបទាន ១ បុណ្ឌរីកត្ថេរាបទាន ១ តរណិយត្ថេរាបទាន ១ មានគាថា ៤២ ដែលអ្នកប្រាជ្ញរាប់ហើយ ។

**សុវណ្ណពិព្វោហនវគ្គទី ២៨ ចប់**

**ភាណវារទី ១១ ចប់**

# អដ្ឋកថា

## បុណ្ណរីកត្ថេរាបទានជាដើម

[ ១៧៩-១៨០ ] *អបទានទី ៩ ទី ១០ មានអត្ថងាយយល់ហើយ ។ល។*

### អដ្ឋកថាបុណ្ណរីកត្ថេរាបទានជាដើម ចប់

# សុត្តន្តបិដក
# បណ្ណទាយកវគ្គទី ២៩

## បណ្ណទាយកត្ថេរាបទានទី ១

[ ១៨១ ] ខ្ញុំអង្គុយនៅក្នុងបណ្ណសាលា កំពុងបរិភោគស្លឹកឈើជាភោជន ព្រះសម្ពុទ្ធជាមហាឥសី ស្តេចចូលមករកខ្ញុំដែលកំពុងអង្គុយ ។ ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈ ជាប្រទីបក្នុងលោក ព្រះអង្គជាអ្នករក្សានូវសត្វលោកទាំងអស់ ខ្ញុំបានថ្វាយស្លឹកឈើចំពោះព្រះអង្គ ដែលទ្រង់គង់នៅលើកម្រាលស្លឹកឈើ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយស្លឹកឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្លឹកឈើ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបណ្ណទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បណ្ណទាយកត្ថេរាបទាន ចប់

# អដ្ឋកថា
# បណ្ណទាយកវគ្គទី ២៩

## បណ្ណទាយកត្ថេរាបទាន

[ ១៨១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ នៃវគ្គទី ២៩ ដូចតទៅនេះ បទថា **បណ្ណភោជនភោជនោ** សេចក្ដីថា ខ្ញុំអង្គុយនៅក្នុងបណ្ណសាលា ដើម្បីបរិភោគភោជន មានទឹកដោះ និងបន្លែជាដើម ។ បទថា **ឧបវិដ្ឋញ្ច មំ សន្តំ** សេចក្ដីថា ខ្ញុំជាអ្នកចូលទៅក្នុងបណ្ណសាលា ។ បទថា **ឧបាគច្ឆិ មហាឥសិ** សេចក្ដីថា ឈ្មោះថា **មហាឥសិ** ព្រោះស្វែងរកគំនរនៃគុណដែលធំក្រៃលែង មានសីលជាដើម អធិប្បាយថា ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ជាអ្នកបំភ្លឺសត្វលោកឲ្យភ្លឺស្វាង ជាប្រទីបរបស់សត្វលោក បានយាងមក គឺយាងមកក្បែរខ្ញុំ ។ បទថា **និសិន្នស្ស បណ្ណសន្ថរេ** ក្អាប់ សេចក្ដីថា ខ្ញុំបានចូលទៅថ្វាយបន្លែស្ងោរទុកបរិភោគឯង ដល់ព្រះមានព្រះភាគ ដែលប្រថាប់គង់លើកម្រាលស្លឹកឈើ ។

**អដ្ឋកថាបណ្ណទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ផលទាយកត្ថេរាបទានទី ២

[ ១៨២ ] ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈ មានព្រះហឫទ័យសន្តោស ស្មើដោយភ្នំសិនេរុ ឬក៏ប្រហែលដោយធរណី ស្តេចចេញចាក សមាធិ ហើយទ្រង់ស្តេចចូលទៅរកខ្ញុំដើម្បីភិក្ខា ។ ខ្ញុំមានចិត្ត ជ្រះថ្លា បានប្រគេនផ្លែឈើទាំងអស់នោះ គឺផ្លែសម៉ កន្ទួតព្រៃ ស្វាយ ព្រីង ផ្លែសម៉ពិភេទក៍ ពុទ្រា រកាំខ្មៅ ស្រគំ ល្មៅ និង ផ្លែមាក់ប្រាង ដល់ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ ព្រះអង្គមាន សេចក្ដីអនុគ្រោះដល់សត្វលោកទាំងពួង ។ ក្នុងកប្បទី ៩៤ អំពី កប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំ មិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ ក្នុងកប្ប ទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមឯកជ្ឈៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសម្ដែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ផលទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ផលទាយកត្ថេរាបទាន

[ ១៨២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះ ភ្ជាប់សេចក្តីថា ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទ្រង់សន្តោស ស្មើដោយភ្នំសិនេរុ ទ្រង់មាំទាំដូចគ្នានឹងធរណី ។ បទថា **វុដ្ឋហិត្វា សមាធិម្ហា** សេចក្តីថា ស្តេចចេញចាកនិរោធសមាបត្តិហើយ គឺទ្រង់ចេញចាកសមាបត្តិ ។ បទថា **ភិក្ខាយ មមុបដ្ឋិតោ** សេចក្តីថា កៀកពេលភិក្ខាចារ ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ បុគ្គលណាម្នាក់ បានថ្វាយទានបន្តិចបន្តួចដល់តថាគត ផលជាច្រើននឹងមានដល់បុគ្គលនោះ ដូច្នេះហើយ ទើបយាងចូលមករកខ្ញុំ ដែលអង្គុយ គឺចូលមកជិតខ្ញុំ ។ បទថា **ហរីតកំ ។បេ។ ផារុសកផលានិ ច** សេចក្តីថា ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយផ្លែឈើទាំងអស់ ដល់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈជាអ្នកស្វែងរកគុណធំ ទ្រង់អនុគ្រោះសត្វលោកទាំងពួង អង្គនោះ ។ល។

**អដ្ឋកថាផលទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បច្ចុគ្គមនិយត្ថេរាបទានទី ៣

[ ១៨៣ ] ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើនូវការក្រោកទទួលព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គជាប្រទីបក្នុងលោក ជាអ្នករក្សាសត្វលោកទាំងពួង ទ្រង់ជានរាសភៈ ទ្រង់ស្តេចមក ដូចសត្វសីហៈត្រាច់ទៅក្នុងព្រៃ ឬដូចនិសភអាជានេយ្យ ឬក៏ដូចលំពង់ថ្វាន់ ដ៏ល្វាសល្វន់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានក្រោកទទួលព្រះនរាសភៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការក្រោកទទួល ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមបរិវារៈ ជាធំជាងជនទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបច្ចុគ្គមនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បច្ចុគ្គមនិយត្ថេរាបទាន ចប់**

# អដ្ឋកថា

## បច្ចុគ្គមនិយត្ថេរាបទាន

[ ១៨៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះ បទថា **សីហំ យថា វនចរំ** ក្លាប់សេចក្តីថា នូវព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ដែលកំពុងត្រាច់ទៅ ដូចរាជសីហ៍ត្រាច់ទៅក្នុងព្រៃ ។ បទថា **និសភាជានិយំ យថា** សេចក្តីថា គោដែលប្រសើរបំផុត មាន ៤ គឺវសភៈ និសភៈ វិសភៈ អាសភៈ បណ្តាគោដ៏ប្រសើរបំផុតទាំង ៤ នោះ ដែលឈ្មោះថា វសភៈ គឺគោដែលជាមេហ្វូងរបស់គោ ១០០ ។ ដែលឈ្មោះថា និសភៈ គឺគោដែលជាមេហ្វូងរបស់គោ ១ ពាន់ ។ ដែលឈ្មោះថា វិសភៈ គឺគោដែលជាមេហ្វូងគោ ១ សែន ។ ដែលឈ្មោះថា អាសភៈ គឺគោដែលជាមេហ្វូងរបស់គោ ១ សែនកោដិ តែក្នុងទីនេះ អាសភៈ លោកហៅថា និសភៈ បានដល់ គោអាជានេយ្យ ដែលដូចគ្នានឹងគោឧសភរាជ ដែលមិនខ្លាច មិនញាប់ញ័រ ។ បទថា **កកុធំ វិលសន្តំវ** សេចក្តីថា ខ្ញុំមានចិត្តជ្រះថ្លាព្រោះប្រកបដោយសទ្ធា បានឃើញព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ជាអ្នកអង់អាច ឧត្តមជានរជនទាំងឡាយ ល្អដូចដើមថ្ងាន់ដែលសម្បូរដោយផ្កានិងត្រួយ កំពុងយាងមក ទើបធ្វើនូវការទទួល ។៚

**អដ្ឋកថាបច្ចុគ្គមនិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឯកបុប្ផិយត្ថេរាបទានទី ៤

[ ១៨៤ ] កាលនោះ ខ្ញុំកើតជាបិសាចនៅត្រង់ទ្វារខាងត្បូង បានឃើញព្រះសម្ពុទ្ធ ព្រះអង្គមិនមានធូលី គឺរាគៈ ដូចជាព្រះអាទិត្យមានរស្មីលឿង ។ ខ្ញុំបានថ្វាយផ្កា ១ ចំពោះព្រះវិបស្សី ព្រះអង្គប្រសើរជាងនរៈ ទ្រង់ស្វែងរកនូវប្រយោជន៍ ដល់សត្វលោកទាំងពួង ព្រះអង្គជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឯកបុប្ផិយត្ថេរាបទាន ចប់**

## មយូរបុប្ផិយត្ថេរាបទានទី ៩

[ ១៨៥ ] ព្រះសយម្ភូ ដែលពួកមារផ្ចាញ់មិនបាន មានឥន្ទ្រិយដ៏ថ្លាស្អាត មិនមានកករល្អក់ ព្រះអង្គទ្រង់ចូលកាន់សមាធិ ក្បែរឆ្នេរស្ទឹងនម្មទា ។ កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឃើញព្រះសម្ពុទ្ធ ដែលពួកមារផ្ចាញ់មិនបាន ហើយបូជាព្រះសយម្ភូអង្គនោះ ដោយផ្កាមយូរព្រឹក្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះមយូរបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

### មយូរបុប្ផិយត្ថេរាបទាន ចប់

## ឧបដ្ឋាយិកត្ថេរាបទានទី ៦

[ ១៨៦ ] ខ្ញុំបានឃើញព្រះមហានាគ ព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ទ្រង់ជានរាសភៈ គួរទទួលនូវគ្រឿងបូជា ស្តេចទៅតាមច្រក ។ ខ្ញុំបានថ្វាយឧបដ្ឋាកម្នាក់ ដល់ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ ដែលខ្ញុំបានឲ្យគេនិមន្ត ព្រះអង្គស្វែងរកនូវប្រយោជន៍ ដល់សត្វលោកទាំងពួង ។ ព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញប្រសើរ ទ្រង់ទទួលហើយ ប្រគល់ឲ្យខ្ញុំវិញ ទ្រង់ក្រោកចាកអាសនៈនោះ មានព្រះកត្រ្តបែរចេញទៅកាន់បាចីនទិស ហើយទ្រង់ចៀសចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយឧបដ្ឋាក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឧបដ្ឋាក ។ ក្នុងកប្បទី ៥៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមពលសេនៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំ បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបដ្ឋាយិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ឧបដ្ឋាយិកត្ថេរាបទាន ចប់**

## អបទានិយត្ថេរាបទានទី ៧

[ ១៨៧ ] ខ្ញុំមានចិត្តជ្រះថ្លា សម្តែងនូវអបទាន ( រឿង ) របស់ព្រះសុគតទាំងឡាយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយក៏ថ្វាយបង្គំព្រះបាទាទាំងគូ ដោយត្បូង និងដៃរបស់ខ្លួន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានសម្តែងនូវអបទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសម្តែង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើ ឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអបទានិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អបទានិយត្ថេរាបទាន ចប់**

# សត្តាហបព្វជិតត្ថេរាបទានទី ៨

[ ១៨៨ ] ក្នុងកពមុន មានព្រះសង្ឃរបស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ដែលទេវតា និងមនុស្សធ្វើសក្ការៈរាប់អានហើយ ខ្ញុំឯងក៏ដល់នូវសេចក្ដីវិនាស បានបែកចាកពួកញាតិ ខ្ញុំចូលទៅកាន់ផ្នួស ដើម្បីរម្ងាប់ទុក្ខព្រួយ ព្រោះសេចក្ដីវិនាសនោះ ខ្ញុំត្រេកអរក្នុងផ្នួសនោះ អស់ ៧ ថ្ងៃ ព្រោះប្រាថ្នាបំពេញកិច្ចក្នុងសាសនារបស់ព្រះសាស្ដា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបួស ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះផលនៃបព្វជ្ជា ។ ក្នុងកប្បទី ៦៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៧ ជាតិ ជាម្ចាស់ផែនដី គេតែងស្គាល់ថា ព្រះបាទសុនេក្ខម្មៈ ដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តាហបព្វជិតត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សត្តាហបព្វជិតត្ថេរាបទាន ចប់

# ពុទ្ធុបដ្ឋាយិកត្ថេរាបទានទី ៩

[ ១៨៩ ] កាលនោះ ខ្ញុំឈ្មោះវេធម្មិទី បិតារបស់ខ្ញុំក៏ឈ្មោះវេធម្មិនីដែរ បិតាខ្ញុំដឹកដៃខ្ញុំចូលទៅរកព្រះមហាមុនី ឯព្រះមហាមុនីសម្តែងប្រាប់ខ្ញុំថា ព្រះពុទ្ធទាំងឡាយនេះ ជាអគ្គនាយកក្នុងលោក ខ្ញុំជ្រះថ្លា បានបម្រើព្រះពុទ្ធទាំងនោះដោយគោរព ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបម្រើព្រះពុទ្ធទាំងឡាយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រើ ។ ក្នុងកប្បទី ២៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៤ ជាតិ មានព្រះនាមសមណុបដ្ឋាកៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធុបដ្ឋាយិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ពុទ្ធុបដ្ឋាយិកត្ថេរាបទាន ចប់

## បុព្វង្គមនិយត្ថេរាបទានទី ១០

[ ១៩០ ] ពួកយើង ៨៤០០០ នាក់ មិនមានសេចក្ដីកង្វល់បាន បួសហើយ ដើម្បីសម្រេចនូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ខ្ញុំឯងជាប្រធាន របស់កុលបុត្តទាំងនោះ ។ ឯកុលបុត្តទាំងនុ៎ះ នៅមានរាគៈ និង មោហៈ តែមានចិត្តជ្រះថ្លា បានបម្រើព្រះពុទ្ធ ដែលមានឥន្ទ្រិយ ថ្លាស្អាត មិនមានកករល្អក់ ដោយគោរព ដោយដៃរបស់ខ្លួន ។ ព្រះសយម្ភូទាំងឡាយ ដែលពួកមារផ្ចាញ់មិនបាន ព្រះអង្គជា ព្រះវិញ្ញាស្រេច មានទោសៈខ្ជាក់ចោលហើយ មានសោឡសកិច្ច ធ្វើរួចហើយ មិនមានអាសវៈ តែងផ្សាយមេត្តាចិត្ត ។ ពួកយើង បានបម្រើព្រះសម្ពុទ្ធទាំងនោះ ដោយសេចក្ដីកោតក្រែង លុះដល់ មរណៈ ក៏បានទៅកាន់អត្តភាពជាទេវតា ។ ក្នុងកប្បទី ៩៤ អំពី កប្បនេះ ព្រោះហេតុដែលខ្ញុំបានរក្សាសីល ខ្ញុំមិនដែលស្គាល់ ទុគ្គតិ នេះជាផលនៃការសង្រួមក្នុងសីល ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុព្វង្គមនិយត្ថេរមានអាយុ បានសម្ដែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បុព្វង្គមនិយត្ថេរាបទាន ចប់**

## ឧទ្ទាន

បណ្ណទាយកត្ថេរាបទាន ១

ផលទាយកត្ថេរាបទាន ១

បច្ចុគ្គមនិយត្ថេរាបទាន ១

ឯកបុប្ផិយត្ថេរាបទាន ១

មឃវបុប្ផិយត្ថេរាបទាន ១

ឧបដ្ឋាយិកត្ថេរាបទាន ១

អបទានិយត្ថេរាបទាន ១

សត្តាហបព្វជិតត្ថេរាបទាន ១

ពុទ្ធុបដ្ឋាយិកត្ថេរាបទាន ១

បុព្វង្គមនិយត្ថេរាបទាន ១ មាន គាថា ៤៨ ដែលអ្នកប្រាជ្ញសម្តែងទុកហើយ ។

### បណ្ណទាយកវគ្គទី ២៩ ចប់

# អដ្ឋកថា

## ឯកបុប្ផិយត្ថេរាបទានជាដើម

[ ១៨៤-១៩០ ] តាំងអំពីអបទានទី ៤ ជាដើមទៅ រហូតដល់អបទានទី ១០ មានអត្ថដ៏ងាយហើយ ។

**អដ្ឋកថាឯកបុប្ផិយត្ថេរាបទានជាដើម ចប់**

**បណ្ណាសកវគ្គទី ២៩ ចប់**

# សុត្តន្តបិដក

# ចិតកបូជកវគ្គទី ៣០

## ចិតកបូជកត្ថេរាបទានទី ១

[ ១៩១ ] កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ឈ្មោះអជិតៈ ខ្ញុំប្រាថ្នានឹងបូជានូវគ្រឿងបូជា បានប្រមូលផ្កាផ្សេងៗ ។ ខ្ញុំឃើញជើងថ្ករដែលកំពុងរុងរឿងរបស់ព្រះពុទ្ធព្រះនាមសិខី ព្រះអង្គជាផៅពង្សនៃសត្វលោក ហើយយកផ្កានោះមករោយរាយចុះត្រង់ជើងថ្ករ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៧ ជាតិ ជាធំជាងពួកមនុស្ស ព្រះនាមសុបជ្ជលិតដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចិតកបូជកត្ថេរាបទាន ចប់

# អដ្ឋកថា
# ចិតកបូជកវគ្គទី ៣០

## ចិតកបូជកត្ថេរាបទាន

[ ១៩១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ នៃវគ្គទី ៣០ ដូចតទៅនេះ បទថា **អាហុតឹ យិដ្ឋុកាមោហំ** សេចក្ដីថា ខ្ញុំមានបំណងនឹងធ្វើការបូជាសក្ការៈ ។ បទថា **នានាបុប្ផំ សមានយឹ** សេចក្ដីថា ខ្ញុំបាននាំយកផ្កា ដូចជាផ្កាចម្ប៉ា និងផ្កាពជព្រឹក្សជាដើមច្រើនប្រភេទ មករួមយ៉ាងល្អ គឺធ្វើជាគំនរ ។

បទថា **សិខិនោ លោកពន្ធុនោ** សេចក្ដីថា ខ្ញុំបានឃើញជើងថ្ករដែលមានគំនរឧសកំពុងឆេះរុងរឿង គឺត្រូវឆេះពេញសរីរៈរបស់ព្រះមានព្រះភាគព្រះនាមសិខី ដែលជាផៅពង្ស គឺជាញាតិរបស់លោកទាំង ៣ ទើបនាំយកផ្កានោះ មកធ្វើការបូជាត្រង់ជើងថ្ករ ៕

**អដ្ឋកថាចិតកបូជកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បុប្ផធារកត្ថេរាបទានទី ២

[ ១៩២ ] ខ្ញុំស្លៀកសំពត់សម្បកឈើ ដណ្តប់សំពត់ស្បែកខ្លា ញុំាងអភិញ្ញា ៥ ឲ្យកើត ជាអ្នកស្ទាបអង្អែលព្រះចន្ទបាន ។ ខ្ញុំបានឃើញព្រះវិបស្សី ព្រះអង្គបំភ្លឺលោក ដែលកំពុងស្តេចមកកាន់សម្នាក់របស់ខ្ញុំ ទើបខ្ញុំបាំងផ្កាបារិច្ឆត្តកព្រឹក្ស ថ្វាយព្រះសាស្តា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបាំងផ្កាថ្វាយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបាំងផ្កា ។ ក្នុងកប្បទី ៨៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ជាម្ចាស់ផែនដី ព្រះនាមសមន្តធរណៈ ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផធារកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បុប្ផធារកត្ថេរាបទាន ចប់

# អដ្ឋកថា

## បុប្ផធារកត្ថេរាបទាន

[ ១៩២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះ បទថា **អជិនុត្តរវាសនោ** សេចក្តីថា ស្លៀកដណ្តប់សំពត់ស្បែកខ្លា និងស្បែកម្រឹគទៀងស្នាខាងឆ្វេង ។ បទថា **អភិញ្ញា បញ្ច និព្វត្តា** សេចក្តីថា ធ្វើអភិញ្ញា ៥ គឺញាណ ៥ មានឥទ្ធិវិធញ្ញាណជាដើមឲ្យកើតឡើង គឺឲ្យសម្រេចឡើងហើយ ។ បទថា **ចន្ទស្ស បរិមជ្ជកោ** សេចក្តីថា ខ្ញុំបានជាអ្នកស្ទាបអង្អែល គឺប៉ះពាល់ព្រះចន្ទបានដោយជុំវិញ ។ បទថា **វិបស្សឹ លោកបជ្ជោតំ** សេចក្តីថា ខ្ញុំបានឃើញព្រះមានព្រះភាគព្រះនាមវិបស្សី ដូចគ្នានឹងប្រទីបក្នុងលោកទាំង ៣ យាងមកក្បែរខ្ញុំ គឺបានយាងមករកជាពិសេស ។ បទថា **និស្សា ចារិច្ឆត្តកបុប្ផានិ** សេចក្តីថា ខ្ញុំបាននាំយកផ្កាបារិច្ឆត្តកៈមកអំពីទេវលោក ហើយលើកឡើងបូជាដោយអាការដូចឆត្រ ខាងលើសីសៈរបស់ព្រះសាស្តាព្រះនាមវិបស្សី ។៚

**អដ្ឋកថាបុប្ផធារកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ឆត្តទាយកត្ថេរាបទានទី ៣

[ ១៩២ ] ក្នុងកាលនោះ កូនរបស់ខ្ញុំបួស ស្លៀកសំពត់កាសាយៈ កូនខ្ញុំនោះ បានដល់ភាពជាព្រះពុទ្ធ ដែលសត្វលោកបូជា បានបរិនិព្វានហើយ ។ ខ្ញុំស្វែងរកកូនរបស់ខ្លួន ក៏ទៅកាន់ជើងថ្ករបស់ព្រះពុទ្ធដ៏ប្រសើរ ជាកូនរបស់ខ្ញុំ ដែលបរិនិព្វានហើយ នៅខាងក្រោយអារាម ។ កាលនោះ ខ្ញុំផ្គងអញ្ជលី ថ្វាយបង្គំជើងថ្ករត្រង់កន្លែងនោះ ហើយខ្ញុំកាន់ស្វេតច្ឆត្រថ្វាយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាឆត្រ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រ ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៧ ជាតិ ជាធំជាងជន ព្រះនាមមហារហៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឆត្តទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ឆត្តទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## ឆត្តនាយកត្ថេរាបទាន

[ ១៩២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះ បទថា **បុត្តោ មម បព្វជិតោ** សេចក្តីថា បុត្តរបស់ខ្ញុំបួសហើយ ដោយសទ្ធា ។ បទថា **កាសាយវសនោ តទា** សេចក្តីថា ក្នុងពេលដែលបានបួសហើយនោះ ក៏ស្លៀកដណ្តប់ដោយសំពត់កាសាយៈ គឺបានបួសជាបព្វជិតក្រៅសាសនា ។ បទថា **សោ ច ពុទ្ធត្តំ សម្បត្តោ** សេចក្តីថា បុត្តរបស់ខ្ញុំនោះ បានសម្រេចដោយល្អនូវភាពជាសាវ័ករបស់ព្រះពុទ្ធ ក្នុងព្រះពុទ្ធទាំង ៤ អង្គ គឺសម្រេចអរហត្ត ។ បទថា **និព្វុតោ លោកបូជិតោ** សេចក្តីថា ជាបុគ្គលដែលសត្វលោកទាំងមូល ធ្វើសក្ការៈហើយ បរិនិព្វានហើយដោយខន្ធបរិនិព្វាន មានសក្ការៈដែលសត្វលោកទាំងអស់ ធ្វើការបូជាហើយ ។ បទថា **វិចិនន្តោ សកំ បុត្តំ** សេចក្តីថា ខ្ញុំបានសួរដល់ទីដែលបុត្តនោះទៅ ស្វែងរកបុត្តរបស់ខ្លួន គឺជាប់តាមទៅអំពីខាងក្រោយ គឺជាអ្នកជាប់តាមទៅ ។ បទថា **និព្វុតស្ស មហន្តស្ស** សេចក្តីថា ខ្ញុំបានទៅដល់ត្រង់ជើងថ្ករ គឺទីប្រជុំភ្លើង ក្នុងទីប្រជុំភ្លើងនៃបុត្តរបស់ខ្ញុំនោះ ដែលឈ្មោះថា **មហន្តស្ស** ព្រោះប្រកបដោយគុណ មានសីលក្ខន្ធជាដើមដែលធំក្រៃលែង ។ បទថា

**បគ្គយ្ហ អញ្ជលឹ តត្ថ** សេចក្ដីថា ខ្ញុំបានផ្គងអញ្ជលី គឺប្រជុំម្រាមទាំង ១០ លើសិរសា ត្រង់ជើងថ្កូរនោះ ហើយថ្វាយបង្គំជើងថ្កូរ គឺគំនរអុសដែលដុត ។ បទថា **សេតច្ឆត្តញ្ច បគ្គយ្ហ** សេចក្ដីថា មិនមែនតែថ្វាយបង្គំតែម្យ៉ាង បានតម្កល់ គឺលើកឆត្រ-សទៀតផង ៕

## អដ្ឋកថាជត្តទាយកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## សទ្ទសញ្ញកត្ថេរាបទានទី ៤

[ ១៩៤ ] កាលព្រះអាទិត្យមិនទាន់រះឡើង សេចក្ដីជ្រះថ្លាយ៉ាងខ្លាំង ចំពោះព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ក៏កើតមានប្រាកដក្នុងលោក ។ ខ្ញុំបានឮសំឡេងប្រកាសថា ព្រះពុទ្ធត្រាស់ហើយ ក្នុងទីនោះ តែខ្ញុំឥតបានឃើញព្រះជិនស្រីនោះ ហើយលុះដល់ខ្ញុំជិតនឹងមរណកាល ខ្ញុំបានចាប់ក្លឹកនឹកដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវពុទ្ធសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសទ្ទសញ្ញកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សទ្ទសញ្ញកត្ថេរាបទាន ចប់

# អដ្ឋកថា

## សទ្ទសញ្ញកត្ថេរាបទាន

[ ១៩៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះ បទថា **អនុគ្គតម្ហិ អាទិច្ចេ** សេចក្តីថា កាលព្រះអាទិត្យមិនទាន់រះ គឺកាលបច្ចូសសម័យមិនទាន់ប្រាកដ ។ បទថា **បសាទោ វិបុលោ អហុ** សេចក្តីថា សេចក្តីជ្រះថ្លានៃចិត្តរបស់ខ្ញុំ ដែលត្រូវរោគជាដើមបៀតបៀន មានយ៉ាងច្រើន គឺជោជន់ដោយការរឭកដល់ព្រះពុទ្ធ ភ្លាប់សេចក្តីថា ការប្រាកដឡើង គឺការប្រាកដនៃព្រះពុទ្ធដ៏ប្រសើរ ជាអ្នកស្វែងរកគុណធំ មានហើយក្នុងលោក ។ បទថា **ឃោសមស្សោសហំ តត្ថ** សេចក្តីថា កាលសេចក្តីប្រាកដនោះកំពុងប្រព្រឹត្តទៅ ខ្ញុំមានជំងឺ បានឮសំឡេងគឹកកងថា ព្រះពុទ្ធកើតឡើងហើយ ។ បទថា **ន ច បស្សាមិ តំ ជិនំ** សេចក្តីថា ខ្ញុំមិនបានឃើញនូវព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ឈ្នះមារទាំង ៥ អង្គនោះ គឺខ្ញុំមានជំងឺធ្ងន់ ទើបមិនអាចទៅគាល់បាន ។ បទថា **មរណញ្ច អនុប្បត្តោ** សេចក្តីថា ដល់កាលជិតស្លាប់ គឺជាអ្នកកៀកនឹងស្លាប់ ។ បទថា **ពុទ្ធសញ្ញមនុស្សរឹ** សេចក្តីថា ខ្ញុំបានរឭកដល់ព្រះនាមព្រះពុទ្ធ គឺបានធ្វើអារម្មណ៍ គឺព្រះពុទ្ធក្នុងចិត្ត ។ល។

**អដ្ឋកថាសទ្ទសញ្ញកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## គោសីសនិក្ខេបកត្ថេរាបទានទី ៥

[ ១៩៥ ] ខ្ញុំបានក្រាលកម្រាលទ្រនាប់ជើង ចេញអំពីទ្វារអារាម ( ថ្វាយចំពោះសង្ឃ ) ខ្ញុំបានទទួលកុសលកម្មរបស់ខ្លួននេះ នេះជាផលនៃបុព្វកម្ម ។ ខ្ញុំបានទូវពាហនៈទាំងអស់នោះ គឺសេះអាជានេយ្យ មានសន្ទុះដូចខ្យល់ និងសេះសិន្ធពជាពាហនៈដ៏លឿន នេះជាផលនៃកម្រាលទ្រនាប់ជើង ។ ឱ ! គ្រឿងសក្ការៈ ជាសក្ការៈដ៏ថ្លៃថ្លា ដែលខ្ញុំបានធ្វើហើយដោយប្រពៃ ចំពោះបុញ្ញក្ខេត្តដ៏ល្អ គ្រឿងសក្ការៈដទៃ មិនដល់មួយចំណិតនៃសក្ការៈដែលខ្ញុំធ្វើចំពោះសង្ឃឡើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានក្រាលកម្រាលទ្រនាប់ជើង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាល ។ ក្នុងកប្បទី ៧៥ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ១ អង្គ ព្រះនាមសុបតិដ្ឋិតៈ ទ្រង់មានតេជៈច្រើន មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគោសីសនិក្ខេបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## គោសីសនិក្ខេបកត្ថេរាបទាន

[ ១៩៥ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះ បទថា **អារាមទ្វារា និក្ខម្ម** សេចក្តីថា ត្រង់ផ្លូវទ្វារដែលសង្ឃចេញចាក អារាម ។ បទថា **គោសីសំ សន្ថតំ មយា** សេចក្តីថា ត្រង់ទ្វារដែលចេញនោះ ខ្ញុំបានក្រាលខ្លឹមចន្ទន៍ស(១) សម្រាប់ដើរជាន់ដោយចេតនាថា គូនៃបាទារបស់ព្រះមានព្រះភាគ និងគូនៃជើងរបស់ភិក្ខុសង្ឃ កុំជាន់ត្រង់កក់ឡើយ ។ បទថា **អនុភោមិ សកំ កម្មំ** សេចក្តីថា ដោយកម្លាំងនៃកម្មដែលខ្លួនក្រាលឈើចន្ទន៍ស ទើបខ្ញុំបានសោយផល គឺមានសេះអាជានេយ្យ ដែលមានសម្ទុះដូចខ្យល់ មានសេះសិន្ធពជាពាហនៈ ដែលមានសម្ទុះរហ័សជាដើម ។ បទថា **អហោ ការំ បរមការំ** សេចក្តីថា កិច្ចបន្តិចបន្តួចដែលខ្ញុំធ្វើដោយល្អ ក្នុងព្រះសង្ឃដែលជាខេត្តដ៏ល្អ ព្រោះផលច្រើន ទើបឲ្យផលច្រើន គឺឧត្តម ជាការអស្ចារ្យពិតហ្ន៎ ។ លោកអធិប្បាយថា ខ្ញុំបានធ្វើកម្ម គឺការក្រាលដើមចន្ទន៍សក្នុងខេត្តនៃព្រះសង្ឃ ដែលមានកាយសមាចារ និងវចីសមាចារដ៏បរិសុទ្ធ ប្រាសចាកទោស មានរាគៈ និងទោសៈជាដើម កម្មនេះ ឲ្យផល

---

១- បាលីអដ្ឋកថាថា គោសីសដ្ឋិ ក្នុងទីនេះ លោកប្រែថា ចន្ទន៍ស ឯក្នុងអម្ពសក្ករបេតវត្ថុ លោកប្រែថា ឆ្អឹងក្បាលគោ ។

ច្រើន ប្រៀបដូចស្រូវសាលីដែលព្រោះក្នុងស្រែដែលប្រាសចាកទោស មានស្មៅជាដើម រមែងឲ្យផលច្រើន ដូច្នោះ ។ បទថា **ឆ អញ្ញំ កលមគ្ឃតិ** ក្នុងសេចក្តីថា កម្មដទៃដែលធ្វើក្រៅសាសនា មានផលមិនដល់ចម្រៀកគឺចំណែកទី ១៦ នៃការធ្វើសក្ការៈដែលធ្វើក្នុងសង្ឃ ។ល។

**អដ្ឋកថាគោសីសនិក្ខេបកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បទបូជកត្ថេរាបទានទី ៦

[ ១៩៦ ] កាលនោះ ខ្ញុំកើតជាកិន្នរ នៅនាភ្នំហិមពាន្ត បានឃើញព្រះសម្ពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ ដូចជាព្រះអាទិត្យ មានរស្មីលឿង ។ កាលនោះ ខ្ញុំចូលទៅរកព្រះពុទ្ធ ព្រះនាមវិបស្សី ព្រះអង្គជានាយកនៃសត្វលោក ហើយស្រោចនូវខ្លឹមចន្ទន៍ និងក្រស្នា លើព្រះបាទាក្នុងកាលនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះបាទា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះបាទា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបទបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បទបូជកត្ថេរាបទាន ចប់**

# តេសកិច្ចិកត្ថេរាបទានទី ៧

[ ១៩៧ ] ក្នុងកាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះឧបសាល្ហក: ខ្ញុំដើរចូលទៅក្នុងព្រៃធំ បានឃើញព្រះលោកនាថ ជានរាសភ: គួរទទួលនូវគ្រឿងបូជារបស់សត្វលោក ហើយខ្ញុំថ្វាយបង្គំទៀបព្រះបាទា ព្រះពុទ្ធទ្រង់ជ្រាបថា ខ្ញុំមានចិត្តជ្រះថ្លាហើយ ក៏ស្តេចបាត់ទៅ ។ ខ្ញុំចេញចាកព្រៃធំនោះ ក៏បានរឭកនឹកដល់ព្រះពុទ្ធដ៏ប្រសើរ ខ្ញុំបានសរសើរនូវប្រទេសនោះ ហើយរីករាយក្នុងស្ថានសួគ៌ អស់ ១ កប្ប ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានពោលសរសើរនូវប្រទេស ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតេសកិច្ចិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**តេសកិច្ចិកត្ថេរាបទាន ចប់**

## សរណាគមនិយត្ថេរាបទានទី ៨

[ ១៩៨ ] កាលនោះ ខ្ញុំកើតជាព្រានព្រៃ នៅនាភ្នំហិមពាន្ត បានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ព្រះអង្គជាចម្បងក្នុងលោក ជានរាសភៈ ។ ខ្ញុំចូលទៅជិតព្រះសម្ពុទ្ធ ធ្វើនូវការបម្រើ ទាំងបានថ្វាយខ្លួនជាឧបាសក ដល់សរណៈ ( ក្នុងសម្នាក់ ) នៃព្រះសម្ពុទ្ធព្រះអង្គជាធំជាងសត្វជើង ២ ប្រកបដោយតាទិគុណ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានដល់សរណៈ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសរណៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណាគមនិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សរណាគមនិយត្ថេរាបទាន ចប់**

# អម្ពបិណ្ឌិយត្ថេរាបទានទី ៩

[ ១៩៩ ] ខ្ញុំឈ្មោះរោមសៈ តែគេស្គាល់រាល់គ្នាថាទានវៈ ខ្ញុំបាន ថ្វាយផ្លែស្វាយមួយដុំ ដល់ព្រះពុទ្ធ ព្រះនាមវិបស្សី ព្រះអង្គ ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុ ដែលខ្ញុំបានថ្វាយផ្លែស្វាយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ ការថ្វាយផ្លែស្វាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពបិណ្ឌិយត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អម្ពបិណ្ឌិយត្ថេរាបទាន ចប់**

## អនុសំសាវកត្ថេរាបទានទី ១០

[ ២០០ ] ខ្ញុំបានឃើញព្រះជិនស្រី ព្រះនាមវិបស្សី កំពុងត្រាច់ទៅបិណ្ឌបាត បានថ្វាយចង្ហាន់ ១ វែក ដល់ព្រះសម្ពុទ្ធ ព្រះអង្គជាធំជាងសត្វជើង ២ ទ្រង់ប្រកបដោយតាទិគុណ ។ កាលនោះខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំ ពោលសរសើរព្រះពុទ្ធ ដើម្បីសម្រេចនូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុសំសាវកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**អនុសំសាវកត្ថេរាបទាន ចប់**

## ឧទ្ទាន

ចិតកបូជកត្ថេរាបទាន ១ បុប្ផធារកត្ថេរាបទាន ១

ឆត្តទាយកត្ថេរាបទាន ១ សទ្ទសញ្ញកត្ថេរាបទាន ១

កូសីសនិក្ខេបកត្ថេរាបទាន ១ បទបូជកត្ថេរាបទាន ១

ទេសកិត្តិកត្ថេរាបទាន ១ សរណគមនិយត្ថេរាបទាន ១

អម្ពបិណ្ឌិយត្ថេរាបទាន ១ អនុសំសាវកត្ថេរាបទាន ១ មានគាថា ៤៧ ដែលពួកអ្នកប្រាជ្ញរាប់ហើយ ។

ចិតកបូជកវគ្គទី ៣០ ចប់

## មួយទៀត ឧទ្ទាននៃវគ្គ

កណិការបុប្ផិយវគ្គ ១ ហត្ថិវគ្គ ១ អាលម្ពនទាយកវគ្គ ១ ឧទកាសនទាយិវគ្គ ១ តុវរទាយិវគ្គ ១ ថោមកវគ្គ ១ ឧក្ខេបវគ្គ ១ សីសុបធានវគ្គ ១ បណ្ណទាយវគ្គ ១ ចិតកបូជកវគ្គ ១ ក្នុងវគ្គនេះ មានគាថា ៤៥១ ដោយសព្វគ្រប់ ។ គាថាទាំងអស់ ១២៥ ផង លើសពីនោះ ៧២ ទៀតផង នៃបទ ១៣០ ដែលអ្នកប្រាជ្ញ ជាអ្នកឃើញនូវប្រយោជន៍ បានរាប់ឃើញហើយ ។

សតកទី ៣ ចប់

# អដ្ឋកថា

## បទបូជកត្ថេរាបទានជាដើម

[ ១៩៦-២០០ ] *អបទានទី ៦ ទី ៧ ទី ៨ ទី ៩ និងទី ១០*

*មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថាបទបូជកត្ថេរាបទានជាដើម ចប់**

**សតកវគ្គទី ៣០ ចប់**

# សុត្តន្តបិដក
# ខុទ្ទកនិកាយ អបទាន
# តតិយភាគ

## បទុមកេសរិយវគ្គទី ៣១

### បទុមកេសរិយត្ថេរាបទានទី ១

[ ១ ] *ក្នុងភពមុន ខ្ញុំកើតជាដំរីឈ្មោះមាតង្គៈ នៅជិតពួកឥសី បានរោយរាយកេសរផ្កាឈូក ដោយចិត្តជ្រះថ្លា ថ្វាយចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ដែលទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លា ចំពោះព្រះបច្ចេកពុទ្ធទាំងនោះ ទ្រង់ឈ្នះមារដ៏ប្រសើរ ទ្រង់មានរាគៈកម្ចាត់បង់ហើយ ប្រកបដោយតាទិគុណ ហើយបានរីករាយក្នុងស្ថានសួគ៌ អស់ ១ កប្ប ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានរោយកេសរផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា ព្រះបទុមកេសរិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

# អដ្ឋកថា
# បទុមកេសរិយវគ្គទី ៣១

## បទុមកេសរិយត្ថេរាបទាន

[ ១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ ក្នុងវគ្គទី ៣១ ដូចតទៅនេះ បទថា **ឥសិសង្ឃេ អហំ បុព្វេ** ក្លាប់សេចក្តីថា ក្នុងកាលមុន គឺក្នុងពេលបំពេញពោធិសម្ភារ ខ្ញុំកើតជាដំរី គឺដំរីកាចក្នុងត្រកូលមាតង្គៈ នៅក្បែរភ្នំហិមពាន្ត ជិតពួកឥសី គឺព្រះបច្ចេកសម្ពុទ្ធ ។ ឈ្មោះថា **វារណោ** ព្រោះរារាំងមនុស្សជាដើមបាន ម្យ៉ាងទៀត ឈ្មោះថា **វារណោ** ព្រោះស្រែក គឺបន្លឺកោញ្ចនាទដោយវាចាបាន ។ បទថា **មហេសីនំ បសាទេន** បានដល់ដោយការជ្រះថ្លាក្នុងព្រះបច្ចេកសម្ពុទ្ធ អ្នកស្វែងរកគុណធំ ។ បទថា **បច្ចេក-ជិនសេដ្ឋេសុ ធុតរាគេសុ តាទិសុ** ក្លាប់សេចក្តីថា ខ្ញុំបានរោយកេសរឈូកបូជាក្នុងព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដែលមិនញាប់ញ័រ ដោយលោកធម៌ទាំងឡាយ ។៚

**អដ្ឋកថាបទុមកេសរិយត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សព្វគន្ធិយត្ថេរាបទានទី ២

[ ២ ] ខ្ញុំបានថ្វាយគ្រឿងក្រអូប និងកម្រងផ្កា ដល់ព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់ស្វែងរកគុណដ៏ធំ ទាំងបានថ្វាយសំពត់កោសេយ្យពស្ត្រដ៏ឧត្តមដល់ព្រះពុទ្ធ ទ្រង់មានព្រះសន្តានដ៏ត្រង់ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយគ្រឿងក្រអូប និងកម្រងផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយគ្រឿងក្រអូប ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ព្រះនាមសុចេលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វគន្ធិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សព្វគន្ធិយត្ថេរាបទាន ចប់

# បរមន្នទាយកត្ថេរាបទានទី ៣

[ ៣ ] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់ជាធ្មេមក្នុងលោក ប្រសើរជាងពួកនរៈ ទ្រង់រុងរឿងដូចផ្កាកណិការ ឬក៏ដូចព្រះអាទិត្យ ដែលទើបនឹងរះ ។ ខ្ញុំផ្គងអញ្ជលីនិមន្តឲ្យស្តេចទៅផ្ទះរបស់ខ្លួន លុះនាំព្រះសម្ពុទ្ធទៅហើយ ក៏បានថ្វាយនូវបាយាសដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយបាយាសដ៏ប្រសើរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបាយាសដ៏ប្រសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបរមន្នទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**បរមន្នទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## សព្វគន្ធិយត្ថេរាបទានជាដើម

[ ២-៣ ] *អបទានទី ២ និងទី ៣ មានអត្ថងាយយល់ហើយ ។*

## អដ្ឋកថាសព្វគន្ធិយត្ថេរាបទានជាដើម ចប់

# សុត្តន្តបិដក

## ធម្មសញ្ញកត្ថេរាបទានទី ៤

[ ៤ ] មានពិធីធ្វើឯមហាពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ឯព្រះសម្ពុទ្ធជាច្បងក្នុងលោក ប្រសើរជាងនរៈ ទ្រង់ស្ថិតនៅទៀបដើមពោធិព្រឹក្ស ។ ក្នុងសម័យនោះ ព្រះមានព្រះភាគ ទ្រង់មានភិក្ខុសង្ឃចោមរោម ទ្រង់ប្រកាសសច្ចៈ ៤ ទ្រង់បន្លឺឡើងនូវវាចាដ៏អង់អាច ។ ព្រះសម្ពុទ្ធមានកិលេស ជាគ្រឿងបិទបើកហើយ ទ្រង់សំដែងធម៌ដោយបង្រួញផង ដោយពិស្តារផង ទ្រង់ញ៉ាំងមហាជនឲ្យរលត់ទុក្ខ ។ ខ្ញុំបានស្តាប់ធម៌របស់ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ជាធ្មេមក្នុងលោក ប្រកបដោយតាទិគុណ ហើយថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា រួចឈមមុខទៅកាន់ឧត្តរទិស ហើយចៀសចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានស្តាប់ធម៌ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្តាប់ធម៌ ។ ក្នុងកប្បទី ៣៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិមួយអង្គ ព្រះនាមសុតវា ជាម្ចាស់ផែនដី ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មសញ្ញកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## ធម្មសញ្ញកត្ថេរាបទាន

[ ៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះ បទថា **មហាពោធិមហោ អហុ** សេចក្ដីថា មានការបូជាដើមឈើ ដែលបានឈ្មោះថា **ពោធិ** ព្រោះជាទីកើតនូវមគ្គញាណ ៤ របស់ព្រះមានព្រះភាគព្រះនាមវិបស្សី ។ បទថា **រុក្ខដ្ឋស្សេវ សម្ពុទ្ធោ** សេចក្ដីថា ប្រាកដដល់មហាជនដែលប្រជុំរួមគ្នា ក្នុងគ្រាបូជាពោធិព្រឹក្សនោះ ដូចព្រះសម្មាសម្ពុទ្ធដែលជាជេដ្ឋបុរសនៃលោក ជាអ្នកអង់អាចជាងនរជន ប្រថាប់គង់ត្រង់គល់ពោធិព្រឹក្ស គឺដូចទ្រង់ឈរក្រោមដើមឈើ ។ បទថា **ភគវា តម្ហិ សមយេ** សេចក្ដីថា ក្នុងសម័យនោះ គឺក្នុងពេលដែលធ្វើការបូជាដើមពោធិ៍ ព្រះមានព្រះភាគចោមរោមដោយភិក្ខុសង្ឃ គឺមានភិក្ខុសង្ឃចោមរោម ។ បទថា **វាចាសភិមុទីរយំ** សេចក្ដីថា ទ្រង់បន្លឺសំឡេងដ៏ស្រទន់ ពីរោះរណ្ដំ និងប្រសើរបំផុត ទ្រង់ប្រកាស គឺទ្រង់សម្ដែងសច្ចៈ ៤ ។ បទថា **សង្ខិត្តេន ច វិត្ថារេន** សេចក្ដីថា កាលទ្រង់សម្ដែងអនុលោមតាមអធ្យាស្រ័យរបស់បុគ្គលដែលជាវេនេយ្យសត្វ ទើបទ្រង់សម្ដែងដោយសង្ខេបខ្លះ ដោយពិស្ដារខ្លះ ។ បទថា **វិវដ្ដច្ឆទ្ទោ** សេចក្ដីថា ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ជាអ្នកមានដំបូល គឺកិលេសបើកហើយ ព្រោះដំបូលដែលលោកពោលយ៉ាងនេះ គឺ

រាគៈជាជំបូល ទោសៈជាជំបូល មោហៈជាជំបូល កិលេសទាំងអស់ ជាជំបូល ដូច្នេះ ត្រូវបើកហើយ ត្រូវភើចកន្ទ្រាក់ហើយ ត្រូវកម្ចាត់ហើយ អធិប្បាយថា ទ្រង់ញុំាងមហាជននោះ ឲ្យរលត់នូវកម្តៅ ដោយទេសនាវិសេស គឺរម្ងាប់នូវការក្តៅក្រហាយបាន ។ បទថា **តស្សាហំ ធម្មំ សុត្វាន** បានដល់ បានស្តាប់ព្រះធម៌របស់ព្រះមានព្រះភាគអង្គនោះ ដែលទ្រង់សម្តែង ។ល។

## អដ្ឋកថាធម្មសញ្ញកត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ផលទាយកត្ថេរាបទានទី ៥

[ ៥ ] កាលនោះ មានអាស្រមនៅទៀបផ្នូរស្ទឹង ឈ្មោះភាគីរសី ខ្ញុំជាអ្នកមិនបានសិក្សា កាន់យកផ្លែឈើដើរតម្រង់មកអាស្រមនោះ ខ្ញុំបានឃើញព្រះវិបស្សី គង់ក្នុងអាស្រមនោះ ទ្រង់មានរស្មីលឿង ដូចព្រះអាទិត្យ ខ្ញុំក៏បានថ្វាយផ្លែឈើទាំងអស់របស់ខ្ញុំ ដល់ព្រះសាស្តា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ផលទាយកត្ថេរាបទាន ចប់**

# អដ្ឋកថា

## ផលទាយកត្ថេរាបទាន

[ ៥ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះ បទថា **ផលហត្ថោ អបេក្ខវា** សេចក្ដីថា ខ្ញុំបានឃើញព្រះមានព្រះភាគ ព្រះនាមវិបស្សីហើយ បានកាន់យកផ្លែឈើមានរសឆ្ងាញ់ ដើរសន្សឹមៗ ទៅកាន់អាស្រម ។ល។

**អដ្ឋកថាផលទាយកត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## សម្បសាទិកត្ថេរាបទានទី ៦

[ ៦ ] បពិត្រព្រះពុទ្ធមានព្យាយាម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ព្រះអង្គផុតស្រឡះហើយ ចាកកិលេសទាំងពួង ខ្ញុំព្រះអង្គដល់ហើយនូវសេចក្តីវិនាស សូមព្រះអង្គជាទីពឹងរបស់ខ្ញុំនោះ ។ ព្រះសិទ្ធត្ថៈ ទ្រង់មិនមានបុគ្គលប្រៀបផ្ទឹមក្នុងលោក ទ្រង់សម្តែងប្រាប់ខ្ញុំថា ព្រះសង្ឃស្មើដោយមហាសមុទ្ទ ប្រមាណមិនបាន ប្រសើរបំផុត អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លា ទាំងចូរបណ្តុះនូវពូជដ៏ល្អ ក្នុងព្រះសង្ឃដែលទុកជាស្រែមិនមានធូលី គឺរាគៈ ជាស្រែប្រគល់ឲ្យផល ឥតមានទីបំផុត ។ ព្រះសព្វញ្ញូ ជាឧត្តមក្នុងលោក ព្រះអង្គប្រសើរជាងពួកនរៈ លុះទ្រង់សម្តែងនូវពាក្យនេះ ទ្រង់ប្រៀនប្រដៅខ្ញុំយ៉ាងនេះហើយ ក៏ស្តេចហោះឡើងទៅឯផ្ទៃអាកាស ។ កាលដែលព្រះសព្វញ្ញូ ប្រសើរជាងពួកនរៈ ស្តេចពុទ្ធដំណើរទៅហើយ មិនយូរប៉ុន្មាន ខ្ញុំក៏ដល់នូវមរណៈ ហើយបានទៅកើតក្នុងស្ថានតុសិត ។ ក្នុងកាលនោះ ខ្ញុំបានញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសង្ឃ ដែលជាស្រែមិនមានធូលី ជាស្រែប្រគល់ឲ្យផល ឥតមានទីបំផុត ខ្ញុំបានរីករាយហើយ ក្នុងស្ថានសួគ៌អស់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំមានសេចក្តីជ្រះថ្លា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីជ្រះថ្លា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន

ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន ប្រតិបត្តិហើយ ។

បានឮថា ព្រះសម្បសាទិកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

សម្បសាទិកត្ថេរាបទាន ចប់

## អារាមទាយកត្ថេរាបទានទី ៧

[ ៧ ] ខ្ញុំបានដាំសួនច្បារ ថ្វាយព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ពួកបក្សីចូលទៅអាស្រ័យ ឰដ៏ដើមឈើទាំងឡាយ ដែលមានម្លប់ត្រជាក់ ។ ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់មិនមានធូលី គឺកិលេស ទ្រង់គួរទទួលនូវគ្រឿងបូជា ទើបនាំព្រះសម្ពុទ្ធ ជាលោកជេដ្ឋៈ ប្រសើរជាងពួកនរៈ ទៅក្នុងសួនច្បារ ។ ខ្ញុំជាអ្នកមានចិត្តរីករាយ បានថ្វាយផ្លែឈើ និងផ្កាឈើ ទាំងមានសេចក្តីជ្រះថ្លាខ្លាំង កើតឡើងក្នុងលំដាប់នោះ ហើយបង្អោនថ្វាយនូវទាននោះ ។ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយទានណា ដល់ព្រះពុទ្ធ ផលរមែងកើតសម្រាប់ខ្ញុំ ក្នុងភពដែលខ្ញុំកើតហើយ ( ព្រោះការថ្វាយទាននោះ ) ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយសួនច្បារ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសួនច្បារ ។ ក្នុងកប្បទី ៣៧ អំពីកប្បនេះ ខ្ញុំបានកើត

ជាស្ដេចចក្កពត្តិ ៧ ជាតិ ព្រះនាមមុទុសីតលៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាកាមទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អាកាមទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## សម្បសាទិកត្ថេរាបទានជាដើម

[ ៦-៧ ] អបទានទី ៦ និងទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសម្បសាទិកត្ថេរាបទានជាដើម ចប់

# សុត្តន្តបិដក

## អនុលេបទាយកត្ថេរាបទានទី ៨

[ ៨ ] ខ្ញុំបានឃើញសាវ័ករបស់ព្រះមុនី ព្រះនាមអត្ថទស្សី កំពុងធ្វើនវកម្ម ខ្ញុំក៏ដើរចូលទៅក្នុងដែន ។ កាលដែលនវកម្មរួចស្រេច ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ក៏បានថ្វាយថ្នាំលាបដល់សាវ័ក ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ក្នុងកប្បទី ១៨០០ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថ្នាំលាប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុលេបទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អនុលេបទាយកត្ថេរាបទាន ចប់

# អដ្ឋកថា

## អនុលេបទាយកត្ថេរាបទាន

[ ៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះ បទថា **និដ្ឋិតេ នវកម្មេ ច** សេចក្តីថា កាលការធ្វើសីមាដល់នូវការសម្រេចហើយ ។ បទថា **អនុលេបមទាសហំ** សេចក្តីថា ខ្ញុំបានឲ្យនូវការបូកលាបដោយបាយ-អ[១] ខាងក្រោយ គឺប្រើបាយអបូកពីលើ ៕

**អដ្ឋកថាអនុលេបទាយកត្ថេរាបទាន ចប់**

---

១- បិដកខ្មែរជា ថ្នាំលាប ។

# សុត្តន្តបិដក

## ពុទ្ធសញ្ញិកត្ថេរាបទានទី ៩

[ ៩ ] ខ្ញុំបានយល់សប្តិឃើញថា ព្រះសិទ្ធត្ថៈ ជាលោកនាយក ទ្រង់ជាធ្មើមក្នុងត្រៃលោក ទ្រង់ប្រសើរជាងពួកនរៈ ទ្រង់មានឥន្ទ្រិយស្ងប់រម្ងាប់ ស្តេចពុទ្ធដំណើរទៅក្នុងចន្លោះព្រៃ ទ្រង់មានរស្មីដូចព្រះអាទិត្យ ដែលទើបនឹងរះ ឬដូចព្រះអាទិត្យដែលមានរស្មីលឿង ខ្ញុំបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះព្រះអង្គនោះហើយ បានទៅកើតក្នុងសុគតិ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានទូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធសញ្ញិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ពុទ្ធសញ្ញិកត្ថេរាបទាន ចប់

## បញ្ញារទាយកត្ថេរាបទានទី ១០

[ ១០ ] ខ្ញុំបានសម្អាតញក ថ្វាយព្រះមានព្រះភាគ ព្រះនាម បិយទស្សី ព្រះអង្គប្រកបដោយតាទិគុណ ទាំងបានតម្កល់ទុកនូវក្អមទឹកសម្រាប់ប្រើប្រាស់ ។ ព្រះពុទ្ធជាមហាមុនី ព្រះនាម បិយទស្សី ទ្រង់ព្យាកររឿងនោះប្រាប់ខ្ញុំថា ប្រាសាទជាវិការនៃកែវមណីខៀវ មានកម្ពស់មួយពាន់សង្កាត់ ព្រួញមានជាន់ច្រើន បរិបូណ៌ដោយទង់នោះផង រតនៈដ៏ច្រើនផង នឹងកើតឡើងសម្រាប់អ្នក ខ្ញុំបានថ្វាយញកជាទានហើយ ខ្ញុំបានរីករាយក្នុងស្ថានសួគ៌អស់មួយកប្ប ។ ក្នុងកប្បទី ៣២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសុពុទ្ធៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ញារទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បញ្ញារទាយកត្ថេរាបទាន ចប់

## ឧទ្ទាន

បទុមកេសរិយត្ថេរាបទាន ១ សព្វគន្ធិយត្ថេរាបទាន ១

បរមន្នទាយកត្ថេរាបទាន ១ ធម្មសញ្ញិកត្ថេរាបទាន ១

ផលទាយកត្ថេរាបទាន ១ សម្បសាទិកត្ថេរាបទាន ១

អារាមទាយកត្ថេរាបទាន ១ អនុលេបទាយកត្ថេរាបទាន ១

ពុទ្ធសញ្ញិកត្ថេរាបទាន ១ បព្ភារទាយកត្ថេរាបទាន ១ មាន

គាថា ៥១ ដែលអ្នកប្រាជ្ញទាំងឡាយ បានគណនាហើយ ។

បទុមកេសរិយវគ្គទី ៣១ ចប់

# អដ្ឋកថា

## ពុទ្ធសញ្ញិកត្ថេរាបទានជាដើម

[ ៩-១០ ] អបទានទី ៩ និងទី ១០ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាពុទ្ធសញ្ញិកត្ថេរាបទានជាដើម ចប់

បទុមកេសរិយវគ្គទី ៣១ ចប់

# ក្បាលទី ៦០

# សុត្តន្តបិដក ចាលីប្រែ -៧២

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ

### សីហាសនិយវគ្គទី ២


សីហាសនទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ២
អដ្ឋកថាសីហាសនទាយកត្ថេរាបទាន ...... ...... ...... ...... ៤
ឯកត្ថម្ភិកត្ថេរាបទានទី ២ ...... ...... ...... ...... ៨
អដ្ឋកថាឯកត្ថម្ភិកត្ថេរាបទាន ...... ...... ...... ...... ១០
នន្ទត្ថេរាបទានទី ៣ ...... ...... ...... ...... ១៣
អដ្ឋកថានន្ទត្ថេរាបទាន ...... ...... ...... ...... ១៥
ចុល្លបន្ថកត្ថេរាបទានទី ៤ ...... ...... ...... ...... ២១
អដ្ឋកថាចុល្លបន្ថកត្ថេរាបទាន ...... ...... ...... ...... ២៤
បិលិន្ទវច្ឆត្ថេរាបទានទី ៥ ...... ...... ...... ...... ៣៣
អដ្ឋកថាបិលិន្ទវច្ឆត្ថេរាបទាន ...... ...... ...... ...... ៣៥
រាហុលត្ថេរាបទានទី ៦ ...... ...... ...... ...... ៣៩
អដ្ឋកថារាហុលត្ថេរាបទាន ...... ...... ...... ...... ៤២
ឧបសេនវង្គន្តបុត្តត្ថេរាបទានទី ៧ ...... ...... ...... ...... ៤៨
អដ្ឋកថាឧបសេនវង្គន្តបុត្តត្ថេរាបទាន ...... ...... ...... ...... ៥០
រដ្ឋបាលត្ថេរាបទានទី ៨ ...... ...... ...... ...... ៥៣
អដ្ឋកថារដ្ឋបាលត្ថេរាបទាន ...... ...... ...... ...... ៥៥
សោបាកត្ថេរាបទានទី ៩ ...... ...... ...... ...... ៦៦
អដ្ឋកថាសោបាកត្ថេរាបទាន ...... ...... ...... ...... ៦៨

សុមង្គលត្ថេរាបទានទី ១០ ...... ...... ...... ...... ៧៤
អដ្ឋកថាសុមង្គលត្ថេរាបទាន ...... ...... ...... ...... ៧៧

## សុភូតិវគ្គទី ៣

សុភូតិត្ថេរាបទានទី ១ ...... ...... ...... ...... ៨២
អដ្ឋកថាសុភូតិត្ថេរាបទាន ...... ...... ...... ...... ៨៩
ឧបវាណត្ថេរាបទានទី ២ ...... ...... ...... ...... ១០៣
អដ្ឋកថាឧបវានត្ថេរាបទាន ...... ...... ...... ...... ១១០
តិណិសរណគមនិយត្ថេរាបទានទី ៣ ...... ...... ...... ...... ១១៣
អដ្ឋកថាតិណិសរណគមនិយត្ថេរាបទាន ...... ...... ...... ...... ១១៧
បញ្ចសីលសមាទានិយត្ថេរាបទានទី ៤ ...... ...... ...... ...... ១១៩
អដ្ឋកថាបញ្ចសីលសមាទានិយត្ថេរាបទាន ...... ...... ...... ...... ១២២
អន្នសំសាវកត្ថេរាបទានទី ៥ ...... ...... ...... ...... ១២៤
អដ្ឋកថាអន្នសំសាវកត្ថេរាបទាន ...... ...... ...... ...... ១២៥
ធូបទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ១២៧
អដ្ឋកថាធូបទាយកត្ថេរាបទាន ...... ...... ...... ...... ១២៨
បុឡិនបូជកត្ថេរាបទានទី ៧ ...... ...... ...... ...... ១៣០
អដ្ឋកថាបុឡិនបូជកត្ថេរាបទាន ...... ...... ...... ...... ១៣១
ឧត្តិយត្ថេរាបទានទី ៨ ...... ...... ...... ...... ១៣៣
អដ្ឋកថាឧត្តិយត្ថេរាបទាន ...... ...... ...... ...... ១៣៥
ឯកញ្ជលិកត្ថេរាបទានទី ៩ ...... ...... ...... ...... ១៣៨
អដ្ឋកថាឯកញ្ជលិកត្ថេរាបទាន ...... ...... ...... ...... ១៣៩
ខោមទាយកត្ថេរាបទានទី ១០ ...... ...... ...... ...... ១៤២
អដ្ឋកថាខោមទាយកត្ថេរាបទាន ...... ...... ...... ...... ១៤៤

## កុណ្ឌធានវគ្គទី ៤


| | | |
|---|---|---|
| កុណ្ឌធានត្ថេរាបទានទី ១ | ...... ...... ...... ...... | ១៤៦ |
| អដ្ឋកថាកុណ្ឌធានត្ថេរាបទាន | ...... ...... ...... ...... | ១៤៩ |
| សាគតត្ថេរាបទានទី ២ | ...... ...... ...... ...... | ១៥៩ |
| អដ្ឋកថាសាគតត្ថេរាបទាន | ...... ...... ...... ...... | ១៦១ |
| មហាកច្ចាយនត្ថេរាបទានទី ៣ | ...... ...... ...... ...... | ១៦៣ |
| អដ្ឋកថាមហាកច្ចាយនត្ថេរាបទាន | ...... ...... ...... ...... | ១៦៦ |
| កាឡុទាយិត្ថេរាបទានទី ៤ | ...... ...... ...... ...... | ១៧០ |
| អដ្ឋកថាកាឡុទាយិត្ថេរាបទាន | ...... ...... ...... ...... | ១៧៣ |
| មោឃរាជត្ថេរាបទានទី ៥ | ...... ...... ...... ...... | ១៨៣ |
| អដ្ឋកថាមោឃរាជត្ថេរាបទាន | ...... ...... ...... ...... | ១៨៦ |
| អធិមុត្តកត្ថេរាបទានទី ៦ | ...... ...... ...... ...... | ១៨៩ |
| អដ្ឋកថាអធិមុត្តត្ថេរាបទាន | ...... ...... ...... ...... | ១៩០ |
| លសុណទាយកត្ថេរាបទានទី ៧ | ...... ...... ...... ...... | ១៩១ |
| អដ្ឋកថាលសុណទាយកត្ថេរាបទាន | ...... ...... ...... ...... | ១៩២ |
| អាយាគទាយកត្ថេរាបទានទី ៨ | ...... ...... ...... ...... | ១៩៤ |
| អដ្ឋកថាអាយាគទាយកត្ថេរាបទាន | ...... ...... ...... ...... | ១៩៥ |
| ធម្មចក្កិកត្ថេរាបទានទី ៩ | ...... ...... ...... ...... | ១៩៧ |
| អដ្ឋកថាធម្មចក្កិកត្ថេរាបទាន | ...... ...... ...... ...... | ១៩៨ |
| កប្បរុក្ខិយត្ថេរាបទានទី ១០ | ...... ...... ...... ...... | ២០០ |
| អដ្ឋកថាកប្បរុក្ខិយត្ថេរាបទាន | ...... ...... ...... ...... | ២០២ |

## ឧបាលិវគ្គទី ៥

ឧបាលិត្ថេរាបទានទី ១ ...... ...... ...... ...... ២០៤
អដ្ឋកថាឧបាលិត្ថេរាបទាន ...... ...... ...... ...... ២០៨
សោណកោឡិវិសត្ថេរាបទានទី ២ ...... ...... ...... ...... ២១១
អដ្ឋកថាសោណកោឡិវិសត្ថេរាបទាន ...... ...... ...... ២១៥
កង្ខារេវតត្ថេរាបទានទី ៣ ...... ...... ...... ...... ២១៨
អដ្ឋកថាកង្ខារេវតត្ថេរាបទាន ...... ...... ...... ...... ២២១
សន្និដ្ឋាបកត្ថេរាបទានទី ៤ ...... ...... ...... ...... ២២៤
អដ្ឋកថាសន្និដ្ឋាបកត្ថេរាបទាន ...... ...... ...... ...... ២២៥
បញ្ចហត្ថិយត្ថេរាបទានទី ៥ ...... ...... ...... ...... ២២៧
អដ្ឋកថាបញ្ចហត្ថិយត្ថេរាបទាន ...... ...... ...... ...... ២២៨
បទុមច្ឆទនិយត្ថេរាបទានទី ៦ ...... ...... ...... ...... ២៣០
អដ្ឋកថាបទុមច្ឆទនិយត្ថេរាបទាន ...... ...... ...... ...... ២៣១
សយនទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ២៣៣
អដ្ឋកថាសយនទាយកត្ថេរាបទាន ...... ...... ...... ...... ២៣៤
ចង្កមទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ២៣៥
អដ្ឋកថាចង្កមទាយកត្ថេរាបទាន ...... ...... ...... ...... ២៣៧
សុភទ្ទត្ថេរាបទានទី ៩ ...... ...... ...... ...... ២៣៩
អដ្ឋកថាសុភទ្ទត្ថេរាបទាន ...... ...... ...... ...... ២៤៣
ចុន្ទត្ថេរាបទានទី ១០ ...... ...... ...... ...... ២៤៨
អដ្ឋកថាចុន្ទត្ថេរាបទាន ...... ...... ...... ...... ២៥២

## វីជនីវគ្គទី ៦

វិធូបនទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ២៥៥
អដ្ឋកថាវិធូបនទាយកត្ថេរាបទាន ...... ...... ...... ...... ២៥៧
សតរំសិយត្ថេរាបទានទី ២ ...... ...... ...... ...... ២៥៩
អដ្ឋកថាសតរំសិយត្ថេរាបទាន ...... ...... ...... ...... ២៦១
សយនទាយកត្ថេរាបទានទី ៣ ...... ...... ...... ...... ២៦៣
អដ្ឋកថាសយនទាយកត្ថេរាបទាន ...... ...... ...... ...... ២៦៤
គន្ធោទកទាយកត្ថេរាបទានទី ៤ ...... ...... ...... ...... ២៦៦
អដ្ឋកថាគន្ធោទកទាយកត្ថេរាបទាន ...... ...... ...... ...... ២៦៧
ឱបវុយ្ហត្ថេរាបទានទី ៥ ...... ...... ...... ...... ២៦៩
អដ្ឋកថាឱបវយ្ហត្ថេរាបទាន ...... ...... ...... ...... ២៧១
សបរិវារាសនត្ថេរាបទានទី ៦ ...... ...... ...... ...... ២៧៣
អដ្ឋកថាសបរិវារាសនត្ថេរាបទាន ...... ...... ...... ...... ២៧៥
បញ្ចទីបកត្ថេរាបទានទី ៧ ...... ...... ...... ...... ២៧៧
អដ្ឋកថាបញ្ចទីបកត្ថេរាបទាន ...... ...... ...... ...... ២៧៨
ធជទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ២៨០
អដ្ឋកថាធជទាយកត្ថេរាបទាន ...... ...... ...... ...... ២៨២
បទុមត្ថេរាបទានទី ៩ ...... ...... ...... ...... ២៨៤
អដ្ឋកថាបទុមត្ថេរាបទាន ...... ...... ...... ...... ២៨៦
អសនពោធិយត្ថេរាបទានទី ១០ ...... ...... ...... ...... ២៨៨
អដ្ឋកថាអសនពោធិយត្ថេរាបទាន ...... ...... ...... ...... ២៩១

## សកចិត្តនិយវគ្គទី ៧


សកចិត្តនិយត្ថេរាបទានទី ១ ...... ...... ...... ...... ២៩៤
អដ្ឋកថាសកចិន្តនិយត្ថេរាបទាន ...... ...... ...... ...... ២៩៥
អាបោបុប្ផិយត្ថេរាបទានទី ២ ...... ...... ...... ...... ២៩៨
អដ្ឋកថាអាបោបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ២៩៩
បច្ចាគមនិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៣០២
អដ្ឋកថាបច្ចាគមនិយត្ថេរាបទាន ...... ...... ...... ...... ៣០៣
បរប្បសាទកត្ថេរាបទានទី ៤ ...... ...... ...... ...... ៣០៥
អដ្ឋកថាបរប្បសាទកត្ថេរាបទាន ...... ...... ...... ...... ៣០៧
ភិសទាយកត្ថេរាបទានទី ៥ ...... ...... ...... ...... ៣១០
អដ្ឋកថាភិសទាយកត្ថេរាបទាន ...... ...... ...... ...... ៣១២
សុចិន្តិតត្ថេរាបទានទី ៦ ...... ...... ...... ...... ៣១៥
អដ្ឋកថាសុចិន្តិតត្ថេរាបទាន ...... ...... ...... ...... ៣១៧
វត្ថទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ៣១៩
អដ្ឋកថាវត្ថទាយកត្ថេរាបទាន ...... ...... ...... ...... ៣២១
អម្ពទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៣២៣
អដ្ឋកថាអម្ពទាយកត្ថេរាបទាន ...... ...... ...... ...... ៣២៥
សុមនត្ថេរាបទានទី ៩ ...... ...... ...... ...... ៣២៧
អដ្ឋកថាសុមនត្ថេរាបទាន ...... ...... ...... ...... ៣២៨
បុប្ផចង្កោដិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៣៣០
អដ្ឋកថាបុប្ផចង្កោដិយត្ថេរាបទាន ...... ...... ...... ...... ៣៣២

## ឆាតសមាលវគ្គទី ៨


| | | |
|---|---|---|
| នាគសមាលត្ថេរាបទានទី ១ | ...... ...... ...... ...... | ៣៣៥ |
| អដ្ឋកថានាគសមាលត្ថេរាបទាន | ...... ...... ...... ...... | ៣៣៦ |
| បទសញ្ញកត្ថេរាបទានទី ២ | ...... ...... ...... ...... | ៣៣៨ |
| អដ្ឋកថាបទសញ្ញកត្ថេរាបទាន | ...... ...... ...... ...... | ៣៣៩ |
| សុសញ្ញកត្ថេរាបទានទី ៣ | ...... ...... ...... ...... | ៣៤១ |
| អដ្ឋកថាសុសញ្ញកត្ថេរាបទាន | ...... ...... ...... ...... | ៣៤២ |
| កិសាលុវទាយកត្ថេរាបទានទី ៤ | ...... ...... ...... ...... | ៣៤៤ |
| អដ្ឋកថាកិសាលុវទាយកត្ថេរាបទាន | ...... ...... ...... ...... | ៣៤៥ |
| ឯកសញ្ញកត្ថេរាបទានទី ៥ | ...... ...... ...... ...... | ៣៤៧ |
| អដ្ឋកថាឯកសញ្ញកត្ថេរាបទាន | ...... ...... ...... ...... | ៣៤៨ |
| តិណសន្ថារទាយកត្ថេរាបទានទី ៦ | ...... ...... ...... ...... | ៣៤៩ |
| អដ្ឋកថាតិណសន្ថរទាយកត្ថេរាបទាន | ...... ...... ...... ...... | ៣៥១ |
| សូចិទាយកត្ថេរាបទានទី ៧ | ...... ...... ...... ...... | ៣៥៣ |
| អដ្ឋកថាសូចិទាយកត្ថេរាបទាន | ...... ...... ...... ...... | ៣៥៤ |
| បាដលិបុប្ផិយត្ថេរាបទានទី ៨ | ...... ...... ...... ...... | ៣៥៥ |
| អដ្ឋកថាបាដលិបុប្ផិយត្ថេរាបទាន | ...... ...... ...... ...... | ៣៥៦ |
| ឋិតញ្ជលិយត្ថេរាបទានទី ៩ | ...... ...... ...... ...... | ៣៥៨ |
| អដ្ឋកថាឋិតញ្ជលិយត្ថេរាបទាន | ...... ...... ...... ...... | ៣៥៩ |
| តីណិបទុមិយត្ថេរាបទានទី ១០ | ...... ...... ...... ...... | ៣៦២ |
| អដ្ឋកថាតីណិបទុមិយត្ថេរាបទាន | ...... ...... ...... ...... | ៣៦៦ |

## តិមិរបុប្ផិយវគ្គទី ៩

តិមិរបុប្ផិយត្ថេរាបទានទី ១ ...... ...... ...... ...... ៣៦៨
អដ្ឋកថាតិមិរបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៣៧០
គតសញ្ញកត្ថេរាបទានទី ២ ...... ...... ...... ...... ៣៧៣
អដ្ឋកថាគតសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៣៧៤
និបន្នញ្ជលិកត្ថេរាបទានទី ៣ ...... ...... ...... ...... ៣៧៦
អដ្ឋកថានិបន្នញ្ជលិកត្ថេរាបទាន ...... ...... ...... ...... ៣៧៧
អធោបុប្ផិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៣៧៩
អដ្ឋកថាអធោបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៣៨១
រំសិសញ្ញិកត្ថេរាបទានទី ៥ ...... ...... ...... ...... ៣៨៣
អដ្ឋកថារំសិសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៣៨៤
រំសិសញ្ញិកត្ថេរាបទានទី ៦ ...... ...... ...... ...... ៣៨៦
អដ្ឋកថាទុតិយរំសិសញ្ញិកត្ថេរាបទាន ...... ...... ...... ...... ៣៨៧
ផលទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ៣៨៩
អដ្ឋកថាផលទាយកត្ថេរាបទាន ...... ...... ...... ...... ៣៩០
សទ្ទសញ្ញកត្ថេរាបទានទី ៨ ...... ...... ...... ...... ៣៩១
អដ្ឋកថាសទ្ទសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៣៩២
ពោធិសិញ្ចកត្ថេរាបទានទី ៩ ...... ...... ...... ...... ៣៩៣
អដ្ឋកថាពោធិសិញ្ចកត្ថេរាបទាន ...... ...... ...... ...... ៣៩៤
បទុមបុប្ផិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៣៩៦
អដ្ឋកថាបទុមបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៣៩៨

## សុធាវគ្គទី ១០

សុធាបិណ្ឌិយត្ថេរាបទានទី ១ ...... ...... ...... ...... ៤០០
អដ្ឋកថាសុធាបិណ្ឌិយត្ថេរាបទាន ...... ...... ...... ...... ៤០២
សុចីបិយត្ថេរាបទានទី ២ ...... ...... ...... ...... ៤០៥
អដ្ឋកថាសុចីបិយត្ថេរាបទាន ...... ...... ...... ...... ៤០៦
អឌ្ឍចេលកត្ថេរាបទានទី ៣ ...... ...... ...... ...... ៤០៧
អដ្ឋកថាអឌ្ឍចេលកត្ថេរាបទាន ...... ...... ...... ...... ៤០៨
សូចិទាយកត្ថេរាបទានទី ៤ ...... ...... ...... ...... ៤០៩
អដ្ឋកថាសូចិទាយកត្ថេរាបទាន ...... ...... ...... ...... ៤១០
គន្ធមាលិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៤១២
អដ្ឋកថាគន្ធមាលិយត្ថេរាបទាន ...... ...... ...... ...... ៤១៣
តិបុប្ផិយត្ថេរាបទានទី ៦ ...... ...... ...... ...... ៤១៤
អដ្ឋកថាតិបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៤១៥
មធុបិណ្ឌិកត្ថេរាបទានទី ៧ ...... ...... ...... ...... ៤១៧
អដ្ឋកថាមធុបិណ្ឌិកត្ថេរាបទាន ...... ...... ...... ...... ៤១៩
សេនាសនទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៤២១
អដ្ឋកថាសេនាសនទាយកត្ថេរាបទាន ...... ...... ...... ...... ៤២២
វេយ្យាវច្ចកត្ថេរាបទានទី ៩ ...... ...... ...... ...... ៤២៣
អដ្ឋកថាវេយ្យាវច្ចកត្ថេរាបទាន ...... ...... ...... ...... ៤២៤
ពុទ្ធុបដ្ឋាកត្ថេរាបទានទី ១០ ...... ...... ...... ...... ៤២៥
អដ្ឋកថាពុទ្ធុបដ្ឋាកត្ថេរាបទាន ...... ...... ...... ...... ៤២៧

# សុត្តន្តបិដក បាលីប្រែ -៧៣

## ភិក្ខាទាយិវគ្គទី ១១

ភិក្ខាទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ៤២៩
អដ្ឋកថាភិក្ខាទាយកត្ថេរាបទាន ...... ...... ...... ...... ៤៣១
ញាណសញ្ញិកត្ថេរាបទានទី ២ ...... ...... ...... ...... ៤៣៣
អដ្ឋកថាញាណសញ្ញិកត្ថេរាបទាន ...... ...... ...... ...... ៤៣៤
ឧប្បលហត្ថិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៤៣៦
អដ្ឋកថាឧប្បលហត្ថិយត្ថេរាបទាន ...... ...... ...... ...... ៤៣៧
បទបូជកត្ថេរាបទានទី ៤ ...... ...... ...... ...... ៤៣៩
អដ្ឋកថាបទបូជកត្ថេរាបទាន ...... ...... ...... ...... ៤៤០
មុដ្ឋិបុប្ផិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៤៤២
អដ្ឋកថាមុដ្ឋិបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៤៤៣
ឧទកបូជកត្ថេរាបទានទី ៦ ...... ...... ...... ...... ៤៤៥
អដ្ឋកថាឧទកបូជកត្ថេរាបទាន ...... ...... ...... ...... ៤៤៦
នឡមាលិយត្ថេរាបទានទី ៧ ...... ...... ...... ...... ៤៤៨
អដ្ឋកថានឡមាលិយត្ថេរាបទាន ...... ...... ...... ...... ៤៥០
អាសនុបដ្ឋាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៤៥២
អដ្ឋកថាអាសនុបដ្ឋាយកត្ថេរាបទាន ...... ...... ...... ...... ៤៥៣
ពិឡាលិទាយកត្ថេរាបទានទី ៩ ...... ...... ...... ...... ៤៥៤
អដ្ឋកថាពិឡាលិទាយកត្ថេរាបទាន ...... ...... ...... ...... ៤៥៦
រេណុបូជកត្ថេរាបទានទី ១០ ...... ...... ...... ...... ៤៥៨

សទ្ទឹកប្រាប់មាតិកា ៩២២

អដ្ឋកថារេណុបូជកត្ថេរាបទាន ...... ...... ...... ...... ៤៦០

មហាបរិវារវគ្គទី ១២

មហាបរិវារត្ថេរាបទានទី ១ ...... ...... ...... ...... ៤៦២

អដ្ឋកថាមហាបរិវារត្ថេរាបទាន ...... ...... ...... ...... ៤៦៤

សុមង្គលត្ថេរាបទានទី ២ ...... ...... ...... ...... ៤៦៦

អដ្ឋកថាសុមង្គលត្ថេរាបទាន ...... ...... ...... ...... ៤៦៨

សរណគមនិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៤៧០

អដ្ឋកថាសរណគមនិយត្ថេរាបទាន ...... ...... ...... ...... ៤៧២

ឯកាសនិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៤៧៤

អដ្ឋកថាឯកាសនិយត្ថេរាបទាន ...... ...... ...... ...... ៤៧៦

សុវណ្ណបុប្ផិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៤៧៨

អដ្ឋកថាសុវណ្ណបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៤៨០

ចិតកបូជកត្ថេរាបទានទី ៦ ...... ...... ...... ...... ៤៨២

អដ្ឋកថាចិតកបូជកត្ថេរាបទាន ...... ...... ...... ...... ៤៨៤

ពុទ្ធសញ្ញកត្ថេរាបទានទី ៧ ...... ...... ...... ...... ៤៨៦

អដ្ឋកថាពុទ្ធសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៤៨៨

មគ្គសញ្ញកត្ថេរាបទានទី ៨ ...... ...... ...... ...... ៤៩០

អដ្ឋកថាមគ្គសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៤៩១

បច្චុបដ្ឋានសញ្ញកត្ថេរាបទានទី ៩ ...... ...... ...... ...... ៤៩៣

អដ្ឋកថាបច្ចុបដ្ឋានសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៤៩៥

ជាតិបូជកត្ថេរាបទានទី ១០ ...... ...... ...... ...... ៤៩៧

អដ្ឋកថាជាតិបូជកត្ថេរាបទាន ...... ...... ...... ...... ៤៩៩

សេរេយ្យវគ្គទី ១៣

សេរេយ្យកត្ថេរាបទានទី ១ ...... ...... ...... ...... ៥០១

អដ្ឋកថាសេរេយ្យកត្ថេរាបទាន ...... ...... ...... ...... ៥០៣

បុប្ផថូបិយត្ថេរាបទានទី ២ ...... ...... ...... ...... ៥០៥

អដ្ឋកថាបុប្ផថូបិយត្ថេរាបទាន ...... ...... ...... ...... ៥០៨

បាយាសទាយកត្ថេរាបទានទី ៣ ...... ...... ...... ...... ៥១០

អដ្ឋកថាបាយសទាយកត្ថេរាបទាន ...... ...... ...... ...... ៥១២

គន្ធោទកិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៥១៤

អដ្ឋកថាគន្ធោទកិយត្ថេរាបទាន ...... ...... ...... ...... ៥១៥

សម្មុខាថវិកត្ថេរាបទានទី ៥ ...... ...... ...... ...... ៥១៧

អដ្ឋកថាសម្មុខាថវិកត្ថេរាបទាន ...... ...... ...... ...... ៥២០

កុសុមាសនិយត្ថេរាបទានទី ៦ ...... ...... ...... ...... ៥២២

អដ្ឋកថាកុសុមាសនិយត្ថេរាបទាន ...... ...... ...... ...... ៥២៤

ផលទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ៥២៧

អដ្ឋកថាផលទាយកត្ថេរាបទាន ...... ...... ...... ...... ៥២៩

ញាណសញ្ញកត្ថេរាបទានទី ៨ ...... ...... ...... ...... ៥៣២

អដ្ឋកថាញាណសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៥៣៤

គន្ធបុប្ផិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៥៣៦

អដ្ឋកថាគន្ធបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៥៣៧

បទុមបូជកត្ថេរាបទានទី ១០ ...... ...... ...... ...... ៥៣៨

សន្ទឹកប្រាប់មាតិកា ៩២៤

អដ្ឋកថាបទុមបូជកត្ថេរាបទាន ...... ...... ...... ...... ៥៤០

**សោភិតវគ្គទី ១៤**

សោភិតត្ថេរាបទានទី ១ ...... ...... ...... ...... ៥៤៣

អដ្ឋកថាសោភិតត្ថេរាបទាន ...... ...... ...... ...... ៥៤៥

សុទស្សនត្ថេរាបទានទី ២ ...... ...... ...... ...... ៥៤៧

អដ្ឋកថាសុទស្សនត្ថេរាបទាន ...... ...... ...... ...... ៥៤៨

ចន្ទនបូជកត្ថេរាបទានទី ៣ ...... ...... ...... ...... ៥៥០

អដ្ឋកថាចន្ទនបូជកត្ថេរាបទាន ...... ...... ...... ...... ៥៥២

បុប្ផឆទនិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៥៥៤

អដ្ឋកថាបុប្ផឆទនិយត្ថេរាបទាន ...... ...... ...... ...... ៥៥៦

រហោសញ្ញិកត្ថេរាបទានទី ៥ ...... ...... ...... ...... ៥៥៨

អដ្ឋកថារហោសញ្ញិកត្ថេរាបទាន ...... ...... ...... ...... ៥៥៩

ចម្បកបុប្ផិយត្ថេរាបទានទី ៦ ...... ...... ...... ...... ៥៦១

អដ្ឋកថាចម្បកបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៥៦២

អត្ថសន្ទស្សកត្ថេរាបទានទី ៧ ...... ...... ...... ...... ៥៦៤

អដ្ឋកថាអត្ថសន្ទស្សកត្ថេរាបទាន ...... ...... ...... ...... ៥៦៦

ឯករំសិយត្ថេរាបទានទី ៨ ...... ...... ...... ...... ៥៦៨

អដ្ឋកថាឯករំសិយត្ថេរាបទាន ...... ...... ...... ...... ៥៦៩

សាលទាយកត្ថេរាបទានទី ៩ ...... ...... ...... ...... ៥៧១

អដ្ឋកថាសាលទាយកត្ថេរាបទាន ...... ...... ...... ...... ៥៧២

ផលទាយកត្ថេរាបទានទី ១០ ...... ...... ...... ...... ៥៧៤

អដ្ឋកថាផលទាយកត្ថេរាបទាន ...... ...... ...... ...... ៥៧៦

## ឆត្តវគ្គទី ១៩

អធិចត្តិយត្ថេរាបទានទី ១ ...... ...... ...... ...... ៥៧៨

អដ្ឋកថាអធិចត្តិយត្ថេរាបទាន ...... ...... ...... ...... ៥៧៩

ថម្ភារោបកត្ថេរាបទានទី ២ ...... ...... ...... ...... ៥៨១

អដ្ឋកថាថម្ភារោបកត្ថេរាបទាន ...... ...... ...... ...... ៥៨២

វេទិការកត្ថេរាបទានទី ៣ ...... ...... ...... ...... ៥៨៥

អដ្ឋកថាវេទិការកត្ថេរាបទាន ...... ...... ...... ...... ៥៨៦

សបរិវារិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៥៨៨

អដ្ឋកថាសបរិវារិយត្ថេរាបទាន ...... ...... ...... ...... ៥៨៩

ឧម្មាបុប្ផិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៥៩១

អដ្ឋកថាឧម្មាបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៥៩២

អនុលោមទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៥៩៤

អដ្ឋកថាអនុលោមទាយកត្ថេរាបទាន ...... ...... ...... ...... ៥៩៥

មគ្គទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ៥៩៧

អដ្ឋកថាមគ្គទាយកត្ថេរាបទាន ...... ...... ...... ...... ៥៩៨

ផលកទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៦០០

អដ្ឋកថាផលកទាយកត្ថេរាបទាន ...... ...... ...... ...... ៦០១

វដំសកិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៦០៣

អដ្ឋកថាវដំសកិយត្ថេរាបទាន ...... ...... ...... ...... ៦០៤

បល្លង្កទាយកត្ថេរាបទានទី ១០ ...... ...... ...... ...... ៦០៦

អដ្ឋកថាបលក្ខទាយកត្ថេរាបទាន ...... ...... ...... ...... ៦០៨

## ពន្ធុជីវកវគ្គទី ១៦

ពន្ធុជីវកត្ថេរាបទានទី ១ ...... ...... ...... ...... ៦១០

អដ្ឋកថាពន្ធុជីវកត្ថេរាបទាន ...... ...... ...... ...... ៦១២

តម្ពបុប្ផិយត្ថេរាបទានទី ២ ...... ...... ...... ...... ៦១៥

អដ្ឋកថាតម្ពបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៦១៧

វីថិសម្មជ្ជកត្ថេរាបទានទី ៣ ...... ...... ...... ...... ៦១៩

អដ្ឋកថាវីថិសម្មជ្ជកត្ថេរាបទាន ...... ...... ...... ...... ៦២០

កក្ការុបូជកត្ថេរាបទានទី ៤ ...... ...... ...... ...... ៦២២

អដ្ឋកថាកក្ការុបូជកត្ថេរាបទាន ...... ...... ...... ...... ៦២៣

មន្ទារវបុប្ផបូជកត្ថេរាបទានទី ៥ ...... ...... ...... ...... ៦២៤

អដ្ឋកថាមន្ទារវបុប្ផបូជកត្ថេរាបទាន ...... ...... ...... ...... ៦២៥

កទម្ពបុប្ផិយត្ថេរាបទានទី ៦ ...... ...... ...... ...... ៦២៦

អដ្ឋកថាកទម្ពបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៦២៧

តិណសូលកត្ថេរាបទានទី ៧ ...... ...... ...... ...... ៦២៩

អដ្ឋកថាតិណសូលកត្ថេរាបទាន ...... ...... ...... ...... ៦៣០

នាគបុប្ផិយត្ថេរាបទានទី ៨ ...... ...... ...... ...... ៦៣២

អដ្ឋកថានាគបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៦៣៣

បុន្នាគបុប្ផិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៦៣៥

អដ្ឋកថាបុន្នាគបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៦៣៦

កុមុទទាយកត្ថេរាបទានទី ១០ ...... ...... ...... ...... ៦៣៧

អដ្ឋកថាកុមុទទាយកត្ថេរាបទាន ...... ...... ...... ...... ៦៣៩

## សុចារិចរិយវគ្គទី ១៧

សុចារិចរិយត្ថេរាបទានទី ១ ...... ...... ...... ...... ៦៤១

អដ្ឋកថាសុចារិចរិយត្ថេរាបទាន ...... ...... ...... ...... ៦៤៣

កណវេរបុប្ផិយត្ថេរាបទានទី ២ ...... ...... ...... ...... ៦៤៥

អដ្ឋកថាកណវេរបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៦៤៦

ខជ្ជទាយកត្ថេរាបទានទី ៣ ...... ...... ...... ...... ៦៤៧

អដ្ឋកថាខជ្ជកទាយកត្ថេរាបទាន ...... ...... ...... ...... ៦៤៨

ទេសបូជកត្ថេរាបទានទី ៤ ...... ...... ...... ...... ៦៥០

អដ្ឋកថាទេសបូជកត្ថេរាបទាន ...... ...... ...... ...... ៦៥១

កណិការច្ឆទនិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៦៥៣

អដ្ឋកថាកណិការច្ឆទនិយត្ថេរាបទាន ...... ...... ...... ...... ៦៥៤

សប្បិទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៦៥៦

អដ្ឋកថាសប្បិទាយកត្ថេរាបទាន ...... ...... ...... ...... ៦៥៧

យូថិកបុប្ផិយត្ថេរាបទានទី ៧ ...... ...... ...... ...... ៦៥៩

អដ្ឋកថាយូថិកបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៦៦០

ទុស្សទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៦៦១

អដ្ឋកថាទុស្សទាយកត្ថេរាបទាន ...... ...... ...... ...... ៦៦២

សមាទបកត្ថេរាបទានទី ៩ ...... ...... ...... ...... ៦៦៤

អដ្ឋកថាសមាទបកត្ថេរាបទាន ...... ...... ...... ...... ៦៦៥

បញ្ចង្គុលិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៦៦៧

អដ្ឋកថាបញ្ចង្គុលិយត្ថេរាបទាន ...... ...... ...... ...... ៦៦៩

## កុមុទវគ្គទី ១៨

កុមុទមាលិយត្ថេរាបទានទី ១ ...... ...... ...... ...... ៦៧១
អដ្ឋកថាកុមុទមាលិយត្ថេរាបទាន ...... ...... ...... ...... ៦៧៣
និស្សេណិទាយកត្ថេរាបទានទី ២ ...... ...... ...... ...... ៦៧៥
អដ្ឋកថានិស្សេណិទាយកត្ថេរាបទាន ...... ...... ...... ...... ៦៧៦
រត្តិយបុប្ផិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៦៧៨
អដ្ឋកថារត្តិយបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៦៧៩
ឧទបានទាយកត្ថេរាបទានទី ៤ ...... ...... ...... ...... ៦៨១
អដ្ឋកថាឧទបានទាយកត្ថេរាបទាន ...... ...... ...... ...... ៦៨២
សីហាសនទាយកត្ថេរាបទានទី ៥ ...... ...... ...... ...... ៦៨៤
អដ្ឋកថាសីហាសនទាយកត្ថេរាបទាន ...... ...... ...... ...... ៦៨៥
មគ្គទត្តិកត្ថេរាបទានទី ៦ ...... ...... ...... ...... ៦៨៧
អដ្ឋកថាមគ្គទត្តិកត្ថេរាបទាន ...... ...... ...... ...... ៦៨៨
ឯកទីបិយត្ថេរាបទានទី ៧ ...... ...... ...... ...... ៦៩០
អដ្ឋកថាឯកទីបិយត្ថេរាបទាន ...... ...... ...... ...... ៦៩១
មណិបូជកត្ថេរាបទានទី ៨ ...... ...... ...... ...... ៦៩២
អដ្ឋកថាមណិបូជកត្ថេរាបទាន ...... ...... ...... ...... ៦៩៣
តិកិច្ឆកត្ថេរាបទានទី ៩ ...... ...... ...... ...... ៦៩៥
អដ្ឋកថាតិកិច្ឆកត្ថេរាបទាន ...... ...... ...... ...... ៦៩៦
សង្ឃុបដ្ឋាកត្ថេរាបទានទី ១០ ...... ...... ...... ...... ៦៩៨

អដ្ឋកថាសង្ឃុបដ្ឋាកត្ថេរាបទាន ...... ...... ...... ...... ៧០០

## កុដជបុប្ផិយវគ្គទី ១៩

កុដជបុប្ផិយត្ថេរាបទានទី ១ ...... ...... ...... ...... ៧០២
ពន្ធុជីវកត្ថេរាបទានទី ២ ...... ...... ...... ...... ៧០៣
កោតុម្ពរិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៧០៤
បញ្ចហត្ថិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៧០៥
ឥសិមុគ្គទាយកត្ថេរាបទានទី ៥ ...... ...... ...... ...... ៧០៦
ពោធិឧបដ្ឋាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៧០៧
ឯកចិន្តិកត្ថេរាបទានទី ៧ ...... ...... ...... ...... ៧០៨
តិកណ្ណិបុប្ផិយត្ថេរាបទានទី ៨ ...... ...... ...... ...... ៧១០
ឯកចារិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៧១១
តិវណ្ដិបុប្ផិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៧១២
អដ្ឋកថាកុដជបុប្ផិយត្ថេរាបទានជាដើម ...... ...... ...... ...... ៧១៤

## តមាលបុប្ផិយវគ្គទី ២០

តមាលបុប្ផិយត្ថេរាបទានទី ១ ...... ...... ...... ...... ៧១៥
អដ្ឋកថាតមាលបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៧១៦
តិណសន្ថារទាយកត្ថេរាបទានទី ២ ...... ...... ...... ...... ៧១៧
អដ្ឋកថាតិណសន្ថារទាយកត្ថេរាបទាន ...... ...... ...... ...... ៧១៨
ខណ្ឌផុល្លិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៧១៩
អដ្ឋកថាខណ្ឌផុល្លិយត្ថេរាបទាន ...... ...... ...... ...... ៧២០
អសោកបូជកត្ថេរាបទានទី ៤ ...... ...... ...... ...... ៧២១
អដ្ឋកថាអសោកបូជកត្ថេរាបទាន ...... ...... ...... ...... ៧២២

អង្គាលកត្ថេរាបទានទី ៥ ...... ...... ...... ...... ៧២៣
អដ្ឋកថាអង្គោលកត្ថេរាបទាន ...... ...... ...... ...... ៧២៤
កិសលយបូជកត្ថេរាបទានទី ៦ ...... ...... ...... ...... ៧២៥
អដ្ឋកថាកិសលយបូជកត្ថេរាបទាន ...... ...... ...... ...... ៧២៦
តិន្ទុកទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ៧២៧
គិរិនេលមុដ្ឋិបូជកត្ថេរាបទានទី ៨ ...... ...... ...... ...... ៧២៨
តិកណ្ណិបុប្ផិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៧២៩
យូថិកបុប្ផិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៧៣០
អដ្ឋកថាតិន្ទុកទាយកត្ថេរាបទានជាដើម ...... ...... ...... ...... ៧៣២

## កណិការបុប្ផិយវគ្គទី ២១

កណិការបុប្ផិយត្ថេរាបទានទី ១ ...... ...... ...... ...... ៧៣៣
មិនេលបុប្ផិយត្ថេរាបទានទី ២ ...... ...... ...... ...... ៧៣៤
កឹកណិកបុប្ផិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៧៣៥
តរណិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៧៣៦
និគ្គុណ្ឌិបុប្ផិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៧៣៧
ឧទកទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៧៣៨
សលឡមាលិយត្ថេរាបទានទី ៧ ...... ...... ...... ...... ៧៣៩
កោរណ្ឌបុប្ផិយត្ថេរាបទានទី ៨ ...... ...... ...... ...... ៧៤០
អាធារទាយកត្ថេរាបទានទី ៩ ...... ...... ...... ...... ៧៤១
បាបនិវារិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៧៤២

## ហត្ថិវគ្គទី ២២

ហត្ថិទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ៧៤៤
បានធិទាយកត្ថេរាបទានទី ២ ...... ...... ...... ...... ៧៤៥

សច្ចសញ្ញកត្ថេរាបទានទី ៣ ...... ...... ...... ...... ៧៤៦
ឯកសញ្ញកត្ថេរាបទានទី ៤ ...... ...... ...... ...... ៧៤៧
រំសិសញ្ញកត្ថេរាបទានទី ៥ ...... ...... ...... ...... ៧៤៨
សន្ធិតត្ថេរាបទានទី ៦ ...... ...... ...... ...... ៧៤៩
តាលវណ្ដទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ៧៥០
អក្កន្តសញ្ញកត្ថេរាបទានទី ៨ ...... ...... ...... ...... ៧៥១
សប្បិទាយកត្ថេរាបទានទី ៩ ...... ...... ...... ...... ៧៥២
បាបនិវារិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៧៥៣

## អាលម្ពនទាយកវគ្គទី ២៣

អាលម្ពនទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ៧៥៤
អជិនទាយកត្ថេរាបទានទី ២ ...... ...... ...... ...... ៧៥៥
ទេវរតនិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៧៥៦
អារក្ខទាយកត្ថេរាបទានទី ៤ ...... ...... ...... ...... ៧៥៧
អព្យាធិកត្ថេរាបទានទី ៥ ...... ...... ...... ...... ៧៥៨
វកុលបុប្ផិយត្ថេរាបទានទី ៦ ...... ...... ...... ...... ៧៥៩
សោវណ្ណវដំសកិយត្ថេរាបទានទី ៧ ...... ...... ...... ...... ៧៦០
មិញ្ជវដំសកិយត្ថេរាបទានទី ៨ ...... ...... ...... ...... ៧៦១
សុកតាវេឡិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៧៦២
ឯកវន្ទនិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៧៦៣
អដ្ឋកថាបុប្ផិយវគ្គទី ២១ ជាដើម ...... ...... ...... ...... ៧៦៥

## ឧទកាសនទាយិវគ្គទី ២៤

ឧទកាសនទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ៧៦៦

កាជនទាយកត្ថេរាបទានទី ២ ...... ...... ...... ...... ៧៦៧
អដ្ឋកថាឧទកាសនទាយកត្ថេរាបទានជាដើម ...... ...... ...... ...... ៧៦៨
សាលបុប្ផិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៧៦៩
អដ្ឋកថាសាលបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៧៧០
កិលញ្ជទាយកត្ថេរាបទានទី ៤ ...... ...... ...... ...... ៧៧១
អដ្ឋកថាកិលញ្ជទាយកត្ថេរាបទាន ...... ...... ...... ...... ៧៧២
វេទិទាយកត្ថេរាបទានទី ៥ ...... ...... ...... ...... ៧៧៣
អដ្ឋកថាវេទិទាយកត្ថេរាបទាន ...... ...... ...... ...... ៧៧៤
វណ្ណការកត្ថេរាបទានទី ៦ ...... ...... ...... ...... ៧៧៥
អដ្ឋកថាវណ្ណការកត្ថេរាបទាន ...... ...... ...... ...... ៧៧៦
បិយាលបុប្ផិយត្ថេរាបទានទី ៧ ...... ...... ...... ...... ៧៧៧
អដ្ឋកថាបិយាលបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៧៧៨
អម្ពយាគទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៧៧៩
អដ្ឋកថាអម្ពយាគទាយកត្ថេរាបទាន ...... ...... ...... ...... ៧៨០
ជគតិការកត្ថេរាបទានទី ៩ ...... ...... ...... ...... ៧៨១
អដ្ឋកថាជគតិការកត្ថេរាបទាន ...... ...... ...... ...... ៧៨២
វាសិទាយកត្ថេរាបទានទី ១០ ...... ...... ...... ...... ៧៨៣
អដ្ឋកថាវាសិទាយកត្ថេរាបទាន ...... ...... ...... ...... ៧៨៤

## តុវរទាយិវគ្គទី ២៥

តុវរដ្ឋិទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ៧៨៥
អដ្ឋកថាតុវរដ្ឋិទាយកត្ថេរាបទាន ...... ...... ...... ...... ៧៨៦
នាគកេសរិយត្ថេរាបទានទី ២ ...... ...... ...... ...... ៧៨៧
អដ្ឋកថានាគកេសរិយត្ថេរាបទាន ...... ...... ...... ...... ៧៨៨

នឡិនកេសរិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៧៨៩
អដ្ឋកថានឡិនកេសរិយត្ថេរាបទាន ...... ...... ...... ...... ៧៩០
វិរវិបុប្ផិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៧៩១
អដ្ឋកថាវិរវិបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៧៩២
កុដិធូបកត្ថេរាបទានទី ៥ ...... ...... ...... ...... ៧៩៣
អដ្ឋកថាកុដិធូបកត្ថេរាបទាន ...... ...... ...... ...... ៧៩៤
បត្តទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៧៩៥
ធាតុបូជកត្ថេរាបទានទី ៧ ...... ...... ...... ...... ៧៩៦
អដ្ឋកថាបត្តទាយកត្ថេរាបទានជាដើម ...... ...... ...... ...... ៧៩៧
សត្តសត្តលិបុប្ផបូជកត្ថេរាបទានទី ៨ ...... ...... ...... ...... ៧៩៨
អដ្ឋកថាសត្តសត្តលិបុប្ផបូជកត្ថេរាបទាន ...... ...... ...... ...... ៧៩៩
ពិម្ពិជាលបុប្ផិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៨០០
អដ្ឋកថាពិម្ពិជាលបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៨០១
ឧទ្ទាលទាយកត្ថេរាបទានទី ១០ ...... ...... ...... ...... ៨០២
អដ្ឋកថាឧទ្ទាលទាយកត្ថេរាបទាន ...... ...... ...... ...... ៨០៣

**ថោមកវគ្គទី ២៦**

ថោមកត្ថេរាបទានទី ១ ...... ...... ...... ...... ៨០៤
អដ្ឋកថាថោមកត្ថេរាបទាន ...... ...... ...... ...... ៨០៥
ឯកាសនទាយកត្ថេរាបទានទី ២ ...... ...... ...... ...... ៨០៦
អដ្ឋកថាឯកាសនទាយកត្ថេរាបទាន ...... ...... ...... ...... ៨០៧
ចិតកបូជកត្ថេរាបទានទី ៣ ...... ...... ...... ...... ៨០៨
អដ្ឋកថាចិតកបូជកត្ថេរាបទាន ...... ...... ...... ...... ៨០៩
ចម្បកបុប្ផិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៨១០

សត្តបាដលិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៨១១
អដ្ឋកថាចម្បកបុប្ផិយត្ថេរាបទានជាដើម ...... ...... ...... ...... ៨១២
ឧបាហនទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៨១៣
អដ្ឋកថាឧបាហនទាយកត្ថេរាបទាន ...... ...... ...... ...... ៨១៤
មញ្ជរិបូជកត្ថេរាបទានទី ៧ ...... ...... ...... ...... ៨១៥
អដ្ឋកថាមញ្ជរិបូជកត្ថេរាបទាន ...... ...... ...... ...... ៨១៦
បណ្ណទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៨១៧
អដ្ឋកថាបណ្ណទាយកត្ថេរាបទាន ...... ...... ...... ...... ៨១៨
កុដិទាយកត្ថេរាបទានទី ៩ ...... ...... ...... ...... ៨១៩
អដ្ឋកថាកុដិទាយកត្ថេរាបទាន ...... ...... ...... ...... ៨២០
អគ្គបុប្ផិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៨២១
អដ្ឋកថាអគ្គបុប្ផិយត្ថេរាបទាន ...... ...... ...... ...... ៨២៣

## សុត្តន្តបិដក ចាលីប្រែ -៧៤

### បទុមុត្ថេរវគ្គទី ២៧

អាកាសុក្ខិបិយត្ថេរាបទានទី ១ ...... ...... ...... ...... ៨២៤
អដ្ឋកថាអាកាសុក្ខិបិយត្ថេរាបទាន ...... ...... ...... ...... ៨២៥
តេលមក្ខិយត្ថេរាបទានទី ២ ...... ...... ...... ...... ៨២៦
អដ្ឋកថាតេលមក្ខិយត្ថេរាបទាន ...... ...... ...... ...... ៨២៧
អឌ្ឍចន្ទិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៨២៨
អដ្ឋកថាអឌ្ឍចន្ទិយត្ថេរាបទាន ...... ...... ...... ...... ៨២៩
ទីបទាយកត្ថេរាបទានទី ៤ ...... ...... ...... ...... ៨៣០
អដ្ឋកថាទីបទាយកត្ថេរាបទាន ...... ...... ...... ...... ៨៣១
ពិឡាលិទាយកត្ថេរាបទានទី ៥ ...... ...... ...... ...... ៨៣២

សន្ទឹកប្រាប់មាតិកា ៩៣៥


អដ្ឋកថាវិឡាលិទាយកត្ថេរាបទាន ...... ...... ...... ...... ៨៣៣
មច្ឆទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៨៣៤
ជវហំសកត្ថេរាបទានទី ៧ ...... ...... ...... ...... ៨៣៥
សលឡបុប្ផិយត្ថេរាបទានទី ៨ ...... ...... ...... ...... ៨៣៦
ឧបាគតហាសនិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៨៣៧
តរណិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៨៣៨
មច្ឆទាយកត្ថេរាបទានជាដើម ...... ...... ...... ...... ៨៤០

## សុវណ្ណពិព្វោហនវគ្គទី ២៨

សុវណ្ណពិព្វោហនិយត្ថេរាបទានទី ១ ...... ...... ...... ...... ៨៤១
អដ្ឋកថាសុវណ្ណពិព្វោហនិយត្ថេរាបទាន ...... ...... ...... ...... ៨៤២
តិលមុដ្ឋិយត្ថេរាបទានទី ២ ...... ...... ...... ...... ៨៤៣
អដ្ឋកថាតិលមុដ្ឋិយត្ថេរាបទាន ...... ...... ...... ...... ៨៤៤
ចង្កោដកិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៨៤៥
អដ្ឋកថាចង្កោដកិយត្ថេរាបទាន ...... ...... ...... ...... ៨៤៦
អព្ភញ្ជនទាយកត្ថេរាបទានទី ៤ ...... ...... ...... ...... ៨៤៧
អដ្ឋកថាអព្ភញ្ជនទាយកត្ថេរាបទាន ...... ...... ...... ...... ៨៤៨
ឯកញ្ជលិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៨៤៩
អដ្ឋកថាឯកញ្ជលិយត្ថេរាបទាន ...... ...... ...... ...... ៨៥០
បោត្ថទាយកត្ថេរាបទានទី ៦ ...... ...... ...... ...... ៨៥១
អដ្ឋកថាបោត្ថទាយកត្ថេរាបទាន ...... ...... ...... ...... ៨៥២
ចិតកបូជកត្ថេរាបទានទី ៧ ...... ...... ...... ...... ៨៥៣
អដ្ឋកថាចិតកបូជកត្ថេរាបទាន ...... ...... ...... ...... ៨៥៤
អាលុវទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៨៥៥

សទ្ទឹកប្រាប់មាតិកា ៩៣៦
អដ្ឋកថាអាលុវទាយកត្ថេរាបទាន ...... ...... ...... ...... ៨៥៦
បុណ្ឌរីកត្ថេរាបទានទី ៩ ...... ...... ...... ...... ៨៥៧
តរណិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៨៥៧
អដ្ឋកថាបុណ្ឌរីកត្ថេរាបទានជាដើម ...... ...... ...... ...... ៨៥៩

## បណ្ណទាយកវគ្គទី ២៩

បណ្ណទាយកត្ថេរាបទានទី ១ ...... ...... ...... ...... ៨៦០
អដ្ឋកថាបណ្ណទាយកត្ថេរាបទាន ...... ...... ...... ...... ៨៦១
ផលទាយកត្ថេរាបទានទី ២ ...... ...... ...... ...... ៨៦២
អដ្ឋកថាផលទាយកត្ថេរាបទាន ...... ...... ...... ...... ៨៦៣
បច្ចុគ្គមនិយត្ថេរាបទានទី ៣ ...... ...... ...... ...... ៨៦៤
អដ្ឋកថាបច្ចុគ្គមនិយត្ថេរាបទាន ...... ...... ...... ...... ៨៦៥
ឯកបុប្ផិយត្ថេរាបទានទី ៤ ...... ...... ...... ...... ៨៦៦
មឃវបុប្ផិយត្ថេរាបទានទី ៥ ...... ...... ...... ...... ៨៦៧
ឧបដ្ឋាយិកត្ថេរាបទានទី ៦ ...... ...... ...... ...... ៨៦៨
អបទានិយត្ថេរាបទានទី ៧ ...... ...... ...... ...... ៨៦៩
សត្តាហបព្វជិតត្ថេរាបទានទី ៨ ...... ...... ...... ...... ៨៧០
ពុទ្ធុបដ្ឋាយិកត្ថេរាបទានទី ៩ ...... ...... ...... ...... ៨៧១
បុព្វង្គមនិយត្ថេរាបទានទី ១០ ...... ...... ...... ...... ៨៧២
អដ្ឋកថាឯកបុប្ផិយត្ថេរាបទានជាដើម ...... ...... ...... ...... ៨៧៤

## ចិតកបូជកវគ្គទី ៣០

ចិតកបូជកត្ថេរាបទានទី ១ ...... ...... ...... ...... ៨៧៥
អដ្ឋកថាចិតកបូជកត្ថេរាបទាន ...... ...... ...... ...... ៨៧៦
បុប្ផធារកត្ថេរាបទានទី ២ ...... ...... ...... ...... ៨៧៧

សទ្ទឹកប្រាប់មាតិកា ៩៣៧
អដ្ឋកថាបុប្ផធារកត្ថេរាបទាន ...... ...... ...... ...... ៨៧៨
ឆត្តទាយកត្ថេរាបទានទី ៣ ...... ...... ...... ...... ៨៧៩
អដ្ឋកថាឆត្តទាយកត្ថេរាបទាន ...... ...... ...... ...... ៨៨០
សទ្ទសញ្ញកត្ថេរាបទានទី ៤ ...... ...... ...... ...... ៨៨២
អដ្ឋកថាសទ្ទសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៨៨៣
គោសីសនិក្ខេបកត្ថេរាបទានទី ៥ ...... ...... ...... ...... ៨៨៤
អដ្ឋកថាគោសីសនិក្ខេបកត្ថេរាបទាន ...... ...... ...... ...... ៨៨៥
បទបូជកត្ថេរាបទានទី ៦ ...... ...... ...... ...... ៨៨៧
តេសកិត្តិកត្ថេរាបទានទី ៧ ...... ...... ...... ...... ៨៨៨
សរណាគមនិយត្ថេរាបទានទី ៨ ...... ...... ...... ...... ៨៨៩
អម្ពបិណ្ឌិយត្ថេរាបទានទី ៩ ...... ...... ...... ...... ៨៩០
អនុសំសាវកត្ថេរាបទានទី ១០ ...... ...... ...... ...... ៨៩១
អដ្ឋកថាបទបូជកត្ថេរាបទានជាដើម ...... ...... ...... ...... ៨៩៣

**បទុមកេសរិយវគ្គទី ៣១**

បទុមកេសរិយត្ថេរាបទានទី ១ ...... ...... ...... ...... ៨៩៤
អដ្ឋកថាបទុមកេសរិយត្ថេរាបទាន ...... ...... ...... ...... ៨៩៥
សព្វគន្ធិយត្ថេរាបទានទី ២ ...... ...... ...... ...... ៨៩៦
បរមន្នទាយកត្ថេរាបទានទី ៣ ...... ...... ...... ...... ៨៩៧
អដ្ឋកថាសព្វគន្ធិយត្ថេរាបទានជាដើម ...... ...... ...... ...... ៨៩៨
ធម្មសញ្ញកត្ថេរាបទានទី ៤ ...... ...... ...... ...... ៨៩៩

សទ្ទិកប្រាប់មាតិកា ៩៣៨
អដ្ឋកថាធម្មសញ្ញកត្ថេរាបទាន ...... ...... ...... ...... ៩០០
ផលទាយកត្ថេរាបទានទី ៥ ...... ...... ...... ...... ៩០២
អដ្ឋកថាផលទាយកត្ថេរាបទាន ...... ...... ...... ...... ៩០៣
សម្បសាទិកត្ថេរាបទានទី ៦ ...... ...... ...... ...... ៩០៤
អារាមទាយកត្ថេរាបទានទី ៧ ...... ...... ...... ...... ៩០៥
អដ្ឋកថាសម្បសាទិកត្ថេរាបទានជាដើម ...... ...... ...... ...... ៩០៦
អនុលេបទាយកត្ថេរាបទានទី ៨ ...... ...... ...... ...... ៩០៧
អដ្ឋកថាអនុលេបទាយកត្ថេរាបទាន ...... ...... ...... ...... ៩០៨
ពុទ្ធសញ្ញិកត្ថេរាបទានទី ៩ ...... ...... ...... ...... ៩០៩
បព្ភារទាយកត្ថេរាបទានទី ១០ ...... ...... ...... ...... ៩១០
អដ្ឋកថាពុទ្ធសញ្ញិកត្ថេរាបទានជាដើម ...... ...... ...... ...... ៩១១